


# សៀវភៅណែនាំអំពី
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ភាគ ១៖ ការបង្កើត ប្រតិបត្តិការ និងសំណុំរឿង**

សំណៅដើមមុនបោះពុម្ព

អង្គជំនុំជម្រះវិសាមញ្ញ
ក្នុងតុលាការកម្ពុជា

# សៀវភៅណែនាំ
# អំពី
# អង្គជំនុំជម្រះវិសាមញ្ញ
# ក្នុងតុលាការកម្ពុជា

## ភាគ ១៖ ការបង្កើត ប្រតិបត្តិការ និងសំណុំរឿង

## មាតិកា


**១. ការរកឃើញនានាអំពីរបបខ្មែរក្រហម ..... 1**

១.១. មុនសម័យកាលកម្ពុជាប្រជាធិបតេយ្យ (១៩៣០-មេសា ១៩៧៥) ..... 1

១.១.១. ដើមកំណើតកុម្មុយនីស្តនៅកម្ពុជា ..... 1

១.១.២. ខ្មែរក្រហមលេចចេញជារូបរាងឡើង ..... 2

១.២. របបខ្មែរក្រហម (១៧ មេសា ១៩៧៥-៧ មករា ១៩៧៩) ..... 5

១.២.១. រចនាសម្ព័ន្ធចាត់តាំងនៃការគ្រប់គ្រងនយោបាយ ..... 5

១.២.២. រចនាសម្ព័ន្ធចាត់តាំងនៃការគ្រង់គ្រងយោធា ..... 7

១.២.៣. មហាលោតផ្លោះមហាអស្ចារ្យ ..... 7

១.២.៣.១. ការជម្លៀសប្រជាជន សហករណ៍ និង ការដ្ឋាន ..... 8

១.២.៣.២. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ..... 11

១.២.៣.៣.១. ការធ្វើបាបលើអតីតមន្ត្រី ទាហាន និងក្រុមគ្រួសាររបបសាធារណរដ្ឋខ្មែរ ..... 17

១.២.៣.៣.២. ការធ្វើបាបពុទ្ធសាសនិក ..... 18

១.២.៣.៣.៣. ការធ្វើបាបលើជនជាតិចាម ..... 19

១.២.៣.៣.៤. ការធ្វើបាបលើជនជាតិវៀតណាម ..... 21

១.២.៣.៣.៥. ការធ្វើបាបលើក្រុមផ្សេងទៀត ..... 23

១.២.៣.៣.៥.១. ខ្មែរក្រោម ..... 23

១.២.៣.៣.៥.២. ជនជាតិថៃ ..... 24

១.២.៣.៣.៥.៣. ក្រុមផ្សេងទៀត ..... 25

១.២.៤. បទបញ្ញាស្តីពីការរៀបអាពាហ៍ពិពាហ៍ ..... 25

១.៣. ការដួលរលំនៃរបបខ្មែរក្រហម ..... 27

**២. ទិដ្ឋភាពនៃការចរចា ការបង្កើត និងប្រតិបត្តិការរបស់ អ.វ.ត.ក. ..... 29**

២.២. ការចរចាចាប់ផ្តើម ..... 31

២.៣. ទម្រង់ការផ្លូវច្បាប់នៅតែបន្ត ហើយវិភាគទានហិរញ្ញវត្ថុចាប់ផ្តើមដំណើរការ ..... 32

២.៤. ការចាប់ផ្តើមប្រតិបត្តិការ ..... 33

២.៥. ព្រឹត្តិការណ៍សំខាន់ៗនៃដំណាក់កាលតុលាការ ..... 34

**៣. អាណត្តិរបស់ អ.វ.ត.ក. ..... 39**

៣.១. គោលបំណងរបស់ អ.វ.ត.ក. ..... 39

៣.២. ក្របខណ្ឌច្បាប់ ..... 39

៣.២.១. ច្បាប់ អ.វ.ត.ក. ..... 39

៣.២.២. កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ..... 41

៣.២.២.១. កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាព ..... 42

៣.២.២.២. កិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម ........ 42
៣.២.៣. វិធានផ្ទៃក្នុង ........ 43
៣.២.៤. សេចក្ដីណែនាំអនុវត្ត ........ 44
៣.៣. យុត្តាធិការ ........ 45
៣.៣.១. យុត្តាធិការលើរឿងក្ដី ........ 45
៣.៣.១.១. ឧក្រិដ្ឋកម្មក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ........ 45
៣.៣.១.២. អំពើប្រល័យពូជសាសន៍ ........ 47
៣.៣.១.៣. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ........ 48
៣.៣.១.៤. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ........ 54
៣.៣.២. យុត្តាធិការលើពេលវេលា ........ 57
៣.៣.៣. យុត្តាធិការលើដែនដី ........ 57
៣.៣.៤. យុត្តាធិការលើរូបបុគ្គល ........ 57
៣.៤. ទម្រង់នៃការទទួលខុសត្រូវ ........ 60
៣.៤.១.១. ការរៀបចំផែនការ ........ 61
៣.៤.១.២. ការញុះញង់ ........ 63
៣.៤.១.៣. ការបញ្ជា ........ 65
៣.៤.១.៤. ការជួយ និងជំរុញ ........ 67
៣.៤.១.៥. ការប្រព្រឹត្តឧក្រិដ្ឋកម្ម ........ 69
៣.៤.១.៦. សហឧក្រិដ្ឋកម្មរួម ........ 70
៣.៤.១.៧. ការទទួលខុសត្រូវរបស់ថ្នាក់លើ/មេបញ្ជាការ ........ 74
៣.៥. ការលើកលែងទោស និងការអនុគ្រោះទោស ........ 78
៣.៦. ទោសបញ្ញត្តិ និងការសម្រេចអំពីទោស ........ 78
៣.៧. លក្ខណៈពិសេស និងកូនកាត់ ........ 80
៣.៧.១. សមាសភាព “ជាតិ” និង “អន្តរជាតិ” ........ 80
៣.៧.២. សេចក្ដីសម្រេចដោយ “សំឡេងភាគច្រើនលើសលប់” ........ 80
៣.៧.៣. នវានុវត្តន៍នៃអង្គបុរេជំនុំជម្រះ ........ 81
៣.៧.៤. យុត្តាធិការមានកំណត់ និងយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ ........ 82
៣.៧.៥. ភាសា ........ 83
៣.៧.៦. ការចូលរួមរបស់ជនរងគ្រោះ ........ 83
**៤. សមាសភាព ........ 85**
៤.១. ការិយាល័យសហព្រះរាជអាជ្ញា ........ 85
៤.២. ការិយាល័យសហចៅក្រមស៊ើបអង្កេត ........ 88

៤.៣. អង្គជំនុំជម្រះតុលាការ ........ 91

៤.៣.១. ការតែងតាំងចៅក្រម ........ 91

៤.៣.២. អង្គបុរេជំនុំជម្រះ ........ 92

៤.៣.៣. អង្គជំនុំជម្រះសាលាដំបូង ........ 95

៤.៣.៤. អង្គជំនុំជម្រះតុលាការកំពូល ........ 96

៤.៤. ផ្នែកគាំពារ ........ 98

៤.៤.១. ផ្នែកគាំពារជនរងគ្រោះ ........ 98

៤.៤.២. ផ្នែកគាំពារការពារក្ដី ........ 99

៤.៤.២.១. សហមេធាវី និងក្រុមការងាររបស់ពួកគេ ........ 102

៤.៤.៣. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ........ 103

៤.៥. ការរៀបចំតុលាការ និងរដ្ឋបាលតុលាការ ........ 106

៤.៥.១. កិច្ចប្រជុំពេញអង្គ ........ 106

៤.៥.២. គណៈកម្មាធិការរដ្ឋបាលតុលាការ ........ 107

៤.៥.៣. គណៈកម្មាធិការនីតិវិធី និងវិធាន ........ 107

៤.៦. ការគាំពារផ្នែកច្បាប់ ........ 108

៤.៦.១. កម្មសិក្សាការី ........ 109

៤.៧. ការិយាល័យរដ្ឋបាល ........ 109

៤.១.៧. ផ្នែកគ្រប់គ្រងតុលាការ ........ 110

៤.៧.១.១. អង្គភាពបណ្ណសារ និងការិយាល័យជួរមុខ ........ 111

៤.៧.១.២. អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ........ 111

៤.៧.១.៣. អង្គភាពបកប្រែភាសា ........ 113

៤.៧.១.៤. អង្គភាពប្រតិចារឹក ........ 113

៤.៧.១.៥. អង្គភាពសោតទស្សន៍ ........ 114

៤.៧.១.៦. អង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង ........ 115

៤.៧.២. ផ្នែកកិច្ចការសាធារណៈ ........ 118

៤.៧.៣. ផ្នែកសេវាកម្មទូទៅ ........ 119

៤.៧.៤. ផ្នែកសន្តិសុខ និងសុវត្ថិភាព ........ 120

៤.៧.៥. ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ........ 121

៤.៧.៦. អង្គភាពគាំពារប្រតិបត្តិការ ........ 121

៤.៧.៦.១. ផ្នែកថវិកា និងហិរញ្ញវត្ថុ ........ 121

៤.៧.៦.២. ផ្នែកគ្រប់គ្រងធនធានមនុស្ស ........ 122

៤.៧.៦.៣. អង្គភាពលទ្ធកម្ម ....... 122
៤.៨. ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម ....... 122
**៥. សំណុំរឿង ....... 123**
៥.១. សំណុំរឿង ០០១....... 123
៥.១.១. ទិដ្ឋភាពទូទៅអំពីជនជាប់ចោទ....... 123
៥.១.២. ការស៊ើបអង្កេតបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ....... 124
៥.១.៣. ការស៊ើបអង្កេតដោយតុលាការ ....... 124
៥.១.៣.១. ការឃុំខ្លួន និងការចោទប្រកាន់....... 124
៥.១.៣.២. ភ័ស្តុតាងនៅក្នុងសំណុំរឿង ....... 125
៥.១.៣.៣. ដីកាសន្និដ្ឋានស្ថាពរ....... 126
៥.១.៣.៤. ដីកាដំណោះស្រាយ....... 126
៥.១.៤. កិច្ចដំណើរការនីតិវិធីអង្គបុរេជំនុំជម្រះ ....... 127
៥.១.៤.១. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ....... 127
៥.១.៤.២. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ....... 128
៥.១.៥. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះសាលាដំបូង....... 130
៥.១.៥.១. សវនាការបឋម ....... 130
៥.១.៥.២. សវនាការលើអង្គសេចក្តី....... 131
៥.១.៥.២.១. អង្គហេតុដែលឯកភាព និងមិនឯកភាព....... 131
៥.១.៥.២.២. ដើមបណ្តឹងរដ្ឋប្បវេណី ....... 131
៥.១.៥.២.៣. ចម្លើយរបស់ជនជាប់ចោទ ....... 133
៥.១.៥.៣. ការបណ្តេញសហមេធាវីអន្តរជាតិ ....... 134
៥.១.៥.៤. សាលក្រមអង្គជំនុំជម្រះសាលាដំបូង ....... 134
៥.១.៥.៥. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ ....... 137
៥.១.៦. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះតុលាការកំពូល ....... 138
៥.១.៦.១. បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ....... 138
៥.១.៦.២. សាលដីកាលើបណ្តឹងសាទុក្ខ ....... 141
៥.១.៧. ដំណាក់កាលក្រោយកំណត់ពិរុទ្ធភាព....... 146
៥.១.៧.១. ការឃុំខ្លួន និងជំនួយក្នុងសំណុំរឿង ០០២....... 146
៥.២. សំណុំរឿង ០០២....... 147
៥.២.១. ទិដ្ឋភាពទូទៅអំពីជនជាប់ចោទ ....... 147

៥.២.២. ការស៊ើបអង្កេតបឋម ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ........ 148
៥.២.៣. កិច្ចស៊ើបសួរផ្នែកតុលាការ ........ 149
៥.២.៣.១. ការឃុំខ្លួន និងការចោទប្រកាន់ ........ 149
៥.២.៣.២. ភ័ស្តុតាងនៅក្នុងសំណុំរឿង ........ 149
៥.២.៣.៣. បញ្ហាប្រឈមផ្នែកយុត្តាធិការ ........ 149
៥.២.៣.៣.១. ការលើកលែងទោស និងការអនុគ្រោះទោស ........ 150
៥.២.៣.៣.២. គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ ........ 150
៥.២.៣.៣.៣. ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម (JCE) ........ 151
៥.២.៣.៤. ដើមបណ្តឹងរដ្ឋប្បវេណី ........ 151
៥.២.៣.៥. ដីកាសន្និដ្ឋានស្ថាពរ ........ 152
៥.២.៣.៦. ដីកាដំណោះស្រាយ ........ 152
៥.២.៤. កិច្ចដំណើរការនីតិវិធីនៅអង្គបុរេជំនុំជម្រះ ........ 153
៥.២.៥. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះសាលាដំបូង ........ 155
៥.២.៥.១. អញ្ញត្រកម្ម និងសវនាការបឋម ........ 155
៥.២.៥.២. ការបំបែកសំណុំរឿង ........ 157
៥.២.៦. សំណុំរឿង ០០២/០១ ........ 162
៥.២.៦.១. ការជំនុំជម្រះ ........ 162
៥.២.៦.២. សម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ការបំបែកសំណុំរឿង និងមរណភាព ........ 164
៥.២.៦.៣. សម្បទាក្នុងចូលរួមសវនាការ និងមរណភាពរបស់ អៀង សារី ........ 165
៥.២.៦.៤. សាលក្រមជំនុំជម្រះ ........ 167
៥.២.៦.៥. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះតុលាការកំពូល ........ 170
៥.២.៦.៥.១. បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ........ 170
៥.២.៦.៥.២. សាលដីកាបណ្តឹងសាទុក្ខ ........ 171
៥.២.៧. សំណុំរឿង ០០២/០២ ........ 177
៥.២.៧.១. ការជំនុំជម្រះ ........ 177
៥.២.៧.២. ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ និងបញ្ហានានាបណ្តាលមកពីការបំបែកសំណុំរឿង ........ 179
៥.២.៧.៣. សាលក្រមជំនុំជម្រះ ........ 181
៥.២.៧.៤. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះតុលាការកំពូល ........ 185
៥.២.៧.៤. មរណភាពរបស់ នួន ជា និង ការបញ្ចប់កិច្ចដំណើរការនីតិវិធី ........ 185

៥.២.៧.៤.២. បណ្តឹងសាទុក្ខលើសាលក្រមសំណុំរឿង ០០២/០២ និងសវនាការលើបណ្តឹងសាទុក្ខ ........ 185
៥.២.៧.៤.៣. សាលដីកាបណ្តឹងសាទុក្ខ ........ 186
៥.២.៧.៥. ដំណាក់កាលក្រោយការផ្តន្ទាទោស ........ 188
៥.៣. សំណុំរឿង ០០៣ និង ០០៤ ........ 189
៥.៣.១. បញ្ហាប្រឈមដែលមានពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤ ........ 189
៥.៣.១.១. បញ្ហាខ្វែងយោបល់ពាក់ព័ន្ធនឹងថាតើត្រូវបើកសំណុំរឿងបន្ថែម ឬទេ ........ 189
៥.៣.១.២. បញ្ហាខ្វែងយោបល់ក្នុងអំឡុងពេលកិច្ចស៊ើបសួរ ........ 190
៥.៣.១.៣. សេចក្តីពិចារណាលើការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ ........ 191
៥.៣.១.៤. បញ្ហាខ្វែងយោបល់ពាក់ព័ន្ធនឹងបញ្ហាថាតើរឿងក្តីនឹងបន្តទៅជំនុំជម្រះ ឬទេ ........ 192
៥.៣.២. សំណុំរឿង ០០៣ ........ 192
៥.៣.២.១. ទិដ្ឋភាពទូទៅអំពីជនសង្ស័យ ........ 192
៥.៣.២.២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ 193
៥.៣.២.៣. កិច្ចស៊ើបសួរតាមផ្លូវតុលាការ ........ 193
៥.៣.២.៤. មរណភាពរបស់ ស៊ូ ម៉េត ........ 195
៥.៣.២.៥. បញ្ហាពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ........ 195
៥.៣.២.៦. ដីកាសន្និដ្ឋានស្ថាពរ ........ 197
៥.៣.២.៧. ដីកាដំណោះស្រាយ ........ 197
៥.៣.២.៨. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ 198
៥.៣.២.៩. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ........ 199
៥.៣.២.១០. សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ........ 200
៥.៣.២.១១. បណ្តឹងវិវាទពាក់ព័ន្ធនឹងស្ថានភាពសំណុំរឿង ០០៣ ........ 201
៥.៣.២.១២. ការបញ្ចប់កិច្ចដំណើរការនីតិវិធី ........ 202
៥.៣.៣. សំណុំរឿង ០០៤ ........ 204
៥.៣.៣.១. ទិដ្ឋភាពទូទៅរបស់ជនជសង្ស័យ ........ 204
៥.៣.៣.២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ 205
៥.៣.៣.៣. កិច្ចស៊ើបសួរតាមផ្លូវតុលាការ ........ 205
៥.៣.៣.៤. បញ្ហាពាក់ព័ន្ធនឹងការមានផ្ទៃពោះដោយបង្ខំ និងការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ.. 206
៥.៣.៣.៥. ការបំបែកកិច្ចដំណើរការនីតិវិធីរឿងក្តី អ៊ឹម ចែម និងការបង្កើតសំណុំរឿង ០០៤/០១ ........ 206
៥.៣.៣.៥.១. ដីកាសន្និដ្ឋានស្ថាពរ ........ 207
៥.៣.៣.៥.២. ដីកាដំណោះស្រាយ ........ 207

៥.៣.៣.៥.៣. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ 208
៥.៣.៣.៥.៤. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ........ 208
៥.៣.៣.៥.៦. ការបញ្ចប់កិច្ចដំណើរការនីតិវិធី ........ 211
៥.៣.៣.៦. ការបំបែកកិច្ចដំណើរការនីតិវិធីរឿងក្តី អោ អាន និងការបង្កើតសំណុំរឿង ០០៤/០២ ........ 211
៥.៣.៣.៦.១. ដីកាសន្និដ្ឋានស្ថាពរ ........ 212
៥.៣.៣.៦.២. ដីកាដំណោះស្រាយ ........ 212
៥.៣.៣.៦.៣. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ 213
៥.៣.៣.៦.៤. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ........ 214
៥.៣.៣.៦.៥. សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ........ 215
៥.៣.៣.៦.៦. ការបញ្ចប់កិច្ចដំណើរការនីតិវិធី ........ 217
៥.៣.៣.៧. សំណុំរឿង ០០៤ - កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង យឹម ទិត្យ ........ 219
៥.៣.៣.៧.១. ការបិទបញ្ចប់កិច្ចស៊ើបសួរ ........ 219
៥.៣.៣.៧.២. ដីកាសន្និដ្ឋានស្ថាពរ ........ 220
៥.៣.៣.៧.៣. ដីកាដំណោះស្រាយ ........ 220
៥.៣.៣.៧.៤. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........ 220
៥.៣.៣.៧.៥. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ........ 221
៥.៣.៣.៧.៦. សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ........ 222
៥.៣.៣.៧.៧. ការបញ្ចប់កិច្ចដំណើរការនិតិវិធី ........ 224
**៦. សំណង ........ 225**
៦.១. សំណុំរឿង ០០១ ........ 225
៦.១.១. ការចងក្រង និងការបោះពុម្ពផ្សាយពាក្យសម្តីសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ........ 225
៦.១.២. ការបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ........ 226
៦.២. សំណុំរឿង ០០២/០១ ........ 226
៦.២.១. ទិវាជាតិនៃការចងចាំ ........ 227
៦.២.២. គម្រោងសាងសង់បូជនីយស្ថានសម្រាប់រម្លឹកជាសាធារណៈនៅភ្នំពេញ - *"សម្រាប់អ្នកដែលបាត់បង់ជីវិត"* ........ 227
៦.២.៣. វិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម ........ 227
៦.២.៤. ក្រុមជួយខ្លួនឯង ........ 228
៦.២.៥. ការតាំងពិព័រណ៍អចិន្ត្រៃយ៍អំពីការផ្លាស់ទីលំនៅដោយបង្ខំ ........ 228
៦.២.៦. ការតាំងពិព័រណ៍ចល័តស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម និង អ.វ.ត.ក. ........ 229
៦.២.៧. ជំពូកកម្មវិធីសិក្សាស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់នៅទួលពោធិ៍ជ្រៃ 229

៦.២.៨. ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅសំរោងក្នុង........................ 230
៦.២.៩. កូនសៀវភៅរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងអង្គហេតុដែលបានវិនិច្ឆ័យក្នុងសំណុំរឿង ០០២/០១ .................................................................................................... 230
៦.២.១០. ការបោះពុម្ពផ្សាយ និងចែកចាយសាលក្រមពេញលេញ និងសាលក្រមសង្ខេប ......... 231
៦.២.១១. ការបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ............................................... 231
៦.៣. សំណុំរឿង ០០២/០២ ....................................................................................... 232
៦.៣.១. កម្មវិធីសិក្សា (App) អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ............................................... 232
៦.៣.២. ការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូអ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ ............................................................................................................ 232
៦.៣.៣. គម្រោង “អណ្តើក”.............................................................................................. 233
៦.៣.៤. គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម ...................... 233
៦.៣.៥. ផ្កាស្លាក្រោមអង្គការ .......................................................................................... 234
៦.៣.៦. សំឡេងពីជនជាតិភាគតិច ................................................................................... 234
៦.៣.៧. រឿងរ៉ាវមិនធ្លាប់បានគេដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២....... 235
៦.៣.៨. ការប្រកួតប្រជែងតាក់តែងបទចម្រៀង៖ *“ពេលវេលាដែលត្រូវចងចាំ”* ................... 235
៦.៣.៩. ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់........................................................... 235
៦.៣.១០. ការចូលមើលកំណត់ត្រារបស់តុលាការ និងសម្ភារៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី....... 236
៦.៣.១១. ការព្យាបាលនិងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ............ 236
៦.៣.១២. ការអប់រំផ្នែកច្បាប់និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច...... 237
៦.៣.១៣. ការគាំពារ និងការផ្តល់ប្រឹក្សាអំពីសុខភាពផ្លូវចិត្ត .................................................. 237
**៧. មុខងារសេសសល់ ........................................................................................ 239**
៧.១. ដំណើរការពិគ្រោះយោបល់ .................................................................................. 239
៧.២. កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀង អ.វ.ត.ក. ............................................. 240
**៨. ឧបសម្ព័ន្ធ....................................................................................................... 242**
៨.១. ឧបសម្ព័ន្ធ ១៖ អានបន្ថែម..................................................................................... 242
៨.២. ឧបសម្ព័ន្ធ២៖ ក្រមឧក្រិដ្ឋច្បាប់ និងក្របខ័ណ្ឌប្រតិបត្តិ ................................................ 245
៨.៣. ឧបសម្ព័ន្ធ ៣៖ បញ្ជីឈ្មោះមន្ត្រីតុលាការសំខាន់ៗ ...................................................... 247
៨.៤. ឧបសម្ព័ន្ធ ៤៖ ឯកសារសំខាន់ៗនៃរឿងក្តី ................................................................ 250
៨.៥. ឧបសម្ព័ន្ធ ៥៖ សេចក្តីសម្រេចរៀបចំតាមមូលបទ...................................................... 252
៨.៦. ឧបសម្ព័ន្ធ ៦៖ ព័ត៌មានហិរញ្ញវត្ថុ............................................................................ 254
៨.៧. ឧបសម្ព័ន្ធ ៧៖ ស្ថិតិផ្សព្វផ្សាយ ............................................................................... 257

## បញ្ជីពាក្យកាត់

1. BAKC (គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា)
2. CHRAC (អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា)
3. ប.ក.ក. (បក្សកុម្មុយនីស្តកម្ពុជា)
4. DC-Cam (មជ្ឈមណ្ឌលឯកសារកម្ពុជា)
5. DESA (ផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គម)
6. អ.វ.ត.ក. (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា)
7. FUNK (រណសិរ្សរួបរួមជាតិកម្ពុជា)
8. GRUNK (រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា)
9. ICP (បក្សកុម្មុយនីស្តឥណ្ឌូចិន)
10. ICTY (សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី)
11. JAC (គណៈកម្មាធិការរដ្ឋបាលតុលាការ)
12. JCE (សហឧក្រិដ្ឋកម្មរួម)
13. KNUFNS (រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា)
14. KPRP (បក្សប្រជាជនបដិវត្តន៍ខ្មែរ)
15. ក.ស.ព. (ការិយាល័យសហព្រះរាជអាជ្ញា)
16. ក.ស.ច.ស. (ការិយាល័យសហចៅក្រមស៊ើបអង្កេត)
17. OLA (ការិយាល័យកិច្ចការច្បាប់)
18. RPC (គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង)
19. TPO (អង្គការចិត្តសង្គមអន្តរវប្បធម៌)
20. អ.ស.ប. (អង្គការសហប្រជាជាតិ)
21. UNAKRT (ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម)
22. UNDSS (ផ្នែកសន្តិសុខ និងសុវត្ថិភាព អ.ស.ប.)
23. UNGA (មហាសន្និបាត អ.ស.ប.)
24. UNSG (អគ្គលេខាធិការ អ.ស.ប.)

# ១. ការរកឃើញនានាអំពីរបបខ្មែរក្រហម

ជំពូកនេះរៀបរាប់អំពីដើមកំណើត និងការរីកចម្រើននៃរបបខ្មែរក្រហម ការពង្រឹងអំណាចត្រួតត្រារបស់ពួកគេលើប្រទេសកម្ពុជា និងគោលនយោបាយឧក្រិដ្ឋ និងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងដើម្បីសម្រេចបានគោលដៅរបស់ខ្លួន។ អង្គហេតុទាំងនេះផ្តល់មូលដ្ឋានសំខាន់សម្រាប់ស្វែងយល់អំពីការបង្កើតប្រតិបត្តិការ និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) នាពេលក្រោយមកទៀត។

អង្គហេតុប្រវត្តិសាស្ត្រខាងក្រោមនេះផ្អែកលើការរកឃើញនានា ដែលទាក់ទងទៅនឹងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក.[1]។ ដូច្នេះ អង្គហេតុប្រវត្តិសាស្ត្រទាំងនេះប្រហែលជាមិនរៀបរាប់លម្អិតអំពីរឿងរ៉ាវទាក់ទងទៅនឹងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងនោះទេ។ សម្រាប់បរិបទប្រវត្តិសាស្ត្របន្ថែមទៀតអំពីរបបខ្មែរក្រហម និងកម្ពុជាប្រជាធិបតេយ្យ សុំមើលបញ្ជីឯកសារណែនាំឱ្យអានបន្ថែមក្នុងឧបសម្ព័ន្ធ ១។

## ១.១. មុនសម័យកាលកម្ពុជាប្រជាធិបតេយ្យ (១៩៣០-មេសា ១៩៧៥)

### ១.១.១. ដើមកំណើតកុម្មុយនីស្តនៅកម្ពុជា

នៅឆ្នាំ១៩៣០ មេដឹកនាំបដិវត្តន៍វៀតណាម ហូ ជីមិញ បានប្រកាសអំពីការបង្កើតបក្សកុម្មុយនីស្តឥណ្ឌូចិន (“ICP”)។ ស្ថិតក្រោមឥទ្ធិពលរបស់បក្សកុម្មុយនីស្តអន្តរជាតិដែលមានមូលដ្ឋាននៅទីក្រុងម៉ូស្គូ បក្សកុម្មុយនីស្តឥណ្ឌូចិនបានចលនាឱ្យមានបដិវត្តន៍សង្គមនិយមនៅវៀតណាម ឡាវ និង កម្ពុជា។ ដើមឡើយមិនមានសមាជិកខ្មែរនៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនទេ។ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៤០ ក្រុមខ្មែរឥស្សរៈ ឬក្រុមអ្នកប្រយុទ្ធដើម្បីសេរីភាព កំពុងតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំង។ សមាជិករបស់ខ្មែរឥស្សរៈរួមមាន កែ ពក, សោ ភឹម, មូល សំបាត់ ហៅ រស់ ញឹម, ឈិត ជឿន ហៅ តាម៉ុក, ណៃ សារ៉ាន់ ហៅ យ៉ា ហៅ ម៉ែន សាន, អាចារ្យ សុក ហៅ ទូ សាមុត និង ស៊ីវ ហេង។ នៅដើមឆ្នាំ១៩៥០ ភ្នាក់ងារវៀតណាមបានរៀបចំរណសិរ្សរួបរួមឥស្សរៈ ដែលនៅពេលនោះរួមមាន ជូ ជេត, កែវ មាស និងអតីតសមាជិកបក្សកុម្មុយនីស្តថៃគឺ នួន ជា។ រណសិរ្សនេះដឹកនាំដោយ សឺង ង៉ុកមិញ ដោយមាន ទូ សាមុត និង ស៊ីវ ហេង ជាអនុប្រធាន ហើយពួកគេបានបញ្ចូលទៅក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិនបន្តិចម្តងៗ។ ត្រឹមឆ្នាំ១៩៥១ វៀតណាមសម្រេចបំបែកបក្សកុម្មុយនិស្តឥណ្ឌូចិនជាបក្សជាតិចំនួនបី។ បក្សសម្រាប់កម្ពុជាមានឈ្មោះថាបក្សប្រជាជនបដិវត្តន៍ខ្មែរ (“KPRP”)[2]។

កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ បានបញ្ជាក់ពីឯករាជ្យរបស់វៀងណាម ឡាវ និងកម្ពុជា។ ក្រុមកុម្មុយនីស្តវៀតណាម និងឡាវ ទទួលបានការអនុញ្ញាតឱ្យចូលរួមនៅក្នុងសន្និសីទនេះ ចំណែកឯក្រុមកុម្មុយនីស្តកម្ពុជាវិញមិនមានតំណាងចូលរួមឡើយ។ កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវតម្រូវឱ្យកងកម្លាំងបារាំង និងវៀតណាមដកចេញពីកម្ពុជា ហើយក្រុមឥស្សរៈត្រូវរំសាយ។ ដោយសារតែកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវទាមទារឱ្យមានការបោះឆ្នោតនៅកម្ពុជា បក្សប្រជាជនបដិវត្តន៍ខ្មែរបានរៀបចំបង្កើតបក្សនយោបាយមួយមានឈ្មោះថា *ក្រុមប្រជាជន* ដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ បក្សនេះដឹកនាំដោយ កែវ មាស ដោយមានជំនួយពី សោ ភឹម, ម៉ែន សាន និង ជូ ជេត។ ក្នុងខែកុម្ភៈ ឆ្នាំ១៩៥៥ សម្តេច នរោត្តម សីហនុ បានដាក់រាជសម្បត្តិ ហើយចាប់ផ្តើមការបោះឆ្នោតជាសាកលអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ព្រះអង្គបានបង្កើតបក្សមួយឈ្មោះថា គណបក្សសង្គមរាស្ត្រនិយម ដែលបានយកជ័យជម្នះលើក្រុមប្រជាជនក្នុងការបោះឆ្នោតសាកលនោះ[3]។

ក្រោយពីបរាជ័យក្នុងការបោះឆ្នោតនេះ ក្រុមកុម្មុយនីស្តកម្ពុជាបានរៀបចំខ្លួនឡើងវិញ។ គណៈកម្មាធិការមជ្ឈិមមួយត្រូវបានបង្កើតឡើងដោយមាន ស៊ីវ ហេង ជាលេខា ទូ សាមុត ជាអនុលេខា សឹង ង៉ុកមិញ

[1] អង្គហេតុប្រវត្តិសាស្ត្រត្រូវបានសន្និដ្ឋានចេញពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ដែលបានពិនិត្យឧក្រិដ្ឋកម្ម និងការអនុវត្តគោលនយោបាយទូទាំងប្រទេសកម្ពុជា។

[2] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ១៩៦-១៩៨។

[3] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ១៩៦-២០០។

, សោ ភឹម និង រស់ ញឹម ជាសមាជិក។ ទូ សាមុត ត្រូវបានចាត់តាំងជាលេខាគណៈកម្មាធិការបក្សប្រចាំទីក្រុងភ្នំពេញ ដោយមាន នួន ជា ជាអនុលេខា។ សាឡុត៍ ស (ដែលក្រោយមកគេស្គាល់ថាជា ប៉ុល ពត) ដែលបានត្រឡប់ពីការសិក្សារបស់គាត់នៅប្រទេសបារាំងមកកាន់ប្រទេសកម្ពុជាវិញក្នុងឆ្នាំ១៩៥៣ ក៏ជាសមាជិកក្នុងគណៈកម្មាធិការនេះដែរ។ ក្រុមប្រជាជនបានបរាជ័យនៅក្នុងការបោះឆ្នោតមួយទៀតក្នុងឆ្នាំ១៩៥៨។ ក្នុងអំឡុងពេលនេះដែរ សម្តេច នរោត្តម សីហនុ បានដាក់ឈ្មោះក្រុមឆ្វេងនិយមនៅក្នុងប្រទេសកម្ពុជាថាជា "ខ្មែរក្រហម"។ អំឡុងឆ្នាំ១៩៥៦ ស៊ីវ ហេង បានផ្តាច់ខ្លួនមកចុះចូលជាមួយរបបរបស់សម្តេច សីហនុ[4]។

### ១.១.២. ខ្មែរក្រហមលេចចេញជារូបរាងឡើង

នៅចុងទសវត្សរ៍ឆ្នាំ១៩៥០ ប៉ុល ពត និង នួន ជា បានរៀបចំធ្វើសេចក្តីព្រាងឯកសារបង្កើតបក្សកុម្មុយនីស្តមួយ ដែលមិនស្ថិតក្រោមឥទ្ធិពលវៀតណាម។ ប៉ុល ពត និង នួន ជា គឺជាអ្នកមានតួនាទីសំខាន់បំផុតក្នុងការតាក់តែងលក្ខន្តិកៈបក្សថ្មីនេះ។ បក្សនេះស្វះស្វែងសម្រេចឱ្យបាននូវបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ដើម្បីលុបបំបាត់ពួកសក្តិភូមិនិយម ពួកប្រតិកិរិយា ពួកម្ចាស់ដី ពួកចក្រពត្តិនិយម និងបរិវាររបស់វា ដើម្បីរំដោះកម្មករ កសិករ របស់ប្រទេសជាតិ និងដើម្បីឈានទៅដល់បដិវត្តសង្គមនិយម[5]។

ក្នុងអំឡុងពេលសន្និបាតបក្សលើកទីមួយ ពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ១៩៦០ ជនកុម្មុយនីស្តមួយក្រុមមានគ្នា ២១ នាក់ ដែលក្នុងនោះ ១៤ នាក់ មកពីតំបន់ទីជនបទ ហើយប្រាំពីរនាក់ផ្សេងទៀតមកពីទីក្រុង បានជួបប្រជុំគ្នានៅក្នុងទីក្រុងភ្នំពេញដើម្បីអនុម័តលក្ខន្តិកៈថ្មីមួយ។ ពួកគេបានឯកភាពលើមាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធីរបស់ ប៉ុល ពត និង នួន ជា និងបានបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការដឹកនាំរបស់បក្សមួយដែលក្រោយមកមានឈ្មោះថា បក្សពលករកម្ពុជា។ ក្នុងការព្យាយាមដើម្បីបញ្ជាក់ពីឯករាជ្យភាពរបស់ខ្លួន និងការងាកចេញពីចលនាកុម្មុយនីស្តវៀតណាម បក្សប្រជាជនបដិវត្តន៍ខ្មែរបានប្តូរឈ្មោះទៅជាបក្សពលករកម្ពុជា ដោយរក្សាជាការសម្ងាត់មិនឱ្យភាគីវៀតណាមដឹងឡើយ។ ទូ សាមុត ត្រូវបានបោះឆ្នោតតែងតាំងជាលេខាបក្សនេះ ដោយមាន នួន ជា ជាអនុលេខា។ ពួកគេទាំងពីររូបក៏ត្រូវបានតែងតាំងជាសមាជិកពេញសិទ្ធិនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ រួមជាមួយ ប៉ុល ពត ចំណែក អៀង សារី ជាសមាជិកបម្រុង[6]។

ប្រហែលជាអំឡុងពេលបោះឆ្នោតឆ្នាំ១៩៦២ ទូ សាមុត បានបាត់ខ្លួន។ នៅក្នុងសន្និបាតបក្សលើកទីពីរ ក្នុងខែកុម្ភៈ ឆ្នាំ១៩៦៣ ប៉ុល ពត ត្រូវបានជ្រើសតាំងជំនួស ទូ សាមុត ចំណែក នួន ជា នៅបន្តតួនាទីជាអនុលេខាដដែល។ អៀង សារី និង សោ ភឹម បានឡើងតួនាទីជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ចំណែក វន វេត, រស់ ញឹម, សុន សេន និង តាម៉ុក ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម។ បក្សក៏បានបញ្ជាក់ឡើងវិញលើមាគ៌ាយុទ្ធសាស្ត្រ និងយុទ្ធវិធី ដែលត្រូវបានអនុវម័តក្នុងឆ្នាំ១៩៦០។ ប៉ុន្មានសប្តាហ៍ក្រោយមក សម្តេច នរោត្តម សីហនុ បានរំលាយរដ្ឋាភិបាលរបស់ព្រះអង្គ និងបានបោះពុម្ពផ្សាយបញ្ជីឈ្មោះចំនួន ៣៤ រូប ដែលសង្ស័យថាជាពួកឆ្វេងនិយម ក្នុងនោះមាន ខៀវ សំផន, ប៉ុល ពត, ហ៊ូ នឹម, អៀង សារី, សុន សេន និង ជូ ជេត។ ដោយសារភ័យខ្លាចការចាប់ខ្លួន ប៉ុល ពត, អៀង សារី និង សុន សេន បានរត់គេចខ្លួនចូលព្រៃ ទៅកាន់តំបន់ក្បែរព្រំដែនវៀតណាម ចំណែក នួន ជា បន្តស្ថិតនៅក្នុងទីក្រុងភ្នំពេញធ្វើជាប្រធានបក្សដែលមានតែឈ្មោះ។ ទោះបីជា ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ បានបាត់បង់តំណែងរបស់ខ្លួននៅក្នុងរដ្ឋាភិបាលក៏ដោយ ក៏ពួកគេបន្តស្ថិតនៅក្នុងទីក្រុងភ្នំពេញ[7]។

ដោយសារតែការវាយប្រហារលើក្រុមឆ្វេងនិយម គណៈកម្មាធិការមជ្ឈិមនៃបក្សពលករកម្ពុជាបានអនុម័តយក "អំពើហិង្សាបដិវត្តន៍" ជាផ្នែកមួយនៃមាគ៌ាបក្សក្នុងខែមករា ឆ្នាំ១៩៦៥។ ក្នុងខែកញ្ញា ឆ្នាំ១៩៦៦ បក្សពលករកម្ពុជាបានអនុម័តសេចក្តីសម្រេចមួយ ដែលបង្គាប់ឱ្យភូមិភាគនីមួយៗត្រៀមរៀបចំ "ការប្រយុទ្ធតស៊ូប្រដាប់អាវុធ"។ បក្សក៏បានផ្លាស់ប្តូរឈ្មោះរបស់ខ្លួនពីបក្សពលករកម្ពុជាទៅជា បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក.) វិញ។ ក្នុងខែមេសា ឆ្នាំ១៩៦៧ មានការប៉ះទង្គិចគ្នាមួយបានកើតឡើងរវាងកងទ័ព និង

[4] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២០០-២០២, ៥៦៤។
[5] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២០២។
[6] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២០៣-២០៤។
[7] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២០៦-២០៩។

កសិករនៅភូមិសំឡូត ខេត្តបាត់ដំបង ដែលជាមូលដ្ឋានរឹងមាំរបស់អតីតក្រុមឥស្សរៈ ដោយសារតែគោលនយោបាយលក់ស្រូវ/កសិផល ជាកាតព្វកិច្ចមិនអាចប្រកែកបានរបស់រដ្ឋាភិបាលសង្គមរាស្ត្រនិយម ដែលជាលទ្ធផលបណ្តាលឱ្យកងទ័ពស្លាប់ និងមានការរឹបអូសអាវុធដោយកសិករដែលបះបោរ[8]។

ក្រោយព្រឹត្តិការណ៍នៅសំឡូត សម្តេច នរោត្តម សីហនុ បានស្តីបន្ទោសទៅលើក្រុមឆ្វេងនិយមដ៏មានប្រជាប្រិយភាពបំផុត ដែលនៅតែកំពុងប្រតិបត្តិការជាចំហ គឺ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ និងបានគំរាមប្រើតុលាការយោធា ដើម្បីកាត់ទោសពួកគេ។ ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់នេះ នួន ជា បានសម្រេចបញ្ជូនអ្នកទាំងបីរូបនេះទៅកាន់ទីសុវត្ថិភាពនៅតំបន់ជនបទ ដែលគ្រប់គ្រងដោយកងកម្លាំងបដិវត្តន៍។ មិនយូរប៉ុន្មានក៏មានពាក្យចចាមអារ៉ាមថា ជនឆ្វេងនិយមទាំងបីរូបត្រូវបានកងកម្លាំងរបស់សម្តេច នរោត្តម សីហនុ ឬកងកម្លាំងរបស់នាយករដ្ឋមន្ត្រី លន់ នល់ សម្លាប់[9]។

នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៦៨ យុទ្ធជន ប.ក.ក. មួយក្រុមបានវាយប្រហារលើប៉ុស្តិ៍នរគបាលនៅបាយតម្រាំ ខេត្តបាត់ដំបង និងបានរឹបអូសយកអាវុធដែលពួកគេបានរកឃើញនៅទីនោះ។ ក្រោយមក ប.ក.ក. បានអនុម័តយកព្រឹត្តិការណ៍នេះជាការចាប់ផ្តើមការតស៊ូប្រដាប់អាវុធ និងជាកាលបរិច្ឆេទបង្កើតកងទ័ពបដិវត្តន៍កម្ពុជា[10]។

ពីខែមីនា ឆ្នាំ១៩៦៩ នៅពេលសហរដ្ឋអាមេរិកបានចាប់ផ្តើមយុទ្ធនាការទម្លាក់គ្រាប់បែកពីលើអាកាសប្រឆាំងនឹងពួកកុម្មុយនីស្តវៀតណាមខាងជើងនៅលើទឹកដីកម្ពុជា ដូច្នេះបានទាញកម្ពុជាចូលទៅក្នុងសង្គ្រាមវៀតណាម សម្តេច នរោត្តម សីហនុ បានអនុញ្ញាតឱ្យវៀតណាមខាងជើងបង្កើតមូលដ្ឋាននានានៅក្នុងប្រទេសកម្ពុជា។ វត្តមានរបស់កងកម្លាំងវៀតណាមកុម្មុយនីស្តនៅភាគខាងកើតប្រទេសកម្ពុជាបណ្តាលឱ្យមានការមិនពេញចិត្តខាងនយោបាយ និងសង្គមកាន់តែច្រើនឡើងៗ និងនាំឱ្យមានការតវ៉ានៅក្នុងខែមីនាធ្វើឡើងតាមរាជបញ្ជារបស់សម្តេច នរោត្តម សីហនុ។ ដោយសារតែសភាជាតិ និងរដ្ឋាភិបាលកាន់តែលែងមានភាពអត់ធ្មត់ជាមួយនឹងការគ្រប់គ្រងរបស់សម្តេច នរោត្តម សីហនុ លោកនាយករដ្ឋមន្ត្រី លន់ នល់ បានចុះហត្ថលេខាលើក្រឹត្យ មួយ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧០ គាំទ្រដល់ការទម្លាក់សម្តេច នរោត្តម សីហនុ ដែលកំពុងគង់នៅទីក្រុងម៉ូស្គូ នាពេលនោះ។ សភាជាតិបានអនុម័តលើការបោះឆ្នោតសម្តែងការមិនទុកចិត្តលើសម្តេច នរោត្តម សីហនុ ដោយបានទម្លាក់ព្រះអង្គចេញពីតំណែងជាព្រះប្រមុខរដ្ឋ[11]។

នៅពេលត្រូវប្រឈមជាមួយនឹងហេតុការណ៍ទាំងអស់នេះ ទើបនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ សម្តេច នរោត្តម សីហនុ បានប្រកាសតាមវិទ្យុដែលផ្សាយចេញពីទីក្រុងប៉េកាំង អំពីការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដោយអំពាវនាវឱ្យជនរួមជាតិរបស់ព្រះអង្គ ចូលរួមក្នុងចលនាប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ និងថ្នាក់ដឹកនាំនៃរបបនេះ រួមបញ្ចូលទាំង លន់ នល់។ មុនពេលប្រកាសនេះ នាយករដ្ឋមន្ត្រីចិន ជូ អេនឡាយ បានប្រគល់សំណើដំបូងរបស់ព្រះអង្គទៅឱ្យ ប៉ុល ពត ហើយ ប៉ុល ពត បានកែសម្រួលចំណុចមួយចំនួនដែលនិយាយអំពីសង្គមនិយម ប្រហែលជាក្នុងគោលបំណងដើម្បីធ្វើឱ្យមានការគាំទ្រពីប្រជាជនឱ្យបានច្រើនចំពោះរណសិរ្សរួបរួមជាតិកម្ពុជា។ ដោយមិនបានបង្ហាញខ្លួន និង ប.ក.ក. ប៉ុល ពត បានបញ្ជូន លិខិតមួយដែលគាំទ្រដល់រណសិរ្សរួបរួមជាតិកម្ពុជា ក្នុងនាមអ្នកនយោបាយឆ្វេងនិយមដែលមានស្រាប់ គឺ ខៀវ សំផន, ហ៊ូ នឹម និង ហ៊ូ យន់ (ដែលគេហៅថា "ខ្មោចទាំងបី")[12]។

នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៧០ សម្តេច នរោត្តម សីហនុ បានប្រកាសពីការបង្កើតរដ្ឋាភិបាលនិរទេសថ្មីមួយ គឺរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ សម្តេច នរោត្តម សីហនុ បានក្លាយជាប្រមុខរដ្ឋ ចំណែក ខៀវ សំផន (ទាំងគាត់មិនបានដឹងពីដំបូងនោះទេ) តែងតាំងជាឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិ។ ហ៊ូ នឹម បានទទួលតំណែងជារដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ ចំណែក ហ៊ូ យន់ ត្រូវបានតែងតាំងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ កំណែទម្រង់ឃុំ និងសហករណ៍។ ទោះបីជាពីមុនមក ចិន

[8] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២០៨-២១០។
[9] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465ក ថាខណ្ឌ ២១១។
[10] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១២។
[11] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១៤-២១៧។
[12] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១៨-២១៩។

និង វៀតណាមខាងជើង មិនបានផ្ដល់ជំនួយយោធាសំខាន់ៗដល់ក្រុមកុម្មុយនីស្តកម្ពុជាក៏ដោយ ការផ្លាស់ប្ដូរផ្នែកភូមិសាស្ត្រនយោបាយនេះ បានប្ដូរគោលនយោបាយរបស់ពួកគេ។ នៅចុងខែមេសា ឆ្នាំ១៩៧០ កងទ័ពកុម្មុយនីស្តវៀតណាមប្រមាណ ៣៥.០០០ នាក់ ទៅ ៤០.០០០ នាក់ បានចាប់ផ្ដើមការវាយប្រហារនៅក្នុងប្រទេសកម្ពុជា និងបានត្រួតត្រាទឹកដីកម្ពុជាប៉ែកខាងកើតមួយភាគធំ។ កងកម្លាំង ប.ក.ក. បានកាន់កាប់ និងត្រួតត្រាជិតមួយភាគប្រាំនៃទឹកដីកម្ពុជានាពេលនោះ។ រយៈពេលនៅសល់នៃឆ្នាំ១៩៧០ ឃើញមានជម្លោះកាន់តែខ្លាំងឡើងៗនៅក្នុងរបបសាធារណរដ្ឋខ្មែរដែលទើបប្រកាសថ្មីៗ និងប្រឆាំងនឹងរបប ថ្មីនេះ (ពោលគឺរដ្ឋាភិបាល លន់ នល់)[13]។

ត្រឹមពាក់កណ្ដាលឆ្នាំ១៩៧០ សមាជិក ប.ក.ក. បានពង្រឹងការគ្រប់គ្រងរបស់ខ្លួនទៅលើរណសិរ្សរួបរួមជាតិកម្ពុជា និង រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា។ គណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក. "បានអនុម័តមាគ៌ាដែលមានភាពបត់បែន ដោយសារមានទំនាក់ទំនងល្អ" ជាមួយនឹងពួកកុម្មុយនីស្តវៀតណាម ពោលគឺដោយសារតែការសន្យារបស់ពួកកុម្មុយនីស្តវៀតណាមថា នឹងដកចេញពី "តំបន់រំដោះ" នៅពេលដែលកម្ពុជាអាចជំនួសពួកគេបាន។ មាគ៌ានេះត្រូវបានផ្លាស់ប្ដូរបន្តិចក្រោយមក បន្ទាប់ពីមហាសន្និបាតលើកទីបីរបស់ ប.ក.ក. នៅខែកញ្ញា ឆ្នាំ១៩៧១ ដែលនៅក្នុងសន្និបាតនោះ មេដឹកនាំបានសម្រេចថា វៀតណាម គឺជា "សត្រូវស្រួចស្រាវ" យូរអង្វែងរបស់កម្ពុជា។ នៅក្នុងមហាសន្និបាតនោះ ខៀវ សំផន ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការមជ្ឈិម ក្នុងនាមជាសមាជិកបម្រុង រួមជាមួយនឹង ជូ ជេត, កែ ពក និង កុយ ធួន។ មហាសន្និបាតក៏បានប្រកាសទទួលស្គាល់ឈ្មោះ ប.ក.ក. និងបានអនុម័តទៅលើលក្ខន្តិកៈបក្សផងដែរ[14]។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៧៣ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម វៀតកុង សាធារណរដ្ឋវៀតណាម និង សហរដ្ឋអាមេរិក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះតម្រូវឱ្យសហរដ្ឋអាមេរិកដកខ្លួនចេញពីជម្លោះវៀតណាម និងតម្រូវឱ្យមានការដកកម្លាំងវៀតណាមខាងជើងចេញពីទឹកដីកម្ពុជា។ ទោះបីជាពួកកុម្មុយនីស្តវៀតណាមបានដកកងកម្លាំងរបស់ខ្លួនចេញពីកម្ពុជា លើកលែងតែកងកម្លាំងមួយចំនួនសម្រាប់ជួយការពារការហូរចូលនៃការផ្គត់ផ្គង់អាវុធពីវៀតណាមខាងជើងទៅវៀតណាមខាងត្បូង ការដកខ្លួនរបស់សហរដ្ឋអាមេរិកពីប្រតិបត្តិការប្រយុទ្ធនៅលើទឹកដីវៀតណាមនេះ បាននាំឱ្យកងទ័ពសហរដ្ឋអាមេរិកបង្វែរការទម្លាក់គ្រាប់បែកពីលើអាកាសរបស់ខ្លួន ទៅលើកងកម្លាំងកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជាទៅវិញ[15]។

ខ្មែរក្រហមបានចាប់យកផលប្រយោជន៍ពីការបំផ្លិចបំផ្លាញ និងស្ថានភាពទុក្ខលំបាកវេទនារបស់ប្រជាជន ដែលបង្កឡើងដោយការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ និងបានធ្វើយុទ្ធនាការប្រមូលកម្លាំងដោយជោគជ័យ បញ្ចូលទៅក្នុងកងកម្លាំងប្រដាប់អាវុធដែលប្រយុទ្ធក្រោមស្លាករបស់រណសិរ្សរួបរួមជាតិកម្ពុជា/រាជរដ្ឋាភិបាលបង្រួមបង្រួមជាតិកម្ពុជា។ ក្នុងខែមិថុនា ឆ្នាំ១៩៧៤ ប.ក.ក. បានធ្វើការប្រជុំគណៈកម្មាធិការមជ្ឈិម ដែលចូលរួមដោយ ប៉ុល ពត, នួន ជា, សោ ភឹម, កុយ ធួន, តាម៉ុក, វន វ៉េត, រស់ ញឹម និង សុន សេន។ ពួកគេបានសម្រេចធ្វើការវាយប្រយុទ្ធជាលើកចុងក្រោយ ដើម្បីរំដោះទីក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀតនៅតាមជនបទ ក្នុងអំឡុងពេលរដូវប្រាំងនៃឆ្នាំ១៩៧៤-១៩៧៥។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្ដើមការវាយប្រហាររយៈពេលបីខែកន្លះមកលើទីក្រុងភ្នំពេញ ដោយប្រើគ្រាប់រ៉ុក្កែត និងអាវុធយុទ្ធភ័ណ្ឌផ្សេងៗទៀត។ នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងសាធារណរដ្ឋខ្មែរបានទទួលរងបរាជ័យយ៉ាងធ្ងន់ធ្ងរ ដែលបានណ្ដាលឱ្យលោក នាយករដ្ឋមន្ត្រី លន់ នល់ លាឈប់ពីមុខតំណែង ហើយភៀសខ្លួនចេញពីប្រទេស។ នៅក្នុងការប្រជុំមួយនៅដើមខែមេសា ឆ្នាំ១៩៧៥ ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន, វន វ៉េត, កុយ ធួន, កែ ពក, សោ ភឹម និង តាម៉ុក បានបញ្ចប់ផែនការកាន់កាប់ទីក្រុងភ្នំពេញ[16]។

ទីក្រុងភ្នំពេញបានធ្លាក់ក្រោមការកាន់កាប់របស់ខ្មែរក្រហមនៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

[13] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១៣-២២៤។
[14] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២២៣-២២៦។
[15] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២២៨-២២៩។
[16] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២២៧, ២២៩-២៣៣។

## ១.២. របបខ្មែរក្រហម (១៧ មេសា ១៩៧៥-៧ មករា ១៩៧៩)

*"ក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលស្ថិតក្នុងចំណោមរបបឃោរឃៅហួសហេតុជាងគេបំផុតក្នុងសតវត្សទីម្ភៃ បានបណ្តាលឱ្យមានការបាត់បង់ជីវិតប្រជាជនប្រមាណពី ១,៥ ទៅ ២ លាននាក់"* ប្រធានអង្គជំនុំជម្រះតុលាការកំពូល[17]។

### ១.២.១. រចនាសម្ព័ន្ធចាត់តាំងនៃការគ្រប់គ្រងនយោបាយ

ការសម្ងាត់ត្រូវបានចាត់ទុកជាមូលដ្ឋានគ្រឹះសំខាន់បំផុត ហេតុដូច្នេះអត្ថិភាពរបស់ ប.ក.ក. មិនត្រូវបានប្រកាសជាសាធារណៈឡើយ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧។ មុនពេលនោះ កម្មាភិបាលត្រូវបានណែនាំឱ្យហៅ ប.ក.ក. ថា *អង្គការ*។ ត្រឹមឆ្នាំ១៩៧៥ រចនាសម្ព័ន្ធចាត់តាំងត្រូវបានរៀបចំឡើងផ្អែកតាមលក្ខន្តិកៈបក្សរបស់ ប.ក.ក.។ "សិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ទូទាំងប្រទេស" ត្រូវបានប្រគល់ឱ្យមហាសន្និបាតបក្ស ដែលត្រូវជួបប្រជុំរៀងរាល់បួនឆ្នាំម្តង។ ហើយក្នុងចន្លោះពេលនៃសន្និបាតទាំងនោះ គណៈកម្មាធិការមជ្ឈិម គឺជាអង្គការប្រតិបត្តិការខ្ពស់ជាងគេនៅក្នុងប្រទេស។ គណៈកម្មាធិការមជ្ឈិមត្រូវជួបប្រជុំយ៉ាងហោចណាស់រៀងរាល់ប្រាំមួយខែម្តង ប៉ុន្តែអំណាចពិតប្រាកដស្ថិតនៅលើគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការមជ្ឈិម។ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានជ្រើសរើសចេញពីគណៈកម្មាធិការមជ្ឈិម ដែលជាស្ថាប័នមានសមាជិកច្រើនជាង និងជួបប្រជុំប្រមាណមួយសប្តាហ៍ម្តង ឬញឹកញាប់ជាងនេះ ប្រសិនបើកាលៈទេសៈតម្រូវ[18]។

គណៈកម្មាធិការយោធាគឺជាអនុគណៈកម្មាធិការ (ក្រោយលក្ខន្តិកៈដោយឡែក) របស់គណៈកម្មាធិការមជ្ឈិម ដែលមាន ប៉ុល ពត ជាប្រធាន សុន សេន ជាសមាជិក និងជាអ្នកគ្រប់គ្រងលើកងទ័ពបដិវត្តន៍កម្ពុជា។ មន្ទីរ ៨៧០ ត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយដំបូងឡើយមានសមាជិកយ៉ាងហោចណាស់ពីរនាក់គឺ សឿ វ៉ាស៊ី ហៅ ឌឿន និង ខៀវ សំផន។ អត្ថន័យពិតប្រាកដរបស់មន្ទីរ ៨៧០ មានភាពមិនច្បាស់លាស់ ដោយសារសាក្សីផ្សេងគ្នាផ្តល់នូវការយល់ឃើញខុសៗគ្នាពាក់ព័ន្ធនឹងលេខកូដ "៨៧០" នេះ។ ប៉ុន្តែក្នុងពេលសវនាការជំនុំជម្រះនៅ អ.វ.ត.ក. អ្នកជំនាញដែលបានផ្តល់សក្ខីកម្មបានឯកភាពគ្នាជាទូទៅថា មន្ទីរ ៨៧០ គឺជាស្ថាប័នរដ្ឋបាលនៅជុំវិញគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលទទួលខុសត្រូវត្រួតពិនិត្យមើលការអនុវត្តគោលនយោបាយ របស់គណៈកម្មាធិការអចិន្ត្រៃយ៍ ផ្សព្វផ្សាយគោលនយោបាយទាំងនោះទៅកាន់ថ្នាក់ក្រោម និងទទួលរបាយការណ៍ស្តីពីការបំពេញការងារ និងបញ្ហានានាទាក់ទងនឹងការអនុវត្ត។ ជាងនេះទៀត មជ្ឈិមបក្សមាន "មន្ទីររដ្ឋាភិបាល" មួយ ដែលមានលេខកូដ ស-៧១ ដែលមន្ទីរនេះដោះស្រាយបញ្ហាបច្ចេកទេស និងរដ្ឋបាល ហើយដំណើរការក្រោមការដឹកនាំរបស់ ឈឹម សំអោក ហៅ ប៉ង់។ មន្ទីរ ស-៧១ ត្រួតពិនិត្យលើបណ្តាញស្ថាប័នដែលមានលេខកូដផ្តើមដោយអក្សរ "ក" មានដូចជា "ក-១" ដែលជាកន្លែងធ្វើការនិងស្នាក់នៅរបស់ ប៉ុល ពត។ "ក-៣" គឺជាកន្លែងធ្វើការនិងស្នាក់នៅសម្រាប់ នួន ជា និង ខៀវ សំផន។ "ក-៦" គឺជាសាលាបណ្តុះបណ្តាលនយោបាយរបស់ ប.ក.ក. នៅបុរីកីឡា និង "ក-១៥" គឺជាសាលាបណ្តុះបណ្តាលនយោបាយជាសំខាន់ស្រាប់ខ្មែរដែលត្រឡប់មកពីបរទេសវិញ ក្នុងចំណោមមន្ទីរផ្សេងៗទៀត[19]។

នៅខាងក្រោមស្ថាប័នអំណាចនយោបាយប្រមូលផ្តុំទាំងអស់នេះ ប្រទេសត្រូវបានបែងចែកតាមភូមិសាស្ត្រជាភូមិភាគ តំបន់ ស្រុក ឃុំ និង ភូមិ។ ប.ក.ក. បានបែងចែកភូមិភាគមុនឆ្នាំ១៩៧៥ ហើយដំបូងឡើយមានភូមិភាគចំនួនប្រាំមួយគឺ ភូមិភាគឧត្តរ ភូមិភាគឦសាន ភូមិភាគបូព៌ា ភូមិភាគនិរតី ភូមិភាគបស្ចិម និង ភូមិភាគពាយ័ព្យ។ មុនឆ្នាំ១៩៧៥ តំបន់ជុំវិញក្រុងភ្នំពេញត្រូវបានកំណត់ថាជាភូមិភាគពិសេស ប៉ុន្តែ

---

[17] សំណុំរឿង ០០២ សេចក្តីសង្ខេប សាលដីកាក្នុងសំណុំរឿង០០២/០២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារ F76.1 កថាខណ្ឌ ៥។

[18] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៤២, ៣៤៣-៣៤៦, ៣៥៥, ៣៥៧, ៣៨៨។

[19] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៥៩, ៣៦២-៣៦៤, ៣៦៦-៣៦៨, ៤២៧។

ក្រោយមកត្រូវបានរំលាយចោលវិញ។ ក្នុងឆ្នាំ១៩៧៧ ភូមិភាគឧត្តរត្រូវបានបំបែកជាភូមិភាគឧត្តរថ្មី និង ភូមិភាគកណ្ដាល[20]។

ភូមិភាគនីមួយៗត្រូវបានបែងចែកទៅជាតំបន់មួយចំនួន ហើយតំបន់ទាំងនោះត្រូវបែងចែកបន្តទៅជាស្រុកផ្សេងៗ ហើយស្រុកត្រូវបានបែងចែកទៅជាឃុំ ហើយនៅក្នុងឃុំទាំងនោះមានភូមិមួយចំនួន។ ក្រោយមក នៅពេលដែលបដិវត្តន៍រីកចម្រើនទៅមុខ ភូមិមួយចំនួន និង ក្នុងករណីខ្លះ ឃុំ ត្រូវបានរៀបចំឡើងវិញទៅជាសហករណ៍។ ក៏មានតំបន់មួយចំនួនត្រូវបានកំណត់ថាជា "តំបន់ស្វយ័ត" មានដូចជា ព្រះវិហារ (តំបន់ ១០៣) សៀមរាប/ឧត្ដរមានជ័យ (តំបន់ ១០៦) មណ្ឌលគិរី (តំបន់ ១០៥) ក្រចេះ (តំបន់ ៥០៥) និង កំពង់សោម។ នៅតាមថ្នាក់នីមួយៗនៅក្នុងឋានានុក្រមចាត់តាំងរបស់ ប.ក.ក. កិច្ចការនានាត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការបក្ស ដែលមាន លេខាម្នាក់ អនុលេខាម្នាក់ និងសមាជិកម្នាក់ ឬពីរនាក់។ លេខានៅតាមថ្នាក់នីមួយៗជាទូទៅត្រូវបានតែងតាំងដោយថ្នាក់លើបន្ទាប់នៃឋានានុក្រម[21]។

ប.ក.ក. បានរៀបចំយន្តការដឹកនាំរដ្ឋជាក់ស្ដែងមួយ ហើយនៅដើមឆ្នាំ១៩៧៦ បានអនុម័តលើរដ្ឋធម្មនុញ្ញ ដែលជាផ្លូវការបានដាក់ឈ្មោះរដ្ឋនោះថាជា "កម្ពុជាប្រជាធិបតេយ្យ"។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យចែងអំពីការបង្កើតសភាតំណាងប្រជាជន ដែលជា "រូបភាពបិទបាំងខាងក្រៅ" សម្រាប់កម្ពុជាប្រជាធិបតេយ្យ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យត្រូវបានប្រកាសដោយគណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក.។ ពីរបីសប្ដាហ៍ក្រោយមក សមាជិកដឹកនាំទាំងអស់នៃរដ្ឋបាលចាស់បានលាឈប់ពីមុខតំណែង ដើម្បីបើកផ្លូវឱ្យរដ្ឋាភិបាលថ្មីមួយដែលដឹកនាំដោយ ប.ក.ក.[22]។

ស្ថាប័នរដ្ឋាភិបាលទាំងអស់នេះបានរាយការណ៍ទៅ និងទទួលបញ្ជាពីគណៈកម្មាធិការអចិន្ត្រៃយ៍នៃ ប.ក.ក.។ សភាតំណាងប្រជាជនអះអាងថាបង្កើតស្ថាប័នតុលាការ គណៈកម្មាធិការតុលាការ ប៉ុន្តែមិនមានស្ថាប័នណាមួយដំណើរការនោះទេ[23]។

រាល់ការប្រាស្រ័យទំនាក់ទំនងទាំងអស់នៅក្នុងបណ្ដាញរចនាសម្ព័ន្ធចាត់តាំងនេះ ពីថ្នាក់ខ្ពស់បំផុតនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ចុះមកថ្នាក់ទាបបំផុតនៅតាមភូមិ និងឃុំ មានលក្ខណៈតាមខ្សែបណ្ដោយខ្លាំងដោយមានការប្រាស្រ័យទំនាក់ទំនងតាមរយៈខ្សែទទឹងតិចតួចបំផុត។ សេចក្ដីណែនាំដាក់ចេញតាមឋានានុក្រម ហើយរបាយការណ៍អនុវត្តត្រូវបញ្ជូនទៅកាន់ថ្នាក់លើវិញ ពីថ្នាក់មួយទៅថ្នាក់បន្ទាប់ជានិច្ច គឺពីថ្នាក់តំបន់ ទៅកាន់ថ្នាក់ភូមិភាគ ឬចុះពីភូមិភាគមកតំបន់ ប៉ុន្តែមិនមែនពីតំបន់មួយទៅកាន់តំបន់មួយផ្សេងទៀតនោះទេ។ មានតែគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះដែលដឹងច្បាស់អំពីអ្វីដែលកំពុងកើតឡើងនៅទូទាំងប្រទេស[24]។

វិធីសាស្ត្រប្រាស្រ័យទំនាក់ទំនងរួមមាន ទូរលេខ ឬ សំបុត្រ វិទ្យុរលកសំឡេងខ្លីសម្រាប់សារនៅក្នុងប្រព័ន្ធឋានានុក្រម ចំណែកវិទ្យុផ្សាយសំឡេង និង ទស្សនាវដ្ដី ជាពិសេសការបោះពុម្ពផ្សាយប្រចាំខែនៃទស្សនាវដ្ដី*ទង់បដិវត្តន៍* និង *យុវជន យុវនារីបដិវត្តន៍* ត្រូវបានប្រើដោយគណៈកម្មាធិការមជ្ឈិមដើម្បីផ្សព្វផ្សាយព័ត៌មាន និង សេចក្ដីណែនាំឱ្យបានកាន់តែទូលំទូលាយ។ មានតែថ្នាក់លើបំផុតមួយចំនួនតូចប៉ុណ្ណោះ ដែលអាចប្រើការទំនាក់ទំនងតាមទូរស័ព្ទបាន។ ក្រៅពីបណ្ដាញនៃការទំនាក់ទំនងផ្ទៃក្នុងទាំងអស់នេះ ក្រសួងការបរទេសក៏បានរៀបចំការឃោសនាសម្រាប់ក្រៅប្រទេស ជាភាសាវៀតណាម អង់គ្លេស បារាំង និង ចិន ផងដែរ។ ក្រសួងឃោសនាការ និងព័ត៌មាន និងក្រសួងការបរទេសទទួលខុសត្រូវត្រួតពិនិត្យតាមដានសេចក្ដីរាយការណ៍ព័ត៌មានបរទេស និងសង្ខេបព័ត៌មានពីក្រៅប្រទេសឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍[25]។

---

20 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧០-៣៧២, ៣៧៦-៣៧៧។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២១៦។

21 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧២-៣៧៣, ៣៨៤។

22 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤១២-៤១៥។

23 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤១៦-៤១៨។

24 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៨៣, ៤៨៧។

25 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៥៧, ៤៦០-៤៦៣, ៤៦៥, ៤៦៧, ៤៧៣-៤៧៨, ៤៨០-៤៨១, ៤៨៦។

### ១.២.២. រចនាសម្ព័ន្ធចាត់តាំងនៃការគ្រប់គ្រងយោធា

មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពរបស់ ប.ក.ក. ស្ថិតក្រោមការគ្រប់គ្រងរបស់លេខាភូមិភាគ ដែលផ្តល់ទៅនឹងមជ្ឈិមបក្ស។ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ ប៉ុល ពត បានប្រកាសអំពីការបង្កើតកងទ័ពបដិវត្តន៍កម្ពុជាថ្មីមួយ ដែលប្រមូលផ្តុំអំណាចគ្រប់គ្រងរបស់មជ្ឈិមលើកងទ័ព។ រចនាសម្ព័ន្ធដឹកនាំថ្មីបានបង្កើតកងទ័ព "មជ្ឈិម" ក្រោមការបញ្ជារបស់អគ្គសេនាធិការ ដឹកនាំដោយ សុន សេន ដែលរាយការណ៍ផ្ទាល់ទៅកាន់ ប៉ុល ពត និងគណៈកម្មាធិការយោធា។ នៅក្នុងអគ្គសេនាធិការនេះ អនុប្រធាន និង ជំនួយការរបស់ សុន សេន ទទួលខុសត្រូវការងារមួយចំនួនទាក់ទងនឹងកិច្ចការយោធា រួមមាន ការស៊ើបការណ៍ ភស្តុភារ ការរៀបចំផែនការ បុគ្គលិក គ្រឿងសព្វាវុធ និង ការប្រាស្រ័យទំនាក់ទំនង[26]។

"កងពលមជ្ឈិម" និង "កងវរសេនាធំឯករាជ្យ" មួយចំនួន រាយការណ៍ផ្ទាល់ទៅកាន់អគ្គសេនាធិការ។ ក្នុងចំណោមកងពលទាំងនេះ កងពល ១៦៤ គឺជាកងទ័ពជើងទឹកស្ថិតក្រោមបញ្ជាការរបស់ មាស មុត ចំណែកកងពល ៥០២ គឺជាកងទ័ពជើងអាកាស ស្ថិតក្រោមបញ្ជាការរបស់ ស៊ូ ម៉េត។ កងពលមជ្ឈិមផ្សេងទៀតរួមមាន កងពល ១៧០, ២៩០, ៣១០, ៤៥០, ៧០៣, ៨០១ និង ៩២០។ កងពលនីមួយៗដឹកនាំដោយលេខាម្នាក់ និងអនុលេខាម្នាក់។ កងពលនីមួយៗមានកងវរសេនាធំចំនួនបី ហើយកងវរសេនាធំនីមួយៗមានកងវរសេនាតូចចំនួនបី។ នៅក្នុងកងវរសេនាតូចនីមួយៗមានកងអនុសេនាធំចំនួនបី ហើយនៅក្នុងកងអនុសេនាធំនីមួយៗមានកងអនុសេនាតូចចំនួនបី។ ក្នុងមួយអនុសេនាតូចមានបីក្រុម ដែលជាទូទៅមួយក្រុមមានទាហានចំនួន ១២ នាក់។ មានកងវរសេនាធំឯករាជ្យ ដែលកងវរសេនាធំឯករាជ្យនីមួយមានមុខងារពិសេសរៀងខ្លួន រួមបញ្ចូលទាំងមន្ទីរសន្តិសុខ ស-២១។ ភាគច្រើននៃកងទាំងអស់នេះត្រូវបានរៀបចំឡើងវិញជាប្រចាំ និងត្រូវបានចាត់តាំងថ្នាក់ដឹកនាំ ការតែងតាំង ភារកិច្ច និងទីតាំងឈរជើងថ្មី។ កងកម្លាំងជាមធ្យមមានចំនួន ៥.០០០ នាក់ ដែលចំនួនប្រែប្រួលពីតិចជាង ១.០០០ នាក់ ទៅ ជាង ៣.០០០ នាក់ នៅក្នុងកងវរសេនាធំឯករាជ្យ។ កងពល និងកងវរសេនាធំឯករាជ្យមួយចំនួន ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គសេនាធិការ ហើយមួយចំនួនទៀតស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគ ឬតំបន់ស្វយ័តនីមួយៗ[27]។

នៅថ្នាក់ភូមិ ឃុំ និងសហករណ៍ មានកងសន្តិសុខមួយប្រភេទទៀតដែលគេហៅថាឈ្លប ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំឃុំ។ ឈ្លបមិនមានសិទ្ធិអំណាចធ្វើការចាប់ខ្លួនដោយចិត្តឯងទេ ការណ៍នេះគឺជាសិទ្ធិអំណាចរបស់ថ្នាក់ស្រុក ឬតំបន់[28]។

### ១.២.៣. មហាលោតផ្លោះមហាអស្ចារ្យ

"*ទោះបីជាបដិវត្តន៍អាចបានផ្តល់អត្ថប្រយោជន៍ដល់សង្គមដោយគ្មានការបង្ហូរឈាម ឬសកម្មភាពល្មើសក៏ដោយ ក៏នេះពុំបានអនុវត្តចំពោះរឿងក្តីបច្ចុប្បន្ននេះឡើយ" អង្គជំនុំជម្រះតុលាការកំពូល*[29]

អ.វ.ត.ក. បានសន្និដ្ឋានថា ត្រឹមថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថ្នាក់ដឹកនាំ ប.ក.ក. បានចាប់ផ្តើម ***អនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈ "មហាលោតផ្លោះមហាអស្ចារ្យ" ដែលរៀបចំឡើងដើម្បីកសាង ការពារប្រទេសពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែរដែលមិនមានសាសនា និងរួបរួមគ្នាមួយ មានតែវណ្ណៈកម្មករ-កសិករ***[30]។ "ខ្មែ

[26] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤២៤, ៤២៨។
[27] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៨៧, ៤២៤, ៤២៧-៤២៨, ៤៣០, ៤៣២, ៤៥២។
[28] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៥៣, ១០៦៦-១០៦៩។
[29] សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ១៨១៥។
[30] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧៤៣, ៤០៦៨។

ក្រហមបានរៀបចំផែនការជាបន្តបន្ទាប់ដើម្បីសម្រេចបានគោលដៅនេះ តាំងពីពេលដំបូងនៃចលនាកុម្មុយនីស្តក្នុងប្រទេសកម្ពុជា[31] ហើយមានលក្ខណៈឧក្រិដ្ឋនៅក្នុងការរៀបចំ និងការអនុវត្តផែនការទាំងនោះ[32]។

អ.វ.ត.ក. បានពិនិត្យភ័ស្តុតាងឧក្រិដ្ឋកម្មតាមរយៈ "គោលនយោបាយ" ដែល ប.ក.ក. បានអនុវត្តគោលការណ៍ "មហាលោតផ្លោះ មហាអស្ចារ្យ" របស់ខ្លួន។ ផ្នែកខាងក្រោមនេះនឹងគូសបញ្ជាក់អំពីគោលនយោបាយនានាដែលបានអនុវត្តចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

### *១.២.៣.១. ការជម្លៀសប្រជាជន សហករណ៍ និង ការដ្ឋាន*

"ប្រព័ន្ធសម្រាប់ការធ្វើបាបរបស់ ប.ក.ក. បានជ្រាបទៅដល់គ្រប់ផ្នែកនៃជីវភាពរស់នៅ ដោយអ្នកដែលមានកាយសម្បទាគ្រប់គ្រាន់ ត្រូវបានគេធ្វើកំណែនិងដាក់ឱ្យទៅជាទាសករនៅតាមការដ្ឋានការងារ និងសហករណ៍នៅទូទាំងប្រទេស" អង្គជំនុំជម្រះសាលាដំបូង[33]

ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋនៃការជម្លៀសប្រជាជនពីទីប្រជុំជនក្រុង និងការតាំងទីលំនៅពួកគេដោយបង្ខំនៅតាមសហករណ៍ និងការដ្ឋាន។ គោលបំណងសំខាន់នៃការជម្លៀសនេះគឺដើម្បីបង្កើនផលិតកម្មដំណាំក្នុងស្រុក និងបំពេញគោលដៅសេដ្ឋកិច្ច ដើម្បីកសាងប្រទេសនិងប្រែក្លាយប្រជាជនទៅជាសង្គមមួយដែលមានតែកម្មករ-កសិករ[34]។

នៅក្នុងនិន្នាការមួយដែលចាប់ផ្តើមឡើងមុនឆ្នាំ១៩៧៥ និងបានបន្តទូទាំងឆ្នាំ១៩៧៨ ប.ក.ក. បានជម្លៀសប្រជាជនដោយបង្ខំចេញពីទីប្រជុំជនក្រុងនៅទូទាំងប្រទេស។ អ.វ.ត.ក. បានពិនិត្យការជម្លៀសប្រជាជនទ្រង់ទ្រាយធំមួយចំនួន ដោយប្រើពាក្យ "ការផ្លាស់ទីលំនៅប្រជាជន"៖

- **មុនឆ្នាំ១៩៧៥៖** ក្នុងតំបន់ "ដែលបានរំដោះ" ពីការគ្រប់គ្រងរបស់សាធារណរដ្ឋខ្មែរ[35]
- **ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃបន្តបន្ទាប់ ("ដំណាក់កាលទី១")៖** ក្រោយពីដួលរលំទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជនយ៉ាងហោចណាស់ពីរលាននាក់ចេញពីរដ្ឋធានី ក៏ដូចជាការជម្លៀសប្រជាជនផ្សេងទៀតនៅតាមទីប្រជុំជនសំខាន់ៗភ្លាមៗបន្ទាប់មកផងដែរ[36]
- **ការបណ្តេញជនស៊ីវិលវៀតណាមទៅកាន់ប្រទេសវៀតណាម៖** ក្នុងឆ្នាំ១៩៧៥ និង ១៩៧៦ ជាពិសេសនៅភូមិភាគបូព៌ា និងសហករណ៍ត្រាំកក់[37]
- **ពីចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ("ដំណាក់កាលទី២")៖** ការផ្លាស់ទីលំនៅប្រជាជនតាមរដូវកាលក្នុងចំនួនរាប់ម៉ឺននាក់នៅក្នុងភូមិភាគ និងរវាងភូមិភាគ[38]

---

[31] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧៣៣, ៣៧៤៣។
[32] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០៦៨។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VIII(ខ)(២)-(៨)។
[33] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៣៦៤។
[34] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៦.៤.១។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VIII(ខ)(៤)។
[35] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ៣.៣.១, ១៤.២។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៨៧៩, ៣៨៨៣។
[36] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០។ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ង)(១)(គ)។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៨៨១, ៣៨៨៣។
[37] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១០.១.១០, ១៣.៣.៧។
[38] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១១។ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ង)(១)(គ)។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩០៣។

- **ឆ្នាំ១៩៧៧-ដើមឆ្នាំ១៩៧៩ (ដំណាក់កាលទី ៣")៖** ដើម្បីឆ្លើយតបទៅនឹងតម្រូវការកសិកម្ម និង ដើម្បីផ្លាស់ទីលំនៅប្រជាជនដែលទទួលរងប៉ះពាល់ដោយការបោសសម្អាតនៅភូមិភាគបូព៌ា និង ការប៉ះទង្គិចនៅតាមព្រំដែន[39]

សហករណ៍នៅក្នុងភូមិភាគ និងតំបន់នីមួយៗ បានទទួលប្រជាជនជម្លៀសទាំងអស់នេះមួយចំនួនធំ។ សហករណ៍ត្រូវបានប្រើជាឧបករណ៍មនោគមន៍វិជ្ជា ដើម្បីរៀបចំប្រជាជនឱ្យមានលក្ខណៈជាសម្ូហភាពពឹងលើខ្លួនឯង។ ក្នុងនាមជាអង្គភាពចម្បងរបស់សង្គម សហករណ៍បានជំនួសទស្សនៈកម្មសិទ្ធិឯកជនឧស្សាហកម្ម មធ្យោបាយផលិតកម្ម ការអប់រំផ្លូវការ ស្ថាប័នសុខាភិបាល និងសូម្បីតែគ្រួសារ។

ជាក់ស្តែង ប.ក.ក. បានប្រើប្រាស់សហករណ៍ដើម្បីគ្រប់គ្រង និងត្រួតត្រាលើធនធានមនុស្ស ដែលខ្លួនត្រូវការដើម្បីអនុវត្តគោលដៅសេដ្ឋកិច្ចរបស់ខ្លួន។ ប្រជាជនត្រូវបានធ្វើឱ្យទៅជាទាសករឱ្យធ្វើកសិកម្មឱ្យបានទិន្នផលក្នុងកម្រិតមួយដែលមិនសមហេតុផល ដើម្បីជំរុញការនាំចេញ និងទុនសម្រាប់គោលបំណងសាងសង់បន្ថែមទៀត និងការការពារប្រទេស។ ទោះបីជាមានគ្រោះរាំងស្ងួតជាបន្តបន្ទាប់ កង្វះខាតអាហារ គ្រោះអត់ឃ្លាន និងបរិក្ខាពេទ្យមិនគ្រប់គ្រាន់ ទីជម្រក និងលក្ខខណ្ឌការងារក៏ដោយ ក៏ប្រជាជនត្រូវបានបង្ខំឱ្យធ្វើកសិកម្ម និងសាងសង់ប្រព័ន្ធភ្លឺស្រែ ប្រឡាយ ទំនប់ អាងស្តុកទឹក ផ្លូវដែក និងផលិតវាយនភ័ណ្ឌ ក្នុងចំណោមការងារផ្សេងទៀត[40]។

> *"អ្នកដែលត្រូវបានគេបង្ខំឱ្យធ្វើការ ត្រូវបានធ្វើឱ្យទៅជាទាសករដើម្បីជាផលប្រយោជន៍របស់បក្សតែមួយគត់" អង្គជំនុំជម្រះសាលាដំបូង*[41]

- **ការផ្លាស់ទីលំនៅដោយបង្ខំ៖** ដែលជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទាក់ទងទៅនឹងការផ្លាស់ទីលំនៅក្រោមលេសនៃការ "ជម្លៀស" បណ្តោះអាសន្ន[42]

- **អំពើមនុស្សឃាត៖** ទាក់ទងទៅនឹងការសម្លាប់ជនស៊ីវិល និងបុគ្គលិកយោធា រួមទាំងអ្នកដែលបដិសេធមិនព្រមចេញពីផ្ទះ និងអ្នកដែលមិនគោរពតាមការណែនាំ ក៏ដូចជាការស្លាប់ដែលបណ្តាលមកពីជំងឺ កង្វះអាហារ ទឹក ថ្នាំសង្កូវ ទីជម្រក និងអនាម័យ[43]

- **ការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស៖** ទាក់ទងទៅនឹងកាលៈទេសៈហិង្សាជុំវិញ "ការជម្លៀស" ចេញពីទីក្រុង ភាពធ្ងន់ធ្ងរនៃស្ថានភាព រយៈពេលធ្វើដំណើរទៅកាន់ទីជនបទ និងការធ្វើបាបពីសំណាក់ទាហានខ្មែរក្រហមនៅតាមផ្លូវ[44]

- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** ទាក់ទងទៅនឹងការប្រព្រឹត្តឃោរឃៅ ដែលខ្លាំងពិតប្រាកដ និងខ្លាំងតាមការសន្មតរបស់ ប.ក.ក. បានជួបប្រទះ[45]

---

[39] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩០៨, ៣៩១៥។ ដោយសារតែការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ អង្គហេតុទាក់ទងនឹងដំណាក់កាលទី ៣ មិនត្រូវបានពិនិត្យយ៉ាងជាក់លាក់នៅពេលជំនុំជម្រះនោះទេ។

[40] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៦.៤.១។

[41] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៨៥។

[42] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០.៤.១។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៣)។

[43] សូមមើល សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០.៤.២។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(១)(ខ)។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការសម្លាប់រង្គាល។ សូមមើល សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(២)(ខ)។

[44] សូមមើល សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០.៤.៤។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៣)។

[45] សូមមើល សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០.៤.៥។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៤)។

តាមរយៈការផ្លាស់ទីលំនៅប្រជាជនពីកន្លែងមួយទៅកន្លែងមួយ និងការបង្ខំពួកគេឱ្យធ្វើការនៅតាមសហករណ៍ និងការដ្ឋាននៅទូទាំងប្រទេស ឧក្រិដ្ឋកម្មនានាខាងក្រោមនេះត្រូវបានប្រព្រឹត្តឡើង៖

- **ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ៖** ដែលជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទាក់ទងទៅនឹងការផ្លាស់ទីលំនៅដោយបង្ខំនៃប្រជាជនស៊ីវិលនៅក្នុងភូមិភាគ និងរវាងភូមិភាគ[46]
- **ការធ្វើមនុស្សឃាត៖** ទាក់ទងទៅនឹងការសម្លាប់ខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មត និងការស្លាប់បណ្តាលមកពីលក្ខខណ្ឌអមនុស្សធម៌នៅតាមសហករណ៍ និងការដ្ឋាន[47]
- **ការធ្វើឱ្យទៅជាទាសករ៖** ទាក់ទងទៅនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព (រួមមានសហករណ៍ ស្រែ ទំនប់ ភ្លឺ និងប្រឡាយ) និងគ្រឿងបរិក្ខាការពារ[48]
- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** ទាក់ទងទៅនឹងការកំណត់គោលដៅលើខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មត រួមមាន ប្រជាជនថ្មី អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ ជនក្បត់ អ្នកប្រឆាំងបដិវត្តន៍ និងអ្នករិះខានដល់បដិវត្តន៍ផ្សេងទៀត ដែលមិនអាចបំពេញតាមគោលដៅបដិវត្តន៍[49]
- **ការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស៖** ដែលជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទាក់ទងទៅនឹងលក្ខខណ្ឌរស់នៅមិនគ្រប់គ្រាន់ (រួមមានរបបអាហារមិនគ្រប់គ្រាន់ ទឹកផឹក កន្លែងស្នាក់នៅ បរិក្ខាបង្គន់ បរិក្ខាពេទ្យ និងអនាម័យ) និង ការអនុវត្តការងារដ៏គ្រោះថ្នាក់[50]
- **ការបាត់ខ្លួនដោយបង្ខំ៖** ដែលជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ទាក់ទងទៅនឹងការបាត់ខ្លួនអ្នកដែលត្រូវបានកំណត់អត្តសញ្ញាណថាជាខ្មាំង[51]។

អ.វ.ត.ក. បានធ្វើការពិនិត្យជាពិសេសទៅលើអង្គហេតុទាក់ទងនឹងការជម្លៀសប្រជាជន សហករណ៍ និងការដ្ឋាននៅក្នុងរឿងក្តីខាងក្រោមនេះ៖

---

[46] សូមមើល សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១១.៦.១។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៣)។

[47] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩២០។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VIII(ខ)(៩) (ការស្លាប់បណ្តាលមកពីលក្ខខណ្ឌដ៏អាក្រក់ [ពោលគឺ ជាមួយនឹងចេតនាប្រយោល] បង្កើតបានជាផ្នែកមួយនៃគោលបំណងរួម ហើយមិនអាចប្រកែកបានដោយផ្ទាល់ចំពោះ ខៀវ សំផន ក្នុងនាមជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ហើយដែល ខៀវ សំផន អាចទទួលខុសត្រូវដោយផ្ទាល់ក្នុងនាមជាសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួម)។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក IV(ឃ)(២)(គ) (កំណត់ឡើងវិញនូវអង្គហេតុនានាទាក់ទងនឹងដំណាក់កាលទី២ ថាជាការធ្វើមនុស្សឃាត)។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ក)(៥)(ក)-(ឃ)។

[48] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩២២-៣៩២៣។

[49] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩២៤-៣៩២៥។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ច)(២)(ខ)។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការរកឃើញដែលថា ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ បង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ សូមមើល សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៤)(ឃ)។

[50] សូមមើល សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១១.៦.៣។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩២៦។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៣)។

[51] សូមមើល សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១១.៦.២។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩២៧។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤ (ឃ)(៣)(ង)។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ឆ)(២)(ក)។

- **សំណុំរឿង ០០១៖** ទាក់ទងទៅនឹងលក្ខខណ្ឌការងាររបស់អ្នកទោសនៅ **មន្ទីរសន្តិសុខ ស-២១**[52] និងលក្ខខណ្ឌរស់នៅនិងធ្វើការនៅ **ស-២៤**[53]

- **សំណុំរឿង ០០២/០១៖** ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ (**ដំណាក់កាលទី ១**)[54] និងការផ្លាស់ទីលំនៅប្រជាជននៅក្នុងភូមិភាគ និងរវាងភូមិភាគ ចន្លោះខែវិច្ឆិកា ឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៧ (**ដំណាក់កាលទី ២**)[55]

- **សំណុំរឿង ០០២/០២៖** ទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម ដែលបានអនុវត្តនៅ**សហករណ៍ត្រាំកក់**[56] **ការដ្ឋានទំនប់ត្រពាំងថ្ម**[57] **ការដ្ឋានទំនប់ ១ មករា**[58] **ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង**[59] និងទាក់ទងទៅនឹងការផ្លាស់ទីលំនៅ**ប្រជាជនចាម** (ក្នុងដំណាក់កាលទី ២)[60]

- **សំណុំរឿង ០០៣៖** ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់កងទ័ពបដិវត្តន៍កម្ពុជានៅ**កន្លែងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង** និង**ការដ្ឋានវាយថ្មស្ទឹងហាវ**[61]

- **សំណុំរឿង ០០៤៖** ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅ**ទីតាំងសាងសង់ទំនប់អន្លង់ជ្រៃ** (ភូមិភាគកណ្តាល) **ទំនប់ត្រពាំងថ្ម ទំនប់ស្ពានស្រែង** និង **ទំនប់ព្រៃរនាម** (ភូមិភាគពាយ័ព្យ)[62]។

### *១.២.៣.២. មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស*

ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋនៃការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន និងការបំបែក និង “ការកម្ទេច” (ពោលគឺ ការសម្លាប់) ប្រភេទខ្មាំងដែលប្រព្រឹត្តកំហុសធ្ងន់ធ្ងរ។ ខ្មាំងដែលប្រព្រឹត្តកំហុសស្រាល ដែលគេហៅថា “សមាសភាពមិនល្អ” ត្រូវអប់រំកសាងតាមរយៈការបំពាក់បំប៉នមនោគមន៍វិជ្ជានយោបាយ ទិតៀន/ស្វ័យទិតៀន និងការចាត់តាំងការងារ ដែលរៀបចំឡើងដើម្បីលត់ដំអ្នកដែលមាននិន្នាការប្រឆាំងបដិវត្តន៍។ គោលនយោបាយទាំងអស់នេះត្រូវបានអនុវត្តនៅតាមមន្ទីរសន្តិសុខជាង ២០០ កន្លែងនៅទូទាំងប្រទេស នៅគ្រប់ថ្នាក់នៃរចនាសម្ព័ន្ធរដ្ឋបាលនិងយោធាទាំងអស់របស់ ប.ក.ក.[63]។

នៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ប.ក.ក. បានពិភាក្សាអំពីខ្មាំងប្រភេទអស់ទាំងនេះជាបន្តបន្ទាប់ និងយ៉ាងទូលំទូលាយនៅក្នុងអំឡុងពេលប្រជុំនៅតាមកម្រិតមួយចំនួន។ អត្ថន័យនៃពាក្យ “ខ្មាំង” នេះរាប់បញ្ចូលទាំងអ្នកដែលគេសន្មត់ថាប្រឆាំងជាក់ស្តែង ឬអ្នកដែលមានសតិអារម្មណ៍ប្រឆាំងនឹងបដិវត្តន៍កុម្មុយនីស្ត។ មនុស្សត្រូវបានចាត់ថ្នាក់ផ្អែកតាមការជាប់ពាក់ព័ន្ធពិតប្រាកដ ឬតាមការសន្មតជាមួយនឹងក្រុម ឬវណ្ណៈជាក់លាក់ណាមួយ ឬដោយសារតែមានជាប់ពាក់ព័ន្ធទៅនឹងអាកប្បកិរិយាប្រឆាំងបដិវត្តន៍តាមជាក់ស្តែង ឬតាមការសន្មត។ តាំងពីដើមមក ការបែងចែករវាងខ្មាំងខាងក្នុង (ពោលគឺ អ្នកដែលមកពីខាងក្នុងប្រទេស និងក្នុងជួរ ប.ក.ក.) និងខ្មាំងខាងក្រៅជួរបក្ស (ខ្មាំងបរទេស) ត្រូវបានបន្តអនុវត្ត[64]។

---

[52] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៤.២.២។
[53] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៤.២.១។
[54] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០។
[55] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១១។
[56] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១០។
[57] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១១.១។
[58] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១១.២។
[59] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១១.៣។
[60] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.៨។
[61] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ កិច្ចដំណើរការនីតិវិធីទាក់ទងនឹងអង្គហេតុទាំងអស់នេះ ត្រូវបានបញ្ចប់។ សូមមើលខាងក្រោម ជំពូក ៥.៣.២។
[62] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ កិច្ចដំណើរការនីតិវិធីទាក់ទងនឹងអង្គហេតុទាំងអស់នេះ ត្រូវបានបញ្ចប់។ សូមមើលខាងក្រោម ជំពូក ៥.៣.៣។
[63] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៦.៤.២។
[64] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧៤៤។

អង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិនិត្យឥរិយាបទផ្លាស់ប្តូររបស់ ប.ក.ក. ចំពោះខ្មាំង ចន្លោះឆ្នាំ ១៩៧៥ និង ១៩៧៩ រួមបញ្ចូលទាំងការកំណត់អត្តសញ្ញាណពួកគេបើបដូច្នោះ។ ជាទូទៅ ប.ក.ក. ចាត់ទុកប្រភេទខាងក្រោមនេះថាជាខ្មាំងនៅក្នុងរយៈពេលស្ទើរតែទាំងស្រុងនៃរបបកម្ពុជាប្រជាធិបតេយ្យ៖

- អតីតបុគ្គលិកស៊ីវិល និងយោធាដែលមានឋានៈនៃរបបសាធារណរដ្ឋខ្មែរ
- វណ្ណៈដែលគេសន្មតថាប្រឆាំងបដិវត្តន៍ ដូចជា ពួកសក្តិភូមិ នាយទុន អាណានិគមបែបថ្មី ចក្រពត្តិនិយម និង "វណ្ណៈជិះជាន់" ផ្សេងទៀត
- "ភ្នាក់ងារ" ដែលគេកំណត់ថាជា សេ.អ៊ី.អា កា.ហ្សេ.បេ កម្មករនិងកសិករដែលមិនពេញចិត្ត "ខ្មាំងបង្កប់" និង ជនបំផ្លាញបដិវត្តន៍
- ប្រទេសវៀតណាម និងសហរដ្ឋអាមេរិក

ប្រភេទផ្សេងទៀត ដូចជា "ប្រជាជនថ្មី" អ្នកត្រឡប់មកពីបរទេស ព្រះសង្ឃ និងជនជាតិថៃ ក៏ត្រូវបានចាត់ទុកថាជាខ្មាំងផងដែរ[65]។

ការបំផ្ទុះគ្រាប់បែកនៅខែមេសា ឆ្នាំ១៩៧៦ នៅជិតព្រះបរមរាជវាំង ក្នុងទីក្រុងភ្នំពេញ និងការចែកខិត្តប័ណ្ណរិះគន់ ប.ក.ក. បាននាំឱ្យមានការចាប់ខ្លួនទ្រង់ទ្រាយធំ។ មនុស្សរាប់រយនាក់ត្រូវបានចាប់ខ្លួន និងធ្វើទារុណកម្មឱ្យផ្តល់ "ចម្លើយសារភាព"។ អ្នកដែលមានឈ្មោះក្នុង "ចម្លើយសារភាព" ក៏ត្រូវបានចាប់ខ្លួន សួរចម្លើយ បង្ខំឱ្យផ្តល់ "ចម្លើយសារភាព" ឆ្លើយដាក់អ្នកផ្សេង ហើយចុងបញ្ចប់ត្រូវបានសម្លាប់ផងដែរ[66]។

លំហូរអ្នកទោសចូលក្នុង និងចេញពីមន្ទីរសន្តិសុខ ស-២១ បានឆ្លុះបញ្ចាំងឱ្យឃើញពីការបោសសម្អាតទ្រង់ទ្រាយធំជាបន្តបន្ទាប់ ដែលបានធ្វើឱ្យវិនាសមុន្នីយោធា និងរដ្ឋបាលចុះខ្សោយនៅទូទាំងប្រទេស រួមបញ្ចូលទាំង កងពល ភូមិភាគ ក្រសួង និងសូម្បីតែថ្នាក់ដឹកនាំកំពូលរបស់ ប.ក.ក. ផងដែរ។ បញ្ជីខាងក្រោមសង្ខេបការរកឃើញរបស់ អ.វ.ត.ក. ទាក់ទងនឹងការបោសសម្អាត និងការសម្លាប់បុគ្គលជាន់ខ្ពស់សំខាន់ៗ[67]៖

**ឆ្នាំ១៩៧៦**

- **កែវ មាស**៖ អតីតឥស្សរៈ និង ជាសមាជិក*ក្រុមប្រជាជន* ក្រោយមកត្រូវបានចោទប្រកាន់ជាសាធារណៈថាចូលដៃជាមួយបុគ្គលខាងក្រោម
- **យឹម សំបាត់**៖ អនុកងអនុសេនាតូច ក្នុងកងពល ១៧០ ហើយទទួលខុសត្រូវទីកន្លែងដែលគ្រាប់បែកផ្ទុះ
- **ចាន់ ចក្រី**៖ លេខាកងពល ១៧០ ត្រូវបាន យឹម សំបាត់ ឆ្លើយដាក់
- **ស្អុស នៅ (ហៅ ឈូក)**៖ លេខាតំបន់ ២៤ (ភូមិភាគបូព៌ា) ត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវចំពោះការវាយប្រហារដោយគ្រាប់បែក និងការចែកផ្សាយខិត្តប័ណ្ណ
- **ណៃ សារ៉ាន់ (ហៅ យ៉ា)**៖ អតីតឥស្សរៈ សមាជិក*ក្រុមប្រជាជន*និងជាលេខាភូមិភាគឦសាន ត្រូវបាន យឹម សំបាត់, ចាន់ ចក្រី, ស្អុស នៅ និង លី ផែន ឆ្លើយដាក់ថាចូលដៃជាមួយវៀតណាម
- **នង សួន (ហៅ ជ័យ សួន)**៖ លេខាគណៈកម្មាធិការកសិកម្ម ត្រូវបានគេឆ្លើយដាក់ថាចូលដៃជាមួយ កែវ មាស រៀបចំផែនការប្រឆាំងនឹងបក្ស និងបដិវត្តន៍

[65] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៦.៣។
[66] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១២.១។
[67] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១២.១, ១២.២.៨។

**ឆ្នាំ១៩៧៧**

- **កុយ ធួន៖** រដ្ឋមន្ត្រីពាណិជ្ជកម្ម និងជាអតីតលេខាភូមិភាគឧត្តរ
- **សឿ វ៉ាស៊ី (ហៅ ឌឿន)៖** ប្រធានមន្ទីរនយោបាយ ៨៧០ ជំនួស កុយ ធួន ជារដ្ឋមន្ត្រីពាណិជ្ជកម្ម
- **ស្បូវ ហ៊ឹម (ហៅ អឿន)៖** លេខាកងពល ៣១០ ក្នុងភូមិភាគឧត្តរ ត្រូវបានចោទថាដឹកនាំផែនការផ្តួលរំលំ ប៉ុល ពត
- **ហ៊ូ នឹម (ហៅ ភាស់)៖** ម្នាក់ក្នុងចំណោម "ខ្មោចទាំងបី" លេខាក្រសួងឃោសនាការ
- **ស៊ាត ឆែ (ហៅ ទុំ)៖** លេខាតំបន់ ២២ នៃភូមិភាគបូព៌ា ដើមឡើយជំនួស យ៉ា ជាអនុលេខា សុន សេន នៅសេនាធិការ

**ឆ្នាំ១៩៧៨**

- **សោ ភឹម៖** អតីតឥស្សរៈ លេខាភូមិភាគបូព៌ា ធ្វើអត្តឃាតមុនពេលចាប់ខ្លួន
- **រស់ ញឹម៖** លេខាភូមិភាគពាយ័ព្យ ត្រូវបានចាប់ខ្លួននៅអំឡុងពេល សោ ភឹម ធ្វើអត្តឃាត
- **ជូ ជេត (ហៅ ស៊ី)៖** អតីតសមាជិក*ក្រុមប្រជាជន* លេខាភូមិភាគបស្ចិម
- **កង ចាប (ហៅ សែ ហៅ ចាន់ សំ)៖** លេខាភូមិភាគឧត្តរថ្មី អតីតលេខាតំបន់ ៣៥ ភូមិភាគនិរតី
- **វន វ៉េត៖** ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍
- **ប៊ិន ណាន (ហៅ យី)៖** លេខាតំបន់ ៥០៥
- **អ៊ិន លន (ហៅ ណាត)៖** អតីតប្រធានមន្ទីរសន្តិសុខ ស-២១
- **ឈឹម សំអោក (ហៅ ប៉ង់)៖** អ្នកនាំពាក្យឱ្យ ប៉ុល ពត និងជាប្រធានមន្ទីរ ស-៧១

*"ខណៈដែលបដិវត្តកំពុងឆ្ពោះទៅមុខ បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ធ្វើបាប និងបោសសម្អាតដោយមិនរើសមុខ និងដោយគ្មានការធ្វើយុត្តិកម្មដ៏សមហេតុផល ដោយមូលហេតុនយោបាយនោះទេ។ សកម្មភាពបែបនេះ មិនមែនជាការធ្វើទុក្ខបុកម្នេញតទៅទៀតនោះទេ ប៉ុន្តែ បង្កើតឱ្យមានការភ័យខ្លាចដែលពុំមានលក្ខណៈវិនិច្ឆ័យដែលស្វែងឱ្យឃើញក្នុងការកំណត់គោលដៅលើជនរងគ្រោះឡើយ" អង្គជំនុំជម្រះតុលាការកំពូល*[68]។

អ.វ.ត.ក. បានពិនិត្យអង្គហេតុទាក់ទងទៅនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅពេលសវនាការនៅក្នុងរឿងក្តីខាងក្រោម៖

- **សំណុំរឿង ០០១៖** ទាក់ទងទៅនឹង**មន្ទីរសន្តិសុខ ស-២១** និងការប្រព្រឹត្តលើអ្នកទោសនៅ**ជើងឯក** និង **ស-២៤**[69]
- **សំណុំរឿង ០០២/០១៖** ទាក់ទងទៅនឹងទីតាំងសម្លាប់មនុស្ស**ទួលពោធិ៍ជ្រៃ**[70]
- **សំណុំរឿង ០០២/០២៖** ទាក់ទងទៅនឹង៖

---

[68] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២៨៣។

[69] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ផ្នែក ៤។

[70] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១២។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤ (ឃ)(១)(គ), (ឃ)(២)(ឃ)។

- សហឧក្រិដ្ឋកម្មរួមដូចដែលបានអនុវត្តទាក់ទងនឹង**ការបោសសម្អាតផ្ទៃក្នុង** នៅ**មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង** និង **មន្ទីរសន្តិសុខភ្នំក្រោល**[71]
- ការធ្វើបាបលើជនជាតិចាមនៅ**មន្ទីរសន្តិសុខភូមិទ្រា** និង**មន្ទីរសន្តិសុខវត្តអូរត្រកួន**[72]
- ការធ្វើបាបលើជនជាតិវៀតណាមនៅទីតាំងជាច្រើនក្នុង**ភូមិភាគបូព៌ា** និង**ភូមិភាគកណ្ដាល** (ភូមិភាគឧត្តរចាស់)[73]។

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**ខាងក្រោមត្រូវបានប្រព្រឹត្តឡើងនៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស[74]៖

- **ការធ្វើមនុស្សឃាត៖** ទាក់ទងទៅនឹងការសម្លាប់ខ្មាំងពិតប្រាកដ និងខ្មាំងតាមការសន្មត និងការស្លាប់ដែលបណ្ដាលមកពីលក្ខខណ្ឌអមនុស្សធម៌[75]
- **ការសម្លាប់រង្គាល៖** ទាក់ទងទៅនឹងប្រតិបត្តិការសម្លាប់ទ្រង់ទ្រាយធំ រួមបញ្ចូលទាំងយ៉ាងហោចណាស់មនុស្ស ១១.៧៤២ នាក់ នៅមន្ទីរសន្តិសុខ ស-២១ និង ១.០០០ នាក់ នៅមន្ទីរសន្តិសុខក្រាំងតាចាន់[76]
- **ការធ្វើឱ្យទៅជាទាសករ៖**ទាក់ទងទៅនឹងការកេងប្រវញ្ចលើកម្មករនៅតាមកន្លែងធ្វើការ ក្នុងគោលបំណងទាយយកផលប្រយោជន៍ឱ្យបក្ស[77]
- **ការដាក់ក្នុងមន្ទីរឃុំឃាំង៖** ទាក់ទងទៅនឹងការឃុំខ្លួនអ្នកទោសដោយចិត្តឯង ដោយសារតែស្ថានភាពជាខ្មាំងតាមការសន្មតរបស់ពួកគេ[78]
- **ការធ្វើទារុណកម្ម៖** ទាក់ទងទៅនឹងការឈឺចាប់ និងទុក្ខវេទនាធ្ងន់ធ្ងរ ដែលបង្កលើអ្នកទោសក្នុងពេលសួរចម្លើយ ក្នុងគោលបំណងទទួលបាន "ចម្លើយសារភាព" អំពីសកម្មភាពប្រឆាំងបដិវត្តន៍

---

[71] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១២១-១២៥។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VI-VII។
[72] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២។
[73] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣។
[74] ការធ្វើបាបជាក់លាក់លើក្រុមដែលត្រូវបានកំណត់គោលដៅត្រូវបានពិភាក្សាដាច់ដោយឡែកខាងក្រោមក្នុងជំពូក ១.២.៣.៣។
[75] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៥.៣.២។ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៦៨៣។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៧៤-៣៩៧៧។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(១)(គ)។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ក)(៥)(ង)។
[76] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៥.៣.២។ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៦៨៤។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៧៨។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(២)(ឃ)។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ខ)។
[77] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៥.៣.៤។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៧៩។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ផ្នែក IV(គ)។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(គ)។
[78] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៥.៣.៦។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៨០។

ទាញយកភ័ស្តុតាងចោទប្រកាន់អំពី "ខ្មាំង" ឬ "ខ្សែបណ្តាញក្បត់" ឬជាមធ្យោបាយបំភិតបំភ័យ ឬដាក់ទណ្ឌកម្មអ្នកទោស[79]

- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** ទាក់ទងទៅនឹងការជ្រើសរើសយកជាលក្ខណៈប្រព័ន្ធនូវខ្មាំងពិតប្រាកដ និងតាមការសន្មតសម្រាប់ការធ្វើបាបតាមរយៈការចាប់ខ្លួន និងឃុំខ្លួនតាមអំពើចិត្តការធ្វើទារុណកម្ម ការធ្វើបាបខាងរាងកាយ និងស្មារតី ការអប់រំកសាង ការបាត់ខ្លួន និងការស្លាប់[80]

- **ការបាត់ខ្លួនដោយបង្ខំ** ដែលជា "អំពើអមនុស្សធម៌ផ្សេងៗទៀត៖ ទាក់ទងទៅនឹងការកម្ចាត់ខ្មាំងក្រោមលេសនៃការសម្លាត់[81]

- **ការវាយប្រហារប្រឆាំងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស** ដែលជា "អំពើមនុស្សធម៌ផ្សេងៗទៀត"៖ ទាក់ទងទៅនឹងការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការឈឺចាប់ធ្ងន់ធ្ងរខាងរាងកាយ និងស្មារតី ដែលបង្កឡើងតាមរយៈឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ[82]

- **អំពើអមនុស្សធម៌ផ្សេងៗទៀត** ដែលជាប្រភេទដាច់ដោយឡែកតែឯង៖ ទាក់ទងទៅនឹងលក្ខខណ្ឌបន្ថោកបន្ទាប និងបាត់បង់លក្ខណៈជាមនុស្សចំពោះការឃុំខ្លួននៅមន្ទីរសន្តិសុខ ស-២១ រួមទាំងការដាក់ខ្នោះជើង ការដាក់ច្រវាក់ ការចងបិទភ្នែក និងការដាក់ខ្នោះដៃ ការវាយដំធ្ងន់ធ្ងរ និងការធ្វើទារុណកម្មលើរាងកាយ ការដាក់ឃុំឃាំងក្នុងបន្ទប់ឃុំតូច ឬបន្ទប់មានអ្នកជាប់ឃុំច្រើនពេក កង្វះអាហារ អនាម័យ និងការថែទាំវេជ្ជសាស្ត្រ ក៏ដូចជា ការបូបឈាម និងការធ្វើពិសោធន៍វេជ្ជសាស្ត្រ[83]

**អំពើប្រល័យពូជសាសន៍** ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងសហគមន៍ជនជាតិវៀតណាម និង ចាម ដែលត្រូវបានសម្លាប់ក្នុងចំនួនដ៏ច្រើននៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស[84]។ **ឧក្រិដ្ឋកម្មសង្គ្រាម** ក៏ត្រូវបានប្រព្រឹត្តឡើងផងដែរនៅមន្ទីរសន្តិសុខ ស-២១ ប្រឆាំងនឹងអ្នកទោសជនជាតិវៀតណាម ដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩[85]។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងការចោទប្រកាន់ ឬបញ្ចប់រឿងក្តី សហចៅក្រមស៊ើបអង្កេតក៏បានពិនិត្យអង្គហេតុនានាទាក់ទងនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សផងដែរ។ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សខាងក្រោមនេះត្រូវបានពិភាក្សានៅក្នុងដីកាដំណោះស្រាយ[86]៖

[79] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៥.៣.៨។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៨១។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ង) (ទាក់ទងនឹងចាម)។

[80] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៥.៣.១៤។ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៦៨៥។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៨២។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២៨៣ ផ្នែក ៤(ង)។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ច)(២)។

[81] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៨៦។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ឆ)។

[82] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩៨៥។

[83] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៥.៣.១២។

[84] សូមមើល ជំពូក ១.២.៣.៣.៣, ១.២.៣.៣.៤។

[85] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៦.៣។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១២.២.២៤.២។

[86] មានតែទីតាំងដែលត្រូវបានពិចារណានៅក្នុងដំណាក់កាលដីកាដំណោះស្រាយប៉ុណ្ណោះត្រូវបានរៀបរាប់នៅទីនេះ។ អង្គហេតុនានាទាក់ទងនឹងទីតាំងដែលត្រូវបានដកចេញពីការស៊ើបអង្កេត ឬកាត់បន្ថយពីវិសាលភាពនៃការស៊ើបអង្កេតដោយសហចៅក្រម

- **សំណុំរឿង ០០៣៖** ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើកងទ័ពបដិវត្តន៍កម្ពុជានៅ **មន្ទីរសន្តិសុខវត្តឥន្ទញាណ គុក ៨១០** និងមន្ទីរសន្តិសុខ និងទីតាំងបោសសម្អាតរបស់កងទ័ពបដិវត្តន៍កម្ពុជាផ្សេងទៀត[87]

- **សំណុំរឿង ០០៤៖** ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅ៖

  - **មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅភូមិភាគកណ្ដាល៖** វត្តអូរត្រកួន វត្តបាធាយ មិត្តសុប (គរ) វត្តភ្នំប្រុស គោកព្រីង ចម្ការស្វាយចន្ទី វត្តស្រង៉ែ ទួលតាផ្គង វត្តកណ្ដាល វត្តបារាយជាន់ដែក

  - **មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅភូមិភាគពាយ័ព្យ៖** វត្តគិរីរម្យ បន្ទាយអូរតាក្រៃ បន្ទាយត្រែង វត្តធម្មយុត វត្តកណ្ដាល វត្តសម្ដេច វត្តពោធិ៍លង្ការ វត្តបន្ទាយនាងល្អាងភ្នំក្ដួយយំ វត្តចំការខ្នុរ គុកលេខ៨ ទួលពោធិ៍ជ្រៃ ភ្នំទ្រយោង ភូមិចក្រី វត្តព្រះនេត្រព្រះ និង ចំការតាឡឹង

  - **មន្ទីរសន្តិសុខនៅភូមិភាគនិរតី៖** វត្តព្រះធាតុ

  - **ទីកន្លែងផ្សេងទៀត៖** ទាក់ទងទៅនឹងការបោសសម្អាតនៅភូមិភាគកណ្ដាល និងភូមិភាគពាយ័ព្យ និងនៅក្នុងបរិបទនៃការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាមនៅក្នុងខេត្តកំពង់ចាម[88]។

- **សំណុំរឿង ០០៤/០១៖** ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលចោទប្រកាន់នៅ**មន្ទីរសន្តិសុខភ្នំទ្រយោង វត្តអង្គស្រីមុន្នី** និង **ទីតាំងសម្លាប់មនុស្សព្រៃសុខុន វត្តព្រះនេត្រព្រះ** និងទាក់ទងទៅនឹង **មន្ទីរសន្តិសុខភូមិចក្រី** និង **វត្តចំការខ្នុរ**[89]

- **សំណុំរឿង ០០៤/០២៖** ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅ**ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្តបាធាយ មន្ទីរសន្តិសុខមិត្តសុប (គរ) ទីតាំងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខវត្តតាមាក់ មន្ទីរសន្តិសុខទួលតាផ្គង មន្ទីរសន្តិសុខវត្តកណ្ដាល មន្ទីរសន្តិសុខចំការស្វាយចន្ទី មន្ទីរសន្តិសុខវត្តបារាយជាន់ដែក មន្ទីរសន្តិសុខវត្តស្រង៉ែ មន្ទីរសន្តិសុខវត្តអង្គញ្ជី ទីតាំងសម្លាប់មនុស្សទួលបេង** ទីតាំងនៅក្នុង**ខេត្តកំពង់ចាម** ទាក់ទងទៅនឹងការចោទប្រកាន់អំពីការសម្លាប់ជនជាតិចាម[90]។

#### ១.២.៣.៣. ការកំណត់គោលដៅលើក្រុមជាក់លាក់

---

ស៊ើបអង្កេត ត្រូវបានលុបចេញ។ សម្រាប់ព័ត៌មានបន្ថែមលើចំណុចទាំងអស់នេះ សូមមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងប្រវត្តិនីតិវិធីនៃដីកាដំណោះស្រាយនៃរឿងក្ដីនីមួយៗ។

[87] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ផ្នែក ៣, ៥។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ផ្នែក ៥។ កិច្ចដំណើរការនិតិវិធីទាក់ទងទៅនឹងអង្គហេតុទាំងអស់នេះត្រូវបានបញ្ចប់។ សូមមើល ជំពូក ៥.៣.២។

[88] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381 ផ្នែក IV។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ផ្នែក ៥.២។ កិច្ចដំណើរការនិតិវិធីទាក់ទងទៅនឹងអង្គហេតុទាំងអស់នេះត្រូវបានបញ្ចប់។ សូមមើល ជំពូក ៥.៣.៣។

[89] សំណុំរឿង ០០៤/០១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 ផ្នែក ៤-៥។

[90] សំណុំរឿង ០០៤/០២, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 ផ្នែក III(ខ)។ សំណុំរឿង ០០៤/០២, ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ផ្នែក ៦.៤។

### ១.២.៣.៣.១. ការធ្វើបាបលើអតីតមន្ត្រី ទាហាន និងក្រុមគ្រួសាររបបសាធារណរដ្ឋខ្មែរ

*"ក្រោយថ្ងៃទី១៧ ខែមេសា [...] សម្រេចថាត្រូវធ្វើគ្រប់មធ្យោបាយដើម្បីកុំឱ្យអាចរៀបចំផែនការវាយបកប្រឆាំងបដិវត្តន៍វិញ"* អៀង សារី និយាយសំដៅលើពួកសាធារណរដ្ឋខ្មែរ[91]

ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋយ៉ាងទូលំទូលាយប្រឆាំងនឹងមន្ត្រី ទាហាន និងក្រុមគ្រួសាររបបសាធារណរដ្ឋខ្មែរ ហើយបានកំណត់គោលដៅធ្វើបាបពួកគេ។ គោលបំណងនៃគោលនយោបាយនេះ ដែលបានបង្កើតឡើងក្នុងអំឡុងពេលនៃរបបនោះ ត្រូវបានធ្វើដើម្បីការពារប្រទេសប្រឆាំងនឹងខ្មាំង - ដោយសារមន្ត្រីរបបសាធារណរដ្ឋ និងក្រុមគ្រួសាររបស់ពួកគេត្រូវបានចាត់ទុកថាជាខ្មាំង - និងដើម្បីប្រែក្លាយប្រជាជនទាំងមូលឱ្យទៅជាសង្គមមួយដែលមានតែកម្មករ-កសិករ[92]។

បន្ទាប់ពីការតស៊ូបដិវត្តន៍ជាច្រើនឆ្នាំប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែរ ខ្មែរក្រហមបានបង្កើតគោលជំហររើសអើងចំពោះមន្ត្រីសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ ដែលកើតមានឡើងនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ ប.ក.ក.[93]។ ភ្លាមៗក្រោយព្រឹត្តិការណ៍ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជននៃរបបសាធារណរដ្ឋខ្មែរបានក្លាយជា "ខ្មាំងសំខាន់" របស់ខ្មែរក្រហម ហើយត្រូវបាន "រុករក" និងសម្លាប់ជាលក្ខណៈប្រព័ន្ធ ដើម្បីការពារកុំឱ្យមានការប្រឆាំងបដិវត្តន៍។ បន្ទាប់ពីផ្អាកមួយរយៈពេលខ្លី មន្ត្រីជាន់ខ្ពស់ត្រូវបានកំណត់ឈ្មោះសម្លាប់ ពីខែតុលា ឆ្នាំ១៩៧៥ ដោយសារតែការគំរាមកំហែងដែលគេសន្និដ្ឋានថាជាការបះបោរប្រឆាំងបដិវត្តន៍នៅក្នុងប្រទេស ហើយត្រូវបានរុករក និងសម្លាប់ចោលជាបន្តបន្ទាប់ រហូតដល់ពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ។ ទាហាន មន្ត្រីរដ្ឋការ ដែលមានឋានៈតូចតាច និងក្រុមគ្រួសាររបស់ពួកគេត្រូវទទួលរងការរើសអើងជាប្រចាំក្នុងរូបភាពជាការចាប់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្ម និងការបាត់ខ្លួននៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[94]។

នៅក្នុងការរើសអើងប្រឆាំងនឹងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិខាងក្រោមនេះត្រូវបានប្រព្រឹត្តឡើង៖

- **ការធ្វើមនុស្សឃាត៖** ទាក់ទងទៅនឹងការសម្លាប់មន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរពីថ្ងៃទី២០ ខែមេសា ដល់ចុងខែឧសភា ឆ្នាំ១៩៧៥ និងការសម្លាប់មន្ត្រីជាន់ខ្ពស់ ពីខែតុលា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩[95]

- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** ទាក់ទងទៅនឹងការធ្វើបាបលើអតីតមន្ត្រី ទាហាន និងសមាជិកគ្រួសារទាំងអស់នៃរបបសាធារណរដ្ឋខ្មែរ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល រួមមានតាមរយៈការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការបាត់ខ្លួន[96]។

---

[91] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០៣៤ (គូសបញ្ជាក់បន្ថែម)។
[92] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៤។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VIII(ខ)(៥)(គ)។
[93] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០៣១។
[94] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៦.៤.៣.៤.១.២-១៦.៤.៣.៤.១.៣។
[95] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(១)(៣)។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០៥៧។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០.២.១៥, ១០.៤.២។ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ង)(១)(ឃ)។
[96] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៤)(គ)-(ឃ)។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០៥៩។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ផ្នែក ១០.២.១៥, ១០.៤.៥។ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ង)(១)(ឃ)។

អ.វ.ត.ក. បានពិនិត្យជាពិសេសលើការធ្វើបាបលើអតីតមន្ត្រី ទាហាន និងសមាជិកក្រុមគ្រួសាររបបសាធារណរដ្ឋខ្មែរនៅក្នុងរឿងក្តីខាងក្រោម៖

- **សំណុំរឿង ០០២/០១៖** ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ ១៩៧៥ (**ដំណាក់កាលទី១**) និងព្រឹត្តិការណ៍នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃបន្ទាប់មកក្នុងខែនោះដែរ

- **សំណុំរឿង ០០២/០២៖** ទាក់ទងទៅនឹងការអនុវត្តគោលនយោបាយនៅ**សហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១** និង **មន្ទីរសន្តិសុខក្រាំងតាចាន់**។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬបញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតក៏បានពិនិត្យអង្គហេតុទាក់ទងទៅនឹងការកំណត់គោលដៅ និងការធ្វើបាបលើមន្ត្រីរបបសាធារណរដ្ឋខ្មែរ ក្រុមគ្រួសាររបស់ពួកគេ និងអ្នកដែលគេសន្មតថាមានទំនាក់ទំនងជាមួយអ្នកទាំងនោះ។ អង្គហេតុទាំងនេះត្រូវបានពិភាក្សានៅក្នុងដីកាដំណោះស្រាយនៅក្នុងរឿងក្តីខាងក្រោម[97] ៖

- **សំណុំរឿង ០០៤៖** ទាក់ទងទៅនឹងភ័ស្តុតាងទូទៅអំពីការកំណត់គោលដៅ និងកាលៈទេសៈជាក់លាក់នៃការធ្វើបាបនៅ មន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខបាណន់ មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្សវត្តអង្គញ មន្ទីរសន្តិសុខវត្តសម្តេច គុកលេខ៨ ទីតាំងសម្លាប់មនុស្សព្រៃស្រុខ៊ុន និងវត្តអង្គសិរីមាលី មន្ទីរសន្តិសុខវត្តគាស់ក្រឡ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ឃុំវាំងកេសី មន្ទីរសន្តិសុខវត្តបន្ទាយនាង ភូមិចក្រី និងទួលពោធិ៍ជ្រៃ[98]

- **សំណុំរឿង ០០៤/០១៖** ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលចោទប្រកាន់នៅមន្ទីរសន្តិសុខភ្នំទ្រយោង[99]

- **សំណុំរឿង ០០៤/០២៖** ទាក់ទងទៅនឹងភ័ស្តុតាងទូទៅនៃការបោសសម្អាត និងកាលៈទេសៈជាក់លាក់នៃការធ្វើបាបនៅ**មន្ទីរសន្តិសុខមិត្តសុប (គរ) មន្ទីរសន្តិសុខទួលតាផុង មន្ទីរសន្តិសុខវត្តស្រង៉ែ មន្ទីរសន្តិសុខវត្តអង្គញ៉ឺ មន្ទីរសន្តិសុខទួលបេង ខេត្តកំពង់ចាម វត្តអូរត្រកួន វត្តបាធាយ វត្តតាមាក**[100]

## ១.២.៣.៣.២. ការធ្វើបាបពុទ្ធសាសនិក

"លោកសង្ឃនិងពុទ្ធសាសនិកត្រូវរលំពី ៩០% ទៅ ៩៥%។ ដូច្នេះ ស្រទាប់ពិសេស [នៃសង្គម]នេះមិនមានអ្វីគួរឱ្យព្រួយបារម្ភទេ" ឯកសារគោលនយោបាយ ប.ក.ក. ពីខែកញ្ញា ឆ្នាំ១៩៧៥[101]

ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋដើម្បីលុបបំបាត់ការប្រតិបត្តិព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា និងបានហាមឃាត់ការប្រតិបត្តិព្រះពុទ្ធសាសនា រវាងខែមេសា ឆ្នាំ១៩៧៥ នឹងខែមករា ឆ្នាំ

---

[97] មានតែទីតាំងដែលត្រូវបានពិចារណានៅក្នុងដំណាក់កាលដីកាដំណោះស្រាយប៉ុណ្ណោះត្រូវបានរៀបរាប់នៅទីនេះ។ អង្គហេតុនានាទាក់ទងនឹងទីតាំងដែលត្រូវបានដកចេញពីការស៊ើបអង្កេត ឬកាត់បន្ថយពីវិសាលភាពនៃការស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេត ត្រូវបានលុបចេញ។ សម្រាប់ព័ត៌មានបន្ថែមលើចំណុចទាំងអស់នេះ សូមមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងប្រវត្តិនីតិវិធីនៃដីកាដំណោះស្រាយនៃរឿងក្តីនីមួយៗ។

[98] សូមមើលជាទូទៅ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D381 ផ្នែក III(១.៩), IV(២)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D382 ផ្នែក ៥.២.២.២, ៥.៥។

[99] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 ផ្នែក ៦.២។

[100] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 ផ្នែក III(ខ)(១) (ជាទូទៅ)។ សំណុំរឿង ០០៤/០២, ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D382 ផ្នែក ៦.២, ៨ (ជាទូទៅ)។

[101] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ១០៨៨, ៤០២០។

១៩៧៩។ គោលបំណងនៃគោលនយោបាយនេះគឺដើម្បីការពារប្រទេសប្រឆាំងនឹងខ្មាំង - ដោយសារតែអ្នកប្រតិបត្តិព្រះពុទ្ធសាសនាត្រូវបានខ្មែរក្រហមចាត់ទុកថាជាខ្មាំង - និងដើម្បីប្រែក្លាយប្រជាជនទាំងមូលឱ្យទៅជាសង្គមមួយដែលមានតែកម្មករ-កសិករ[102]។

ខ្មែរក្រហមចាត់ទុកព្រះពុទ្ធសាសនាថាមិនចុះសម្រុងជាមួយនឹងបដិវត្តន៍។ ព្រះសង្ឃត្រូវបានផ្សឹកដោយបង្ខំ ហើយត្រូវបានបណ្តេញចេញពីវត្តអារាមទូទាំងប្រទេស។ វត្តអារាមត្រូវបានបិទ ឬប្រែក្លាយទៅជាគោលដៅផ្សេងក្រៅពីសាសនា និងប្រើប្រាស់ក្នុងលក្ខណៈប្រមាថមើលងាយ។ ការគោរពប្រណិប័តន៍ធម្មតារបស់ពុទ្ធសាសនិកត្រូវបានហាមឃាត់ រួមទាំងការអុជធូប ការរៀបអាពាហ៍ពិពាហ៍និងបុណ្យសពតាមប្រពៃណីផងដែរ។ ព្រះពុទ្ធបដិមា និងវត្ថុតំណាងឱ្យសាសនាត្រូវបានបំផ្លាញចោល ហើយ ប.ក.ក. ប្រឆាំងទៅនឹងព្រះពុទ្ធសាសនា ចាត់ទុកសាសនានេះថាមានលក្ខណៈ "ប្រតិកិរិយា" ដោយប្ដេជ្ញាបំផ្លាញការប្រតិបត្តិសាសនានេះ[103]។

តាមរយៈការធ្វើបាបព្រះសង្ឃពុទ្ធសាសនា និងពុទ្ធសាសនិក ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិខាងក្រោមនេះត្រូវបានប្រព្រឹត្តឡើង៖

- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា៖** ទាក់ទងទៅនឹងការផ្សឹកព្រះសង្ឃ ការហាមឃាត់ការគោរពប្រណិបតន៍ និងការបំផ្លិចបំផ្លាញវត្ត និមិត្តរូប និងការប្រតិបត្តិសាសនា[104]។

  អ.វ.ត.ក. បានពិនិត្យជាពិសេសលើការធ្វើបាបពុទ្ធសាសនិកនៅក្នុងរឿងក្តីខាងក្រោម៖

- **សំណុំរឿង ០០២/០២៖** ទាក់ទងទៅនឹងគោលនយោបាយទូទាំងប្រទេស ដូចដែលបានអនុវត្តនៅក្នុង**ស្រុកត្រាំកក់**[105]។

ភ័ស្តុតាងនៃការដាក់ក្នុងមន្ទីរឃុំឃាំងនៃព្រះសង្ឃពុទ្ធសាសនានៅ**មន្ទីរសន្តិសុខ ស-២១** ត្រូវបានបង្ហាញនៅក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០១[106] និង ឧទាហរណ៍ការកំណត់គោលដៅជាទូទៅ**នៅកន្លែងផ្សេងទៀតក្នុងប្រទេស**ត្រូវបានពិនិត្យនៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ និង ០០៤/០២[107]។

### ១.២.៣.៣.៣. ការធ្វើបាបលើជនជាតិចាម

*"តាមការអនុវត្តជាក់ស្តែង ប.ក.ក. មិនដែលបានអនុវត្តសិទ្ធិសេរីភាពជំនឿសាសនាអ្វីឡើយ សូម្បីនៅក្នុងការការពារដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យក្តី ហើយបានចាត់ទុកថាសាសនាអ៊ីស្លាម គឺជា "សាសនាប្រតិកិរិយា" ដូច្នេះ "ត្រូវហាមឃាត់ជាដាច់ខាត"*[108] អង្គជំនុំជម្រះសាលាដំបូង[109]។

ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋរើសអើងប្រឆាំងនឹងជនជាតិចាម ហើយបានកំណត់គោលដៅធ្វើបាបពួកគេ។ គោលបំណងគោលនយោបាយនេះ ដែលបានបង្កើតឡើងពីការបំបែកពង្រាយសហគមន៍ចាមក្នុងការកម្ទេចពួកគេជាក្រុម ត្រូវបានធ្វើឡើងដើម្បីការពារប្រទេសពីសំណាក់ខ្មាំង -

[102] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០២១។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VIII(ខ)(៥)(ឃ)។
[103] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៦.៤.៣.៣.១។
[104] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១០.១.៩។
[105] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១០.១.៩។
[106] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៣៨៦។
[107] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 កថាខណ្ឌ ២២៦, ៣១១។
[108] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 កថាខណ្ឌ ៥២៧។
[109] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣២១៥។

ដោយសារជនជាតិចាមពេលនោះត្រូវបានចាត់ទុកថាជាខ្មាំង - និងដើម្បីកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែរដែលមិនមានសាសនា និងរួបរួមគ្នាមួយ[110]។

ក្រុមជនជាតិចាមគឺជាក្រុមជាតិពន្ធ និងក្រុមសាសនាដាច់ដោយឡែកនៅក្នុងប្រទេសកម្ពុជា ដែលសមាជិករបស់ខ្លួនមានភាសានិងវប្បធម៌រួមគ្នា និងប្រតិបត្តិសាសនាអ៊ីស្លាម។ ក្នុងឆ្នាំ១៩៧៥ ចាមគឺជាក្រុមជនជាតិភាគតិចដែលមានប្រជាជនច្រើនជាងគេក្នុងប្រទេសកម្ពុជា ហើយទោះបីជាពួកគេមាននៅទូទាំងប្រទេសក្តី ភាគច្រើនពួកគេរស់នៅតាមបណ្តោយដងទន្លេមេគង្គ និងទន្លេសាប ដោយស្រុកក្រូចឆ្មារ ក្នុងខេត្តកំពង់ចាមត្រូវគេចាត់ទុកថាគឺជាទីកន្លែងសំខាន់មួយដែលមានសហគមន៍ចាមរស់នៅច្រើនជាងគេក្នុងប្រទេសកម្ពុជា[111]។

នៅដើមឆ្នាំនៃរបប កម្ពុជាប្រជាធិបតេយ្យបានកំណត់គោលដៅជាក់លាក់លើជនជាតិចាម តាមរយៈការរឹតត្បិតការប្រតិបត្តិសាសនា និងវប្បធម៌របស់ពួកគេ ក្នុងគំនិតផ្តួចផ្តើមមួយធ្វើយ៉ាងណាដើម្បីបញ្ចូលពួកគេជាមួយនឹងសហគមន៍ខ្មែរ។ នៅពេលដែលជនជាតិចាមបដិសេធការបោះបង់អត្តសញ្ញាណជាតិពន្ធនឹងសាសនារបស់ខ្លួន “ការបះបោរ” ត្រូវបានបង្ក្រាបយ៉ាងឃោរឃៅ មេដឹកនាំសាសនា និងសហគមន៍ត្រូវបានសម្លាប់ ហើយសហគមន៍ចាមត្រូវបានបំបែក។ របត់ចុងក្រោយបានកើតឡើងចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ នៅពេលដែលមានបញ្ជាឱ្យធ្វើការបោសសម្អាតជនជាតិចាមទាំងអស់។ ការណ៍នេះកើតឡើងដំណាលគ្នាជាមួយនឹងការកើនឡើងនៃជម្លោះជាមួយវៀតណាម នៅពេលដែលអាទិភាពខ្ពស់បំផុតនោះគឺចាំបាច់ត្រូវថែរក្សាពូជសាសន៍ខ្មែរ និងការពារប្រជាជនកម្ពុជាពីសំណាក់ខ្មាំង[112]។

អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានប្រព្រឹត្តឡើងតាមរយៈការធ្វើបាបលើជនជាតិចាម៖

- **អំពើប្រល័យពូជសាសន៍**តាមរយៈការសម្លាប់សមាជិកក្រុមជនជាតិចាម **ការធ្វើមនុស្សឃាត** និង **ការសម្លាប់រង្គាល** ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ - ទាក់ទងទៅនឹងការប្រព្រឹត្តបែបរើសអើងនៃការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់ទ្រង់ទ្រាយធំនៃជនជាតិចាមនៅតាមមន្ទីរសន្តិសុខ ដោយមានចេតនាបំផ្លាញរូបរាងរបស់ជាតិពន្ធ និងក្រុមសាសនា បែបដូច្នោះ[113]
- **ការដាក់ក្នុងមន្ទីរឃុំឃាំង៖** ទាក់ទងទៅនឹងការដាក់ក្នុងមន្ទីរឃុំឃាំងតាមទំនើងចិត្តនៅតាមមន្ទីរសន្តិសុខដោយមិនមានដំណើរការច្បាប់ត្រឹមត្រូវ[114]
- **ការធ្វើទារុណកម្ម៖** ទាក់ទងទៅនឹងការឈឺចាប់និងទុក្ខវេទនាធ្ងន់ធ្ងរ ដែលបណ្តាលមកពីការធ្វើបាបផ្នែករាងកាយ និងស្មារតីនៅអំឡុងពេលឃុំខ្លួន[115]
- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ៖** ទាក់ទងទៅនឹងការកំណត់គោលដៅបែបរើសអើងលើជនជាតិចាមក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនពីភូមិភាគបូព៌ា ទៅកាន់ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)[116]

---

[110] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៦.៤.៣.១.២។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VIII(ខ)(៥)(ខ)។
[111] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.៤។
[112] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣២២៨។
[113] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.១០.១, ១៣.២.១០.២, ១៣.២.១០.១០។
[114] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.១០.៣។
[115] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.១០.៤។
[116] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.១០.៥។

- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា៖** ទាក់ទងទៅនឹងការគាបសង្កត់បែបរើសអើងលើវប្បធម៌ ប្រពៃណី ភាសា និងសាសនាចាមនៅក្នុងភូមិភាគបូព៌ា និងបន្ទាប់ពីបំបែកពួកគេទៅកាន់ភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)[117]

- **ការផ្លាស់ទីលំនៅដោយបង្ខំ** ដែលជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"៖ ទាក់ទងទៅនឹងការបំបែកសហគមន៍ចាមដោយបង្ខំពីភូមិភាគបូព៌ា[118]។

អ.វ.ត.ក. បានពិនិត្យជាពិសេសលើការធ្វើបាបជនជាតិចាមនៅក្នុងរឿងក្តីខាងក្រោមនេះ៖

- **សំណុំរឿង ០០២/០២៖** ទាក់ទងទៅនឹងគោលនយោបាយទូទាំងប្រទេស ដូចដែលបានអនុវត្តមួយចំនួននៅ**មន្ទីរសន្តិសុខភូមិទ្រា មន្ទីរសន្តិសុខវត្តអូរត្រកួន** និងក្នុងអំឡុងពេល**ដំណាក់កាលទី២**[119]

- **សំណុំរឿង ០០៤/០២៖** ទាក់ទងទៅនឹងការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍លើជនជាតិចាមនៅ**ខេត្តកំពង់ចាម**[120]។

ភ័ស្តុតាងនៃការដាក់ក្នុងមន្ទីរឃុំឃាំង និងការសម្លាប់ជនជាតិចាមនៅ**មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខស្វាយជ្រុំ** និង **មន្ទីរសន្តិសុខវត្តសម្តេច** ត្រូវបានពិនិត្យនៅក្នុងសំណុំរឿង ០០៤[121]។

### ១.២.៣.៣.៤. ការធ្វើបាបលើជនជាតិវៀតណាម

*"ភ័ស្តុតាងចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញគ្រប់គ្រាន់ថា ជនជាតិវៀតណាមទាំងអស់ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាត្រូវបានកំណត់គោលដៅជាក់លាក់សម្រាប់ការបំផ្លាញ [...]។ ចេតនាក្នុងការបំផ្លាញនោះ ប្រសិនបើជោគជ័យ នឹងបណ្តាលទៅជាការលុបបំបាត់ឱ្យផុតពូជនៃជនជាតិវៀតណាមទាំងអស់ពីកម្ពុជា"* អង្គជំនុំជម្រះតុលាការកំពូល[122]

ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋរើសអើងប្រឆាំងនឹងជនជាតិវៀតណាម ដោយបានកំណត់គោលដៅយ៉ាងទូលំទូលាយដើម្បីធ្វើបាបពួកគេនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ គោលបំណងគោលនយោបាយនេះ ដែលបានបង្កើតឡើងក្នុងពេលនៃរបបនោះ គឺដើម្បីការពារប្រទេសពីសំណាក់ខ្មាំង - ដោយសារជនជាតិវៀតណាមត្រូវបានចាត់ទុកថាជាខ្មាំង - និងដើម្បីកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែររួបរួមគ្នាមួយ[123]។"

ក្រុមជនជាតិវៀតណាមគឺជាក្រុមជាតិពន្ធ ជាតិសាសន៍ និងពូជសាសន៍ដាច់ដោយឡែកនៅក្នុងប្រទេសកម្ពុជា ដែលសមាជិករបស់ខ្លួនមានភាសា វប្បធម៌ និងកេរដំណែលរួមគ្នា[124]។ ជាតិពន្ធវៀតណាមជាញឹកញាប់ត្រូវបានកំណត់អត្តសញ្ញាណតាមរយៈការនិយាយស្តី លក្ខណៈរូបរាងរបស់ពួកគេ ឬគ្រួសារ ហើយ ប.ក.ក. ពិចារណាជាតិពន្ធវៀតណាមយកខ្សែខាងម្តាយ[125]។

---

117 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.១០.៦។

118 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.២.១០.៨។

119 ការរកឃើញផ្នែកអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះការធ្វើបាបជនជាតិចាម ត្រូវបានដាក់ជាក្រុមតាមខ្លឹមសារជាជាងតាមទីតាំងឧក្រិដ្ឋកម្ម។ ចំពោះវិសាលភាពពិតប្រាកដនៃការពិនិត្យរបស់អង្គជំនុំជម្រះ សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣១៨៤។

120 សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 ផ្នែក III(ខ) ១.១៦។ សំណុំរឿង ០០៤/០២, ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ផ្នែក ៦.៤.២។

121 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 កថាខណ្ឌ ៤៨៩, ៧៧៨, ៨៥៧-៨៥៨។

122 សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ១៦៣៥។

123 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣.៥, ១៦.៤.៣.៥, ១៦.៤.៣.២។

124 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣.៦.១។

125 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣.៦.២-១៣.៣.៦.៣។

ជំហររបស់ ប.ក.ក. ចំពោះជនជាតិវៀតណាមផ្អែកលើទស្សនៈរបស់ខ្លួនស្ដីពីកំហឹងយូរអង្វែងរវាងជនជាតិខ្មែរនិងជនជាតិវៀតណាម និងបានសម្រេចថា វៀតណាម គឺជា "សត្រូវស្រួចស្រាវ"យូរអង្វែងរបស់កម្ពុជាតាំងពីឆ្នាំ១៩៧១។ ការបែកបាក់ទំនាក់ទំនងរវាងប្រទេស និងការធ្វើបាបលើជនជាតិវៀតណាមបានកើនឡើងជាមួយនឹងស្ថានភាពយោធា[126]។ ការប៉ះទង្គិចប្រដាប់អាវុធបានចាប់កើតមានឡើងនៅតាមខាងក្រៅព្រំដែនគោក និងព្រំដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យតាំងពីដើមខែឧសភា ឆ្នាំ១៩៧៥ ហើយការវាយប្រយុទ្ធគ្នាបានរីករាលដាលយ៉ាងឆាប់រហ័សដល់បណ្ដាកោះ និងតាមព្រំដែនគោក ក្នុងអំឡុងរយៈពេលពីរឆ្នាំបន្ទាប់មក[127]។

ជនជាតិវៀតណាមត្រូវបានកំណត់សម្រាប់ការនិរទេសរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងខែមេសា ឆ្នាំ១៩៧៧ ក្នុងការកម្ទេចពួកគេជាក្រុមនាពេលក្រោយមក ហើយសមាជិកភាពរបស់ខ្លួនត្រូវស្ថិតក្រោមការរើសអើងជាលក្ខណៈប្រព័ន្ធនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ក្នុងនាមជាសត្រូវដ៏គ្រោះថ្នាក់បំផុតរបស់ប្រទេស[128]។

នៅក្នុងការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ អ.វ.ត.ក. បានពិនិត្យអង្គហេតុទាក់ទងទៅនឹងការធ្វើបាបទូទាំងប្រទេសលើជនជាតិវៀតណាម[129]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ខ្មែរក្រហមបានប្រព្រឹត្ត**អំពើប្រល័យពូជសាសន៍** តាមរយៈការសម្លាប់សមាជិកក្រុមជាតិពន្ធុ ជាតិសាសន៍ និងពូជសាសន៍វៀតណាមនៅក្នុងប្រទេសកម្ពុជា និងមានចេតនាបំផ្លាញពួកគេជាក្រុម[130]។

តាមរយៈការធ្វើបាបជនជាតិវៀតណាម ខ្មែរក្រហមក៏បានប្រព្រឹត្ត**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ**ខាងក្រោមនេះផងដែរ[131]៖

- **ការធ្វើមនុស្សឃាត និង ការសម្លាប់រង្គាល**[132]៖ ទាក់ទងទៅនឹងការសម្លាប់ជាប្រព័ន្ធនូវជនទាំងឡាយណាដែលមានអត្តសញ្ញាណវៀតណាមពិតប្រាកដ ឬតាមការសន្មត
- **ការនិរទេស៖** ទាក់ទងទៅនឹងការបណ្ដេញជនជាតិវៀតណាមចេញពីទឹកដីកម្ពុជារវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងខែមេសា ឆ្នាំ១៩៧៧[133]
- **ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍៖** ទាក់ទងទៅនឹងការប្រព្រឹត្តបែបរើសអើងចំពោះជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា[134]

**ឧក្រិដ្ឋកម្មសង្គ្រាម**ខាងក្រោមនេះត្រូវបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ ស-២១ ប្រឆាំងនឹងអ្នកទោសជនជាតិវៀតណាម ដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖[135]

- **ការឃុំខ្លួនដោយខុសច្បាប់**

[126] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣.៥.២។
[127] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២៨២-២៨៤។
[128] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣.៥.២។
[129] សម្រាប់វិសាលភាពនៃការពិនិត្យរបស់អង្គជំនុំជម្រះ សូមមើល សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៣៦០។
[130] សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ជ)។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣។
[131] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣.១០។
[132] សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ខ)(២)។
[133] សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ឃ)។
[134] សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ច)(៤)។
[135] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ផ្នែក ២.៦.៣។ សំណុំរឿង ០០២/០២ សាលក្រម ឯកសារ E465 ផ្នែក ១២.២.២៤.២។

- **ការធ្វើទារុណកម្ម ការប្រព្រឹត្តដោយអមនុស្សធម៌ និង ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព**

- **ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់ និង**

- **ការធ្វើមនុស្សឃាតដោយចេតនា**

នៅក្នុងរឿងក្ដីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងការចោទប្រកាន់ ឬបញ្ចប់រឿងក្ដី សហចៅក្រមស៊ើបអង្កេតក៏បានពិនិត្យអង្គហេតុទាក់ទងទៅនឹងការកំណត់គោលដៅ និងការធ្វើបាបលើជនជាតិវៀតណាម និងអ្នកទាំងឡាយណាដែលខ្មែរក្រហមសន្មតថាមានទំនាក់ទំនងជាមួយនឹងពួកគេផងដែរ។ អង្គហេតុទាំងអស់នេះត្រូវបានពិភាក្សានៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿងខាងក្រោម ៖[136]

- **សំណុំរឿង ០០៣៖** ទាក់ទងទៅនឹងភ័ស្ដុតាងអំពីការចោទប្រកាន់លើការធ្វើបាបអ្នកនេសាទជនជាតិវៀតណាម និងជនស៊ីវិលវៀតណាមនៅតាម**បណ្ដាកោះ** និង**ដែនទឹក** និងក្នុងបរិបទនៃ**ជម្លោះប្រដាប់អាវុធ**ជាមួយវៀតណាម និង**ការបោសសម្អាត** និងនៅតាម**មន្ទីរសន្ដិសុខ** និង**ទីតាំងសម្លាប់មនុស្ស**[137]

- **សំណុំរឿង ០០៤/០១៖** ទាក់ទងទៅនឹងការឃុំខ្លួន "ពលរដ្ឋ" វៀតណាមនៅ**មន្ទីរសន្ដិសុខភ្នំទ្រយោង** និងអ្នកទាំងឡាយដែលខ្មែរក្រហមសន្មតថាមានចំណងគ្រួសារវៀតណាមនៅ**ការដ្ឋានប្រឡាយស្ពានស្រែង**[138]។

### ១.២.៣.៣.៥. ការធ្វើបាបលើក្រុមផ្សេងទៀត

#### ១.២.៣.៣.៥.១ . ខ្មែរក្រោម

ខ្មែរក្រោមមិនត្រូវបានកំណត់យ៉ាងជាក់លាក់ថាជាក្រុមដែលត្រូវបានកំណត់គោលដៅនោះទេ នៅក្នុងសំណុំរឿង ០០១ ឬសំណុំរឿង ០០២[139]។ ម្យ៉ាងវិញទៀត នៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬបញ្ចប់រឿងក្ដី សហចៅក្រមស៊ើបអង្កេតបានពិនិត្យអង្គហេតុនានាទាក់ទងទៅនឹងការកំណត់គោលដៅ និងការធ្វើបាបលើខ្មែរក្រោម។ អង្គហេតុទាំងអស់នេះត្រូវបានពិភាក្សានៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿងខាងក្រោម៖[140]

- **សំណុំរឿង ០០៣៖** ទាក់ទងទៅនឹងការជាប់ទាក់ទងរបស់ពួកគេទៅនឹងប្រទេសវៀតណាម ឬជនជាតិវៀតណាម ការបាត់ខ្លួនប្រជាជនខ្មែរក្រោមពី**ការដ្ឋានកងកេង** និង**បិតត្រាង** និងការកំណត់គោលដៅលើក្រុមនៅ**មន្ទីរសន្ដិសុខទឹកសាប**[141]។

---

[136] មានតែទីតាំងដែលត្រូវបានពិចារណានៅដំណាក់កាលដំកាដំណោះស្រាយប៉ុណ្ណោះ ត្រូវបានរៀបរាប់នៅទីនេះ។ អង្គហេតុទាក់ទងនឹងទីតាំងដែលត្រូវបានដកចេញពីការស៊ើបអង្កេត ឬកាត់វិសាលភាពដោយសហចៅក្រមស៊ើបអង្កេត ត្រូវបានលុបចោល។ សម្រាប់ព័ត៌មានបន្ថែមអំពីទីតាំងទាំងនេះ សូមមើលដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងប្រវត្តិនីតិវិធីនៃដីកាដំណោះស្រាយនីមួយៗ។

[137] សូមមើលជាទូទៅ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ឯកសារ D266។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D267។

[138] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 ផ្នែក ៤.៦។

[139] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៨១៦។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ៦៧៣-៦៧៤។

[140] មានតែទីតាំងដែលត្រូវបានពិចារណានៅក្នុងដំណាក់កាលដីកាដំណោះស្រាយប៉ុណ្ណោះត្រូវបានរៀបរាប់នៅទីនេះ។ អង្គហេតុនានាទាក់ទងនឹងទីតាំងដែលត្រូវបានដកចេញពីការស៊ើបអង្កេត ឬកាត់បន្ថយពីវិសាលភាពនៃការស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេត ត្រូវបានលុបចេញ។ សម្រាប់ព័ត៌មានបន្ថែមលើចំណុចទាំងអស់នេះ សូមមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងប្រវត្តិនីតិវិធីនៃដីកាដំណោះស្រាយនៃរឿងក្ដីនីមួយៗ។

[141] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ ១៩៦, ៣៥២, ៤១៩។

- **សំណុំរឿង ០០៤៖** ទាក់ទងទៅនឹងការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍លើប្រជាជនខ្មែរក្រោមតាមរយៈការសម្លាប់នៅ៖[142]
    - **ភូមិភាគនិរតី តំបន់ ១៣៖** មន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្សនៅភូមិព្រាល ទីតាំងសម្លាប់មនុស្សវត្តអង្គញ ទីតាំងសម្លាប់មនុស្សនៅភូមិព្រៃស្តែង ទីតាំងសម្លាប់មនុស្សវត្តអង្គសិរីមាលី ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងភូមិសោម
    - **ភូមិភាគពាយ័ព្យ តំបន់ ១៖** ការដ្ឋានទំនប់កង្ហត ការដ្ឋានរោងចក្រស្ករសកំពង់កុល
    - **ភូមិភាគពាយ័ព្យ តំបន់ ២៖** មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ
    - **ភូមិភាគពាយ័ព្យ តំបន់ ៤៖** ឃុំកំពង់ព្រៀង (រួមទាំងមន្ទីរសន្តិសុខវត្តពោធិ៍លង្ការ ភូមិកាច់រទេះ ភូមិថ្មី និង ភូមិសាលាត្រាវ) ឃុំរឹងកេសី
- **សំណុំរឿង ០០៤/០១៖** ទាក់ទងទៅនឹងការចោទប្រកាន់អំពីការឃុំខ្លួនប្រជាជនខ្មែរក្រោមនៅ**វត្តអង្គសិរីមាលី** និងការចោទប្រកាន់អំពីការសម្លាប់នៅ**ទីតាំងសម្លាប់មនុស្សព្រៃសុខុន**[143]។

### ១.២.៣.៣.៥.២. ជនជាតិថៃ

ជនជាតិថៃមិនត្រូវបានកំណត់អត្តសញ្ញាណជាក់លាក់ថាជាក្រុមដែលត្រូវបានកំណត់គោលដៅនោះទេនៅក្នុងសំណុំរឿង ០៧ ឬសំណុំរឿង ០០២។

ក្នុង**សំណុំរឿង ០០២/០២** អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យភ័ស្តុតាងនៃការរឹបអូសយកទូកថៃ និងការចាប់និងសម្លាប់អ្នកនេសាទជនជាតិថៃ នៅក្នុងបរិបទដ៏ទូលំទូលាយនៃការចាប់ទូកនេសាទវៀតណាមនៅឯសមុទ្រដោយកងទ័ពជើងទឹក (កងពល ១៦៥) របស់របបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះក៏បានពិនិត្យផងដែរលើការកំណត់អត្តសញ្ញាណរបស់ ប.ក.ក. លើជនជាតិថៃថាជាខ្មាំង[144]។ ប៉ុន្តែ អង្គជំនុំជម្រះមិនបានធ្វើការសន្និដ្ឋាន ឬធ្វើការដាក់ពិរុទ្ធភាពជាក់លាក់ទាក់ទងនឹងជនជាតិថៃនោះទេ។

ក្នុង**សំណុំរឿង ០០៣** សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដាក់បញ្ចូលយ៉ាងជាក់លាក់នៃអ្នកដែលមានជាតិពន្ធថៃ ឬសញ្ជាតិថៃទៅក្នុងគោលនយោបាយកំណត់គោលដៅរបស់ ប.ក.ក. និងបានស៊ើបអង្កេតលើអង្គហេតុនានាទាក់ទងទៅនឹងការចោទប្រកាន់លើកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើមនុស្សឃាតគិតទុកជាមុនលើជនជាតិថៃ[145]។ សហចៅក្រមស៊ើបអង្កេតជាតិក៏បានពិភាក្សាលើភ័ស្តុតាងទាក់ទងទៅនឹងការរឹបអូសទូកនេសាទ និងការធ្វើបាបលើជនជាតិថៃនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនផងដែរ[146]។ រឿងក្តីមិនបានបន្តទៅជំនុំជម្រះទេ ហើយត្រូវបានបញ្ចប់នៅដំណាក់កាលបុរេជំនុំជម្រះ។

ការចោទប្រកាន់អំពីការកំណត់គោលដៅលើជនជាតិថៃមិនមាននៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. ទេ។

---

[142] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381 ផ្នែក (៤) ២.១-២.២។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ផ្នែក ៥.២.១, ៥.៥។

[143] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ២៤៩។

[144] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៣.៣.៩.១, ១៦.៣។

[145] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ផ្នែក ៥.២.៣, ៥.៤, ១២ (បទចោទ ២, ៣, ៤)។

[146] សូមមើល ជាទូទៅ សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។

### ១.២.៣.៣.៥.៣. ក្រុមផ្សេងទៀត

ការធ្វើទុក្ខបុកម្នេញដោយ ប.ក.ក. ចំពោះខ្មាំង ដែលមិនត្រូវបានកំណត់ប្រភេទនៅក្រោមគោលនយោបាយខាងលើ គឺជាលក្ខណៈសំខាន់នៃរឿងក្តីទាំងអស់នៅចំពោះមុខ អ.វ.ត.ក.។ ប្រភេទទាំងនោះរួមមាន៖

- ប្រជាជនថ្មី (ឬប្រជាជន ១៧ មេសា) និងបញ្ញាវន្ត
- អ្នកត្រឡប់ពីបរទេស និងជនបរទេស
- "ភ្នាក់ងារ" សេ.អ៊ី.អា, កា.ហ្សេ.បេ និង វៀតណាម (រួមទាំងអតីតទាហានធីវគី សមាជិក FULRO និង ជាតិពន្ធចារ៉ាយ)
- អ្នកប្រឆាំងបដិវត្តន៍ អ្នកសក្តិភូមិ អ្នកបន្ទះបង្អាប់បដិវត្តន៍ និងជនក្បត់បដិវត្តន៍ អ្នករិះគន់បក្ស និងអ្នកទាំងឡាយណាដែលគេសង្ស័យថាជាខ្មាំង ឬត្រូវបានគេឆ្លើយដាក់ថាចូលរួមជាមួយខ្មាំង។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ទោះបីជាក្រុមទាំងនេះមិនមានទម្រង់ស្របគ្នាតែមួយក៏ពួកគេត្រូវបានកំណត់យ៉ាងច្បាស់លាស់ថាជា "ខ្មាំងនយោបាយ" និងអាចត្រូវបានចាត់ទុកតាមច្បាប់ថាជាក្រុមគោលដៅ[147]។

សម្រាប់ព័ត៌មានបន្ថែមអំពីសេចក្តីពិចារណារបស់ អ.វ.ត.ក. ទាក់ទងនឹងក្រុមដែលត្រូវបានកំណត់គោលដៅ សូមមើលការរកឃើញផ្នែកអង្គហេតុ និងអង្គច្បាប់នៅក្នុងរឿងក្តីនីមួយៗ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

## ១.២.៤. បទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍

*"ប.ក.ក. បានព្យាយាមយ៉ាងសកម្មក្នុងការផ្លាស់ប្តូររបៀបរបបប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍ ដោយប្រព័ន្ធដែលត្រូវបានអនុវត្តឡើងដោយអាជ្ញាធរមូលដ្ឋានយោងទៅតាមការណែនាំពីគណៈកម្មាធិការមជ្ឈិមបក្សក្នុងការផ្សំផ្គុំតាមទំនើងចិត្ត ស្ទើរតែមិនមានមតិយោបល់ពីសំណាក់បុគ្គលជាគូស្រករឬពីក្រុមគ្រួសារឡើយ"* អង្គជំនុំជម្រះសាលាដំបូង[148]

ប.ក.ក. បានអនុវត្តគោលនយោបាយឧក្រិដ្ឋក្នុងការរៀបចំបុរស និងស្ត្រីឱ្យរៀបការ និងរួមដំណេកដោយបង្ខំ។ គោលបំណងនៃគោលនយោបាយនេះគឺដើម្បីបង្កើនចំនួនប្រជាជនរបស់ប្រទេស ដើម្បីឱ្យប្រជាជនអាចកសាងប្រទេស ការពារប្រទេសពីសំណាក់ខ្មាំង - ជាពិសេស វៀតណាម ដែលមានចំនួនប្រជាជននិងយោធាច្រើនជាងកម្ពុជាប្រជាធិបតេយ្យខ្លាំង - និងដើម្បីប្រែក្លាយសង្គមឱ្យបានយ៉ាងរហ័ស[149]។

គូស្រករត្រូវបានផ្សំផ្គុំដោយកម្មាភិបាល ប.ក.ក. និងត្រូវបានឯកភាពពីថ្នាក់ស្រុក ទោះបីជាក្នុងករណីខ្លះ គូស្រករដែលបានស្នើសុំរៀបការ ទទួលបានការយល់ព្រមក្តី។[150] ឪពុកម្តាយរបស់គូស្រករជាផ្លូវតាមិនបានចូលរួមក្នុងការសម្រេច ឬពិធីការរៀបអាពាហ៍ពិពាហ៍នោះទេ[151]។ គូស្រករជាច្រើនដែលត្រូវបានផ្គូផ្គងដោយកម្មាភិបាល មិនដែលបានជួបគ្នាមុនថ្ងៃរៀបការរបស់ខ្លួនឡើយ ហើយក្នុងករណីភាគច្រើន មិន

---

[147] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ផ្នែក ៤(ង)។ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក ៤(ឃ)(៤)។ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ង)(២)(ខ)។

[148] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០៦៥។

[149] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០៦៦។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ឆ)(៣)។

[150] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៦០៤-៣៦០៨ ជើងទំព័រ ១២០៥១។

[151] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៦១៣, ៣៦៤០។

មានសិទ្ធិបដិសេធទេ[152]។ ពិធីរៀបអាពាហ៍ពិពាហ៍មានទំហំខុសៗគ្នាចាប់ពីមួយគូ ទៅ ៧០-៨០ គូ[153]។ ក្នុងអំឡុងពីធីរៀបអាពាហ៍ពិពាហ៍របស់ខ្លួន គូស្រករជាញឹកញាប់ត្រូវបានគេណែនាំថា ពួកគេត្រូវប្ដេជ្ញាបង្កើតកូនជូនអង្គការ ដើម្បីបង្កើនចំនួនប្រជាជន[154]។ ក្រោយពិធីចប់ គូស្រករត្រូវគេបញ្ជូនទៅកាន់កូនខ្ទមមួយ ជាកន្លែងដែលពួកគេត្រូវបានគេរំពឹងថារួមដំណេកអាពាហ៍ពិពាហ៍របស់ខ្លួន ជាលក្ខខណ្ឌតម្រូវមួយដែលជាញឹកញាប់ត្រូវបានអនុវត្តដោយមានឈ្លបពួននៅខាងក្រោមខ្ទម ដើម្បីតាមដានថាតើគូស្រករនោះបានរួមដំណេកក្នុងអាពាហ៍ពិពាហ៍ឬទេ[155]។ ទំនាក់ទំនងប្រុសនិងស្រី មុន ឬក្រៅ បរិបទអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាជា "កំហុសសីលធម៌" និងអាចត្រូវបានដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ[156]។

តាមរយៈការបង្ខំគូស្រករឱ្យរៀបការ និងបង្ខំឱ្យពួកគេរួមដំណេកក្នុងអាពាហ៍ពិពាហ៍របស់ខ្លួន អ.វ.ត.ក. បានរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិខាងក្រោមត្រូវបានប្រព្រឹត្តឡើង៖

- **ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ** ដែលជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"៖ ទាក់ទងទៅនឹងការផ្សំផ្គុំដោយបង្ខំ ដែលមិនឆ្លុះបញ្ចាំងពីប្រពៃណីនៃការរៀបអាពាហ៍ពិពាហ៍របស់ខ្មែរ ត្រូវបានធ្វើឡើងនៅក្នុងបរិយាកាសនៃភាពភ័យខ្លាចដ៏រីករាលដាល និងមិនមានការព្រមព្រៀងពិតប្រាកដ[157]
- **ការរំលោភសេពសន្ថវៈ** ដែលជា "អំពើអមនុស្សធម៌ផ្សេងទៀត"៖ ទាក់ទងទៅនឹងការរួមដំណេកដោយបង្ខំរវាងគូស្រករដែល"រៀបការ"ថ្មីៗ ក្រោមការគំរាមកំហែងសម្លាប់ ឬអប់រំកសាង និងដោយគ្មានការព្រមព្រៀងពិតប្រាកដ[158]។

ទាំងស្ត្រី និងទាំងបុរសបានទទួលរងការឈឺចាប់ផ្នែករាងកាយ និងផ្លូវចិត្ត ដែលបណ្ដាលមកពីការដែលត្រូវបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ និងការរួមដំណេកក្នុងអាពាហ៍ពិពាហ៍របស់ខ្លួន ហើយការណ៍នេះបង្កើតបានជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរលើសេចក្ដីថ្លៃថ្នូររបស់មនុស្ស[159]។

*"ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រព្រឹត្តឡើងដើម្បីដាក់ការគ្រប់គ្រងលើបុរស និងស្ត្រី"* អង្គជំនុំជម្រះតុលាការកំពូល[160]

អ.វ.ត.ក. បានពិនិត្យជាពិសេសលើបទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍នៅក្នុងសំណុំរឿងខាងក្រោមនេះ៖

- **សំណុំរឿង ០០២/០២៖** ទាក់ទងទៅនឹងការអនុវត្តគោលនយោបាយទូទាំងប្រទេស[161] រួមបញ្ចូលទាំងសហករណ៍ត្រាំកក់[162] ការដ្ឋានទំនប់ត្រពាំងថ្ម[163] និងការដ្ឋានទំនប់ ១ មករា[164]

---

152 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៦១៥, ៣៥១៩, ៣៦២៣។
153 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៦៣១-៣៦៣២។
154 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៥៥៦។
155 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៦៤១, ៣៦៤៤ ជើងទំព័រ ១២១៧៦។
156 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៥៦៣។
157 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៤.៤.១.។
158 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៤.៤.២។
159 សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ផ្នែក VII(ឆ)(៣)។
160 សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ១២១៣។
161 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៤.៣.១០។
162 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៤.៣.១១.១។
163 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៤.៣.១១.២។
164 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ផ្នែក ១៤.៣.១១.៣។

- **សំណុំរឿង ០០៣៖** ទាក់ទងទៅនឹងការចោទប្រកាន់អំពីការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំនៅ **កំពង់សោម** (ក្រុងព្រះសីហនុ)[165]
- **សំណុំរឿង ០០៤៖** ទាក់ទងទៅនឹងការចោទប្រកាន់អំពីការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំនៅ **ស្រុក ១ និង ស្រុក ៤ នៅភូមិភាគពាយ័ព្យ**[166]
- **សំណុំរឿង ០០៤/០២៖** ទាក់ទងទៅនឹងការចោទប្រកាន់អំពីការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់ ៤១ នៃភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)[167]

## ១.៣. ការដួលរលំនៃរបបខ្មែរក្រហម

នៅចុងខែធ្នូ ឆ្នាំ១៩៧៨ កងទ័ពវៀតណាមបានចាប់ផ្តើមការវាយប្រហារទ្រង់ទ្រាយធំប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ[168]។ នៅដើមខែមករា ឆ្នាំ១៩៧៩ នួន ជា បានបញ្ជា ឌុច ឱ្យយកអ្នកទោសទាំងអស់ដែលនៅសល់នៅមន្ទីរ ស-២១ ទៅសម្លាប់ចោល[169]។ នៅថ្ងៃទី៦ ឬប្រហែលជាថ្ងៃនោះ ក្នុងខែមករា ឆ្នាំ១៩៧៩ ឌុច ត្រូវបានកោះហៅឱ្យទៅចូលរួមការប្រជុំមួយដឹកនាំដោយ ខៀវ សំផន ដែលបានប្រាប់កម្មាភិបាលដែលប្រមូលផ្តុំគ្នាថា ពួកគេមិនគួរភ័យស្លន់ស្លោនោះទេ ហើយគួរតែបន្តធ្វើការងារធម្មតា ដោយសារតែកងទ័ពបដិវត្តន៍កម្ពុជាបានគ្រប់គ្រងស្ថានការណ៍បានហើយ[170]។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ កងកម្លាំងវៀតណាម និង KNUFNS បានចូលដល់ទីក្រុងភ្នំពេញ និងបានគ្រប់គ្រងទាំងស្រុងលើមួយផ្នែកធំនៃទឹកដីប្រទេសកម្ពុជា[171] ដោយបានទម្លាក់ខ្មែរក្រហមចេញពីអំណាច និងបង្ខំពួកគេឱ្យដកថយក្រោយពេលកាន់អំណាចបានបីឆ្នាំ ប្រាំបីខែ និង ២០ថ្ងៃ[172]។

ទោះបីជាការដួលរលំនៃរបបនេះកំណត់ការបញ្ចប់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ក្តី ក៏ភ័ស្តុតាងនៃព្រឹត្តិការណ៍ក្រោយៗមកទៀត ត្រូវបានពិនិត្យដោយ អ.វ.ត.ក. ទាក់ទងទៅនឹងបញ្ហាផ្នែកច្បាប់ និងផ្នែកនីតិវិធី ដូចជា *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ការលើកលែងទោស ការអនុគ្រោះទោស យុត្តាធិការលើរូបបុគ្គល និងការកាត់ទោស។ បញ្ហាទាំងអស់នេះត្រូវបានពិភាក្សានៅក្នុងជំពូក ៥.២.៣.។

គួរកត់សម្គាល់ថា ក្រោយដួលរលំរបបខ្មែរក្រហមក្នុងខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងក្រោមឈ្មោះ សាធារណរដ្ឋប្រជាមានិតកម្ពុជា។ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតតុលាការប្រជាជនបដិវត្តន៍ក្នុងឆ្នាំ១៩៧៩ ដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុល ពត និង អៀង សារី ត្រូវបានកាត់ទោស និង

---

165 សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ផ្នែក ៥.១១។ សហចៅក្រមស៊ើបអង្កេតជាតិបានពិនិត្យអង្គហេតុពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ជាទូទៅ នៅទូទាំងប្រទេសនៅក្នុងដីកាសម្រេចលើកលែងចោទប្រកាន់របស់ខ្លួន។ សូមមើល សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។

166 សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381 ផ្នែក ៤(២.១.៣), ៤(២.២.២៦)។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267 ផ្នែក ៥.៥.៧។

167 សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 ផ្នែក III (ខ)(១.១៥) សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ផ្នែក ៦.៣.៤.៤។

168 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៨០។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២៩៣។

169 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២៥៥៥។

170 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២៥៥៧។

171 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២៥៥៨។ សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៨០។

172 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២៩៣។

ផ្តន្ទាទោសពីបទប្រល័យពូជសាសន៍ ហើយត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខ[173]។ អ.វ.ត.ក. បានសម្រេចថា កិច្ចដំណើរការនីតិវិធីរបស់តុលាការប្រជាជនបដិវត្តន៍ មានភាពខ្វះខាតក្នុងចំណុចជាច្រើន ហើយមិនត្រូវបានធ្វើឡើងដោយឯករាជ្យ ឥតលម្អៀង ឬស្របតាមដំណើរការត្រឹមត្រូវនៃច្បាប់ឡើយ[174]។

របបសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានជំនួសជាបន្តបន្ទាប់ដោយរបប រដ្ឋកម្ពុជា (១៩៨៩-១៩៩២) អាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) (១៩៩៣) និងព្រះរាជាណាចក្រកម្ពុជា (១៩៩៣-បច្ចុប្បន្ន)។ ការចរចាបានចាប់ផ្តើមក្នុងឆ្នាំ១៩៩៧ ដើម្បីបង្កើត អ.វ.ត.ក.។ ទាំងនេះត្រូវបានរៀបរាប់នៅក្នុងជំពូកខាងមុខ។

គិតត្រឹមពេលដែល អ.វ.ត.ក. បានចាប់ផ្តើមប្រតិបត្តិការ កម្មាភិបាលជាន់ខ្ពស់ជាច្រើនរបស់ ប.ក.ក. ដែលរួចផុតពីការបោសសម្អាតផ្ទៃក្នុងរវាងឆ្នាំ១៩៧៦-១៩៧៨ (មើលខាងលើ ជំពូក ១.២.៣.២) បានទទួលមរណភាព៖

- **ប៉ុល ពត** (ស្លាប់ក្នុងខែមេសា ឆ្នាំ១៩៩៨)
- **សុន សេន** (ត្រូវបានសម្លាប់ក្នុងឆ្នាំ១៩៩៧ រួមជាមួយនឹងប្រពន្ធរបស់គាត់ឈ្មោះ យន់ យ៉ាត)
- **កែ ពក** (ស្លាប់ក្នុងខែកុម្ភៈ ឆ្នាំ២០០២)
- **ឈិត ជឿន** (ហៅ **តាម៉ុក**) (ស្លាប់ក្នុងខែកក្កដា ឆ្នាំ២០០៦ ខណៈពេលស្ថិតក្រោមការឃុំខ្លួនដោយយោធា)

**អៀង សារី** និងប្រពន្ធរបស់គាត់ **អៀង ធីរិទ្ធ** បានប្រគល់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៦។ **ខៀវ សំផន** និង **នួន ជា** បានប្រគល់ខ្លួនក្នុងខែធ្នូ ឆ្នាំ១៩៩៨។

ការណ៍នេះបានបង្ហាញអំពីការដួលរលំនៃចលនាខ្មែរក្រហម។

---

173 ឯកសារតុលាការប្រជាជនបដិវត្តន៍ត្រូវបានទទួលយកជាភ័ស្តុតាងជាវត្ថុតាងក្នុងឯកសារ E3/2144។

174 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 ផ្នែក III(ឃ)។ សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្ម របស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 ផ្នែក ៤។

## ២. ទិដ្ឋភាពនៃការចរចា ការបង្កើត និងប្រតិបត្តិការរបស់ អ.វ.ត.ក.

ជំពូកនេះផ្តល់នូវទិដ្ឋភាពនៃព្រឹត្តិការណ៍នានាដែលនាំទៅរកការចរចា និងការបង្កើត អ.វ.ត.ក. ការចាប់ផ្តើមប្រតិបត្តិការ និងព្រឹត្តិការណ៍សំខាន់ៗនៃដំណាក់កាលតុលាការ (២០០៧-២០២២)។ អង្គហេតុដែលបង្ហាញផ្តែកលើកំណត់ត្រាផ្លូវការ ដែលអាចរកបានជាសាធារណៈ។ សម្រាប់បរិបទ និងព័ត៌មានលម្អិតបន្ថែមទៀតអំពីការចរចា និងការចាប់ផ្តើមប្រតិបត្តិការ អ.វ.ត.ក. សូមមើលបញ្ជីឯកសារផ្លូវការ និងអត្ថបទនៅក្នុងឧបសម្ព័ន្ធ ១។ មុខងារសេសសល់របស់ អ.វ.ត.ក. និងដំណើរការដែលកើតឡើងមុនការអនុម័តកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាមានពិភាក្សាក្នុងជំពូក ៧។

### ២.១. ប្រវត្តិនៃការចរចា

**ខែកញ្ញា ឆ្នាំ១៩៩៦**

បន្ទាប់ពីប្រគល់ខ្លួនចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា អៀង សារី ត្រូវបានលើកលែងទោសចំពោះឧក្រិដ្ឋកម្មដែលគាត់ត្រូវបានផ្តន្ទាទោសដោយកំបាំងមុខក្នុងឆ្នាំ១៩៧៩ ដោយតុលាការប្រជាជនបដិវត្តន៍ និងត្រូវបានអនុគ្រោះទោសដោយព្រះរាជក្រឹត្យចំពោះការចោទប្រកាន់ក្រោម *ច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់*។

**ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៧**

តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ដាក់របាយការណ៍ស្តីពីបេសកកម្មផ្លូវការរបស់ខ្លួនមកកាន់ប្រទេសកម្ពុជា នៅដើមឆ្នាំ១៩៩៦ ដោយសង្កេតឃើញថា ការលើកលែងទោសចំពោះ អៀង សារី "មិនគួរបដិសេធលទ្ធភាពនៃការបង្កើតគណៈកម្មការស្វែងរកការពិត ដើម្បីបញ្ជាក់អង្គហេតុ និងកំណត់ការទទួលខុសត្រូវ" ចំពោះអំពើឃោរឃៅនៃរបបខ្មែរក្រហមនោះឡើយ។

**ខែមីនា-ខែមេសា ឆ្នាំ១៩៩៧**

ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិអនុម័តសំណើរបស់ UNHRC ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ("UNSG") "សុំឱ្យពិនិត្យសំណើណាមួយរបស់ប្រទេសកម្ពុជាសម្រាប់ជួយដល់ការឆ្លើយតបទៅនឹងការរំលោភធ្ងន់ធ្ងរពីអតីតកាលលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិដែលជាមធ្យោបាយនាំមកនូវការបង្រួបបង្រួមជាតិ ការពង្រឹងប្រជាធិបតេយ្យ និងការដោះស្រាយបញ្ហានៃការទទួលខុសត្រូវជាបុគ្គល"។

**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៧**

សុន សេន និងភរិយារបស់គាត់ យន់ យ៉ាត ត្រូវបានធ្វើឃាត ប្រហែលជាដោយសារតែការបែកបាក់នៅក្នុងក្រុមខ្មែរក្រហម។

**ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧**

នាយករដ្ឋមន្ត្រីទីមួយ និងទីពីររបស់ប្រទេសកម្ពុជាបានផ្ញើរលិខិតរួមគ្នា ទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្នើសុំជំនួយពី អ.ស.ប. និងសហគមន៍អន្តរជាតិដើម្បី "នាំយកមកវិនិច្ឆ័យទោស ជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេលគ្រប់គ្រងដោយខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"។

**ខែកញ្ញា ឆ្នាំ១៩៩៧**

តំណាងពិសេសអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ផ្តល់អនុសាសន៍ទៅកាន់មហាសន្និបាត អ.ស.ប. (“UNGA”) ថា អ្នកជំនាញមួយក្រុមនឹងត្រូវតែងតាំងដើម្បីវាយតម្លៃលក្ខណៈនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ស្ថានភាពនៃភ័ស្តុតាង និងច្បាប់ជាធរមាន និង ផ្តល់ការណែនាំយន្តការសមស្រប ដើម្បីអនុវត្ត។

**ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧**

មហាសន្និបាត អ.ស.ប. អនុម័តអនុសាសន៍របស់តំណាងពិសេស និងស្នើឱ្យអគ្គលេខាធិការ អ.ស.ប. “ពិនិត្យសំណើរបស់អាជ្ញាធរកម្ពុជាសុំជំនួយដើម្បីឆ្លើយតបទៅនឹងការរំលោភធ្ងន់ធ្ងរលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ រួមបញ្ចូលទាំងលទ្ធភាពនៃការតែងតាំង ដោយអគ្គលេខាធិការ នូវអ្នកជំនាញមួយក្រុម ដើម្បីធ្វើការវាយតម្លៃភ័ស្តុតាងដែលមានស្រាប់ និងលើកវិធានការបន្តទៀត ដែលជាមធ្យោបាយនៃការនាំមកនូវការបង្រួបបង្រួមជាតិ ការពង្រឹងប្រជាធិបតេយ្យ និងការដោះស្រាយបញ្ហានៃការទទួលខុសត្រូវជាបុគ្គល”។

**ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨**

ប៉ុល ពត ទទួលមរណភាពក្នុងពេលជាប់ឃុំឃាំងក្នុងផ្ទះតាមបញ្ជា តាម៉ុក។

**ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៨**

អ.ស.ប. ប្រកាសតែងតាំង Sir Ninian Stephen (អូស្ត្រាលី) Rajsoomer Lallah (ម៉ូរីស) និង Steven Ratner (អាមេរិក) ជាក្រុមអ្នកជំនាញ ដើម្បីធ្វើការពិនិត្យបញ្ហានៃការទទួលខុសត្រូវរបស់ខ្មែរក្រហម។

**ខែវិច្ឆិកា ឆ្នាំ១៩៩៨**

ក្រុមអ្នកជំនាញចាប់ផ្តើមបេសកកម្មរបស់ខ្លួនមកកាន់ប្រទេសកម្ពុជា ដោយជួបជាមួយមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា គណៈប្រតិភូការទូត និងមន្ត្រីមកពីអង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដែលចាប់អារម្មណ៍ ហើយចុះពិនិត្យទីតាំងមួយចំនួនដែលពាក់ព័ន្ធនឹងសម័យខ្មែរក្រហម។

**ខែធ្នូ ឆ្នាំ១៩៩៨**

នួន ជា និង ខៀវ សំផន ប្រគល់ខ្លួនជូនរាជរដ្ឋាភិបាលកម្ពុជា។

**ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៩**

ក្រុមអ្នកជំនាញបញ្ជូនរបាយការណ៍របស់ខ្លួនទៅកាន់ UNSG ដោយសន្និដ្ឋានថា៖ ខ្មែរក្រហមបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មផ្សេងៗទៀត ដែលមេដឹកនាំអាចត្រូវបានចោទប្រកាន់ និងបានផ្តល់អនុសាសន៍ឱ្យបង្កើតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិចំពោះកិច្ចមួយ។

**ថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៩**

នាយករដ្ឋមន្ត្រីកម្ពុជាជូនដំណឹង UNSG ថា សេចក្តីសម្រេចណាមួយក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកវិនិច្ឆ័យទោស ត្រូវតែពិចារណាលើតម្រូវការរបស់កម្ពុជាចំពោះសន្តិភាព ការបង្រួបបង្រួម និងការអភិវឌ្ឍន៍សេដ្ឋកិច្ច។

**ថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៩៩**

ឈិត ជឿន ហៅ (ហៅ តាម៉ុក) លេខាភូមិភាគនិរតីរបស់ខ្មែរក្រហម និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក.") ត្រូវបានចាប់ខ្លួន ដែលនាំឱ្យមានរឿងក្តីព្រហ្មទណ្ឌប្តឹងប្រឆាំងនឹងគាត់នៅក្នុងតុលាការយោធាក្រុងភ្នំពេញ។

**ថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩**

រាជរដ្ឋាភិបាលកម្ពុជាជូនដំណឹង UNSG ថា ខ្លួនមានបំណងធ្វើការជំនុំជម្រះក្នុងស្រុកសម្រាប់ តាម៉ុក ប៉ុន្តែខ្លួនទទួលយកជំនួយ និងបច្ចេកទេសបរទេស។

**ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩**

កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ត្រូវបានចាប់ខ្លួន និងត្រូវបានចោទប្រកាន់ដោយតុលាការយោធាចំពោះការរំលោភលើច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់។

## ២.២. ការចរចាចាប់ផ្តើម

**ឆ្នាំ១៩៩៩**

អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនលិខិតឆ្លើយឆ្លងទៅវិញទៅមកជាច្រើនទាក់ទងនឹងសេចក្តីព្រាងមួយច្បាប់ស្តីពីកិច្ចសហការរវាង អ.ស.ប. និង រដ្ឋាភិបាលកម្ពុជា។

**ខែកុម្ភៈ-ខែមីនា ឆ្នាំ២០០០**

អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូនលិខិតឆ្លើយឆ្លងទៅវិញទៅមកជាច្រើន ទាក់ទងនឹងសេចក្តីព្រាងមួយច្បាប់ ស្តីពីកិច្ចសហការរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ដែលក្រោយមកក្លាយជា "កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា"។ កិច្ចពិភាក្សាកើតមានបន្តបន្ទាប់ទៀតទាក់ទងនឹងសមាសភាពអង្គជំនុំជម្រះ វិធានស្តីពីការធ្វើសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ការលើកលែងទោស និងការអនុគ្រោះទោស និងការធានាចំពោះការចាប់ខ្លួន និងការប្រគល់ខ្លួនអ្នកដែលត្រូវចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ។

**ខែមករា ឆ្នាំ២០០១**

រដ្ឋសភាជាតិអនុម័តច្បាប់ អ.វ.ត.ក. នៅថ្ងៃទី២ ខែមករា បន្ទាប់មកព្រឹទ្ធសភាអនុម័តនៅថ្ងៃទី១៥ ខែមករា។

**ខែកក្កដា ឆ្នាំ២០០១**

រដ្ឋសភាជាតិអនុម័តវិសោធនកម្មច្បាប់ អ.វ.ត.ក. ដើម្បីធ្វើច្បាប់នេះឱ្យស្របទៅនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១១ ខែកក្កដា ហើយព្រឹទ្ធសភាអនុម័តនៅថ្ងៃទី២៣ ខែកក្កដា។

**ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១**

សម្តេច នរោត្តម សីហនុ ប្រកាសឱ្យប្រើច្បាប់ អ.វ.ត.ក.។

**ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២**

អ.ស.ប. ដកខ្លួនចេញពីការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយសារគោលជំហរផ្ទុយគ្នាស្តីពីទំនាក់ទំនងរវាងច្បាប់ អ.វ.ត.ក. និងមាត្រាស្តីពីកិច្ចសហការរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា។

**ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២**

មហាសន្និបាត អ.ស.ប. ស្នើសុំ អគ្គលេខាធិការ អ.ស.ប. ឱ្យបន្តការចរចាឡើងវិញជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបញ្ចប់កិច្ចព្រមព្រៀងដែលស្របទៅនឹងបទប្បញ្ញត្តិនៃសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប.។

**ខែមករា ឆ្នាំ២០០៣**

ការចរចាបន្តនៅរាជធានីភ្នំពេញ ហើយបានបញ្ចប់សេចក្តីព្រៀងចុងក្រោយ។

**ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣**

មហាសន្និបាត អ.ស.ប. អនុម័តសេចក្តីព្រាងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាដោយមតិទូទៅ។

**ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣**

អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចុះហត្ថលេខាលើ *"កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ"* ("កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា")។

## ២.៣. ទម្រង់ការផ្លូវច្បាប់នៅតែបន្ត ហើយវិភាគទានហិរញ្ញវត្ថុចាប់ផ្តើមដំណើរការ

**ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣**

អគ្គលេខាធិការ អ.ស.ប. ផ្តល់អនុសាសន៍ថា ជំនួយអន្តរជាតិមកកាន់ អ.វ.ត.ក. ត្រូវតែផ្តល់ហិរញ្ញប្បទានតាមរយៈវិភាគទានដែលវាយតម្លៃដោយអង្គការសហប្រជាជាតិ។

**ថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៣**

មហាសន្និបាត អ.ស.ប. សម្រេចថា ការចំណាយរបស់ អ.ស.ប. សម្រាប់ជំនួយដល់ អ.វ.ត.ក. "ត្រូវយកមកពីវិភាគទានស្ម័គ្រចិត្តពីសហគមន៍អន្តរជាតិ" និង "អំពាវនាវដល់សហគមន៍អន្តរជាតិឱ្យផ្តល់ជំនួយ រួមបញ្ចូលទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបុគ្គលិកមកកាន់អង្គជំនុំជម្រះវិសាមញ្ញ"។

**ថ្ងៃទី៧-១៣ ខែធ្នូ ឆ្នាំ២០០៣**

ក្រុមបច្ចេកទេស អ.ស.ប. ធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញ ដើម្បីរៀបចំផែនការប្រតិបត្តិការបឋម រួមមាន តារាងរចនាសម្ព័ន្ធ បញ្ជីការងារ កាលកំណត់ និងក្របខ័ណ្ឌសំខាន់ៗផ្សេងទៀត។ ក្រុមនេះពិនិត្យលក្ខខណ្ឌតម្រូវផ្នែកបុគ្គលិក ចំណុចសំខាន់ៗទាក់ទងអគារ និងតម្រូវការធនធានផ្សេងៗទៀត។

**ថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤**

រដ្ឋសភាជាតិអនុម័តច្បាប់ស្តីពីការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា។

**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤**

អគ្គលេខាធិការ អ.ស.ប. រាយការណ៍ថា ថវិកាដែលព្យាករណ៍សម្រាប់បីឆ្នាំដំបូងសម្រាប់ភាគីជាតិ និងអន្តរជាតិមានចំនួន ៥៧ លានដុល្លារអាមេរិក។

**ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤**

កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាត្រូវបានផ្តល់សច្ចាប័ន ដោយរាជរដ្ឋាភិបាលកម្ពុជា។

**ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤**

ច្បាប់ អ.វ.ត.ក. ត្រូវបានធ្វើវិសោធនកម្មដើម្បីឆ្លុះបញ្ចាំងអំពីបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា។

**ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៤**

លក្ខខណ្ឌតម្រូវផ្នែកច្បាប់ត្រូវបានបំពេញដើម្បីឱ្យកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាចូលជាធរមាន។

**ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤**

អគ្គលេខាធិការ អ.ស.ប. រាយការណ៍ថា ការជូនដំណឹងទៅវិញទៅមករបស់អង្គការសហប្រជាជាតិនឹងត្រូវបានផ្តល់ជូន "នៅពេលដែលទទួលបានការធានាសម្រាប់រយៈពេលបីឆ្នាំពេញនៃប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាវិភាគទានជាក់ស្តែងសម្រាប់ឆ្នាំដំបូងនៃប្រតិបត្តិការរបស់ខ្លួន"។

**ខែធ្នូ ឆ្នាំ២០០៤**

ក្រុមការងារ អ.ស.ប. ធ្វើការពិភាក្សា និងឯកភាពជាមួយតំណាងរាជរដ្ឋាភិបាលកម្ពុជាស្តីពីថវិកាចំនួន ៥៦ លានដុល្លារអាមេរិក ក៏ដូចជាអគារ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការជំនុំជម្រះ។

**ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៥**

អ.ស.ប. បញ្ជូនការជូនដំណឹងផ្លូវការទៅកាន់រាជរដ្ឋាភិបាលកម្ពុជា ដោយបញ្ជាក់ថា លក្ខខណ្ឌតម្រូវផ្នែកច្បាប់ខាងភាគី អ.ស.ប. ដើម្បីឱ្យកិច្ចព្រមព្រៀងចូលជាធរមាន ត្រូវបានបំពេញរួចហើយ ដោយសារតែ "ទទួលបានការសន្យា និងវិភាគទានគ្រប់គ្រាន់ [...] ដើម្បីផ្តល់មូលនិធិផ្នែកបុគ្គលិកអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ និងប្រតិបត្តិការរបស់ខ្លួនសម្រាប់រយៈពេលដែលអាចទ្រទ្រង់បាន"។

**ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥**

កិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជាចូលជាធរមាន។

## ២.៤. ការចាប់ផ្តើមប្រតិបត្តិការ

**ពាក់កណ្តាលឆ្នាំ២០០៥**

ទីតាំងសម្រាប់អគាររបស់ អ.វ.ត.ក. នៅចោមចៅ ត្រូវបានព្រមព្រៀង។

**ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៥**

អគ្គលេខាធិការ អ.ស.ប. តែងតាំងលោកស្រី Michelle Lee (ចិន) ជាមន្ត្រីសម្របសម្រួល UNAKRT។

**ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៥**

លោក ស៊ាន វិសុទ្ធ ត្រូវបានតែងតាំងជាប្រធានរដ្ឋបាលដោយព្រះរាជក្រឹត្យ ដោយ លោក ក្រាញ់ តូនី ជាប្រធានបម្រុង។ លោកស្រី Michelle Lee ត្រូវបានតែងតាំងជាអនុប្រធានរដ្ឋបាល។

**ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៦**

អគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ប្រគល់អគារ អ.វ.ត.ក. ហើយការងាររៀបចំដំបូងបានចាប់ផ្តើម។

**ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៦**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអនុម័តលើការជ្រើសរើសសហព្រះរាជអាជ្ញា ចៅក្រម និងសហចៅក្រមស៊ើបអង្កេត។

**ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦**

សហព្រះរាជអាជ្ញា ចៅក្រម និងសហចៅក្រមស៊ើបអង្កេតត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ។

**ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦**

សហព្រះរាជអាជ្ញា ចៅក្រម និងសហចៅក្រមស៊ើបអង្កេតបានស្បថចូលកាន់តំណែងជាផ្លូវការក្នុងពិធីមួយនៅព្រះបរមរាជវាំង ក្នុងរាជធានីភ្នំពេញ។

**ថ្ងៃទី៤-៧ ខែកក្កដា ឆ្នាំ២០០៦**

សិក្ខាសាលារៀបចំផែនការយុទ្ធសាស្ត្រ និងអភិវឌ្ឍន៍តុលាការបានរៀបចំឡើង ដើម្បីបង្កើតគណៈកម្មាធិការវិធាន និងនីតិវិធី (RPC) និងគណៈកម្មាធិការរដ្ឋបាលតុលាការ (JAC)។

**ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦**

សហព្រះរាជអាជ្ញាចាប់ផ្តើមតួនាទីរបស់ខ្លួន។

**ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦**

ឈិត ជឿន (ហៅ តាម៉ុក) ទទួលមរណភាព ខណៈពេលកំពុងស្ថិតក្នុងមន្ទីរឃុំឃាំងយោធា។

**ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៦**

សហចៅក្រមស៊ើបអង្កេតចាប់ផ្តើមតួនាទីរបស់ខ្លួន។

**ថ្ងៃទី២០-២៥ ខែវិច្ឆិកា ឆ្នាំ២០០៦**

កិច្ចប្រជុំពេញអង្គដំបូងរបស់ អ.វ.ត.ក. ចាប់ផ្តើម។

**ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧**

កិច្ចប្រជុំពេញអង្គ អ.វ.ត.ក. អនុម័តលើវិធានផ្ទៃក្នុង។

**ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៧**

វិធានផ្ទៃក្នុងចូលជាធរមាន។

## ២.៥. ព្រឹត្តិការណ៍សំខាន់ៗនៃដំណាក់កាលតុលាការ

**ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧**

សហព្រះរាជអាជ្ញាដាក់សំណើជាផ្លូវការចោទប្រកាន់ នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ចំពោះឧក្រិដ្ឋកម្មមួយចំនួន[175]។

**ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧**

[175] សំណុំរឿង ០០១/០០២ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3។

កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ត្រូវបានឃុំខ្លួនដោយដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត ត្រូវបានបញ្ជូនទៅ អ.វ.ត.ក. និងបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេត[176]។

**ថ្ងៃទី១៩ ខែកញ្ញា-ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧**

នួន ជា, ខៀវ សំផន, អៀង សារី និង អៀង ធីរិទ្ធ ត្រូវបានចាប់ខ្លួនតាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត និងត្រូវបានឃុំខ្លួននៅ អ.វ.ត.ក.[177]។

**ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨**

សហចៅក្រមស៊ើបអង្កេតចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម[178]។

**ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩**

សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០១ ប្រឆាំង ឌុច បានចាប់ផ្តើម[179]។

**ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩**

សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំចោទប្រកាន់ មាស មុត, ស៊ូ ម៉េត, យឹម ទិត្យ, អោ អាន និង អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មមួយចំនួន[180]។

**ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩**

សវនាការក្នុងសំណុំរឿង ០០១ បិទបញ្ចប់ដោយសេចក្តីថ្លែងបិទកិច្ចពិភាក្សាដេញដោល[181]។

**ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០**

អង្គជំនុំជម្រះសាលាដំបូងកាត់ទោស ឌុច ឱ្យជាប់ពន្ធនាគារ ៣០ ឆ្នាំ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម[182]។

**ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០**

សហចៅក្រមស៊ើបអង្កេតចោទប្រកាន់ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មតាមច្បាប់ជាតិ[183]
។

**ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១**

---

[176] សំណុំរឿង ០០១ ដីកាបង្គាប់ឱ្យនាំខ្លួន កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ C1។ សំណុំរឿង ០០១ កំណត់ហេតុនៃការចូលខ្លួនដំបូងរបស់ កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ E3/915។

[177] សំណុំរឿង ០០២ ដីកាបង្គាប់ឱ្យនាំខ្លួន នួន ជា ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ C6។ សំណុំរឿង ០០២ ដីកាបង្គាប់ឱ្យនាំខ្លួន អៀង សារី ឯកសារ C12។ សំណុំរឿង ០០២ ដីកាបង្គាប់ឱ្យនាំខ្លួន អៀង ធីរិទ្ធ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C13។ សំណុំរឿង ០០២ ដីកាបង្គាប់ឱ្យនាំខ្លួន ខៀវ សំផន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C24។

[178] សំណុំរឿង ០០១ ដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ D99។

[179] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ឯកសារ E1/5.1។

[180] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

[181] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ E1/77.1។

[182] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188។

[183] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមាននីតិសម្បទាក្នុងការចូលរួមសវនាការ[184]។

**ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១**

សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១ ប្រឆាំងនឹង នួន ជា, ខៀវ សំផន និង អៀង សារី បានចាប់ផ្តើម[185]។

**ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១**

អៀង ធីរិទ្ធ ត្រូវបានដោះលែងក្រោមការត្រួតពិនិត្យរបស់តុលាការ បន្ទាប់ពីត្រូវបានរកឃើញថា មិនមាននីតិសម្បទាក្នុងការចូលរួមសវនាការ[186]។

**ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២**

អង្គជំនុំជម្រះតុលាការកំពូលកាត់ទោស ឌុច ឡើងវិញដាក់ពន្ធនាគារមួយជីវិត[187]។

**ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣**

អៀង សារី ទទួលមរណភាព ដូច្នេះកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ត្រូវបានបញ្ចប់[188]។

**ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣**

ស៊ូ ម៉េត ទទួលមរណភាព ដូច្នេះកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ត្រូវបានបញ្ចប់[189]។

**ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣**

សវនាការក្នុងសំណុំរឿង ០០២/០១ បិទបញ្ចប់ដោយសេចក្តីថ្លែងបិទកិច្ចពិភាក្សាដេញដោល[190]។

**ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤**

អង្គជំនុំជម្រះសាលាដំបូងកាត់ទោស នួន ជា និង ខៀវ សំផន ជាប់ពន្ធនាគារមួយជីវិតពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងសំណុំរឿង ០០២/០១[191]។

**ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥**

សវនាការក្នុងសំណុំរឿង ០០២/០២ ប្រឆាំង នួន ជា និង ខៀវ សំផន បានចាប់ផ្តើម[192]។

**ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥**

---

[184] សំណុំរឿង ០០២ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E138។

[185] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E1/13.1។

[186] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ E138/1/7។

[187] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28។

[188] សំណុំរឿង ០០២ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ឯកសារ E270/1។

[189] សំណុំរឿង ០០៣ ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊ូ ម៉េត ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D86/3។

[190] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ឯកសារ E1/237.1។

[191] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313។

[192] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ឯកសារ E1/247.1។

អៀង ធីរិទ្ធ ទទួលមរណភាពខណៈ ពេលស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ បន្ទាប់ពីត្រូវបានរកឃើញថាមិនមាននីតិសម្បទាក្នុងការចូលរួមសវនាការ ដូច្នេះកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់ត្រូវបានបញ្ចប់[193]។

**ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦**

អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការកាត់ទោសជាប់ពន្ធនាគារមួយជីវិតរបស់ នួន ជា និង ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១[194]។

**ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧**

សវនាការក្នុងសំណុំរឿង ០០២/០២ បញ្ចប់ដោយសេចក្តីថ្លែងបិទកិច្ចពិភាក្សាដេញដោល[195]។

**ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧**

សហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម[196]។

**ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨**

សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយផ្ទុយគ្នាទាក់ទងនឹង អោ អាន[197]។

**ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨**

សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយផ្ទុយគ្នាទាក់ទងនឹង មាស មុត[198]។

**ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨**

អង្គជំនុំជម្រះសាលាដំបូងបានកាត់ទោស នួន ជា និង ខៀវ សំផន ឱ្យជាប់ពន្ធនាគារមួយជីវិតចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ក្នុងសំណុំរឿង ០០២/០២[199]។

**ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩**

សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយផ្ទុយគ្នាទាក់ទងនឹង យឹម ទិត្យ[200]។

**ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩**

---

[193] សំណុំរឿង ០០២ សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ឯកសារ E359/1។

[194] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទ២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36។

[195] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ឯកសារ E1/519.1។

[196] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308។ សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3។

[197] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360។

[198] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267។

[199] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465។

[200] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

នួន ជា ទទួលមរណភាពក្រោយពេលដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន ដូច្នេះកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខបន្តទៀតពាក់ព័ន្ធនឹងគាត់ត្រូវបានបញ្ចប់[201]។

### ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០

អង្គជំនុំជម្រះតុលាការកំពូលបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង អោ អាន ដោយសារមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន[202]។

### ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១

អង្គជំនុំជម្រះតុលាការកំពូលបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង មាស មុត ដោយសារមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន[203]។

### ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១

អង្គជំនុំជម្រះតុលាការកំពូលបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំង យឹម ទិត្យ ដោយសារមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន[204]។

### ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២

អង្គជំនុំជម្រះតុលាការកំពូលតម្កល់ការកាត់ទោសជាប់ពន្ធនាគារមួយជីវិតរបស់ ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រល័យពូជសាសន៍ ក្នុងសំណុំរឿង ០០២/០២[205]។

### ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣

អ.វ.ត.ក. ចាប់ផ្ដើមមុខងារសេសសល់។

---

[201] សំណុំរឿង ០០២  សេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F46/3។

[202] សំណុំរឿង ០០៤/០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2។

[203] សំណុំរឿង ០០៣ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 3/1/1/1។

[204] សំណុំរឿង ០០៤ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1។

[205] សំណុំរឿង ០០២/០២ សេចក្ដីសង្ខេបសាលដីកាសំណុំរឿង ០០២/០២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារ F76.1។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76។

## ៣. អាណត្តិរបស់ អ.វ.ត.ក.

ជំពូកនេះរៀបរាប់អំពីគោលបំណង និងលក្ខណៈកូនកាត់របស់ អ.វ.ត.ក. ក៏ដូចជាអត្ថបទគតិយុត្តិជាមូលដ្ឋាន និងយុត្តិសាស្ត្ររបស់ខ្លួន។

### ៣.១. គោលបំណងរបស់ អ.វ.ត.ក.

បុព្វកថាភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. គូសបញ្ជាក់ "ការស្វែងរកយុត្តិធម៌ និងការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ" ដែលជាគោលបំណងសំខាន់របស់ អ.វ.ត.ក.[206]។

ការស្វែងរកយុត្តិធម៌ត្រូវបានចាត់ទុកថាជាមធ្យោបាយមួយ នៃការលើកកម្ពស់ការបង្រួបបង្រួមជាតិ បន្ទាប់ពីអំពើឃោរឃៅត្រូវបានប្រព្រឹត្តឡើង ប្រឆាំងនឹងសង្គមកម្ពុជាមួយផ្នែកធំ។ ក្រុមអ្នកជំនាញដែលបានតែងតាំងដោយ អ.ស.ប. ក្នុងឆ្នាំ១៩៩៨ ដើម្បីពិនិត្យបញ្ហានៃការទទួលខុសត្រូវរបស់ខ្មែរក្រហមនោះ បានពិចារណាថា ការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស គឺជាមធ្យោបាយមួយក្នុងការនាំមកនូវការបង្រួមបង្រួមជាតិ ការពង្រឹងប្រជាធិបតេយ្យ និងការដោះស្រាយបញ្ហានៃការទទួលខុសត្រូវជាបុគ្គល[207]។ អ្នកជំនាញបានពិចារណាថា "ប្រសិនបើយុត្តិធម៌ត្រូវបាននាំមកស្របជាមួយនឹងស្ថានការណ៍ផ្ទាល់របស់ប្រទេសមួយនោះ គណនេយ្យភាព និងការផ្សះផ្សាជាតិ ជាការពិត គឺជាការបំពេញបន្ថែម ទោះមិនអាចបំបែកបានក៏ដោយ"[208]។

ទោះជាយ៉ាងណា បរិបទប្រទេសគឺជាចំណុចមួយដែលការស្វែងរកយុត្តិធម៌មិនគួរធ្វើឡើងឱ្យខូចតម្លៃការបង្រួបបង្រួមជាតិ និងសន្តិភាពនោះទេ[209]។ អ្នកជំនាញបានកត់សម្គាល់អំពីទស្សនៈដែលថា ការកាត់ក្តីមេដឹកនាំខ្មែរក្រហម ដែលបានព្រមព្រៀងបញ្ឈប់ការតស៊ូរបស់ខ្លួនប្រឆាំងនឹងរដ្ឋាភិបាល ដើម្បីដោះដូរជាមួយនឹងការលើកលែងទោស នឹងធ្វើឱ្យកម្ពុជាអស្ថេរភាព និងហានិភ័យនៃការកើតមានសង្គ្រាមស៊ីវិលក្នុងប្រទេសនេះឡើងវិញ[210]។

ទំនាក់ទំនងនៃគោលការណ៍គន្លឹះទាំងអស់នេះ ត្រូវបានទទួលស្គាល់នៅក្នុងសេចក្តីសម្រេចចិត្តលេខ ៥៧/២២៨ នៃមហាសន្និបាត អ.ស.ប. ដែលលើកឡើងថា "ការទទួលខុសត្រូវរបស់ចារីម្នាក់ៗ ចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ គឺជាធាតុផ្សំដ៏សំខាន់មួយក្នុងចំណោមធាតុផ្សំសំខាន់ៗនានា នៃដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស និងជាកត្តាគន្លឹះក្នុងការធានាបាននូវប្រព័ន្ធយុត្តិធម៌ដ៏ត្រឹមត្រូវ និងសមធម៌ និងជាចុងក្រោយនោះគឺ ការបង្រួបបង្រួមជាតិ និងស្ថេរភាពនៅក្នុងប្រទេស"[211]។

### ៣.២. ក្របខណ្ឌច្បាប់

#### ៣.២.១. ច្បាប់ អ.វ.ត.ក.

ច្បាប់ អ.វ.ត.ក. គឺជាច្បាប់កម្ពុជាដែលបង្កើត អ.វ.ត.ក. ដើម្បី "វិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាង

---

206 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល បុព្វកថា។ សូមមើលផងដែរ វិធានផ្ទៃក្នុង បុព្វកថា។
207 របាយការណ៍ក្រុមអ្នកជំនាញ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ឧបសម្ព័ន្ធ កថាខណ្ឌ ១០៥។
208 របាយការណ៍ក្រុមអ្នកជំនាញ កថាខណ្ឌ ៣។
209 សូមមើល UNGA/UNSC លិខិតដូចគ្នាចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៩ ពីតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ ផ្ញើទៅកាន់អគ្គលេខាធិការ និងប្រធានក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ លេខ A/53/801-S/1999/67 ឧបសម្ព័ន្ធ I-II។ UNGA/UNSC លិខិតដូចគ្នា ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៩ ពី ពីតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ ផ្ញើទៅកាន់អគ្គលេខាធិការ និងប្រធានក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៩ លេខ A/53/851-S/1999/230 ឧបសម្ព័ន្ធ។
210 របាយការណ៍ក្រុមអ្នកជំនាញ កថាខណ្ឌ ១០៤។
211 UNGA, ការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ A/RES/57/228 បុព្វកថា។

ធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តឡើងក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩”[212]។

ច្បាប់ អ.វ.ត.ក. ចែងអំពី៖

- យុត្តាធិការលើរូបបុគ្គល យុត្តាធិការលើដែនដី យុត្តាធិការលើពេលវេលា និងយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក.[213]
- សមាសភាពនៃអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល[214]
- ការតែងតាំងចៅក្រមជម្រះក្តី និងការសម្រេចសេចក្តីរបស់ចៅក្រម[215]
- ការតែងតាំង និងតួនាទីរបស់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត ប្រធានការិយាល័យរដ្ឋបាល និងអនុប្រធានការិយាល័យរដ្ឋបាល[216]
- គោលការណ៍នៃការទទួលខុសត្រូវជាបុគ្គល[217]
- កិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្តី[218]
- ទោសបញ្ញត្តិ[219]
- ការលើកលែងទោស និងការអនុគ្រោះទោស[220]
- ឋានៈ សិទ្ធិ បុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់ចៅក្រមអន្តរជាតិ សហចៅក្រមអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល និងក្រុមគ្រួសាររបស់ពួកគេ[221]
- ទីតាំង ការចំណាយ និង ភាសាការងារ របស់ អ.វ.ត.ក.[222]
- ករណីគ្មានចៅក្រមជម្រះក្តី ចៅក្រមស៊ើបអង្កេត ឬព្រះរាជអាជ្ញាបរទេស[223]
- គោលការណ៍ដែល អ.វ.ត.ក. ត្រូវរលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់ជាស្ថាពរ[224]
- ការអនុវត្តកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តដូចច្បាប់នៅក្នុងប្រទេសកម្ពុជា[225]

ច្បាប់ អ.វ.ត.ក. ត្រូវបានអនុម័តដោយរដ្ឋសភាជាតិក្នុងឆ្នាំ២០០១ ហើយត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០០៤។ វិសោធនកម្មរួមមានការកែប្រែដ៏សំខាន់ទៅលើមាត្រា ៣ ពាក់ព័ន្ធនឹងយុត្តាធិការរបស់ អ.វ.ត.ក. ក្នុងការចោទប្រកាន់ បទមនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ សំណៅដើមចែងថា អាជ្ញាយុកាល “ត្រូវបានពន្យារពេលបន្ថែម ២០ ឆ្នាំទៀត” ពីអាជ្ញាយុកាល ១០ ឆ្នាំពីមុននៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។ សំណៅវិសោធនកម្មនៃបទប្បញ្ញត្តិបានពន្យារពេលអាជ្ញាយុកាល “បន្ថែម ៣០ ឆ្នាំទៀត”។ វិសោធនកម្មនេះត្រូវបានធ្វើឡើងដើម្បីអនុញ្ញាតឱ្យសាលាក្តីកាត់សេចក្តីជនសង្ស័យ ចំពោះឧក្រិដ្ឋកម្មជាតិទាំងអស់នេះ ដោយសារតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ អាចត្រូវបានរារាំងក្រោមអាជ្ញាយុកាលដើម។

---

[212] ច្បាប់ អ.វ.ត.ក. មាត្រា ១។
[213] ច្បាប់ អ.វ.ត.ក. ជំពូកទី ២។
[214] ច្បាប់ អ.វ.ត.ក. ជំពូកទី ៣។
[215] ច្បាប់ អ.វ.ត.ក. ជំពូកទី ៤-៥។
[216] ច្បាប់ អ.វ.ត.ក. ជំពូកទី ៦, ៧, ៩។
[217] ច្បាប់ អ.វ.ត.ក. ជំពូកទី ៨។
[218] ច្បាប់ អ.វ.ត.ក. ជំពូកទី ១០។
[219] ច្បាប់ អ.វ.ត.ក. ជំពូកទី ១១។
[220] ច្បាប់ អ.វ.ត.ក. ជំពូកទី ១២។
[221] ច្បាប់ អ.វ.ត.ក. ជំពូកទី ១៣។
[222] ច្បាប់ អ.វ.ត.ក. ជំពូកទី ១៤-១៦។
[223] ច្បាប់ អ.វ.ត.ក. ជំពូកទី ១៧។
[224] ច្បាប់ អ.វ.ត.ក. ជំពូកទី ១៨។
[225] ច្បាប់ អ.វ.ត.ក. ជំពូកទី ១៩។

### ៣.២.២. កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា

កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាត្រូវបានរៀបចំឡើងបន្ទាប់ពីច្បាប់ អ.វ.ត.ក. ទទួលបានការឯកភាពគ្នា និងប្រកាសឱ្យប្រើជាច្បាប់ក្នុងប្រទេសកម្ពុជា។ កិច្ចព្រមព្រៀងនេះគឺជាលិខិតូបករណ៍អន្តរជាតិដែលធ្វើឡើងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ដែលចែងអំពីកិច្ចសហប្រតិបត្តិការរបស់ពួកគេ ទាក់ទងនឹង អ.វ.ត.ក. ហើយត្រូវបានអនុវត្តតាមរយៈច្បាប់ អ.វ.ត.ក.[226]។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់នូវមូលដ្ឋាន និងគោលការណ៍គតិយុត្តិ និងទម្រង់ការសម្រាប់កិច្ចសហប្រតិបត្តិការនៅក្នុងកម្រិតទ្វេភាគី[227] ហើយមានបទប្បញ្ញត្តិលម្អិតអំពីប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ កិច្ចព្រមព្រៀងនេះផ្ទាល់មិនមែនជាមូលដ្ឋានសម្រាប់ការនាំយកមកកាត់ទោសនៅ អ.វ.ត.ក. ទេ ដោយសារការណ៍នេះត្រូវបានចែងនៅក្នុងច្បាប់ អ.វ.ត.ក.[228]។

ស្រដៀងគ្នាទៅនឹងច្បាប់ អ.វ.ត.ក. ដែរ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាមានបទប្បញ្ញត្តិស្តីពីបញ្ហាមួយចំនួន រួមមាន៖

- សមាសភាពអង្គជំនុំជម្រះ និងការសម្រេចក្តីរបស់តុលាការ[229]
- ការងាររបស់សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា[230]
- ការដោះស្រាយការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា[231]
- មុខងាររបស់ការិយាល័យរដ្ឋបាល[232]
- ឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. និងទោសបញ្ញត្តិ[233]
- ការលើកលែងទោស និងការអនុគ្រោះទោស[234]
- នីតិវិធី[235]
- សិទ្ធិរបស់ជនជាប់ចោទ[236]
- អគាររបស់ អ.វ.ត.ក. និងប្រាក់បៀវត្ស និងប្រាក់បំណាច់របស់បុគ្គលិកជាតិ និងអន្តរជាតិ[237]
- ជំនួយហិរញ្ញវត្ថុ និងជំនួយផ្សេងៗទៀតរបស់ អ.ស.ប.[238]
- ភាពមិនអាចរំលោភបំពានបាននៃបណ្ណសារ និងឯកសារ និងបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់មន្ត្រីជាក់លាក់ និងបុគ្គលិកផ្សេងទៀត[239]
- សាក្សី និងអ្នកជំនាញ និងការការពារសាក្សីនិងអ្នកជំនាញ[240]
- សន្តិសុខ សុវត្ថិភាព និងការការពារបុគ្គល ដែលមានចែងក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា[241]
- កាតព្វកិច្ចជួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះវិសាមញ្ញ[242]

---

226 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២(២)។
227 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១។
228 សូមមើល សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ៦៩០។
229 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣-៥។
230 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៥-៦។
231 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៧។
232 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៨។
233 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៩-១០។
234 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១១។
235 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១២។
236 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១៣។
237 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១៤-១៦។
238 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១៧។
239 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ១៨-២១។
240 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២២-២៣។
241 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៤។
242 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៥។

- ភាសាប្រើប្រាស់ជាផ្លូវការនៅក្នុងការងាររបស់ អ.វ.ត.ក.[243]
- ការរៀបចំតាមសភាពជាក់ស្តែង ការដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការ និងការដោះស្រាយជម្លោះ[244]

កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពី ការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់ អ.វ.ត.ក. ផ្តល់ឱ្យអង្គជំនុំជម្រះវិសាមញ្ញនូវមុខងារសេសសល់ បន្ទាប់ពីបិទបញ្ចប់ការជំនុំជម្រះក្តី។ ចំណុចនេះមានពិភាក្សាបន្ថែមទៀតនៅក្នុងជំពូក ៧។

កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាមានកិច្ចព្រមព្រៀងបន្ថែមចំនួនពីរ៖ កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខនិងសុវត្ថិភាព ព្រមទាំងកិច្ចព្រមព្រៀងបន្ថែមរបស់វា និងកិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម។ កិច្ចព្រមព្រៀងបន្ថែមនីមួយៗត្រូវបានរៀបរាប់សង្ខេបខាងក្រោម។

### ៣.២.២.១. កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាព

កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខនិងសុវត្ថិភាព បញ្ជាក់ឡើងវិញអំពីកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកំណត់ការទទួលខុសត្រូវចំពោះសន្តិសុខ សុវត្ថិភាព និងការការពារបុគ្គលទាំងអស់ដែលមានចែងក្នុងកិច្ចព្រមព្រៀងគោល[245]។ កិច្ចព្រមព្រៀងបន្ថែមនេះលើកឡើងថា អ.ស.ប. ទទួលខុសត្រូវចំពោះសន្តិសុខនៅក្នុងបន្ទប់សវនាការ និងបរិវេណអគារ ចំណែករាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះសន្តិសុខទូទៅខាងក្រៅបរិវេណ អ.វ.ត.ក.។ កិច្ចព្រមព្រៀងនេះក៏គូសបញ្ជាក់ការទទួលខុសត្រូវរបស់មន្ត្រីសន្តិសុខ អ.ស.ប. និងមន្ត្រីសន្តិសុខជាតិផងដែរ ក៏ដូចជាសិទ្ធិរបស់ អ.ស.ប. ក្នុងការនាំចូលអាវុធ គ្រាប់រំសេវ និងសម្លៀកបំពាក់ការពារដោយមិនគិតថ្លៃ និងមិនមានការរឹតបន្តឹង និងសិទ្ធិរបស់មន្ត្រីឯកសណ្ឋានមួយចំនួនក្នុងការកាន់អាវុធក្នុងពេលបំពេញភារកិច្ច[246]។

### ៣.២.២.២. កិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម

កិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម បញ្ជាក់ឡើងវិញអំពីការទទួលខុសត្រូវដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងសង្កត់ធ្ងន់លើការទទួលខុសត្រូវរបស់ភាគីនីមួយៗ ចំពោះការចំណាយផ្សេងៗ។ កិច្ចព្រមព្រៀងចែងថា អ.ស.ប. ទទួលខុសត្រូវចំពោះឧបករណ៍ យានយន្ត គ្រឿងកុំព្យូទ័រទាំងផ្នែករឹងនិងកម្មវិធី ថ្លៃប្រើប្រាស់ទូរគមនាគមន៍ ការបណ្តុះបណ្តាល និងការគាំទ្រសម្រាប់ផ្នែកការពារក្តី និងសាក្សីនិងជនរងគ្រោះ ចំណែករាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះការផ្តល់អគារចាំបាច់សម្រាប់តុលាការ សម្រាប់ប្រើជាការិយាល័យ សម្រាប់ការឃុំខ្លួនចុងចោទ និងការស្នាក់នៅមានសុវត្ថិភាពរបស់សាក្សី និងជនរងគ្រោះដែលត្រូវការការការពារ ថ្លៃប្រើប្រាស់អគ្គិសនី និងទឹក និងចំពោះការផ្តល់សេវាទូរគមនាគមន៍[247]។

កិច្ចព្រមព្រៀងបន្ថែមនេះត្រូវបានធ្វើវិសោធនកម្ម ក្នុងឆ្នាំ២០១១ ដើម្បីចែងថា រាជរដ្ឋាភិបាលនឹងរៀបចំឱ្យមានបរិក្ខាសង្គ្រោះបឋមនៅក្នុងអគារ អ.វ.ត.ក. សម្រាប់ប្រើប្រាស់ក្នុងករណីបន្ទាន់។ កិច្ចព្រមព្រៀងនេះក៏ចែងអំពីការធានារបស់រាជរដ្ឋាភិបាលនូវការបញ្ជូនជាបន្ទាន់ ទៅកាន់មន្ទីរពេទ្យកាល់ម៉ែត ឬមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្នុងទីក្រុងភ្នំពេញ នៅពេលណាដែលត្រូវការក្នុងករណីបន្ទាន់ ហើយការដឹកជញ្ជូនគឺជាបន្ទុករបស់រាជរដ្ឋាភិបាល[248]។

---

243 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៦។
244 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៧-២៩។
245 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២៤។
246 សូមមើល កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាព។
247 សូមមើល កិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម។
248 វិសោធនកម្មលើកិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់បរិក្ខារនិងសេវាកម្ម។

### ៣.២.៣. វិធានផ្ទៃក្នុង

វិធានផ្ទៃក្នុងត្រូវបានបង្កើតឡើងដើម្បីបញ្ជាក់លើនីតិវិធីដែលអាចអនុវត្តបាន ស្របតាមមាត្រា ១២ (១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា[249]។ វិធានទាំងនេះ "ច្របាច់បញ្ចូលនូវច្បាប់នីតិវិធីកម្ពុជា ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. និងប្រើនីតិវិធីអន្តរជាតិ ក្នុងគោលបំណងដើម្បីធានានូវយុត្តិធម៌ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់"[250] ជាពិសេសក្នុងករណីដែលនីតិវិធីដែលមានស្រាប់មិនបានដោះស្រាយបញ្ហាជាក់លាក់ណាមួយ ឬករណីដែលមិនមានភាពច្បាស់លាស់ ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តរបស់ពួកវា ឬបញ្ហាចោទទាក់ទងនឹងសង្គតិភាពជាមួយនឹងបទដ្ឋានអន្តរជាតិ[251] ។

ត្រង់ចំណុចនេះ វិធានផ្ទៃក្នុង "បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក." និងថា "គោលបំណងរបស់ អ.វ.ត.ក. ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យ អ.វ.ត.ក. មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស"[252]។

អង្គជំនុំជម្រះសាលាដំបូងបានបដិសេធការជំទាស់ទៅនឹងការចោទប្រកាន់ពីអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង ដោយបានសន្និដ្ឋានថាវិធានផ្ទៃក្នុង "តំណាងឱ្យបទដ្ឋានអន្តរជាតិដែលមាននាពេលបច្ចុប្បន្ន ពាក់ព័ន្ធទៅនឹងរឿងក្តីទានា ដែលតុលាការយកមកប្រើដើម្បីវិនិច្ឆ័យទោសលើឧក្រិដ្ឋកម្មអន្តរជាតិ ហើយវិធានទាំងនេះក៏ស្របតាមកាតព្វកិច្ចរបស់ អ.វ.ត.ក. [...] ក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធី អនុលោមតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការតាមច្បាប់កំណត់"[253]។ ការជំទាស់ស្រដៀងគ្នានេះក៏ត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូលផងដែរ[254]។

វិធានផ្ទៃក្នុងមានបួនជំពូក ដែលគ្របដណ្តប់ចំណុចខាងក្រោម៖

- បទបញ្ញត្តិទាក់ទងទៅនឹងវិធានផ្ទៃក្នុងខ្លួនឯងផ្ទាល់ (ការពិភាក្សាអំពីការចូលជាធរមានរបស់វិធាន និងការបកស្រាយ នីតិវិធីក្នុងករណីមានចន្លោះប្រហោងក្នុងវិធានផ្ទៃក្នុង និងការធ្វើវិសោធនកម្ម)
- ការរៀបចំ អ.វ.ត.ក. (ការពិភាក្សាអំពីតួនាទី និងប្រតិបត្តិការរបស់ការិយាល័យរដ្ឋបាល ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត នគរបាលយុត្តិធម៌ អ្នកស៊ើបអង្កេត និងក្រឡាបញ្ជី អង្គជំនុំជម្រះ និងការរៀបចំតុលាការ)
- នីតិវិធីជាធរមាន
- នីតិវិធីដែលអាចអនុវត្តបានក្នុងដំណាក់កាលមុខងារសេសសល់

បន្ទាប់ពីទទួលបានការអនុម័តក្នុងឆ្នាំ២០០៧ វិធានផ្ទៃក្នុងត្រូវបានកែតម្រូវចំនួនដប់ដង ដោយមូលហេតុផ្សេងៗ មានដូចជាកែសម្រួល និងធ្វើឱ្យទៅជាផ្លូវការនូវវិធានការ និងនីតិវិធីមួយចំនួន ដែលមានចែងក្នុងវិធាន។ ការធ្វើវិសោធនកម្មទាំងនេះគឺកើតមានជាទូទៅនៅក្នុងសាលាក្តីអន្តរជាតិ និងសាលាក្តីអន្តរជា

---

[249] សូមមើល UNGA របាយការណ៍របស់អគ្គលេខាធិការស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ឯកសារ A/62/304 កថាខណ្ឌ ៣២។

[249] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១០៤។

[250] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២១។

[251] វិធានផ្ទៃក្នុង បុព្វកថា។ សូមមើលផងដែរ UNGA របាយការណ៍របស់អគ្គលេខាធិការស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ឯកសារ A/62/304 កថាខណ្ឌ ៣២។

[252] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ១៤។

[253] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ឯកសារ E51/14 កថាខណ្ឌ ៧។

[254] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ជំពូក ៤(ក)។

ត្ថុបនីយកម្ម[255]។ គណៈកម្មាធិការវិធាន និងនីតិវិធី បានទទួលសំណើស្នើសុំការធ្វើវិសោធនកម្មវិធាន និង បានដាក់សំណើទៅកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក. ដើម្បីធ្វើការអនុម័ត[256]។ សំណើសុំធ្វើវិសោធនកម្ម អាចធ្វើឡើងដោយចៅក្រមម្នាក់ សហចៅក្រមម្នាក់ សហព្រះរាជអាជ្ញាម្នាក់ ប្រធានផ្នែកគាំពារការការពារក្តី ផ្នែកគាំពារជនរងគ្រោះ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ឬប្រធានការិយាល័យរដ្ឋបាល ឬអនុប្រធានការិយាល័យរដ្ឋបាល[257]។

## ៣.២.៤. សេចក្តីណែនាំអនុវត្ត

សេចក្តីណែនាំអនុវត្តត្រូវបានអនុម័តដោយគណៈកម្មាធិការវិធាននិងនីតិវិធី[258]។ បន្ទាប់ពីអនុម័ត ហើយ សេចក្តីណែនាំអនុវត្តអាចត្រូវបានពិនិត្យ និងធ្វើវិសោធនកម្មនៅកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក.[259] ។ សេចក្តីណែនាំអនុវត្តចំនួនបួន ត្រូវបានអនុម័ត៖

i. **សេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង** ចែងថាតើឯកសារណាខ្លះដែលត្រូវធ្វើចំណាត់ប្រភេទជាសាធារណៈ សម្ងាត់ ឬសម្ងាត់បំផុត ដើម្បីរក្សាតុល្យភាពការសម្ងាត់នៃការស៊ើបអង្កេតតាមផ្លូវតុលាការ និងការសម្ងាត់នៃផ្នែកផ្សេងទៀតនៃកិច្ចដំណើរការនីតិវិធី ដែលបិតបាំងមិនឱ្យសាធារណជនដឹង ក្នុងគោលបំណងធានាបាននូវតម្លាភាពនៃកិច្ចដំណើរការនីតិវិធីជាសាធារណៈ និងដើម្បីបំពេញគោលបំណងនៃការអប់រំ និងកេរដំណែល[260]។

ii. **សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅ អ.វ.ត.ក.** ចែងអំពីចំណុចលម្អិតពាក់ព័ន្ធនឹងការដាក់ និងការរៀបចំទម្រង់ឯកសារ ដូចជា ការចុះលេខរៀងសំណុំរឿង ម៉ោងដាក់ឯកសារផ្លូវការ និងទំហំអក្សរ ហើយក៏មានបទប្បញ្ញត្តិស្តីពីចំនួនទំព័រកំណត់នៃឯកសារ បញ្ជីឯកសារយោង ការបកប្រែភាសា ពេលវេលាកំណត់សម្រាប់ដាក់សារណា និងពាក្យសុំ ការដាក់ឯកសារយឺត និងការដាក់ឯកសារមិនគ្រប់គ្រាន់[261]។

iii. **សេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមរបស់ជនរងគ្រោះ** ចែងអំពីនីតិវិធី និងទម្រង់ការក្នុងការដាក់ពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងពិភាក្សាអំពីការតំណាងអោយដើមបណ្តឹងរដ្ឋប្បវេណី និងការបង្កើតសមាគមជនរងគ្រោះ[262]។

iv. **សេចក្តីណែនាំអនុវត្តស្តីអំពីវិធានការការពារ** ត្រូវបានណែនាំដើម្បីការពារជនរងគ្រោះដែលបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងនាមជា អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី ដោយអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ចាត់វិធានការនានា ដូចជាការបង្គាប់ឱ្យដាក់កំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬផ្នែកជាក់លាក់នៃកិច្ចដំណើរការនីតិវិធី តាមរបៀប “បិទស្លាកបោះត្រា” បង្គាប់ឱ្យហាមឃាត់សាធារណជនចូលពិនិត្យឯកសារណាមួយក្នុងសំណុំរឿង ចេញវិធានការដើម្បីការពារជារូបវន្តដល់បុគ្គលដែលត្រូវការពារ ដូចជាតាមរយៈការផ្តល់ជាកន្លែងស្នាក់នៅដែលមានសុវត្ថិភាព ឬបង្គាប់ឱ្យមានការដកចេញនូវព័ត៌មានដែលអាចឱ្យគេស្គាល់នូវអត្តសញ្ញាណរបស់បុគ្គលដែលត្រូវការពារ[263]។

---

[255] ឧទាហរណ៍ វិធានស្តីពីនីតិវិធី និងភ័ស្តុតាង នៅតុលាការ ICTY ត្រូវបានធ្វើវិសោធនកម្ម ៥០ ដង ហើយវិធានស្តីពីនីតិវិធី និងភ័ស្តុតាងរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ត្រូវបានធ្វើវិសោធនកម្ម ១៤ ដង។ សូមមើល វិធានស្តីពីនីតិវិធី និងភ័ស្តុតាង ICTY ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ IT/32/Rev. 50។ វិធានស្តីពីនីតិវិធី និងភ័ស្តុតាងនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២។

[256] វិធានផ្ទៃក្នុង វិធាន ៣។

[257] វិធានផ្ទៃក្នុង វិធាន ៣(១)។

[258] វិធានផ្ទៃក្នុង វិធាន ២០(៣)។

[259] វិធានផ្ទៃក្នុង វិធាន ១៨(៦)(ខ)។

[260] សេចក្តីណែនាំអនុវត្តស្តីអំពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ត្រូវអនុម័ត មាត្រា ១.២។

[261] សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅអ.វ.ត.ក មាត្រា ១-៣, ៥-១០។

[262] សេចក្តីណែនាំអនុវត្តស្តីអំពីការចូលរួមរបស់ជនរងគ្រោះ មាត្រា ២-៥។

[263] សេចក្តីណែនាំអនុវត្តស្តីអំពីវិធានការការពារ មាត្រា ១.២, ៣.១។

## ៣.៣. យុត្តាធិការ

### ៣.៣.១. យុត្តាធិការលើរឿងក្តី

យុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក. មានចែងនៅក្នុងមាត្រា ១, ២ និង ៩ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ១-៨ នៃច្បាប់ អ.វ.ត.ក.[264]។ ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក. មានដូចខាងក្រោម៖

i. មនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា ដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦
ii. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍
iii. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[265]
iv. ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ
v. ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌យោងតាមអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារសម្បត្តិវប្បធម៌ក្នុងពេលជម្លោះប្រដាប់អាវុធ
vi. ឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ យោងតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត។

ឧក្រិដ្ឋកម្មពីរប្រភេទចុងក្រោយមិនត្រូវបានចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក. ទេ។ ឧក្រិដ្ឋកម្មផ្សេងទៀតដែលស្ថិតក្រោមយុត្តាធិការលើរឿងក្តីរបស់ អ.វ.ត.ក. ត្រូវបានរៀបរាប់លម្អិតខាងក្រោម។

#### ៣.៣.១.១. ឧក្រិដ្ឋកម្មក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦

មាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក. ចែងថា៖

> អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ៦ មករា ឆ្នាំ១៩៧៩៖
>
> - មនុស្សឃាត (មាត្រា ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧ និងមាត្រា ៥០៨)
>
> - ទារុណកម្ម (មាត្រា ៥០០)
>
> - ការវាយប្រហារលើសាសនា (មាត្រា ២០៩ និងមាត្រា ២១០)
>
> អាជ្ញាយុកាលនៃបណ្តឹងអាជ្ញានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែលទាក់ទងដល់បទល្មើសខាងលើ ត្រូវបានពន្យារពេលបន្ថែម ៣០ ឆ្នាំទៀត ទៅលើអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាសម្រាប់ឧក្រិដ្ឋកម្មទាំងឡាយខាងលើ ដែលស្ថិតក្នុងសមត្ថកិច្ចនៃអង្គជំនុំជម្រះវិសាមញ្ញ។
>
> ទោសប្បញ្ញត្តិចែងក្នុងមាត្រា ២០៩, ៥០០, ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវកំណត់ជាអតិបរមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជាក់បន្ថែមដោយមាត្រា ៣៨ និង ៣៩ ថ្មី នៃច្បាប់នេះ។

---

[264] កិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាល មាត្រា ១-២, ១០។ ច្បាប់ អ.វ.ត.ក. មាត្រា ១-៨។

[265] ទោះបីជា មាត្រា ២ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល ចែងថា អ.វ.ត.ក. មានយុត្តាធិការលើរឿងក្តីស្របជាមួយនឹងបញ្ញត្តិដែលចែងក្នុងច្បាប់ អ.វ.ត.ក. យ៉ាងណាក្តី ក៏មាត្រា ៩ បញ្ជាក់ថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" គឺដូចដែលមានចែងក្នុងលក្ខន្តិកៈទីក្រុងរ៉ូមឆ្នាំ១៩៩៨ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ។

អង្គបុរេជំនុំជម្រះបានរកឃើញថាអំពើមនុស្សឃាតគិតទុកជាមុន - ដែលជាទម្រង់មួយក្នុងចំណោមទម្រង់ពីរនៃអំពើមនុស្សឃាត យោងតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ - មិនត្រូវបានដាក់បញ្ចូលនៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិនៃការធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការធ្វើមនុស្សឃាតដោយចេតនា ដែលជាការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវទេ ដោយសារវាតម្រូវឱ្យមានការគិតទុកជាមុន និងធាតុផ្សំអត្តនោម័តិខ្ពស់ ពោលគឺ ចេតនាសម្លាប់ ជាជាងចេតនាទាបជាងនេះដែលបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរលើរាងកាយ[266]។ ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថាមនុស្សឃាតដោយមិនមានចេតនាសម្លាប់ ត្រូវបានដាក់បញ្ចូលនៅក្នុងឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់នេះ[267]។

មិនមានជនជាប់ចោទណាចុងក្រោយត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មជាតិ នៅ អ.វ.ត.ក. ឡើយ។ ក្នុងសំណុំរឿង ០០១ បន្ទាប់ពីត្រូវបានចោទប្រកាន់ដោយឧក្រិដ្ឋកម្មជាតិយោងតាមមាត្រា ៣(ថ្មី) នៃច្បាប់ អ.វ.ត.ក.[268] ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានដាក់អញ្ញត្រកម្មទៅកាន់អង្គជំនុំជម្រះសាលាដំបូង ដោយតវ៉ាថា មាត្រា ៣(ថ្មី) មិនមានសុពលភាព ដោយសារវាល្មើសទៅនឹងបញ្ញត្តិនៃមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដោយការបន្ថែមរយៈពេលកំណត់លើសពីរយៈពេលកំណត់ ១០ ឆ្នាំ ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ហេតុដូច្នេះ ផ្តល់លទ្ធភាពឱ្យមានការចោទប្រកាន់ឧក្រិដ្ឋកម្មក្រោយរយៈពេលអាជ្ញាយុកាលរបស់ពួកវាបានផុតទៅហើយនោះ[269]។ ចៅក្រមអង្គជំនុំជម្រះសាលាដំបូងមានមតិខ្វែងគ្នាត្រង់ចំណុចនេះ។ អវត្តមានសំឡេងភាគច្រើនលើសលប់បានបដិសេធការចោទប្រកាន់ជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មជាតិ ប៉ុន្តែបន្តការចោទប្រកាន់ប្រឆាំងគាត់សម្រាប់អំពើដូចគ្នានេះ ដែលបង្កើតបានជាឧក្រិដ្ឋកម្មអន្តរជាតិ[270]។

ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានយោងទៅលើប្រវត្តិនីតិវិធីនៃសំណុំរឿង ០០១ និងបានលើកឡើងថា ពួកគាត់មិនអាចឯកភាពទៅនឹងបញ្ហា (i) កាត់ទោសពីរដងចំពោះអង្គហេតុដដែល (ii) រយៈពេលកំណត់សម្រាប់ឧក្រិដ្ឋកម្មជាតិដែលពាក់ព័ន្ធ និង (iii) អានុភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា ដែលសន្និដ្ឋានថា ការពន្យារពេលអាជ្ញាយុកាលរបស់មាត្រា ៣ មិនបានល្មើសទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជា។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតពន្យាពេលចេញសេចក្តីសម្រេចលើបញ្ហាថាតើវិធានការនីតិវិធីអ្វីដែលត្រូវធ្វើ ទាក់ទងទៅនឹងឧក្រិដ្ឋកម្មជាតិ[271]។ នៅដំណាក់កាលជំនុំជម្រះ ការចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មជាតិត្រូវបានច្រានចោល ដោយសារដីកាដំណោះស្រាយខកខានមិនបានបញ្ជាក់ឱ្យច្បាស់អំពីអង្គហេតុពាក់ព័ន្ធសំខាន់ៗ ឬទម្រង់នៃការទទួលខុសត្រូវ ទាក់ទងនឹងឧក្រិដ្ឋកម្មជាតិដែលបានចោទប្រកាន់ទាំងនោះ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មិនអាចកំណត់វិសាលភាពនៃរឿងក្តីប្រឆាំងនឹងជនជាប់ចោទបានទេ ទាក់ទងនឹងឧក្រិដ្ឋកម្មជាតិ ដែលត្រូវបានចោទប្រកាន់ទាំងនោះ[272]។

[266] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ ៩២-៩៣ យោងទៅសំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៧៨។

[267] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៨៣។

[268] ការចោទប្រកាន់ទាំងអស់នេះត្រូវបានដាក់បន្ថែមទៅក្នុងដីកាដំណោះស្រាយ ដោយអង្គបុរេជំនុំជម្រះ។ សូមមើល ជំពូក ៥.១.៤.២។

[269] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ៤។

[270] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 យោបល់របស់ចៅក្រម Silvia Cartwright និងចៅក្រម Jean-Marc Lavergne កថាខណ្ឌ ៥៤-៥៦។

[271] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ១៥៧៤។

[272] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E122 កថាខណ្ឌ ២១-២២។ សូមមើលផងដែរ ជំពូក ៥.១.៤.២ និង ៥.២.៥.១ ពិភាក្សាបញ្ហាទាក់ទងនឹងការអនុវត្តឧក្រិដ្ឋកម្មជាតិក្នុងសំណុំរឿង ០០១ និង ០០២។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬ បញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថាមានភ័ស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាអំពីអំពើមនុស្សឃាតគិតទុកជាមុន នៅក្នុងរឿងក្តីខាងក្រោមនេះ៖

- **សំណុំរឿង ០០៣៖** ទាក់ទងទៅនឹងការសម្លាប់ជនជាតិវៀតណាម និងថៃ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ការបោសសម្អាតកងពលយោធាចំនួនបួនកងពល និងការស្លាប់នៅក្នុងមន្ទីរសន្តិសុខចំនួនពីរ ទីតាំងសម្លាប់មនុស្សចំនួនមួយ និងការដ្ឋាននានា[273]។
- **សំណុំរឿង ០០៤៖** នៅក្នុងទីកន្លែងនានា រួមមានតំបន់ ១៣ នៃភូមិភាគនិរតី និងតំបន់ ១, ២, ៣, ៤ និង ៧ នៃភូមិភាគពាយ័ព្យ[274]។
- **សំណុំរឿង ០០៤/០១៖** នៅក្នុងមន្ទីរសន្តិសុខចំនួន ១ និងការដ្ឋានចំនួន ១ ក្នុងតំបន់ ៥ នៃភូមិភាគពាយ័ព្យ[275]។
- **សំណុំរឿង ០០៤/០២៖** នៅក្នុងទីតាំងចំនួនប្រាំបី[276]។

### ៣.៣.១.២. អំពើប្រល័យពូជសាសន៍

អំពើប្រល័យពូជសាសន៍នៅ អ.វ.ត.ក. ត្រូវបានកំណត់និយមន័យស្របជាមួយនឹងអនុសញ្ញាប្រល័យពូជសាសន៍។ និយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ “គឺជានិយមន័យមួយដែលមានលក្ខណៈជាសកល អាចប៉ាន់ស្មានបាន និងមិនប្រែប្រួល ហើយនិយមន័យនេះត្រូវបានកំណត់ដូចគ្នាក្នុងអនុសញ្ញាស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក៏ដូចជាច្បាប់ អ.វ.ត.ក.”[277]។ មាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ពន្យល់ថា អំពើជាក់លាក់ រួមមាន ការសម្លាប់សមាជិកនៃក្រុមមួយ បង្កើតបានជាអំពើប្រល័យពូជសាសន៍ នៅពេលដែល “ប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ”។

ក្នុងសំណុំរឿង ០០២/០២ ជនជាប់ចោទត្រូវបានចោទប្រកាន់ និងដាក់ពិរុទ្ធភាពពីបទប្រល័យពូជសាសន៍[278]។ នួន ជា ត្រូវបានដាក់ពិរុទ្ធភាពនៅពេលជំនុំជម្រះពីបទប្រល័យពូជសាសន៍ប្រឆាំងនឹងក្រុមជនជាតិចាម និង ក្រុមជនជាតិវៀតណាម[279] ចំណែកការដាក់ពិរុទ្ធភាព ខៀវ សំផន ពីបទប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម ត្រូវបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូល នៅដំណាក់កាលសាទុក្ខ[280]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខ្លួនមានយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយ

---

[273] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 បទចោទទី ៤។
[274] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ មិថុនា ឆ្នាំ២០១៩ ឯកសារ D382 បទចោទទី ៤។
[275] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ៤(i)។
[276] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 បទចោទទី ៣។
[277] សំណុំរឿង ០០២ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៤៨។
[278] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ 782.
[279] សំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើសំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្រោយមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ F46/2/4/2 កថាខណ្ឌ៨៦។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ *ជាអាទិ៍*ថា ការបញ្ចប់កិច្ចដំណើរការនីតិវិធីបន្ទាប់ពីមរណភាពរបស់ នួន ជា មិនបានមោឃៈសាលក្រមសំណុំរឿង០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូងទេ និងថា ក្នុងពេលជាមួយគ្នានេះដែរ ពុំមានការចេញសាលក្រម ឬសាលដីកាស្ថាពរលើភាពមានពិរុទ្ធ ឬគ្មានពិរុទ្ធរបស់ នួន ជា ទេ ដោយសារមរណភាពរបស់គាត់បានរារាំងការពិនិត្យឡើងវិញលើទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ។ សូមមើល ជំពូក ៥.២.៧.៤.១។
[280] សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ២០៦៨-២០៧០ ផ្នែកសម្រេចសេចក្តី។

ពិចារណាថា គេអាចប្រមើលឃើញនិងអាចដឹងជាទូទៅថា អំពើប្រល័យពូជសាសន៍អាចត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មត្រឹមឆ្នាំ១៩៧៥[281]។

ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតក៏បានចោទប្រកាន់ អៀង សារី និង អៀង ធីរិទ្ធ ពីបទប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងជនជាតិចាម ផងដែរ[282] ប៉ុន្តែបទចោទទាំងនោះមិនត្រូវបានសម្រេចនៅដំណាក់កាលជំនុំជម្រះទេ ដោយសារមរណភាពរបស់ អៀង សារី និងការដោះលែង អៀង ធីរិទ្ធ ដោយមិនមានសម្បទាក្នុងការចូលរួមសវនាការ។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬ បញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថាមានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាអំពីអំពើប្រល័យពូជសាសន៍ នៅក្នុងរឿងក្តីខាងក្រោមនេះ៖

- **សំណុំរឿង ០០៣៖** អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម តាមរយៈការសម្លាប់សមាជិកនៃក្រុម[283]
- **សំណុំរឿង ០០៤៖** អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម តាមរយៈការសម្លាប់សមាជិកនៃក្រុម[284]
- **សំណុំរឿង ០០៤/០២៖** អំពើប្រល័យពូជសាសន៍លើជនជាតិចាម តាមរយៈការសម្លាប់សមាជិកនៃក្រុមមួយ និងការបង្កព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរទៅលើបណ្តាសមាជិកនៃក្រុម[285]។

### ៣.៣.១.៣. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

មាត្រា ៥ នៃច្បាប់ អ.វ.ត.ក. កំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជា "អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធ ពូជសាសន៍ ឬសាសនា" ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត។

ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងជួបបញ្ហាប្រឈមទៅនឹងយុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ច្បាប់កម្ពុជាមិនមានបទប្បញ្ញត្តិណាដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ទេ ហើយកម្ពុជាក៏មិនមែនជាភាគីទៅនឹងអនុសញ្ញាពាក់ព័ន្ធណាមួយក្នុងអំឡុងពេលនោះដែរ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបង្កើតបានជាផ្នែកមួយយ៉ាងស៊ីចង្វាក់គ្នាទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចាប់តាំងពីធម្មនុញ្ញ Nuremberg[286]។ ដូច្នេះ គេអាចប្រមើលដឹងថា ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលគាត់ត្រូវបានចោទប្រកាន់ ហើយគាត់បានដឹងថាមានច្បាប់ចែងនៅពេលប្រព្រឹត្តឧក្រិដ្ឋកម្ម[287]។ ជាងនេះទៀត អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "លក្ខណៈឃោរឃៅនៃឧក្រិដ្ឋកម្ម [...] អាចបដិសេធចំពោះការអះអាងរបស់ជនជាប់ចោទដែលថា ខ្លួនមិនបានដឹងអំពីលក្ខណៈឧក្រិដ្ឋនៃអំពើទាំងនោះ"[288]។

---

281 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៧៨៩។
282 សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427 ជំពូក ៥ ផ្នែកសេចក្តីសម្រេចបញ្ចប់។
283 សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 បទចោទទី១។
284 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 បទចោទទី១។
285 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 បទចោទទី១។
286 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ២៩០។
287 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ២៩៤។
288 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ២៩៥។

អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជាក់ដែរថា បើទោះជាបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់តាំងពីធម្មនុញ្ញ Nuremberg៖

> ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នា ហើយធាតុផ្សំរបស់ឧក្រិដ្ឋកម្មនេះ ក៏ត្រូវបានធ្វើឱ្យកាន់តែច្បាស់លាស់ជាបន្តបន្ទាប់ជាច្រើនឆ្នាំមកហើយ។ ករណីនេះ ឆ្លុះបញ្ចាំងឱ្យឃើញទាំងការវិវត្តលក្ខណៈទំនៀមទម្លាប់របស់ឧក្រិដ្ឋកម្ម និងហេតុដែលយុត្តាធិការរបស់តុលាការលើឧក្រិដ្ឋកម្ម មិនមែនសុទ្ធតែត្រូវបានកំណត់ដូចគ្នាដោយវិសាលភាពពេញលេញដែលអនុញ្ញាតក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ គោលការណ៍នីត្យានុកូលភាពមិនបានហាមឃាត់អង្គជំនុំជម្រះ ក្នុងការយោងទៅលើច្បាប់ទំនៀមទម្លាប់ដែលពុំមានសរសេរជាលាយលក្ខណ៍អក្សរ ឬការសម្រេចណាមួយធ្វើឡើងតាមរយៈដំណើរការនៃការបកស្រាយ និងការស្រាយបំភ្លឺចំពោះធាតុផ្សំនៃឧក្រិដ្ឋកម្មជាកំលាក់ណាមួយនោះទេ។ ទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. ដូចគ្នានឹងទម្រង់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ [...][289]។

អង្គជំនុំជម្រះនីមួយៗផ្សេងទៀតនៅ អ.វ.ត.ក. បានឯកភាពថា អ.វ.ត.ក. មានយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[290]។

ភាពខុសគ្នាមួយរវាងច្បាប់ អ.វ.ត.ក. និង កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា នោះគឺការយោងនៅក្នុងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជាទៅលើ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ ១៩៩៨" ក្នុងមាត្រា ៩ ដែលចែងលម្អិតអំពីឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក.។

មាត្រា ៥ នៃច្បាប់ អ.វ.ត.ក. មិនយោងទៅលើលក្ខន្តិកៈទីក្រុងរ៉ូមទេ ប៉ុន្តែកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជា "អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"[291]។

លក្ខន្តិកៈទីក្រុងរ៉ូម ដែលមាត្រា ៩ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ខុសពីច្បាប់ អ.វ.ត.ក. នៅក្នុងនិយមន័យរបស់ខ្លួនអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧទាហរណ៍ វាមិនរួមបញ្ចូលលក្ខខណ្ឌតម្រូវដែលថា ការវាយប្រហារត្រូវប្រព្រឹត្តឡើងដោយមូលហេតុរើសអើងណាមួយឡើយ ប៉ុន្តែគ្រាន់តែកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជា "អំពើណាមួយដូចខាងក្រោម ដែលប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហារជាលក្ខណៈប្រព័ន្ធ និងយ៉ាងរីករាលដាល សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយដឹងអំពីការវាយប្រហារនោះ"[292]។

សំណុំរឿង ០០២/០២ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធធាតុផ្សំអត្តនោម័តនៃការធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[293]។ ដូច្នេះ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រើនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ មិនអនុវត្តនៅ អ.វ.ត.ក. ទេ។

អង្គជំនុំជម្រះក៏បានពិចារណាលើអំណះអំណាងទាក់ទងនឹងលក្ខខណ្ឌតម្រូវទូទៅនៃមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. និងលើអត្ថិភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ (និងភាពអាចអនុវត្តបាននៅ អ.វ.ត.ក .) នៃឧក្រិដ្ឋកម្មជាមូលដ្ឋានផ្សេងៗទៀតប្រឆាំងនឹងមនុស្សជាតិ។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាដំបូងក្នុង

289 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ២៩០។

290 សូមមើលឧទាហរណ៍ សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ៩៨-១១២។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ កុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/3/15 កថាខណ្ឌ ១៣១, ១៣៣។

291 ច្បាប់ អ.វ.ត.ក. មាត្រា ៥។

292 លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧។

293 សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ៦៩០។

សំណុំរឿង ០០១ បានពិចារណាថាតើ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវការចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ក្នុងឆ្នាំ១៩៧៥ ដែរឬយ៉ាងណា ហើយបានសម្រេចថា ចំណងទាក់ទងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធមិនត្រូវការទេ[294]។ ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានធ្វើការសន្និដ្ឋានខុសពីនេះ[295] ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានរក្សាគោលជំហរពីមុនរបស់ខ្លួនដែលថា មិនតម្រូវឱ្យមានចំណងទាក់ទង ហើយគោលជំហរនេះត្រូវបានតម្កល់នៅដំណាក់កាលបណ្តឹងសាទុក្ខដោយអង្គជំនុំជម្រះតុលាការកំពូល[296]។

អត្ថិភាពនៃការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក ក៏ត្រូវបានពិចារណាផងដែរ។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានពិចារណាថា ការរំលោភសេពសន្ថវៈ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក[297] ប៉ុន្តែការកំណត់នេះត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល ដែលបានសន្និដ្ឋានថា ការពិនិត្យមើលទំនៀមទម្លាប់ និងអនុសញ្ញានៅមុន និងក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. បានបញ្ជាក់ថា ការរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកនៅពេលនោះទេ[298]។ នេះក៏ជាគោលជំហររបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០២ ផងដែរ[299]។

**ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក.**

| **សំណុំរឿង** | **ពិរុទ្ធភាពស្ថាពរ**[300] | **កំណត់សម្គាល់** |
|---|---|---|
| **សំណុំរឿង ០០១**<br>*កាំង ហ្គេកអ៊ាវ (ហៅ ឌុច)* | • ការសម្លាប់រង្គាល<br>• ការធ្វើឱ្យទៅជាទាសករ<br>• ការដាក់ក្នុងមន្ទីរឃុំឃាំង<br>• ការធ្វើទារុណកម្ម (រួមបញ្ចូល ការរំលោភសេពសន្ថវៈមួយករណី)<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ<br>• អំពើអមនុស្សធម៌ផ្សេងៗទៀត។ | នៅដំណាក់កាលបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការដាក់បញ្ចូលក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលខ្លួនរកឃើញថា ឌុច ទទួលខុសត្រូវ។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការដាក់ពិរុទ្ធភាពបន្ថែមចំពោះការសម្លាប់រង្គាល (ដោយរួមបញ្ចូលការធ្វើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត) |
| **សំណុំរឿង ០០២/០១**<br>*នួន ជា* | • ការសម្លាប់រង្គាល (រួមបញ្ចូលការធ្វើមនុស្សឃាត)<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ | នៅដំណាក់កាលបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធពិរុទ្ធភាពចំពោះ (i) ការសម្លាប់រង្គាលទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីមួយ) (ii) ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូល |

[294] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ២៩១-២៩២។
[295] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/3/15 កថាខណ្ឌ១៤៤។
[296] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ១៧៧។ សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៧២១។
[297] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៣៦១-៣៦៦។
[298] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ១៨០-១៨៣។
[299] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/3/15 កថាខណ្ឌ១៥៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ៣៧១។
[300] ទាំងនេះគឺជាការដាក់ពិរុទ្ធភាពដែលត្រូវបានចាត់ទុកថាស្ថាពរ បន្ទាប់ពីបណ្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូល និងផ្អែកទៅលើការអានសាលក្រម និងសាលដីកាទាំងមូល។

| | | |
|---|---|---|
| *ខៀវ សំផន* | • អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស)។ | ហេតុនយោបាយទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទីពីរ) និង (iii) ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងនឹងអង្គហេតុពាក់ព័ន្ធនឹង ទួលពោធិ៍ជ្រៃ។ |
| **សំណុំរឿង ០០២/០២**<br><br>*ខៀវ សំផន* | • ការធ្វើមនុស្សឃាត<br>• ការសម្លាប់រង្គាល<br>• ការធ្វើឱ្យទៅជាទាសករ<br>• ការនិរទេស<br>• ការដាក់ក្នុងមន្ទីរឃុំឃាំង<br>• ការធ្វើទារុណកម្ម<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា<br>• អំពើអមនុស្សធម៌ផ្សេងៗទៀត (តាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីលំនៅដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) | នៅដំណាក់កាលបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធពិរុទ្ធភាពនៃ (i) ការធ្វើមនុស្សឃាតនៅមន្ទីរសន្តិសុខភ្នំក្រោល និង (ii) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើប្រជាជនថ្មីនៅការដ្ឋានទំនប់ ១ មករា។<br><br>អង្គជំនុំជម្រះបានបដិសេធទម្រង់នៃការទទួលខុសត្រូវចំពោះការធ្វើមនុស្សឃាតនៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់ ១ មករា ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ដាក់ពិរុទ្ធភាពពីបទធ្វើមនុស្សឃាតដោយចេតនាប្រយោល ដែលបានប្រព្រឹត្តឡើងតាមរយៈសហឧក្រិដ្ឋកម្មរួម។<br><br>អង្គជំនុំជម្រះបានដាក់ពិរុទ្ធភាពបន្ថែមទៀតចំពោះបទអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលត្រូវបានកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបានកំណត់បទចោទបន្ថែម ជាអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងទម្រង់ជាអំពើហិង្សាផ្លូវភេទ ដែលបង្កើតបានជាការរួមភេទដោយបង្ខំក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ ទាក់ទងនឹងជនរងគ្រោះជាបុរស។ |
| **សំណុំរឿង ០០២/០២**<br><br>*នួន ជា* | • គ្មាន | នៅពេលជំនុំជម្រះ នួន ជា ត្រូវបានដាក់ពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចនឹង ខៀវ សំផន ដែរ។ នួន ជា បានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ខ្លួនជំទាស់ទៅនឹងពិរុទ្ធភាពនេះ ប៉ុន្តែ គាត់បានទទួលមរណភាពមុនដាក់បណ្តឹងសាទុក្ខរបស់គាត់។ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ថា មរណភាពរបស់ នួន ជា មិនទុកជាមោឃៈ សាលក្រមសំណុំរឿង ០០២/០២ ឡើយ និងថាក្នុងពេលជាមួយគ្នានេះ មិនមានសាលក្រមស្ថាពរស្តីពីពិរុទ្ធភាព ឬ ភាពគ្មានពិរុទ្ធរបស់ នួន ជា នោះទេ ដោយសារមរណភាពរបស់គាត់ បានរារាំងមិនឱ្យមានការពិនិត្យលើបណ្តឹងសាទុក្ខដោយ អង្គជំនុំជម្រះតុលាការកំពូល[301]។ |

## ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងៗទៀត ដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០២

[301] សូមមើល ជំពូក ៥.២.៧.៤.១។

| សំណុំរឿង | ឧក្រិដ្ឋកម្មចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត | ផ្នែកសម្រេចសេចក្តី |
|---|---|---|
| **សំណុំរឿង ០០២**<br><br>*អៀង សារី*<br><br>*អៀង ធីរិទ្ធ* | • ការធ្វើមនុស្សឃាត<br>• ការសម្លាប់រង្គាល<br>• ការធ្វើឱ្យទៅជាទាសករ<br>• ការនិរទេស<br>• ការដាក់ក្នុងមន្ទីរឃុំឃាំង<br>• ការធ្វើទារុណកម្ម<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា<br>• ការរំលោភសេពសន្ថវៈ<br>• អំពើអមនុស្សធម៌ផ្សេងៗទៀត (តាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ) | អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមានសម្បទាចូលរួមក្នុងសវនាការ។ រឿងក្តីរបស់គាត់ត្រូវបាន ***បញ្ចប់***បន្ទាប់ពីមរណភាពរបស់គាត់។<br><br>(សូមមើល ជំពូក ៥.២.៦.២)<br><br>រឿងក្តី អៀង សារី ត្រូវបាន***បញ្ចប់*** បន្ទាប់ពីមរណភាពរបស់គាត់។<br><br>(សូមមើល ជំពូក ៥.២.៦.៣) |

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់នៅក្នុងរឿងក្តីផ្សេងទៀត**

| សំណុំរឿង | ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ | ផ្នែកសម្រេចសេចក្តី |
|---|---|---|
| **សំណុំរឿង ០០៣**<br><br>*មាស មុត* | បទចោទផ្សេងៗ មាននៅក្នុងទីកតាំងជាច្រើន៖<br><br>• ការធ្វើមនុស្សឃាត<br>• ការសម្លាប់រង្គាល<br>• ការធ្វើឱ្យទៅជាទាសករ<br>• ការដាក់ក្នុងមន្ទីរឃុំឃាំង<br>• ការធ្វើទារុណកម្ម<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង ពូជសាសន៍<br>• អំពើអមនុស្សធម៌ផ្សេងៗទៀត (តាមរយៈ ការធ្វើបាបបែបអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ពល | ***រឿងក្តីត្រូវបានបញ្ចប់***<br><br>(សូមមើល ជំពូក ៥.៣.២) |

| | | |
|---|---|---|
| | កម្មដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភសេពសន្ថវ:) | |
| **សំណុំរឿង ០០៤**<br><br>*យឹម ទិត្យ* | បទចោទផ្សេងៗ មាននៅក្នុង ២៣ ទីតាំង៖<br><br>• ការធ្វើមនុស្សឃាត<br>• ការសម្លាប់រង្គាល<br>• ការធ្វើឱ្យទៅជាទាសករ<br>• ការដាក់ក្នុងមន្ទីរឃុំឃាំង<br>• ការធ្វើទារុណកម្ម<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ នឹង ពូជសាសន៍<br>• អំពើអមនុស្សធម៌ផ្សេងៗទៀត (តាមរយៈ ការជម្លៀសដោយបង្ខំ ការឃុំខ្លួន និងការធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) | ***រឿងក្តីត្រូវបានបញ្ចប់***<br><br>(សូមមើល ជំពូក ៥.៣.៣) |
| **សំណុំរឿង ០០៤/០១**<br><br>*អ៊ឹម ចែម* | បទចោទផ្សេងៗ មាននៅក្នុងពីរទីតាំង៖<br><br>• ការធ្វើមនុស្សឃាត<br>• ការសម្លាប់រង្គាល<br>• ការធ្វើឱ្យទៅជាទាសករ<br>• ការដាក់ក្នុងមន្ទីរឃុំឃាំង<br>•<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ<br>• អំពើអមនុស្សធម៌ផ្សេងៗទៀត (តាមរយៈ ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស) | ***ត្រូវបានលើកលែងចោទប្រកាន់***<br><br>(សូមមើល ជំពូក ៥.៣.៣.៥) |
| **សំណុំរឿង ០០៤/០២**<br><br>*អោ អាន* | បទចោទផ្សេងៗ មាននៅក្នុងប្រាំបួនទីតាំង៖<br><br>• ការធ្វើមនុស្សឃាត<br>• ការសម្លាប់រង្គាល<br>• ការធ្វើឱ្យទៅជាទាសករ<br>• ការដាក់ក្នុងមន្ទីរឃុំឃាំង | ***រឿងក្តីត្រូវបានបញ្ចប់***<br><br>(សូមមើល ជំពូក ៥.៣.៣.៦) |

| | | |
|---|---|---|
| | • ការធ្វើទារុណកម្ម<br>• ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង សាសនា<br>• អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមាន ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) | |

## ៣.៣.១.៤. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

មាត្រា ៦ នៃច្បាប់ អ.វ.ត.ក. ចែងថា អ.វ.ត.ក. ត្រូវមានយុត្តាធិការលើការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ "ដូចជាអំពើប្រឆាំងមនុស្ស ឬទ្រព្យសម្បត្តិ ដែលត្រូវការពារដោយបទប្បញ្ញត្តិនៃអនុសញ្ញានេះ 'ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩"៖

i. ការធ្វើមនុស្សឃាតដោយចេតនា
ii. ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
iii. ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
iv. ការបំផ្លាញ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិ ដោយមិនមានហេតុផលចាំបាច់ខាងយោធាដែលធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
v. ការបង្ខំឱ្យឈ្លើយសឹក ឬជនស៊ីវិល បម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
vi. ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់
vii. ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
viii. ការយកជនស៊ីវិលជាចំណាប់ខ្មាំង។

ក្នុងសំណុំរឿង ០០២ អង្គបុរេជំនុំជម្រះបានបង្ហាញថា ការទទួលខុសត្រូវក្រោមការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ អាចប្រមើលឃើញ និងអាចដឹងចំពោះជនជាប់ចោទ "ដោយហេតុថាមានសន្ធិសញ្ញាទាំងឡាយ ដែលប្រទេសកម្ពុជាចូលជាភាគី លក្ខណៈនៃច្បាប់ទំនៀមទម្លាប់ដែលមានតាំងពីមុនរួចមកហើយ ដែលបានយកមកដាក់បញ្ចូលនៅក្នុងសន្ធិសញ្ញាទាំងនោះ និងលក្ខណៈនៃសិទ្ធិនីមួយៗដែលត្រូវបានគេចោទប្រកាន់ថាបានរំលោភបំពាន"[302]។

ក្នុងសំណុំរឿង ០០២/០២ ជនជាប់ចោទត្រូវបានចោទពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវសម្រាប់អំពើដែលកើតឡើងក្នុងសហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស និងទាក់ទងទៅនឹងការប្រព្រឹត្តប្រឆាំងនឹងប្រជាជនវៀតណាម។ ទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរមួយចំនួន ដែលបានចោទប្រកាន់ និងបានបង្ហាញក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "លើកលែងតែលក្ខខណ្ឌតម្រូវទូទៅ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរតាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការឃុំខ្លួនដោយខុសច្បាប់ មានធាតុផ្សំគតិយុត្តិដូចគ្នា ជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំង"[303]។

### ពិរុទ្ធភាពចំពោះបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

[302] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/3/15 កថាខណ្ឌ១០៩-១១១។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ២៥៥ (និងកថាខណ្ឌក្រោយមកទៀត)។

[303] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤០០៧។

| សំណុំរឿង | ពិរុទ្ធភាពស្ថាពរ | កំណត់សម្គាល់ |
|---|---|---|
| **សំណុំរឿង ០០១**<br>*កាំង ហ្គេកអ៊ាវ (ហៅឌុច)*<br><br>**សំណុំរឿង ០០២/០២**<br>***ខៀវ សំផន*** | ទាក់ទងនឹងជនជាតិវៀតណាមដែលត្រូវបានការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ៖<br>• ការធ្វើមនុស្សឃាតដោយចេតនា<br>• ការធ្វើទារុណកម្ម<br>• ការធ្វើបាបដោយអមនុស្សធម៌<br>• ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព<br>• ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់<br>• ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ | ពិរុទ្ធភាពសម្រាប់បទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ មិនត្រូវបានប្ដឹងសាទុក្ខទៅកាន់អង្គជំនុំជំម្រះតុលាការកំពូលនោះទេ។ |
| **សំណុំរឿង ០០២/០២**<br>*នួន ជា* | គ្មាន | នៅពេលជំនុំជម្រះ នួន ជា ត្រូវបានដាក់ពិរុទ្ធភាពចំពោះបទបំពារបំពានយ៉ាងធ្ងន់ធ្ងរដូច ខៀវ សំផន ដែរ។ នួន ជា បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងពិរុទ្ធភាពនេះ ប៉ុន្ដែបានទទួលមរណភាពមុនពេលដាក់សារណាបណ្ដឹងសាទុក្ខរបស់គាត់។ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ថា មរណភាពរបស់ នួន ជា មិនទុកជាមោឃៈ សាលក្រមសំណុំរឿង ០០២/០២ ឡើយ និងថាក្នុងពេលជាមួយគ្នានេះ មិនមានសាលក្រមស្ថាពរស្ដីពីពិរុទ្ធភាព ឬ ភាពគ្មានពិរុទ្ធរបស់ នួន ជា នោះទេ ដោយសារមរណភាពរបស់គាត់ បានរារាំងមិនឱ្យមានការពិនិត្យលើបណ្ដឹងសាទុក្ខដោយ អង្គជំនុំជម្រះតុលាការកំពូល[304]។ |

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានចោទប្រកាន់ក្នុងសំណុំរឿង ០០២**

| សំណុំរឿង | ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ | ផ្នែកសម្រេចសេចក្ដី |
|---|---|---|

[304] សូមមើល ជំពូក ៥.២.៧.៤.១។

| | | |
|---|---|---|
| **សំណុំរឿង ០០២**<br><br>*អៀង សារី*<br><br>*អៀង ធីរិទ្ធ* | ទាក់ទងនឹងជនជាតិវៀតណាមដែលត្រូវបានការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ៖<br>• ការធ្វើមនុស្សឃាតដោយចេតនា<br>• ការធ្វើទារុណកម្ម<br>• ការធ្វើបាបដោយអមនុស្សធម៌<br>• ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព<br>• ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់<br>• ការនិរទេសដោយខុសច្បាប់ ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ | អៀង ធីរិទ្ធ ត្រូវបានរកឃើញថាមិនមានសម្បទាក្នុងការចូលរួមសវនាការ។ រឿងក្ដីរបស់គាត់ត្រូវបាន ***បញ្ចប់***បន្ទាប់ពីមរណភាពរបស់គាត់។<br><br>(សូមមើល ជំពូក ៥.២.៦.២)<br><br>រឿងក្ដី អៀង សារី ត្រូវបាន***បញ្ចប់*** បន្ទាប់ពីមរណភាពរបស់គាត់។<br><br>(សូមមើល ជំពូក ៥.២.៦.៣) |

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលបានចោទប្រកាន់ក្នុងសំណុំរឿងផ្សេងទៀត**

| **សំណុំរឿង** | **ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ** | **ផ្នែកសម្រេចសេចក្ដី** |
|---|---|---|
| **សំណុំរឿង ០០៣**<br><br>*មាស មុត* | ទាក់ទងនឹងជនជាតិវៀតណាម និងថៃ ដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ៖<br>• ការធ្វើមនុស្សឃាតដោយចេតនា<br>• ការធ្វើទារុណកម្ម<br>• ការបង្កដោយចេតនាឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព<br>• ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ | ***រឿងក្ដីត្រូវបានបញ្ចប់***<br><br>(សូមមើល ជំពូក ៥.៣.២) |

| | | |
|---|---|---|
| **សំណុំរឿង ០០៤**<br>*យឹម ទិត្យ* | ទាក់ទងនឹងជនជាតិវៀតណាមដែលត្រូវបានការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ៖<br>• ការធ្វើមនុស្សឃាតដោយចេតនា<br>• ការជម្លៀស ឬការនិរទេសជនស៊ីវិលដោយខុសច្បាប់ | ***រឿងក្តីត្រូវបានបញ្ចប់***<br>(សូមមើល ជំពូក ៥.៣.៣) |

## ៣.៣.២. យុត្តាធិការលើពេលវេលា

យុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក. យោងតាមមាត្រា ២(ថ្មី) នៃច្បាប់ អ.វ.ត.ក. និងមាត្រា ១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

យោងតាមក្រុមអ្នកជំនាញ "ការពិចារណាលើការរំលោភសិទ្ធិមនុស្ស ដោយភាគីណាមួយ មុន ឬក្រោយ រយៈពេលនោះ នឹងកាត់បន្ថយលក្ខណៈពិសេស និងវិសាមញ្ញនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ"[305]។

## ៣.៣.៣. យុត្តាធិការលើដែនដី

ទាំងច្បាប់ អ.វ.ត.ក. និងទាំងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មិនមានចែងយ៉ាងច្បាស់លាស់អំពីយុត្តាធិការលើដែនដីរបស់អង្គជំនុំជម្រះវិសាមញ្ញ។ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត បានពិចារណាថា យុត្តាធិការលើដែនដីរបស់ អ.វ.ត.ក. បានពង្រីកហួសព្រំដែនកម្ពុជា។ ក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២ សហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលជំពូកមួយស្តីពី "ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជាលើទឹកដីវៀតណាម" និងបានកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានប្តឹងមកសហចៅក្រមស៊ើបអង្កេត អំពីឧក្រិដ្ឋកម្មនានាដែលចោទប្រកាន់ថាបានប្រព្រឹត្តឡើងប្រឆាំងនឹងជនជាតិវៀតណាម ក្នុងអំឡុងពេលលុកលុយចូលទៅក្នុងទឹកដីវៀតណាម ដោយកងទ័ពបដិវត្តន៍កម្ពុជា[306]។ ដោយសារការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២ ការចោទប្រកាន់ទាំងនេះមិនត្រូវបានលើកយកមកជម្រះនៅពេលជំនុំជម្រះទេ[307]។

## ៣.៣.៤. យុត្តាធិការលើរូបបុគ្គល

មាត្រា ១ និង ២(ថ្មី) នៃច្បាប់ អ.វ.ត.ក. និងមាត្រា ១ និង ២(១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចែងថា អ.វ.ត.ក. មានយុត្តាធិការលើ "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជាធិបតេយ្យ និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលមានចែងក្នុងច្បាប់ អ.វ.ត.ក.[308]។ ពាក្យពេចន៍នេះត្រូវបានឯកភាព បន្ទាប់ពីការពិភាក្សាអស់រយៈពេលជាច្រើនឆ្នាំ។

---

305 *របាយការណ៍ក្រុមអ្នកជំនាញ* កថាខណ្ឌ១៤៩។

306 សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ៨៣២-៨៤០។

307 សូមមើល សំណុំរឿង ០០២/០២ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលទាក់ទងនឹងសំណុំរឿង ០០២/០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ E301/9/1.1 លើកឡើងថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជា លើទឹកដីវៀតណាម នឹងត្រូវដកចេញពីសំណុំរឿង ០០២/០២។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សេចក្តីសម្រេចស្តីពីការកាត់បន្ថយវិសាលភាពសំណុំរឿង ០០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ E439/5 ដែលបានបញ្ចប់កិច្ចដំណើរការនីតិវិធីទាក់ទងនឹងរាល់អង្គហេតុទាំងអស់ ដែលមានចែងក្នុងដីកាដំណោះស្រាយ ដែលមិនត្រូវបញ្ចូលក្នុងសំណុំរឿង ០០២/០១ ឬ ០០២/០២។

308 *ច្បាប់ អ.វ.ត.ក.* មាត្រា១, ២ (ថ្មី)។ *កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល* មាត្រា១, ២(១)។

ដំបូងឡើយ នៅក្នុងលិខិតផ្ញើទៅកាន់អគ្គលេខាធិការ អ.ស.ប. (“UNSG”) ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជា បានស្នើសុំជំនួយពី អ.ស.ប. និងសហគមន៍អន្តរជាតិដើម្បី “នាំយកមកវិនិច្ឆ័យទោស *ជនទាំងឡាយដែលទទួលខុសត្រូវ*ចំពោះអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេលគ្រប់គ្រងអំណាចរបស់ខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩”[309]។ ទោះបីជាសំណើនេះមិនបានកំណត់គោលដៅដែលចង់បានក្តី ក៏ អ.ស.ប. បានសង្ខេបសំណើរបស់កម្ពុជាថាជា “សំណើដំបូងរបស់កម្ពុជាទៅកាន់អង្គការសហប្រជាជាតិ ដើម្បីនាំខ្លួន*មេដឹកនាំខ្មែរក្រហម*មកជំនុំជម្រះ”[310]។

ក្រុមអ្នកជំនាញមានភារកិច្ចពិចារណាអំពីលទ្ធភាព ក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមមកវិនិច្ឆ័យ ដែលជាការឆ្លើយតបទៅនឹងសំណើរបស់កម្ពុជា។ របាយការណ៍ឆ្នាំ១៩៩៩ បានពិចារណាលើបញ្ហាថាតើនរណាគួរជា “គោលដៅនៃការស៊ើបអង្កេត” នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌនាពេលអនាគតប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម។ ប្រធានបទនេះគឺជាកម្មវត្ថុនៃការពិភាក្សាដ៏ទូលំទូលាយ ក្នុងការប្រជុំដែលក្រុមអ្នកជំនាញបានធ្វើឡើងជាមួយប្រជាជនកម្ពុជា ដែលបានផ្តល់យោបល់ ដោយមតិភាគច្រើនថា មានតែមេដឹកនាំខ្មែរក្រហមប៉ុណ្ណោះ គឺជាគោលដៅ ហើយមិនមែនកម្មាភិបាលថ្នាក់ទាបនោះទេ បើទោះបីជាកម្មាភិបាលថ្នាក់ទាបអាចបានប្រព្រឹត្តអំពើឃោរឃៅដោយផ្ទាល់ក្តី[311]។

ក្រុមអ្នកជំនាញបានធ្វើការសន្និដ្ឋានចំនួនប្រាំ៖

i. ពួកគេយល់ឃើញថា ផ្អែកលើបញ្ហាភស្តុភារ និងហិរញ្ញវត្ថុ តុលាការមិនអាចនាំខ្លួនមនុស្សភាគច្រើនដែលបានប្រព្រឹត្តការរំលោភលើច្បាប់អន្តរជាតិ ឬច្បាប់កម្ពុជាក្នុងអំឡុងរយៈពេលដែលពាក់ព័ន្ធនោះមកវិនិច្ឆ័យទោសបានទេ។ ការណ៍នេះក៏នឹងបង្អាក់ដល់កិច្ចខិតខំប្រឹងប្រែងបង្រួបបង្រួមជាតិ ហើយបញ្ហាគតិយុត្តិពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់អ្នកប្រព្រឹត្តបទល្មើសថ្នាក់ក្រោម មានលក្ខណៈស្មុគស្មាញខ្លាំង។

ii. ទោះបីជាពួកគេបានកត់សម្គាល់អំពីការព្រួយបារម្ភ ទាក់ទងនឹងការចោទប្រកាន់ជនទាំងឡាយដែលបានប្រគល់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលរួចហើយ ពួកគេមិនយល់ឃើញថាការប្រគល់ខ្លួននោះធានាឱ្យរួចផុតពីការចោទប្រកាន់នោះទេ។ ការណ៍នេះនឹងមើលរំលងគោលការណ៍ដែលថា ការទទួលខុសត្រូវព្រហ្មទណ្ឌ គួរតែភ្ជាប់ទៅនឹងកម្រិតនៃការទទួលខុសត្រូវជាបុគ្គល ហើយមិនមែនជាការប្រកាន់បក្សពួកនយោបាយរបស់បុគ្គលនោះទេ។ ជាងនេះទៀត ដោយសារតែមេដឹកនាំខ្មែរក្រហមស្ទើរតែទាំងអស់ បានប្រគល់ខ្លួនចុះចូល ដូច្នេះវាស្ទើរតែមិនមានការចោទប្រកាន់។

iii. ពួកគេមិនយល់ឃើញថា ពាក្យ “មេដឹកនាំ” គួរត្រូវបានប្រដូចទៅនឹងបុគ្គលនៅកម្រិតជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឡើយ ”ដោយសារបញ្ជីនេះអាចមិនស្របទៅនឹងបញ្ជីឈ្មោះអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្ស។

iv. តុលាការណាក៏ដោយ គួរផ្តោតលើជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះការរំលោភធ្ងន់ធ្ងរបំផុតលើសិទ្ធិមនុស្ស ក្នុងអំឡុងពេលកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ រួមទាំងមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយនៅថ្នាក់ទាប ដែលត្រូវបានចោទប្រកាន់ដោយផ្ទាល់ក្នុងអំពើឃោរឃៅធ្ងន់ធ្ងរបំផុត។ ពួកគេបានប៉ាន់ប្រមាណថា ក្រុមបុគ្គលប្រភេទនេះមានចំនួនចន្លោះពី ២០ ទៅ ៣០ នាក់។

v. ការសន្និដ្ឋានខាងលើមិនគួរបង្កើតជាធាតុផ្សំយុត្តាធិការរបស់តុលាការនោះទេ ប៉ុន្តែគួរតែជាសេចក្តីណែនាំសម្រាប់ព្រះរាជអាជ្ញា។ ដូច្នេះ លិខិតុបករណ៍ច្បាប់ដែលពាក់ព័ន្ធទៅនឹងតុលាការ គួរមានយុត្តាធិការលើជនណា ដែលអំពើរបស់ខ្លួនស្ថិតនៅក្នុងយុត្តាធិការរឿងក្តីរ

[309] UNGA/UNSC លិខិតដូចគ្នា ផ្ញើជូនប្រធាន UNGA និង UNSC ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧ A/51/930-S/1997/488 (គូសបញ្ជាក់បន្ថែម)។

[310] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៤៦ (យោងទៅ UNGA/UNSC លិខិតដូចគ្នា ផ្ញើជូនប្រធាន UNGA និង UNSC ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ A/53/850-S/1999/231 (គូសបញ្ជាក់បន្ថែម))។

[311] របាយការណ៍ក្រុមអ្នកជំនាញ កថាខណ្ឌ១០២-១០៣។

> បរស់តុលាការ ហើយការសម្រេចថាតើនរណាត្រូវចោទប្រកាន់ ឬយ៉ាងណានោះ គួរស្ថិតលើការសម្រេចចិត្តរបស់ព្រះរាជអាជ្ញា ផ្អែកតាមសេចក្តីណែនាំខាងលើ[312]។

នៅក្នុងការពិភាក្សាដេញដោលរបស់រដ្ឋសភាជាតិ ដែលនាំឱ្យមានការអនុម័តច្បាប់ អ.វ.ត.ក. ដំបូងនោះ ពាក្យពេចន៍នៃមាត្រា ១ ត្រូវបានបង្កើតឡើង (និងមិនបានផ្លាស់ប្តូរនាពេលក្រោយមក នៅក្នុងសំណៅចុងក្រោយនៃច្បាប់ អ.វ.ត.ក. នោះឡើយ)។

និយមន័យត្រឹមត្រូវនៃ “មេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ត្រូវបានដោះស្រាយនៅក្នុងករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក.។ ក្នុងសំណុំរឿង ០០១ ឌុច បានតវ៉ាថា គាត់មិនស្ថិតក្នុងក្រុមណាមួយនោះទេ[313]។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ពាក្យ “មេដឹកនាំជាន់ខ្ពស់” និង “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” សំដៅទៅលើក្រុមជនសង្ស័យពីរប្រភេទផ្សេងគ្នា[314]។ អង្គជំនុំជម្រះបានសន្និដ្ឋានថា អំពើ និងការប្រព្រឹត្តរបស់ ឌុច ធ្វើឱ្យគាត់ស្ថិតក្នុងចំណោមជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” ដែលធ្វើឱ្យអង្គជំនុំជម្រះមិនចាំបាច់សម្រេចថាតើ ឌុច គឺជា “មេដឹកនាំជាន់ខ្ពស់” នោះទេ[315]។

អង្គជំនុំជម្រះតុលាការកំពូល បានយោងទៅលើការចរចាររវាង អ.ស.ប. និង កម្ពុជា រួមមានរបាយការណ៍ក្រុមអ្នកជំនាញ និងបានពិចារណាថា ប្រវត្តិនៃការធ្វើសេចក្តីព្រាងបានបង្ហាញប្រភេទចំនួនពីរ គឺ មួយប្រភេទជា *មេដឹកនាំជាន់ខ្ពស់* ដែលទទួលខុសត្រូវខ្ពស់បំផុត និងមួយប្រភេទទៀតជា *អ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់* ដែលទទួលខុសត្រូវខ្ពស់បំផុត[316]។ ជនសង្ស័យនីមួយៗត្រូវតែជាកម្មាភិបាលខ្មែរក្រហម និងថាចំណុចនេះគឺជាបញ្ហាអង្គហេតុ ហេតុដូច្នេះគឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ដែលអាចវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[317]។

ជនសង្ស័យនីមួយៗក៏ត្រូវតែជា “អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត” ផងដែរ។ អង្គជំនុំជម្រះតុលាការកំពូល បានរកឃើញថា នេះ*មិន* មែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ដែលអាចវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងទេ ប៉ុន្តែគឺជាគោលនយោបាយផ្នែកស៊ើបអង្កេត និងចោទប្រកាន់ សម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តឆន្ទានុសិទ្ធិដាច់ដោយឡែករបស់ខ្លួន ក្នុងការស៊ើបអង្កេត និងការចោទប្រកាន់អ្នកប្រព្រឹត្តបទល្មើសដ៏ធ្ងន់ធ្ងរបំផុត ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[318]។ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធអំណះអំណាងដែលថា អត្ថន័យនៃពាក្យពេចន៍ “មេដឹកនាំជាន់ខ្ពស់” កំណត់ត្រឹមតែអតីតសមាជិកគណៈកម្មាធិការមជ្ឈិម[319]។

ចំពោះនិយមន័យនៃពាក្យ “ទទួលខុសត្រូវខ្ពស់បំផុត” អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០១ បានរកឃើញថា “អត្ថន័យធម្មតានៃ ‘ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត’ បង្ហាញនូវកម្រិតនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដោយប្រៀបធៀបជាមួយនឹងកម្មាភិបាលខ្មែរក្រហមទាំងអស់ ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.”[320]។ ទោះជាយ៉ាងណាដូចដែលអង្គជំនុំជម្រះបានរកឃើញ ពាក្យពេចន៍មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការទេ អង្គជំនុំជម្រះបានកត់សម្គាល់ថា គេមិនអាចកំណត់និយមន័យវា ឬស្វែងរកការបង្ហាញលក្ខណៈវិនិច្ឆ័យណាមួយឱ្យបានច្បាស់ ចំពោះថាតើ នរណាត្រូវបានចាត់ទុកថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះឡើយ។ ការណ៍នេះគឺជា

---

[312] របាយការណ៍ក្រុមអ្នកជំនាញ កថាខណ្ឌ១០៦-១១១។
[313] សំណុំរឿង ០០១ សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តី កាំង ហ្គេកអ៊ាវ ហៅ “ឌុច” ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F14 កថាខណ្ឌ១១-៦៥។ សូមមើលផងដែរ ជំពូក ៥.១.៦.១។
[314] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ២២។
[315] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២៣។
[316] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៥៧។
[317] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦១។
[318] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ជំពូក ៣(ក)(៥)(ខ)។
[319] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៧៦។
[320] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦២។

ការងាររបស់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត អនុលោមតាមមាត្រា ៥(៣) និង ៦(៣) នៃកិច្ចព្រមព្រៀង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា[321]។

សំណុំរឿង ០០៣, ០០៤, ០០៤/០១ និង ០០៤/០២ បានជួបបញ្ហាប្រឈមជាច្រើន ដោយសារការបកស្រាយផ្សេងគ្នាអំពីអត្ថន័យនៃឃ្លា "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[322]។ សហចៅក្រមស៊ើបអង្កេតជាតិប្រកាន់គោលជំហរថាពាក្យ "ទទួលខុសត្រូវខ្ពស់បំផុត" ត្រូវបានដាក់បញ្ចូលក្នុងច្បាប់ អ.វ.ត.ក. យ៉ាងជាក់លាក់ ដើម្បីឱ្យ ឌុច អាចត្រូវបានចោទប្រកាន់ និងថាការដាក់បញ្ចូលបុគ្គលផ្សេងទៀតនៅក្នុងប្រភេទនេះ នឹងពង្រីកវិសាលភាពហួសពីគោលបំណងដែលមានក្នុងពេលចរចា[323]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជំទាស់ ដោយសន្និដ្ឋានថា បុគ្គលទាំងឡាយក្នុងសំណុំរឿង ០០៣, ០០៤ និង ០០៤/០២ អាចត្រូវបានចាត់ទុកថាជា "ទទួលខុសត្រូវខ្ពស់បំផុត"[324]។ អង្គបុរេជំនុំជម្រះទាំងមូលបានពិចារណាថា "អត្តសញ្ញាណរបស់បុគ្គលដែលស្ថិតក្នុងប្រភេទទទួលខុសត្រូវខ្ពស់បំផុត រួមមានការវាយតម្លៃជាបរិមាណ និងគុណភាព ទៅលើទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម (ដែលរងការចោទ ឬត្រូវបានចោទប្រកាន់) និងកម្រិតនៃការទទួលខុសត្រូវរបស់ជនសង្ស័យ"[325] ប៉ុន្តែ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះក៏បានលើកឡើងផងដែរថា ពួកគេឯកភាពជាមួយសហចៅក្រមស៊ើបអង្កេតជាតិ ដោយកត់សម្គាល់ថា ប្រវត្តិនៃការធ្វើសេចក្តីព្រាងនៃច្បាប់ អ.វ.ត.ក. បានផ្តល់ជាយោបល់ថា ចំនួនមនុស្សដែលត្រូវកាត់ទោសដោយ អ.វ.ត.ក. គឺថេរ និងត្រូវបានផ្តួចផ្តើមរួចហើយ ហើយបុគ្គលម្នាក់ៗក្នុងចំណោមបុគ្គលទាំងនោះក៏ត្រូវបានជំនុំជម្រះរួចហើយដែរ ក្នុងសំណុំរឿង ០០១ និង ០០២[326]។ ដោយសារតែបញ្ហានីតិវិធី ដែលបណ្តាលមកពីការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាដោយសហចៅក្រមស៊ើបអង្កេត មិនមានរឿងក្តីណាក្នុងចំណោមរឿងក្តីទាំងនេះបានទៅដល់ដំណាក់កាលជំនុំជម្រះទេ[327]។

## ៣.៤. ទម្រង់នៃការទទួលខុសត្រូវ

ទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបាននៅ អ.វ.ត.ក. មានចែងក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក. ដែលសរសេរថា៖ "ជនសង្ស័យណាមួយ ដែលមានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និង ៨ នៃច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ"[328]។ មាត្រា ២៩ ក៏ចែងផងដែរថា អង្គហេតុដែលថាអំពើដែលលើក

---

[321] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ៦៣-៧៤។

[322] សូមមើល ជំពូក ៥.៣.១។

[323] សូមមើល សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D266 កថាខណ្ឌ ៣៩០-៤០៧។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381 កថាខណ្ឌ ៦៣២-៦៣៨។

[324] សូមមើល សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ។ សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360។

[325] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 កថាខណ្ឌ៦៥។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ៥៣។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ១៤០។

[326] សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ១២៨-១២៩។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360 យោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី កថាខណ្ឌ២២៣-២២៧។

[327] សូមមើល ជំពូក ៥.៣.២.១២, ៥.៣.៣.៥.៦, ៥.៣.៣.៦.៦, ៥.៣.៣.៧.៧។

[328] ច្បាប់ អ.វ.ត.ក. មាត្រា២៩ (គូសបញ្ជាក់បន្ថែម)។ ជាងនេះទៀត មាត្រា៤ នៃច្បាប់ អ.វ.ត.ក. យោងទៅ៖ "ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍"។ ទោះជាយ៉ាងណា បទល្មើសទាំងនេះត្រូវបានអង្គបុរេជំនុំជម្រះរកឃើញថាមិនបង្កើតបានជាទម្រង់នៃការទទួលខុសត្រូវដោយខ្លួនឯងផ្ទាល់នោះទេ ប៉ុន្តែផ្ទុយទៅវិញ វាគឺជាអំពើដែលអាចផ្តន្ទាទោសខុសៗគ្នាចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដូចគ្នានេះ។" សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១

ឡើងនៅក្នុងមាត្រាទាំងនោះ ត្រូវបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោម មិនបានធ្វើឱ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ ហើយអង្គហេតុដែលថាបុគ្គលម្នាក់បានប្រព្រឹត្តតាមបញ្ជារបស់ថ្នាក់លើ ឬរដ្ឋាភិបាល មិនបានធ្វើឱ្យបុគ្គលនោះរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយ[329]។ ផ្នែកទីមួយនៃបទប្បញ្ញត្តិនេះ ត្រូវបានបកស្រាយថាគ្របដណ្តប់លើទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ឬការទទួលខុសត្រូវរបស់មេបញ្ជាការ ដែលត្រូវបានដោះស្រាយលម្អិតបន្ថែមទៀតនៅផ្នែកខាងក្រោម។ ផ្នែកទីពីរនៃបទប្បញ្ញត្តិនេះ រារាំងការការពារដែលអាចបដិសេធការទទួលខុសត្រូវព្រហ្មទណ្ឌ នូវអំណះអំណាងដែលថាបុគ្គលម្នាក់បានប្រព្រឹត្តតាមការបញ្ជារបស់ថ្នាក់លើរបស់ខ្លួន[330]។

ទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម (“JCE”) មិនមានចែងច្បាស់លាស់នៅក្នុងច្បាប់ អ.វ.ត.ក. ទេ។ ទោះជាយ៉ាងណា ទម្រង់នេះត្រូវបានរកឃើញថាគឺជាទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ជាពិសេស អាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ[331]។

ផ្នែកខាងក្រោមរៀបរាប់អំពីការបកស្រាយរបស់ អ.វ.ត.ក. និងវិធីសាស្ត្រចំពោះទម្រង់នៃការទទួលខុសត្រូវនីមួយៗដែលអាចអនុវត្តបាន។

### ៣.៤.១.១. ការរៀបចំផែនការ

ទម្រង់នៃការទទួលខុសត្រូវតម្រូវថា “បុគ្គលម្នាក់ ឬច្រើននាក់ បានរៀបចំប្រព្រឹត្តអំពើឧក្រិដ្ឋ ហើយក្រោយមកការប្រព្រឹត្តិអំពើទាំងនោះ បង្កើតឱ្យមានឧក្រិដ្ឋកម្មមួយ ឬច្រើន”[332]។ ការរៀបចំផែនការត្រូវតែកើតឡើងមុន និងជាកត្តាចូលរួមចំណែកសំខាន់ចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្ម ហើយជនជាប់ចោទត្រូវតែមានចេតនាឱ្យឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តឡើង ឬបានដឹងអំពីលទ្ធភាពខ្លាំងខ្លាដែលថាឧក្រិដ្ឋកម្មនោះនឹងត្រូវបានប្រព្រឹត្តឡើង[333]។

ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរៀបចំផែនការកើតឡើង “នៅពេលដែលបុគ្គលម្នាក់ ឬច្រើននាក់ បានគូសវាសនូវផែនការសកម្មភាពឧក្រិដ្ឋ ដែលបង្កជាឧក្រិដ្ឋកម្មមួយ ឬច្រើន។ សកម្មភាពនេះត្រូវតែជាមូលហេតុដែលនាំឱ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់”[334]។ វាមិនចាំបាច់បង្ហាញថា បើគ្មានផែនការរបស់ជនជាប់ចោទ បទឧក្រិដ្ឋនោះមិនត្រូវបានប្រព្រឹត្តនោះឡើយ។ ចំពោះឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ (ដូចជា អំពើប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ) វាត្រូវតែរកឱ្យឃើញថា ជនជាប់ចោទមានចេតនាដែលតម្រូវ។ ទម្រង់នៃការទទួលខុសត្រូវនៃការរៀបចំផែនការ តម្រូវឱ្យមានអំពើសកម្មមួយកើតឡើងជាក់ស្តែង[335]។

---

ឯកសារ D427/1/30 កថាខណ្ឌ៧៩។ ក្នុងរឿងក្តីនៅចំពោះមុខ អ.វ.ត.ក. មិនមានបុគ្គលណាត្រូវបានចោទប្រកាន់ ឬដាក់ពិរុទ្ធពីបទប៉ុនប៉ង ឬបទសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ។

329 ច្បាប់ អ.វ.ត.ក. មាត្រា២៩។

330 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥៥០ និងបន្តបន្ទាប់។

331 សូមមើលឧទាហរណ៍ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ៣៧០៦។ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩០។ សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥១១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ២៦០ យោងទៅ សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ១៣១៨, ១៥២១។ សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិការ ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ១១៦។

332 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥១៨។ សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ៨០។

333 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥១៨។ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩៨។ សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ៨០។

334 សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ១៥៤៤។

335 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ៣៧១៧។

នៅ អ.វ.ត.ក. មិនមានការដាក់ពិរុទ្ធភាពក្រោមទម្រង់នៃការទទួលខុសត្រូវនេះទេ ដោយសារជនជាប់ចោទត្រូវបានរកឃើញថា ទទួលខុសត្រូវក្រោមទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម ("JCE") ជំនួសវិញ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះបានពិនិត្យភស្តុតាងដែលថា ជនជាប់ចោទបានរៀបចំផែនការឧក្រិដ្ឋកម្មជាមូលដ្ឋាន ក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១៖

- **កាំង ហ្កេកអ៊ាវ (ហៅ ឌុច)៖** បានរៀបចំផែនការទីកន្លែង និងមុខងាររបស់មន្ទីរសន្តិសុខ ស-២១ និងបានជ្រើសរើស ជើងឯក ធ្វើជាទីតាំងសម្លាប់មនុស្ស[336]
- **នួន ជា៖** បានរៀបចំផែនការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ (ដំណាក់កាលទី១)[337] និងក្រោយមកការផ្លាស់ទីលំនៅប្រជាជនទូទាំងប្រទេស (ដំណាក់កាលទី២)[338]
- **ខៀវ សំផន៖** បានរៀបចំផែនការជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ (ដំណាក់កាលទី១)[339] និងក្រោយមកការផ្លាស់ទីលំនៅប្រជាជនទូទាំងប្រទេស (ដំណាក់កាលទី២)[340]

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះការរៀបចំផែនការឧក្រិដ្ឋកម្ម ត្រូវកំណត់ប្រភេទថាជា*ការប្រព្រឹត្ត*តាមរយៈទម្រង់ JCE ព្រោះវាមានភាពត្រឹមត្រូវ និងសមស្របជាង ហើយបានបន្តពិនិត្យអង្គហេតុទាំងនេះក្រោមការទទួលខុសត្រូវក្នុងទម្រង់ JCE[341]។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬបញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថា មានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាក្នុងការចោទប្រកាន់ពីបទការរៀបចំផែនការឧក្រិដ្ឋកម្មខាងក្រោម៖

- **មាស មុត៖** ការរៀបចំផែនការ ជំនួសឱ្យការទទួលខុសត្រូវតាម JCE៖
    - អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម[342]
    - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបយ៉ាងអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ពលកម្មដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ) នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ និងតំបន់កំពង់សោម មន្ទីរសន្តិសុខចំនួនបី (រួមទាំង ស-២១) ការដ្ឋានចំនួនពីរ ទីតាំងសម្លាប់មនុស្សមួយកន្លែង និងកន្លែងផ្សេងៗទៀត ហើយជាពិសេសទាក់ទងទៅនឹងការបោសសម្អាតកងពល ១៦៤ និង ១១៧[343]
    - ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាម និងថៃ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[344]

[336] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥២១។
[337] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.១.១។
[338] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.២.១។
[339] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៦.៣.១.១។
[340] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៦.៣.២.១។
[341] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤១៧៧-៤១៧៩, ៤៣០៩-៤៣១១។
[342] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទ ១)។
[343] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី ២)។
[344] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី៣)។

- អំពើមនុស្សឃាតគិតទុកជាមុន ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅក្នុងបរិបទចំនួនប្រាំពីរ (លើកលែងតែទាក់ទងនឹងកងពល ៥០២ និង ៣១០)[345]។

- **អ៊ឹម ចែម**៖ ការរៀបចំផែនការអំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស)[346]
- **អោ អាន**៖ ការរៀបចំផែនការ ជំនួយឱ្យការទទួលខុសត្រូវតាម JCE៖
  - អំពើប្រល័យពូជសាសន៍លើជនជាតិចាម នៅក្នុងខេត្តកំពង់ចាម[347]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅទីតាំងចំនួនប្រាំបី៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[348]
  - អំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅទីតាំងចំនួនបួន[349]។
- **យឹម ទិត្យ**៖ ការរៀបចំផែការ រួមផ្សំជាមួយនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត៖
  - អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម (១១ ករណី)[350]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (២២ ករណី) រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ 'ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ ការឃុំខ្លួន និងធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[351]
  - ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (បួនករណី)[352]
  - អំពើមនុស្សឃាតគិតទុកជាមុនក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (២១ ករណី)[353]។

### ៣.៤.១.២. ការញុះញង់

ទម្រង់នៃការទទួលខុសត្រូវនៃការញុះញង់ "តម្រូវថា បុគ្គលម្នាក់តាមរយៈអំពើសកម្ម ឬអកម្ម ជំរុញបុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម"[354]។ តម្រុយនោះអាចជាអំពើស្ងៀមស្ងាត់ ជាលាយលក្ខណ៍អក្សរ ឬមិនផ្ទាល់មាត់[355]។

---

345 សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី៤)។

346 សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ៤។

347 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី១)។

348 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី២)។

349 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី៣)។

350 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី១)។

351 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី២)។

352 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី៣)។

353 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី៤)។

354 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥២២។

355 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥២២។

អ្នកញុះញង់ត្រូវតែបានធ្វើលើសពីការដែលគ្រាន់តែសម្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលផ្ទុយទៅនឹងការជួយនិងជំរុញ។ ការញុះញង់ត្រូវតែជាកត្តាចូលរួមចំណែកយ៉ាងសំខាន់ ដល់ការប្រព្រឹត្តបទឧក្រិដ្ឋ[356] ។ ជនជាប់ចោទ "ត្រូវតែមានចេតនាបង្កហេតុ ឬនាំហេតុឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងអំពីភាពសំខាន់ដែលថាឧក្រិដ្ឋកម្មទំនងនឹងត្រូវបានប្រព្រឹត្តដោយសារការញុះញង់"[357]។ ការញុះញង់ត្រូវតែបានកើតឡើងមុនការប្រព្រឹត្តឧក្រិដ្ឋកម្ម[358]។

ផ្ទុយទៅនឹងការបញ្ជា ការញុះញង់មិនតម្រូវថា ជនជាប់ចោទមានសិទ្ធិអំណាចណាមួយលើចារីនោះទេ[359]។ ទោះជាយ៉ាងណា "ការខកខានរបស់ថ្នាក់លើម្តងហើយម្តងទៀតក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើចារីចំពោះឧក្រិដ្ឋកម្មអាចមានន័យស្មើនឹងការញុះញង់ឱ្យចារីប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមផ្សេងទៀត"[360]។ ទោះបីជាសំណៅជាភាសាខ្មែរ និងបារាំងនៃមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក. សំដៅលើ "ការញុះញង់" អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សញ្ញាណនៃពាក្យថា ការជំរុញ និងការញុះញង់ ត្រូវបានចាត់ទុកថាជាពាក្យមានន័យដូចគ្នា[361]។

នៅ អ.វ.ត.ក. មិនមានការដាក់ពិរុទ្ធភាពក្រោមទម្រង់នៃការទទួលខុសត្រូវនេះទេ ដោយសារជនជាប់ចោទត្រូវបានរកឃើញថាទទួលខុសត្រូវក្រោមទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ("JCE") ជំនួសវិញ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះវិសាមញ្ញ បានពិនិត្យភស្តុតាងដែលថា ជនជាប់ចោទបានញុះញង់ឱ្យមានឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០២៖

- **កាំង ហ្កេកអ៊ាវ (ហៅ ឌុច)**៖ បានញុះញង់ឱ្យមានឧក្រិដ្ឋកម្មតាមរយៈការបញ្ចូលមនោគមន៍វិជ្ជាដល់បុគ្គលិក ស-២១ ឱ្យឃោរឃៅ និងចាត់ទុកអ្នកជាប់ឃុំទាំងអស់ដូចជាខ្មាំង និងតាមរយៈការផ្តល់ការបណ្តុះបណ្តាលជាក់ស្តែងដល់អ្នកសួរចម្លើយ លើការប្រើហិង្សាលើរាងកាយ និង ស្មារតី[362]
- **នួន ជា**៖ បានជំរុញ និងបានចូលរួមចំណែកដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលការជម្លៀសប្រជាជនចេញពីភ្នំពេញ (ដំណាក់កាលទី១)[363] និងការផ្លាស់ទីលំនៅប្រជាជនទូទាំងប្រទេសជាបន្តបន្ទាប់ (ដំណាក់កាលទី២)[364]
- **ខៀវ សំផន**៖ បានញុះញង់ និងបានចូលរួមចំណែកដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលការជម្លៀសប្រជាជនចេញពីភ្នំពេញ (ដំណាក់កាលទី១)[365] និងការផ្លាស់ទីលំនៅប្រជាជនទូទាំងប្រទេសជាបន្តបន្ទាប់ (ដំណាក់កាលទី២)[366]

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះការញុះញង់ឱ្យមានឧក្រិដ្ឋកម្ម ត្រូវកំណត់ប្រភេទថាជា*ការប្រព្រឹត្ត*តាមរយៈទម្រង់ JCE ព្រោះវាមានភាពត្រឹមត្រូវ និងសមស្របជាង ហើយបានបន្តពិនិត្យអង្គហេតុទាំងនេះក្រោមការទទួលខុសត្រូវក្នុងទម្រង់ JCE[367]។

---

356 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥២២។
357 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥២៤។
358 សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ៨១។
359 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥២២។
360 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥២៣។
361 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩៩។
362 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥២៦។
363 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.១.៣។
364 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.២.៣។
365 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៦.៣.១.៤។
366 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៦.៣.២.៣។
367 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ៤១៧៧-៤១៧៩, ៤៣០៩-៤៣១១។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬបញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថា មានភ័ស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាក្នុងការចោទប្រកាន់ពីបទញុះញង់ឱ្យមានឧក្រិដ្ឋកម្មខាងក្រោម៖

- **អ៊ឹម ចែម**៖ អំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស)[368]។
- **អោ អាន**៖ ជំនួសឱ្យការទទួលខុសត្រូវតាម JCE៖
  - អំពើប្រល័យពូជសាសន៍លើជនជាតិចាម ក្នុងខេត្តកំពង់ចាម[369]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាតនៅទីតាំងចំនួនប្រាំបី៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[370]។
- **យឹម ទិត្យ**៖ ការញុះញង់ រួមផ្សំជាមួយនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត៖
  - អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម (ប្រាំបីករណី) [371]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (១៨ ករណី) រួមមានការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ ការឃុំខ្លួន និងការធ្វើពលកម្មក្នុងលក្ខខណ្ឌអមនុស្សធម៌ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[372]។
  - ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (ពីរករណី) រួមមានការធ្វើមនុស្សឃាតដោយចេតនា និងការផ្លាស់ទីលំនៅប្រជាជនដោយខុសច្បាប់[373]។

### ៣.៤.១.៣. ការបញ្ជា

ទម្រង់នៃការទទួលខុសត្រូវចំពោះការបញ្ជាតម្រូវថា “បុគ្គលម្នាក់ក្នុងឋានៈជាអ្នកមានអំណាចបង្គាប់បុគ្គលផ្សេងទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ជាផ្លូវការរវាងបុគ្គលទាំងពីរ មិនមែនជាលក្ខខណ្ឌចាំបាច់នោះទេ។ បុគ្គលដែលបញ្ជា ត្រូវតែមានអំណាចតាមផ្លូវច្បាប់ ឬតាមអង្គហេតុ ក្នុងការបញ្ជាឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម”[374]។ បញ្ជានោះអាចត្រូវបានចេញ ផ្តល់អំណាច ឬ ផ្ទេរបញ្ជា រួមទាំងតាមរយៈអន្តរការី។ ការបញ្ជាអាចជាទម្រង់ណាមួយ ហើយអត្ថិភាពរបស់វាអាចត្រូវបានបញ្ជាក់តាមរយៈភ័ស្តុតាងកាលៈទេសៈ[375]។ ការចេញបញ្ជាត្រូវតែជាកត្តាចូលរួមចំណែកដ៏សំខាន់ទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយជនជាប់ចោទត្រូវតែមានបំណង ឬបានដឹងអំពីភវនីយភាពជាសំខាន់ ថាឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តឡើង[376]។

---

368 សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ៤។

369 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី១)។

370 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី២)។

371 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី១)។

372 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី២)។

373 សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី៣)។

374 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥២៧។

375 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥២៧។

376 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥២៧-៥២៨។

នៅ អ.វ.ត.ក. មិនមានការដាក់ពិរុទ្ធភាពក្រោមទម្រង់នៃការទទួលខុសត្រូវនេះទេ ដោយសារជនជាប់ចោទត្រូវបានរកឃើញថាទទួលខុសត្រូវក្រោមទ្រឹស្តីសហឧក្រិដ្ឋកម្មរួម (“JCE”) ជំនួសវិញ។ ទោះជាយ៉ាងណា ជាផ្នែកមួយនៃការវាយតម្លៃរបស់ខ្លួនលើ JCE អង្គជំនុំជម្រះវិសាមញ្ញ បានពិនិត្យភស្តុតាងដែលថាជនជាប់ចោទបានបញ្ជាឱ្យមានឧក្រិដ្ឋកម្មជាមូលដ្ឋាននៅក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១៖

- **កាំង ហ្គេកអ៊ាវ (ហៅ ឌុច)**៖ បានបញ្ជាឱ្យមានឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខ ស-២១ តាមរយៈការចេញបញ្ជា ផ្តល់អំណាច ឬ ផ្ទេរបញ្ជា ទៅបុគ្គលិកឱ្យចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់អ្នកជាប់ឃុំ[377]
- **នួន ជា**៖ បានបញ្ជា និងបានចូលរួមចំណែកដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីភ្នំពេញ (ដំណាក់កាលទី១)[378] និងការផ្លាស់ទីលំនៅប្រជាជនទូទាំងប្រទេសជាបន្តបន្ទាប់ (ដំណាក់កាលទី២)[379]។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន ចំពោះការបញ្ជាឱ្យមានឧក្រិដ្ឋកម្ម ត្រូវកំណត់ប្រភេទថាជា*ការប្រព្រឹត្ត*តាមរយៈទម្រង់ JCE ព្រោះវាមានភាពត្រឹមត្រូវ និងសមស្របជាង ហើយបានបន្តពិនិត្យអង្គហេតុទាំងនេះក្រោមការទទួលខុសត្រូវក្នុងទម្រង់ JCE[380]។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬបញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថា មានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាក្នុងការចោទប្រកាន់ពីបទបញ្ជាឱ្យមានឧក្រិដ្ឋកម្មខាងក្រោម៖

- **មាស មុត**៖ ជំនួសឱ្យការទទួលខុសត្រូវតាម JCE៖
  - អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម[381]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ពលកម្មដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ) នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ និងតំបន់កំពង់សោម មន្ទីរសន្តិសុខចំនួនបី (រួមទាំង ស-២១) ការដ្ឋានចំនួនពីរ ទីតាំងសម្លាប់មនុស្សមួយ និងកន្លែងផ្សេងៗទៀត ហើយជាពិសេសទាក់ទងទៅនឹងការបោសសម្អាតកងពល ១៦៤ និង ១១៧[382]
  - ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាម និងថៃ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[383]
  - អំពើមនុស្សឃាតគិតទុកជាមុន ក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅក្នុងបរិបទចំនួនប្រាំពីរ (លើកលែងតែទាក់ទងនឹងកងពល ៥០២ និង ៣១០)[384]។

---

[377] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣១។
[378] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.១.២។
[379] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.២.២។
[380] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤១៧៧-៤១៧៩, ៤៣០៩-៤៣១១។
[381] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី១)។
[382] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី២)។
[383] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី៣)។
[384] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ឯកសារ (បទចោទទី៤)។

- **អ៊ឹម ចែម**៖ អំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស)។[385]
- **អោ អាន**៖ ជំនួសឱ្យការទទួលខុសត្រូវតាម JCE៖
  - អំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅទីតាំងចំនួនបួន[386]
  - អំពើប្រល័យពូជសាសន៍លើជនជាតិចាម នៅក្នុងខេត្តកំពង់ចាម[387]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត នៅទីតាំងចំនួនប្រាំបី៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)។[388]
- **យឹម ទិត្យ**៖ ការបញ្ជា រួមផ្សំជាមួយនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត៖
  - អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម (ប្រាំបី ករណី)[389]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (១៨ ករណី) រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ ការឃុំខ្លួន និងធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[390]
  - ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (ពីរករណី) រួមទាំងការធ្វើមនុស្សឃាតដោយចេតនា និងការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់[391]
  - អំពើមនុស្សឃាតគិតទុកជាមុនក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (១៨ ករណី)[392]។

### ៣.៤.១.៤. ការជួយ និងជំរុញ

ទម្រង់នៃការទទួលខុសត្រូវនៃការជួយ និងជំរុញ មានការជួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រខាងស្មារតី ដែលមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ចារី។ ការជួយពាក់ព័ន្ធនឹងការផ្តល់ជំនួយ ចំណែកឯការជំរុញ ពាក់ព័ន្ធទៅនឹង "ការជួយសម្រួលឱ្យប្រព្រឹត្តអំពើណាមួយដោយសារតែ (ការលើកទឹកចិត្ត)"[393]។

មិនមានលក្ខខណ្ឌតម្រូវឱ្យមានផែនការ ឬ ការព្រមព្រៀងរវាងអ្នកជួយ និងអ្នកជំរុញ និងចារីនោះទេ។ ឧក្រិដ្ឋកម្មត្រូវតែបានប្រព្រឹត្តឡើង ដើម្បីឱ្យជនជាប់ចោទត្រូវបានដាក់ពិរុទ្ធភាពពីបទជួយ និងជំរុញ

---

[385] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ៤។

[386] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី៣)។

[387] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី១)។

[388] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី២)។

[389] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី១)។

[390] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី២)។

[391] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី៣)។

[392] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី៤)។

[393] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣៣។

ឧក្រិដ្ឋកម្មនោះ ប៉ុន្តែចារីមិនចាំបាច់ត្រូវបានជំនុំជម្រះ ឬកំណត់អត្តសញ្ញាណនោះទេ[394]។ ជនជាប់ចោទត្រូវតែដឹងថាឧក្រិដ្ឋកម្មប្រហែលជាអាចត្រូវបានប្រព្រឹត្តឡើង ឧក្រិដ្ឋកម្មពិតជាត្រូវបានប្រព្រឹត្តឡើងមែន ហើយជនជាប់ចោទត្រូវតែដឹងថា អំពើរបស់ខ្លួនបានជួយដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[395]។ ជនជាប់ចោទត្រូវតែបានដឹងអំពីចេតនារបស់ចារី ទោះបីជាគាត់មិនមានចេតនាបែបនោះក្តី[396]។

ការជួយ និងជំរុញ ក៏អាចមានទម្រង់ជាការទទួលខុសត្រូវចំពោះអំពើអកម្មដែលនាំឱ្យមានពិរុទ្ធ។ ដូចដែលបញ្ជាក់ដោយអង្គជំនុំជម្រះសាលាដំបូង ឯកសារសម័យ Nuremberg៖

> ទទួលស្គាល់ថា ជនជាប់ចោទអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើអកម្មដែលបានជួយ និងជំរុញដល់ការប្រព្រឹត្តបទឧក្រិដ្ឋ។ ការណ៍ដែលថា តើអំពើអកម្មបាន ឬមិនបានជួយ ឬជំរុញឱ្យមានបទឧក្រិដ្ឋនោះ វាជាបញ្ហាដែលត្រូវយកមកកំណត់ទៅតាមករណីនីមួយៗ។ ការកំណត់នេះនឹងទំនងជាត្រូវពិនិត្យទៅលើតួនាទី និងអំណាចរបស់ជនជាប់ចោទ[397]។

អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា ទោះបីជាសំណៅជាភាសាបារាំងនៃមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក. ប្រដូចការជួយ និងជំរុញ ជាមួយសញ្ញាណនៃពាក្យ ការញុះញង់ ក៏ដោយ ក៏ពាក្យការញុះញង់អាចគ្របដណ្តប់អំពើទូលំទូលាយជាង ហើយឃ្លា *"aidé et encouragé"* ឆ្លុះបញ្ចាំងច្បាស់លាស់អំពីលក្ខណៈទម្រង់នៃការទទួលខុសត្រូវនេះ ជាងសញ្ញាណនៃពាក្យ *"complicité"*[398]។

នៅ អ.វ.ត.ក. មានការដាក់ពិរុទ្ធភាពមួយត្រូវបានកត់ត្រាតាមទម្រង់នៃការទទួលខុសត្រូវនេះ ដោយសារតែជនជាប់ចោទ ភាគច្រើនត្រូវបានរកឃើញថាទទួលខុសត្រូវក្រោមទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ("JCE") ជំនួសវិញ។

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការទទួលខុសត្រូវរបស់ នួន ជា និង ខៀវ សំផន សម្រាប់ការជួយ និងជំរុញឧក្រិដ្ឋកម្មមួយចំនួនធំទូទាំងប្រទេស ត្រូវកំណត់ប្រភេទថាជា *ការប្រព្រឹត្ត*តាមរយៈទម្រង់ JCE ព្រោះវាមានភាពត្រឹមត្រូវ និងសមស្របជាង ហើយបានបន្តពិនិត្យអង្គហេតុពាក់ព័ន្ធក្រោមការទទួលខុសត្រូវក្នុងទម្រង់ JCE[399]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះជឿជាក់ថា អង្គហេតុទាក់ទងនឹងការស្លាប់ ដែលបណ្តាលមកពីលក្ខខណ្ឌនៅតាមសហករណ៍ ការដ្ឋាន និងមន្ទីរសន្តិសុខ មិនអាចស្ថិតនៅក្នុងគោលបំណងរួមនៃ JCE នោះទេ (ហើយ ហេតុដូច្នេះ មិនអាចទាក់ទាញការទទួលខុសត្រូវតាមទម្រង់ JCE នោះឡើយ) និងហេតុដូច្នេះបានដាក់ពិរុទ្ធភាព នួន ជា និង ខៀវ សំផន ពីបទ*ការជួយ និងជំរុញ* ដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយ*ចេតនាមិនផ្ទាល់ (ផ្លូវច្បាប់)* នៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា ការដ្ឋានទំនប់ត្រពាំងថ្ម ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល[400]។ នៅដំណាក់កាលបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ថាមិនត្រឹមត្រូវ ហើយបានកំណត់បទចោទឡើងវិញចំពោះការទទួលខុសត្រូវរបស់ ខៀវ សំផន លើឧក្រិដ្ឋកម្មទាំងអស់នេះ ទៅជាការទទួលខុសត្រូវក្រោមទម្រង់ JCE វិញ[401]។

---

394 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣៤។
395 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣៥។
396 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣៥។
397 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៧០៦។
398 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣២។
399 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤១៧៧-៤១៧៩, ៤៣០៩-៤៣១១។
400 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ជំពូក ១៧.៣.១, ១៨៣.១។
401 សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ជំពូក ៨(ខ)(៩)(ខ)។

ដោយសារតែ នួន ជា បានស្លាប់មុនបណ្តឹងសាទុក្ខ ពិរុទ្ធភាពរបស់គាត់ពីបទការជួយ និងជំរុញដល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ដោយមាន*ចេតនាមិនផ្ទាល់ (ផ្លូវច្បាប់)* នៅតាមទីតាំងទាំងអស់នេះ នៅតែមាន ប៉ុន្តែមិនត្រូវបានចាត់ទុកថាជាពិរុទ្ធភាពស្ថាពរទេ[402]។

ក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១ អង្គជំនុំជម្រះវិសាមញ្ញ បានពិនិត្យភ័ស្តុតាងថា ជនជាប់ចោទបានជួយ និងជំរុញដល់ឧក្រិដ្ឋកម្ម ប៉ុន្តែធ្វើការដាក់ពិរុទ្ធភាពតែតាមរយៈការទទួលខុសត្រូវតាមទម្រង់ JCE តែប៉ុណ្ណោះ។

- **កាំង ហ្គេកអ៊ាវ (ហៅ ឌុច)**៖ បានជួយ និងបានជំរុញដល់ឧក្រិដ្ឋកម្មតាមរយៈការផ្តល់ជំនួយជាក់ស្តែង ការលើកទឹកចិត្ត និង ការគាំទ្រផ្នែកស្មារតីដល់បុគ្គលិកមន្ទីរសន្តិសុខ ស-២១[403]
- **នួន ជា**៖ បានជួយ និងបានជំរុញដល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ក្នុងអំឡុងពេលការជម្លៀសប្រជាជនចេញពីភ្នំពេញ (ដំណាក់កាលទី ១)[404] និងការផ្លាស់ទីលំនៅប្រជាជនទូទាំងប្រទេសជាបន្តបន្ទាប់ (ដំណាក់កាលទី២)[405]។
- **ខៀវ សំផន**៖ បានជួយ និងបានជំរុញដល់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ក្នុងអំឡុងពេលការជម្លៀសប្រជាជនចេញពីភ្នំពេញ (ដំណាក់កាលទី ១)[406] និងការផ្លាស់ទីលំនៅប្រជាជនទូទាំងប្រទេសជាបន្តបន្ទាប់ (ដំណាក់កាលទី២)[407]។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬបញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថា មានភ័ស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាក្នុងការចោទប្រកាន់ពីបទបញ្ជាឱ្យមានឧក្រិដ្ឋកម្មខាងក្រោម៖

- **អ៊ឹម ចែម**៖ អំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស)[408]

### ៣.៤.១.៥. ការប្រព្រឹត្តឧក្រិដ្ឋកម្ម

ទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម (លើកលែងតាមរយៈទម្រង់ JCE ដែលត្រូវបានពិភាក្សាដាច់ដោយឡែកខាងក្រោម) មានការប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់ ឬដោយអំពើអកម្មដែលនាំឱ្យមានពិរុទ្ធ។ ចារីត្រូវតែបានមានចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបានដឹងជាសំខាន់ថាឧក្រិដ្ឋកម្មទំនងជាកើតមានឡើងជាលទ្ធផលនៃអំពើនោះ[409]។ ទាក់ទងនឹងអំពើអកម្មដែលនាំឱ្យមានពិរុទ្ធ អង្គជំនុំជម្រះសាលាដំបូង បានរកឃើញក្នុងសំណុំរឿង ០០២/០២ ថា "ឧក្រិដ្ឋកម្មមួយអាចប្រព្រឹត្តឡើងដោយអំពើអកម្ម ដែលនាំឱ្យមានពិរុទ្ធ ក្នុងស្ថានភាពដែលមានកាតព្វកិច្ចក្នុងការចាត់វិធានការ"[410]។

ទម្រង់នៃការទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម អាចត្រូវបានធ្វើឡើងដោយចារីតែម្នាក់ ឬសហចារី។ យោងតាមអង្គបុរេជំនុំជម្រះ ទម្រង់មូលដ្ឋាននៃសហចារី "គឺជាទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម

---

402 សូមមើល ជំពូក ៥.២.៧.៤.១។
403 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៥៣៧។
404 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.១.៤។
405 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.២.៤។
406 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៦.៣.១.៣។
407 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៦.៣.២.៤។
408 សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ៤។
409 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ៤៨០-៤៨១។
410 សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ៦២៧។

ដែលស្ថិតក្រោមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក. ហើយអាចត្រូវបានពិចារណាទាក់ទងនឹងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[411]។

នៅ អ.វ.ត.ក. មិនមានការដាក់ពិរុទ្ធភាពក្រោមទម្រង់នៃការទទួលខុសត្រូវនេះទេ ដោយសារតែជនជាប់ចោទត្រូវបានចោទប្រកាន់ភាគច្រើនក្រោមទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ("JCE")។ ក្នុងសំណុំរឿង ០០១ កាំង ហ្គេកអ៊ាវ (ហៅ ឌុច) ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទារុណកម្ម ឬ អំពើអមនុស្សធម៌ផ្សេងៗទៀត ប៉ុន្តែត្រូវបានកាត់ឱ្យរួចពិរុទ្ធភាពពីបទឧក្រិដ្ឋទាំងនេះ នៅពេលជំនុំជម្រះ[412]។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬ បញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថាមានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាក្នុងការចោទប្រកាន់ពីបទរៀបចំផែនការឧក្រិដ្ឋកម្មខាងក្រោមនេះ៖

- **មាស មុត៖** ជាសហចារីនៃអំពើមនុស្សឃាត ទាក់ទងនឹង (ក) ជនជាតិវៀតណាម និង ថៃ (ខ) ការបោសសម្អាតកងពលចំនួនបួន (គ) មន្ទីរសន្តិសុខចំនួនពីរ (ឃ) ការដ្ឋានចំនួនមួយ និង (ង) ទីតាំងសម្លាប់មនុស្សចំនួនមួយ[413]។
- **អ៊ឹម ចែម៖** ជាសហចារីនៃអំពើមនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅទីតាំងឧក្រិដ្ឋកម្មចំនួនពីរ[414]។
- **អោ អាន៖**
  - ជាចារីផ្ទាល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងស្រុកកំពង់សៀម និងព្រៃឈរ (តំបន់ ៤១)[415]
  - ជាសហចារីនៃអំពើមនុស្សឃាតគិតទុកជាមុនក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នៅទីតាំងចំនួនប្រាំបី[416]។
- **យឹម ទិត្យ៖**
  - ជាចារីផ្ទាល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ) ក្នុងស្រុកសំឡូត[417]
  - ជាសហចារីនៃអំពើមនុស្សឃាតគិតទុកជាមុនក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ( ២២ ករណី)[418]។

### ៣.៤.១.៦. សហឧក្រិដ្ឋកម្មរួម

ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ("JCE") ប្រកាន់យកនូវស្ថានភាពដែលជនជាប់ចោទអាចនឹងមានលក្ខណៈដាច់ឆ្ងាយចេញពីការចូលរួមប្រព្រឹត្តជាក់ស្តែងនៃ*អំពើពិរុទ្ធ*នៃបទឧក្រិដ្ឋ ជាជាងស្ថានភាពទាំងឡាយដែលត្រូវបានដឹងមុនតាមរយៈការចូលរួមផ្ទាល់ ដែលត្រូវបានកំណត់លក្ខខណ្ឌយោងតាមច្បាប់ក្នុង

---

[411] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ១១៦-១១៧។

[412] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ជំពូក ២.៧.១.២។

[413] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី៤)។

[414] សំណុំរឿង ០០៤/០១ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ៤(i)។

[415] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី២)។

[416] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក១៤ (បទចោទទី ៣)។

[417] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី២)។

[418] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ២ (បទចោទទី៤)។

ស្រុក[419]។ ការចូលរួមក្នុងទម្រង់ JCE គឺជាការប្រព្រឹត្តនៅក្នុងវិសាលភាពនៃមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក .[420]។ ទម្រង់នៃការប្រព្រឹត្តនេះតម្រូវឱ្យមានមនុស្សច្រើនចូលរួម ជាគោលបំណងរួមដែលបង្កើតបានជា ឬពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម និងថាជនជាប់ចោទត្រូវតែចូលរួមក្នុងគោលបំណងរួម តាមរយៈការចូលរួមចំណែកដ៏សំខាន់ ប៉ុន្តែមិនមែនមិនអាចខ្វះបាននោះទេ[421]។

ជាងនេះទៀត "ការចូលរួមក្នុងគោលបំណងរួមអាចតាមរយៈអំពើសកម្ម ឬអំពើអកម្ម" ហើយការចូលរួមរបស់ជនជាប់ចោទក្នុងគោលបំណងរួម "មិនតម្រូវថា ទាល់តែមានការចូលរួមប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ណាមួយ ដែលមានចែងក្នុងកិច្ចព្រមព្រៀង ឬ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. នោះទេ (ឧទាហរណ៍ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ឬការធ្វើទារុណកម្ម) ប៉ុន្តែវាអាចជាទម្រង់នៃការជួយជ្រោមជ្រែង ឬការចូលរួមចំណែកនៅក្នុងការអនុវត្តគោលបំណងរួមនោះ"[422]។ ជាងនេះទៀត អ្នកចូលរួមក្នុង JCE "អាចតម្រូវឱ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយចារី ដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ប្រសិនបើត្រូវបានរកឃើញថា ឧក្រិដ្ឋកម្មទាំងនោះអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ យ៉ាងហោចណាស់ទៅលើអ្នកចូលរួមណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម ហើយអ្នកចូលរួមនេះបានប្រើប្រាស់ចារីដើម្បីសម្រេចគោលបំណងរួមនោះ"[423]។

នៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ មានទម្រង់ JCE ចំនួនបីគឺ៖ ទម្រង់មូលដ្ឋាន (JCE I) នៅពេលដែលអ្នកចូលរួមទាំងអស់ប្រព្រឹត្តទៅតាមគោលបំណងរួម និងមានចេតនាឧក្រិដ្ឋតែមួយដូចគ្នា។ ទម្រង់ជាប្រព័ន្ធ (JCE II) សំដៅលើស្ថានភាពនៃការធ្វើបាបនៅក្នុងស្ថាប័នដែលមានចរនាសម្ព័ន្ធចាត់តាំង ដូចជា ជំរុំប្រមូលផ្តុំជាដើម។ ទម្រង់ទូលាយ (JCE III) គឺនៅពេលដែលអ្នកចូលរួមបានព្រមព្រៀងលើគោលបំណងរួមមួយដែលនាំឱ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ ហើយដូច្នេះទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋនោះ ទោះបីជាវានៅក្រៅគោលបំណងរួមក៏ដោយ ឱ្យតែអំពើឧក្រិដ្ឋទាំងនោះគឺជាផលវិបាកជាធម្មជាតិ នឹងដែលអាចប្រមើលដឹងជាមុនបានចំពោះផលវិបាកនៃគោលបំណងរួមនេះ[424]។

ចំពោះ JCE I ជនជាប់ចោទត្រូវតែមានចេតនាចូលរួមក្នុងគោលបំណងរួម ហើយអ្នកចូលរួមផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួមត្រូវមានចេតនានេះផងដែរ[425]។ ចំពោះ JCE II ជនជាប់ចោទត្រូវដឹងអំពីចរិតលក្ខណៈនៃឧក្រិដ្ឋកម្មដែលមានការធ្វើបាបជាប្រព័ន្ធ និងមានចេតនាជួយជ្រោមជ្រែងប្រព័ន្ធធ្វើបាបជារួមនេះ[426]។ ចំពោះ JCE III ជនជាប់ចោទត្រូវតែដឹងថា ឧក្រិដ្ឋកម្មនៅក្រៅផែនការរួម គឺជាផលវិបាកជាធម្មជាតិ និងអាចប្រមើលដឹងជាមុននៃផែនការរួមនោះ និងបានទទួលយកដោយស្ម័គ្រចិត្តនូវហានិភ័យនេះ[427]។

បញ្ហាចោទអំពីលទ្ធភាពអនុវត្ត JCE នៅ អ.វ.ត.ក. បានកើតមានឡើងជាច្រើនដង និងនៅចំពោះមុខអង្គជំនុំជម្រះមួយចំនួន ជាពិសេស ការអនុវត្ត JCE III[428]។ ក្នុងសំណុំរឿង ០០១ សហព្រះរាជអាជ្ញាតវ៉ាថា សហចៅក្រមស៊ើបអង្កេតមានកំហុសដោយការខកខានមិនបញ្ចូល JCE នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំណែក ឌុច បានអះអាងថា JCE មិនអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក. ឡើយ[429]។ ទោះជា

---

[419] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម(JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ១០១។
[420] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩០។
[421] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩២។
[422] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩៣។
[423] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩៣។
[424] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ៦៩០។
[425] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៦៩៤។
[426] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៦៩៤។
[427] សូមមើល សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ វ ត ក នូវទម្រង់នៃការទទួលខុសត្រូវខាង ព្រហ្មទណ្ឌដែលគេហៅថាសហឧក្រឹតដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១៦។
[428] សូមមើល ជំពូក ៥.២.៣.៣, ៥.២.៤។
[429] សំណុំរឿង ០០១ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ លើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ D99/3/3 កថាខណ្ឌ៤៣-៦៣។

យ៉ាងណា អង្គបុរេជំនុំជម្រះ បន្ទាប់ពីអញ្ជើញអ្នកមិនមែនជាភាគីនៃរឿងក្ដី ឱ្យដាក់សារណាលើបញ្ហានេះ[430] បានបដិសេធក្នុងការសម្រេចលើបញ្ហានេះ ដោយពិចារណាថា JCE មិនត្រូវបានដាក់បញ្ចូលក្នុងមូលដ្ឋានអង្គហេតុនៃកិច្ចស៊ើបសួរ[431]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានរកឃើញថា ទ្រឹស្ដី JCE គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥ និងត្រូវបានបញ្ចូលក្នុងច្បាប់ អ.វ.ត.ក. ជាទម្រង់មួយនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងបានរកឃើញថា ឌុច ទទួលខុសត្រូវតាមរយៈ JCE II ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅមន្ទីរសន្តិសុខ ស-២១[432]។ ក្នុងសំណុំរឿង ០០២ សហចៅក្រមស៊ើបអង្កេតបានប្រកាសថា JCE អាចអនុវត្តបាននៅ អ.វ.ត.ក. ក្នុងទម្រង់នីមួយៗរបស់វា ទោះបីជាពួកគាត់លើកឡើងថា វាមិនអាចអនុវត្តទៅលើឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិក្ដី[433]។ ក្រុមមេធាវីការពារក្ដីភាគច្រើន និងភាគីដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងឧទ្ធរណ៍[434] ហើយអង្គបុរេជំនុំជម្រះបានសម្រេចថា ខណៈដែល JCE I និង JCE II មានមូលដ្ឋានរឹងមាំគ្រប់គ្រាន់នៅក្នុងច្បាប់ជាធរមាន ត្រឹមឆ្នាំ១៩៧៥ JCE III មិនមាននោះទេ ហើយដូច្នេះមិនអាចអនុវត្តនៅ អ.វ.ត.ក. ឡើយ[435]។ នៅពេលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យសម្រេចថា JCE III អាចអនុវត្តបាននៅ អ.វ.ត.ក. ដោយឯកភាពជាមួយនឹងអង្គបុរេជំនុំជម្រះថាវាមិនអាចអនុវត្តបានទេ[436]។ អង្គជំនុំជម្រះតុលាការកំពូលក្រោយមកបានគាំទ្រគោលជំហរនេះ[437]។

នៅក្នុងរឿងក្ដីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬ បញ្ចប់រឿងក្ដីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថាមានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាក្នុងការចោទប្រកាន់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈការចូលរួមក្នុង JCE៖

- **មាស មុត៖** ជាទម្រង់មូលដ្ឋាននៃការទទួលខុសត្រូវ៖

---

សំណុំរឿង ០០១ ចម្លើយតបរបស់ក្រុមមេធាវីការពារក្ដីចំពោះបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងដីកាដំណោះស្រាយចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ចុះថ្ងៃទី១៦ ខែកញ្ញា ២០០៨ ឯកសារ D99/3/8 កថាខណ្ឌ ២។

[430] សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ១៤-១៥។ សំណុំរឿង ០០១ សារណាអំពីទ្រឹស្ដីសហកម្មឧក្រិដ្ឋកម្មរួម ដោយសាស្ត្រាចារ្យ Antonio Cassese សមាជិក *ទស្សនាវដ្ដីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/24។ សំណុំរឿង ០០១ សារណារបស់អ្នកមិនមែនជាភាគីក្នុងរឿងក្ដីដាក់ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្ស និងពហុច្បាប់ McGill University ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/25។ សំណុំរឿង ០០១ វណារបស់អ្នកមិនមែនជាភាគីក្នុងរឿងក្ដី [របស់សាស្ត្រាចារ្យបណ្ឌិត Kai Ambos] ទាក់ទងនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក./ក.ស.ច.ស. (អ.ប.ជ.០២) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/27។

[431] សំណុំរឿង ០០១ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ១១៥-១៤២។

[432] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ជំពូក ២.៧.១.៣។

[433] សំណុំរឿង ០០២ ដីកាសម្រេចស្ដីពីការអនុវត្តន៍នៅ អ វ ត ក នូវទម្រង់នៃការទទួលខុសត្រូវខាង ព្រហ្មទណ្ឌដែលគេហៅថាសហឧក្រឹតដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13។

[434] សំណុំរឿង ០០២ បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ប្រឆាំងនឹង “ដីកាសម្រេចលើការអនុវត្តនៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម” ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ឯកសារ D97/15/1។ សំណុំរឿង ០០២ បណ្ដឹងឧទ្ទវណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស. លើការអនុវត្តនៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១០ ឯកសារ D97/14/5។ សំណុំរឿង ០០២ បណ្ដឹងឧទ្ទវណ៍ប្រឆាំងនឹងដីកាសម្រេចលើការអនុវត្តនៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D97/16/1។ សំណុំរឿង ០០២ សារណាបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការអនុវត្តនៅ អ.វ.ត.ក. នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១០ ឯកសារ D97/17/1។ ដើមបណ្ដឹងរដ្ឋប្បវេណីតវ៉ាថា JCE គួរត្រូវបានអនុវត្តចំពោះឧក្រិដ្ឋកម្មជាតិ ក៏ដូចជាឧក្រិដ្ឋកម្មអន្តរជាតិដែរ។

[435] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម(JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9។

[436] សំណុំរឿង ០០២ សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E100/6 កថាខណ្ឌ២៦-៣៨។

[437] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ ៨០៧។

    - អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម[438]
    - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ពលកម្មដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ) នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ និងតំបន់កំពង់សោម មន្ទីរសន្តិសុខចំនួនបី (រួមទាំង ស-២១) ការដ្ឋានចំនួនពីរ ទីតាំងសម្លាប់មនុស្សមួយ និងកន្លែងផ្សេងៗទៀត ហើយទាក់ទងនឹងការបោសសម្អាតកងពលចំនួនបួន[439]
    - ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាម និងថៃ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[440]
- **អ៊ឹម ចែម**៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស)[441]
- **អោ អាន**៖ ជាទម្រង់មូលដ្ឋាននៃការទទួលខុសត្រូវ៖
    - អំពើប្រល័យពូជសាសន៍លើជនជាតិចាម៉ នៅក្នុងខេត្តកំពង់ចាម[442]
    - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត នៅទីតាំងចំនួនប្រាំបួន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[443]
- **យឹម ទិត្យ**៖ រួមផ្សំជាមួយនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត៖
    - អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម (១១ ករណី នៃ JCE I មួយករណីនៃ JCE II)[444]
    - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (២២ ករណីនៃ JCE I មួយករណីនៃ JCE II) រួមបញ្ចូលទាំង ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ ការឃុំខ្លួន និងធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[445]

---

[438] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី១)។

[439] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី ២)។

[440] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី៣)។

[441] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ៤(ii)។

[442] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី១)។

[443] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក១៤ (បទចោទទី២)។

[444] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី១)។

[445] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី២)។

- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (បួនករណី) រួមទាំងការធ្វើមនុស្សឃាតដោយចេតនា និងការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់ នឹងការនិរទេស ឬការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់ [446]។

### ៣.៤.១.៧. ការទទួលខុសត្រូវរបស់ថ្នាក់លើ/មេបញ្ជាការ[447]

មានលក្ខខណ្ឌតម្រូវចំនួនបីចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ៖

(ក) ត្រូវតែមានទំនាក់ទំនងថ្នាក់លើនិងអ្នកនៅក្រោមបង្គាប់ រវាងជនជាប់ចោទ និងជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម (ខ) ជនជាប់ចោទត្រូវតែបានដឹង និងមានហេតុផលដឹងថា ឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្ត ឬត្រូវបានប្រព្រឹត្តហើយ (គ) ជនជាប់ចោទអាចនឹងខកខានមិនបានចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[448]។

ក្នុងការពិចារណាថាតើទម្រង់នៃការទទួលខុសត្រូវនេះមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឬយ៉ាងណា ក្នុងឆ្នាំ១៩៧៥-១៩៧៩ អង្គបុរេជំនុំជម្រះបានពិចារណាលើប្រភពអន្តរជាតិនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ រួមទាំងយុត្តិសាស្ត្រពីសាលាក្តីយោធាសម័យ Nuremberg ក៏ដូចជាយុត្តិសាស្ត្រពីសាលាក្តីអន្តរជាតិចំពោះកិច្ច និងបានរកឃើញថា៖

> ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលបានបញ្ជាក់ច្បាស់នៅក្នុងមាត្រា ២៩(ថ្មី) នៃច្បាប់ អ.វ.ត.ក. មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥។ ទោះបីជាការបញ្ជាក់ច្បាស់អំពីធាតុផ្សំទាំងនោះនាំពេលបច្ចុប្បន្ន ហើយការអនុវត្តធាតុផ្សំទាំងអស់នោះ ចំពោះអង្គហេតុជាក់លាក់នៅក្នុងរឿងក្តីក្រោយសង្គ្រាមលោកលើកទី២ ជួនកាលមិនស៊ីចង្វាក់គ្នា និងមិនពេញលេញយ៉ាងណាក៏ដោយ ក៏គោលការណ៍ដែលថាថ្នាក់លើអាចត្រូវបានចាប់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តឡើងដោយអ្នកនៅក្រោមបង្គាប់ ប្រសិនបើមានទំនាក់ទំនងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ដោយមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នោះធាតុផ្សំអត្តនោម័តនៃការដឹងពិតប្រាកដ ឬដឹងតាមការសន្មត និងធាតុផ្សំសត្យានុម័តនៃការខកខានត្រូវបានបង្ហាញឡើង[449]។

អង្គជំនុំជម្រះសាលាដំបូងបានបន្តរកឃើញថា៖

> ទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានយល់ឃើញថា មិនកំណត់តែចំពោះមេបញ្ជាការយោធាប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានគ្របដណ្តប់ដល់ថ្នាក់លើដែលមិនមែនជាយោធាផងដែរ។ ហេតុដូច្នេះ យុត្តិសាស្ត្រនេះបង្ហាញថា លក្ខណៈពិតប្រាកដនៃតួនាទី ឬមុខងាររបស់នរណាម្នាក់ដែលជាថ្នាក់លើ និងបញ្ហាថាតើ *តាមផ្លូវច្បាប់ (dejure)* ឬ *តាមហេតុការណ៍ពិត (de facto)* មិនសូវ

---

[446] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី៣)។

[447] ទ្រឹស្តីនៃពាក្យ "ការទទួលខុសត្រូវរបស់ថ្នាក់លើ" និង "ការទទួលខុសត្រូវរបស់មេបញ្ជាការ" បង្កើតបានជាទម្រង់នៃការទទួលខុសត្រូវ "ផ្ទាល់" ដូចគ្នា ហើយពាក្យទាំងនេះត្រូវបានប្រើជំនួសឱ្យគ្នាទៅវិញទៅមកដោយអង្គជំនុំជម្រះ។ សូមមើល សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៨៥។

[448] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣៨។ សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៧១៥-៧១៦។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧២៥-៣៧២៦។

[449] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៥៨។ កត់សម្គាល់ថា មិនមានមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ទេ។ នេះគឺជាកំហុសអក្ខរាវិរុទ្ធ ហើយអង្គបុរេជំនុំជម្រះយោងទៅមាត្រា ២៩។

មានលក្ខណៈសំខាន់ស្មើនឹងកម្រិតនៃការបញ្ជា ឬការអនុញ្ញាតដែលបានធ្វើលើអ្នកនៅក្រោមបង្គាប់ឡើយ[450]។

អង្គបុរេជំនុំជម្រះបានអនុវត្តបទដ្ឋានអន្តរជាតិសម្រាប់គោលការណ៍នីត្យានុកូលភាព និងបានរកឃើញថា ដោយសារតែទ្រឹស្តីនៃការទទួលខុសត្រូវរបស់មេបញ្ជាការ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ វាគឺជាសូចនាកររឹងមាំដែលបញ្ជាក់ថា ជនជាប់ចោទអាចប្រមើលឃើញថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែង។ អង្គជំនុំជម្រះសាលាដំបូងបានឯកភាពជាមួយអង្គបុរេជំនុំជម្រះ និងបានរកឃើញថា ការទទួលខុសត្រូវរបស់ថ្នាក់លើពិតជាមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់ នៅក្នុងពេលវេលាដែលពាក់ព័ន្ធនោះមែន[451]៕

ចំពោះលក្ខណៈទម្រង់នៃការទទួលខុសត្រូវនេះ ទំនាក់ទំនងថ្នាក់លើនិងអ្នកក្រោមបង្គាប់ អាចកើតមានតាមរយៈអំណាចរបស់ថ្នាក់លើតាមផ្លូវច្បាប់ ឬតាមអង្គហេតុលើអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្ម។ គេត្រូវបង្ហាញថា ជនជាប់ចោទអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើអ្នកក្រោមបង្គាប់ - ពោលគឺ ជនជាប់ចោទមាន "សមត្ថភាពខាងសម្ភារៈដើម្បីទប់ស្កាត់ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់"[452]។

កត្តាបញ្ជាក់អំពីការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព អាចរួមបញ្ចូលមុខតំណែងរបស់ជនជាប់ចោទនីតិវិធីសម្រាប់ការតែងតាំង និងភារកិច្ចជាក់ស្តែងដែលបានបំពេញ សមត្ថភាពរបស់ជនជាប់ចោទក្នុងការចេញបញ្ជា និងថាតើបញ្ជាបែបទាំងនោះពិតជាត្រូវបានអនុវត្តឬយ៉ាងណា អង្គហេតុដែលថា អ្នកក្រោមបង្គាប់បង្ហាញការគោរពវិន័យពេលមានវត្តមានរបស់ជនជាប់ចោទ សិទ្ធិអំណាចក្នុងការដាក់វិធានការវិន័យ និងសិទ្ធិអំណាចក្នុងការដោះលែង ឬបញ្ជូនអ្នកទោស។ មនុស្សគ្រប់រូបដែលអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើអ្នកក្រោមបង្គាប់ អាចទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មរបស់ពួកគេ[453]។

ថ្នាក់លើត្រូវតែដឹង ឬមានហេតុផលត្រូវដឹងថា អ្នកក្រោមបង្គាប់បានប្រព្រឹត្ត ឬអាចនឹងប្រព្រឹត្តឧក្រិដ្ឋកម្ម។ ការដឹងបែបនេះមិនមែនដោយការសន្មតនោះទេ ប៉ុន្តែត្រូវបានបង្កើតដោយភស្តុតាង។ ថ្នាក់លើក៏ត្រូវតែដឹងអំពីអំពើឧក្រិដ្ឋរបស់អ្នកក្រោមបង្គាប់ផងដែរ មិនមែនត្រឹមតែការដឹងអំពីការកើតមានឡើងនៃឧក្រិដ្ឋកម្មទាំងនោះឡើយ។ ការដឹងអាចត្រូវបានបញ្ជាក់ដោយការទទួលបានព័ត៌មានគ្រប់គ្រាន់ - ប៉ុន្តែព័ត៌មានបែបនោះអាចមានលក្ខណៈទូទៅ និងមិនតម្រូវឱ្យមានសេចក្តីលម្អិតអំពីឧក្រិដ្ឋកម្មឡើយ។ ថ្នាក់លើមិនអាចមិនព្រមទទួលព័ត៌មានពាក់ព័ន្ធដោយចេតនានោះឡើយ ក្នុងករណីដែលមានមធ្យោបាយក្នុងការទទួលព័ត៌មាននោះ[454]។

ប្រសិនបើថ្នាក់លើខកខានក្នុងការចាត់វិធានការចាំបាច់ និងសមស្រប (ពោលគឺ វិធានការដែលបង្ហាញពីកិច្ចខិតខំប្រឹងប្រែងពិតប្រាកដ ដែលស្ថិតក្នុងអំណាចជាក់ស្តែងរបស់ថ្នាក់លើយ៉ាងសមស្រប) ក្នុងការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬក្នុងការដាក់ទណ្ឌកម្មចារី ថ្នាក់លើអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវក្រោមការបទទទួលខុសត្រូវរបស់ថ្នាក់លើ។ ការខកខានក្នុងការទប់ស្កាត់ "និងការខកខានក្នុងការដាក់ទណ្ឌកម្ម គឺខុសគ្នាទាំងខាងអង្គហេតុ និងទាំងខាងអង្គច្បាប់"- តួនាទីក្នុងការទប់ស្កាត់កើតមានចាប់ពីពេលដែលថ្នាក់លើបានដឹង ឬមានហេតុផលដឹងថាឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្ត និងតួនាទីក្នុងការដាក់ទណ្ឌកម្មនឹងកើតមានបន្ទាប់ពីពេលប្រព្រឹត្តឧក្រិដ្ឋកម្ម[455]។

---

[450] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៥៩។

[451] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៧១៨។

[452] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៤០។

[453] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៤១-៥៤២។

[454] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៤៣-៥៤៤។

[455] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៤៥, ៥៤៧។

ជនជាប់ចោទមិនអាចត្រូវបានជំនុំជម្រះ ឬកាត់ទោសផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ *និង* ផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវផ្ទាល់ចំពោះអំពើដូចគ្នាឡើយ[456]។ ផ្ទុយទៅវិញ "ក្នុងករណីជនជាប់ចោទត្រូវបានរកឃើញថាត្រូវទទួលខុសត្រូវផ្ទាល់ និងត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើទាក់ទងនឹងអំពើដូចគ្នា អង្គជំនុំជម្រះត្រូវផ្តន្ទាទោសដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវផ្ទាល់ ហើយចាត់ទុកឋានៈជាថ្នាក់លើរបស់ជនជាប់ចោទជាស្ថានទម្ងន់ទោសនៅពេលសម្រេចអំពីទោស"[457]។

អ.វ.ត.ក. បានដាក់ពិរុទ្ធភាព នួន ជា យោងតាមទម្រង់នៃការទទួលខុសត្រូវនេះ ក្នុងសំណុំរឿង ០០២/០២ ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកក្រុមជាតិពន្ធុ និងក្រុមសាសនាចាម[458]។

មិនមានការដាក់ពិរុទ្ធភាពផ្សេងទៀតត្រូវបានកត់ត្រា យោងតាមទម្រង់នៃការទទួលខុសត្រូវនេះទេ ដោយសារតែជនជាប់ចោទត្រូវបានរកឃើញថាទទួលខុសត្រូវ យោងតាមទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ("JCE") ជំនួសវិញ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះវិសាមញ្ញបានសម្រេចថា ជនជាប់ចោទពីររូបទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ហើយចំណុចនេះត្រូវបានពិចារណានៅដំណាក់កាលសម្រេចអំពីទោស៖

- **កាំង ហ្គេកអ៊ាវ (ហៅ ឌុច)**៖ បានអនុវត្តការគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើបុគ្គលិកមន្ទីរសន្តិសុខ ស-២១ បានដឹងថាថ្នាក់ក្រោមបង្គាប់របស់គាត់បានកំពុងប្រព្រឹត្តឧក្រិដ្ឋកម្ម និងបានខកខានក្នុងការចាត់វិធានការចាំបាច់ ឬ សមស្របដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មចារី[459]។
- **នួន ជា**៖ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* និង*តាមច្បាប់*លើសមាជិក ប.ក.ក. និង កងទ័ពបដិវត្តន៍កម្ពុជា បានដឹង ឬមានហេតុផលដឹងថា ថ្នាក់ក្រោមបង្គាប់របស់ខ្លួនកំពុងប្រព្រឹត្តឧក្រិដ្ឋកម្មខាងក្រោម ហើយខកខានក្នុងការចាត់វិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មខាងក្រោម ឬដាក់ទណ្ឌកម្មចារី[460]៖
  - **សំណុំរឿង ០០២/០១**៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលជម្លៀសប្រជាជនពីភ្នំពេញ (ដំណាក់កាលទី ១)[461] និងការផ្លាស់ទីលំនៅប្រជាជនជាបន្តបន្ទាប់ទូទាំងប្រទេសកម្ពុជា (ដំណាក់កាលទី ២)[462]។
  - **សំណុំរឿង ០០២/០២**៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ដោយមាន*ចេតនាមិនផ្ទាល់ (ផ្លូវច្បាប់)* នៅសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា ការដ្ឋានទំនប់ត្រពាំងថ្ម ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល[463]។

នៅក្នុងរឿងក្តីផ្សេងទៀតនៅចំពោះមុខ អ.វ.ត.ក. មុនពេលលើកលែងចោទប្រកាន់ ឬ បញ្ចប់រឿងក្តីទាំងនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាថាមានភស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នា ដែលថាបុគ្គលខាងក្រោមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្នុងនាមជាថ្នាក់លើ ឬមេបញ្ជាការ៖

- **មាស មុត**៖ ជាជម្រើសមួយបន្ថែមទៀតទៅនឹងការទទួលខុសត្រូវតាម JCE និងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត៖

---

[456] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ១៥៥៧។ សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣៩។

[457] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧០២។ សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៣៩។

[458] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ជំពូក ១៧.៣.២-១៧.៤។ ទាក់ទងនឹងភាពស្ថាពរនៃសាលក្រមនោះ សូមមើល ជំពូក ៥.២.៧.៤.១។

[459] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ជំពូក ២.៧.១០.៤។

[460] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក១៥.៤.១.៥, ១៥.៤.២.៥។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ជំពូក ១៧.៣.២។

[461] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.១.៥។

[462] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤.២.៥។

[463] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ជំពូក ១៧.៣.២-១៧.៤។

- អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម[464]
- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស ពលកម្មដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរំលោភសេពសន្ថវៈ) នៅក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ និងតំបន់កំពង់សោម មន្ទីរសន្តិសុខចំនួនបី (រួមទាំង ស-២១) ការដ្ឋានចំនួនពីរ ទីតាំងសម្លាប់មនុស្សមួយ និងកន្លែងផ្សេងៗទៀត[465]
- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ទាក់ទងនឹងការសម្លាប់ជនជាតិវៀតណាម និងថៃ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[466]

- **អ៊ឹម ចែម**៖ អំពើមនុស្សឃាតយោងតាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស)[467]
- **អោ អាន**៖ ជាជម្រើសមួយបន្ថែមទៀតទៅនឹងការទទួលខុសត្រូវតាម JCE និងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត៖
  - អំពើប្រល័យពូជសាសន៍លើជនជាតិចាម នៅក្នុងខេត្តកំពង់ចាម[468]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត នៅទីតាំងចំនួនប្រាំបី៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត (រួមទាំងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[469]
- **យឹម ទិត្យ**៖ រួមផ្សំជាមួយនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត៖
  - អំពើប្រល័យពូជសាសន៍លើខ្មែរក្រោម (ប្រាំបីករណី)[470]
  - ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (១៨ ករណី) រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ទីលំនៅដោយបង្ខំ ការឃុំខ្លួន និងធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ)[471]

---

[464] សំណុំរឿង ០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី១)។
[465] សំណុំរឿង ០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី២)។
[466] សំណុំរឿង ០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២ (បទចោទទី៣)។
[467] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើកលែងចោទប្រកាន់ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ៤។
[468] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី១)។
[469] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក ១៤ (បទចោទទី២)។
[470] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី១)។
[471] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី២)។

○ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (ពីរករណី) រួមមាន ការធ្វើមនុស្សឃាតដោយចេតនា និងការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់[472]។

## ៣.៥. ការលើកលែងទោស និងការអនុគ្រោះទោស

មាត្រា ៤០ (ថ្មី) នៃច្បាប់ អ.វ.ត.ក. ចែងថា៖

> រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឱ្យមានការលើកលែងទោស ឬការអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងក្នុងមាត្រា ៣, ៤, ៥, ៦, ៧ និង មាត្រា ៨ នៃច្បាប់នេះបានឡើយ។ វិសាលភាពនៃការលើកលែងទោស ឬអនុគ្រោះទោសដែលអាចត្រូវបានផ្តល់អោយមុនការអនុម័តច្បាប់នេះ គឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ[473]។

ស្រដៀងគ្នានេះ មាត្រា ១១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជាចែងថា៖

> ១. រាជរដ្ឋាភិបាលកម្ពុជានឹងមិនស្នើសុំឱ្យមានការលើកលែងទោស ឬអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចនឹងត្រូវស៊ើបអង្កេត ឬនឹងត្រូវផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះទេ។
>
> ២. ប្រការនេះផ្អែកលើសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជាថា រហូតមកដល់ពេលនេះមានតែករណីមួយគត់ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះ នៅថ្ងៃទី១៤ កញ្ញា ១៩៩៦ ពេលដែលការលើកលែងទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ដែលត្រូវបានផ្តន្ទាទោសនៅឆ្នាំ ១៩៧៩ ពីបទប្រល័យពូជសាសន៍។ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះគឺត្រូវសំរេចដោយ អង្គជំនុំជម្រះវិសាមញ្ញ។

សំណើសុំលើកលែងទោស និងអនុគ្រោះទោសនៅចំពោះមុខ អ.វ.ត.ក. ត្រូវបានពិចារណាទាក់ទងនឹងករណី អៀង សារី[474]។

## ៣.៦. ទោសបញ្ញត្តិ និងការសម្រេចអំពីទោស

មាត្រា ៣៨ និង ៣៩ នៃច្បាប់ អ.វ.ត.ក. និងមាត្រា ១០ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចែងអំពីបញ្ញត្តិនានាទាក់ទងនឹងទោសបញ្ញត្តិនៅ អ.វ.ត.ក.។ មាត្រា ៣៨ ចែងថា ទោសបញ្ញត្តិទាំងអស់ត្រូវកំណត់ត្រឹមការដាក់ពន្ធនាគារ ហើយមាត្រា ៣៩ ចែងថា ជនណាដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំ រហូតដល់មួយជីវិត និងថា ក្រៅពីទោសដាក់ពន្ធនាគារ អ.វ.ត.ក. អាចបង្គាប់ឱ្យរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ និងលុយកាក់ ដែលទទួលបានដោយខុសច្បាប់ ឬក៏ដោយការប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម។ មាត្រា ១០ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចែងថាទណ្ឌកម្មជាអតិបរមាគឺកំណត់ត្រឹមដាក់ពន្ធនាគារអស់មួយជីវិត។

ច្បាប់ អ.វ.ត.ក. បានឆ្លងកាត់ការពិភាក្សាដេញដោល និងកំណែទម្រង់ដ៏សំខាន់ ទាក់ទងនឹងបញ្ហាទោសប្រហារជីវិត។ មាត្រា ៣ នៃច្បាប់ អ.វ.ត.ក. ដំបូង យោងទៅលើឧក្រិដ្ឋកម្មមួយចំនួននៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ឧក្រិដ្ឋកម្មនីមួយៗក្នុងចំណោមនោះកំណត់ការផ្តន្ទាទោសប្រហារជីវិត។ ចំណុចនេះផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ដែលបានដាក់ទោសប្រហារជីវិតនៅក្រៅច្បាប់។ ច្បាប់ អ.វ.ត.ក. ដំបូង បានអនុម័ត ប៉ុន្តែត្រូវបានពិនិត្យដោយក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា អត្ថបទនេះត្រូវបានបញ្ជូនត្រឡប់មក

---

[472] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១២ (បទចោទទី៣)។

[473] ច្បាប់ អ.វ.ត.ក. មាត្រា ៤០ (ថ្មី)។

[474] សូមមើល ជំពូក៥.២.៣.៣។

រដ្ឋសភាកម្ពុជាវិញ ដើម្បីធ្វើវិសោធនកម្មលើមាត្រា ៣ ដោយសារក្រុមប្រឹក្សាធម្មនុញ្ញពិចារណាថា អត្ថបទដូចដែលបានតាក់តែងឡើងនេះវាផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ។ ជាចុងក្រោយ ពាក្យពេចន៍ក្នុងមាត្រា ៣ ត្រូវបានកែតម្រូវដូចខាងក្រោម៖

> ទោសបញ្ញត្តិចែងក្នុងមាត្រា ២០៩, ៥០០, ៥០៦ និងមាត្រា ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវកំណត់ថាអតិបរមាត្រឹមទោសដាក់ពន្ធនាគារអស់មួយជីវិត អនុលោមតាមមាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងចែងបន្ថែមក្នុងមាត្រា ៣៨ និងមាត្រា ៣៩ ថ្មី នៃច្បាប់នេះ[475]។

**ទោសបញ្ញត្តិកំណត់ដោយ អ.វ.ត.ក.**

| | |
|---|---|
| **សំណុំរឿង ០០១**<br>*កាំង ហ្កេកអ៊ាវ (ហៅ ឌុច)* | ដាក់ពន្ធនាគារ ៣០ ឆ្នាំ នៅដំណាក់កាលជំនុំជម្រះ (ដាក់ពន្ធនាគារ ៣៥ ឆ្នាំ ដោយកាត់បន្ថយប្រាំឆ្នាំដោយសារការឃុំខ្លួនខុសច្បាប់)[476]<br><br>ត្រូវបានដំឡើងទៅ***ដាក់ពន្ធនាគារអស់មួយជីវិត*** នៅដំណាក់កាលបណ្តឹងសាទុក្ខ។ |
| **សំណុំរឿង ០០២/០១**<br>*នួន ជា* និង *ខៀវ សំផន* | ***ដាក់ពន្ធនាគារអស់មួយជីវិត*** នៅដំណាក់កាលជំនុំជម្រះ។<br><br>ត្រូវបានតម្កល់ទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ។ |
| **សំណុំរឿង ០០២/០២**<br>*នួន ជា* | ដាក់ពន្ធនាគារអស់មួយជីវិតនៅដំណាក់កាលជំនុំជម្រះ បញ្ចូលជាមួយទោសដាក់ពន្ធនាគារអស់មួយជីវិតដែលបានកំណត់ក្នុងសំណុំរឿង ០០២/០១។<br><br>***ការសម្រេចអំពីទោសនេះមិនចាត់ទុកថាស្ថាពរទេ*** ដោយសារ នួន ជា បានស្លាប់ក្រោយពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួនទៅអង្គជំនុំជម្រះតុលាការកំពូល ជំទាស់ទៅនឹងការសម្រេចអំពីទោសនេះ ក្នុងចំណោមបញ្ហាផ្សេងទៀតនៃការផ្តន្ទាទោសគាត់ដោយអង្គជំនុំជម្រះសាលាដំបូង[477]។ |
| **សំណុំរឿង ០០២/០២**<br>*ខៀវ សំផន* | ***ដាក់ពន្ធនាគារអស់មួយជីវិត***នៅដំណាក់កាលជំនុំជម្រះ បញ្ចូលជាមួយទោសដាក់ពន្ធនាគារអស់មួយជីវិតដែលបានកំណត់ក្នុងសំណុំរឿង ០០២/០១។<br><br>ត្រូវបានតម្កល់ទោសនៅដំណាក់កាលបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថាការកំណត់អំពីទោសដែលបានធ្វើឡើងនៅក្នុងសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២ តាមផ្លូវច្បាប់គឺជាទោសជាប់ពន្ធនាគារតែមួយ |

[475] ច្បាប់ អ.វ.ត.ក. មាត្រា ៣ (ថ្មី)។
[476] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៣១, ៦៧៩។
[477] សូមមើល ជំពូក ៥.២.៧.៤.១។

| | |
|---|---|
| | ប៉ុណ្ណោះ មិនមែនជាទោសត្រួតគ្នាក្នុងពេលតែមួយនោះទេ[478]។ |

## ៣.៧. លក្ខណៈពិសេស និងកូនកាត់

អ.វ.ត.ក. ត្រូវបានបង្កើតឡើងស្របតាមច្បាប់កម្ពុជា ជាយុត្តាធិការពិសេស (“អង្គជំនុំជម្រះវិសាមញ្ញ”) នៅក្នុងប្រព័ន្ធតុលាការដែលមានស្រាប់ (“ក្នុងតុលាការកម្ពុជា”)។ ក្នុងឋានៈជាស្ថាប័នជាតិ អ.វ.ត.ក. មានទីតាំងរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ជាដែនដីដែលឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់ក្រោមយុត្តាធិការរបស់ខ្លួនត្រូវបានប្រព្រឹត្តឡើង[479]។ ការគាំទ្រពីសហគមន៍អន្តរជាតិ - ដែលផ្តល់តាមរយៈអង្គការសហប្រជាជាតិ - ត្រូវបានដាក់បញ្ចូលជាធាតុផ្សំរចនាសម្ព័ន្ធជាប់មកជាមួយរបស់ អ.វ.ត.ក. ដោយបានប្រែក្លាយជាស្ថាប័នជាតិ-អន្តរជាតិ (ឬ“កូនកាត់”) ពិសេសតែមួយគត់។

### ៣.៧.១. សមាសភាព “ជាតិ” និង “អន្តរជាតិ”

អ.វ.ត.ក. មានប្រព័ន្ធ “សហប្រធាន” ដោយមានខ្មែរម្នាក់ (“ភាគីជាតិ”) និង បរទេសម្នាក់ (“ភាគីអន្តរជាតិ”) ត្រូវបានតែងតាំង ដើម្បីចែករំលែកការទទួលខុសត្រូវចំពោះតួនាទីសំខាន់ៗ[480] ដូចខាងក្រោម៖

- សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ទទួលបន្ទុកធ្វើការចោទប្រកាន់រឿងក្តី[481]
- សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ ទទួលបន្ទុកធ្វើការស៊ើបអង្កេតតាមផ្លូវតុលាការ[482]
- សហមេធាវីជាតិ និងអន្តរជាតិ តំណាងជនសង្ស័យ ជនត្រូវចោទ និង ជនជាប់ចោទម្នាក់ៗ[483]
- សហមេធាវីជាតិ និងអន្តរជាតិ តំណាងផលប្រយោជន៍រួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលដំណាក់កាលកិច្ចនីតិវិធីជំនុំជម្រះ និងបណ្តឹងសាទុក្ខ[484]។

ទោះបីជាមិនអនុវត្តតាមគោលការណ៍ដូចគ្នា ការិយាល័យរដ្ឋបាលដឹកនាំដោយប្រធានការិយាល័យរដ្ឋបាលម្នាក់ដែលជាជនជាតិខ្មែរ និងមានអនុប្រធានការិយាល័យរដ្ឋបាលម្នាក់ជាជនបរទេស[485]។ តាមការអនុវត្តជាក់ស្តែង អនុប្រធានក៏បំពេញមុខងារជាមន្ត្រីសម្របសម្រួលរបស់ UNAKRT ផងដែរ[486]។

### ៣.៧.២. សេចក្តីសម្រេចដោយ “សំឡេងភាគច្រើនលើសលប់”

ចៅក្រមនៃអង្គជំនុំជម្រះ ត្រូវព្យាយាមសម្រេចឱ្យបាននូវការឯកភាពគ្នា ក្នុងសេចក្តីសម្រេចរបស់ខ្លួន[487]។ ទោះជាយ៉ាងណា ក្នុងករណីដែលមិនមានការឯកភាពគ្នាទេនោះ សេចក្តីសម្រេចចេញដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យមានសំឡេងឆ្នោតគាំទ្រយ៉ាងហោចណាស់ពីចៅក្រមបួនរូប (ក្នុងចំណោមប្រាំរូប) ហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល តម្រូវឱ្យមានសំឡេងឆ្នោតគាំទ្រពីចៅក្រមយ៉ាងហោចណាស់ចំនួន ប្រាំរូប (ក្នុងចំណោមប្រាំពីររូប)[488]។ លក្ខខណ្ឌតម្រូវ “សំឡេងភាគច្រើនលើសលុប” នេះ រារាំងយ៉ាងមានប្រសិទ្ធភាព មិនឱ្យមានការជាប់គាំង ចំពោះយោបល់ផ្សេងគ្នារវាងផ្នែកចៅក្រមជាតិ និងផ្នែកចៅក្រមអន្តរជាតិ។

---

478 សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 ជំពូក ៤(ខ)។
479 ច្បាប់ អ.វ.ត.ក. មាត្រា២(ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ២។
480 សូមមើល UNGA អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មុខងារសេសសល់៖ របាយការណ៍របស់អគ្គលេខាធិការ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ឯកសារ A/75/809 កថាខណ្ឌ ៩។
481 ច្បាប់ អ.វ.ត.ក. មាត្រា២, ៤៣(ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៦។
482 ច្បាប់ អ.វ.ត.ក. មាត្រា ២៣(ថ្មី)-២៨។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៥។
483 បទបញ្ជារដ្ឋបាលផ្នែកគាំពារការការពារក្តី បទបញ្ជាលេខ ៥.៣។
484 វិធានផ្ទៃក្នុង វិធាន ១២ *ស្ទួនពីរ* (៤)។
485 ច្បាប់ អ.វ.ត.ក. មាត្រា ៣០-៣១(ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៨។
486 សូមមើល ជំពូក ៤.៨។
487 ច្បាប់ អ.វ.ត.ក. មាត្រា ១៤ (ថ្មី) (១)។ វិធានផ្ទៃក្នុង វិធាន ៩៨(១៦៤), ១១១(៦)។
488 ច្បាប់ អ.វ.ត.ក. មាត្រា១៤(ថ្មី)។ វិធានផ្ទៃក្នុង វិធាន ៧១(៤)(គ), ៧២(៤)(ឃ), ៧៧(១៣)។

**សមាសភាពការិយាល័យតុលាការ និងអង្គជំនុំជម្រះ៖**[489]

| ការិយាល័យតុលាការ ឬអង្គជំនុំជម្រះ | សមាសភាព | ប្រធាន | សំឡេងឆ្នោតត្រូវការ ដើម្បីធ្វើសេចក្តីសម្រេច ("សំឡេងភាគច្រើនលើសលប់") |
|---|---|---|---|
| **ការិយាល័យសហព្រះរាជអាជ្ញា** | ព្រះរាជអាជ្ញាជាតិម្នាក់ (១)<br>ព្រះរាជអាជ្ញាអន្តរជាតិម្នាក់ (១) | គ្មាន សិទ្ធិស្មើគ្នា | មិនពាក់ព័ន្ធ |
| **ការិយាល័យសហចៅក្រមស៊ើបអង្កេត** | ចៅក្រមស៊ើបអង្កេតជាតិម្នាក់ (១)<br>ចៅក្រមស៊ើបអង្កេតអន្តរជាតិម្នាក់ (១) | គ្មាន សិទ្ធិស្មើគ្នា | មិនពាក់ព័ន្ធ |
| **អង្គបុរេជំនុំជម្រះ** | ចៅក្រមជាតិបីរូប (៣)<br>ចៅក្រមអន្តរជាតិពីររូប (២) | ចៅក្រមជាតិជាប្រធាន | យ៉ាងហោចណាស់បួន (៤) |
| **អង្គជំនុំជម្រះសាលាដំបូង** | ចៅក្រមជាតិបីរូប (៣)<br>ចៅក្រមអន្តរជាតិពីររូប (២) | ចៅក្រមជាតិជាប្រធាន | យ៉ាងហោចណាស់បួន (៤) |
| **អង្គជំនុំជម្រះតុលាការកំពូល** | ចៅក្រមជាតិបួនរូប (៤)<br>ចៅក្រមអន្តរជាតិបីរូប (៣) | ចៅក្រមជាតិជាប្រធាន | យ៉ាងហោចណាស់ប្រាំ (៥) |

### ៣.៧.៣. នវានុវត្តន៍នៃអង្គបុរេជំនុំជម្រះ

កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់ អ.វ.ត.ក. បង្កើតអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា និង សហចៅក្រមស៊ើបអង្កេត[490]។ នេះដោយសារតែការិយាល័យតុលាការទាំងពីរនេះមិនមានប្រធាន ដែលមានសំឡេងឆ្នោតអាចធ្វើសេចក្តីសម្រេចបាន ហើយសំឡេងឆ្នោតភាគច្រើនលើសលប់មិនអាចធ្វើទៅបាន។ តួនាទីរបស់អង្គបុរេជំនុំជម្រះមានលក្ខណៈពិសេស ដោយសារមិនមានសាលាក្តីណាមានលក្ខណៈស្រដៀងនេះ មានភារកិច្ចដោះស្រាយវិវាទរវាងព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតដែលមានសិទ្ធិអំណាចស្មើគ្នានោះទេ[491]។

---

[489] ច្បាប់ អ.វ.ត.ក. មាត្រា ៩(ថ្មី), ១៦, ២០ (ថ្មី), ២៦។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា ៣(២), ៥(១), ៦(១), ៧(២)។ វិធានផ្ទៃក្នុង វិធាន ១៤(១), ២០(១)។
[490] ច្បាប់ អ.វ.ត.ក. មាត្រា២០ (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា៧។
[491] សេចក្តីពិសារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ២០។

អង្គបុរេជំនុំជម្រះក៏មានយុត្តាធិការផងដែរលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ពាក្យសុំមោឃភាពកិច្ចស៊ើបសួរ និងបណ្តឹងឧទ្ធរណ៍ផ្សេងទៀតដែលមានចែងក្នុងវិធានមួយចំនួននៃវិធានផ្ទៃក្នុង[492]។ តាមការអនុវត្តជាក់ស្តែង អង្គបុរេជំនុំជម្រះអនុម័តការបកស្រាយទូលំទូលាយអំពីយុត្តាធិការរបស់ខ្លួន ដោយបានសន្និដ្ឋានថា ខ្លួនបំពេញតួនាទីជាសភាស៊ើបសួរកម្ពុជា[493]។ ដូច្នេះ តួនាទីរបស់អង្គបុរេជំនុំជម្រះស្រដៀងគ្នាទៅនឹងអង្គបុរេជំនុំជម្រះនានា នៃសាលាក្តីអន្តរជាតិ និងសាលាក្តីអន្តរជាតូនីយកម្មផ្សេងទៀត។

## ៣.៧.៤. យុត្តាធិការមានកំណត់ និងយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ

ខុសពីតុលាការកម្ពុជា យុត្តាធិការរបស់ អ.វ.ត.ក. កំណត់ត្រឹមតែ “មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះអំពើមនុស្សឃាត ការធ្វើទារុណកម្ម និងធ្វើការទុក្ខបុកម្នេញដោយមូលហេតុសាសនា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងពេលជម្លោះប្រដាប់អាវុធ ឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ ក្នុងអំឡុងពេលចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[494]
។

អ.វ.ត.ក. មានយុត្តាធិការលើឧក្រិដ្ឋកម្មអន្តរជាតិ និងអាចអនុវត្តទម្រង់នៃការទទួលខុសត្រូវដែលមានអត្ថិភាពក្នុងច្បាប់អន្តរជាតិ សូម្បីតែក្នុងករណីដែលឧក្រិដ្ឋកម្មនិងទម្រង់នៃការទទួលខុសត្រូវទាំងអស់នេះ មិនមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌជាតិរបស់កម្ពុជាត្រឹមឆ្នាំ១៩៧៥ ក៏ដោយ។ អង្គបុរេជំនុំជម្រះបានបដិសេធការជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក. លើឧក្រិដ្ឋកម្មអន្តរជាតិ ដែលថាឧក្រិដ្ឋកម្មអន្តរជាតិមិនត្រូវបានប្រកាសឱ្យប្រើនៅក្នុងច្បាប់ជាតិ នៅពេលនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងថាការអនុវត្តយុត្តាធិការទាំងនេះនឹងរំលោភលើគោលការណ៍នីត្យានុកូលភាពជាតិ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា៖

> នៅក្នុងការទាមទារឱ្យ អ.វ.ត.ក. អនុវត្តច្បាប់សន្ធិសញ្ញា និងច្បាប់ទំនៀមទម្លាប់ ដែលកំណត់បទល្មើសអន្តរជាតិចម្បងៗ ជាបទល្មើសព្រហ្មទណ្ឌ ដោយផ្ទាល់តែម្តង និងការទាមទារឱ្យ អ.វ.ត.ក. អនុវត្តយុត្តាធិការរបស់ខ្លួនលើបទល្មើសទាំងនេះ ឱ្យស្របទៅនឹងគោលការណ៍នីត្យានុកូលភាពអន្តរជាតិ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ប្រទេសកម្ពុជាបានអនុវត្តវិធីសាស្ត្រ ដែលរដ្ឋមួយចំនួនបានយកមកអនុវត្តរួចមកហើយ ដែលវិធីសាស្ត្រនេះ យោងតាមបទប្បញ្ញត្តិនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប បានចែងបញ្ចូលអញ្ញត្រកម្មលើបទល្មើសអន្តរជាតិ ដោយអនុញ្ញាតឱ្យកំណត់ទៅតាមគោលការណ៍នីត្យានុកូលភាពនៅក្នុងច្បាប់ជាតិរបស់ខ្លួន។ ទោះបីជាករណីនេះ មិនឆ្លុះបញ្ចាំងអំពីការអនុវត្តរួមមួយ និងជាហូរហែមកក៏ដោយ តុលាការក្នុងស្រុកមួយចំនួនបានចេញសេចក្តីសម្រេចរបស់ខ្លួនដោយអនុវត្តបទដ្ឋានគោលការណ៍នីត្យានុកូលភាពខុសគ្នារវាងបទល្មើសជាតិ និងបទល្មើសអន្តរជាតិ។ ហេតុដូច្នេះ រដ្ឋមួយចំនួនបានអនុវត្តច្បាប់អន្តរជាតិដោយផ្ទាល់តែម្តង ដោយគ្រាន់តែផ្អែកលើសន្ធិសញ្ញា និង/ឬ ច្បាប់ទំនៀមទម្លាប់ ដោយមិនចាំបាច់មានបទប្បញ្ញត្តិជាក់លាក់ណាមួយនៅក្នុងច្បាប់ជាតិ ចែងកំណត់ថា ទង្វើមួយជាបទល្មើសព្រហ្មទណ្ឌ ឬនៅក្នុងករណីមួយចំនួន ដោយគ្រាន់តែបញ្ចូលច្បាប់អន្តរជាតិតែប៉ុណ្ណោះ។ [...] គ្មានទទ្បីករណ៍ណាមួយ [...] ជំរុញឱ្យអង្គបុរេជំនុំជម្រះជឿថា ខ្លួនមានកាតព្វកិច្ចអនុវត្តយុត្តាធិការលើបទល្មើសអន្តរជាតិ ឱ្យស្របតាមគោល

[492] វិធានផ្ទៃក្នុង វិធាន ៧៣។

[493] សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន របស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៧។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤០-៤៤។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ D359/24 & 360/33 ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ៣០។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E004/2/1/1/2 ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៦១។

[494] ច្បាប់ អ.វ.ត.ក. មាត្រា១-៨។ សូមមើល ជំពូក ៣.៣ ទាក់ទងនឹងយុត្តិសាស្ត្ររបស់ អ.វ.ត.ក.។

> ការណ៍នីត្យានុកូលភាពជាតិ ហើយមានកាតព្វកិច្ចមិនត្រូវគោរពតាមបទដ្ឋានណែនាំយ៉ាងច្បាស់លាស់របស់ អ.វ.ត.ក. នៅក្នុងករណីនេះឡើយ[495]។

អង្គបុរេជំនុំជម្រះបានសម្រេចបន្ថែមជាពិសេសទៀតថា ទាក់ទងទៅនឹងអំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ៖

> ទោះបីជាសន្ធិសញ្ញាមិនត្រូវបានអនុវត្តនៅក្នុងច្បាប់កម្ពុជាក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក៏ដោយ ក៏សន្ធិសញ្ញានេះត្រូវគោរពតាមគោលការណ៍ *គោរពកិច្ចព្រមព្រៀង*។ [...] មាត្រា ២៧ នៃអនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញា ហាមឃាត់ភាគីនៃសន្ធិសញ្ញា មិនឱ្យយកច្បាប់ជាតិមកធ្វើជាយុត្តិកម្ម នៅពេលខ្លួនខកខានមិនបំពេញកាតព្វកិច្ចរបស់ខ្លួន។ ដូច្នេះ ករណីនេះបញ្ជាក់យ៉ាងច្បាស់ថា បុគ្គលម្នាក់ៗអាចទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុស័ញ្ញាទីក្រុងហ្សឺណែវ[496]។

### ៣.៧.៥. ភាសា

អ.វ.ត.ក. ដំណើរការជាបីភាសា៖ ភាសាខ្មែរ អង់គ្លេស និង បារាំង[497]។ “ភាសាផ្លូវការ” របស់ អ.វ.ត.ក. គឺភាសាខ្មែរ[498] ខណៈដែលភាសាទាំងបីត្រូវបានចាត់ទុកថាជា “ភាសាការងារ”[499]។

ឯកសារទាំងអស់ដែលដាក់នៅ អ.វ.ត.ក. តម្រូវឱ្យមានជាភាសាខ្មែរ និងជាភាសាអង់គ្លេស ឬភាសាបារាំង ដើម្បីជួយសម្រួលដល់ដំណើរការពហុភាសា។ ទោះបីជាការណ៍នេះរំពឹងថាកើតឡើងក្នុងពេលដំណាលគ្នា សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះអាចអនុញ្ញាតឱ្យភាគីដាក់ឯកសារជាភាសាអង់គ្លេស ឬជាភាសាបារាំងជាមុនសិន ចំណែកការបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន[500]។

### ៣.៧.៦. ការចូលរួមរបស់ជនរងគ្រោះ

នៅ អ.វ.ត.ក. ជនរងគ្រោះអាចចូលរួមជាពិសេសនៅក្នុងកិច្ចដំណើរការនីតិវិធីតាមវិធីមួយចំនួន៖

- ក្នុងនាមជា**អ្នកដាក់បណ្តឹង** ដែលផ្តល់ព័ត៌មានទៅឱ្យសហព្រះរាជអាជ្ញា សម្រាប់ប្រើប្រាស់ក្នុងការចោទប្រកាន់
- ក្នុងនាមជា**ដើមបណ្តឹងរដ្ឋប្បវេណី** ដែលគាំទ្រការចោទប្រកាន់ក្នុងពេលជំនុំជម្រះ និងពេលបណ្តឹងសាទុក្ខ និងក្នុងតុលាការ ដោយផ្តល់សេចក្តីថ្លែងអំពីទុក្ខ និងមានមេធាវីតំណាង
- ក្នុងនាមជា**សាក្សី** ដែលផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហម
- តាមរយៈការស្នើសុំ**សំណង**ផ្លូវចិត្ត និងសមូហភាព ដើម្បីទទួលស្គាល់ជាផ្លូវការអំពីការឈឺចាប់ និងភាពរងគ្រោះរបស់ខ្លួន
- តាមរយៈការចូលរួមក្នុង**កម្មវិធីផ្សព្វផ្សាយ** និង**វិធានការក្រៅតុលាការ**

ទម្រង់នៃការចូលរួមទាំងអស់ខាងលើនេះមានពិភាក្សាបន្ថែមទៀតក្នុងជំពូក ៤.៤.១ (ផ្នែកគាំពារជនរងគ្រោះ) ៤.៤.៣ (ផ្នែកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង ផ្នែកសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី) ៤.៧.១.២ (អង្គភាពគាំពារសាក្សី និងអ្នកជំនាញ) និង ៦ (សំណង)។

---

[495] សំណុំរឿង 00២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/3/15 កថាខណ្ឌ ៩៧។

[496] សំណុំរឿង 00២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/3/15 កថាខណ្ឌ ១០៩-១១១។

[497] ច្បាប់ អ.វ.ត.ក. មាត្រា៤៥ (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា២៦(២)។

[498] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល មាត្រា២៦(១)។

[499] ច្បាប់ អ.វ.ត.ក. មាត្រា៤៥ (ថ្មី)។

[500] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. (វិសោធនកម្មទី៨) មាត្រា៧.១-៧.២។

## ៤. សមាសភាព

ជំពូកនេះរៀបរាប់អំពីសមាសភាពរបស់ អ.វ.ត.ក. ចាប់ពីការិយាល័យតុលាការ និងអង្គជំនុំជម្រះរបស់ខ្លួន រហូតដល់ផ្នែកគាំទ្រផ្សេងៗរបស់ អ.វ.ត.ក. ដោយបង្ហាញពីការរៀបចំ និងរដ្ឋបាលតុលាការ។

## ៤.១. ការិយាល័យសហព្រះរាជអាជ្ញា

ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព.") ទទួលខុសត្រូវចំពោះដំណើរការដាក់ពាក្យបណ្ដឹង និងដឹកនាំការស៊ើបអង្កេតបឋម ចូលរួមក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត និងដឹកនាំការចោទប្រកាន់រឿងក្ដីប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឃោរឃៅ ដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យនៅទូទាំងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត បុរេជំនុំជម្រះ ជំនុំជម្រះ និង បណ្ដឹងសាទុក្ខ[501]។

ក.ស.ព. គឺជាការិយាល័យឯករាជ្យនៅក្នុង អ.វ.ត.ក. ដែលដឹកនាំដោយសហព្រះរាជអាជ្ញាពីររូប មួយរូបជាជនជាតិខ្មែរ ("ភាគីជាតិ") និងមួយរូបទៀតជាជនបរទេស ("ភាគីអន្តរជាតិ") ជាបុគ្គលដែលមាន "ចរិតលក្ខណៈ និងស្មារតីខ្ពស់" "កម្រិតសមត្ថភាពវិជ្ជាជីវៈខ្ពស់" និង "បទពិសោធន៍ទូលំទូលាយក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ក្នុងរឿងក្ដីព្រហ្មទណ្ឌ"[502]។ សហព្រះរាជអាជ្ញាជាតិត្រូវបានតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិវិញ ត្រូវបានជ្រើសរើសដោយអគ្គលេខាធិការ អ.ស.ប. ("UNSG") និងចុងក្រោយត្រូវបានតែងតាំងដោយព្រះមហាក្សត្រ បន្ទាប់ពីការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[503]។ សហព្រះរាជអាជ្ញាដែលត្រូវបានតែងតាំងត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសអនុប្រធាន និង ជំនួយការសហព្រះរាជអាជ្ញារបស់ខ្លួន[504]។ លោកស្រី ជា លាង គឺជាសហព្រះរាជអាជ្ញាជាតិ។ តាមលំដាប់ សហព្រះរាជអាជ្ញាអន្តរជាតិមានលោក Robert Petit (កាណាដា) លោក Andrew T. Cayley (ចក្រភពអង់គ្លេស) លោក Nicholas Koumjian (ស.រ.អ.) លោកស្រី Brenda J. Hollis (ស.រ.អ.) និង លោក Dale Lysak (កាណាដា)។

ទោះបីជាសហព្រះរាជអាជ្ញាត្រូវបានតម្រូវឱ្យផ្ដោតលើអភិក្រមរួមសម្រាប់ការចោទប្រកាន់ក៏ដោយ[505] ក៏ពួកគេអាចធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនទៅឱ្យម្នាក់ក្នុងចំណោមពួកគេបាន តាមរយៈសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររួមគ្នាមួយ (លើកលែងតែសម្រាប់កិច្ចជាក់លាក់ដែលត្រូវតែបំពេញរួមគ្នា)[506]។ ពួកគេក៏អាចធ្វើប្រតិភូកម្មកិច្ចការជាក់លាក់ទៅឱ្យអ្នកស៊ើបអង្កេតរបស់ខ្លួន នគរបាលយុត្តិធម៌ ឬសហព្រះរាជអាជ្ញារងរបស់ខ្លួនផងដែរ[507]។ សេចក្ដីសម្រេចរបស់សហព្រះរាជអាជ្ញាមិនអាចប្ដឹងទាស់បានទេ ហើយក្នុងករណីដែលមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ គោលជំហរស្វ័យប្រវត្តិនោះគឺ ការចោទប្រកាន់ត្រូវបន្ត លុះត្រាតែព្រះរាជអាជ្ញាម្នាក់ក្នុងចំណោមអ្នកទាំងពីរបានស្នើសុំថា ការខ្វែងយោបល់គ្នារបស់ពួកគាត់ត្រូវដោះស្រាយដោយអង្គបុរេជំនុំជម្រះ[508]។ អង្គបុរេជំនុំជម្រះត្រូវដោះស្រាយបញ្ហាខ្វែងយោបល់ណាមួយបែបនេះ ដោយសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមចំនួនបួនរូប ហើយប្រសិនបើមិនអាចរកសំឡេងគាំទ្រនេះបានទេ នោះការចោទប្រកាន់ត្រូវបន្ត[509]។

---

501 វិធានផ្ទៃក្នុង វិធាន ៤៩-៥៤។

502 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦(២)។ ច្បាប់ អ.វ.ត.ក. មាត្រា ១៦, ១៩។ វិធានផ្ទៃក្នុង វិធាន១៣(១)។

503 ច្បាប់ អ.វ.ត.ក. មាត្រា ១៨ ថ្មី។

504 វិធានផ្ទៃក្នុង វិធាន ១៣(១)។

505 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦(៤)។

506 វិធានផ្ទៃក្នុង វិធាន ១៣(៣)។

507 វិធានផ្ទៃក្នុង វិធាន ១៣(៤)។

508 ច្បាប់ អ.វ.ត.ក. មាត្រា ២០ ថ្មី។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦-៧។ វិធានផ្ទៃក្នុង វិធាន ១៣ (៦)។

509 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៦-៧។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន៧១។ សូមមើល សំណៅកោសល្យុបសាធារណៈ នៃសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ឯកសារ D1/1.3។

ការចោទប្រកាន់បទឧក្រិដ្ឋទាំងឡាយនៅ អ.វ.ត.ក. អាចធ្វើទៅបានតាមរយៈការផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ "ទោះជាការសម្រេចចិត្តដោយឯកឯង ឬដោយផ្អែកតាមពាក្យបណ្តឹង" ដែលដាក់ដោយបុគ្គលណាម្នាក់ អង្គការណាមួយ ឬប្រភពផ្សេងទៀត ដែលបានដឹងឮ ឬជាជនរងគ្រោះនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់នោះ[510]។ ទោះបីជាសហព្រះរាជអាជ្ញាត្រូវពិចារណាលើរាល់បណ្តឹងជាលាយលក្ខណ៍អក្សរទាំងអស់ដែលបានដាក់ដោយជនរងគ្រោះ និងអ្នកផ្សេងទៀត ដែលបានឃើញបទឧក្រិដ្ឋដែលបានចោទប្រកាន់ ឬដែលបានដឹងឮអំពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ក៏ដោយ ក៏ពាក្យបណ្តឹងទាំងនោះមិនផ្តួចផ្តើមបង្កើតបានជាការចោទប្រកាន់ព្រហ្មទណ្ឌជាស្វ័យប្រវត្តិនោះឡើយ[511]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាបានធ្វើការសម្រេចតាមឆន្ទានុសិទ្ធិរបស់ខ្លួន "ថាតើត្រូវតម្កល់បណ្តឹងទុកឥតចាត់ការ ឬបញ្ចូលបណ្តឹងនោះទៅក្នុងរឿងដែលការស៊ើបអង្កេតបឋមកំពុងដំណើរការ ឬបើកការស៊ើបអង្កេតបឋមថ្មី ឬ បញ្ជូនពាក្យបណ្តឹងនោះដោយផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត"[512]។

ក្នុងអំឡុងពេលស៊ើបអង្កេតបឋម សហព្រះរាជអាជ្ញាទទួលខុសត្រូវចំពោះការកំណត់អត្តសញ្ញាណភ័ស្តុតាង ដែលបង្ហាញថាបទឧក្រិដ្ឋស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. អាចត្រូវបានប្រព្រឹត្តឡើង ក៏ដូចជាការកំណត់អត្តសញ្ញាណជនសង្ស័យ និងសាក្សីសក្ខានុពលផងដែរ[513]។ ប្រសិនបើសហព្រះរាជអាជ្ញាមានហេតុផលជឿជាក់ថា ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានប្រព្រឹត្តឡើង ពួកគេដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅកាន់សហចៅក្រមស៊ើបអង្កេត ដែលរៀបរាប់អំពីអង្គហេតុ បទល្មើសដែលចោទប្រកាន់ ច្បាប់ជាធរមាន និង តាមដែលអាចដឹង ឈ្មោះរបស់បុគ្គលដែលត្រូវស៊ើបអង្កេត[514]។ ប្រសិនបើអង្គហេតុថ្មីលេចឡើងក្រោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានដាក់ ដែលអង្គហេតុទាំងនោះចាំបាច់ត្រូវឱ្យមានការកែប្រែការចោទប្រកាន់ខាងដើម ឬការបន្ថែមការចោទប្រកាន់ណាមួយ សហព្រះរាជអាជ្ញាអាចដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[515]។ មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរសរុបចំនួនបី[516] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួន ១០[517] ត្រូវបានដាក់នៅក្នុងរឿងក្តីទាំងអស់។

---

[510] វិធានផ្ទៃក្នុង វិធាន ៤៩(១)-(២)។
[511] វិធានផ្ទៃក្នុង វិធាន ៤៩(២), (៤)។
[512] វិធានផ្ទៃក្នុង វិធាន ៤៩(៤)។
[513] វិធានផ្ទៃក្នុង វិធាន ៥០(១)។
[514] វិធានផ្ទៃក្នុង វិធាន ៥៣(១)។
[515] វិធានផ្ទៃក្នុង វិធាន ៥៥(២)-(៣)។
[516] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3 (ដែលបានក្លាយជាសំណុំរឿង ០០១ និង សំណុំរឿង ០០២ - សម្ងាត់) ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 (ដែលបានក្លាយជាសំណុំរឿង ០០៣)។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 (ដែលបានក្លាយជាសំណុំរឿង ០០៤)។
[517] សំណុំរឿង ០០២ កំណត់ពន្យល់ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3/V។ សំណុំរឿង ០០២ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាទាក់ទងនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៨ ឯកសារ D83 ។ សំណុំរឿង ០០២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមជាយថាហេតុ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ឯកសារ D146/3។ សំណុំរឿង ០០២ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើចាម ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D196។ សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ D120។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D27។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D237/1។ សំណុំរឿង ០០៤ ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តអង្គតាមាក់ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ D254/1។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

នៅពេលដែលសហព្រះរាជអាជ្ញាបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅឱ្យសហចៅក្រមស៊ើបអង្កេត ពេលនោះដំណាក់កាលស៊ើបអង្កេតបឋមត្រូវបានបិទបញ្ចប់ ដែលនាំឱ្យសហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវចំពោះកិច្ចស៊ើបសួរលើការចោទប្រកាន់ទាំងឡាយ[518]។ ទោះជាយ៉ាងណា ក្នុងអំឡុងពេលកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា អាចបំពេញកិច្ចខាងក្រោមបាន៖

- ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា និងបំពេញកិច្ចស៊ើបសួរ ដែលខ្លួនបានពិចារណាថា "មានប្រយោជន៍ដល់ការស៊ើបសួរ"[519]
- ស្នើសុំឱ្យអង្គបុរេជំនុំជម្រះពិនិត្យសេចក្តីសម្រេចណាមួយ ចេញដោយសហចៅក្រមស៊ើបអង្កេត[520]
- នៅចុងបញ្ចប់កិច្ចស៊ើបសួរ ដាក់ដីកាសន្និដ្ឋានស្ថាពរ ផ្អែកតាមភស្តុតាងដែលបានប្រមូល ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចោទប្រកាន់ជនសង្ស័យ ឬ ស្នើសុំឱ្យលើកលែងចោទប្រកាន់[521]។

បន្ទាប់មកសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ដែលជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬជាដីកាសម្រេចលើកលែងចោទប្រកាន់[522]។

ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ សហព្រះរាជអាជ្ញាអាច៖

- សួរសំណួរសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងជនជាប់ចោទ (ប្រសិនបើជនជាប់ចោទផ្តល់ភស្តុតាង) និងបង្ហាញអំណះអំណាងអង្គច្បាប់ និងអង្គហេតុលើភស្តុតាង និងការចោទប្រកាន់[523]
- ធ្វើសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់នៅពេលចាប់ផ្តើម និងធ្វើសេចក្តីសន្និដ្ឋានបិទនៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធី[524]
- ដាក់បណ្តឹងសាទុក្ខភ្លាមៗទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលជំនុំជម្រះ ផ្អែកលើកំហុសអង្គច្បាប់និងអង្គហេតុ និងកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិ[525]
- បន្ទាប់ពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង ប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល ដោយមានការជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ថាតើកំហុសអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូងនាំឱ្យសាលក្រមនោះមោឃភាពដោយរបៀបណា និង/ឬកំហុសអង្គហេតុណាខ្លះនាំឱ្យមានភាពអយុត្តិធម៌ដោយរបៀបណា[526]

---

បន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D272/1។

[518] វិធាន ៥៥(២)-(៣) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សំណុំរឿង ០០៣ ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង០០៣ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ ឯកសារ D14 កថាខណ្ឌ ៥។ សំណុំរឿង ០០៣ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសេចក្តីប្រកាសព័ត៌មានជាសាធារណៈ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ឯកសារ D14/1/3 កថាខណ្ឌ ៣០-៣១។

[519] វិធានផ្ទៃក្នុង វិធាន ៥៥(១០)។

[520] វិធានផ្ទៃក្នុង វិធាន ៧៤(២)។

[521] វិធានផ្ទៃក្នុង វិធាន ៦៦(៥)។ ក្នុងសំណុំរឿង ០០៤/១, ០០៤/២, ០០៣ និង ០០៤ ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហព្រះរាជអាជ្ញាជាតិស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតលើកលែងចោទប្រកាន់រឿងក្តីប្រឆាំង អ៊ឹម ចែម, អោ អាន, មាស មុត និង យឹម ទិត្យ។ សូមមើល សំណុំរឿង ០០៤/០១ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹង អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D304/1។ សំណុំរឿង ០០៤/០២ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹង អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/4។ សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹង មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/6។

[522] វិធានផ្ទៃក្នុង វិធាន ៦៧(១)។

[523] វិធានផ្ទៃក្នុង វិធាន ៨០, ៩០-៩១។

[524] វិធានផ្ទៃក្នុង វិធាន ៨៩ ស្ទួន(២), ៩៤។

[525] វិធានផ្ទៃក្នុង វិធាន ១០៤(១), ១០៥(២)។

[526] វិធានផ្ទៃក្នុង វិធាន១០៤(១), ១០៥(៣)។

- នៅពេលណាដែលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចូលជាស្ថាពរ ស្នើសុំការអនុវត្តទោស និងស្នើសុំជំនួយពីអាជ្ញាធរអនុវត្តច្បាប់ ដើម្បីធានាដល់ការអនុវត្តទោស[527]។

បន្ថែមលើការទទួលខុសត្រូវតាមផ្នែកតុលាការរបស់ខ្លួន ក.ស.ព. បានធ្វើសកម្មភាពផ្សព្វផ្សាយ ក្នុងកិច្ចសហការជាមួយអង្គភាពផ្សេងទៀតនៃ អ.វ.ត.ក. ដូចជា ផ្នែកកិច្ចការសាធារណៈ ផ្នែកគាំពារជនរងគ្រោះ និងផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សកម្មភាពទាំងអស់នេះបានផ្សព្វផ្សាយការងាររបស់ អ.វ.ត.ក. ទាំងការងារទាក់ទងនឹងការងារសំខាន់ៗរបស់ខ្លួន និងវិធានផ្នែកនីតិវិធី ទៅកាន់អ្នកចូលរួមផ្សេងៗ។ អ្នកចូលរួមទាំងអស់នេះរួមមាន សាធារណជនកម្ពុជា សិស្ស និស្សិត អ្នកហាត់ការផ្នែកតុលាការ ចៅក្រម និងព្រះរាជអាជ្ញាកម្ពុជា និងពីបរទេស តំណាងមកពីរដ្ឋាភិបាល និងមកពីអង្គការក្រៅរដ្ឋាភិបាល។

## ៤.២. ការិយាល័យសហចៅក្រមស៊ើបអង្កេត

ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស.) ទទួលខុសត្រូវចំពោះការបំពេញកិច្ចស៊ើបសួរ នៅចំពោះមុខ អ.វ.ត.ក.[528]។ កិច្ចស៊ើបសួរ “ត្រូវតែធ្វើឡើងដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ” មានន័យថា កិច្ចស៊ើបសួរត្រូវតែធ្វើឡើងមុនពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះណាមួយអាចចាប់ផ្តើម[529]។ អាណត្តិរបស់ ក.ស.ច.ស. បានមកពីច្បាប់កម្ពុជា ដែលប្រើគំរូនៃ “ចៅក្រមស៊ើបសួរ” របស់បារាំង ឬ “*juge d’instruction*” ដែលទទួលខុសត្រូវចំពោះការស៊ើបអង្កេតមុនពេលជំនុំជម្រះ[530]។

ក.ស.ច.ស. គឺជាការិយាល័យឯករាជ្យ ដែលដឹកនាំដោយសហចៅក្រមស៊ើបអង្កេតកម្ពុជាម្នាក់ (“ភាគីជាតិ”) និងបរទេសម្នាក់ (“ភាគីអន្តរជាតិ”) ដែល “មានចរិតលក្ខណៈនិងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត” និងជាអ្នកដែលមាន “គុណសម្បត្តិ ដែលតម្រូវសម្រាប់តែងតាំងឱ្យបម្រើការក្នុងការិយាល័យតុលាការនៅក្នុងប្រទេសរបស់ខ្លួនក្នុងផ្នែកនេះ”[531]។ ស្រដៀងគ្នាទៅនឹងដំណើរការតែងតាំងសហព្រះរាជអាជ្ញាដែរ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានតែងតាំងសហចៅក្រមស៊ើបអង្កេតជាតិ ហើយ UNSG បានជ្រើសរើសសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលចុងក្រោយត្រូវបានតែងតាំងដោយព្រះមហាក្សត្របន្ទាប់ពីទទួលបានការអនុម័តយល់ព្រមពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[532]។ សហចៅក្រមស៊ើបអង្កេតក៏ “មានបុគ្គលិកខ្មែរ និងបុគ្គលិកអន្តរជាតិជាជំនួយការទៅតាមតម្រូវការជាក់ស្តែងសម្រាប់បម្រើការនៅការិយាល័យរបស់ខ្លួន”ផងដែរ[533]។ សហចៅក្រមស៊ើបអង្កេតជាតិគឺចៅក្រម យូ ប៊ុនឡេង នៅក្នុងប្រតិបត្តិការ អ.វ.ត.ក. ទាំងមូល។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានចៅក្រម Marcel Lemonde (បារាំង) ចៅក្រម Siegfried Blunk (អាល្លឺម៉ង់) ចៅក្រម Laurent Kasper-Ansermet (បម្រុង) (ស្វីស) ចៅក្រម Mark Brian Harmon (ស.រ.អ.) និងចៅក្រម Michael Bohlander (អាល្លឺម៉ង់) តាមលំដាប់។

ស្រដៀងគ្នាទៅនឹងសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតអាចធ្វើប្រតិភូកម្មអំណាចរួមគ្នារបស់ខ្លួនទៅឱ្យម្នាក់ក្នុងចំណោមពួកគាត់ តាមរយៈសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររួមគ្នា ឬធ្វើប្រតិភូកម្មការអនុវត្តមុខងារជាក់លាក់ទៅឱ្យអ្នកស៊ើបអង្កេតរបស់ខ្លួន ឬនគរបាលយុត្តិធម៌ តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស[534]។ ទោះបីជាសហចៅក្រមស៊ើបអង្កេតតម្រូវឱ្យសហការគ្នាដើម្បីសម្រេចបានវិធីសាស្ត្រ

---

[527] វិធានផ្ទៃក្នុង វិធាន ១១៣។
[528] ច្បាប់ អ.វ.ត.ក. មាត្រា ២៣ ថ្មី។
[529] វិធានផ្ទៃក្នុង វិធាន ៥៥(១)។
[530] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ ដីកាបង្គាប់ទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺអំពីការចោទប្រកាន់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D198/1។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៣៥។
[531] ច្បាប់ អ.វ.ត.ក. មាត្រា ២៥។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៥(១)-(៣)។ វិធានផ្ទៃក្នុង វិធាន ១៤(១)។
[532] ច្បាប់ អ.វ.ត.ក. មាត្រា ២៦ ថ្មី។
[533] ច្បាប់ អ.វ.ត.ក. មាត្រា ២៨។
[534] វិធានផ្ទៃក្នុង វិធាន ១៤(៤)-(៥)។

រួមចំពោះការស៊ើបអង្កេតយ៉ាងណាក្តី ក៏ពួកគេមិនតម្រូវឱ្យសម្រេចឱ្យបាននូវការឯកភាពគ្នានេះដែរ[535]។ ក្នុងករណីដែលមានការខ្វែងយោបល់គ្នាចំពោះថាតើការស៊ើបអង្កេតត្រូវបន្តឬយ៉ាងណានោះ គោលជំហរស្វ័យប្រវត្តិអនុលោមតាមមាត្រា ៥(៤) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល គឺថាការស៊ើបអង្កេតត្រូវបន្ត ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនស្នើសុំថា ការខ្វែងយោបល់របស់ខ្លួនត្រូវដោះស្រាយដោយអង្គបុរេជំនុំជម្រះទេនោះ។ កត់សម្គាល់ថា ក្របខ័ណ្ឌ អ.វ.ត.ក. មិនចែងដាច់ខាតថា សហចៅក្រមស៊ើបអង្កេតត្រូវតែបញ្ជូនជម្លោះរបស់ខ្លួនទៅឱ្យអង្គបុរេជំនុំជម្រះដោះស្រាយនោះឡើយ ហើយមានឆន្ទានុសិទ្ធិធ្វើកំណត់ហេតុបញ្ហាខ្វែងយោបល់គ្នារបស់ខ្លួនជាលក្ខណៈផ្ទៃក្នុង[536]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចបញ្ជូនបញ្ហាវិវាទរបស់ខ្លួនទៅអង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបញ្ហាវិវាទនេះតម្រូវឱ្យមានសំឡេងភាគច្រើនលើសលប់ពីចៅក្រមចំនួនបួនរូប[537]។ ប្រសិនបើមិនមានសំឡេងភាគច្រើនលើសលប់សម្រាប់សេចក្តីសម្រេចទេនោះ គោលជំហរស្វ័យប្រវត្តិនោះគឺថា ការស៊ើបអង្កេតត្រូវបន្ត[538]។

មាត្រា ៥(៣) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល បានកម្រិតវិសាលភាពនៃការស៊ើបអង្កេតរបស់ ក.ស.ច.ស. ត្រឹមតែបុគ្គលទាំងឡាយណាដែល អ.វ.ត.ក. មានយុត្តាធិការបុគ្គលលើប៉ុណ្ណោះ[539]។ ក្នុងការអនុវត្តការស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតតម្រូវឱ្យបំពេញកិច្ចដោយឯករាជ្យ និងមិនលម្អៀង ដោយមិនមានការស្វែងរកការណែនាំ ឬទទួលការណែនាំពីរដ្ឋាភិបាលណាមួយ ឬប្រភពណាមួយផ្សេងទៀតឡើយ[540]។ ការស៊ើបអង្កេតរបស់ពួកគេ ក៏ត្រូវបានធ្វើឡើងជាសម្ងាត់ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគីផងដែរ[541] និងដើម្បីឱ្យមានការការពារសាក្សី និងជនរងគ្រោះ[542]
។

សហចៅក្រមស៊ើបអង្កេតបានចាប់ផ្តើមការស៊ើបអង្កេតលើអង្គហេតុ បន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងក្នុងករណីពាក់ព័ន្ធ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពីសហព្រះរាជអាជ្ញា[543]។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវលើការប្រមូលភស្តុតាង ដើម្បីកំណត់ថាតើអង្គហេតុដែលបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬទេ[544]។ សហចៅក្រមស៊ើបអង្កេតស៊ើបសួរតែអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ ហើយប្រសិនបើសហចៅក្រមស៊ើបអង្កេតដឹងថាមានអង្គហេតុថ្មី ពួកគេត្រូវជូនដំណឹងទៅសហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំណត់ក្នុងដីកាសន្និដ្ឋានដែលមានស្រាប់[545]។ ក្នុងការអនុវត្តការស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអាច "ចាត់វិធានការស៊ើបសួរ" ដែលខ្លួនចាត់ទុកថានាំទៅរកការបង្ហាញការពិត រួមមាន៖

- កោះហៅ និងសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ
- ស្តាប់ចម្លើយជនរងគ្រោះ និងសាក្សី
- ប្រមូលវត្ថុតាង ស្វែងរកមតិយោបល់ពីអ្នកជំនាញ និងដឹកនាំការស៊ើបសួរចុះដល់ទីកន្លែងកើតហេតុ

---

535 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៥(៤)។ ច្បាប់ អ.វ.ត.ក.មាត្រា ២៣ ថ្មី។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ១៤(៧), ៧២(១)។ សូមមើលផងដែរ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ២៧៥។
536 វិធានផ្ទៃក្នុង វិធាន ៧២(១)-(២)។
537 ច្បាប់ អ.វ.ត.ក. មាត្រា ២៣ ថ្មី។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៥(៤), ៧(៤)។
538 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៥(៤) និង ៧(៤)។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ៧២(៤)(ឃ)។
539 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៥(៣)។ ទាក់ទងនឹងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. សូមមើល ជំពូក ៣.៣.៤។
540 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៥(៣)។ វិធានផ្ទៃក្នុង វិធាន ១៤(១), ៥៥(៥)។
541 វិធានផ្ទៃក្នុង វិធាន ៥៦(១)។
542 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២៣។ វិធានផ្ទៃក្នុង វិធាន ៥៥(៥)(ខ)។
543 វិធានផ្ទៃក្នុង វិធាន ៥៥(២), (៥)។
544 វិធានផ្ទៃក្នុង វិធាន ៥៥(២)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៥(៣)។
545 វិធានផ្ទៃក្នុង វិធាន ៥៥(២)-(៣)។

- ស្វែងរកជំនួយពីរដ្ឋនានា អ.ស.ប. និងអង្គការផ្សេងៗទៀត ដែលពួកគេជឿថាសមស្រប
- តាមការចាំបាច់ ចេញដីកានានាដើម្បីបំពេញកិច្ចស៊ើបសួរ ដូចជាដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាបង្គាប់ឱ្យចាប់ខ្លួន[546]។

សហចៅក្រមស៊ើបអង្កេតមានអំណាចចោទប្រកាន់បុគ្គលណាដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងអ្នកដែលមាន "តម្រុយច្បាស់លាស់ និងស៊ីចង្វាក់បញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ" ចំពោះការប្រព្រឹត្តបទឧក្រិដ្ឋស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក.[547]។ ក្នុងការដាក់ឱ្យស្ថិតក្រោមការពិនិត្យ សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ចឱ្យគោរពតាមការកំណត់បទល្មើស ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាឡើយ ប៉ុន្តែមានសិទ្ធិកំណត់ប្រភេទបទល្មើសនៃអង្គហេតុដែលខ្លួនយល់ថាសមស្របដោយសេរី។ ទោះបីជាការជូនដំណឹងផ្លូវការអំពីការដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយសហចៅក្រមស៊ើបអង្កេត បានកំណត់ជាក់លាក់អំពីការកំណត់បទល្មើសនៃអង្គហេតុទាំងនោះក្តី ក៏ការកំណត់បទល្មើសទាំងនោះ មានលក្ខណៈបណ្តោះអាសន្នប៉ុណ្ណោះនៅដំណាក់កាលកិច្ចស៊ើបសួរនេះ[548]។

បញ្ហាមួយដែលមិនត្រូវបានដោះស្រាយសម្រាប់សហចៅក្រមស៊ើបអង្កេតនោះគឺ ថាតើពួកគេមានអំណាចដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខដែរឬទេ។ ក្នុងសំណុំរឿង ០០៣ និង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon បានសន្និដ្ឋាន ផ្អែកលើការវិភាគរបស់គាត់លើក្របខ័ណ្ឌ អ.វ.ត.ក. ច្បាប់កម្ពុជា និងវិធាននីតិវិធីនៅកម្រិតអន្តរជាតិថា សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិដាក់ជនសង្ស័យឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ នៅពេលដែលពួកគេបដិសេធមិនចូលបង្ហាញខ្លួនលើកដំបូង[549]។ ទោះជាយ៉ាងណា ដោយសារតែជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ចុងក្រោយបានមកបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael Bohlander ដូច្នេះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon ត្រូវទៅជាមោឃៈ ហើយអង្គបុរេជំនុំជម្រះមិនចាំបាច់សម្រេចថាតើការដាក់ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខអាចធ្វើទៅបាននៅ អ.វ.ត.ក. ឬយ៉ាងណានោះឡើយ[550]។

ក្នុងពេលណាមួយមុនពេលបិទកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាជាក់លាក់ ឬ បំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ថាចាំបាច់សម្រាប់ការធ្វើការស៊ើបអង្កេត[551]។ នៅចុងបញ្ចប់ការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីនានាអំពីការបិទបញ្ចប់របស់ខ្លួន ដែលបន្ទាប់មកភាគីមានរយៈពេល ១៥ ថ្ងៃដើម្បីស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយបន្ថែមទៀត[552]។ នៅពេលដែលផុតរយៈពេលនេះ ឬរយៈពេលនេះត្រូវបានបោះបង់ចោល កិច្ចស៊ើបសួរដែលត្រូវបានស្នើសុំត្រូវបានបំពេញរួចហើយ ឬបណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងការបដិសេធរបស់ខ្លួនត្រូវបានស្តាប់សវនាការដោយអង្គបុរេជំនុំជម្រះរួចហើយនោះ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅកាន់សហព្រះរាជអាជ្ញា ដែលបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន[553]។

---

546 វិធានផ្ទៃក្នុង វិធាន ៥៥(៥)។
547 វិធានផ្ទៃក្នុង វិធាន ៥៥(៤)។
548 សំណុំរឿង ០០២ ដីកាបង្គាប់ទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺអំពីការចោទប្រកាន់ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D198/1 កថាខណ្ឌ ១០។
549 សំណុំរឿង ០០៣ សេចក្តីសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128។ សំណុំរឿង ០០៤ សេចក្តីសម្រេចដាក់ អ៊ឹម ចែម ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D239។
550 សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីជូនដំណឹងអំពីការចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេត Harmon ប្រឆាំងនឹង មាស មុត ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D128.1/1/11។
551 វិធានផ្ទៃក្នុង វិធាន ៥៥(១០)។
552 វិធានផ្ទៃក្នុង វិធាន ៦៦(១)។
553 វិធានផ្ទៃក្នុង វិធាន ៦៦(៤)-(៥)។

សហចៅក្រមស៊ើបអង្កេត មិនជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញានោះទេ និងអាចបិទបញ្ចប់ការស៊ើបអង្កេតដោយការចេញដីកាដំណោះស្រាយ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬជាដីកាសម្រេចលើកលែងចោទប្រកាន់[554]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវកំណត់អត្តសញ្ញាណជនជាប់ចោទ និងការរៀបរាប់អំពីអង្គហេតុពាក់ព័ន្ធសំខាន់ៗ និងការកំណត់បទល្មើស ដោយសហចៅក្រមស៊ើបអង្កេត ដែលរួមបញ្ចូលបទប្បញ្ញត្តិព្រហ្មទណ្ឌពាក់ព័ន្ធ និងលក្ខណៈនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[555]។ ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវចេញ ក្នុងករណីដែលអំពើនោះមិនបង្កើតបានជាឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ចារីមិនត្រូវបានកំណត់អត្តសញ្ញាណ ឬមិនមានភស្តុតាងគ្រប់គ្រាន់សម្រាប់ចោទប្រកាន់ជនត្រូវចោទ[556]។ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវទទួលបានការជូនដំណឹងអំពីដីកាដំណោះស្រាយ[557]។

សហព្រះរាជអាជ្ញាមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ទោះវាជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬជាដីកាសម្រេចលើកលែងចោទប្រកាន់[558]។ ជនត្រូវចោទ ឬជនជាប់ចោទក៏អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែរ ក្នុងកម្រិតដែលថាវា "បញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"[559]។ លើសពីនេះ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ប្រសិនបើដីកាដំណោះស្រាយនោះត្រូវបានប្តឹងឧទ្ធរណ៍ដោយសហព្រះរាជអាជ្ញា[560]។

ប្រសិនបើមិនមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទេនោះ (ឬប្រសិនបើដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពបន្ទាប់ពីបណ្តឹងឧទ្ធរណ៍) ក្រឡាបញ្ជី ក.ស.ច.ស. បញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ដើម្បីកំណត់កាលបរិច្ឆេទសម្រាប់ការជំនុំជម្រះ[561]។ ប្រសិនបើមិនមានបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ទេនោះ (ឬប្រសិនបើដីកាសម្រេចលើកលែងចោទប្រកាន់មានសុពលភាពបន្ទាប់ពីបណ្តឹងឧទ្ធរណ៍) សំណុំរឿងនឹងត្រូវតម្កល់ទុកក្នុងបណ្ណសារ[562]។ ចាប់ពីពេលនេះទៅ សហចៅក្រមស៊ើបអង្កេតមិនដើរតួនាទីណាមួយបន្ថែមទៀតទេនៅក្នុងរឿងក្តី។ ទោះជាយ៉ាងណា ប្រសិនបើ និងនៅពេលណាអាចមានភស្តុតាងថ្មី ក្រោយពេលចេញដីកាសម្រេចលើកលែងចោទប្រកាន់ កិច្ចស៊ើបសួរតាមផ្លូវតុលាការអាចបើកឡើងវិញដោយសហចៅក្រមស៊ើបអង្កេត តាមគំនិតផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញា[563]។

ក.ស.ច.ស. បានចេញសេចក្តីសម្រេច ដីកា និងឯកសារតុលាការផ្សេងទៀតនៅក្នុងសំណុំរឿងនៅចំពោះមុខខ្លួនចំនួនជាង ១.៤០០។

## ៤.៣. អង្គជំនុំជម្រះតុលាការ

### ៤.៣.១. ការតែងតាំងចៅក្រម

ការតែងតាំងចៅក្រមនៅអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូលមានរៀបរាប់នៅក្នុងជំពូក ៤ នៃច្បាប់ អ.វ.ត.ក.[564]។ មាត្រា ១០ ថ្មី ចែងអំពីការតែងតាំងចៅក្រមពីបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ និងមានបទពិសោធន៍ធ្លាប់ជាចៅក្រម ជាពិសេសក្នុងវិស័យ

554 វិធានផ្ទៃក្នុង វិធាន ៦៧(១)។
555 វិធានផ្ទៃក្នុង វិធាន ៦៧(២)។
556 វិធានផ្ទៃក្នុង វិធាន ៦៧(៣)។
557 វិធានផ្ទៃក្នុង វិធាន ៦៧(៥)។
558 វិធានផ្ទៃក្នុង វិធាន ៧៤(២)។
559 វិធានផ្ទៃក្នុង វិធាន ៧៤(៣)(ក)។
560 វិធានផ្ទៃក្នុង វិធាន ៧៤(៤)(ច)។
561 វិធានផ្ទៃក្នុង វិធាន ៦៩(២)(ក)។
562 វិធានផ្ទៃក្នុង វិធាន ៦៩(២)(ខ)។
563 វិធានផ្ទៃក្នុង វិធាន ៧០។
564 ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី)-១៣។

ច្បាប់ព្រហ្មទណ្ឌ និងច្បាប់អន្តរជាតិ រួមបញ្ចូលទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្ស[565]។ ចៅក្រមត្រូវមានឯករាជភាព ក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួល ឬស្វែងរកការណែនាំពីរដ្ឋាភិបាលណាមួយ ឬពីប្រភពណាមួយឡើយ[566]។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទទួលខុសត្រូវចំពោះការតែងតាំងចៅក្រមជាតិ និងប្រធានអង្គជំនុំជម្រះ ហើយក៏ទទួលខុសត្រូវលើការតែងតាំងចៅក្រមបម្រុងផងដែរ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក៏តែងតាំងបុគ្គលដែលមានសញ្ជាតិបរទេស ដើម្បីបំពេញមុខងារជាចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះផងដែរ ផ្អែកតាមបញ្ជីឈ្មោះបេក្ខជនពី UNSG[567]។ ប្រធានអង្គជំនុំជម្រះនីមួយៗ អាចចាត់តាំងចៅក្រមអន្តរជាតិបម្រុងម្នាក់ ឬច្រើននាក់ ដែលទទួលបានការតែងតាំងរួចហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីមានវត្តមាននៅដំណាក់កាលជំនុំជម្រះ ឬដើម្បីជំនួសចៅក្រមអន្តរជាតិដែលមិនអាចបន្តការជំនុំជម្រះបាន[568]។

## ៤.៣.២. អង្គបុរេជំនុំជម្រះ

ទាំងប្រព័ន្ធតុលាការក្នុងស្រុករបស់កម្ពុជា និងទាំងប្រព័ន្ធតុលាការបារាំង ដែល អ.វ.ត.ក. ផ្អែកលើសុទ្ធតែមិនមានអង្គបុរេជំនុំជម្រះ[569]។ មូលហេតុមានអង្គបុរេជំនុំជម្រះនៅ អ.វ.ត.ក. គឺថា ក្នុងអំឡុងពេលចរចាដ៏អូសបន្លាយពេលដែលឈានទៅរកការបង្កើត អ.វ.ត.ក. រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប. បានប្រមើលថា សហចៅក្រមស៊ើបអង្កេតអាចខ្វែងយោបល់គ្នាយ៉ាងសមហេតុផល ក្នុងរយៈពេលនៃការស៊ើបអង្កេតរបស់ខ្លួន ជាពិសេស លើការសម្រេចអំពីបញ្ហាយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.។ ក្នុងអំឡុងពេលចរចាក្នុងខែមេសា ឆ្នាំ២០០០ អ.ស.ប. បានផ្តល់ជាយោបល់ថា បញ្ហាខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត ត្រូវដោះស្រាយដោយអង្គបុរេជំនុំជម្រះ ដោយចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូប ដោយបានស្នើឡើងនូវវិធានសំឡេងភាគច្រើនលើសលប់ ដើម្បីធានាថា ការចោទប្រកាន់ និងការស៊ើបអង្កេតលើជននងសង្ស័យមិនត្រូវបានបញ្ឈប់ ដោយភាពជាប់គាំងរវាងសហចៅក្រមស៊ើបអង្កេត។ ច្បាប់ អ.វ.ត.ក. ជាចុងក្រោយបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ តម្កល់វិធានសំឡេងភាគច្រើនលើសលប់សម្រាប់អង្គបុរេជំនុំជម្រះថា៖ ប្រសិនបើមិនមានសំឡេងភាគច្រើនលើសលប់ទេ "ការស៊ើបអង្កេតត្រូវបន្ត"។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាល ឆ្លុះបញ្ចាំងច្បាប់ អ.វ.ត.ក.[570] ហើយ វិធានផ្ទៃក្នុងឆ្លុះបញ្ចាំងកិច្ចព្រមព្រៀងរវាង អ.ស.ប. និង រាជរដ្ឋាភិបាល និងច្បាប់ អ.វ.ត.ក.[571]។ តួនាទីដោះស្រាយវិវាទនេះគឺជាមុខងារចម្បងរបស់អង្គបុរេជំនុំជម្រះ។

អង្គបុរេជំនុំជម្រះមានចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូប ហើយសេចក្តីសម្រេចណាមួយរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមចំនួនបួននាក់ ក្នុងចំណោមចៅក្រមទាំងប្រាំនាក់[572]។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះមាន ចៅក្រម ប្រាក់ គឹមសាន (ប្រធាន) ចៅក្រម ហួត វុទ្ធី ចៅក្រម ន័យ ថុល និង ចៅក្រម ប៉ែន ពេជ្រសាលី (បម្រុង)។ ចៅក្រមអន្តរជាតិមានចៅក្រម Rowan Downing (អូស្ត្រាលី) ចៅក្រម Kathinka Lahuis (ហូឡង់) ចៅក្រម Catherine Marchi-Uhel (បារាំង) ចៅក្រម Chang-ho Chung (សាធារណរដ្ឋកូរ៉េ) ចៅក្រម Olivier Beauvallet (បារាំង) ចៅក្រម Kang Jin Baik (សាធារណរដ្ឋកូរ៉េ) និង ចៅក្រម Steven J. Bwana (បម្រុង) (តង់សានី)។

---

565 វិធានផ្ទៃក្នុង វិធាន ១០ (ថ្មី)។ សូមមើលផងដែរ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣(៤)។

566 ច្បាប់ អ.វ.ត.ក. មាត្រា ១០ (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣(៣)។

567 ច្បាប់ អ.វ.ត.ក. មាត្រា ១១ (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣។

568 ច្បាប់ អ.វ.ត.ក. មាត្រា ១១ (ថ្មី)។

569 ប្រព័ន្ធច្បាប់ទាំងពីរមាន "សភាស៊ើបសួរ" ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យភាពប្រក្រតីនៃការស៊ើបអង្កេត និងដំណើរការត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ។

570 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៧(៤)។ មើលផងដែរ ច្បាប់ អ.វ.ត.ក. មាត្រា២៣ (ថ្មី)។

571 វិធានផ្ទៃក្នុង វិធាន ៧២(៤)(ឃ), ៧៧(១៣)។

572 វិធានផ្ទៃក្នុង វិធាន ៧១(៤)(គ), ៧២(៤)(ឃ), ៧៧(១៣)។

ដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត មានឆន្ទានុសិទ្ធិ ថាតើត្រូវចុះកំណត់ហេតុបញ្ហាខ្វែងយោបល់របស់ខ្លួនផ្ទៃក្នុង ឬបញ្ជូនបញ្ហាខ្វែងយោបល់របស់ខ្លួនទៅឱ្យអង្គបុរេជំនុំជម្រះដោះស្រាយ[573]។ ប្រសិនបើអង្គបុរេជំនុំជម្រះបានទទួលបញ្ហាខ្វែងយោបល់នេះហើយ តែបរាជ័យមិនអាចរកសំឡេងភាគច្រើនបាន គោលជំហរស្វ័យប្រវត្តិនោះគឺថា ការចោទប្រកាន់ ឬការស៊ើបអង្កេតត្រូវបន្ត[574]។ ដោយបង្ហាញពីការអនុវត្តវិធានស្វ័យប្រវត្តិ *ចំណុចដែលមិនពាក់ព័ន្ធភស្តុតាងឬសាលក្រម (កំណត់សម្គាល់របស់ចៅក្រម)* នៅក្នុងសាលដីកានៃសំណុំរឿង ០០១ លើការខ្វែងយោបល់គ្នាតាមការសន្មតរវាងសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះតុលាការកំពូលបានលើកហេតុផលថា៖

> ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬក្នុងការស្នើឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬមិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ អង្គបុរេជំនុំជម្រះមិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនេះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"[575]។

អង្គបុរេជំនុំជម្រះ ក៏មានយុត្តាធិការលើបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត យោងតាមមូលដ្ឋានសម្រាប់បណ្ដឹងឧទ្ធរណ៍ដែលមានចែងក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង[576]។ សហព្រះរាជអាជ្ញា អាចប្ដឹងឧទ្ធរណ៍ជំទាស់រាល់ដីកាទាំងអស់របស់សហចៅក្រមស៊ើបអង្កេត[577]។ ជនត្រូវចោទ ឬជនជាប់ចោទ អាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកា ឬសេចក្ដីសម្រេច ដែល *ជាអាទិ៍* បញ្ជាក់យុត្តាធិការរបស់ អ.វ.ត.ក. បដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ សម្រេចលើការឃុំខ្លួនបណ្ដោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ ប្រកាសទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការ[578]។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតបានដែរ ដែល *ជាអាទិ៍* បានបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ប្រកាសមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងវិធានការការពារ និងកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការ។ ដូចបានរៀបរាប់ខាងលើ ពួកគេក៏អាចប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ក្នុងករណីដែលសហព្រះរាជអាជ្ញាប្ដឹងឧទ្ធរណ៍ដែរ[579]។

មុខងារមួយផ្សេងទៀតរបស់អង្គបុរេជំនុំជម្រះ គឺត្រូវសម្រេចលើសំណើសុំមោឃភាពកិច្ចស៊ើបសួរ។ វិធាន ៧៦ នៃវិធានផ្ទៃក្នុងចែងអំពីនីតិវិធីសម្រាប់មោឃភាពកិច្ចស៊ើបសួរ ដោយអង្គបុរេជំនុំជម្រះ។ តាមវិធាន ៧៦(២) នៃវិធានផ្ទៃក្នុង ក្នុងករណីដែលភាគីយល់ឃើញថា ផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីត្រូវចាត់ទុកជាមោឃៈ ភាគីនោះអាចដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុទៅសហចៅក្រមស៊ើបអង្កេត ស្នើសុំឱ្យពួកគេប្ដឹងទៅអង្គបុរេជំនុំជម្រះសុំឱ្យធ្វើមោឃភាពវា[580]។ តួនាទីរបស់សហចៅក្រមស៊ើបអង្កេត បន្ទាប់មកត្រូវពិនិត្យសំណើនោះផ្អែកលើមូលដ្ឋានពីរ៖ (១) អត្ថិភាពនៃវិការៈផ្នែកនីតិវិធី និង (២) ចំណុចដែលមានវិការៈបែបនោះ ថាតើវាបានបណ្ដាលឱ្យមានការរំលោភបំពានលើសិទ្ធិរបស់ភាគី ដែលដាក់ពាក្យសុំនោះដែរឬយ៉ាងណា[581]។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតអនុញ្ញាតទទួលយកសំណើនោះ ប្ដឹងទៅអង្គបុរេជំនុំជម្រះ បន្ទាប់មកអង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើ សំណើនោះអាចទទួលយកបានឬទេ មុនពេលសម្រេច

---

[573] វិធានផ្ទៃក្នុង វិធាន ៧១(១)-(២), ៧២(១)-(២)។
[574] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៧(៤)។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ៧១(៤)(គ), ៧២(៤)(ឃ), ៧៧(១៣)។
[575] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥ (គូសបញ្ជាក់បន្ថែម) ដកស្រង់ច្បាប់ អ.វ.ត.ក. មាត្រា ២៣ (ថ្មី)។ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៧(៤)។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ៧២(៤)(ឃ)។
[576] វិធានផ្ទៃក្នុង វិធាន ៧៣។
[577] វិធានផ្ទៃក្នុង វិធាន ៧៤(២)។
[578] វិធានផ្ទៃក្នុង វិធាន ៧៤(៣)។
[579] វិធានផ្ទៃក្នុង វិធាន ៧៤(៤)។
[580] វិធានផ្ទៃក្នុង វិធាន ៧៦(២)។
[581] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព ចុះថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ២២។

ថាតើត្រូវមោឃៈកិច្ចស៊ើបសួរដែលរងការជំទាស់នោះ[582]។ នីតិវិធីធ្វើមោឃភាពគឺ “មិនមែនសម្រាប់មោឃភាពកិច្ចស៊ើបសួរទូទៅទេ [...] ផ្ទុយទៅវិញនីតិវិធីនេះត្រូវបានកំណត់ឡើងសម្រាប់មោឃភាពផ្នែកទាំងឡាយនៃដំណើរការនីតិវិធី ដែលធ្វើឱ្យខូចប្រយោជន៍របស់ [ភាគី]”[583]។ ដូច្នេះ ពាក្យសុំធ្វើមោឃភាពត្រូវតែ “បញ្ជាក់ហេតុផលឱ្យបានជាក់លាក់ថាតើកិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះណាមួយដែលមានកំហុសនីតិវិធី និងនៅពេលណាដែលអាចអនុវត្តបាន បញ្ជាក់អះអាងពីផលប្រយោជន៍ដែលត្រូវបានប៉ះពាល់”[584]។ នៅពេលដែលអង្គបុរេជំនុំជម្រះអនុញ្ញាតទទួលយកពាក្យសុំមោឃភាព កិច្ចស៊ើបសួរ ឬកិច្ចរបស់តុលាការដែលត្រូវបានប្រកាសថាមោឃៈនោះ ត្រូវដកចេញពីសំណុំរឿង[585]។

លើសពីនេះ អង្គបុរេជំនុំជម្រះក្នុងឱកាសជាច្រើនបានចាត់ទុកខ្លួនឯងថាជា “សភាស៊ើបសួរតាមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា” នៅក្នុង អ.វ.ត.ក. ដែលមានយុត្តាធិការពិនិត្យនីតិវិធី ដែលបានអនុវត្តដោយសហចៅក្រមស៊ើបអង្កេត កែប្រែវិការៈនីតិវិធី និងស៊ើបអង្កេតរឿងក្តីដោយខ្លួនឯង នៅពេលដែលបានទទួលដីកាសម្រេចលើកលែងចោទប្រកាន់[586]។ ឧទាហរណ៍ ក្នុងសំណុំរឿង ០០៤/០២ អង្គបុរេជំនុំជម្រះជាឯកច្ឆ័ន្ទបានពិចារណាថា នៅពេលដែលខ្លួនបំពេញកិច្ចជាសភាស៊ើបសួរ អង្គបុរេជំនុំជម្រះគឺជា “ស្ថាប័នត្រួតពិនិត្យ” ដែលមានយុត្តាធិការចុងក្រោយលើដំណាក់កាលមុនជំនុំជម្រះតាមផ្លូវតុលាការ នៅ អ.វ.ត.ក.[587] អាច “ជាតុលាការស៊ើបអង្កេតថ្នាក់ទីពីរ”[588] មាន “សិទ្ធិអំណាចទូលំទូលាយក្នុងការវាយតម្លៃទៅលើសុចរិតភាពនៃកិច្ចស៊ើបសួរ”[589] និង ចុងក្រោយបង្អស់ “ទទួលខុសត្រូវក្នុងការធានានៅក្នុងដំណាក់កាលស៊ើបសួរថា គោលការណ៍ជាសារវន្តដែលជាមូលដ្ឋាននៃនីតិវិធីព្រហ្មទណ្ឌជាធរមាននៅចំពោះមុខ អ.វ.ត.ក. ត្រូវបានគោរព”[590]។ អង្គបុរេជំនុំជម្រះបានពិចារណាថា អំណាចត្រួតពិនិត្យជាសភាស៊ើបសួរនេះ “ជាគោលបំណងសំខាន់ ក្នុងការធានាថា លក្ខខណ្ឌនៃការចេញដីកាដំណោះស្រាយ និងការស៊ើបអង្កេតជាបឋម អនុលោមតាមវិធាន ២១ និងវិធាន ៧៦ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. និងមាត្រា ២៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា”[591]។

អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេច ដីកា និងឯកសារតុលាការផ្សេងទៀតក្នុងសំណុំរឿងចំពោះមុខខ្លួនចំនួនប្រមាណ ១.៤៥០។ តាមការអនុវត្តជាក់ស្តែង ដោយសារតែមិនអាចសម្រេចបានការព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទលើបញ្ហាមួយចំនួន ឬទាំងអស់ អង្គបុរេជំនុំជម្រះបានចេញ “សេចក្តីពិចារណា”

---

582 វិធានផ្ទៃក្នុង វិធាន ៧៦(៤)-(៥)។

583 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំធ្វើមោឃភាពដោយមូលហេតុរំលោភនីតិវិធី ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១០ ឯកសារ D197/5/8 កថាខណ្ឌ ២៤។

584 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២៤។

585 សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D263/2/6 កថាខណ្ឌ ២៧។

586 សូមមើល សំណុំរឿង ០០១ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤១-៤២។ សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារ C5/45 កថាខណ្ឌ ៦៨។ សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៣០, ៣៥, ៤០-៤១, ៤៤, ៤៧-៤៨, ៥០។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 កថាខណ្ឌ ១២៩-១៣០។ (យោបល់ចៅក្រម Olivier Beauvallet និង Kang-Jin Baik)។

587 សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៣៤, ៤១, ៤៩ (“សេចក្តីពិចារណា”)។

588 សំណុំរឿង ០០៤/០២ សេចក្តីពិចារណា ឯកសារ D359/24 & D360/33 កថាខណ្ឌ ៤១ (លុបយោងខាងក្នុង)។

589 សំណុំរឿង ០០៤/០២ សេចក្តីពិចារណា ឯកសារ D359/24 & D360/33 កថាខណ្ឌ ៤៩ (លុបយោងខាងក្នុង)។

590 សំណុំរឿង ០០៤/០២ សេចក្តីពិចារណា ឯកសារ D359/24 & D360/33 កថាខណ្ឌ ៥២។

591 សំណុំរឿង ០០៤/០២ សេចក្តីពិចារណា ឯកសារ D359/24 & D360/33 កថាខណ្ឌ ៥០។

ចំនួន ៨២ ពោលគឺឯកសារតុលាការ ដែលមានផ្នែកសេចក្តីសម្រេចរួម ដែលមានការសន្និដ្ឋានរបស់ចៅក្រមទាំងអស់ ដែលមានយោបល់ដោយឡែក ឬរួមគ្នារបស់ចៅក្រមលើបញ្ហាដាច់ដោយឡែក។

### ៤.៣.៣. អង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. គឺជាអង្គជំនុំជម្រះដំបូងដែលទទួលខុសត្រូវបើកសវនាការជំនុំជម្រះ និងការចេញសាលក្រមលើពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ជនជាប់ចោទ បន្ទាប់ពីបិទបញ្ចប់កិច្ចស៊ើបសួរដោយតុលាការ[592]។ អង្គជំនុំជម្រះសាលាដំបូង ក៏ចេញសេចក្តីសម្រេចលើបណ្តឹងទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមផងដែរ រួមមានលើសំណើសុំសំណង[593]។

អង្គជំនុំជម្រះសាលាដំបូងមានចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូប[594]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់បួនរូប ក្នុងចំណោមចៅក្រមទាំងប្រាំរូប[595]។ ចៅក្រមជាតិនៃអង្គជំនុំជម្រះសាលាដំបូងមានចៅក្រម និល ណុន (ប្រធាន) ចៅក្រម យ៉ា សុខន ចៅក្រម យូរ ឧត្តរា និងចៅក្រម ធូ មណី (បម្រុង)។ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូងមានចៅក្រម Silvia Cartwright (នូវែលសេឡង់) ចៅក្រម Jean-Marc Lavergne (បារាំង) ចៅក្រម Claudia Fenz (អូទ្រីស) និងចៅក្រម Martin Karopkin (ស.រ.អ.)។

ក្នុងអំឡុងពេលកិច្ចដំណើរការនិតិវិធី អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សវនាការលើភ័ស្តុតាង និងអំណះអំណាងដែលបានបង្ហាញ ក៏ដូចជាការសួរដេញដោលជនជាប់ចោទ និងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី[596]។ សវនាការរបស់អង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងជាសាធារណៈ ហើយការិយាល័យរដ្ឋបាលបានធានាថា សវនាការទាំងនោះបានផ្សព្វផ្សាយជាសាធារណៈ តាមវិធានការការពារដែលមានស្រាប់[597]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងផ្អែកទាំងស្រុងលើ ភ័ស្តុតាងនៅក្នុងសំណុំរឿង ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងបានឆ្លងកាត់ការសួរដេញដោល[598]។ អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិបដិសេធភ័ស្តុតាងជាក់លាក់ ប្រសិនបើវាមិនពាក់ព័ន្ធ ឬចំដែល មិនអាចរកបានក្នុងពេលវេលាសមស្រប មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុ ច្បាប់មិនអនុញ្ញាត មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍[599]។ នៅពេលចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យមានកិច្ចស៊ើបសួរបន្ថែម[600]។ ក្នុងដំណាក់កាលណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងក៏អាចបង្គាប់ថា កិច្ចដំណើរការនីតិវិធីត្រូវបំបែក ប្រសិនបើប្រយោជន៍យុត្តិធម៌តម្រូវឱ្យធ្វើដូច្នោះ[601]។ ចំណុចនេះត្រូវបានធ្វើនៅក្នុងសំណុំរឿង ០០២ ដែលក្នុងខែកញ្ញា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកការចោទប្រកាន់ក្នុងដីកាដំណោះស្រាយទៅជាសំណុំរឿង ០០២/០១ និង សំណុំរឿង ០០២/០២[602]។

កិច្ចប្រជុំពិភាក្សាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានធ្វើឡើងដោយសម្ងាត់ សម្រាប់ឱ្យចៅក្រមធ្វើការសម្រេចចេញសាលក្រម ហើយក្នុងដំណាក់កាលនោះ មិនមានសារណាបន្ថែមអាចធ្វើឡើង

---

592 វិធានផ្ទៃក្នុង វិធាន ៧៩, ៩៨។
593 វិធានផ្ទៃក្នុង វិធាន ១០០។
594 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣(២)(ក)។
595 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៤(១)(ក)។
596 វិធានផ្ទៃក្នុង វិធាន ៨៧, ៩០, ៩១, ៩៤, ១០១(៣)។
597 វិធានផ្ទៃក្នុង វិធាន ៧៩(៦)(ក)។
598 វិធានផ្ទៃក្នុង វិធាន ៨៧(២)-(៣)។
599 វិធានផ្ទៃក្នុង វិធាន ៨៧(៣)។ សូមមើល ឧទាហរណ៍ សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៩ ឯកសារ E43/4 កថាខណ្ឌ ១៦, ២០។ សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងភាពអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រតិចារឹកនៅសំណុំរឿង ០០១ ដែលស្នើសុំដោយសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ឯកសារ E299 កថាខណ្ឌ ៤១។
600 វិធានផ្ទៃក្នុង វិធាន ៩៣។ សូមមើល ឧទាហរណ៍ សំណុំរឿង ០០២/០២ ដីកាសម្រេចធ្វើការស៊ើបអង្កេតទៅលើឯកសារនានាដែលទទួលបានពីសាស្ត្រាចារ្យ Walter Heynowski ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ E443/5។
601 វិធានផ្ទៃក្នុង វិធាន ៨៩ *ស្ទួនពីរ*។
602 សូមមើល ជំពូក ៥.២.៥.២។

បានឡើយ[603]។ ទោះបីជាសាលក្រមអង្គជំនុំជម្រះសាលាដំបូង កំណត់ត្រឹមអង្គហេតុ ដែលមានរៀបរាប់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះអាចផ្លាស់ប្តូរការកំណត់បទចោទនៃឧក្រិដ្ឋកម្ម ដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ដរាបណាការណ៍នេះមិនបញ្ចូលធាតុផ្សំថ្មីនៃបទចោទ[604]។ ក្នុងអំឡុងពេលប្រជុំពិភាក្សារបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យថាតើអំពើដែលបង្កើតបានជាបទល្មើស ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬទេ និងថាតើជនជាប់ចោទបានប្រព្រឹត្តអំពើដែលបានចោទប្រកាន់នោះដែរឬទេ ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានបង្ហាញ[605]។ សាលក្រមទាំងអស់ត្រូវបានចេញ និងប្រកាសក្នុងអំឡុងពេលសវនាការសាធារណៈ ហើយសេចក្តីសង្ខេបសំអាងហេតុ និងផ្នែកសម្រេចសេចក្តីត្រូវបានអានដោយប្រធានអង្គជំនុំជម្រះសាលាដំបូង ឬចៅក្រមណាម្នាក់នៃអង្គជំនុំជម្រះសាលាដំបូង រួមជាមួយនឹងសេចក្តីសង្ខេបយោបល់ជំទាស់ណាមួយ[606]។ ប្រសិនបើជាសាលក្រមដាក់ពិរុទ្ធភាព អង្គជំនុំជម្រះបានកាត់ទោសជនជាប់ចោទ ស្របតាមនីតិវិធីដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក. និងវិធានផ្ទៃក្នុង[607]។ ប្រសិនបើមិនទទួលបានសំឡេងគាំទ្រភាគច្រើនដែលតម្រូវទេនោះ គោលជំហរស្វ័យប្រវត្តិនោះគឺ ជនជាប់ចោទនឹងត្រូវរួចផុតពីបទចោទ ប៉ុន្តែស្ថានភាពនេះមិនធ្លាប់កើតមានទេ[608]។

អង្គជំនុំជម្រះសាលាដំបូងបានចេញដីកា និងសេចក្តីសម្រេចប្រមាណ ៤៣០ នៅក្នុងរឿងក្តីទាំងអស់នៅចំពោះមុខខ្លួន រួមទាំងសាលក្រមចំនួនបីផងដែរ។

### ៤.៣.៤. អង្គជំនុំជម្រះតុលាការកំពូល

អង្គជំនុំជម្រះតុលាការកំពូលបម្រើការជាអង្គជំនុំជម្រះសាលាឧទ្ធរណ៍ផង និងជាអង្គជំនុំជម្រះចុងក្រោយផង[609]។ អង្គជំនុំជម្រះតុលាការកំពូលធ្វើការសម្រេចលើបណ្តឹងសាទុក្ខ ដែលដាក់ដោយសហព្រះរាជអាជ្ញា ជនជាប់ចោទ ឬដោយដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងសេចក្តីសម្រេច ឬសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អំពីកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬ កំហុសក្នុងការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[610]។

អង្គជំនុំជម្រះតុលាការកំពូល មានចៅក្រមចំនួនប្រាំពីររូប ក្នុងនោះមានចៅក្រមជាតិបួនរូប ដែលម្នាក់ជាប្រធាន និងចៅក្រមអន្តរជាតិបីរូប[611]។ សេចក្តីសម្រេចណាក៏ដោយតម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់ចំនួនប្រាំរូប ក្នុងចំណោមចៅក្រមទាំងប្រាំពីររូប[612]។ ចៅក្រមជាតិនៃអង្គជំនុំជម្រះតុលាការកំពូលមាន ចៅក្រម គង់ ស្រីម (ប្រធាន) ចៅក្រម សោម សិរីវុឌ្ឍ ចៅក្រម យ៉ា ណារិន ចៅក្រម ម៉ុង មុន្នីចរិយា និង ចៅក្រម ស៊ិន រិទ្ធ (បម្រុង)។ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះតុលាការកំពូលមាន ចៅក្រម Nihal Jayasinghe (ស្រីលង្កា) ចៅក្រម Motoo Noguchi (ជប៉ុន) ចៅក្រម Florence Ndepele Mwachande Mumba (សំប៊ី) ចៅក្រម Agnieszka Klonowiecka-Milart (ប៉ូឡូញ) ចៅក្រម Maureen Harding Clark (អៀរឡង់) និង ចៅក្រម Phillip Rapoza (ស.រ.អ.) តាមលំដាប់។

ទាំងសហព្រះរាជអាជ្ញា និងទាំងជនជាប់ចោទអាចប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ទៅអង្គជំនុំជម្រះតុលាការកំពូលបាន ចំណែកដើមបណ្តឹងរដ្ឋប្បវេណីវិញអាចប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះអំពីសំណង[613]។ ប្រសិនបើសហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខ

603 វិធានផ្ទៃក្នុង វិធាន ៩៦។
604 វិធានផ្ទៃក្នុង វិធាន ៩៨(២)។
605 វិធានផ្ទៃក្នុង វិធាន ៩៨(៣)។
606 វិធានផ្ទៃក្នុង វិធាន ១០២។
607 វិធានផ្ទៃក្នុង វិធាន ៩៨(៥)។
608 វិធានផ្ទៃក្នុង វិធាន ៩៨(៦)។
609 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣(២)(ខ)។
610 វិធានផ្ទៃក្នុង វិធាន ១០៤(១), ១០៥(១)។
611 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣(២)(ខ)។
612 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៤(១)(ខ)។ វិធានផ្ទៃក្នុង វិធាន ១១១(៦)។
613 វិធានផ្ទៃក្នុង វិធាន ១០៥(១)-(២)។

ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងរួចហើយនោះ ដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងសាទុក្ខប្រឆាំងសាលក្រមបាន ប៉ុន្តែមិនអាចប្តឹងប្រឆាំងនឹងសេចក្តីសម្រេចផ្តន្ទាទោសបានទេ[614]។ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុង ចែងអំពីបណ្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងផ្អែកលើមូលដ្ឋានចំនួនពីរ៖ “កំហុសលើអង្គច្បាប់ ដែលនាំឱ្យមោឃៈសាលក្រមលើអង្គសេចក្តី ឬសេចក្តីសម្រេចនោះមានភាពអយុត្តិធម៌”[615]។ ភាគីដាក់បណ្តឹងសាទុក្ខត្រូវបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួននូវកំហុសអង្គច្បាប់ដែលនាំឱ្យមោឃៈសេចក្តីសម្រេច និង/ឬកំហុសអង្គហេតុដែលនាំឱ្យមានភាពអយុត្តិធម៌ ហើយសារណាបណ្តឹងសាទុក្ខត្រូវតែបង្ហាញអំណះអំណាងដោយមានបញ្ជីឯកសារយោងគាំទ្រមូលដ្ឋាននីយមួយៗ[616]។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះមួយចំនួនអាចត្រូវបានប្តឹងសាទុក្ខភ្លាមៗ ដូចជាសេចក្តីសម្រេចណាដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី សេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឱ្យស្ថិតក្រោមការពិនិត្យតាមផ្លូវតុលាការ សេចក្តីសម្រេចអំពីវិធានការការពារ និងសេចក្តីសម្រេចស្តីពីការជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ[617]។ បន្ថែមលើកំហុសអង្គច្បាប់ និងអង្គហេតុ វិធាន ១០៤(១) នៃវិធានផ្ទៃក្នុងបានផ្តល់មូលដ្ឋានបន្ថែមទៀតសម្រាប់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ពោលគឺ ក្នុងករណីដែលមានកំហុសជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យមានភាពអយុត្តិធម៌[618]។ ក្រោយពីរកឃើញកំហុសអង្គច្បាប់ កំហុសអង្គហេតុ ឬកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរួចមក អង្គជំនុំជម្រះតុលាការកំពូលអាចតម្កល់ កែប្រែ ឬ មោឃៈសេចក្តីសម្រេចទាំងមូល ឬ ដោយផ្នែក[619]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលគឺជាសេចក្តីសម្រេចស្ថាពរ[620]។

ទោះបីជាវិធាន ១០៤(១) និង (៤) នៃវិធានផ្ទៃក្នុង បានចែងថា អង្គជំនុំជម្រះតុលាការកំពូលត្រូវបើកសវនាការបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចជាច្រើនឥតគណនារបស់អង្គជំនុំជម្រះសាលាដំបូងក៏ក្នុងការអនុវត្តជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូលបានកាត់សេចក្តីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចហួសពីវិសាលភាពនៃយុត្តាធិការភ្លាមៗរបស់ខ្លួនទៅទៀត រួមមានការកាត់សេចក្តីលើបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅពេលដែល “មានភាពចាំបាច់តម្រូវឱ្យមានការធានានូវរដ្ឋបាលតុលាការល្អ និងយុត្តិធម៌”[621]។

ដូចគ្នានឹងអង្គជំនុំជម្រះសាលាដំបូងដែរ សវនាការរបស់អង្គជំនុំជម្រះតុលាការកំពូលក៏ធ្វើឡើងជាសាធារណៈផងដែរ ហើយការិយាល័យរដ្ឋបាលធានាថា សវនាការទាំងនោះបានឭផ្សាយជាសាធារណៈតាមវិធានការការពារដែលមានស្រាប់[622]។ ការអនុវត្តទោសបានធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញា ហើយការអនុវត្តសំណងត្រូវបានអនុវត្តដោយអាជ្ញាធរជាតិដែលមានសមត្ថកិច្ច ស្របតាមច្បាប់កម្ពុជា តាមគំនិតផ្តួចផ្តើមរបស់សមាជិកដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់នៃក្រុមសមូហភាព[623]។

---

614 វិធានផ្ទៃក្នុង វិធាន ១០៥។
615 វិធានផ្ទៃក្នុង វិធាន ១០៤(១)។
616 វិធានផ្ទៃក្នុង វិធាន ១០៥(២)។
617 វិធានផ្ទៃក្នុង វិធាន ១០៤(៤)។
618 វិធានផ្ទៃក្នុង វិធាន ១០៤(១)។
619 វិធានផ្ទៃក្នុង វិធាន ១០៤(២)។
620 ច្បាប់ អ.វ.ត.ក. មាត្រា ៣៦(ថ្មី)។
621 សូមមើល ឧទាហរណ៍ សំណុំរឿង ០០៣ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 3/1/1/1។ សំណុំរឿង ០០៤ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1។ សំណុំរឿង ០០៤/០២ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំការបញ្ជាក់បំភ្លឺ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ E284/2/1/2 កថាខណ្ឌ ១២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងការប្រកាសសេចក្តីសម្រេចសង្ខេបនៃសាលក្រមដែលបានធ្វើឡើងនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារ E463/1/3 កថាខណ្ឌ ១៦-១៧។
622 វិធានផ្ទៃក្នុង វិធាន ១០៩(២)។
623 វិធានផ្ទៃក្នុង វិធាន ១១៣។

អង្គជំនុំជម្រះតុលាការកំពូលបានចេញដីកា និងសេចក្តីសម្រេចប្រមាណ ១៦០ នៅក្នុងរឿងក្តីនៅចំពោះមុខខ្លួន រួមទាំងសាលដីកាលើបណ្តឹងសាទុក្ខចំនួនបី។

## ៤.៤. ផ្នែកគាំពារ

### ៤.៤.១. ផ្នែកគាំពារជនរងគ្រោះ

ដើមឡើយវាគឺជាអង្គភាពជនរងគ្រោះ ហើយក្រោយមកបានប្តូរឈ្មោះតាមរយៈវិសោធនកម្មវិធានផ្ទៃក្នុង[624]។ ផ្នែកគាំពារជនរងគ្រោះ គឺជាចំណុចទំនាក់ទំនងរវាង អ.វ.ត.ក. ជនរងគ្រោះ និង តំណាងរបស់ពួកគេ។ ជនរងគ្រោះត្រូវបានកំណត់និយមន័យដោយ អ.វ.ត.ក. ជា "រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ"[625]។ ការការពារផលប្រយោជន៍ជនរងគ្រោះ គឺជាអាណត្តិស្នូលរបស់ អ.វ.ត.ក. ដោយវិធានផ្ទៃក្នុងចែងថាក្របខ័ណ្ឌ អ.វ.ត.ក. ទាំងមូលត្រូវតែ "បកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និង*ជនរងគ្រោះ*"[626]។ ទោះបីមិនត្រូវមានចែងច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង ផ្នែកគាំពារជនរងគ្រោះក៏បានប្រើដើម្បីកោះប្រជុំជនរងគ្រោះ មេធាវី អង្គការអន្តរការី និងអ្នកមកពីអង្គភាពផ្សេងទៀតនៃ អ.វ.ត.ក. ផងដែរ។

ផ្នែកគាំពារជនរងគ្រោះ រួមជាមួយនឹងផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[627] ត្រូវបានបង្កើតឡើងដើម្បីរៀបចំការចូលរួមរបស់ជនរងគ្រោះ[628]។ តួនាទីរបស់ផ្នែកគាំពារជនរងគ្រោះ រួមមានការជួយជនរងគ្រោះដាក់ពាក្យបណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រក្សាទុកបញ្ជីមេធាវី ដែលមានបំណងធ្វើជាដំណាងឱ្យជនរងគ្រោះ នៅចំពោះមុខ អ.វ.ត.ក. គ្រប់គ្រងពាក្យស្នើសុំចុះឈ្មោះ ក្នុងបញ្ជីរបស់សហគមន៍ជនរងគ្រោះ ដែលបានទទួលការយល់ព្រមឱ្យបំពេញកិច្ចក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់ព័ត៌មានទូទៅដល់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី និងជួយសម្រួលនិងគាំពារដល់ការចូលរួមនៅក្នុងនីតិវិធីតុលាការរបស់ដើមបណ្តឹងរដ្ឋប្បវេណី[629]។

ផ្នែកគាំពារជនរងគ្រោះបានធ្វើសកម្មភាពផ្សព្វផ្សាយជាប្រចាំ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពី អ.វ.ត.ក. និងរឿងក្តីរបស់ខ្លួន និងដើម្បីភ្ជាប់ទំនាក់ទំនងដើមបណ្តឹងរដ្ឋប្បវេណីទៅវិញទៅមក និងទៅកាន់ អ.វ.ត.ក.។ មកទល់ពេលនេះ ផ្នែកគាំពារជនរងគ្រោះ រួមជាមួយនឹងផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើវេទិកាថ្នាក់តំបន់ជាប្រចាំសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។

ផ្នែកគាំពារជនរងគ្រោះ និងផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏សហការជាមួយអង្គការរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលផងដែរ ដើម្បីកំណត់ រៀបចំ និងអនុវត្តគម្រោងសំណងដើមបណ្តឹងរដ្ឋប្បវេណី[630]។ ផ្នែកគាំពារជនរងគ្រោះបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយអង្គការដៃគូជាច្រើន សម្រាប់ការអនុវត្តគម្រោងទាំងអស់នេះ[631]។

---

624 វិធានផ្ទៃក្នុង (វិ.៥) ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ វិធាន ១២, ១២ ស្ទួន។
625 វិធានផ្ទៃក្នុង សន្ទានុក្រម។
626 វិធានផ្ទៃក្នុង វិធាន ២១ (គូសបញ្ជាក់បន្ថែម)។
627 សម្រាប់ព័ត៌មានអំពីផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមមើល ជំពូក ៤.៤.៣។
628 វិធានផ្ទៃក្នុង វិធាន ១២។
629 វិធានផ្ទៃក្នុង វិធាន ១២ស្ទួន។
630 វិធានផ្ទៃក្នុង វិធាន ១២ស្ទួន(៣), ២៣*ស្ទួនបួន*(៣)(ខ)។
631 ឧទាហរណ៍ ផ្នែកគាំពារជនរងគ្រោះ បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ជាមួយសារៈមន្ទីរទួលស្លែង ស្តីពីការបង្កើតស្តូបរំលឹកនៅសារៈមន្ទីរទួលស្លែង ដែលជាវិធានការក្រៅតុលាការ។ ផ្នែកអង្គភាពជនរងគ្រោះ ក៏បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយ៖ (១) មជ្ឈមណ្ឌលឯកសារកម្ពុជា លើគម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍អំពីការផ្លាស់ទីលំនៅដោយបង្ខំ និង ទួលពោធិ៍ជ្រៃ (២) អង្គការក្តីករុណា និង យុវសន្តិភាព លើគម្រោងពិព័រណ៍ចល័ត អំពីការផ្លាស់ទីលំនៅដោយបង្ខំ និងទួលពោធិ៍ជ្រៃ (៣) អង្គការចិត្តសង្គមអន្តរវប្បធម៌ លើគម្រោងការព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងក្រុមជួយខ្លួនឯងនឹង (៤) យុវសន្តិភាព លើគម្រោងមជ្ឈមណ្ឌលសិក្សាសន្តិភាព នៅក្រាំងតាចាន់ ក្នុងខេត្តតាកែវ។

ផ្នែកគាំពារជនរងគ្រោះក៏បានអនុវត្ត "វិធានការក្រៅតុលាការ" មួយចំនួន ជាមធ្យោបាយបន្ថែមនៃការទទួលស្គាល់ជនរងគ្រោះ-អ្នករស់រានមានជីវិត និងព្យសនកម្មដែលពួកគាត់បានទទួលរង ដោយមិនគិតពីឋានៈផ្លូវច្បាប់របស់ពួកគេនៅចំពោះមុខ អ.វ.ត.ក.។ គម្រោងធំៗចំនួនបួនត្រូវបានអនុវត្ត៖

១. ការសាងសង់ទីរំលឹកដល់ជនរងគ្រោះនៃរបបខ្មែរក្រហម នៅសារមន្ទីរទួលស្លែង ក្នុងទម្រង់ជាស្តូប និងសៀវភៅក្រាំងមាស (មានឈ្មោះជនរងគ្រោះ ដែលបានបាត់បង់ជីវិតនៅមន្ទីរសន្តិសុខ ស-២១)។ គម្រោងនេះត្រូវបានអនុវត្តក្រោមកិច្ចសហការជាមួយ អ.វ.ត.ក. និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

២. ការលើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងសិទ្ធិទទួលបានយុត្តិធម៌សម្រាប់អ្នករស់រានមានជីវិតជាស្ត្រី និងជនរងគ្រោះនៃអំពើហិង្សាយេនឌ័រ ក្នុងរបបខ្មែរក្រហម។ គម្រោងដែលបានអនុវត្តរួមមាន (ក) សិទ្ធិទទួលបានយុត្តិធម៌ និងការចូលរួមរបស់ជនរងគ្រោះ (ខ) ការលើកកម្ពស់ការយល់ដឹង និងការតស៊ូមតិ (គ) ការអន្តរាគមន៍ផ្នែកស្មារតី និង (ឃ) ការកសាងសមត្ថភាព។ គម្រោងនេះត្រូវបានអនុវត្តក្រោមកិច្ចសហការជាមួយអង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO)។

៣. គម្រោងសិក្សាសន្តិភាពសហគមន៍ (CPLC) ត្រូវបានបង្កើតឡើង ដើម្បីរួមបញ្ចូលសហគមន៍ក្រាំងតាចាន់ ដើម្បីជួយប្រែក្លាយអតីតកាលដ៏ខ្មៅងងឹតរបស់ពួកគេ តាមរយៈការប្រែក្លាយទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម ទៅជាទីកន្លែងសម្រាប់ជាការរំលឹក ការចងចាំ ការអប់រំ និងការសន្ទនា។

៤. ពិធីព្យាបាលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីកាន់ទុក្ខសាច់ញាតិដែលបានបាត់បង់ រួមជាមួយនឹងសហគមន៍របស់ខ្លួន។

## ៤.៤.២. ផ្នែកគាំពារការពារក្តី

ផ្នែកគាំពារការពារក្តី បានជួយសម្រួលដល់ការធ្វើជាតំណាងផ្នែកច្បាប់របស់បុគ្គលដែលមានសិទ្ធិទទួលបានមេធាវីការពារក្តី នៅចំពោះមុខ អ.វ.ត.ក.[632]។ ផ្នែកគាំពារការការពារក្តីបានគ្រប់គ្រងប្រព័ន្ធចាត់តាំងមេធាវី និងបុគ្គលិកផ្សេងទៀតឱ្យជួយ ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងបុគ្គលដែលមានសិទ្ធិទទួលបានការការពារផ្សេងទៀត រួមបញ្ចូលទាំងជនក្រីក្រ[633]។ ផ្នែកនេះក៏ផ្តល់កិច្ចសន្យាការងារឱ្យមេធាវីការពារក្តី និងផ្នែកគាំពារច្បាប់[634] ផ្តល់ការគាំពារផ្នែកច្បាប់ជាមូលដ្ឋានដល់មេធាវីការពារក្តី[635] រួមបញ្ចូលទាំងតាមរយៈការទំនាក់ទំនងជាមួយផ្នែកពាក់ព័ន្ធនៅ អ.វ.ត.ក.[636] និងបានរៀបចំការបណ្តុះបណ្តាលសម្រាប់មេធាវីការពារក្តីនៅ អ.វ.ត.ក.[637]។ ជាផ្នែកមួយនៃការទទួលខុសត្រូវពិសេសរបស់ខ្លួន ផ្នែកគាំពារការការពារក្តីក៏អាចជួយបុគ្គល ដែលត្រូវបានចោទប្រកាន់ពីបទជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះផងដែរ[638]។

ផ្នែកគាំពារការការពារក្តីមានស្វ័យភាពក្នុងផ្នែកសំខាន់ៗនៃការកាពារក្តី[639] ប៉ុន្តែនៅតែស្ថិតក្រោមការត្រួតពិនិត្យរបស់ការិយាល័យរដ្ឋបាល សម្រាប់បញ្ហាហិរញ្ញវត្ថុ[640]។ ដូច្នេះ ផ្នែកនេះមានសិទ្ធិបង្កើតបទ

---

[632] សូមមើលជាទូទៅ វិធានផ្ទៃក្នុង វិធាន ១១។
[633] វិធានផ្ទៃក្នុង វិធាន ១១(២)(ក)-(ច)។
[634] វិធានផ្ទៃក្នុង វិធាន ១១(២)(ឆ)-(ឈ)។
[635] វិធានផ្ទៃក្នុង វិធាន ១១(២)(ញ)។
[636] ឧទាហរណ៍ ផ្នែកគាំពារការការពារក្តី ម្តងម្កាលបានស្នើសុំ ជូនដំណឹងទៅមន្ទីរឃុំឃាំងដោយផ្ទាល់ អំពីការផ្លាស់ប្តូរណាមួយនៅក្នុងសមាសភាពក្រុមការពារក្តី ដើម្បីទទួលបានការអនុញ្ញាតជួបកូនក្តីរបស់ខ្លួន ក្នុងការអនុវត្តវិធាន ៩.១៥ នៃវិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង។
[637] វិធានផ្ទៃក្នុង វិធាន ១១(២)(ត)។
[638] វិធានផ្ទៃក្នុង វិធាន ៣៥(៣)។
[639] វិធានផ្ទៃក្នុង វិធាន ១១(១)។
[640] អ.ស.ប. ទទួលខុសត្រូវលើប្រាក់បៀវត្សរ៍របស់មេធាវីការពារក្តី។ សូមមើល កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៧។

បញ្ញារដ្ឋបាលផ្ទាល់របស់ខ្លួន បន្ទាប់ពីការពិគ្រោះយោបល់ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា[641] ដរាបណាពួកគេនៅតែគោរពតាមវិធានផ្ទៃក្នុង និងអាស្រ័យលើការពិនិត្យរបស់គណៈកម្មាធិការវិធាន និងនីតិវិធី[642]។

បទបញ្ញារដ្ឋបាលរបស់ផ្នែកគាំពារការពារក្តី ចែងអំពីលក្ខណៈវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការទទួលយកមេធាវីនៅក្នុងបញ្ជីមេធាវីរបស់ អ.វ.ត.ក. នីតិវិធីសម្រាប់ការជ្រើសរើស និងការជួលសហមេធាវី ភារកិច្ចរបស់ពួកគេក្នុងនាមជាសហមេធាវី ក៏ដូចជា ភារកិច្ចរបស់សមាជិកក្រុមការងារច្បាប់របស់ផ្នែកគាំពារការពារក្តីផងដែរ[643]។ ជាងនេះទៀត ដើម្បីធានាបាននូវការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព នៃចុងចោទនៅ អ.វ.ត.ក. ដែលមិនមានមធ្យោបាយចំណាយលើការពារក្តីរបស់ខ្លួន អ.វ.ត.ក. ក៏បានបង្កើតគម្រោងជំនួយផ្នែកច្បាប់ ដែលត្រូវបានគ្រប់គ្រង និងអនុវត្តដោយផ្នែកគាំពារការការពារក្តី។

ការទទួលខុសត្រូវស្នូលរបស់ផ្នែកគាំពារការការពារក្តីនោះគឺការបង្កើត បញ្ជីមេធាវីដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក. ដោយពិភាក្សាជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (“បញ្ជីមេធាវី អ.វ.ត.ក.”)[644]។ បញ្ជីនេះមានឈ្មោះមេធាវីការពារក្តី ដែលបានចុះឈ្មោះដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្ហាញខ្លួននៅចំពោះមុខ អ.វ.ត.ក.[645] រួមបញ្ចូលទាំងមេធាវីជាតិ និងអន្តរជាតិ ដែលទទួលបានការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈច្បាប់នៅក្នុងរដ្ឋជាសមាជិក អ.ស.ប.[646]។ ជាងនេះទៀត បញ្ជីនេះបានបែងចែកជាកូនបញ្ជីតូចៗចំនួនពីរ៖ បញ្ជីមួយមានឈ្មោះមេធាវី និងអ្នកប្រកបវិជ្ជាជីវៈទាំងអស់ ដែលទទួលប្រាក់ឈ្នួលពី អ.ស.ប. សម្រាប់ការការពារក្តីជនក្រីក្រ[647] និងបញ្ជីមួយទៀតមានឈ្មោះមេធាវីដែលទទួលប្រាក់ឈ្នួលជាឯកជនពីចុងចោទ ឬអ្នកដែលធ្វើការសម្រាប់ប្រយោជន៍សាធារណៈ (ស្ម័គ្រចិត្ត)[648]។ ទោះជាយ៉ាងណា តាមការអនុវត្តជាក់ស្តែង ផ្នែកគាំពារការការពារក្តីបានជ្រើសរើសចេញតែពីបញ្ជីទីមួយប៉ុណ្ណោះ ដោយសារតែមិនមានចុងចោទណាជួលសហមេធាវីការពារក្តីផ្ទាល់ខ្លួនទេ។

ផ្នែកគាំពារការការពារក្តីបានផ្សព្វផ្សាយឱ្យបេក្ខជនដាក់ពាក្យ ដើម្បីធ្វើការជ្រើសរើសបញ្ចូលឈ្មោះទៅក្នុងបញ្ជី អ.វ.ត.ក. និងបានផ្តល់ព័ត៌មានលម្អិតអំពីឯកសារចាំបាច់ដែលត្រូវដាក់[649]។ ផ្នែកនេះក៏ជួយសម្រួលដំណើរការដាក់ពាក្យសម្រាប់មេធាវីបរទេស ក្នុងការចុះឈ្មោះជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ[650] ដោយរួមបញ្ចូលទាំងការបង់ថ្លៃចុះឈ្មោះមួយដង ៥០០ ដុល្លារអាមេរិក[651]។ ក្នុងឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបន្ថែមថ្លៃចុះឈ្មោះសម្រាប់មេធាវីបរទេស ប៉ុន្តែសេចក្តីសម្រេចនេះត្រូវបានបដិសេធវិញក្នុងឆ្នាំ២០២០[652]។ ផ្នែកគាំពារការការពារក្តីរួមមានមេធាវីសរុបចំនួន ៩៧ នាក់ នៅក្នុងបញ្ជី អ.វ.ត.ក. (ក្នុងនោះ ៤៧ នាក់ជាមេធាវីជាតិ និង ៥០ នាក់ ជាមេធាវីបរទេស)។

ចុងចោទនៅចំពោះមុខ អ.វ.ត.ក. ជាទូទៅអាចជ្រើសរើសសហមេធាវីជាតិម្នាក់ និងសហមេធាវីអន្តរជាតិម្នាក់[653] និងទទួលបានបញ្ជី អ.វ.ត.ក. និងព័ត៌មានដើម្បីធ្វើការជ្រើសរើសប្រកបដោយព័ត៌មាន

641 វិធានផ្ទៃក្នុង វិធាន ១១(២)(ក)។
642 វិធានផ្ទៃក្នុង វិធាន ៤។
643 បទបញ្ញត្តិផ្នែកគាំពារការការពារក្តី។
644 វិធានផ្ទៃក្នុង វិធាន ១១(២)(ខ)-(ង)។
645 វិធានផ្ទៃក្នុង វិធាន ១១(២)(ខ)-(គ)។
646 វិធានផ្ទៃក្នុង វិធាន ១១(២)(គ)(i)-(ii)។
647 វិធានផ្ទៃក្នុង វិធាន ១១(២)(ឃ)។ បប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១(២)(ក)។ សូមមើលផងដែរ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៧(គ)។
648 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១(២)(ខ)។
649 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១(៣)។
650 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ៤(៧)-(៨)។
651 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ៤(៩)។
652 សេចក្តីសម្រេចរបស់ BAKC អំពីការចុះបញ្ជី និងការចេញវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈសម្រាប់មេធាវីបរទេស ដែលប្រកបវិជ្ជាជីវៈមេធាវីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០។
653 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ៥(៣)។

គ្រប់ជ្រុងជ្រោយ អំពីការតំណាងផ្លូវច្បាប់របស់ពួកគេ[654]។ ប្រសិនបើចុងចោទមានបំណងជ្រើសរើសមេធាវីពីខាងក្រៅបញ្ជី អ.វ.ត.ក. នោះផ្នែកគាំពារការការពារក្ដីនឹងជួយពួកគេ[655]។ ពេលជ្រើសរើសហើយ សហមេធាវីត្រូវធ្វើការលើរឿងក្ដីនេះរហូតដល់ "ចប់ស្ពាន"[656]។ ការផ្លាស់ប្ដូរ ឬការដកខ្លួនរបស់មេធាវីត្រូវបានអនុញ្ញាតតែក្នុងកាលៈទេសៈពិសេសប៉ុណ្ណោះ[657] ចំណែកការដកមេធាវី អាចធ្វើទៅបានដោយ អ.វ.ត.ក. ប្រសិនបើខ្លួនសម្រេចថា មេធាវីរូបនោះលែងមានសិទ្ធិ បំពេញការងារការពារចុងចោទទៀតហើយ[658]។ ក្នុងរយៈពេលប្រតិបត្តិការរបស់ អ.វ.ត.ក. ទាំងមូល ចុងចោទទទួលបានជំនួយការពារក្ដីពីសហមេធាវីចំនួន ៣៤ រូប (សហមេធាវីជាតិ ១៦ រូប និង សហមេធាវីអន្តរជាតិ ១៨ រូប)។

ចុងចោទដែលបានអះអាងថាក្រីក្រ និងបានស្នើសុំមេធាវីតំណាងផ្លូវច្បាប់ ពីបញ្ជី អ.ស.ប. ត្រូវតែបង្ហាញថា ពួកគេមិនមានមធ្យោបាយគ្រប់គ្រាន់បង់ថ្លៃការពារក្ដីរបស់ខ្លួន នៅចំពោះមុខ អ.វ.ត.ក.[659]។ ជាពិសេស ពួកគេត្រូវផ្ដល់ព័ត៌មានដល់ផ្នែកគាំពារការការពារក្ដី ទាក់ទងនឹងប្រាក់ចំណូលផ្ទាល់របស់ខ្លួន លេខគណនេយ្យធនាគារ ទ្រព្យសម្បត្តិពិតប្រាកដ ឬផ្ទាល់ខ្លួន ប្រាក់សោធននិវត្តន៍ មូលប័ត្រ សញ្ញាបណ្ណ ឬទ្រព្យផ្សេងទៀត គ្រួសារក្នុងបន្ទុក និងអត្ថប្រយោជន៍សង្គម[660]។ ក្រោយពីបានពិនិត្យព័ត៌មាន ផ្នែកគាំពារការការពារក្ដី "បានសម្រេចថាតើចុងចោទមិនមានមធ្យោបាយគ្រប់គ្រាន់ចំណាយលើការការពារក្ដីរបស់ខ្លួនទាំងមូល ដោយផ្នែក ឬយ៉ាងណា[661]។ ប្រសិនបើគេរកឃើញថា ចុងចោទមានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយលើការតំណាងផ្នែកច្បាប់របស់ខ្លួន នោះសំណើដែលស្នើសុំចាត់តាំងមេធាវីដែលទទួលប្រាក់ឈ្នួលពី អ.ស.ប. នឹងត្រូវបដិសេធ ហើយផ្ទុយទៅវិញ ចុងចោទនឹងត្រូវជួលមេធាវីដោយខ្លួនឯងផ្ទាល់[662]។ "

សេចក្ដីសម្រេចរបស់ផ្នែកគាំពារការការពារក្ដី ឬប្រធានរបស់ខ្លួន អាចប្ដឹងឧទ្ធរណ៍បាននៅចំពោះមុខស្ថាប័នផ្សេងៗរបស់ អ.វ.ត.ក.។ ឧទាហរណ៍ សេចក្ដីសម្រេចរបស់ផ្នែកគាំពារការការពារក្ដី ទាក់ទងនឹងការបញ្ចូលឈ្មោះមេធាវី ដែលបានដាក់ពាក្យសុំការអនុញ្ញាតដាក់បញ្ចូលទៅក្នុងបញ្ជី អ.វ.ត.ក. ត្រូវស្ថិតក្រោមការពិនិត្យលើបណ្ដឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះ[663]។ ការសម្រេចរបស់ផ្នែកគាំពារការពារក្ដី ទាក់ទងនឹងភាពក្រីក្ររបស់ចុងចោទ និងការចាត់តាំងមេធាវីការពារអត្ថប្រយោជន៍របស់ពួកគេ ត្រូវស្ថិតក្រោមបណ្ដឹងឧទ្ធរណ៍/សាទុក្ខនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ដែលចុងចោទនោះបង្ហាញខ្លួន[664]។ តាមការអនុវត្ត សហមេធាវីក៏ដាក់ញត្តិទៅកាន់អង្គជំនុំជម្រះផងដែរ ទាក់ទងនឹងកម្រិតធនធាន ដែលបានអនុម័តដោយផ្នែកគាំពារការការពារក្ដី។ សេចក្ដីសម្រេចលើញត្តិស្នើសុំធនធានទាំងនេះមានរៀបរាប់ក្នុងឧបសម្ព័ន្ធ ៥.ខ។

លើសពីនេះ សហមេធាវីអាចដាក់ញត្តិទាក់ទងនឹងកិច្ចសន្យាផ្ដល់សេវាកម្មរបស់ខ្លួន នៅចំពោះមុខមជ្ឈត្តករ ដែលបានតែងតាំងពីក្នុងចំណោមចៅក្រមអន្តរជាតិ អ.វ.ត.ក.។ ញត្តិកិច្ចសន្យាបែបនេះចំនួន ១០ បានដាក់។ សេចក្ដីសម្រេចលើញត្តិកិច្ចសន្យាទាំងនេះមាននៅគេហទំព័រ អ.វ.ត.ក.។

---

654 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ៥(១)។
655 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ៥(១)។
656 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ៧(១)។
657 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ៧(២), ៧(៣)។
658 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ៧(៤)។
659 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ១១(១)។
660 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ១១(៣)។
661 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ១១(៤)-(៦)។ ក្នុងករណីដែលផ្នែកគាំពារការការពារក្ដីបានរកឃើញថា ចុងចោទមានមធ្យោបាយគ្រប់គ្រាន់ក្នុងការចំណាយមួយផ្នែកលើថ្លៃតំណាងផ្លូវច្បាប់ នោះ អ.វ.ត.ក. នឹងទទួលបន្ទុកតែផ្នែកមួយនៃថ្លៃសេវានោះប៉ុណ្ណោះគឺ៖ សហមេធាវីដែលត្រូវបានជ្រើសរើសនោះ នឹងត្រូវចំណាយដោយគម្រោងជំនួយផ្នែកច្បាប់ ហើយ អ.វ.ត.ក. នឹងដកយកថ្លៃដែលបានកំណត់នោះពីជនជាប់ចោទ ប្រសិនបើពួកគេជឿជាក់។ សូមមើល បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ១១(៦)។
662 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ១១(៥)។
663 វិធានផ្ទៃក្នុង វិធាន ១១(៥)។
664 វិធានផ្ទៃក្នុង វិធាន ១១(៦)។

## ៤.៤.២.១. សហមេធាវី និងក្រុមការងាររបស់ពួកគេ

ក្នុងការតំណាងឱ្យជនត្រូវចោទ និងជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក. សហមេធាវីជាតិ និងសហមេធាវីអន្តរជាតិ ទទួលការជួយជ្រោមជ្រែងពីបុគ្គលិកប្រឹក្សាខាងផ្នែកច្បាប់ អ្នកគ្រប់គ្រងរឿងក្តី ជំនួយការរឿងក្តី អ្នកវិភាគភស្តុតាង និងកម្មសិក្សាការី។ រួមបញ្ចូលគ្នាពួកគេមានឈ្មោះថា "ក្រុមការពារក្តី" ។

សហមេធាវី និងក្រុមការងាររបស់ពួកគេ ត្រូវស្ថិតក្រោមកាតព្វកិច្ចក្រមសីលធម៌ និងវិជ្ជាជីវៈមួយចំនួន ក្នុងការបំពេញមុខងាររបស់ខ្លួន[665]។ ឧទាហរណ៍ បទបញ្ញត្តិផ្នែកគាំពារការការពារក្តីចែង*ជាអាទិ៍*ថា សហមេធាវីត្រូវ "មានពេលវេលាផ្តល់ការណែនាំ និងការតំណាងផ្នែកច្បាប់ប្រកបដោយប្រសិទ្ធភាព"[666] រក្សាការសម្ងាត់ចំពោះឯកសារផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ[667] ជៀសវាងទំនាក់ទំនងជាមួយកូនក្តីរបស់សហមេធាវីផ្សេងទៀត លើកលែងពេលមានការអនុញ្ញាត[668] ហើយជាទូទៅ ជៀសវាងចូលរួមក្នុងសកម្មភាពដែលមិនស្របទៅនឹងភារកិច្ចរបស់ខ្លួន ក្នុងឋានៈជាអ្នកតំណាងផ្នែកច្បាប់របស់ចុងចោទ (ដូចជាការទទួលការណែនាំពីរដ្ឋាភិបាលណាមួយ)[669]។ សហមេធាវីក៏ទទួលខុសត្រូវផងដែរលើការប្រកាន់ខ្ជាប់របស់ក្រុមមេធាវីការពារក្តីទៅនឹងបទដ្ឋាន និងភារកិច្ច ដែលបានកំណត់ចំពោះពួកគេ[670]។

សហមេធាវីត្រូវដាក់ផលប្រយោជន៍កូនក្តីរបស់ខ្លួនមុនផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍របស់អ្នកផ្សេងទៀត និងត្រូវយកចិត្តទុកដាក់ទាំងអស់ដើម្បីធានាថា មិនមានទំនាស់ផលប្រយោជន៍កើតឡើង[671]។ សហមេធាវីអាចត្រូវបានចាត់តាំងឱ្យតំណាងជនជាប់ចោទលើសពីម្នាក់ ក្នុងលក្ខខណ្ឌដែលថាមិនមានទំនាស់ផលប្រយោជន៍។ ការណ៍នេះកើតឡើងក្នុងករណីមួយប៉ុណ្ណោះ គឺនៅពេលដែលសហមេធាវីការពារក្តី អៀង សារី ក្នុងសំណុំរឿង ០០២ ត្រូវបានចាត់តាំងដោយផ្នែកគាំពារការការពារក្តី ឱ្យតំណាង មាស មុត ក្នុងសំណុំរឿង ០០៣។ ការចាត់តាំងរបស់ពួកគេនេះដើមឡើយត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកលើមូលហេតុ "ទំនាស់ផលប្រយោជន៍"[672] ប៉ុន្តែអង្គបុរេជំនុំជម្រះបានបដិសេធទំនាស់នេះថា "ត្រឹមតែជាសម្មតិកម្ម" ក្នុងករណីនេះ និងបានអនុញ្ញាតឱ្យសហមេធាវីតំណាងក្តីឱ្យ មាស មុត[673]។

សហមេធាវីត្រូវបានហាមឃាត់ដោយផ្ទាល់មិនឱ្យពាក់ព័ន្ធក្នុងកិច្ចការហិរញ្ញវត្ថុជាក់លាក់ រួមមានការទទួលយកប្រាក់ឈ្នួលសម្រាប់ការតំណាងផ្លូវច្បាប់របស់ចុងចោទមកពីប្រភពផ្សេង ក្រៅពី អ.វ.ត.ក.[674] ការផ្ទេរប្រាក់ ឬ ការឱ្យខ្ចីប្រាក់ ឬទ្រព្យ ទៅឱ្យចុងចោទ សាច់ញាតិ ឬមិត្តភក្តិរបស់ចុងចោទ ឬជនទីបីណាម្នាក់ ឬអង្គការណាមួយ ដែលកូនក្តីមានផលប្រយោជន៍ផ្ទាល់ខ្លួន[675] និងការផ្តល់ការទូទាត់ជាការដោះដូរជាមួយនឹងការដែលត្រូវបានធ្វើជាមេធាវីការពាររបស់ចុងចោទ[676]។ ការរំលោភណាមួយដោយសហមេធាវីម្នាក់ ឬក្រុមមេធាវីការពារក្តីណាផ្សេងទៀត លើសកម្មភាពដែលបានហាមឃាត់ណាមួយក្នុងចំណោម

---

[665] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១៥-១៨។
[666] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១៦(១)។
[667] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១៧(១)។
[668] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១៨(៦)។
[669] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ៩(១)។
[670] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១០(៥), ១៨(៩)។
[671] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ៩(២)។
[672] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ដែលស្នើឱ្យបដិសេធការតែងតាំងសហមេធាវីការពារក្តី មាស មុត នៅលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ ឯកសារ D56/18 កថាខណ្ឌ ១២៩។ គិតត្រឹមពេលនេះ អៀង សារី បានទទួលមរណភាពហើយ។
[673] សំណុំរឿង ០០៣ សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបដិសេធការតែងតាំងលោក អាង ឧត្តម និងលោក Michael KARNAVAS មិនឱ្យធ្វើជាសហមេធាវីរបស់គាត់ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ D56/19/38 កថាខណ្ឌ ៦៩។
[674] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១៥(១)។
[675] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១៥(២)។
[676] បទប្បញ្ញត្តិផ្នែកគាំពារការការពារក្តី បទប្បញ្ញត្តិ ១៥(៦)។

សកម្មភាពទាំងនេះ ឬសំណើណាមួយរបស់សហមេធាវី ឬសមាជិកក្រុមមេធាវីការពារក្ដី ដើម្បីប្រព្រឹត្តការរំលោភបំពាន ត្រូវតែរាយការណ៍ទៅកាន់ផ្នែកគាំពារការការពារក្ដី[677]។'

### ៤.៤.៣. មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

នវានុវត្តន៍ដ៏សំខាន់មួយនៃ អ.វ.ត.ក. គឺការពង្រឹងការទទួលស្គាល់ជនរងគ្រោះនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងបណ្ដឹងសាទុក្ខ ដែលជនរងគ្រោះអាចចូលរួមក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី។ ការចូលរួមរបស់ជនរងគ្រោះក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី មានប្រភពចេញមកពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយរួមបញ្ចូលសិទ្ធិសម្រាប់ឱ្យជនរងគ្រោះចូលរួមក្នុងឋានៈជាភាគី ទៅនឹងការជំនុំជម្រះក្ដីព្រហ្មទណ្ឌ និងក្នុងពេលជាមួយគ្នានោះស្វែងរកវិធានការរដ្ឋប្បវេណី សម្រាប់សំណងផ្លូវចិត្ត និងសមូហភាព ប្រឆាំងនឹងជនជាប់ចោទ[678]។ ដើម្បីទទួលបានការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី បុគ្គលនោះត្រូវតែបង្ហាញថាខ្លួនទទួលរងព្យសនកម្មប្រភេទណាមួយ ដែលជាលទ្ធផលផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងរឿងក្ដីនោះ[679]។ នៅពេលត្រូវបានទទួលស្គាល់ហើយនោះ ដើមបណ្ដឹងរដ្ឋប្បវេណីបានក្លាយជាភាគីមួយទៅនឹងកិច្ចដំណើរការនីតិវិធី ដោយមានសិទ្ធិចូលរួមក្នុងនីតិវិធីយ៉ាងទូលំទូលាយ ដែលស្រដៀងគ្នាទៅនឹងភាគីចោទប្រកាន់ និងភាគីការពារក្ដីដែរ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្ត នីតិវិធីព្រហ្មទណ្ឌដែលមានការចូលរួមពីដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវបានបង្កើតឡើង ដើម្បីសម្រួលដល់ជនរងគ្រោះចំនួនច្រើននៅក្នុងអំឡុងពេលជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិនោះទេ[680]។ ដូច្នេះ អង្គជំនុំជម្រះត្រូវដោះស្រាយជាមួយនឹងបញ្ហាប្រឈមជាច្រើនដែលកើតចេញពីកិច្ចដំណើរការនីតិវិធីនានា ដែលមានដើមបណ្ដឹងរដ្ឋប្បវេណីចូលរួម[681]។ ឧទាហរណ៍ ក្នុងសំណុំរឿង ០០១ វិធានជាធរមាននៅពេលនោះតម្រូវឱ្យអង្គជំនុំជម្រះ សម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗ ហើយនិងសិទ្ធិរបស់ពួកគេក្នុងការស្នើសុំសំណង នៅក្នុងសាលក្រមនោះ មិនមែននៅពេលចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីនោះទេ[682]។' ដូច្នេះ ទោះបីជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៩៣ នាក់ បានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូលក្នុងសំណុំរឿង ០០១ ក៏ចុងបញ្ចប់អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ភាពអាចទទួលយកបាន និងសិទ្ធិជាបន្តបន្ទាប់ចំពោះសំណង តែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៤ នាក់ ប៉ុណ្ណោះ នៅក្នុងសាលក្រមរបស់ខ្លួន[683]។

អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយបញ្ហានេះនៅដំណាក់កាលបណ្ដឹងសាទុក្ខ នៅពេលដែលខ្លួនបានលើកឡើងតាងនាមឱ្យដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២២ នាក់ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគេ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងប្រកាសថាមិនអាចទទួលយកបាន។ អង្គជំនុំជម្រះតុលាការកំពូលបានកែតម្រូវវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និងបានទទួលស្គាល់អ្នកដាក់

---

677 បទប្បញ្ញត្តិផ្នែកគាំពារការការពារក្ដី បទប្បញ្ញត្តិ ១៥(៤)-(៥)។

678 សូមមើល ឧទាហរណ៍ សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៦០-៦៦១។ សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស និងសេចក្ដីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្ដល់សក្ខីកម្ម ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ២៨-៤០។

679 វិធានផ្ទៃក្នុង វិធាន ២៣*ស្ទួន*(១)។

680 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១១០៩។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៤០៤។

681 សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស និងសេចក្ដីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្ដល់សក្ខីកម្ម ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 (យោបល់ជំទាស់របស់ចៅក្រម Lavergne)។

682 វិធានផ្ទៃក្នុង (វ.១) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ វិធាន ១០០(១)៖ "អង្គជំនុំជម្រះត្រូវសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណីនៅក្នុងសាលក្រម។ អង្គជំនុំជម្រះត្រូវសម្រេចអំពីភាពដែលអាចទទួលយកបាន និងខ្លឹមសារនៃការទាមទារចំពោះជនជាប់ចោទ"។

683 សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៣៧, ៦៤៥-៦៥០។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២២ នាក់នោះ ដែលនាំឱ្យចំនួនចុងក្រោយនៃដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ក្នុងសំណុំរឿង ០០១ ឡើងដល់ ៧៤ នាក់[684]។

ក្នុងសំណុំរឿង ០០១ បាននាំឱ្យមានការចាប់អារម្មណ៍លើបញ្ហាប្រឈមនៃអត្ថិភាពក្រុមខណ្ឌដើមបណ្តឹងរដ្ឋប្បវេណី។ ជាលទ្ធផល វិធានផ្ទៃក្នុងត្រូវបានកែប្រែ ដោយកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក. នៅក្នុងខែកុម្ភៈ ឆ្នាំ២០១០ ដើម្បី "ថ្លឹងថ្លែងសិទ្ធិរបស់ភាគីទាំងអស់ ដើម្បីការពារលទ្ធភាពរបស់ អ.វ.ត.ក. ក្នុងការសម្រេចបានអាណត្តិរបស់ខ្លួន ខណៈដែលរក្សាបាននូវការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីបង្កើនគុណភាពនៃការតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី"[685]។ វិសោធនកម្មដ៏សំខាន់មួយនោះគឺការបញ្ចូលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បី "ធានាប្រសិទ្ធភាពអំពីការរៀបចំការតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ"[686]។ ជាងនេះទៀត វិធានផ្ទៃក្នុងត្រូវបានកែប្រែដើម្បីឱ្យការទទួលយកដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានកំណត់ដោយសហចៅក្រមស៊ើបអង្កេត និងចុងក្រោយ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ដោយអង្គបុរេជំនុំជម្រះ នៅចុងបញ្ចប់កិច្ចស៊ើបសួរ ជាជាងនៅចុងបញ្ចប់ការជំនុំជម្រះ[687]។

បន្ទាប់ពីកំណែទម្រង់ ដើម្បីចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីពេលចេញដីកាដំណោះស្រាយ[688]។ ទោះជាយ៉ាងណា ចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើការតំណាងឱ្យបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ។ ចាប់ពីពេលនេះ តួនាទីរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវគាំទ្រការងាររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (តាមការជួយដោយសារណាផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ការស្តាប់ចម្លើយ និងជំនួយផ្នែកនីតិវិធីផ្សេងទៀត) និងត្រូវបម្រើជាចំណុចទំនាក់ទំនងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ[689]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានតំណាងផលប្រយោជន៍បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ និងមានការទទួលខុសត្រូវចុងក្រោយសម្រាប់ការផ្តល់ការគាំទ្រ យុទ្ធសាស្ត្រជាទូទៅ ព្រមទាំងការតំណាងចំពោះមុខតុលាការ អំពីផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ[690]។

ទោះជាយ៉ាងណា សំខាន់បំផុតនោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវស្វែងរកទស្សនៈផ្សេងៗពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនឹងព្យាយាមសម្របសម្រួលឱ្យអស់ពីលទ្ធភាពដើម្បីឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆន្ទ ក្នុងការធ្វើជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណាក់កាលជំនុំជម្រះ[691]។ ក្នុងពេលកិច្ចដំណើរការជំនុំជម្រះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាច៖

- សួរសំណួរជនជាប់ចោទ សាក្សី និងអ្នកជំនាញ លើកលែងតែទាក់ទងនឹងអត្តចរិតរបស់ពួកគេ[692]

[684] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ជំពូក ៦។
[685] *កិច្ចប្រជុំពេញអង្គលើកទី៧ របស់ អ.វ.ត.ក. បិទបញ្ចប់។*
[686] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ*((១)។
[687] ប្រៀបធៀបវិធានផ្ទៃក្នុង (វិ.១) ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ វិធាន ២៣ ជាមួយនឹង វិធានផ្ទៃក្នុង វិធាន ២៣*ស្ទួន*(៣) (តម្រូវឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយដីកាសម្រេចដាច់ដោយឡែកមួយ)។
[688] វិធានផ្ទៃក្នុង វិធាន ២៣*ស្ទួនពីរ*(១)។
[689] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ*(៦)។
[690] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ*(៥)(ខ)។
[691] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ*(៣)។
[692] វិធានផ្ទៃក្នុង វិធាន ៩០(២)។ សំណុំរឿង ០០១ សេចក្តីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្តីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្តីសន្និដ្ឋានផ្តន្ទាទោស និងសេចក្តីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្តល់សក្ខីកម្ម ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3 កថាខណ្ឌ ៤៨។

- ធ្វើសារណាជាលាយលក្ខណ៍អក្សរតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី[693]
- ធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល[694]
- អាចប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចអំពីសំណង[695]។ នៅពេលសហព្រះរាជអាជ្ញា បានធ្វើបណ្តឹងសាទុក្ខរួចហើយ ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អាចដាក់ពាក្យបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម តែមិនមែនប្តឹងសាទុក្ខសេចក្តីសម្រេចផ្តន្ទាទោសនោះទេ[696]។

មានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីកម្ពុជាម្នាក់ (“ភាគីជាតិ”) និងបរទេសម្នាក់ (“ភាគីអន្តរជាតិ”) អ្នកទាំងពីរត្រូវបានផ្តល់កិច្ចសន្យាការងារដោយ អ.វ.ត.ក.។ មុខងាររបស់ពួកគេបានចាប់ផ្តើមនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ហើយពួកគេត្រូវធ្វើការរួមគ្នា លើកលែងតែនៅពេលដែលមានការប្រគល់សិទ្ធិឱ្យទៅនរណាម្នាក់ ក្នុងចំណោមពួកគាត់ ដើម្បីដោះស្រាយបញ្ហាណាមួយជាក់លាក់[697]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិគឺលោក ពេជ អង្គ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិមាន Elisabeth Simonneau-Fort (បារាំង) Marie Guiraud (បារាំង) Megan Hirst (អូស្ត្រាលី) និង Falguni Debnath (កាណាដា) តាមលំដាប់។ ទោះបីជាសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនមានចែងនៅក្នុងឯកសារមូលដ្ឋានគោលរបស់ អ.វ.ត.ក. ដូចជា ច្បាប់ អ.វ.ត.ក. កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដោយ ក៏សិទ្ធិអំណាចរបស់ពួកគេបានមកពីវិធានផ្ទៃក្នុង[698]។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានតំណាងបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ ដែលមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៩ នាក់ ក្នុងសំណុំរឿង ០០២/០១ និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣.៨៦៧ នាក់ ក្នុងសំណុំរឿង ០០២/០២[699]។

បន្ថែមលើការផ្តល់អំណះអំណាង និងការតំណាងក្នុងតុលាការ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើសកម្មភាពផ្សព្វផ្សាយ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពី អ.វ.ត.ក. និងការជំនុំជម្រះជាបន្តបន្ទាប់របស់ខ្លួន និងដើម្បីភ្ជាប់ដើមបណ្តឹងរដ្ឋប្បវេណីជាមួយគ្នា ជាមួយ អ.វ.ត.ក. និងជាមួយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការយ៉ាងជិតស្និទ្ធជាមួយផ្នែកគាំពារជនរងគ្រោះ ក្នុងការធ្វើព្រឹត្តិការណ៍ផ្សព្វផ្សាយ និងការចូលរួមក្នុងព្រឹត្តិការណ៍ផ្សព្វផ្សាយ[700]។

ជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី អាចទាមទារសំណងផ្លូវចិត្ត និងសំណងសមូហភាពប្រឆាំងនឹងជនដែលត្រូវបានផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក.។ បញ្ហាសំណាងមានពិភាក្សាបន្ថែមទៀតនៅក្នុងជំពូក ៦។

---

693 វិធានផ្ទៃក្នុង វិធាន ៩២។ សំណុំរឿង ០០១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធសំណើរបស់មេធាវីដើមបណ្តឹង រដ្ឋប្បវេណីក្រុម២ ក្នុងការស្នើសុំធ្វើសេចក្តីសន្និដ្ឋានបើកពេលសវនាការលើអង្គសេចក្តី ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៩ ឯកសារ E23/4។

694 វិធានផ្ទៃក្នុង វិធាន ៩៤(១)(គ)។

695 វិធានផ្ទៃក្នុង វិធាន ១០៥(១)(គ)។

696 វិធានផ្ទៃក្នុង វិធាន ១០៥(១)(គ)។

697 វិធានផ្ទៃក្នុង វិធាន*ស្ទួនពីរ*(៤)។

698 វិធានផ្ទៃក្នុង វិធាន ១២*ស្ទួនពីរ*(២)។

699 សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១១១១។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៤០៧។

700 ព័ត៌មានបន្ថែមអំពីសកម្មភាពផ្សព្វផ្សាយជនរងគ្រោះ មាននៅជំពូក ៤.៤.១។

## ៤.៥. ការរៀបចំតុលាការ និងរដ្ឋបាលតុលាការ

### ៤.៥.១. កិច្ចប្រជុំពេញអង្គ

កិច្ចប្រជុំពេញអង្គគឺជាការប្រជុំដែលចៅក្រមទាំងអស់នៃអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងចៅក្រមបម្រុង និងសហព្រះរាជអាជ្ញាបម្រុងទាំងអស់របស់ខ្លួន ប្រធានផ្នែកគាំពារការការពារក្តី និង ប្រធានផ្នែកគាំពារជនរងគ្រោះ និងប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាល បានចូលរួមបោះឆ្នោតលើបញ្ហានានា រួមមានវិសោធនកម្ម ទាក់ទងទៅនឹងវិធានផ្ទៃក្នុង[701]។ កិច្ចប្រជុំពេញអង្គបានធ្វើឡើងរៀងរាល់ប្រាំមួយខែម្តង[702] ដែលក្នុងអំឡុងពេលនោះអ្នកចូលរួមក៏ធ្វើការពិនិត្យមើលសេចក្តីណែនាំអនុវត្តន៍ និងវិសោធនកម្មពាក់ព័ន្ធផងដែរ[703]។ កិច្ចប្រជុំពេញអង្គវិសាមញ្ញ ក៏បានរៀបចំឡើងសម្រាប់បញ្ហាបន្ទាន់ផងដែរ ដោយប្រធានកិច្ចប្រជុំពេញអង្គ*តាមភារកិច្ចរបស់ខ្លួន* ឬអនុលោមតាមសំណើដែលគាំទ្រដោយសំឡេងភាគច្រើនលើសលប់របស់ចៅក្រមដែលមានសិទ្ធិបោះឆ្នោត[704] ទោះជាយ៉ាងណាចំណុចនេះមិនធ្លាប់កើតឡើងទេ។

កូរ៉ុមសម្រាប់កិច្ចប្រជុំពេញអង្គឆ្លុះបញ្ចាំងពីវិធានសំឡេងភាគច្រើនលើសលប់ សម្រាប់ការបោះឆ្នោតអំពីការធ្វើវិសោធនកម្មលើជំពូកខុសៗគ្នានៃវិធានផ្ទៃក្នុង។ ខណៈដែលសហព្រះរាជអាជ្ញា តាមឋានៈពិសេសរបស់ខ្លួនក្នុងនាមជាមន្ត្រីតុលាការយោងតាមច្បាប់កម្ពុជា មានសិទ្ធិបោះឆ្នោតរួមជាមួយនឹងចៅក្រមលើបញ្ហា និងវិសោធនកម្មនានា ទាក់ទងនឹងជំពូក ១ និង ២ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធទៅនឹងរដ្ឋបាលរបស់ អ.វ.ត.ក.[705] មានតែសហចៅក្រមស៊ើបអង្កេត និងចៅក្រមនៃអង្គជំនុំជម្រះតែប៉ុណ្ណោះ ត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតលើបញ្ហា និងវិសោធនកម្មទាក់ទងនឹងជំពូក ៣ នៃវិធានផ្ទៃក្នុង ពោលគឺ វិធានដែលចែងអំពីនីតិវិធី និងកិច្ចដំណើរការនិតិវិធី អ.វ.ត.ក.[706]។ អ្នកចូលរួមទាំងអស់ផ្សេងទៀតបានចូលរួមក្នុងកិច្ចប្រជុំពេញអង្គក្នុងសមត្ថកិច្ចពិគ្រោះយោបល់[707]។ ដូច្នេះ សំឡេងភាគច្រើនលើសលប់ (និងកូរ៉ុម) យ៉ាងហោចណាស់ចៅក្រម និងសហព្រះរាជអាជ្ញាចំនួន ១៥ នាក់ លើ ២១ នាក់ គឺត្រូវការសម្រាប់សេចក្តីសម្រេចលើជំពូក ១ និង ២ នៃវិធានផ្ទៃក្នុង ខណៈដែលសេចក្តីសម្រេចលើជំពូក ៣ នៃវិធានផ្ទៃក្នុង តម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់ ១៤ នាក់ លើ ១៩ នាក់ ដែលមានសិទ្ធិបោះឆ្នោត[708]។ កូរ៉ុមនេះអាចគណនាឡើងវិញបាន ប្រសិនបើចំនួនសរុបនៃចៅក្រមដែលមានសិទ្ធិបោះឆ្នោត បានផ្លាស់ប្តូរ[709]។

ការបោះឆ្នោតតាមរយៈអ្នកទទួលសិទ្ធិប្រទានអាចធ្វើទៅបានសម្រាប់ចៅក្រម និងសហព្រះរាជអាជ្ញា ដែលមិនអាចចូលរួមកិច្ចប្រជុំពេញអង្គបាន[710]។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការពិភាក្សា និងសេចក្តីសម្រេចដែលបានធ្វើឡើង បានធ្វើជាភាសាខ្មែរ អង់គ្លេស និងបារាំង ហើយរក្សាទុកដោយលេខាធិការដ្ឋានមួយ ដែលមានសមាជិកជ្រើសរើសដោយអង្គជំនុំជម្រះ ក.ស.ច.ស. និង ក.ស.ព. តាមករណីចាំបាច់ និងសមស្រប[711]។ ការពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គបានធ្វើឡើងជាសម្ងាត់[712]។ សរុបមានកិច្ចប្រជុំពេញអង្គចំនួន ១២ ត្រូវបានធ្វើឡើង។

---

[701] វិធានផ្ទៃក្នុង វិធាន ១៨(១), (៣)។
[702] វិធានផ្ទៃក្នុង វិធាន ១៨(៦)។
[703] វិធានផ្ទៃក្នុង វិធាន ១៨(៦), ២០(២), ២០(៣)។
[704] វិធានផ្ទៃក្នុង វិធាន ១៨(៧)។
[705] វិធានផ្ទៃក្នុង វិធាន ១៨(៣)(ក)។
[706] វិធានផ្ទៃក្នុង វិធាន ១៨(៣)(ខ)។
[707] វិធានផ្ទៃក្នុង វិធាន ១៨(៣)(ខ)។
[708] វិធានផ្ទៃក្នុង វិធាន ១៨(៣)(ខ)។
[709] វិធានផ្ទៃក្នុង វិធាន ១៨(៣)(គ)។
[710] វិធានផ្ទៃក្នុង វិធាន ១៨(៥)។
[711] វិធានផ្ទៃក្នុង វិធាន ១៨(៩)។
[712] វិធានផ្ទៃក្នុង វិធាន ១៨(១០)។

### ៤.៥.២. គណៈកម្មាធិការរដ្ឋបាលតុលាការ

គណៈកម្មាធិការរដ្ឋបាលតុលាការ គឺជាស្ថាប័នចំពោះកិច្ច ដែលទទួលខុសត្រូវលើការផ្តល់ឱវាទ និងការណែនាំដល់ការិយាល័យរដ្ឋបាល អំពីការផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងតុលាការដល់ អង្គជំនុំជម្រះ ក.ស.ច.ស. និង ក.ស.ព.[713]។ ការណ៍នេះរួមមានការរៀបចំ និងការអនុវត្តថវិកា[714] ការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីវិន័យចំពោះបុគ្គលិក និងការតែងតាំងចៅក្រមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះបណ្តឹងដិតចិត្ត[715]។

គណៈកម្មាធិការរដ្ឋបាលតុលាការមានសមាសភាពចៅក្រមចំនួនប្រាំរូប៖ ចៅក្រមជាតិបីរូប និងចៅក្រមអន្តរជាតិពីររូប និងចៅក្រមបម្រុងពីររូបសម្រាប់ជំនួសករណីអវត្តមាន។ ចៅក្រមទាំងអស់ត្រូវបានជ្រើសតាំងនៅកិច្ចប្រជុំពេញអង្គ ហើយចៅក្រមជាតិម្នាក់ធ្វើជាប្រធាន។ សហព្រះរាជអាជ្ញា ប្រធានការិយាល័យរដ្ឋបាល និង អនុប្រធានការិយាល័យរដ្ឋបាល ជួយគណៈកម្មាធិការរដ្ឋបាលតុលាការក្នុងនាមជាអ្នកពិគ្រោះយោបល់[716]។ អ្នកជំនាញពីខាងក្រៅអាចផ្តល់ឱវាទដល់គណៈកម្មាធិការរដ្ឋបាលតុលាការបាន[717]។ ស្រដៀងគ្នាទៅនឹងកិច្ចប្រជុំពេញអង្គដែរ កិច្ចប្រជុំគណៈកម្មាធិការរដ្ឋបាលតុលាការត្រូវបានកោះប្រជុំដោយប្រធានរបស់ខ្លួន ហើយការពិភាក្សាត្រូវធ្វើជាសម្ងាត់[718]។ ដើម្បីជួយសម្រួលដល់ប្រតិបត្តិការរបស់គណៈកម្មាធិការរដ្ឋបាលតុលាការ គេបានបង្កើតលេខាធិការដ្ឋានមួយ ដែលមានសមាជិកដែលតែងតាំងដោយអង្គជំនុំជម្រះ ក.ស.ច.ស. និង ក.ស.ព. តាមករណីចាំបាច់និងសមស្រប[719]។

### ៤.៥.៣. គណៈកម្មាធិការនីតិវិធី និងវិធាន

គណៈកម្មាធិការនីតិវិធី និងវិធាន គឺជាស្ថាប័នចំពោះកិច្ចរបស់ អ.វ.ត.ក. ដែលទទួល និងពិចារណាសំណើសុំធ្វើវិសោធនកម្មវិធានផ្ទៃក្នុង និងធ្វើសេចក្តីព្រាងសំណើស្តីពីវិសោធនកម្មនោះ សម្រាប់ការពិភាក្សា និងអនុម័តនៅកិច្ចប្រជុំពេញអង្គ[720]។ ប្រសិនបើមានចន្លោះប្រហោងនៅក្នុងវិធានផ្ទៃក្នុង សំណើសុំធ្វើវិសោធនកម្មត្រូវបញ្ជូនទៅគណៈកម្មាធិការនីតិវិធី និងវិធាន ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន[721]។ ការប្រជុំសម្រាប់វិសោធនកម្មវិធានផ្ទៃក្នុងត្រូវធ្វើជាសម្ងាត់ និងកោះប្រជុំដោយប្រធានគណៈកម្មាធិការនីតិវិធី និងវិធាន[722]។

គណៈកម្មាធិការនីតិវិធី និងវិធានក៏ទទួលបន្ទុកអនុម័តសេចក្តីណែនាំអនុវត្តន៍ស្តីពីមុខងាររបស់ អ.វ.ត.ក. ផងដែរ ដែលក្រោយមកត្រូវបានពិនិត្យនៅក្នុងកិច្ចប្រជុំពេញអង្គ។ ការប្រជុំបែបនេះត្រូវបានកោះប្រជុំឡើងតាមការចាំបាច់ដោយប្រធានគណៈកម្មាធិការនីតិវិធី និងវិធាន ឬដោយចៅក្រម សហព្រះរាជអាជ្ញា ប្រធានផ្នែកគាំពារការការពារក្តី ប្រធានផ្នែកគាំពារជនរងគ្រោះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រធាន ឬអនុប្រធានការិយាល័យរដ្ឋបាល[723]។

គណៈកម្មាធិការនីតិវិធី និងវិធានមានសមាសភាពចៅក្រមប្រាំបួនរូប៖ ចៅក្រមជាតិប្រាំរូប និងចៅក្រមអន្តរជាតិបួនរូប ដែលចៅក្រមទាំងអស់ត្រូវបានជ្រើសតាំងនៅក្នុងកិច្ចប្រជុំពេញអង្គ ដោយមានចៅក្រមម្នាក់ជាប្រធាន។ ក៏មានសមាជិកជំនួសពីររូបផងដែរ៖ សមាជិកជំនួសជាតិម្នាក់ និងអន្តរជាតិ

---

[713] វិធានផ្ទៃក្នុង វិធាន ១៩(២)។
[714] វិធានផ្ទៃក្នុង វិធាន ១៩(២)។
[715] វិធានផ្ទៃក្នុង វិធាន ៩(១), ៣៤(៦)។
[716] វិធានផ្ទៃក្នុង វិធាន ១៩(១)។
[717] វិធានផ្ទៃក្នុង វិធាន ១៩(៥)។
[718] វិធានផ្ទៃក្នុង វិធាន ១៩(៣)។
[719] វិធានផ្ទៃក្នុង វិធាន ១៩(៥)។
[720] វិធានផ្ទៃក្នុង វិធាន ២០(២)។
[721] វិធានផ្ទៃក្នុង វិធាន ២។
[722] វិធានផ្ទៃក្នុង វិធាន ២០(២)។
[723] វិធានផ្ទៃក្នុង វិធាន ២០(៣)។

ម្នាក់[724]។ ការចូលរួមអាចធ្វើឡើងដោយផ្ទាល់ ឬពីចម្ងាយ[725] ហើយគណៈកម្មាធិការនីតិវិធី និងវិធាន អាចទទួលឱវាទពីអ្នកជំនាញខាងក្រៅ[726]។ លេខាធិការដ្ឋានមួយដែលបានបង្កើតឡើងតាមសំណើរបស់ប្រធានគណៈកម្មាធិការនីតិវិធី និងវិធាន បានជួយគណៈកម្មាធិការនេះនៅក្នុងប្រតិបត្តិការរបស់ខ្លួន[727]។

## ៤.៦. ការគាំពារផ្នែកច្បាប់

ក្រឡាបញ្ជីគឺជា "ជំនួយការរបស់សហព្រះរាជអាជ្ញា [ស.ច.ស.] និងអង្គជំនុំជម្រះ"[728]។ ពួកគេទទួលបាននីតិសម្បទាពីក្រសួងយុត្តិធម៌[729] និងដើរតួនាទីសំខាន់នៅក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់អង្គជំនុំជម្រះ និងការិយាល័យតុលាការ ជាទូទៅតួនាទីរួមមាន៖

- រក្សាទុកកំណត់ត្រាផ្លូវការនៃកិច្ចស៊ើបសួរ និងកិច្ចដំណើរការនីតិវិធី[730]
- ទទួលការដាក់ឯកសារ និងឯកសារដើមផ្សេងទៀតពីភាគី[731]
- ធានាថាសេចក្តីសម្រេចតុលាការទាំងអស់ត្រូវបានជូនដំណឹងត្រឹមត្រូវ[732]
- បញ្ជូនដីកាកោះ[733]
- ក្នុងករណីរបស់អង្គជំនុំជម្រះ និង ក្រឡាបញ្ជី ក.ស.ច.ស.៖ (i) ត្រួតពិនិត្យការធ្វើប្រតិចារឹក និងការថតទុកជាឯកសារនូវកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[734] (ii) តម្កល់ទុកក្នុងបណ្ណសារនូវកិច្ចស៊ើបសួរ និងដីការបស់ ក.ស.ច.ស. ដែលត្រូវបានមោឃ[735] និង (iii) ជូនដំណឹងភាគីអំពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[736]។

**មុខងារជាក់លាក់របស់ក្រឡាបញ្ជី**

| | |
|---|---|
| **ក្រឡាបញ្ជី ក.ស.ព.** | • រក្សាទុកកំណត់ហេតុខ្មែងឃោលប់គ្នារវាងសហព្រះរាជអាជ្ញា[737] |
| **ក្រឡាបញ្ជី ក.ស.ច.ស.** | • គ្រប់គ្រងការពិនិត្យសំណុំរឿង[738]<br>• រក្សាទុកសៀវភៅចុះបណ្តឹងឧទ្ធរណ៍ និងពាក្យសុំទាំងអស់មកកាន់ ក.ស.ច.ស.[739]<br>• អានកំណត់ហេតុស្តាប់ចម្លើយឱ្យអ្នកដែលត្រូវបានស្តាប់ចម្លើយស្តាប់ពេលណាដែលចាំបាច់[740]<br>• អមដំណើរសហចៅក្រមស៊ើបអង្កេតក្នុងពេលទស្សនកិច្ចទីកន្លែងកើតហេតុផ្ទាល់[741] |

---

724 វិធានផ្ទៃក្នុង វិធាន ២០(១)។
725 វិធានផ្ទៃក្នុង វិធាន ២០(៥)។
726 វិធានផ្ទៃក្នុង វិធាន ២០(៦)។
727 វិធានផ្ទៃក្នុង វិធាន ២០(៦)។
728 វិធានផ្ទៃក្នុង សន្ទានុក្រម។
729 វិធានផ្ទៃក្នុង វិធាន ១៦ស្ទួន។
730 វិធានផ្ទៃក្នុង វិធាន ៧១(៦)។
731 វិធានផ្ទៃក្នុង វិធាន ៣៩(៦)។
732 វិធានផ្ទៃក្នុង សន្ទានុក្រម។
733 វិធានផ្ទៃក្នុង វិធាន ៤១(៣)។ ចំពោះដីកាកោះហៅសាក្សី មុនពេលការបង្ហាញខ្លួនរបស់ពួកគេនៅចំពោះមុខកិច្ចដំណើរការនីតិវិធីជំនុំជម្រះ សូមមើល វិធានផ្ទៃក្នុង វិធាន ៨៤(២)។
734 វិធានផ្ទៃក្នុង វិធាន ៩៧(២)។
735 វិធានផ្ទៃក្នុង វិធាន ៧៦(៥)។
736 វិធានផ្ទៃក្នុង វិធាន ៧៧(១៤)។
737 វិធានផ្ទៃក្នុង វិធាន ៧១(១)។
738 វិធានផ្ទៃក្នុង វិធាន ៥៥(៦)។
739 វិធានផ្ទៃក្នុង វិធាន ៧៧(១)។
740 វិធានផ្ទៃក្នុង វិធាន ៥៥(៧)។
741 វិធានផ្ទៃក្នុង វិធាន ៥៥(៨)។

| | |
|---|---|
| **ក្រឡាបញ្ជី អ.ប.ជ.** | • រក្សាទុកសៀវភៅចុះបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះ និងពាក្យសុំទាំងអស់[742] |
| **ក្រឡាបញ្ជី អ.ជ.ស.ដ.** | • ទទួលបញ្ជីសាក្សី មុនពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[743]<br>• ជូនដំណឹងភាគីអំពីកាលបរិច្ឆេទសវនាការ[744]<br>• ចូលរួមការសួរចម្លើយជនជាប់ចោទពីចម្ងាយក្នុងអំឡុងពេលជំនុំជម្រះ[745] |
| **ក្រឡាបញ្ជី អ.ជ.ត.ក.** | • ទទួលការជូនដំណឹងអំពីបណ្តឹងសាទុក្ខ សារណាបណ្តឹងសាទុក្ខ[746] និងសារណាអំពីបណ្តឹងសាទុក្ខ[747]<br>• ជូនដំណឹងភាគីអំពីកាលបរិច្ឆេទសវនាការ[748] |

### ៤.៦.១. កម្មសិក្សាការី

អ.វ.ត.ក. ផ្តល់ឱកាសឱ្យ សិស្ស និស្សិតដែលទើបបញ្ចប់ការសិក្សាថ្មីៗ និងអ្នកប្រកបវិជ្ជាជីវៈវ័យក្មេងមកពីប្រទេសកម្ពុជា ឬមកពីបរទេស ធ្វើការនៅក្នុងផ្នែកមួយក្នុងចំណោមផ្នែកនានានៃ អ.វ.ត.ក.។ ភាគីជាតិ និងភាគីអន្តរជាតិនៃ អ.វ.ត.ក. ដំណើរការកម្មវិធីកម្មសិក្សាពីរដាច់ដោយឡែកពីគ្នា។ បេក្ខជនត្រូវចុះឈ្មោះក្នុងកម្មវិធីថ្នាក់បរិញ្ញាបត្រ ឬបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ឬបានចុះឈ្មោះក្នុងឆ្នាំសិក្សាចុងក្រោយនៃកម្មវិធីថ្នាក់បរិញ្ញាបត្រ ឬបានបញ្ចប់ការសិក្សាឆ្នាំចុងក្រោយនៃកម្មវិធីថ្នាក់បរិញ្ញាបត្រ។

កម្មសិក្សាការីមានលទ្ធភាពបំពេញកម្មសិក្សាដំបូងរយៈពេលបីខែ ដោយមានលទ្ធភាពបន្តសម្រាប់បីខែបន្ថែមទៀត។ កម្មសិក្សាមិនមានរយៈពេលខ្លីជាងពីរខែ ឬវែងជាងប្រាំមួយខែបានឡើយ។ បេក្ខជនអាចបង្ហាញចំណាប់អារម្មណ៍របស់ខ្លួនសម្រាប់ផ្នែកនានានៃ អ.វ.ត.ក. ដែលពួកគេមានបំណងចង់ចូលរួមធ្វើកម្មសិក្សា។ ក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ កម្មសិក្សាការីបានបំពេញកម្មសិក្សាពីចម្ងាយដោយសារការធ្វើដំណើរមកកាន់ប្រទេសកម្ពុជាត្រូវបានរឹតត្បិត។ ចន្លោះខែឧសភា ឆ្នាំ២០០៧ និងខែធ្នូ ឆ្នាំ២០២៣ អ.វ.ត.ក. បានផ្តល់កម្មសិក្សាជាង ១៩៥០ (ក្នុងនោះកម្មសិក្សាជាង ៦០០ ត្រូវបានគ្រប់គ្រងដោយភាគីជាតិ ហើយប្រមាណ ១៣០០ ទៀត ត្រូវបានគ្រប់គ្រងដោយ UNAKRT)។

### ៤.៧. ការិយាល័យរដ្ឋបាល

ការិយាល័យរដ្ឋបាល "គាំទ្រដល់ការបំពេញការងាររបស់អង្គជំនុំជម្រះ ការិយាល័យសហព្រះរាជអាជ្ញា ការិយាល័យសហចៅក្រមស៊ើបអង្កេត និងកិច្ចប្រជុំពេញអង្គ និងត្រូវទទួលខុសត្រូវចំពោះកិច្ចការរដ្ឋបាល និងការផ្តល់សេវាកម្មរបស់ស្ថាប័នទាំងនោះ"[749]។ ការទទួលខុសត្រូវរបស់ការិយាល័យរដ្ឋបាលរួមបញ្ចូលការធានាសន្តិសុខរបស់ អ.វ.ត.ក. ដូចមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែមស្តីពីសុវត្ថិភាពនិងសន្តិសុខ[750] ការធានាផ្តល់ជូននូវសម្ភារៈ ការគ្រប់គ្រងអាគារ បច្ចេកវិទ្យាព័ត៌មាន ភស្តុភារ យានជំនិះ និងមធ្យោបាយធ្វើដំណើរ ដូចមានចែងក្នុងកិច្ចព្រមព្រៀងបន្ថែមស្តីពីសម្ភារៈប្រើប្រាស់[751] ដើរតួនាទីជាច្រក

742 វិធានផ្ទៃក្នុង វិធាន ៧៧(១)។
743 វិធានផ្ទៃក្នុង វិធាន ៨០(១)-(២)។
744 វិធានផ្ទៃក្នុង វិធាន៨០(៦)។
745 វិធានផ្ទៃក្នុង វិធាន ៨១(៦)។
746 វិធានផ្ទៃក្នុង វិធាន ១០៦(៥)។
747 វិធានផ្ទៃក្នុង វិធាន ១០៨(៦)។
748 វិធានផ្ទៃក្នុង វិធាន ១០៨(៣)។
749 វិធានផ្ទៃក្នុង វិធាន ៩(១)។ ចំពោះការិយាល័យរដ្ឋបាល សូមមើលផងដែរ កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៨។
750 វិធានផ្ទៃក្នុង វិធាន ៩(២)។
751 វិធានផ្ទៃក្នុង វិធាន ៩(៣)។

ទំនាក់ទំនងផ្លូវការសម្រាប់ការទំនាក់ទំនងខាងក្នុង និងខាងក្រៅ អ.វ.ត.ក.[752] ថែរក្សាមូលដ្ឋានទិន្នន័យឱ្យបានសមស្រប ការពារថែរក្សាទុក និងរក្សាសុវត្ថិភាពឯកសារ និងសម្ភារៈក្នុងសំណុំរឿង[753] និងសម្របសម្រួលនិងគាំទ្រការបណ្ដុះបណ្ដាលបុគ្គលិក អ.វ.ត.ក.[754]។ ការិយាល័យរដ្ឋបាលមានផ្នែកជាច្រើន ដែលមានមុខងារ និងការទទួលខុសត្រូវខុសៗគ្នា រួមមាន ផ្នែកគ្រប់គ្រងតុលាការ ផ្នែកកិច្ចការសាធារណៈ ផ្នែកសេវាកម្មទូទៅ ផ្នែកសុវត្ថិភាព និងសន្តិសុខ ផ្នែកបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន និងអង្គភាពគាំទ្រមួយចំនួនទៀត។

ការិយាល័យរដ្ឋបាលដឹកនាំដោយប្រធានការិយាល័យរដ្ឋបាលម្នាក់ និងអនុប្រធានការិយាល័យរដ្ឋបាលម្នាក់[755]។ លក្ខខណ្ឌតម្រូវសម្រាប់តំណែងជាប្រធានការិយាល័យរដ្ឋបាលរួមមានបទពិសោធន៍សំខាន់ៗក្នុងរដ្ឋបាលតុលាការ ចេះភាសាបារាំង ឬភាសាអង់គ្លេសស្ទាត់ និងមានសីលធម៌ខ្ពស់ និងសុចរិតភាព[756]។ ប្រធានការិយាល័យរដ្ឋបាលទទួលខុសត្រូវលើការគ្រប់គ្រងការិយាល័យរដ្ឋបាល លើកលែងបញ្ហាដែលស្ថិតក្រោមវិធាន និងនីតិវិធីរបស់ អ.ស.ប.[757]។ អនុប្រធានការិយាល័យរដ្ឋបាលត្រូវបានជ្រើសរើសជាអន្តរជាតិ និងត្រូវបានតែងតាំងដោយ UNSG[758]។ គាត់ទទួលខុសត្រូវលើការជ្រើសរើសបុគ្គលិកអន្តរជាតិទាំងអស់ និងការគ្រប់គ្រងរដ្ឋបាលលើសមាសភាពអន្តរជាតិ និងផ្នែកនានានៃ អ.វ.ត.ក.[759]។ តួនាទីនេះមានការទទួលខុសត្រូវដាច់ដោយឡែកពីការទទួលខុសត្រូវរបស់មន្ត្រីសម្របសម្រួល UNAKRT ប៉ុន្តែដើម្បីប្រសិទ្ធភាពផ្នែកប្រតិបត្តិការ តួនាទីទាំងពីរនេះត្រូវបានបំពេញរួមគ្នាដោយបុគ្គលម្នាក់ប៉ុណ្ណោះ។ ក្នុងបរិបទនេះ អនុប្រធានការិយាល័យរដ្ឋបាល/មន្ត្រីសម្របសម្រួល UNAKRT គ្រប់គ្រងរដ្ឋបាលលើធនធាន ដែលបានផ្ដល់ជូនតាមរយៈ អ.ស.ប.[760]។

ប្រធានការិយាល័យរដ្ឋបាល និង អនុប្រធានការិយាល័យរដ្ឋបាល ដោយមានការពិគ្រោះយោបល់ជាមួយប្រធានផ្នែកគាំពារការការពារក្ដី អង្គជំនុំជម្រះ ក.ស.ព និង ក.ស.ច.ស. ទទួលខុសត្រូវរួមគ្នាលើការធានាថា ការិយាល័យរដ្ឋបាលទទួលបានការជូនដំណឹងដ៏ត្រឹមត្រូវអំពីលក្ខខណ្ឌនៃការឃុំខ្លួន[761]។ ទោះបីជាកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាល កំណត់អាណត្តិកិច្ចសហប្រតិបត្តិការរបស់ពួកគេឱ្យធានាបាននូវការបំពេញមុខងាររដ្ឋបាលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលយ៉ាងណាក្ដី[762] ក៏ក្របខណ្ឌច្បាប់ អ.វ.ត.ក. មិនបានផ្ដល់យន្តការណាមួយដើម្បីដោះស្រាយបញ្ហាខ្វែងយោបល់គ្នាណាមួយដែលអាចមានរវាងប្រធានការិយាល័យរដ្ឋបាល និងអនុប្រធានការិយាល័យរដ្ឋបាលនោះឡើយ។

### ៤.១.៧. ផ្នែកគ្រប់គ្រងតុលាការ

ផ្នែកគ្រប់គ្រងតុលាការសម្របសម្រួល និងផ្ដល់សេវាទៅឱ្យរាល់ការិយាល័យតុលាការ និងអង្គជំនុំជម្រះទាំងអស់ក្នុងការបំពេញមុខងាររបស់ពួកគេ។ វាមានការិយាល័យរងមួយចំនួន រួមមាន អង្គភាពបណ្ណសារ ការិយាល័យជូរមុខ អង្គភាពបកប្រែភាសា អង្គភាពប្រតិចារឹក អង្គភាពសោតទស្សន៍ និងអង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង។

---

[752] វិធានផ្ទៃក្នុង វិធាន ៩(៤)។
[753] វិធានផ្ទៃក្នុង វិធាន ៩(៥)-(៦), ១០(៤)។
[754] វិធានផ្ទៃក្នុង វិធាន ៩(៧)។
[755] ច្បាប់ អ.វ.ត.ក. មាត្រា ៣០ និង ៣១។ វិធានផ្ទៃក្នុង វិធាន ៨។ សម្រាប់ព័ត៌មានបន្ថែមស្ដីពីការតែងតាំង ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល សូមមើល ជំពូក ៤.៨។
[756] ច្បាប់ អ.វ.ត.ក. មាត្រា ៣១ ថ្មី។
[757] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៨(២)។ ច្បាប់ អ.វ.ត.ក. មាត្រា ៣១ ថ្មី។
[758] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៨(៣)។ ច្បាប់ អ.វ.ត.ក. មាត្រា ៣១ ថ្មី។ បទប្បញ្ញត្តិទាំងនេះបញ្ជាក់ថា បន្ទាប់ពីត្រូវបានតែងតាំងរួច អនុប្រធានការិយាល័យរដ្ឋបាលត្រូវតែចាត់តាំងដោយរាជរដ្ឋាភិបាលកម្ពុជា។
[759] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៨(៣)។ ច្បាប់ អ.វ.ត.ក. មាត្រា ៣១ ថ្មី។
[760] ច្បាប់ អ.វ.ត.ក. មាត្រា ៣១ ថ្មី។
[761] លក្ខណ្ឌបែបនេះត្រូវគោរពតាមច្បាប់កម្ពុជា វិធានអង្គការសហប្រជាជាតិស្ដីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តលើជនជាប់ឃុំ និងគោលការណ៍មូលដ្ឋានរបស់ អ.ស.ប. សម្រាប់ការប្រព្រឹត្តលើអ្នកទោស។ សូមមើល វិធានផ្ទៃក្នុង វិធាន ១០(៣)។ សូមមើលផងដែរ ជំពូក ៤.៧.១.៥ ទាក់ទងនឹងអង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង។
[762] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៨(៤)។

### ៤.៧.១.១. អង្គភាពបណ្ណសារ និងការិយាល័យជួរមុខ

អង្គភាពបណ្ណសារ គឺជាការិយាល័យទទួលខុសត្រូវលើការថែរក្សាឯកសារតុលាការ នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក.។ អង្គភាពបណ្ណសារ ថែរក្សា រក្សាទុក និងរក្សាសុវត្ថិភាពឯកសារដើមរបស់សំណុំរឿង ក៏ដូចជាឯកសារជាអេឡិចត្រូនិក "ឯកសារដូចជា វត្ថុតាង ចម្លើយ និងឯកសារទាំងឡាយដែលប្រមូលបានក្នុងពេលស៊ើបអង្កេតបឋម ពេលស៊ើបសួរ ពេលជំនុំជម្រះនៅអង្គជំនុំជម្រះសាលាដំបូង និងនៅអង្គជំនុំជម្រះតុលាការកំពូល"[763]។ រួមគ្នាជាមួយនឹងក្រឡាបញ្ជីទទួលបន្ទុក អង្គភាពបណ្ណសារក៏ទទួលបន្ទុកការធ្វើកាត់តាឡុក និងការបែងចែកឯកសារ និងវត្ថុតាងតុលាការទាំងអស់ផងដែរ។

ក្នុងអំឡុងពេលកិច្ចដំណើរការតុលាការ អង្គភាពបណ្ណសារបានធ្វើការយ៉ាងជិតស្និទ្ធជាមួយការិយាល័យជួរមុខ និងមន្ត្រីតុលាការ និងទទួលខុសត្រូវលើការទទួលដាក់ឯកសារ និងការសម្របសម្រួលការគ្រប់គ្រងសំណុំរឿងជាមួយក្រឡាបញ្ជី[764]។ ក្នុងពេលសវនាការ និងជំនុំជម្រះ ការិយាល័យជួរមុខបានធានាថារាល់ការរៀបចំទូទៅទាំងអស់ត្រូវបានរៀបចំជាស្រេចសម្រាប់វគ្គសវនាការរបស់តុលាការ ដើម្បីឱ្យដំណើរការបានរលូន និងស្របតាមការណែនាំរបស់មន្ត្រីតុលាការ និងអង្គជំនុំជម្រះ។

អង្គភាពបណ្ណសារថែរក្សាឯកសារសំណុំរឿង ស្របតាមលក្ខខណ្ឌត្រួតពិនិត្យបរិយាកាស និងវិធានការសុវត្ថិភាព[765]។ ឯកសារត្រូវបានរក្សាទុកក្នុងប្រអប់គ្មានជាតិអាស៊ីត ក្នុងសីតុណ្ហភាព និងនិហិតដ្ឋានដែលត្រូវបានត្រួតពិនិត្យកម្រិតសំណើម។ ទ្វារអគ្គិភ័យ របៀបរបបចេញចូលសុវត្ថភាព និងកាមេរ៉ាសុវត្ថិភាព ផានាសន្តិសុខ និងសុចរិតភាពរបស់ឯកសារ។ ជាមួយនឹងការចាប់ផ្តើមមុខងារសេសសល់ និងតម្រូវការថែរក្សា រក្សាទុក និងគ្រប់គ្រងបណ្ណសាររបស់ខ្លួន ស្របតាមបទដ្ឋានអន្តរជាតិ និហិតដ្ឋានត្រូវបានបំពាក់ដោយធ្នើរ(ចល័ត) ឧបករណ៍កំណត់កម្រិតសំណើម និងទ្រនាប់ការពារកម្តៅ ដើម្បីការពារឯកសារបន្ថែមទៀតពីកម្តៅ សំណើម ជាតិពុល និងសត្វល្អិត។

បណ្ណសារមានឯកសារជាង ២,៣ លានទំព័រ ដែលមានឯកសារប្រមាណ ២៣២.០០០ ជាភាសាខ្មែរ បារាំង និង អង់គ្លេស រួមបញ្ចូលទាំងសេចក្តីសម្រេច និងដីការតុលាការជាង ១.៣៤៥ ប្រតិចារឹកសវនាការចំនួន ៦៧០ និងវត្ថុតាងរាប់សែន។ ឯកសាររបស់ អ.វ.ត.ក. ត្រូវបានធ្វើឱ្យទៅជាឌីជីថលទាំងស្រុង ហើយឯកសារសំណុំរឿងសាធារណៈអាចរកបានតាមអនឡាញ។

កម្រងឯកសារពិសេស មានសៀវភៅជាង ១.៨០០ ក្បាល សៀវភៅអេឡិចត្រូនិក និងការបោះពុម្ពផ្សាយផ្សេងទៀត ក៏ត្រូវបានគ្រប់គ្រងដោយអង្គភាពបណ្ណសារផងដែរ។ ដើមឡើយឯកសារនេះត្រូវបានផ្តល់ជាសេវាផ្ទៃក្នុងទៅឱ្យការិយាល័យតុលាការ និងអង្គជំនុំជម្រះ រួមទាំងមេធាវី និងអ្នកប្រើប្រាស់ផ្សេងទៀត ប៉ុន្តែត្រូវបានបើកឱ្យប្រើជាឯកសារយោងសាធារណៈ រួមជាមួយនឹងឯកសារសំណុំរឿងសាធារណៈ នៅមជ្ឈមណ្ឌលធនធាន អ.វ.ត.ក. នៅភ្នំពេញ។

### ៤.៧.១.២. អង្គភាពគាំពារសាក្សី និងអ្នកជំនាញ

អង្គភាពគាំពារសាក្សីនិងអ្នកជំនាញត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់ការបង្ហាញខ្លួនសាក្សី អ្នកជំនាញ និងដើម្បបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក.[766]។ អង្គភាពនេះបានគាំពារសាក្សី នៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការតុលាការ (ដំណាក់កាលស៊ើបអង្កេតបឋម ស៊ើបអង្កេតដោយតុលាការ ការជំនុំជម្រះ និងបណ្តឹងសាទុក្ខ)[767] ដោយអនុវត្តមុខងារខាងក្រោម៖

---

763 វិធានផ្ទៃក្នុង វិធាន ៩(៦)។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ១០(៤)។

764 សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ១០(៤)។ សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក. មាត្រា ២.១។

765 វិធានផ្ទៃក្នុង វិធាន ១០(៤)។

766 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២៣។ ច្បាប់ អ.វ.ត.ក. មាត្រា ៣៣។ វិធានផ្ទៃក្នុង វិធាន ២៩។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ។

767 ច្បាប់ អ.វ.ត.ក. មាត្រា ២៣ ថ្មី, ៣៣ ថ្មី។ វិធានផ្ទៃក្នុង វិធាន ២៤, ២៦, ៣១, ៥៥(៥), ៦០, ៨៤, ៩១, ៩៣(២), ១០៨(៧)។

- ជូនដំណឹងសាក្សីអំពីសិទ្ធិរបស់ពួកគេ
- ធានាបរិយាកាសសុវត្ថិភាពនិងសន្តិសុខសម្រាប់សាក្សីទាំងអស់ ក្នុងការទំនាក់ទំនងរបស់ពួកគេជាមួយនឹង អ.វ.ត.ក. រួមបញ្ចូលទាំងតាមរយៈការផ្តល់ការគាំពារប្រចាំការ ២៤ ម៉ោង ក្នុងពេលស្នាក់នៅភ្នំពេញ ប្រសិនបើចាំបាច់
- ផ្តល់ការទំនាក់ទំនងទៅអង្គការចិត្តសង្គមអន្តរវប្បធម៌ សម្រាប់ការគាំពារផ្នែកផ្លូវចិត្ត និងផ្លូវកាយ
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយមន្ត្រីតុលាការ នឹង/ឬ អង្គជំនុំជម្រះ ផ្នែកគាំពារជនរងគ្រោះ ផ្នែកគ្រប់គ្រងតុលាការ និងការិយាល័យរដ្ឋបាល ដើម្បីផ្តល់ការគាំពារផ្នែកប្រតិបត្តិការ ភ័ស្តុភារ និងរដ្ឋបាល ដើម្បីផ្តល់លទ្ធភាពដល់ការបង្ហាញខ្លួនរបស់សាក្សី
- ជៀសវាងមិនឱ្យមានព្យសនកម្មបន្ថែម និងការកើតជំងឺបាក់ស្បាតឡើងវិញចំពោះជនរងគ្រោះ ដែលងាយនឹងទទួលរងគ្រោះ

ការទទួលខុសត្រូវរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ រួមបញ្ចូលការអនុវត្តវិធានការការពារសម្រាប់សាក្សី ដោយសហការជាមួយគណៈកម្មការសន្តិសុខ អ.វ.ត.ក. នឹង/ឬ អាជ្ញាធរមូលដ្ឋាន។ មុនពេលអនុម័តវិធានការការពារណាមួយ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានផ្តល់ការវាយតម្លៃហានិភ័យជាលក្ខណៈបុគ្គល ទាក់ទងនឹងវិធានការដែលបានស្វែងរក[768]។ បន្ទាប់មក វិធានការការពារដែលបង្គាប់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ ទាំងតាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬបន្ទាប់ពីមានសំណើរបស់ភាគី[769]។

វិធានការការពារចំនួនពីរបានអនុវត្ត។ វិធានការក្រៅតុលាការធ្វើឡើងដើម្បីកាត់បន្ថយការប្រឈមមុខនឹងការគំរាមកំហែងដល់សាក្សី ឬផ្តល់ការឆ្លើយតបសមស្របទៅនឹងការគំរាមកំហែងនៅកន្លែងស្នាក់នៅរបស់ពួកគេ។ វិធានការក្នុងតុលាការបានធ្វើឡើងដើម្បីការពារអត្តសញ្ញាណរបស់សាក្សី និង/ឬកន្លែងស្ថិតនៅ ក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់ពួកគេនៅចំពោះមុខ អ.វ.ត.ក.។ វិធានការទាំងនេះរួមមាន៖

- ដកចេញឈ្មោះសាក្សី អាសយដ្ឋាន ទីកន្លែងស្ថិតនៅ និងព័ត៌មានផ្សេងទៀត ដែលអាចកំណត់អត្តសញ្ញាណសាក្សីបាន
- ផ្តល់រហស្សនាម និងបង្គាប់ភាគីឱ្យយោងសំដៅលើសាក្សីដោយប្រើរហស្សនាម ជំនួសឱ្យឈ្មោះរបស់ពួកគេ
- ដកឈ្មោះសាក្សីចេញពីឯកសារតុលាការ និងបោះត្រា ឬកោសលុប ព័ត៌មានបែបនោះពីកំណត់ត្រាសាធារណៈ
- បំប្លែងសំឡេង និង/ឬ លក្ខណៈរូបរាងភិនភាគរបស់សាក្សី នៅលើផ្ទាំងព័ត៌មានក្នុងតុលាការ និង/ឬ ដាក់របាំងបិទជុំវិញសាក្សី ដើម្បីកុំឱ្យសាធារណជនដែលអង្គុយក្នុងសាលសវនាការស្គាល់សាក្សី
- ដំណើរការនីតិវិធីជាសម្ងាត់[770]។

នៅពេលបង្គាប់ឱ្យមានវិធានការការពារ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះត្រូវថ្លឹងថ្លែងពីផលប្រយោជន៍ខុសៗគ្នា ដូចជា តម្រូវការរបស់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី សិទ្ធិរបស់ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ (តាមដំណាក់កាលកិច្ចដំណើរការនីតិវិធី) និងភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី[771]។

នៅពេលផ្តល់សក្ខីកម្ម សាក្សីមានសិទ្ធិមានមេធាវី នៅពេលដែលសក្ខីកម្មនោះអាចដាក់បន្ទុកលើខ្លួនឯង[772]។ ត្រង់ចំណុចនេះ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានរក្សាទុកបញ្ជីមេធាវីប្រចាំការ ដើម្បីផ្តល់

---

768 សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ មាត្រា ២.៣, ២.៥។
769 វិធានផ្ទៃក្នុង វិធាន ២៩(៣)។ សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ មាត្រា ១។
770 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២៣។ ច្បាប់ អ.វ.ត.ក. មាត្រា ៣៣។ វិធានផ្ទៃក្នុង វិធាន ២៩ (៤)។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ មាត្រា ៣។
771 កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២៣។ ច្បាប់ អ.វ.ត.ក. មាត្រា ៣៣។ វិធានផ្ទៃក្នុង វិធាន ២៩។ សូមមើលផងដែរ សេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ។
772 វិធានផ្ទៃក្នុង វិធាន ២៨(៩)។

ដំបូន្មានផ្នែកច្បាប់ដល់សាក្សី។ ដើម្បីជួយសម្រួលបន្ថែមទៀតដល់ការបង្ហាញខ្លួនរបស់ពួកគេនៅចំពោះមុខ អ.វ.ត.ក. អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានរៀបចំភស្តុភារនានា រួមមានការធ្វើដំណើរ ការហូបចុក និងប្រាក់ឧបត្ថម្ភផ្សេងៗ។

## ៤.៧.១.៣. អង្គភាពបកប្រែភាសា

តួនាទីចម្បងរបស់អង្គភាពបកប្រែភាសា គឺផ្តល់ឱវាទ និងផ្តល់សេវាបកប្រែភាសាលើភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក.៖ ភាសាខ្មែរ អង់គ្លេស និងបារាំង។ អ្នកបកប្រែផ្ទាល់ អ.វ.ត.ក. បានផ្តល់ការបកប្រែផ្ទាល់មាត់ដំណាលគ្នា ឬជាប់គ្នា រវាងបីភាសានៅពេលសវនាការ ការស្តាប់ចម្លើយរបស់តុលាការ កិច្ចប្រជុំពេញអង្គ ការប្រជុំគណៈកម្មាធិការ ការបណ្តុះបណ្តាល និងព្រឹត្តិការណ៍សំខាន់ៗផ្សេងទៀត នៅ អ.វ.ត.ក.។ អ្នកបកប្រែផ្ទាល់មាត់បានផ្តល់សេវាបកប្រែផ្ទាល់មាត់ ក្នុងអំឡុងពេលដំណាក់កាលស៊ើបអង្កេតបឋម និងដំណាក់កាលស៊ើបសួរដោយតុលាការ នៅពេលប្រជុំរវាងចុងចោទ និងមេធាវីការពារក្តីរបស់ខ្លួន ក្នុងពេលពិភាក្សាជាមួយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងពេលសវនាការនៅចំពោះមុខអង្គជំនុំជម្រះនៃ អ.វ.ត.ក.។

អង្គភាពបកប្រែភាសាក៏បានធ្វើការជាមួយអ្នកបកប្រែភាសាក្រៅក្របខណ្ឌ និងបានបញ្ជូនការងារបកប្រែទៅឱ្យក្រុមហ៊ុនខាងក្រៅធ្វើម្តងម្កាលផងដែរ ដើម្បីធានាបានថាលក្ខខណ្ឌតម្រូវផ្នែកតួលេខការទាំងអស់ត្រូវបានបំពេញ។ អង្គភាពបកប្រែភាសាបានបង្កើតគោលការណ៍ណែនាំសម្រាប់អ្នកប្រកប្រែក្រៅក្របខណ្ឌ និងក្រុមហ៊ុនខាងក្រៅ ដើម្បីធានាថាការបកប្រែភាសា ដែលបានធ្វើហើយនោះ ស្របជាមួយនឹងលទ្ធផលការងាររបស់អ្នកបកប្រែភាសា អ.វ.ត.ក. និងដើម្បីធានាថាវាត្រឹមត្រូវតាមទម្រង់បទដ្ឋាន។

ដោយសារតែភាពស្មុគស្មាញផ្នែកភាសា ការបកប្រែជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាផ្សេងទៀតត្រូវបានធ្វើឡើងក្នុងបរិមាណ បួនទំព័រក្នុងមួយថ្ងៃ សម្រាប់អ្នកបកប្រែម្នាក់ ឬប្រាំទំព័រក្នុងមួយថ្ងៃសម្រាប់ការបកប្រែបន្ទាន់។ តាមបទដ្ឋានកំណត់ មួយទំព័រភាសាខ្មែរ មានចំនួន ១៥០០ ព្យាង្គ ចំណែកឯកសារជាភាសាអង់គ្លេស និងបារាំងកំណត់ជាមូលដ្ឋាន ៣០០ ពាក្យ ក្នុងមួយទំព័រ។ ដើម្បីជួយសម្រួលការងាររបស់ខ្លួន និងដើម្បីបង្កើតភាពស៊ីចង្វាក់គ្នានៃភាសាផ្ទៃក្នុង និងក្នុងប្រទេសកម្ពុជា អង្គភាពបកប្រែភាសាបានចងក្រងសទ្ទានុក្រមជាបីភាសា ផ្អែកលើឯកសារផ្សេងៗពី អ.វ.ត.ក. និង ក្របខណ្ឌច្បាប់ អ.វ.ត.ក.។ សទ្ទានុក្រមនេះមាននៅលើគេហទំព័រ អ.វ.ត.ក.។

## ៤.៧.១.៤. អង្គភាពប្រតិចារឹក

តួនាទីចម្បងរបស់អង្គភាពប្រតិចារឹក គឺត្រូវផ្តល់កំណត់ហេតុត្រឹមត្រូវតាមពាក្យពេចន៍ នៃកិច្ចដំណើរការនីតិវិធីតុលាការ ជាបីភាសាផ្លូវការ និងផ្តល់ជូនទៅអង្គជំនុំជម្រះ និងភាគីឱ្យបានទាន់ពេលវេលា។ ការណ៍នេះរួមបញ្ចូលទាំង ការជួយដល់បេសកកម្មតាមបណ្តាខេត្ត និងការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស.។ បុគ្គលិកប្រតិចារឹករបស់ អ.វ.ត.ក. ត្រូវកត់ត្រាពាក្យពេចន៍ឱ្យបានត្រឹមត្រូវនៅក្នុងកិច្ចដំណើរការនីតិវិធី មានន័យថា បញ្ហាណាក៏ដោយទាក់ទងនឹងកំហុសវេយ្យាករណ៍ ការផ្លាស់ប្តូរគំនិត ពាក្យបំពេញ ការនិយាយខុស ឬប្រយោគរៀបចំមិនបានល្អ ត្រូវតែធ្វើប្រតិចារឹកឱ្យបានដូចតាមអ្វីដែលបាននិយាយនោះ។

អ្នកធ្វើប្រតិចារឹកបានធ្វើការរួមគ្នាជាមួយនឹងអ្នកកត់ត្រាក្នុងតុលាការ។ អ្នកកត់ត្រាក្នុងតុលាការទទួលខុសត្រូវធ្វើបញ្ជីកិច្ចដំណើរការតុលាការទាំងអស់ និងព័ត៌មានពាក់ព័ន្ធ ដើម្បីឱ្យអ្នកធ្វើប្រតិចារឹកអាចបង្កើតប្រតិចារឹកមួយដែលកត់ត្រាបានត្រឹមត្រូវ និងពេញលេញ។ ដើម្បីធ្វើដូច្នេះបាន អ្នកកត់ត្រាបានកំណត់អាទិភាពអត្តសញ្ញាណអ្នកនិយាយ និងបានស្តាប់សំឡេងដែលបានថត (ដែលផ្ទុយទៅនឹងប្រភពនៃសម្តី) ដើម្បីស្វែងរកចំណុចណាដែលមិនប្រក្រតី។

ប្រតិចារឹកកិច្ចដំណើរការនីតិវិធីបានធ្វើឡើងជាពីរដំណាក់កាល៖ ទីមួយ សេចក្តីព្រាងប្រតិចារឹកត្រូវបានប្រគល់ជូនក្រឡាបញ្ជីនៃអង្គជំនុំជម្រះពាក់ព័ន្ធ និងចែករំលែកជាមួយភាគីដែលមានសមត្ថកិច្ច។ ទីពីរ ប្រតិចារឹកចុងក្រោយត្រូវបានដាក់ទៅអង្គភាពបណ្ណសារ សម្រាប់ដាក់បញ្ចូលក្នុងសំណុំរឿង។ អាចមានដំណាក់កាលទីបី ប្រសិនបើអង្គជំនុំជម្រះចេញដីកាបង្គាប់ឱ្យធ្វើការកោសលុប ដែលតម្រូវឱ្យធ្វើការកោសលុបប្រតិចារឹកនោះ ក្នុងករណីបែបនេះ ប្រតិចារឹកត្រូវបានកែតម្រូវ និងដាក់ឡើងវិញ។ ប្រតិចារឹកសំណៅ

ចុងក្រោយតាមភាសានីមួយៗអាចរកបានប្រមាណប្រាំថ្ងៃ ក្រោយពេលសវនាការ។ ក្រោយមក អង្គភាពប្រតិចារឹក ដាក់ប្រតិចារឹកចុងក្រោយជាសំណៅរឹង និងទន់ ទៅអង្គភាពបណ្ណសារ។ សំណើសុំប្រតិចារឹកត្រូវបានកត់ត្រា និងបញ្ជូនទៅកាន់អង្គភាពបណ្ណសារ។

វិធាន ៩៧ នៃវិធានផ្ទៃក្នុង ចែងថា ភាគីអាចស្នើទៅកាន់អង្គជំនុំជម្រះសាលាដំបូង សុំឱ្យកែតម្រូវកំហុសណាមួយ (ដូចជា កំហុសការធ្វើប្រតិចារឹក ឬការបកប្រែ) នៅក្នុងប្រតិចារឹក[773]។ ដំណើរការកែតម្រូវនេះមានគូសបញ្ជាក់នៅក្នុងមាត្រា ៣.១៧ និង ៣.១៧(ស្ទួន) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ ប្រសិនបើការកែប្រែ បានផ្លាស់ប្តូរខ្លឹមសារអត្ថបទ ដូច្នេះសំណៅចាស់ក៏ត្រូវរក្សាទុកក្នុងសំណុំរឿងសម្រាប់ជាឯកសារយោងនាពេលអនាគតដែរ។

## ៤.៧.១.៥. អង្គភាពសោតទស្សន៍

អង្គភាពសោតទស្សន៍ ទទួលខុសត្រូវលើការផ្តល់សេវាសោតទស្សន៍។ អង្គភាពនេះទទួលខុសត្រូវលើការថតចម្លង និងការផ្សាយបន្តផ្ទាល់ វគ្គសវនាការទាំងអស់ដែលបានធ្វើឡើងនៅចំពោះមុខ អ.វ.ត.ក. ក៏ដូចជា ការថតចម្លងការស្តាប់ចម្លើយ ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។ អង្គភាពនេះក៏ជួយការិយាល័យជួរមុខ និងអង្គភាពបណ្ណសារនៃផ្នែកគ្រប់គ្រងតុលាការ ក្នុងការរក្សាទុក និងការទាញយកសម្ភារៈសោតទស្សន៍ផងដែរ និងធានាថាមានខ្សែអាត់ និងស្លាកគ្រប់គ្រាន់មុនពេលសវនាការនីមួយៗ។

ជាទូទៅ ការថតចម្លងសោតទស្សន៍ បានចាប់ផ្តើមនៅពេលក្រឡាបញ្ជីអង្គជំនុំជម្រះចុចកណ្តឹងដំបូង។ ការថតចម្លងវគ្គសវនាការ ដោយ DVCam បានបន្តរយៈពេលយូរបំផុត ១៨៤ នាទី នេះគឺជាថិរវេលាអតិបរមាក្នុងមួយខ្សែអាត់។ ការថតចម្លងបានចប់នៅពេលដែលចៅក្រមបានចាកចេញពីសាលសវនាការ។ ក្នុងវគ្គសវនាការសាធារណៈ មានផ្ទាំងផ្សាយបន្តផ្ទាល់នៅលើអេក្រង់ ឧបករណ៍បំពងសំឡេង និងកាស់ស្តាប់ការបកប្រែប្រដេញផ្ទាល់មាត់នៅក្នុងសាលសាធារណៈ និងបន្ទប់សារព័ត៌មាន។ ក្នុងអំឡុងពេលវគ្គសវនាការអសាធារណៈ និងសវនាការសម្ងាត់ ផ្ទាំងផ្សាយបន្តផ្ទាល់ពីបន្ទប់សវនាការត្រូវបានបិទជាបណ្តោះអាសន្ន ហើយត្រូវបានជំនួសដោយផ្ទាំងអក្សរសរសេរថា កិច្ចដំណើរការនីតិវិធីកំពុងធ្វើឡើងជាអសាធារណៈ ឬជាសម្ងាត់។ នៅក្នុងវគ្គសវនាការអសាធារណៈ វាំងននបន្ទប់សវនាការនៅតែបើក ប៉ុន្តែនៅក្នុងវគ្គសវនាការសម្ងាត់វិញ វាំងននត្រូវបានបិទ ដើម្បីកុំឱ្យមើលពីសាលសាធារណៈមកឃើញ។

នៅពេលដែលសាក្សីទទួលបានការការពារ បានផ្តល់សក្ខីកម្មក្នុងសាលសវនាការ អង្គភាពសោតទស្សន៍ត្រូវធានាថា វិធានការបច្ចេកទេសសមស្របត្រូវបានត្រៀមរៀបចំជាស្រេច។ ឧទាហរណ៍ ក្នុងពេលសក្ខីកម្ម អ្នកចូលរួមអាចមើលឃើញសាក្សីនៅក្នុងសាលសវនាការ (រួមទាំងជនជាប់ចោទ) និងអ្នកបកប្រែភាសា ប៉ុន្តែត្រូវបានបិទបាំងពីសាលសាធារណៈ តាមរយៈការប្រើប្រាស់ផ្ទាំងបិទបាំង ឬការបំប្លែង។ វិធានការបំប្លែងនេះ មានដូចជាការបំប្លែងរូបភាព (ការធ្វើឱ្យរូបភាពសាក្សីមើលមិនស្គាល់នៅលើអេក្រង់ទាំងអស់ លើកលែងតែចៅក្រមជំនុំជម្រះ) និង/ឬ បំប្លែងសំឡេងសាក្សី (ការបំប្លែងសំឡេងនៅតាមប្រព័ន្ធសំឡេងទាំងអស់ចេញទៅខាងក្រៅសាលសវនាការ)។ ជាងនេះទៀត អ្នកបច្ចេកទេសសោតទស្សន៍ ក្នុងពេលណាក៏ដោយមិនអាចផ្តោតកាមេរ៉ាលើអេក្រង់ក្នុងសាលសវនាការ ដែលអាចបង្ហាញរូបភាពមិនបំប្លែងរបស់សាក្សីបានទេ ទោះតាមរយៈការថតពីចម្ងាយ ឬការថតជិតក្តី (ឧទាហរណ៍ លើអេក្រង់របស់ចៅក្រម)។ ជាចុងក្រោយ សាលសវនាការត្រូវបានរៀបចំផ្នែករូបវន្ត តាមរបៀបមួយដែលអាចធានាដល់ការការពារអត្តសញ្ញាណរបស់សាក្សីពីសាលសាធារណៈ (*ពោលគឺ* មានបំពាក់វាំងននៅក្នុងសាលសវនាការ និងមានរបាំងការពារ)។

វគ្គតុលាការនីមួយៗត្រូវបានថតចម្លងទុកក្នុង DVD ចំនួនពីរ៖ DVD មួយមានវីដេអូពេញជាភាសាខ្មែរ និងមានប៉ុស្តិ៍សំឡេងភាសាដើមរបស់អ្នកនិយាយ ហើយ DVD មួយទៀត មានការថតចម្លងវីដេអូពេញអមដោយប៉ុស្តិ៍សំឡេងជាភាសាអង់គ្លេស និងបារាំង។ ប្រសិនបើអង្គជំនុំជម្រះចេញដីកាបង្គាប់ឱ្យដាក់បង្ហាញ នោះសាធារណជនអាចចូលប្រើប្រាស់ការថតចម្លងពេញបាន។ ទោះជាយ៉ាងណា ប្រសិនបើបន្ទាប់

[773] វិធានផ្ទៃក្នុង វិធាន ៩៧(៤)។

ពីការពិនិត្យខ្សែអាត់ដើម អង្គជំនុំជម្រះចេញដីកាបង្គាប់ឱ្យធ្វើការកោសលុប នោះអង្គភាពសោតទស្សន៍ត្រូវដកសម្ភារៈទាំងអស់ដែលមាននៅក្នុងដីកាបង្គាប់ឱ្យធ្វើការកោសលុបនោះ។

### ៤.៧.១.៦. អង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង

យោងតាមកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា រាជរដ្ឋាភិបាលទទួលខុសត្រូវលើការឃុំខ្លួនចុងចោទនៅ អ.វ.ត.ក. ដោយភាគីទាំងពីរ អ.ស.ប. និងរាជរដ្ឋាភិបាលទទួលខុសត្រូវធានាថា បន្ទប់ឃុំខ្លួនមានសុវត្ថិភាព និងសន្តិសុខ សម្រាប់ដាក់ជនជាប់ចោទ[774]។ ក្នុងន័យនេះ អង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំង ទទួលខុសត្រូវលើការសម្របសម្រួល និងការទំនាក់ទំនងរវាង អ.វ.ត.ក. និង ប្រធានមន្ទីរឃុំឃាំង ដែលបានដំណើរការក្រោមការគាំទ្រពីអគ្គនាយកដ្ឋានពន្ធនាគារ របស់ក្រសួងមហាផ្ទៃ។ អង្គភាពនេះក៏សម្របសម្រួលជាមួយទីភ្នាក់ងារ អាជ្ញាធរ និងអង្គការជាតិ និងអន្តរជាតិផ្សេងទៀត ដែលទទួលបានការអនុញ្ញាតផងដែរ។ អង្គភាពទំនាក់ទំនងមន្ទីរឃុំឃាំងបានធានាថា បញ្ហាណាក៏ដោយដែលទាក់ទងទៅនឹងសុខុមាលភាព សុខភាព និងលក្ខខណ្ឌនៃការឃុំខ្លួនរបស់អ្នកជាប់ឃុំ ត្រូវបានរាយការណ៍ទាន់ពេលវេលា និងធានាបានថាមានការចាត់វិធានការចាំបាច់និងសមស្រប។

ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល បានធ្វើការជាមួយអាជ្ញាធរកម្ពុជា ដើម្បីធានាថាការិយាល័យរដ្ឋបាល និងបុគ្គលិករបស់ខ្លួន ទទួលបានការជូនដំណឹងត្រឹមត្រូវអំពីលក្ខខណ្ឌនៃការឃុំខ្លួនដែល "គោរពតាមច្បាប់កម្ពុជា និងបទដ្ឋាននៃអប្បបរិមានៃបទវិន័យសម្រាប់គ្រប់គ្រងជនជាប់ឃុំ និងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការគាំពារដល់ទណ្ឌិត"[775]។

វិធានស្តីពីមន្ទីរឃុំឃាំងចែងអំពីការគ្រប់គ្រងរដ្ឋបាលមន្ទីរឃុំឃាំង ក៏ដូចជាសិទ្ធិ និងនីតិវិធីទាំងអស់ទាក់ទងនឹងការឃុំខ្លួនចុងចោទ[776]។ ពួកវាផ្តល់វិធានលម្អិតអំពីការទទួលអ្នកជាប់ឃុំ នឹងការបំបែកអ្នកជាប់ឃុំ ការសួរសុខទុក្ខ ឯកសណ្ឋាន និងឧបករណ៍ក្នុងបន្ទប់ឃុំខ្លួន ការផ្តល់អាហារ ការប្រតិបត្តិសាសនា ការថែទាំសុខភាព ការហៅទូរស័ព្ទ សំណើសុំ និងបណ្តឹង ទ្រព្យសម្បត្តិរបស់អ្នកជាប់ឃុំ ករណីស្លាប់ក្នុងមន្ទីរឃុំឃាំង នីតិវិធីបន្ទាន់ និងការរាយការណ៍អំពីឧប្បត្តិហេតុ ការប្រើប្រាស់កម្លាំងដោយអ្នកយាម និងវិធីសាស្ត្រទប់ទល់ ការផ្លាស់ទីអ្នកជាប់ឃុំ និងការនាំខ្លួនទៅកាន់អាគារតុលាការ ការផ្ទេរអ្នកជាប់ឃុំទៅមន្ទីរឃុំឃាំងផ្សេងទៀត វិន័យរបស់អ្នកយាម សន្តិសុខ អធិការកិច្ច និងបញ្ហាសារព័ត៌មាន[777]។

ជនសង្ស័យ ជនជាប់ចោទ ឬ អ្នកជាប់ឃុំ ត្រូវបានបញ្ជូនមកកាន់មន្ទីរឃុំឃាំង អ.វ.ត.ក. នៅពេលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនដោយ ក.ស.ព., ក.ស.ច.ស. ឬ អង្គជំនុំជម្រះ ឬដីកាបង្គាប់ឱ្យឃុំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួន ចេញដោយ ក.ស.ច.ស. ឬ អង្គជំនុំជម្រះ[778]។ ព័ត៌មានអំពីអ្នកជាប់ឃុំ និងពេលវេលារបស់ពួកគេនៅមន្ទីរឃុំឃាំង ត្រូវបានកត់ត្រាក្នុងឯកសារផ្ទាល់ខ្លួន និងឯកសារពេទ្យ[779] ដែលត្រូវបានរក្សាទុកនៅទីតាំងមានសុវត្ថិភាព នៅក្នុងមន្ទីរឃុំឃាំងនោះ[780]។ ច្បាប់ចម្លងនៃឯកសារទាំងនេះត្រូវបានបញ្ជូនទៅប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល នៅពេលដែលមានការដោះលែងអ្នកជាប់ឃុំ ឬមរណភាពរបស់អ្នកជាប់ឃុំ ចំណែកច្បាប់ដើមត្រូវបញ្ជូនទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ[781]។

ក្នុងអំឡុងពេលឃុំខ្លួននៅមន្ទីរឃុំឃាំង អ្នកជាប់ឃុំបានទទួលអត្ថប្រយោជន៍ពីសិទ្ធិជាក់លាក់មួយចំនួន ដូចជាការរក្សាទុកទ្រព្យសម្បត្តិផ្ទាល់ខ្លួន (ក្រោយពីឯកភាពពីប្រធានមន្ទីរឃុំឃាំង)[782] ការហៅទូរស័ព្ទ

---

[774] កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាព មាត្រា ៩(២)។
[775] វិធានផ្ទៃក្នុង វិធាន ១០(៣)។
[776] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង។
[777] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២-៣០។ ទោះជាយ៉ាងណា វិធាន ១ ចែងថា ការអនុវត្តន៍វិធានទាំងនេះទៅលើរឿងក្តីនីមួយៗ អាចប្រែប្រួលដោយសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះនៃ អ.វ.ត.ក.។
[778] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២(១)។
[779] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ៥។
[780] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ៥(៣)។
[781] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ៥(៣)។
[782] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១៥(១)។

និងការទទួលទូរសព្ទពីបុគ្គលដែលទទួលបានការអនុញ្ញាតជាមុន ដោយមិនមានតាមដាន និងការបញ្ជូន និងការទទួលសំបុត្រ នឹងកញ្ចប់ឥវ៉ាន់[783]។ ទោះជាយ៉ាងណា សិទ្ធិក្រោយនេះអនុវត្តក្រោមការត្រួតពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះពាក់ព័ន្ធ ដែលអាចបើកសំបុត្រ ឬកញ្ចប់ដែលបញ្ជូនចេញ ឬដែលបានទទួលនោះមើល នៅចំពោះមុខវត្តមានរបស់ជនជាប់ឃុំ ដោយត្រួតពិនិត្យខ្លឹមសាររបស់វា និងសម្រេចថាតើអ្នកជាប់ឃុំនោះត្រូវបានអនុញ្ញាតឱ្យទទួលវាឬអត់ ដោយយោងទៅលើភាពចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់ល្អនៅមន្ទីរឃុំឃាំង[784]។ អ្នកជាប់ឃុំមិនអាចប្រើប្រាស់ភាសាហិង្សានៅក្នុងការឆ្លើយឆ្លងរបស់ខ្លួនទេ[785]។

អ្នកជាប់ឃុំបានអនុវត្តតាមទម្លាប់តឹងរ៉ឹង (តាមលក្ខខណ្ឌសុខភាពណាមួយ) និងបានធ្វើលំហាត់ប្រាណពីរម៉ោងជាអប្បបរមាក្នុងមួយថ្ងៃ[786]។ លើសពីនេះ កម្រិតអាហារូបត្ថម្ភនៃអាហាររបស់ពួកគេត្រូវបានគ្រប់គ្រងយ៉ាងតឹងរ៉ឹង[787]។ អ្នកជាប់ឃុំមានសិទ្ធិប្រតិបត្តិសាសនារបស់ពួកគេ រួមទាំងប្រតិបត្តិជាសមូហភាពជាមួយអ្នកជាប់ឃុំដទៃទៀត[788] នឹងអាចទទួលការសួរសុខទុក្ខពីតំណាងសាសនា[789]។

ប្រសិនបើអ្នកជាប់ឃុំបានរំលោភរបបវិន័យមន្ទីរឃុំឃាំង (ឧទាហរណ៍ ដោយការលេងល្បែងទទួលទានស្រា រក្សាទុកកាំភ្លើង មិនគោរពបទបញ្ជា ឬ វាយប្រហារ ឬបង្ករបួសស្នាមដល់អ្នកដទៃ[790]) ពួកគេត្រូវទទួលរងវិធានការវិន័យ[791]។ ប្រធានមន្ទីរឃុំឃាំងអាចចេញទណ្ឌកម្មវិន័យដូចខាងក្រោម ដាច់ដោយឡែកពីគ្នា ឬរួមបញ្ចូលគ្នា៖ វគ្គប្រឹក្សាយោបល់ ការព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ការបង្ខាំងអ្នកជាប់ឃុំនៅក្នុងបន្ទប់របស់ពួកគេរយៈពេលបីថ្ងៃ ដោយទទួលបានខ្យល់អាកាសខាងក្រៅក្រោមការត្រួតពិនិត្យរយៈពេលមួយម៉ោងក្នុងមួយថ្ងៃ ការរឹបអូសវត្ថុល្មើស ការដកសិទ្ធិ ឬកាត់បន្ថយសិទ្ធិ ឬការបដិសេធការចូលសួរសុខទុក្ខ ឬការទទួលឬផ្ញើសំបុត្រ និងកញ្ចប់ឥវ៉ាន់ សម្រាប់រយៈពេលអតិបរមាពីរសប្តាហ៍ (លើកលែងតែសម្រាប់ការទំនាក់ទំនងជាមួយមេធាវី)[792]។ ជាទូទៅ ប្រធានមន្ទីរឃុំឃាំងមិនអាចដាក់ទណ្ឌកម្មជាសហមូហភាព ឬដាក់ខ្នោះជើងអ្នកជាប់ឃុំ ដាក់ឃុំក្នុងបន្ទប់ដាច់ដោយឡែក កាន់បន្ថយរបបអាហារ ឬការប្រព្រឹត្តបែបឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកណាមួយ ជាទម្រង់នៃការដាក់វិន័យនោះទេ[793]។ ប្រសិនបើប្រធានមន្ទីរឃុំឃាំង បានទទួលរបាយការណ៍អំពីការរំលោភធ្ងន់ធ្ងរលើសន្តិសុខ ឬការចោទប្រកាន់អំពីបទល្មើស ដែលបានប្រព្រឹត្តឡើងដោយអ្នកជាប់ឃុំនោះ បញ្ហានេះត្រូវបញ្ជូនទៅអគ្គនាយកដ្ឋានពន្ធនាគារសម្រាប់ចាត់វិធានការបន្ត[794]។

ដើម្បីធានាសុវត្ថិភាព និងសន្តិសុខនៅមន្ទីរឃុំឃាំង អ.វ.ត.ក. អ្នកជាប់ឃុំត្រូវឆែកឆេរក្នុងពេលមួយចំនួន ដូចជា៖ ពេលចូលមកដល់ នៅពេលផ្លាស់ពីផ្នែកនៃអាគារមួយ ទៅផ្នែកនៃអាគារមួយទៀត ក្រោយពេលសួរសុខទុក្ខ ក្រោយពេលចាកចេញ ឬត្រឡប់ទៅមន្ទីរឃុំឃាំងវិញ នៅពេលអ្នកយាមមានមូលហេតុសង្ស័យថាអ្នកជាប់ឃុំមានកាន់កាប់របស់មិនត្រូវបានអនុញ្ញាត និងនៅពេលមានបញ្ជាពីប្រធានផ្នែក

783 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១៤(១), ៣០(២), ៣០(៧)។
784 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១៤(១), ១៤(៤)។
785 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១៤(៤)។
786 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៧។
787 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន៧។ ជាពិសេស អ្នកជាប់ឃុំត្រូវតែទទួលបានទឹកស្អាតផឹក នៅគ្រប់ពេលទាំងអស់ និងទទួលបានអាហារដែលមានធាតុផ្សំអប្បបរមាខាងក្រោម៖ បាយ៖ ៦០០ ក្រាម, ត្រី/សាច់ស្រស់ ឬប្រឡាក់៖ ១៥០ ក្រាម, បន្លែ ៖ ១៥០ ក្រាម, ប្រេងចម្អិន៖ ១០ ម.ល, អំបិល ឬទឹកត្រី៖ ១០ ក្រាម, គ្រឿងសម្ល៖ ២០ ក្រាម។
788 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ៨(២)។
789 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ៨(៤)។
790 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១០(៨)។
791 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១០(១)។
792 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១០(៥)។
793 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១០(២)។
794 វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១០(៣)។

មន្ទីរឃុំឃាំង[795]។ ទីកន្លែងស្នាក់នៅនៅកន្លែងឃុំខ្លួនក៏ត្រូវបានឆែកឆេរផងដែរ យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍[796]។

ការប្រើប្រាស់កម្លាំងណាមួយដោយអ្នកយាមមន្ទីរឃុំឃាំង ត្រូវមានភាពសមហេតុផល និងចាំបាច់ក្នុងកាលៈទេសៈទាំងនោះ និងត្រូវបានអនុញ្ញាតតែក្នុងករណីដែលមិនមានមធ្យោបាយគ្រប់គ្រងផ្សេងប៉ុណ្ណោះ[797]។ ការប្រើប្រាស់កម្លាំងមិនអាចធ្វើឡើងតាមទំនើងចិត្ត ឬដោយការរំលោភបំពានឡើយ[798]។ ស្ថិតក្រោមការកំហិតនេះ គេអាចប្រើកម្លាំងដើម្បីបង្ខំឱ្យអ្នកជាប់ឃុំគោរពតាមបទបញ្ជាចាំបាច់ រារាំងការគំរាមកំហែងដល់សុវត្ថិភាព ឬសុខុមាលភាពរបស់បុគ្គលម្នាក់ផ្សេងទៀត បំបែកមនុស្សក្នុងពេលឈ្លោះគ្នា ការពារខ្លួន ឬការពារអ្នកដទៃ ឬបង្ក្រាបអ្នកជាប់ឃុំដែលមិនស្តាប់បង្គាប់[799]។ អ្នកយាមមន្ទីរឃុំឃាំងបានទទួលការបណ្តុះបណ្តាលជាប្រចាំស្តីពីការប្រើប្រាស់កម្លាំង ហើយការប្រើប្រាស់កម្លាំងណាមួយ ត្រូវបានរាយការណ៍ទៅកាន់ប្រធានមន្ទីរឃុំឃាំង[800]។ ការប្រើប្រាស់ខ្នោះដៃលើអ្នកជាប់ឃុំត្រូវដាក់កម្រិតផងដែរ[801]។

ចៅក្រម និងសហព្រះរាជអាជ្ញា អ.វ.ត.ក. អាចពិនិត្យមើលមន្ទីរឃុំឃាំង ក៏ដូចជាបុគ្គល ឬអង្គការជាក់លាក់ផ្សេងទៀតផងដែរ[802]។ ឧទាហរណ៍ គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម មានសិទ្ធិធ្វើអធិការកិច្ចមន្ទីរឃុំឃាំង ហើយអធិការកិច្ចរបស់ខ្លួនត្រូវបានរៀបចំឡើងផ្ទាល់ ដោយប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ក្រោមការពិគ្រោះយោបល់ជាមួយប្រធានមន្ទីរឃុំឃាំង[803]។ បុគ្គលផ្សេងទៀត ដែលអាចធ្វើអធិការកិច្ចមន្ទីរឃុំឃាំងបាន រួមមាន តំណាងរដ្ឋសភា ព្រឹទ្ធសភា ព្រះមហាក្សត្រ ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និង ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ.ស.ប.[804] ក៏ដូចជា អង្គការក្រៅរដ្ឋាភិបាលបន្ទាប់ពីមានសំណើជាលាយលក្ខណ៍អក្សរ និងការអនុញ្ញាតជាមុន[805]។

ការផ្តល់បទសម្ភាសន៍របស់អ្នកជាប់ឃុំជាមួយប្រព័ន្ធផ្សព្វផ្សាយ ត្រូវសុំការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត ឬដោយអង្គជំនុំជម្រះ ដែលអាចកំណត់លក្ខខណ្ឌណាមួយ (ឧទាហរណ៍ ទាក់ទងនឹងបុគ្គលដែលអាចសម្ភាស និងការប្រើប្រាស់ឧបករណ៍ជាក់លាក់) និងអាចធ្វើឡើងតែក្រោយពេលអ្នកជាប់ឃុំមានឱកាសពិគ្រោះយោបល់ជាមួយក្រុមមេធាវីការពារក្តីរបស់ខ្លួនប៉ុណ្ណោះ ប្រសិនបើក្រុមមេធាវីការពារក្តីមិនមានវត្តមាននៅក្នុងពេលសម្ភាសន៍ទៃនោះ[806]។

ការដោះលែងអ្នកជាប់ឃុំត្រូវបានព្យាករណ៍ទុកតែក្នុងករណីមានកម្រិតមួយចំនួនប៉ុណ្ណោះ រួមមាន នៅពេលដែលអ្នកជាប់ឃុំទទួលបានការអនុញ្ញាតឱ្យនៅក្រៅឃុំ ការលើកលែងទោស ការដោះលែងបណ្តោះអាសន្ន នៅពេលដែលរឿងក្តីរបស់ខ្លួនត្រូវបានលើកលែងចោទប្រកាន់ ឬនៅពេលដែលពួកគេត្រូវបានរកឃើញថាគ្មានពិរុទ្ធភាព[807]។ ប្រធានមន្ទីរឃុំឃាំងធ្វើការដោះលែងណាមួយ បន្ទាប់ពីមានដីកាបង្គាប់ពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ និងបន្ទាប់ពីមានការបញ្ជាក់ពីប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល[808]។

---

[795] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១៨(៥)។
[796] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ១៨(៩)។
[797] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន២០(១), (៣)។
[798] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន២០(៦)។
[799] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២០(២)។
[800] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន២០(៧), (៨)។
[801] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៣។
[802] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៦(១)(១)។
[803] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៦(១)(១), ២៦(៤)(៣)។
[804] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៦(១)(១)។
[805] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៦(៤)(១)-(២)។
[806] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៨(២)-(៣)។
[807] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៥(១)។
[808] វិធានស្តីពីការគ្រប់គ្រងមន្ទីរឃុំឃាំង វិធាន ២៥(១)-(២)។

**ការឃុំខ្លួនជនជាប់ចោទនៅ អ.វ.ត.ក.**

| | |
|---|---|
| **កាំង ហ្កេកអ៊ាវ (ហៅ ឌុច)** | **ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧-ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣** (៥ឆ្នាំ ១០ ខែ) បានផ្ទេរទៅពន្ធនាគារខេត្តកណ្តាល ដើម្បីអនុវត្តទោសជាប់ពន្ធនាគារមួយជីវិតដែលនៅសល់[809]។ |
| **អៀង ធីរិទ្ធ** | **ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧-ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២** (៤ឆ្នាំ ១០ ខែ) ត្រូវបានដោះលែងក្រោមការត្រួតពិនិត្យដោយតុលាការ បន្ទាប់ពីរកឃើញថាមិនមានសមត្ថភាពក្នុងការចូលរួមសវនាការ។[810] |
| **អៀង សារី** | **ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧-ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣** (៥ឆ្នាំ ៤ខែ) ទទួលមរណភាពនៅមន្ទីរពេទ្យ ខណៈពេលឃុំខ្លួនបណ្តោះអាសន្ន[811]។ |
| **នួន ជា** | **ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧-ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩** (១១ឆ្នាំ ៨ខែ) ទទួលមរណភាពនៅមន្ទីរពេទ្យ ខណៈពេលឃុំខ្លួន[812]។ |
| **ខៀវ សំផន** | **ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៧-ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣** (១៥ឆ្នាំ ២ ខែ) ផ្ទេរទៅពន្ធនាគារខេត្តកណ្តាល ដើម្បីអនុវត្តទោសជាប់ពន្ធនាគារមួយជីវិតដែលនៅសល់[813]។ |

មន្ទីរឃុំឃាំងត្រូវនៅទំនេរនៅខែកុម្ភៈ ឆ្នាំ២០២៣ បន្ទាប់ពីការផ្ទេរទណ្ឌិតចុងក្រោយ។

### ៤.៧.២. ផ្នែកកិច្ចការសាធារណៈ

ផ្នែកកិច្ចការសាធារណៈ ទទួលខុសត្រូវលើការផ្សព្វផ្សាយព័ត៌មានទៅកាន់សាធារណជន អំពីប្រតិបត្តិការរបស់ អ.វ.ត.ក.[814] ក៏ដូចជារឿងក្តីនានាដែលស្ថិតក្រោមការស៊ើបអង្កេតដោយតុលាការ[815]។

ផ្នែកកិច្ចការសាធារណៈធ្វើសកម្មភាពផ្សព្វផ្សាយមួយចំនួន ដែលមានគោលបំណងផ្តោតលើការជូនដំណឹងដល់ប្រជាជនកម្ពុជា អំពីការងាររបស់ អ.វ.ត.ក. និងដំណើរការជំនុំជម្រះ ដើម្បីបង្កើនការយល់ដឹង និងការចូលរួមរបស់ពួកគេក្នុងការងាររបស់ អ.វ.ត.ក.។ ការផ្សព្វផ្សាយបានធ្វើឡើងក្នុងរូបភាពជាច្រើន ដូចជា តាមរយៈការបោះពុម្ពផ្សាយ វេទិកាសាធារណៈ សិក្ខាសាលា និងសន្និសីទ គេហទំព័រ អ.វ.ត.ក. កម្មវិធីវិទ្យុប្រចាំសប្តាហ៍ និងកម្មវិធីទូរទស្សន៍។ បន្ថែមលើការរៀបចំសកម្មភាពផ្សព្វផ្សាយផ្ទាល់ខ្លួន ផ្នែកកិច្ចការសាធារណៈបានចាប់ដៃគូជាមួយអង្គការផ្សេងទៀត (អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ រដ្ឋាភិបា

[809] សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ផ្នែកសម្រេចសេចក្តី។ សំណុំរឿង ០០១ សំណើសុំអនុវត្តទោស ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ឯកសារ F29 ដែល ក.ស.ព. បានស្នើសុំអគ្គនាយកដ្ឋានពន្ធនាគារ ឯកភាពលើទីតាំងសមស្របសម្រាប់ឃុំខ្លួន ឌុច សម្រាប់រយៈពេលអនុវត្តទោសសេសសល់របស់គាត់។

[810] សំណុំរឿង ០០២ សេចក្តីសម្រេចឃាត់ខ្លួន អៀង ធីរិទ្ធ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C15។ សំណុំរឿង ០០២ សេចក្តីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E138/1/10។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E138/1/10/1/5/7។

[811] សំណុំរឿង ០០២ សេចក្តីសម្រេចឃុំខ្លួន អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C22។ សំណុំរឿង ០០២ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ឯកសារ E270/1។

[812] សំណុំរឿង ០០២ សេចក្តីសម្រេចឃុំខ្លួន នួន ជា បណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ C/11។ សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F46/3។

[813] សេចក្តីសម្រេចឃុំខ្លួន ខៀវ សំផន បណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C26។ សំណុំរឿង ០០២/០២ សំណើសុំផ្ទេរទណ្ឌិត ខៀវ សំផន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៣ ឯកសារ F82។ សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញា ស្តីពីផែនការនៃលក្ខខណ្ឌឃុំខ្លួន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F77/1/1។

[814] វិធានផ្ទៃក្នុង វិធាន ៩(៤)។

[815] វិធានផ្ទៃក្នុង វិធាន ៩(៤), ៥៦(២)(ក)។

លថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ) ដើម្បីជួយសម្រួលដល់ការផ្សព្វផ្សាយសម្ភារៈអាន វីដេអូ កម្មវិធីវិទ្យុ និងទូរទស្សន៍។ ផ្នែកកិច្ចការសាធារណៈក៏ធ្វើសកម្មភាពផ្សព្វផ្សាយ ទាក់ទងនឹងជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ក្រោមការពិគ្រោះយោបល់ជាមួយផ្នែកគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី[816]។

តាមរយៈកម្មវិធីផ្សព្វផ្សាយជាច្រើនរបស់ខ្លួន ផ្នែកកិច្ចការសាធារណៈ បានផ្សព្វផ្សាយដល់ប្រជាជនចំនួនជាង ៦៤០.០០០ នាក់ ក្នុងអំឡុងពេលដំណាក់កាលតុលាការ។ ស្ថិតិមាននៅក្នុងឧបសម្ព័ន្ធ ៧។

ផ្នែកកិច្ចការសាធារណៈបានចែករំលែកព័ត៌មាន និងវឌ្ឍនភាពរបស់តុលាការ ដូចជា សេចក្ដីសម្រេច លិខិតុបករណ៍ច្បាប់ ឯកសារហិរញ្ញវត្ថុ របាយការណ៍ រូបថត និងជីវប្រវត្តិ ជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ និងសាធារណជន តាមរយៈគេហទំព័ររបស់ អ.វ.ត.ក.។ សេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍ត្រូវបានចែកចាយដោយសារអេឡិចត្រូនិក តាមរយៈបញ្ជីសារ ហើយក៏ត្រូវបានដាក់ផ្សាយនៅលើគេហទំព័រ និងសារព័ត៌មានសង្គមផងដែរ។ ផ្នែកកិច្ចការសាធារណៈ ក៏ធ្វើការជាអ្នកបញ្ជូនសំណើសម្ភាសន៍ជាមួយមន្ត្រីតុលាការ និងបុគ្គលិកការិយាល័យរដ្ឋបាល ផងដែរ។

កិច្ចដំណើរការនីតិវិធីតុលាការជាសាធារណៈនៅ អ.វ.ត.ក. បានផ្សព្វផ្សាយតាមទូរទស្សន៍កម្ពុជា។ វីដេអូអំពីសវនាការពីមុនៗ ក៏មាននៅលើគេហទំព័រ អ.វ.ត.ក. និង YouTube ផងដែរ។ រូបថត និង ព័ត៌មានផ្សេងទៀត ត្រូវបានផ្សព្វផ្សាយលើប្រព័ន្ធផ្សព្វផ្សាយសង្គម រួមមាន Facebook, Flicker, Instagram, Tik-Tok និង X (ពីមុនជា Twitter)។

### ៤.៧.៣. ផ្នែកសេវាកម្មទូទៅ

អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចែករំលែកការទទួលខុសត្រូវ និងភារកិច្ច ទាក់ទងទៅនឹងការផ្ដល់ និងការថែទាំបរិក្ខារ អគារ និងសេវាកម្មនៅ អ.វ.ត.ក. និងមានចែងនៅក្នុងកិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម[817]។ ការទទួលខុសត្រូវសំខាន់ៗមួយចំនួនក្រោមកិច្ចព្រមព្រៀងនេះ ស្ថិតក្រោមអាណត្តិរបស់ផ្នែកសេវាកម្មទូទៅ ដែលបានដំណើរការក្រោមការិយាល័យរដ្ឋបាល និងបានផ្ដល់ការគាំពារផ្នែករដ្ឋបាល និងភស្តុភារដល់ អ.វ.ត.ក.។

**ការទទួលខុសត្រូវសំខាន់ៗក្រោមកិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម**

| រាជរដ្ឋាភិបាលកម្ពុជា | អង្គការសហប្រជាជាតិ |
|---|---|
| • ថែទាំ ធ្វើការកែលម្អ និងផ្លាស់ប្ដូរអគារតាមការចាំបាច់ និងសមស្រប<br>• ធានាថាអគារត្រូវបានផ្គត់ផ្គង់ដោយឧបករណ៍ប្រើប្រាស់ និងសេវាកម្មចាំបាច់នៅគ្រប់ថ្ងៃ និងគ្រប់ពេលវេលា<br>• ធានាថាការងារចាំបាច់ទាំងអស់ត្រូវបានអនុវត្ត ហើយហេដ្ឋារចនាសម្ព័ន្ធទាំងអស់ត្រូវបានរៀបចំ និងរក្សាទុកនៅនឹងកន្លែងជាស្រេច សម្រាប់ទទួលឧបករណ៍ប្រើប្រាស់ និងសេវាកម្ម នឹងអាចរកបាននៅក្នុងអគារ។ | • ដំឡើងប្រព័ន្ធទូរគមនាគមន៍ និងអេឡិចត្រូនិក និងឧបករណ៍សុវត្ថិភាពក្នុងអគារ<br>• ទទួលខុសត្រូវលើការចំណាយលើការបង្កើត ថែទាំ និងប្រើប្រាស់ការតភ្ជាប់ជាមួយបណ្ដាញទូរគមនាគមន៍តាមដី និងតាមប្រព័ន្ធទូរសព្ទ |

[816] វិធានផ្ទៃក្នុង វិធាន ១២*ស្ទួន*(១)(i)។
[817] កិច្ចព្រមព្រៀងបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម។

| | |
|---|---|
| • រៀបចំឱ្យមានបរិក្ខារពេទ្យគ្រប់គ្រាន់នៅក្នុងអគារសម្រាប់ការសង្គ្រោះបឋម និងធានាឱ្យមានការចូលទៅកាន់មន្ទីរពេទ្យ និងបញ្ជូនចូលមន្ទីរពេទ្យភ្លាមៗ រួមទាំងការដឹកជញ្ជូននៅគ្រប់ថ្ងៃ និងគ្រប់ពេលវេលា។<br>• ផ្តល់ការដឹកជញ្ជូនគ្រប់គ្រាន់ទៅកាន់កន្លែងធ្វើការ និងចេញពីកន្លែងធ្វើការ សម្រាប់បុគ្គលិក និងសាធារណៈជន | |

## ៤.៧.៤. ផ្នែកសន្តិសុខ និងសុវត្ថិភាព

ផ្នែកសន្តិសុខ និងសុវត្ថិភាព ទទួលខុសត្រូវលើសុវត្ថិភាព និងសន្តិសុខនៅ អ.វ.ត.ក.។ នៅក្នុងផ្នែកសន្តិសុខ និងសុវត្ថិភាព រាជរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវជាចំបងលើសន្តិសុខខាងក្រៅបរិវេណ អ.វ.ត.ក. សុវត្ថិភាពបុគ្គលិករបស់ អ.វ.ត.ក. និងចុងចោទ និងការការពារផ្ទាល់សម្រាប់បុគ្គលិកជាតិសំខាន់ៗ[818]។ អ.ស.ប. ទទួលខុសត្រូវលើសន្តិសុខខាងក្នុងបរិវេណ អ.វ.ត.ក. (មកទល់ត្រឹមជញ្ជាំង និងរួមទាំងបរិវេណជញ្ជាំង) និងការការពារផ្ទាល់សម្រាប់បុគ្គលិកអន្តរជាតិសំខាន់ៗ[819]។ ភាគីទាំងពីរទទួលខុសត្រូវរួមលើការគ្រប់គ្រង និងដឹកនាំការរៀបចំសន្តិសុខនៅក្នុងសាលសវនាការ[820]។

**ការទទួលខុសត្រូវសំខាន់ៗក្រោមកិច្ចព្រមព្រៀងបន្ថែមលើសុវត្ថិភាព និងសន្តិសុខ**

| **រាជរដ្ឋាភិបាលកម្ពុជា** | **អង្គការសហប្រជាជាតិ** |
|---|---|
| • កំណត់ការទទួលខុសត្រូវរបស់ប្រធានសន្តិសុខជាតិ លើការការពារផ្ទាល់សម្រាប់មន្ត្រីកម្ពុជាសំខាន់ៗ ក៏ដូចជាលំនៅឋានរបស់ពួកគេ នៅពេលចាំបាច់<br>• ផ្តល់ការវាយតម្លៃអំពីស្ថានភាពសន្តិសុខក្នុងប្រទេសកម្ពុជា ការជូនដំណឹងអំពីការគំរាមកំហែងដែលអាចមាន ឬពិតប្រាកដទៅលើបុគ្គលសំខាន់ៗ<br>• ធានាឱ្យមានសេវាសង្គ្រោះបន្ទាន់<br>• ធានាសន្តិសុខរបស់ជនជាប់ចោទ<br>• ផ្តល់មន្ត្រីការពារផ្ទាល់បន្ថែមទៀតដើម្បីពង្រឹងការការពារមន្ត្រីអន្តរជាតិ បន្ទាប់ពីមានសំណើពីប្រធានសន្តិសុខអន្តរជាតិ | • កំណត់ការទទួលខុសត្រូវរបស់ប្រធានសន្តិសុខអន្តរជាតិ លើការការពារផ្ទាល់សម្រាប់មន្ត្រីតុលាការអន្តរជាតិសំខាន់ៗ<br>• បង្កើតគោលនយោបាយ និងនីតិវិធីសម្រាប់ដំណើរការប្រតិបត្តិការសន្តិសុខនៅក្នុងបរិវេណ អ.វ.ត.ក.<br>• ធ្វើការក្រោមការត្រួតពិនិត្យបច្ចេកទេស និងការណែនាំរបស់ UNDSS និងអ្នកសម្របសម្រួល អ.ស.ប. ប្រចាំនៅកម្ពុជា<br>• ផ្តល់ជូនមន្ត្រីសន្តិសុខព័ត៌មានម្នាក់ |

មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ គឺជាចំណុចទំនាក់ទំនងសំខាន់ សម្រាប់បញ្ហាសន្តិសុខ និងសុវត្ថិភាពទាំងអស់ដែលទាក់ទងនឹង អ.វ.ត.ក.។ មជ្ឈមណ្ឌលប្រតិបត្តិការសន្តិសុខ បានធ្វើសកម្មភាពសន្តិសុខជាប្រចាំនៅបរិវេណ អ.វ.ត.ក. ដូចជា ការត្រួតពិនិត្យភ្ញៀវចូល និងការចេញបណ្ណចំណត និងកូនសោការិយាល័យ។ វាក៏បានដំណើរការប្រព័ន្ធ CCTV និងប្រព័ន្ធសញ្ញាអាសន្នពេលមានអគ្គីភ័យ និងប្រព័ន្ធការពារអគ្គីភ័យ ហើយទទួលខុសត្រូវចំពោះការផ្តល់ជំនួយសុវត្ថិភាពសង្គ្រោះបន្ទាន់។

---

[818] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២៤។ កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាព មាត្រា ១(១)។

[819] កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាព មាត្រា ២(ក)(i) មាត្រា ២(ក)(i)-(ii), ៥(១)។

[820] កិច្ចព្រមព្រៀងបន្ថែមលើសន្តិសុខ និងសុវត្ថិភាព មាត្រា ៨(១)។

បុគ្គលិកផ្នែកសន្តិសុខ និងសុវត្ថិភាពបានចូលរួម និងបានធ្វើការបណ្តុះបណ្តាលជាប្រចាំ។ បន្ថែមលើការបណ្តុះបណ្តាលផ្នែកសន្តិសុខជាចាំបាច់របស់ខ្លួន ពួកគេក៏បានចូលរៀនវគ្គបណ្តុះបណ្តាលហ្វឹកហាត់ឡើងវិញជារៀងរាល់ឆ្នាំផងដែរ។ បុគ្គលិកផ្នែកសន្តិសុខ និងសុវត្ថិភាព បានផ្តល់ការបណ្តុះបណ្តាល ដល់បុគ្គលិក អ.វ.ត.ក. ផ្សេងទៀតផងដែរ ដូចជា វគ្គបណ្តុះបណ្តាលសង្គ្រោះបឋម សម្រាប់អ្នកគ្រប់គ្រងតាមអគារ និងតាមតំបន់ និងបានធ្វើលំហាត់ជម្លៀសចេញពីអគារជាប្រចាំ។

### ៤.៧.៥. ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង

ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង គាំទ្ររចនាសម្ព័ន្ធឌីជីថលរបស់ អ.វ.ត.ក. រួមមាន សំណុំរឿងតុលាការ ក៏ដូចជា ឧបករណ៍ទំនាក់ទំនង។ ផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង មានបួនផ្នែកសំខាន់ៗគឺ៖ (i) ផ្នែកសេវាប្រព័ន្ធ ទទួលខុសត្រូវលើការថែទាំបណ្តាញតាមផ្នែកឱ្យមានសុវត្ថិភាព ប្រព័ន្ធមូលដ្ឋានទិន្នន័យ និង ប្រព័ន្ធថតចម្លងទុក (backup) (ii) ផ្នែកសេវាទំនាក់ទំនង ទទួលខុសត្រូវលើការផ្សាយផ្ទាល់តាមផ្កាយរណប ការផ្តល់សក្ខីកម្មពីចម្ងាយ និងការទំនាក់ទំនងនៅនឹងកន្លែង (iii) ផ្នែកសេវាផ្តល់ព័ត៌មាននិងជំនួយដល់អ្នកប្រើប្រាស់កុំព្យូទ័រ ទទួលខុសត្រូវលើ ការជួយដោះស្រាយបញ្ហា និងការបែងចែកធនធាន និង (iv) ផ្នែកសេវាគ្រប់គ្រងទ្រព្យសម្បត្តិ ទទួលខុសត្រូវលើការថែរក្សាបញ្ជីសារពើភ័ណ្ឌ។

### ៤.៧.៦. អង្គភាពគាំពារប្រតិបត្តិការ

ដោយសារតែក្របខ័ណ្ឌរាយការណ៍ និងរដ្ឋបាលដាច់ដោយឡែករបស់ខ្លួន នៅក្នុងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ អង្គភាពគាំពារប្រតិបត្តិការរបស់ អ.វ.ត.ក. មានពីរផ្នែក គឺផ្នែកខាងជាតិ និងផ្នែកខាងអន្តរជាតិ។ ការទទួលខុសត្រូវរបស់ផ្នែកនីមួយៗមានរៀបរាប់ខាងក្រោម។

#### ៤.៧.៦.១. ផ្នែកថវិកា និងហិរញ្ញវត្ថុ

ទំនួលខុសត្រូវទូទៅនៃផ្នែកថវិកា និងហិរញ្ញវត្ថុសម្រាប់ភាគីនីមួយៗគឺផ្តល់ការគាំទ្រក្នុងការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ដែលរួមមានការរៀបចំថវិកា ការពិនិត្យឡើងវិញ ការព្យាករណ៍ និងការអនុវត្តក៏ដូចជាការវិភាគហិរញ្ញវត្ថុ និងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធានាបាននូវប្រតិបត្តិការរលូន។

ផ្នែកភាគីជាតិទទួលខុសត្រូវលើ (i) ការបង្កើត ការអនុវត្ត និងការកែប្រែសៀវភៅណែនាំនីតិវិធីហិរញ្ញវត្ថុ ឱ្យស្របជាមួយនឹងគម្រោងជំនួយផ្នែកហិរញ្ញវត្ថុពីខាងក្រៅ និងសៀវភៅណែនាំលទ្ធកម្ម ទំនិញ ការងារ និងសេវាកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា និងការបង្កើតប្រព័ន្ធគណនេយ្យតាមកុំព្យូទ័រ (ii) កំណត់តម្រូវការធនធានពីរឆ្នាំម្តង សម្រាប់របាយការណ៍រួមផ្ទៃក្នុង (iii) ការត្រួតពិនិត្យការចំណាយ និងការគ្រប់គ្រងលំហូរសាច់ប្រាក់ ដើម្បីធានាបាននូវការគោរពតាមថវិកាដែលបានអនុម័ត (iii) ធ្វើការទូទាត់ឱ្យឈ្នួល និងប្រាក់បំណាច់ និងអត្ថប្រយោជន៍របស់បុគ្គលិក និង (iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់អ្នកពាក់ព័ន្ធផ្ទៃក្នុង រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធខាងក្រៅ។

ផ្នែកភាគីអន្តរជាតិទទួលខុសត្រូវលើ (i) ការដឹកនាំការធ្វើរបាយការណ៍រួមអំពីថវិកា អ.វ.ត.ក. ការរៀបចំ និងការខិតខំប្រឹងប្រែងធ្វើការកែសម្រួលឱ្យត្រូវតាមគោលការណ៍ណែនាំរបស់ការិយាល័យផែនការកម្មវិធី ហិរញ្ញវត្ថុ និងថវិការបស់អង្គការសហប្រជាជាតិ ដើម្បីបង្ហាញទៅកាន់ស្ថាប័នគ្រប់គ្រងសំខាន់ៗ (ii) ការបង្កើតវិធាន និងនីតិវិធីប្រតិបត្តិស្តង់ដា ដែលស្របទៅនឹងបទប្បញ្ញត្តិ និងច្បាប់ហិរញ្ញវត្ថុ អ.ស.ប. (iii) ការត្រួតពិនិត្យការចំណាយ ដើម្បីធានាថា វាស្ថិតនៅក្នុងដែនកំណត់ដែលអនុញ្ញាត និង (iv) ធ្វើការយ៉ាងជិតស្និទ្ធជាមួយទីស្នាក់ការកណ្តាលរបស់ អ.ស.ប. ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាការការពារធនធាន ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍អនុវត្តថវិកា និងការបិទបញ្ជីចុងឆ្នាំ ស្របតាម IPSAS និងកិច្ចព្រមព្រៀងម្ចាស់ជំនួយ។

ផ្នែកភាគីអន្តរជាតិស្ថិតក្រោមការគ្រប់គ្រងហិរញ្ញវត្ថុរបស់ UNAKRT[821]។ UNAKRT ត្រូវបានផ្តល់មូលនិធិទាំងស្រុងតាមរយៈវិភាគទានស្ម័គ្រចិត្ត របស់រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ[822]។ វិភាគទានស្ម័គ្រចិត្ត មិនបានបំពេញគ្រប់គ្រាន់លើចំនួនសរុបនៃមូលនិធិដែលបានស្នើសុំ និងអនុម័តនៅក្នុងថវិកាប្រចាំឆ្នាំរបស់ UNAKRT ជានិច្ចនោះទេ[823]។ ការណ៍នេះបាននាំឱ្យ UNGA អនុញ្ញាតឱ្យ UNSG ផ្តល់មូលនិធិ ដែលត្រូវបានគេស្គាល់ថាជាប្រាក់ឧបត្ថម្ភធន ដើម្បីបំពេញបន្ថែមកង្វះខាតក្នុងវិភាគទានស្ម័គ្រចិត្ត ចាប់ពីឆ្នាំ២០១៥[824]។

ទំនាក់ទំនងម្ចាស់ជំនួយ និងការគ្រប់គ្រងមូលនិធិទំនុកចិត្តរបស់ UNAKRT ត្រូវបានចាត់ចែងដោយផ្នែកកិច្ចការសេដ្ឋកិច្ច និងសង្គមរបស់ អ.ស.ប. ("DESA") រហូតដល់ឆ្នាំ២០២៤។ អ្នកគ្រប់គ្រងមូលនិធិទំនុកចិត្ត បានបំពេញមុខងាររបស់អ្នកគ្រប់គ្រងមូលនិធិ និងគ្រប់គ្រងមូលនិធិដែលទទួលបាន និងចំណាយដោយ UNAKRT ។ UNAKRT បានពិគ្រោះជាមួយ DESA ក្នុងការរៀបចំថវិកាសម្រាប់រយៈពេលពីរឆ្នាំម្តងរបស់ខ្លួន[825]។

### ៤.៧.៦.២. ផ្នែកគ្រប់គ្រងធនធានមនុស្ស

ផ្នែកធនធានមនុស្សនៃភាគីជាតិនិងអន្តរជាតិ ទទួលខុសត្រូវលើការបំពេញមុខងារគ្រប់គ្រងធនធានមនុស្ស ដែលរួមមាន ការជ្រើសរើសបុគ្គលិក និងការជ្រើសរើសអ្នកធ្វើការដែលមិនមែនជាបុគ្គលិក កិច្ចសន្យាបុគ្គលិក ការគ្រប់គ្រងប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ ការគ្រប់គ្រងការអនុវត្តការងារ ការអភិវឌ្ឍន៍ផ្នែកវិជ្ជាជីវៈ និងគោលនយោបាយបុគ្គលិក តាមផ្នែកនៃការទទួលខុសត្រូវរៀងៗខ្លួន។ ភាគីជាតិទទួលខុសត្រូវលើការអនុវត្តមុខងារទាំងនេះតាមផ្ទៃក្នុង រួមទាំងការបង្កើត និងការធ្វើវិសោធនកម្មសៀវភៅណែនាំស្តីពីគោលនយោបាយ និងនីតិវិធីធនធានមនុស្ស ដែលស្របតាមគោលនយោបាយការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ផ្នែកធនធានមនុស្សរបស់ភាគីអន្តរជាតិ ត្រូវបានគ្រប់គ្រងនៅក្នុង UNAKRT រហូតដល់ឆ្នាំ២០១៧ នៅពេលដែលវាត្រូវបានផ្ទេរទៅឱ្យ គណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់ អ.ស.ប. សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (UN ESCAP) នៅទីក្រុងបាងកក។

### ៤.៧.៦.៣. អង្គភាពលទ្ធកម្ម

ការទទួលខុសត្រូវរបស់អង្គភាពលទ្ធកម្ម សម្រាប់ភាគីនីមួយៗគឺ ការទិញទំនិញ សេវាកម្ម ធ្វើការតាមផែនការលទ្ធកម្ម និងប្រកាន់ខ្ជាប់ទៅនឹងសៀវភៅណែនាំស្តីពីលទ្ធកម្មរៀងៗខ្លួន។ ភាគីជាតិទទួលខុសត្រូវលើការត្រួតពិនិត្យសកម្មភាពលទ្ធកម្មទាំងអស់ ស្របតាមសៀវភៅណែនាំស្តីពីលទ្ធកម្មរបស់រដ្ឋាភិបាលដែលបានបង្កើតឡើង ការចេញការបញ្ជាទិញ ទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ និងការគ្រប់គ្រងឯកសារ។ លទ្ធកម្មរបស់ភាគីអន្តរជាតិ ត្រូវបានគ្រប់គ្រងនៅក្នុង UNAKRT រហូតដល់ឆ្នាំ២០១៨ នៅពេលដែលវាត្រូវបានផ្ទេរទៅឱ្យ UN ESCAP។

## ៤.៨. ជំនួយអង្គការសហប្រជាជាតិសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម

UNAKRT គឺជាគម្រោងរបស់ អ.ស.ប. ដែលផ្តល់ជំនួយបច្ចេកទេសអន្តរជាតិទៅឱ្យ អ.វ.ត.ក. នៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងកិច្ចព្រមព្រៀងបន្ថែម។ ការ

---

[821] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៦-១៧។ ច្បាប់ អ.វ.ត.ក. មាត្រា ៤៤ថ្មី។
[822] UNGA, របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការជំនុំជម្រះក្តីខ្មែរក្រហម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ឯកសារ អ.ស.ប. លេខ A/57/769 កថាខណ្ឌ ៧២-៧៥។
[823] សូមមើល សំណុំរឿង ០០៤/០២ សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក. និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D349 កថាខណ្ឌ ១-២, ២៤-៣៣។
[824] សម្រាប់ សេចក្តីសម្រេចរបស់ UNGA លើសំណើសុំឧបត្ថម្ភធនក្នុងឆ្នាំទាំងនោះ សូមមើល ឧបសម្ព័ន្ធ ៦(គ)។
[825] សូមមើល សំណុំរឿង ០០៤/០២ មតិយោបល់របស់ការិយាល័យរដ្ឋបាល ស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក. និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៧ D349/3 កថាខណ្ឌ ២១។

ទទួលខុសត្រូវរបស់ អ.ស.ប. ចំពោះ អ.វ.ត.ក. តាមមាត្រា ១៧ នៃកិច្ចព្រមព្រៀងត្រូវបានធ្វើឡើងតាមរយៈមន្ត្រីសម្របសម្រួលម្នាក់[826] និងរួមមាន៖

(ក) ប្រាក់បៀវត្សរ៍របស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធានការិយាល័យរដ្ឋបាល និងបុគ្គលិកអន្តរជាតិផ្សេងទៀត

(ខ) ថ្លៃសេវាប្រើប្រាស់ និងសេវានានា តាមការព្រមព្រៀងដាច់ដោយឡែករវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា

(គ) ប្រាក់បៀវត្សរ៍មេធាវីការពារក្ដី

(ឃ) ការធ្វើដំណើររបស់សាក្សីក្នុងប្រទេសកម្ពុជា និងពីបរទេស

(ង) ការរៀបចំសុវត្ថិភាព និងសន្តិសុខ ដូចដែលបានព្រមព្រៀងដាច់ដោយឡែកពីគ្នារវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាល

(ច) ជំនួយមានកម្រិតផ្សេងទៀត តាមការចាំបាច់ ដើម្បីធានាឱ្យមានដំណើរការរលូននៃផ្នែកស៊ើបអង្កេត ផ្នែកចោទប្រកាន់ និងអង្គជំនុំជម្រះវិសាមញ្ញ។

ដើម្បីធានាថា កិច្ចដំណើរការនីតិវិធី អ.វ.ត.ក. ដំណើរការទៅមុខដោយរលូន រួមទាំងអំឡុងពេលមានបន្ទុកការងារខ្ពស់ក្នុងអង្គជំនុំជម្រះ និងការិយាល័យតុលាការ UNAKRT បានចុះកិច្ចសន្យាជាមួយបុគ្គលិកផ្សេងទៀត រួមទាំងទីប្រឹក្សា ដើម្បីគាំទ្រការងាររបស់ អ.វ.ត.ក រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ UNAKRT ក៏បានជួលបុគ្គលិកកម្ពុជាផងដែរ ដើម្បីគាំទ្រដល់ការដំណើរការផ្នែកតុលាការ និងខាងប្រតិបត្តិការ។

## ៥. សំណុំរឿង

### ៥.១. សំណុំរឿង ០០១

> “សហព្រះរាជអាជ្ញាមិនបានបំផ្លើសឡើយ នៅពេលដែលសហព្រះរាជអាជ្ញាបានសំដៅទៅលើមន្ទីរ ស-២១ ថាជា “ទីកន្លែងសម្លាប់មនុស្សដ៏ធំ ដោយមានការរៀបចំ” កាំង ហ្កេកអ៊ាវ បានបញ្ជា និងប្រតិបត្តិការទីកន្លែងសម្លាប់មនុស្សនេះអស់រយៈពេលជាងបីឆ្នាំ។ កាំង ហ្កេកអ៊ាវ បានសម្លាប់មនុស្សអស់យ៉ាងតិច ១២.២៧២ (ដប់ពីរពាន់ពីររយចិតសិបពីរ) នាក់ ដោយគ្មានធម៌មេត្តា ដែលក្នុងនោះរួមមានស្ត្រី និងកុមារផងដែរ”_ អង្គជំនុំជម្រះតុលាការកំពូល[827]

#### ៥.១.១. ទិដ្ឋភាពទូទៅអំពីជនជាប់ចោទ

កាំង ហ្កេកអ៊ាវ ហៅ ឌុច (១៩៤២-២០២០) កើតនៅភូមិពៅវើយ ស្រុកស្ទោង ខេត្តកំពង់ធំ[828] ត្រូវបានចោទប្រកាន់ពីបទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុង

---

[826] បុគ្គលិក អ.ស.ប. កម្រិតប្រធាន ដែលតាមការអនុវត្តជាក់ស្ដែង ក៏ត្រូវបានតែងតាំងជាអនុប្រធានរដ្ឋបាលនៃ អ.វ.ត.ក. ផងដែរ។

[827] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៨០។ ភ័ស្តុតាងក្នុងសំណុំរឿង ០០១ ភាគច្រើនមិនត្រូវបានជំទាស់ដោយ កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ទេ។ ផ្ទុយទៅវិញ សំណុំរឿង ០០២/០២ ត្រូវបានជំទាស់ដោយ ខៀវ សំផន និង នួន ជា ហើយអង្គជំនុំជម្រះសាលាដំបូងបានធ្វើការពិនិត្យមើលភ័ស្តុតាងដោយខ្លួនឯង។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា “យ៉ាងហោចណាស់អ្នកជាប់ឃុំចំនួន ១១.៧៤២ នាក់ ត្រូវបានសម្លាប់ក្នុងបរិវេណ ឬជុំវិញបរិវេណមន្ទីរសន្តិសុខ ស-២១” ប៉ុន្តែថា “នេះគឺជាការរកឃើញកម្រិតទាបបំផុត ដែលមិនរាប់បញ្ចូលឯកសារទាំងអស់ដែលបានបង្កើតឡើងក្នុងអំឡុងពេលមន្ទីរ ស-២១ ប្រតិបត្តិការឡើយ”។ សូមមើល សំណុំរឿង០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ជំពូក ១២.២.២២។

[828] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ១។

ហ្សីណែរ សម្រាប់តួនាទីរបស់គាត់នៅ ស-២១ ដែលជាមន្ទីរសន្តិសុខមួយ នៅទីក្រុងភ្នំពេញ មានភារកិច្ចសួរចម្លើយ និងសម្លាប់អ្នកដែលគេសន្មតថាប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក.)។ ស-២១ រួមមានមន្ទីរឃុំឃាំង និងតំបន់ជុំវិញ ព្រមទាំងកន្លែងសម្លាប់មនុស្ស នឹងជំរំអប់រំកសាងបឹងជើងឯក និង ព្រៃ ស (ស-២៤)[829]។

ឌុច គឺជាប្រធានមន្ទីរ ម-១៣ (មន្ទីរសន្តិសុខដែលមានទីតាំងនៅ អមលាំង ក្នុងខេត្តកំពង់ស្ពឺ) ចាប់ពីខែកក្កដា ឆ្នាំ១៩៧១ ដល់ខែមករា ឆ្នាំ១៩៧៥[830] ជាអនុប្រធានមន្ទីរសន្តិសុខ ស-២១ ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ដល់ខែមីនា ឆ្នាំ១៩៧៦ និងជាប្រធាន ស-២១ ពីខែមីនា ឆ្នាំ១៩៧៦ រហូតដល់ពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[831]។

### ៥.១.២. ការស៊ើបអង្កេតបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ សហព្រះរាជអាជ្ញាបានផ្តួចផ្តើមការស៊ើបអង្កេតបឋម ទៅលើឧក្រិដ្ឋកម្មនានា ដែលអាចត្រូវបានប្រព្រឹត្តឡើងដោយមេដឹកនាំជាន់ខ្ពស់ នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដែលបានប្រព្រឹត្តឡើងរវាងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[832]។ ក្រោយការបញ្ចប់ការស៊ើបអង្កេតបឋម នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា បានដាក់ដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅកាន់សហចៅក្រមស៊ើបអង្កេត ដែលបានបើកកិច្ចស៊ើបសួរប្រឆាំងនឹង នួន ជា, អៀង សារី , អៀង ធីរិទ្ធ, ខៀវ សំផន និង ឌុច[833]។ រឿងក្តីប្រឆាំងនឹង ឌុច ទាក់ទងនឹង “អំពើដែលបានប្រព្រឹត្តឡើងនៅក្នុងក្របខ័ណ្ឌ ស-២១” ក្រោយមកត្រូវបានបំបែក ហើយបានក្លាយជាសំណុំរឿង ០០១ ចំណែកឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថា បានប្រព្រឹត្តឡើងដោយជនសង្ស័យទាំងប្រាំរូប នៅក្នុងបរិបទទូលំទូលាយជាងនេះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានក្លាយជាសំណុំរឿង ០០២។ សេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ បានធ្វើឡើង ដោយសារតែអង្គហេតុដែលបានចោទប្រកាន់ជាក់លាក់ តម្រូវឱ្យមានការស៊ើបអង្កេតលម្អិតបន្ថែមទៀត ខណៈដែលអង្គហេតុប្រឆាំងនឹង ឌុច ដែលជាប្រធាន ស-២១ មិនមានភាពស្មុគស្មាញ និងមិនត្រូវបានជំទាស់ដោយ ឌុច[834]។

### ៥.១.៣. ការស៊ើបអង្កេតដោយតុលាការ

#### ៥.១.៣.១. ការឃុំខ្លួន និងការចោទប្រកាន់

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត បានចេញដីកាបង្គាប់ឱ្យនាំខ្លួន ឌុច[835] ហើយ ឌុច បានបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមនៅថ្ងៃបន្ទាប់។ នៅពេលបង្ហាញខ្លួននេះ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹង ឌុច ថា គាត់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានចេញសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា ស្នើសុំឱ្យឃុំខ្លួន ឌុច បណ្តោះអាសន្ន[836]។

មេធាវីរបស់ ឌុច បានស្នើសុំឱ្យដោះលែង ឌុច ឱ្យនៅក្រៅឃុំ ដោយលើកឡើងថា គាត់បានជាប់ឃុំអស់រយៈពេលជាងប្រាំបីឆ្នាំរួចហើយ ចាប់តាំងពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ដោយសារតែកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់នៅតុលាការយោធា[837]។ សហចៅក្រមស៊ើបអង្កេតបានពិចារណាលើបញ្ហាចោទថាតើ ការ

---

[829] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២។
[830] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ១១៥។
[831] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ១១១, ១១៩, ១២១, ១៣០, ២០៣។ សូមមើលផងដែរ សំណុំរឿង០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១៣៥, ២១៤៨, ២១៥៧។
[832] សំណុំរឿង០០១ ដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ឯកសារ D99 កថាខណ្ឌ ៤។
[833] សំណុំរឿង០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ៣។
[834] សំណុំរឿង ០០២ ដីកាបំបែកសំណុំរឿង ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ D18។
[835] សំណុំរឿង ០០១ ដីកាបង្គាប់ឱ្យនាំខ្លួន ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ C5/2។
[836] សំណុំរឿង០០១ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែក្កដា ឆ្នាំ២០០៧ ឯកសារ C3។
[837] សំណុំរឿង០០១ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែក្កដា ឆ្នាំ២០០៧ ឯកសារ C3 កថាខណ្ឌ១-២។

ឃុំខ្លួន ឌុច នៅក្នុងកិច្ចដំណើរការនីតិវិធីដោយឡែក បានប៉ះពាល់លើកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ឬយ៉ាងណា? រួមទាំងលើបញ្ហាថាតើ ការឃុំខ្លួនគាត់មានលក្ខណៈហួសហេតុ និងអាចប៉ះពាល់ដល់សិទ្ធិរបស់គាត់ ដែលនាំឱ្យកិច្ចដំណើរការនីតិវិធី អ.វ.ត.ក. ប្រឆាំងគាត់ គួរត្រូវផ្អាក ឬយ៉ាងណា[838]។ ពួកគេបានសម្រេចថា នីត្យានុកូលភាពនៃការឃុំខ្លួនពីមុនរបស់ ឌុច មិនស្ថិតក្នុងយុត្តាធិការរបស់ខ្លួនទេ និងបានសន្និដ្ឋានថា ការឃុំខ្លួនមានភាពចាំបាច់នៅក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. ហេតុដូច្នេះ ឌុច ត្រូវបានផ្ទេរមកកាន់មន្ទីរឃុំឃាំង អ.វ.ត.ក.[839]។ ទោះបីជាការឃុំខ្លួនគាត់ ដំបូងឡើយត្រូវបានបង្គាប់សម្រាប់រយៈពេលមិនលើសមួយឆ្នាំក៏ដោយ[840] ការឃុំខ្លួននេះបានពន្យារពេលជាច្រើនដង រហូតទាល់តែកិច្ចដំណើរការនីតិវិធីប្រឆាំងគាត់បានបញ្ចប់[841]។

នៅថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹង ឌុច ថា បន្ថែមលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឌុច ក៏អាចត្រូវបានចោទប្រកាន់ពីបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ផងដែរ[842]។ បន្ទាប់ពីការបិទបញ្ចប់កិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ចោទប្រកាន់ ឌុច យោងតាមមាត្រា ៣ នៃច្បាប់ អ.វ.ត.ក. ពីបទឧក្រិដ្ឋកម្មមនុស្សឃាត និងការធ្វើទារុណកម្ម ដូចដែលបានកំណត់ក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ផងដែរ។ សហចៅក្រមស៊ើបអង្កេត បានបដិសេធសំណើនេះ ដោយបានពិចារណាថា ក្នុងករណីមិនមានធាតុផ្សំណាថ្មីនោះទេ វាមិនចាំបាច់ធ្វើការបើកការស៊ើបអង្កេតឡើងវិញ ដើម្បីដាក់ការចោទប្រកាន់បន្ថែមនោះទេ[843]។

### ៥.១.៣.២. ភស្តុតាងនៅក្នុងសំណុំរឿង

ភស្តុតាងនៅក្នុងសំណុំរឿង រួមមានកំណត់ហេតុសួរចម្លើយ ឌុច ចំនួន ២១[844] ការស្តាប់ចម្លើយសាក្សីមួយចំនួន រួមទាំងអតីតបុគ្គលិក និងអ្នកជាប់ឃុំ ស-២១ កំណត់ហេតុនៃការចុះធ្វើការអង្កេតដល់កន្លែងកើតហេតុ (នៅ ស-២១ និង ជើងឯក ហៅ "វាលពិឃាត")[845] និងឯកសារជាច្រើនទៀត ដែលបានដាក់ក្នុងសំណុំរឿង ដោយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង ឌុច បន្ថែមលើឯកសារ ដែលបានដាក់ដោយសហព្រះរាជអាជ្ញា ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួន[846]។

---

[838] សំណុំរឿង០០១ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ C3 កថាខណ្ឌ ៣។
[839] សំណុំរឿង០០១ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ C3 កថាខណ្ឌ ២០-២៣។ សំណុំរឿង០០១ ដីកាសម្រេចដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ឯកសារ D99 កថាខណ្ឌ ៤។
[840] សំណុំរឿង ០០១ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឯកសារ C3 ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ ផ្នែកសម្រេចសេចក្តី។
[841] សូមមើលសំណុំរឿង ០០១ សាលក្រម៖ ឧបសម្ព័ន្ធ ១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ជំពូក ៦.១។
[842] សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ ឯកសារ E3/26។
[843] សូមមើល សំណុំរឿង ០០១ ដីកាបង្គាប់ទាក់ទងនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ D94/I។
[844] សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ឯកសារ E3/25។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០០៧ ឯកសារ E3/26។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ ឯកសារ E3/2។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ E3/17។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ ឯកសារ E3/11។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ ឯកសារ E3/437។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ ឯកសារ E3/380។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ឯកសារ E3/225។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/5។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/117។ សំណុំរឿង ០០១ កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/3។
[845] សូមមើល ឧទាហរណ៍ សំណុំរឿង ០០១ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/244។ សំណុំរឿង ០០១ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/245។ សំណុំរឿង ០០១ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៨ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/246។ សំណុំរឿង ០០១ កំណត់ហេតុស្តីពីការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ឯកសារ E3/242។
[846] សូមមើល សំណុំរឿង០០១ ដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ឯកសារ D99 កថាខណ្ឌ៩។

### ៥.១.៣.៣. ដីកាសន្និដ្ឋានស្ថាពរ

នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានបិទបញ្ចប់ការស៊ើបអង្កេតរបស់ខ្លួន[847] ហើយនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ពួកគេបានបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញាពិនិត្យដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរ[848]។ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា បានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចោទប្រកាន់និងបញ្ជូនខ្លួន ឌុច ទៅជំនុំជម្រះចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦[849]។

ឌុច បានឆ្លើយតបថា ការសហការពេញលេញ និងការទទួលស្គាល់របស់គាត់ ចំពោះការទទួលខុសត្រូវរបស់គាត់ មិនត្រូវបានលើកឡើង និងថាដីកាសន្និដ្ឋានស្ថាពរ បានបញ្ចូលអង្គហេតុដែលមិនបានបង្កើតក្នុងពេលស៊ើបអង្កេត ជាការដាក់បញ្ចូលអង្គហេតុផ្អែកតាមឯកសារ និង "សក្ខីកម្ម" មិនស្ថិតក្រោមការពិភាក្សាដេញដោល។ គាត់បានបដិសេធមិនទទួលស្គាល់ថា ស-២១ ស្ថិតនៅក្នុងប្រព័ន្ធឋានានុក្រមខ្ពស់បំផុតនៃមន្ទីរសន្តិសុខ ការចូលរួមយ៉ាងសកម្មរបស់ ស-២១ ក្នុងការចាប់ខ្លួន ការពាក់ព័ន្ធផ្ទាល់ខ្លួនរបស់គាត់ក្នុងការសួរចម្លើយ និងការធ្វើទារុណកម្ម គាត់បានសម្រេចលើការសម្លាប់ និងគាត់បានដឹងគ្រប់យ៉ាងអំពីអ្វីដែលបានកើតឡើងនៅទូទាំងប្រទេស។ ឌុច បានតវ៉ាបន្ថែមទៀតថា មានបរិយាកាសភ័យខ្លាចនៅ ស-២១ ដែលរូបគាត់មិនអាចដកខ្លួនចេញពីភារកិច្ច ឬរត់គេចបានឡើយ និងថាការងាររបស់គាត់គឺអាន និងធ្វើចំណារលើចម្លើយសារភាព[850]។

### ៥.១.៣.៤. ដីកាដំណោះស្រាយ

សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ ដែលបានចោទប្រកាន់និងបញ្ជូនខ្លួន ឌុច ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[851]។

i. **ផ្នែកទី១** នៃដីកាដំណោះស្រាយមានសេចក្តីសង្ខេបអង្គហេតុ ដែលពិភាក្សាពីបរិបទប្រវត្តិសាស្ត្រ និងនយោបាយ ដែលនាំឱ្យមានការបង្កើត ស-២១ ការបង្កើតមន្ទីរនេះ ការអនុវត្តគោលនយោបាយ ប.ប.ក. នៅ ស-២១ និងតួនាទីរបស់មន្ទីរ ស-២១។
ii. ផ្នែកទី២ ពិភាក្សាអំពីការកំណត់បទចោទនៃអង្គហេតុនានា ដោយមានការរកឃើញរបស់សហចៅក្រមស៊ើបអង្កេតថា ទោះបី ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ តែគាត់ "អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនានា [...] ដោយផ្អែកលើអំណាចឋានានុក្រមជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ខ្លួន ក្នុងឋានៈជាអនុលេខា បន្ទាប់មកជាលេខា [ស-២១]"[852]។ សហចៅក្រមស៊ើបអង្កេត បានរកឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ នៃការឃុំខ្លួនជនស៊ីវិលខុសច្បាប់ ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ការបង្កឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបអមនុស្សធម៌ និងអំពើមនុស្សឃាតដោយចេតនាទាំងអស់នេះបានកើតមានឡើង និងថា ឌុច ទទួលខុសត្រូវផ្ទាល់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ និងទទួលខុសត្រូវតាមរយៈការញុះញង់ ការបញ្ជា ការជួយ និងជំរុញ និងការទទួលខុសត្រូវក្នុងនាមជាមេបញ្ជាការ។ ដីកាដំណោះស្រាយមិនបានយោងទៅទម្រង់នៃការទទួលខុសត្រូវ ដែលគេស្គាល់ថាជា សហឧក្រិដ្ឋកម្មរួម ("JCE")

---

[847] សំណុំរឿង ០០១ សេចក្តីជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ ឯកសារ D89។
[848] សំណុំរឿង ០០១ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ D95។
[849] សំណុំរឿង ០០១ ដីកាសន្និដ្ឋានស្ថាពរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ D96។
[850] សំណុំរឿង ០០១ ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ D96/1។
[851] សំណុំរឿង០០១ ដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ឯកសារ D99។
[852] សំណុំរឿង០០១ ដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ឯកសារ D99 កថាខណ្ឌ១២៩។

នោះទេ ឬយោងទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈសហចារីកម្មនោះទេ។ សហចៅក្រមស៊ើបអង្កេត បានលើកឡើងថា ទោះបីជាអំពើមួយចំនួន ក៏អាចបង្កើតបានជាឧក្រិដ្ឋកម្មជាតិនៃអំពើមនុស្សឃាត និងការធ្វើទារុណកម្មក្តី ក៏ពួកគាត់មិនចោទប្រកាន់ ឌុច ពីបទឧក្រិដ្ឋកម្មជាតិនោះទេ ដោយសារ "អំពើទាំងនេះត្រូវតែទទួលបានការចោទប្រកាន់ក្រោមការកំណត់ប្រភេទបទល្មើសដែលមានលក្ខណៈខ្ពស់ជាងគេ" ដែលនៅក្នុងករណីនៃសំណុំរឿងនេះគឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩"[853]។

iii. **ផ្នែកទី ៣** ពិភាក្សាអំពីសាវតាររបស់ ឌុច និងការវិវឌ្ឍន៍ផ្នែកនយោបាយ វិជ្ជាជីវៈ និងលក្ខណៈបុគ្គលរបស់គាត់ ការទទួលស្គាល់របស់ ឌុច លើការទទួលខុសត្រូវ និងលទ្ធផលនៃការវាយតម្លៃផ្នែកបញ្ហាស្មារតីរបស់គាត់។ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ច្បាស់ថា ឌុច បានទទួលស្គាល់ការទទួលខុសត្រូវរបស់គាត់យ៉ាងស៊ីចង្វាក់គ្នា ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅ ស-២១ ក្រោមការបញ្ជារបស់គាត់ និងថា គាត់មានចេតនាសហការក្នុងកិច្ចស៊ើបសួរ។ សហចៅក្រមស៊ើបអង្កេតក៏បានរកឃើញទៀតថា គាត់បានព្យាយាមរត់គេចចេញពី ស-២១ ប៉ុន្តែមិនបានជោគជ័យ និងមិនអាចធ្វើទៅបាន ដោយសារតែមានការឃាមការពារជាប់ជានិច្ច។

## ៥.១.៤. កិច្ចដំណើរការនីតិវិធីអង្គបុរេជំនុំជម្រះ

### ៥.១.៤.១. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

សហព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ ដោយលើកឡើងថា៖

- សហចៅក្រមស៊ើបអង្កេត ខកខានមិនបានចោទប្រកាន់ឧក្រិដ្ឋកម្មជាតិ និងទម្រង់នៃការទទួលខុសត្រូវតាម JCE និងហេតុដូច្នេះ "ឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទប្រកាន់លើ ឌុច" មិនបានឆ្លុះបញ្ចាំងនោះទេ
- ឧក្រិដ្ឋកម្មជាតិមិនត្រឹមតែមិនបានបង្ហាញ ដោយការរកឃើញនៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះទេ ប៉ុន្តែការដែលខកខានមិនបានបញ្ចូលវាទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយនឹងឧក្រិដ្ឋកម្មអន្តរជាតិ អាចនាំឱ្យ ឌុច រួចពីវុទ្ធភាពទាំងស្រុង ប្រសិនបើឧក្រិដ្ឋកម្មអន្តរជាតិមិនត្រូវបានបញ្ជាក់ដោយភស្តុតាងនៅពេលជំនុំជម្រះទេនោះ
- JCE គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានគេទទួលយក ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានលក្ខណៈចង្អៀតមិនសមហេតុផលដោយគ្មានទម្រង់នៃការទទួលខុសត្រូវនេះ និងថា ឌុច អាចមិនត្រូវបានដាក់ឱ្យទទួលខុសត្រូវពេញលេញចំពោះអំពើរបស់គាត់[854]។

ឌុច បានឆ្លើយតបថា សហព្រះរាជអាជ្ញា បានពឹងផ្អែកលើការបកស្រាយខុស នៃវិធាននីតិវិធីជាធរមាន នៅចំពោះមុខ អ.វ.ត.ក. និងថា សហចៅក្រមស៊ើបអង្កេតមិនមានកំហុសអង្គច្បាប់ ដោយការមិនចោទប្រកាន់ ឌុច ចំពោះបទឧក្រិដ្ឋកម្មជាតិ និងតាមទម្រង់ JCE នោះឡើយ[855]។

នៅថ្ងៃទី២៣ និងទី២៥ ខែកញ្ញា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ បានស្នើសុំអ្នកមិនមែនជាភាគីនៃរឿងក្តីដែលបានជ្រើសរើសចំនួនបីរូប ឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរអំពី៖

- ការបង្កើតទ្រឹស្តីសហឧក្រិដ្ឋកម្មរួម និងការវិវឌ្ឍន៍នៃនិយមន័យនៃទម្រង់នៃការទទួលខុសត្រូវនោះដោយមានការយោងជាក់លាក់ទៅរយៈពេលចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩

[853] សំណុំរឿង០០១ ដីកាដំណោះស្រាយ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨ ឯកសារ D99 កថាខណ្ឌ ១៥២។
[854] សំណុំរឿង ០០១ បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព. ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ D99/3/3។
[855] សំណុំរឿង ០០១ ចម្លើយតបទៅនឹង បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព. ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០០៨ ឯកសារ D99/3/8។

- ថាតើសហឧក្រិដ្ឋកម្មរួម ដែលជាទម្រង់នៃការទទួលខុសត្រូវ អាចអនុវត្តបាននៅ អ.វ.ត.ក. ឬយ៉ាងណា ដោយពិចារណាថា ឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើងចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩[856]។

អ្នកមិនមែនជាភាគីនៃរឿងក្តីចំនួនបីនាក់ បានដាក់សារណារៀងៗខ្លួនតាមការស្នើសុំ។ សាស្ត្រាចារ្យ Antonio Cassese និងសមាជិកផ្សេងទៀត នៃទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ បានសន្និដ្ឋានថា ការទទួលខុសត្រូវតាម JCE នៅក្នុងប្រភេទទាំងបីរបស់វានីមួយៗ មានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រឹមឆ្នាំ១៩៧៥ និងអាចអនុវត្តបាននៅ អ.វ.ត.ក.[857]។ សាកលវិទ្យាល័យ McGill បានសន្និដ្ឋានថា ការទទួលខុសត្រូវចំពោះទម្រង់មួយចំនួននៃផែនការរួម មានអត្ថិភាពនៅក្នុងច្បាប់អន្តរជាតិ ចាប់តាំងពីយ៉ាងហោចណាស់ ឆ្នាំ១៩៤៥ ដែលការទទួលខុសត្រូវតាម JCE អាចអនុវត្តបាននៅ អ.វ.ត.ក. និងថា "ជាពិសេស ទម្រង់ទី៣ ដែលជាទម្រង់ពង្រីកបន្ថែមអាចត្រូវបានកំណត់និយមន័យតាមលក្ខណៈមួយដែលមិនប៉ះពាល់ដល់សិទ្ធិជនជាប់ចោទ"[858]។ សាស្ត្រាចារ្យបណ្ឌិត Kai Ambos បានសន្និដ្ឋានថា មានតែ JCE I ប៉ុណ្ណោះដែលមានអត្ថិភាពក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិយ៉ាងច្បាស់លាស់ត្រឹមឆ្នាំ១៩៧៥ និងអាចអនុវត្តបានជាទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម និងថា JCE II មានអត្ថិភាព និងអាចអនុវត្តបាន ប្រសិនបើបកស្រាយជាទម្រង់រងនៃ JCE I ប៉ុន្តែការអនុវត្ត JCE III នឹងផ្ទុយទៅនឹងគោលការណ៍ស្តីពីភាពដែលគួរដាក់ទណ្ឌកម្មបាន[859]។

ឌុច និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពីររូប បានឆ្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តីទាំងនេះ[860] ចំណែកសហព្រះរាជអាជ្ញា មិនបានឆ្លើយតបទេ។

### ៥.១.៤.២. សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

អង្គបុរេជំនុំជម្រះបានទទួលយកមូលដ្ឋានទីមួយ នៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាមួយផ្នែក ដោយសន្និដ្ឋានថា ឧក្រិដ្ឋកម្មជាតិនៃការធ្វើទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុន ដូចដែលបានកំណត់និយមន័យដោយក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ គួរត្រូវបានបញ្ចូលទៅក្នុងដីកាដំណោះស្រាយ[861]។ ទោះជាយ៉ាងណា អង្គបុរេបានច្រានចោលមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ដោយ

---

[856] សំណុំរឿង ០០១ សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ D99/3/12។ សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ D99/3/13។ សេចក្តីអញ្ជើញអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ឯកសារ D99/3/14។

[857] សំណុំរឿង ០០១ សារណាអំពីទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ដោយសាស្ត្រាចារ្យ Antonio Cassese សមាជិក *ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/24 កថាខណ្ឌ២០-២១។

[858] សំណុំរឿង ០០១ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ដាក់ជូនដោយមជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្ស និងពហុច្បាប់ (Centre for Human Rights and Legal Pluralism) នៃសកលវិទ្យាល័យ McGill University ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០០៨ ឯកសារ D99/3/25 កថាខណ្ឌ ៧-៨។

[859] សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តី ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក./ក.ស.ច.ស (អ.ប.ជ.០២) សាស្ត្រាចារ្យ បណ្ឌិត Kai Ambos ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ D99/3/27 កថាខណ្ឌ២-៤។

[860] សំណុំរឿង ០០១ សារណារបស់សហមេធាវីអន្តរជាតិ [Silke Studzinsky] នៃដើមបណ្តឹងរដ្ឋប្បវេណី តបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D99/3/32។ សំណុំរឿង ០០១ ចម្លើយតប [របស់ Martine Jacquin និង Philippe Canonne ] ទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D99/3/33។ សំណុំរឿង ០០១ ចម្លើយតបរបស់ក្រុមការពារក្តីទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D99/3/37។ សំណើសុំធ្វើសារណាលើប្រធានបទនេះ ក៏បានទទួលផងដែរពីជនជាប់ចោទផ្សេងទៀតក្នុងសំណុំរឿង ០០២ ផងដែរ ប៉ុន្តែសំណើទាំងនេះត្រូវបានបដិសេធ។ សូមមើល សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ D99/3/42 កថាខណ្ឌ ១៨-១៩។

[861] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42។

សន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមិនមានកំហុស ក្នុងការខកខានមិនបញ្ចូល JCE ជាទម្រង់នៃការទទួលខុសត្រូវនៅក្នុងដីកាដំណោះស្រាយឡើយ[862]។

ក្នុងការពិចារណាលើមូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានរកឃើញថា សហចៅក្រមស៊ើបអង្កេត មិនបានគោរពតាមវិធានផ្ទៃក្នុង ឬបទដ្ឋានអន្តរជាតិទេ នៅពេលដែលពួកគេខកខានក្នុងការផ្តល់មូលហេតុ ថាតើហេតុអ្វីពួកគេចាត់ទុកបទល្មើសក្រោមច្បាប់អន្តរជាតិ មានការកំណត់បទចោទដែលមានលក្ខណៈខ្ពស់ជាងបទល្មើសក្រោមច្បាប់ជាតិ[863]។ អង្គបុរេជំនុំជម្រះបានពិចារណាលើនិយមន័យឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ និងឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ដើម្បីសម្រេចថាតើ ឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិមានធាតុផ្សំសារធាតុ ដែលមិនមាននៅក្នុងឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិឬអត់[864]។ អង្គបុរេបានរកឃើញថា ឧក្រិដ្ឋកម្មទាំងពីរនេះមានលក្ខណៈដាច់ដោយឡែកពីគ្នា និងថាឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិនៃការធ្វើទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុន (ផ្ទុយពីអំពើមនុស្សឃាត ដូចដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា) មិនមានដាក់បញ្ចូលក្នុងឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិទេ[865]។ អង្គបុរេបានរកឃើញទៀតថា ការដាក់បញ្ចូលបទចោទលើសពីមួយ ចំពោះអំពើតែមួយ មិនបាន "ប៉ះពាល់ដល់គោលការណ៍*គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង* ពីព្រោះវាមិនពាក់ព័ន្ធនឹងការកំណត់ជាក់លាក់លើការទទួលខុសត្រូវ ឬការដាក់ទោសទណ្ឌ"[866]។ ដោយរកឃើញមូលដ្ឋានអង្គហេតុគ្រប់គ្រាន់មួយ ក្នុងការចោទប្រកាន់និងបញ្ជូនខ្លួន ឌុច ទៅជំនុំជម្រះពីបទការធ្វើទារុណកម្ម និងបទមនុស្សឃាតគិតទុកជាមុន យោងតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ អង្គបុរេជំនុំជម្រះបានបន្ថែមឧក្រិដ្ឋកម្មទាំងនោះទៅក្នុងដីកាដំណោះស្រាយ[867]។

ទាក់ទងនឹងមូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍ អង្គបុរេបានរកឃើញថា សហចៅក្រមស៊ើបអង្កេតបានខកខានក្នុងការផ្តល់ហេតុផល ថាតើហេតុអ្វីបានជាសំណើសុំដាក់បញ្ចូលការចោទប្រកាន់តាម JCE ត្រូវបានបដិសេធ និងខកខានក្នុងការពន្យល់អំពីការកំណត់បទចោទដែលខ្លួនបានជ្រើសរើស។ ដូច្នេះ អង្គបុរេជំនុំជម្រះបានធ្វើការពិនិត្យកិច្ចដំណើរការនីតិវិធីស៊ើបអង្កេត ក្នុងសំណុំរឿង ០០១ ដោយខ្លួនឯង[868]។

អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ទម្រង់ JCE ដែល ឌុច និងអ្នកផ្សេងទៀតត្រូវបានចោទប្រកាន់ថាបានជាប់ពាក់ព័ន្ធនោះ គឺស្ថិតនៅក្នុងសំណុំរឿងដាច់ដោយឡែកនៃសំណុំរឿង ០០២[869]។ ដោយសារតែមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងទៅនឹង JCE កើតឡើងនៅក្នុង ស-២១ និងមិនមានសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមទៅក្នុងទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវបានផ្តួចផ្តើមឡើងក្នុងសំណុំរឿង ០០១ ទេនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការទទួលខុសត្រូវតាម JCE មិនមែនជាផ្នែកយ៉ាងជាក់លាក់នៃការស៊ើបអង្កេតនោះឡើយ[870]។

---

[862] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 ផ្នែកសម្រេចសេចក្តី។
[863] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ៥៦-៥៧។
[864] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ៥០-៨៤។
[865] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ៨៥។
[866] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ៨៨។
[867] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ៩៩, ១០៣, ១០៥-១០៧។
[868] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ១១៥-១១៦។
[869] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ១២៣។
[870] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ១២៥។

ទោះជាយ៉ាងណា អង្គបុរេជំនុំជម្រះបានពិចារណាថាតើ ការទទួលខុសត្រូវតាម JCE នៅ ស-២១ បានបង្កើតជាផ្នែកមួយនៃមូលដ្ឋានអង្គហេតុ សម្រាប់ការស៊ើបអង្កេតឬទេ បើទោះបីជាមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ អង្គបុរេបានរកឃើញថា ទោះបីជាធាតុផ្សំមួយចំនួននៃការទទួលខុសត្រូវតាម JCE អាចត្រូវបានពិចារណា ដើម្បីបង្កើតបានជាផ្នែកមួយនៃការស៊ើបអង្កេតក៏ដោយ ក៏ធាតុផ្សំផ្សេងទៀតនៃទម្រង់ទាំងបីនៃ JCE មិនត្រូវបានស៊ើបអង្កេតនោះទេ។ ដូច្នេះ ដោយពិចារណាថា វាមិនមែនគ្រាន់តែជាសំណួរអំពីការកំណត់បទល្មើស ដូចដែលបានលើកឡើងដោយសហព្រះរាជអាជ្ញានោះទេ អង្គបុរេយល់ឃើញថា មិនមានមូលដ្ឋានអង្គហេតុគ្រប់គ្រាន់ ដើម្បីអនុញ្ញាតឱ្យធ្វើការកំណត់បទល្មើសតាម JCE នោះឡើយ[871]។ ជាងនេះទៀត ឌុច មិនទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ទាក់ទងនឹងការចូលរួមរបស់គាត់នៅ ស-២១ ក្រោមទម្រង់ JCE នោះទេ មុនពេលចេញដីកាសន្និដ្ឋានស្ថាពរ ដែលជាលក្ខខណ្ឌតម្រូវដើម្បីការពារសិទ្ធិរបស់គាត់ ក្នុងការទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់[872]។ ផ្អែកលើសំអាងហេតុរបស់ខ្លួន អង្គបុរេជំនុំជម្រះ យល់ឃើញថា វាមិនចាំបាច់ក្នុងការសម្រេចអំពីឋានៈនៃច្បាប់អន្តរជាតិស្តីពីការទទួលខុសត្រូវលើ JCE ក្នុងឆ្នាំ១៩៧៥ ឬ ភាពអាចអនុវត្តបានរបស់វានៅ អ.វ.ត.ក. ជាទូទៅនោះទេ[873]។

អង្គបុរេជំនុំជម្រះបានធ្វើការកែប្រែដីកាដំណោះស្រាយ ដើម្បីបញ្ចូលបទមនុស្សឃាតគិតទុកជាមុន និងបទល្មើសនៃការធ្វើទារុណកម្ម និងបានបង្គាប់ឱ្យបន្តការឃុំខ្លួន ឌុច បណ្តោះអាសន្ន[874]។

## ៥.១.៥. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះសាលាដំបូង

### ៥.១.៥.១. សវនាការបឋម

សវនាការបឋមបានចាប់ផ្តើមនៅថ្ងៃទី១៧ និង ១៨ ខែកុម្ភៈ ឆ្នាំ២០០៩[875]។ ជាដំបូង អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សាអំពីអញ្ញត្រកម្មរបស់ ឌុច ទាក់ទងនឹងភាពអាចអនុវត្តបាននៃអាជ្ញាយុកាល ចំពោះឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ[876]។ អង្គជំនុំជម្រះបានពិចារណាថា អញ្ញត្រកម្មអាចទទួលយកបាន ប៉ុន្តែបានសម្រេចលើការកំណត់អំពីអញ្ញត្រកម្ម នៅពេលជាមួយគ្នានឹងសាលក្រមរបស់ខ្លួនលើអង្គសេចក្តីនៃរឿងក្តី ដូចដែល ឌុច បានស្នើសុំ[877]។

បន្ទាប់មក សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី ពួកគេនឹងសុំឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើ ភាពអាចអនុវត្តបាននៃទ្រឹស្តី JCE ដោយលើកឡើងថា ពួកគេយល់ឃើញថា អង្គបុរេជំនុំជម្រះមានកំហុស និងថា JCE I និង JCE II នឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាលើទំហំពេញលេញនៃការទទួលខុសត្រូវដែលអាចមានពិរុទ្ធរបស់ ឌុច។ មេធាវីការពារក្តីបានលើកឡើងថា ខ្លួនមានបំណងលើកឡើងអំពីអនីត្យានុកូលភាពនៃការឃុំខ្លួនបឋមជាបន្តរបស់ ឌុច[878]។

---

871 សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ១៣១-១៣៧។
872 សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ១៣៨-១៤២។
873 សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 កថាខណ្ឌ ១៤២។
874 សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឯកសារ D99/3/42 ផ្នែកសម្រេចសេចក្តី។
875 សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3.1។ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/4.2។
876 សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3.1 ទំព័រ ៧ (អង់គ្លេស)។
877 សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3.1 ទំព័រ៧-៨ (អង់គ្លេស)។
878 សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3.1 ទំព័រ ៩-១១ (អង់គ្លេស)។

បញ្ហាផ្សេងទៀតនៃសវនាការបឋម ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បញ្ជីឯកសារថ្មី និងវត្ថុតាងដែលបានស្នើឡើងដោយភាគី សាក្សី និង អ្នកជំនាញ ដើម្បីស្តាប់សវនាការនៅពេលជំនុំជម្រះ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជំនុំជុំម្រះ[879]។

### ៥.១.៥.២. សវនាការលើអង្គសេចក្តី

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ សវនាការលើអង្គសេចក្តីបានចាប់ផ្តើម[880]។ ការជំនុំជម្រះបានបំបែកជាវគ្គសវនាការលើប្រធានបទដូចតទៅ៖ (១) បញ្ហានានាទាក់ទងទៅនឹង ម-១៣ (២) ការបង្កើត ស-២១ និងគុកតាខ្មៅ (៣) ការអនុវត្តគោលនយោបាយ ប.ក.ក. នៅ ស-២១ (៤) ជម្លោះប្រដាប់អាវុធ (៥) តួនាទីរបស់ ស-២១ រួមទាំង ជើងឯក (៦) ការបង្កើត និងតួនាទី ព្រៃ ស (ស-២៤) និង (៧) បញ្ហានានាទាក់ទងទៅនឹងអត្តចរិតរបស់ ឌុច[881]។

#### ៥.១.៥.២.១. អង្គហេតុដែលឯកភាព និងមិនឯកភាព

សហព្រះរាជអាជ្ញា និងមេធាវីការពារក្តីបានឯកភាពគ្នាលើអង្គហេតុជាក់លាក់មួយចំនួន មុនពេលសវនាការលើអង្គសេចក្តី បន្ទាប់ពីមានសេចក្តីណែនាំពី អង្គជំនុំជម្រះសាលាដំបូង។ សហព្រះរាជអាជ្ញាបានផ្តល់បញ្ជីអង្គហេតុចំនួន ៣៥១ ទៅឱ្យមេធាវីការពារក្តី ដើម្បីធ្វើការពិនិត្យ និងឯកភាព ដែលអង្គហេតុទាំងនោះមិនទាន់បានឯកភាពនៅឡើយនៅពេលសវនាការបឋម ប៉ុន្តែមេធាវីការពារក្តីបានបញ្ជាក់ថា ខ្លួននឹងឆ្លើយតបនៅមុនសវនាការលើអង្គសេចក្តី[882]។

ក្នុងអំឡុងពេលសវនាការលើអង្គសេចក្តី នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី បានដាក់សេចក្តីសន្និដ្ឋានលើអង្គហេតុដែលបានឯកភាព។ ឌុច បានឯកភាពទៅនឹងអង្គហេតុចំនួន ១៥៧ ក្នុងចំណោមអង្គហេតុ ៣៥១ ចំណែកការចោទប្រកាន់ផ្នែកអង្គហេតុចំនួន ៨១ ទៀត “មិនត្រូវបានជំទាស់” ទេ។ ឌុច ជំទាស់ទៅនឹងការចោទប្រកាន់ផ្នែកអង្គហេតុចំនួន ២១។ ដូច្នេះ អង្គហេតុចំនួន ២៣៨ ក្នុងចំណោម ៣៥១ មិនត្រូវបានជំទាស់ដោយ ឌុច នៅក្នុងអំឡុងពេលសវនាការទេ[883]។ ឌុច បានដាក់ឯកសារមួយ[884] ដែលរៀបរាប់អំពីអង្គហេតុទាំងអស់ ដែលគាត់បានឯកភាព និងមិនឯកភាព ហើយនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ មេធាវីការពារក្តីបានអានអង្គហេតុដែលឯកភាព ឬ “មិនជំទាស់” ក្នុងអំឡុងពេលសវនាការ[885]។

#### ៥.១.៥.២.២. ដើមបណ្តឹងរដ្ឋប្បវេណី

ការិយាល័យសហចៅក្រមស៊ើបអង្កេត បានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨ ក្នុងអំឡុងពេលដំណាក់កាលស៊ើបអង្កេត ហើយបុគ្គលចំនួន ៦៦ នាក់ បានកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងដំណាក់កាលជំនុំជម្រះ មុនកាលបរិច្ឆេទកំណត់ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៩។ ក្រោយមក ពាក្យសុំបួន ក្នុងចំណោមពាក្យសុំទាំងអស់នេះ ត្រូវបានដកចេញវិញ ឬត្រូវបានបដិសេធ ដូច្នេះមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៣ នាក់ បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០១។ ដើម

---

[879] See សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3.1 ទំព័រ ២ (អង់គ្លេស)។
[880] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ឯកសារ E1/5.1។
[881] សំណុំរឿង ០០១ ដីកាសម្រេចកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី និង ថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែដំបូង ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E15 កថាខណ្ឌ ៩.១។
[882] សូមមើល សំណុំរឿង០០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/3.1 ទំព័រ ១៥-១៧ (អង់គ្លេស)។
[883] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ ឯកសារ E1/6.1 ទំព័រ ៩៥ (អង់គ្លេស)។
[884] សំណុំរឿង ០០១ គោលជំហររបស់មេធាវីការពារក្តីលើអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៩ ឯកសារ E5/11/6.1។
[885] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៩ ឯកសារ E1/7.1។

បណ្ដឹងរដ្ឋប្បវេណីបានរៀបចំជាបួនក្រុម ដែលក្រុមនីមួយៗត្រូវបានតំណាងដោយមេធាវីរបស់ខ្លួនផ្ទាល់[886]។

ទម្រង់ការទាក់ទងទៅនឹងការចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធី ដើមឡើយមានភាពមិនច្បាស់លាស់ទេ[887]។ នៅថ្ងៃសវនាការទី ៥០ អង្គជំនុំជម្រះសាលាដំបូង បានផ្ដល់គោលការណ៍ណែនាំស្ដីពីការតាំងសំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទៅកាន់ជនជាប់ចោទ។ អង្គជំនុំជម្រះបានលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណីគួរប្រើពេលវេលាទាំងអស់របស់ខ្លួនដែលបានផ្ដល់ឱ្យ សម្រាប់ការតាំងសំណួរទៅកាន់សាក្សី មកសួរសំណួរ ឌុច វិញ ប្រសិនបើពួកគេមានបំណងធ្វើដូច្នេះ ប៉ុន្តែអង្គជំនុំជម្រះមិនផ្តល់ពេលបន្ថែមសម្រាប់ការសួរសំណួរបែបនោះទេ ហើយសំណួរដែលនៅសល់សម្រាប់ ឌុច ដែលមិនបានសួរនៅក្នុងពេលដែលបានផ្ដល់ឱ្យនោះ នឹងមិនអនុញ្ញាតឡើយ ដោយពិចារណាលើភាពចាំបាច់ក្នុងការធានាបាននូវការជំនុំជម្រះដែលត្រឹមត្រូវយុត្តិធម៌ និងឆាប់រហ័ស[888]។ ក្នុងអំឡុងពេលសវនាការនោះ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានកត់សម្គាល់ថា ពួកគេបានឯកភាពគ្នាថា ដើម្បីប្រើពេលវេលាឱ្យមានប្រយោជន៍ មានតែសហមេធាវីម្នាក់ប៉ុណ្ណោះតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលផ្ដល់សក្ខីកម្មម្នាក់ៗ[889]។

មួយខែក្រោយមក មានការពិភាក្សាដេញដោលលើបញ្ហាថាតើ ដើមបណ្ដឹងរដ្ឋប្បវេណីគួរត្រូវបានអនុញ្ញាតឱ្យតាំងសំណួរទៅកាន់ ឌុច សាក្សី និង អ្នកជំនាញអំពីអត្តចរិតរបស់ ឌុច ដែរ ឬទេ។ សហមេធាវីតំណាងក្រុមដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន បានស្នើសុំអង្គជំនុំជម្រះឱ្យទទួលស្គាល់សិទ្ធិរបស់ខ្លួនជាភាគីដើម្បីតាំងសំណួរទៅកាន់សាក្សី ដែលនឹងត្រូវផ្ដល់សក្ខីកម្មអំពីអត្តចរិតរបស់ ឌុច ចំណែកមេធាវីការពារក្ដីវិញ បានតវ៉ាថា ដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសិទ្ធិដាក់សារណាលើការផ្ដន្ទាទោស ឬបញ្ហាគតិយុត្តិដែលទាក់ទងទៅនឹងការផ្ដន្ទាទោសនោះ មិនមានមូលហេតុណាដែលតម្រូវឱ្យពួកគាត់តាំងសំណួរអំពីចរិតលក្ខណៈរបស់ ឌុច នោះទេ[890]។ អង្គជំនុំជម្រះ លើកលែងតែចៅក្រម Jean-Marc Lavergne ដែលជំទាស់មួយផ្នែក បានសម្រេចថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យតាំងសំណួរទាក់ទងទៅនឹងអត្តចរិតទេ[891]។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២៨ នាក់ ដែលបានដាក់លិខិតបង្ហាញពីក្ដីកង្វល់របស់ខ្លួនទៅកាន់អង្គជំនុំជម្រះ មិនបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីចំនួនមួយសប្ដាហ៍[892]។ បន្ថែមលើនេះ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្រុម ២ និង ក្រុម ៣ បានប្ដឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការ

---

[886] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ឧបសម្ព័ន្ធ I៖ ប្រវត្តិនីតិវិធី កថាខណ្ឌ ១១។ ចំនួនដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង ០០១ ត្រូវបានពិនិត្យនៅដំណាក់កាលបណ្ដឹងសាទុក្ខ។ សូមមើល ជំពូក ៥.១.៦.២(vi)។

[887] សូមមើល ការពិភាក្សានៅសវនាការបឋម៖ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ E1/4.1 ទំព័រ ៨-១៩ (អង់គ្លេស)។ សូមមើលផងដែរ ការពិភាក្សានៅកិច្ចប្រជុំត្រៀមរៀបចំសវនាការ៖ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E1/31.1 ទំព័រ ១០៧-១១០ (អង់គ្លេស)។ សូមមើលផងដែរ ការពិភាក្សាក្នុងអំឡុងពេលសវនាការ៖ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E1/35.1 ទំព័រ ៩១-៩៨ (អង់គ្លេស)។

[888] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ E1/54.1 ទំព័រ ២៧-៣១(អង់គ្លេស)។

[889] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ E1/54.1 ទំព័រ ៣៧ (អង់គ្លេស)។

[890] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E1/70.1 ទំព័រ ៥១-៦៤ (អង់គ្លេស)។

[891] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ឯកសារ E1/70.1 ទំព័រ ៧៤ (អង់គ្លេស)។ សំណុំរឿង ០០១ សេចក្ដីសម្រេចលើសំណើរួមរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំឱ្យចេញសេចក្ដីសម្រេចអំពី សិទ្ធិរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការធ្វើសេចក្ដីសន្និដ្ឋានផ្ដន្ទាទោស និងសេចក្ដីណែនាំទាក់ទងនឹងការសួរជនជាប់ចោទ អ្នកជំនាញ និងសាក្សីដែលបានកោះហៅឱ្យផ្ដល់សក្ខីកម្ម ទាក់ទងនឹងអត្តចរិតរបស់ជនជាប់ចោទ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ ឯកសារ E72/3។

[892] សំណុំរឿង ០០១ លិខិតរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ ទៅកាន់ប្រធានអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០៩ ឯកសារ E166.1។

កំពូល ជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបណ្ដឹងសាទុក្ខនេះត្រូវបានអង្គជំនុំជម្រះតុលាការកំពូលបដិសេធថាមិនអាចទទួលយកបាន[893]។

ការពិភាក្សាទាក់ទងនឹងបញ្ហាពាក់ព័ន្ធនឹងតួនាទី និងការតំណាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុងបញ្ចប់បាននាំឱ្យមានការធ្វើវិសោធនកម្មវិធានផ្ទៃក្នុង នៅក្នុងកិច្ចប្រជុំពេញអង្គលើកទី ៧ មុនសំណុំរឿង ០០២ ចាប់ផ្ដើមសវនាការ ទោះជាយ៉ាងណា វិសោធនកម្មដែលបានធ្វើឡើងនោះមិនបានអនុវត្តចំពោះសំណុំរឿង ០០១ ទេ[894]។

## ៥.១.៥.២.៣. ចម្លើយរបស់ជនជាប់ចោទ

ឌុច បានថ្លែងទៅកាន់អង្គជំនុំជម្រះស្ទើរតែរាល់ថ្ងៃ នៃកិច្ចដំណើរការនីតិវិធីលើអង្គសេចក្ដី។ ក្នុងចំណោមថ្ងៃសវនាការ ៧៨ ថ្ងៃ ឌុច បាននិយាយចំនួន ៦៥ ថ្ងៃ[895]។

នៅថ្ងៃចុងក្រោយនៃសវនាការលើអង្គសេចក្ដី ឌុច ត្រូវបានស្នើសុំឱ្យធ្វើសេចក្ដីថ្លែងចុងក្រោយរបស់ខ្លួន។ គាត់បានបញ្ជាក់ពីកិច្ចសហការរបស់គាត់ ជាមួយនឹង អ.វ.ត.ក. រួមទាំងការឆ្លើយសំណួរទាំងអស់ដែលបានចោទសួរមកគាត់[896]។ គាត់បានទទួលស្គាល់អំពីការឈឺចាប់របស់អ្នកទាំងឡាយ ដែលបានស្លាប់បាត់បង់ជីវិតក្នុងអំឡុងពេលរបបខ្មែរក្រហម បានធ្វើការសុំអភ័យទោសចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ដោយ ប.ក.ក. ដោយកត់សម្គាល់ថា គាត់គឺជាសមាជិកម្នាក់របស់ ប.ក.ក.[897]។ គាត់បានបញ្ជាក់អំពីការទទួលខុសត្រូវរបស់គាត់ ចំពោះឧក្រិដ្ឋកម្មនៅ ស-២១ ដោយមិនបដិសេធឡើយ[898]។ បន្ទាប់មក ឌុច បានសន្និដ្ឋានបញ្ចប់ដូចខាងក្រោម៖

> ផ្ទាល់ខ្លួនខ្ញុំ ឧក្រិដ្ឋកម្មនៅ ស-២១ អត់បដិសេធទេ រឿងរ៉ាវដែលមានការឃុំឃាំងខ្ញុំ ចាប់តាំងពីថ្ងៃ៨ ខែឧសភា ឆ្នាំ១៩៩៩ រហូតមកដល់បច្ចុប្បន្ននេះ វាដប់ឆ្នាំ ប្រាំមួយខែ ដប់ប្រាំបីថ្ងៃ ដប់ប្រាំបួនថ្ងៃហើយ។ ខ្ញុំទុកជារយៈកាល ដែលខ្ញុំបានសហការជាមួយនឹងតុលាការ ខ្ញុំអត់ទាមទារថា អាហ្នឹងខុសច្បាប់ អាហ្នឹងស្អីទេ ខ្ញុំទុកជារង្វាន់ការដែលខ្ញុំបានសហការជាមួយតុលាការ ប៉ុន្តែបើខ្លឹមសារនេះ ដែលខ្ញុំបានរាប់រៀបរួចមកហើយ គោលគំនិតច្បាប់បង្កើត អ.វ.ត.ក. នេះ ខ្ញុំសូមលើកជាសំណូមពរជូនអង្គជំនុំជម្រះមេត្តាដោះលែងខ្ញុំ។[899]

ប្រធានអង្គជំនុំជម្រះ បានសួរថាតើ ឌុច ស្នើសុំឱ្យរួចពិរុទ្ធភាពពីការចោទប្រកាន់ ឬសុំការបន្ធូរបន្ថយទោស ផ្អែកលើការសហការរបស់គាត់ និងរយៈពេលយូរនៃការឃុំខ្លួនគាត់ ឬយ៉ាងណា[900]។ ឌុច បានផ្ទេរសំណួរនេះទៅឱ្យសហមេធាវីជាតិរបស់គាត់ឆ្លើយ ដែលសហមេធាវីជាតិគាត់បានលើកឡើងថា សំណើសុំឱ្យដោះលែងនេះផ្អែកលើអង្គហេតុដែលថា ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់ និងមិនស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតទេ ដោយសារគាត់បានធ្វើតាមបញ្ជារបស់ ប.ក.ក.[901]។

---

[893] សំណុំរឿង ០០១ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខដែលបានដាក់ដោយ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម២ និងក្រុម៣ ប្រឆាំងនឹងសេចក្ដីសម្រេចធ្វើឡើងដោយផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ E169/1/2 ទំព័រ ៤ (អង់គ្លេស)។

[894] សម្រាប់ព័ត៌មានបន្ថែមអំពីវិសោធនកម្មវិធានផ្ទៃក្នុង សូមមើល ជំពូក ៤.៤.៣។

[895] សូមមើល ប្រតិចារឹកទាំងអស់តាមលំដាប់លំដោយពីសំណុំរឿង ០០១ ប្រតិចារឹកថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ ឯកសារ E1/5.1 ដល់ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ E1/77.1។ ឌុច មិនបានថ្លែងទៅកាន់អង្គជំនុំជម្រះសាលាដំបូងនៅកាលបរិច្ឆេទខាងក្រោម៖ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩, ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩, ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៩, ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩, ថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៩, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩, ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩, ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩, ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩។

[896] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៥៣-៥៥ (អង់គ្លេស)។

[897] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៥៥-៥៦ (អង់គ្លេស)។

[898] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៥៦ (អង់គ្លេស)។

[899] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៥៩ (អង់គ្លេស)។

[900] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៦០ (អង់គ្លេស)។

[901] សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៦០-៦២ (អង់គ្លេស)។

បន្ទាប់មក ចៅក្រម Silvia Cartwright បានសួរថាតើ នេះមានន័យថា ឌុច បានស្នើសុំឱ្យរួចពិរុទ្ធភាព ឬយ៉ាងណា ហើយសហមេធាវីជាតិរបស់ ឌុច បានបញ្ជាក់ថា ឌុច ពិតជាបានស្នើសុំដូច្នេះមែន[902]។ ការណ៍នេះផ្ទុយទៅនឹងចម្លើយពីមុនដែលបានធ្វើឡើងនៅថ្ងៃនោះ ដោយសហមេធាវីអន្តរជាតិរបស់ ឌុច ដែលបានថ្លែងថា ឌុច មិនស្នើសុំឱ្យរួចពិរុទ្ធភាពនោះទេ ប៉ុន្តែបានស្នើសុំបន្ធូរបន្ថយទោសរបស់គាត់ ដើម្បីឱ្យគាត់បានមានសេរីភាពបន្ទាប់ពីសាលក្រម[903]។

### ៥.១.៥.៣. ការបណ្ដេញសហមេធាវីអន្តរជាតិ

នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ ពីរបីសប្ដាហ៍មុនការប្រកាសសាលក្រម ប្រធានផ្នែកគាំពារការការពារក្ដី បានប្រកាសថា គាត់បានទទួលសំណើពី ឌុច សុំឱ្យដកសហមេធាវីអន្តរជាតិរបស់គាត់ ដោយសារការបាត់បង់ភាពជឿជាក់លើការតំណាងរបស់គាត់[904]។ សំណើរនេះត្រូវបានទទួលយក ហើយការដកសហមេធាវីអន្តរជាតិនេះត្រូវបានជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០[905]។ សហមេធាវីអន្តរជាតិរបស់ ឌុច ត្រូវបានជំនួសដោយសហមេធាវីជាតិនៅខែសីហា ឆ្នាំ២០១០[906]។

### ៥.១.៥.៤. សាលក្រមអង្គជំនុំជម្រះសាលាដំបូង

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូង បានប្រកាស[907] និងបានចេញសាលក្រមសំណុំរឿង ០០១ ដោយផ្ដន្ទាទោស ឌុច ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[908]។ សាលក្រមមានកម្រាស់ ៤០៩ ទំព័រជាភាសាខ្មែរ ២៤៦ ទំព័រជាភាសាអង់គ្លេស និង ២៨៩ ទំព័រជាភាសាបារាំង ដោយមិនរាប់បញ្ចូលឧបសម្ព័ន្ធរបស់វា។ សាលក្រមនេះចែកជាប្រាំជំពូក៖

i. **ជំពូក ១** គឺជាសេចក្ដីផ្ដើម ដែលពិភាក្សាអំពីការបង្កើត អ.វ.ត.ក. សេចក្ដីសង្ខេបអំពីទិដ្ឋភាពទូទៅនៃរឿងក្ដី បទចោទប្រកាន់ប្រឆាំង ឌុច យុត្តាធិការលើរឿងក្ដី យុត្តាធិការក្នុងពេលវេលា និងយុត្តាធិការលើដែនដី គោលការណ៍នីត្យានុកូលភាព និងវិធានផ្ទៃក្នុង និងគោលការណ៍នៃភ័ស្ដុតាងជាធរមាន។ ទាក់ទងនឹងយុត្តាធិការលើរូបបុគ្គល អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា "នៅក្នុងអំឡុងពេលសវនាការបឋម មិនមានការលើកឡើងអំពីអញ្ញត្រកម្មចំពោះយុត្តាធិការរបស់ អ.វ.ត.ក." ទេ ប៉ុន្តែនៅក្នុងសេចក្ដីថ្លែងបិទកិច្ចពិភាក្សាដេញដោលរបស់ខ្លួន ឌុច បានធ្វើការសន្និដ្ឋានជាច្រើនចោទប្រកាន់អង្គជំនុំជម្រះថាគ្មានយុត្តាធិការ[909]។ អង្គជំនុំជម្រះលើកឡើងថា ខ្លួន "មិនចាត់ទុកសេចក្ដីសន្និដ្ឋាន ដែលបានលើកឡើងមិនទាន់ពេលវេលានោះ ថាជាអញ្ញត្រកម្មនោះទេ" និងមិនវិភាគបញ្ហាយុត្តាធិការលើរូបបុគ្គលបន្ថែមទៀតទេ[910]។

ii. **ជំពូក ២** បង្ហាញពីសំអាងហេតុ និងសំអាងច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង។ ជំពូកនេះគ្របដណ្ដប់បរិបទប្រវត្តិសាស្ត្រ និងជម្លោះប្រដាប់អាវុធ ទិដ្ឋភាពទូទៅនៃរយៈកាលកម្ពុជាប្រជាធិបតេយ្យ មន្ទីរស-២១ និងតួនាទីរបស់ ឌុច អង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តឡើងនៅ ស-២១ ច្បាប់ជាធរមាន និងសំអាងហេតុទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិច្បាប់ជាធរមាន និងសំអាងហេតុទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺ

---

902 សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៦២ (អង់គ្លេស)។

903 សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E1/82.1 ទំព័រ ៥២ (អង់គ្លេស)។

904 សំណុំរឿង ០០១ កម្មវត្ថុ៖ សំណើរបស់លោក កាំង ហ្កេកអ៊ាវ សុំដកសហមេធាវី Francois Roux ថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E186។

905 សំណុំរឿង ០០១ សេចក្ដីជូនដំណឹងពីការដកការតែងតាំងសហមេធាវីការពារក្ដី ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E186/1។

906 សំណុំរឿង ០០១ ការចាត់តាំងភារកិច្ចជាអចិន្ត្រៃយ៍ជូនលោក កង ឫទ្ធារី ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០១០ ឯកសារ E189.1។

907 សំណុំរឿង០០១ ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E1/83.1។

908 សំណុំរឿង ០០២/០២ ប្រតិចារក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E1/529.1។

909 សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ១៤។

910 សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ១៥។

ណែរ និងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់ ឌុច។ នៅក្នុងផ្នែករងទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល័ អង្គជំនុំជម្រះសាលាដំបូងពិភាក្សាលើទ្រឹស្តី JCE និង ម្យ៉ាងវិញទៀតលើបញ្ហាថាតើវាអាចអនុវត្តបាននៅ អ.វ.ត.ក. ឬទេ និងមួយវិញទៀត ថាតើវាអាចអនុវត្តបានក្នុងបរិបទសំណុំរឿង ០០១ ឬទេ[911] ដូចដែលបានតវ៉ាដោយសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលជំនុំជម្រះ[912]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា បញ្ហាជាបឋម ខ្លួនមិនជាប់កាតព្វកិច្ចត្រូវអនុវត្តតាមការកំណត់បទចោទប្រកាន់ ដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនោះទេ[913]។ ក្រោយមក អង្គជំនុំជម្រះបានពិភាក្សាលើទ្រឹស្តី JCE ដោយសន្និដ្ឋានថា ទ្រឹស្តី JCE មាននៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក.[914] និងបានសម្រេចថា JCE ជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩[915]។ អង្គជំនុំជម្រះសាលាដំបូងបានវិភាគលើការបង្កើត និងព្រឹត្តិការណ៍នៅ ស-២១ ក្នុងបរិបទ JCE និងជាលទ្ធផល បានរកឃើញថា ឌុច បានចូលរួមក្នុង JCE ទម្រង់ជាប្រព័ន្ធ នៅ ស-២១ ហេតុដូច្នេះ មានការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលតាមរយៈ JCE ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[916]។ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញទៀតថា ឌុច ទទួលខុសត្រូវចំពោះការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយ និងជំរុញ ឧក្រិដ្ឋកម្ម ដែលរូបគាត់ត្រូវបានផ្តន្ទាទោស និងថាគាត់ទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងនេះ ក្នុងនាមជាថ្នាក់លើ[917]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ការបង្កើតទម្រង់នៃការទទួលខុសត្រូវបន្ថែមទៀតនេះ មិននាំឱ្យមានការដាក់ពិរុទ្ធភាពត្រួតគ្នាទេ ប៉ុន្តែវាអាចជួយអង្គជំនុំជម្រះក្នុងដំណាក់កាលផ្តន្ទាទោស ក្នុងការបញ្ជាក់អំពីកម្រិតនៃការទទួលខុសត្រូវពេញលេញរបស់ ឌុច[918]។ ទាក់ទងនឹងការកំណត់ពិរុទ្ធភាពត្រួតគ្នា អង្គជំនុំជម្រះបានរកឃើញថា ការកំណត់ពិរុទ្ធភាពចំពោះការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចាំបាច់ត្រូវមានការបង្ហាញភស្តុតាងអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត ដែលឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញផ្អែកលើ (ពោលគឺ ការធ្វើមនុស្សឃាត ឬអំពើអមនុស្សធម៌ផ្សេងៗទៀត)។ ដូច្នេះ អង្គជំនុំជម្រះបានរកឃើញថា បទល្មើសទាំងនោះបានបញ្ចូលគ្នាជាមួយការកំណត់ពិរុទ្ធភាពផ្សេងទៀត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើការកំណត់ពិរុទ្ធភាពទាំងពីរនោះផ្អែកលើអំពើឧក្រិដ្ឋដូចគ្នា[919]។

iii. **ជំពូក ៣** ពិភាក្សាអំពីការផ្តន្ទាទោស។ ឌុច ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ ៣៥ ឆ្នាំ[920] ចៅក្រម Lavergne មានយោបល់ជំទាស់។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញជាឯកច្ឆន្ទថា ការបន្ថយទោសប្រាំឆ្នាំគឺសមស្រប ដែលជាលទ្ធផលនៃការរំលោភលើសិទ្ធិរបស់ ឌុច ដោយសារការឃុំខ្លួនគាត់ខុសច្បាប់ដោយតុលាការយោធាកម្ពុជា ចន្លោះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ និងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧[921]។ គាត់ក៏មានសិទ្ធិទទួលបានការទូទាត់ចំពោះពេលវេលាទាំងអស់ដែលគាត់បានចំណាយនៅក្នុងមន្ទីរឃុំឃាំង ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩

[911] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ជំពូក ២.៧.១.៣។
[912] សំណុំរឿង០០១ សំណើរបស់សហព្រះរាជអាជ្ញា សុំអោយអនុវត្តសហកម្មឧក្រិដ្ឋកម្មរួម ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E73។ សូមមើលផងដែរ សំណុំរឿង ០០១ ចម្លើយរបស់មេធាវីការពារក្តីចំពោះសំណើរសុំរបស់សហព្រះរាជអាជ្ញា ដែលស្នើឱ្យមានការអនុវត្តទៅលើរឿងក្តី នូវទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ E73/2។ អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់នៅក្នុងពេលសវនាការថា ខ្លួននឹងដោះស្រាយបញ្ហានេះនៅក្នុងសាលក្រម។ សំណុំរឿង ០០១ ប្រតិចារឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ឯកសារ E1/39.1 ទំព័រ ៨ (អង់គ្លេស)។
[913] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៤៩២។
[914] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥១១។
[915] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥១២។
[916] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥១២-៥១៦។
[917] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥១៨-៥៤៩។
[918] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥១៧។
[919] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៦៥។
[920] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៧៧, ៦៧៩។
[921] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៨០។

រហូតដល់កាលបរិច្ឆេទដែលសាលក្រមចូលជាស្ថាពរ ពោលគឺ រយៈពេល ១១ឆ្នាំ ២ខែ ១៧ថ្ងៃ នាពេលនោះ[922]។

iv. **ជំពូក ៤** ពិភាក្សាអំពីសំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូង បានវាយតម្លៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បដិសេធឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គលជាក់លាក់មួយចំនួន[923]។ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានអះអាងថាជាអ្នករស់រានមានជីវិតពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅ ស-២១ និង ស-២៤ អង្គជំនុំជម្រះបានបដិសេធពាក្យសុំចំនួនបួន ផ្អែកលើមូលដ្ឋានដែលថា ពួកគេមិនបានបង្ហាញ តាមបទដ្ឋានតម្រូវ ថាពួកគេត្រូវបានឃុំខ្លួន និងធ្វើបាប នៅក្នុងមន្ទីរសន្តិសុខណាមួយ ក្នុងចំណោមមន្ទីរសន្តិសុខទាំងពីរនេះ[924]។ អង្គជំនុំជម្រះសាលាដំបូងក៏បានបដិសេធផងដែរ ចំពោះពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៩ នាក់ ដែលមិនបានបង្ហាញ តាមបទដ្ឋានតម្រូវ ពីអត្ថិភាពនៃជនរងគ្រោះដោយផ្ទាល់ ឬចំណងពិសេសនៃសេចក្តីស្រឡាញ់ជាមួយនឹងជនរងគ្រោះ[925]។ បន្ទាប់មក អង្គជំនុំជម្រះបានវាយតម្លៃលើការទាមទារសំណង[926]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ខ្លួន "មានការលំបាកក្នុងការបំពេញភារកិច្ចរបស់ខ្លួនចំពោះសំណើសុំនៅចំពោះមុខអង្គជំនុំជម្រះ និងប្រភេទនៃសំណង ដែលអនុញ្ញាតស្របតាមវិធានផ្ទៃក្នុង"[927]។ អង្គជំនុំជម្រះបានចង្អុលបង្ហាញថា ខ្លួនមិនមានយុត្តាធិការលើអាជ្ញាធរកម្ពុជា ឬអាជ្ញាធរជាតិផ្សេងទៀត ឬស្ថាប័នអន្តរជាតិទេ ហើយខ្លួនក៏មិនអាចដាក់កាតព្វកិច្ចលើ ឬផ្តល់សិទ្ធិឱ្យ បុគ្គលណា ឬស្ថាប័នណា ដែលមិនមែនជាភាគីទៅនឹងកិច្ចដំណើរការនីតិវិធីចំពោះមុខខ្លួនបានដែរ[928]។ ដូច្នេះ ស្ថិតក្នុងការអនុញ្ញាតមានដែនកំណត់ អង្គជំនុំជម្រះសាលាដំបូងបានឯកភាពចងក្រង សេចក្តីថ្លែងសុំអភ័យទោស និងការទទួលស្គាល់ការទទួលខុសត្រូវ ទាំងអស់ ដែលបានធ្វើឡើងដោយជនជាប់ចោទ ក្នុងអំឡុងពេលជំនុំជម្រះ និងផ្សព្វផ្សាយការចងក្រងនេះនៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក. ក្នុងរយៈពេល ១៤ ថ្ងៃ នៅពេលដែលសាលក្រមចូលជាស្ថាពរ[929]។ អង្គជំនុំជម្រះក៏ឯកភាពបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតរបស់ពួកគេ ដែលបានស្លាប់នៅ ស-២១ នៅក្នុងសាលក្រមផងដែរ[930]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងបានបដិសេធ សំណើផ្សេងទៀតទាំងអស់ ដោយមូលហេតុនៅក្រៅវិសាលភាពរបស់ អ.វ.ត.ក. និងវិធានផ្ទៃក្នុងរបស់ខ្លួន ដោយមូលហេតុមិនមានភាពជាក់លាក់ ឬដោយសារសំណើទាំងនោះមិនអាចផ្តល់មូលដ្ឋានសម្រាប់ចេញដីកាបង្គាប់ដែលអាចអនុវត្តបាន[931]។

v. **ជំពូក ៥** រៀបរាប់អំពីផ្នែកសម្រេចសេចក្តី។ ឌុច ត្រូវបានរកឃើញថាមានពិរុទ្ធភាពចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលអង្គជំនុំជម្រះសាលាដំបូង បានរកឃើញថាត្រូវបានបញ្ចូលគ្នាជាមួយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការសម្លាប់រង្គាល (រួមបញ្ចូលការធ្វើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភលើផ្លូវភេទមួយករណីផងដែរ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ឌុច ក៏ត្រូវបានរកឃើញថាមានពិរុទ្ធភាពចំពោះការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវខាងក្រោមនេះផងដែរ៖ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាង

---

[922] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៨១។
[923] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៣៩-៦៥០។
[924] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៤៧។
[925] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៤៨-៦៤៩។
[926] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៥១-៦៧៥។
[927] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៦២។
[928] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៦៣។
[929] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៦៧-៦៦៨, ៦៨២-៦៨៣។ សូមមើល ផងដែរ សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៨។
[930] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៦៧។
[931] សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៦៨-៦៧៥។

កាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ និង ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ ចៅក្រម Jean-Marc Lavergne បានចេញយោបល់ជំទាស់ដោយឡែក ទៅនឹងសាលក្រមនេះ ទាក់ទងនឹងការកំណត់ទោស[932]។ គាត់យល់ឃើញថា ការផ្តន្ទាទោសជាប់ពន្ធនាគារ ៣៥ ឆ្នាំ គឺផ្ទុយទៅនឹងបទដ្ឋាននៃការផ្តន្ទាទោសដែលមាននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់កម្ពុជា ដែលច្បាប់ទាំងពីរនេះចែងថា ការផ្តន្ទាទោសណាមួយដែលលើសពី ៣០ ឆ្នាំ គឺជាការផ្តន្ទាទោសមួយជីវិត។ ដូច្នេះ ការផ្តន្ទាទោស ៣៥ ឆ្នាំ មិនត្រូវបានអនុញ្ញាតដោយច្បាប់ជាធរមាននោះទេ។ ជាងនេះទៀត គាត់យល់ឃើញថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" និងថា "វិធាន ២១(១) នៃវិធានផ្ទៃក្នុង ក៏បានចែងផងដែរថា ច្បាប់ អ.វ.ត.ក. និងវិធានផ្ទៃក្នុង ត្រូវតែបកស្រាយ ក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនជាប់ចោទ"។ ជាលទ្ធផល គាត់ប៉ាន់ពិចារណាថា អង្គជំនុំជម្រះសាលាដំបូងគួរណាផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារ ៣០ ឆ្នាំ[933]។

### ៥.១.៥.៥. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ

អង្គជំនុំជម្រះសាលាដំបូងមិនបានពិភាក្សា អញ្ញត្រកម្មរបស់ ឌុច ទាក់ទងនឹងបញ្ហាថាតើ មាត្រា ៣ (ថ្មី) អាចត្រូវបានអនុវត្ត បើទោះជាមានអត្ថិភាពអាជ្ញាយុកាល និងមិនបានកំណត់ពិរុទ្ធភាព ឌុច ចំពោះបទមនុស្សឃាតគិតទុកជាមុន ឬបទទារុណកម្ម ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដូចដែលបានកែប្រែដោយអង្គបុរេជំនុំជម្រះនោះទេ[934]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដាច់ដោយឡែកមួយ ដោះស្រាយបញ្ហានេះ នៅថ្ងៃដែលខ្លួនចេញសាលក្រមដែរ។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គបុរេជំនុំជម្រះ ក្នុងការបន្ថែមបទចោទប្រកាន់ នៃបទមនុស្សឃាតគិតទុកជាមុន និងបទទារុណកម្មទៅក្នុងដីកាដំណោះស្រាយ មិនបានពិចារណាលើផលប៉ះពាល់នៃចិរវេលានៃអាជ្ញាយុកាលទៅលើសមត្ថកិច្ចរបស់ អ.វ.ត.ក. ក្នុងការវិនិច្ឆ័យទោសឧក្រិដ្ឋកម្មទាំងនោះទេ ហើយដូច្នេះ បានកំណត់ថាខ្លួនត្រូវធ្វើការសម្រេច៖ (១) ថាតើចិរវេលានៃអាជ្ញាយុកាល ១០ ឆ្នាំ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ របស់កម្ពុជា ត្រូវបានផ្អាក់ ឬពន្យារ ដែរឬទេ ហើយប្រសិនបើដូច្នោះ ថាតើក្នុងរយៈពេលមួយណា និង (២) ថាតើការពន្យារចិរវេលានៃអាជ្ញាយុកាលនេះ ស្របទៅនឹងបទដ្ឋានជាតិ និងអន្តរជាតិដែរឬទេ ហើយប្រសិនបើចិរវេលានៃអាជ្ញាយុកាលបានផុតរលត់មុនពេល "ការពន្យារ" ចិរវេលានៃអាជ្ញាយុកាលរបស់វា ដោយមាត្រា ៣(ថ្មី) នោះ ថាតើអង្គជំនុំជម្រះអាចបកស្រាយមាត្រា ៣(ថ្មី) ថាជាបទប្បញ្ញត្តិដែលបង្កើតសាជាថ្មីនូវសិទ្ធិចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មតាមច្បាប់ជាតិបានដែរ ឬទេ[935]។

អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ចន្លោះឆ្នាំ១៩៧៥-១៩៧៩ មិនមានប្រព័ន្ធច្បាប់ ឬប្រព័ន្ធតុលាការ នៅក្នុងប្រទេសកម្ពុជាទេ ហើយដូច្នេះ មិនមានការស៊ើបអង្កេតព្រហ្មទណ្ឌ ឬការវិនិច្ឆ័យទោសអាចធ្វើទៅបាននាពេលនោះឡើយ ហេតុដូច្នេះចិរវេលានៃអាជ្ញាយុកាលមិនបានចាប់ផ្តើមក្នុងអំឡុងពេលនៃកាលបរិច្ឆេទទាំងនោះទេ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះមិនអាចឯកភាពលើបញ្ហាថាតើ ចិរវេលានៃអាជ្ញាយុកាលត្រូវបានពន្យារ ឬបានកាត់ផ្តាច់ នៅចន្លោះឆ្នាំ១៩៧៩-១៩៩៣ នោះឡើយ ហើយហេតុដូច្នេះ ថាតើចិរវេលានោះបានផុតរលត់នៅពេលដែលមាត្រា ៣ និង មាត្រា ៣(ថ្មី) ត្រូវបានប្រកាសឱ្យប្រើ ឬយ៉ាងណា[936]។

---

[932] សំណុំរឿង ០០១ មតិជំទាស់របស់ចៅក្រម Jean-Marc LAVERGNE ពាក់ព័ន្ធទៅនឹងការកំណត់ទោស ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188.1។ វិសាលភាពនៃមតិជំទាស់របស់ចៅក្រម Lavergne មិនពាក់ព័ន្ធនឹងការវាយតម្លៃរបស់សាលក្រមលើពិរុទ្ធភាពរបស់ ឌុច ទេ លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ឬស្ថានទម្ងន់ទោស ឬស្ថានសម្រាលទោស ដែលត្រូវអនុវត្តឡើយ៖ "អង្គជំនុំជម្រះបានសម្រេចដោយសំឡេងឯកច្ឆន្ទរួចមកហើយ"។

[933] សំណុំរឿង ០០១ មតិជំទាស់របស់ចៅក្រម Jean-Marc LAVERGNE ពាក់ព័ន្ធទៅនឹងការកំណត់ទោស ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188.1 កថាខណ្ឌ ២-៤, ៨-៩។

[934] សូមមើល សំណុំរឿង០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៧៨។

[935] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ៨។

[936] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ១៤។

ចៅក្រមជាតិយល់ឃើញថា ចិរវេលានៃអាជ្ញាយុកាលបានចាប់ផ្តើមរាប់ដំបូងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ នៅពេលដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើង[937] ចំណែកចៅក្រមអន្តរជាតិយល់ឃើញថា ទោះបីជាសមត្ថភាពតុលាការនៅមានកំម្រិតក្រោយរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏មិនមានការបញ្ជាក់ភ័ស្តុតាងណាឱ្យដល់កម្រិតបទដ្ឋានតម្រូវ អំពីអសមត្ថភាពនៃប្រព័ន្ធច្បាប់ ក្នុងការធ្វើការស៊ើបអង្កេត និងវិនិច្ឆ័យទោស នៅរយៈពេលក្រោយរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ[938]។ ចៅក្រមជាតិយល់ឃើញថា មាត្រា ៣ និងមាត្រា ៣(ថ្មី) អាចពន្យារចិរវេលានៃអាជ្ញាយុកាលយ៉ាងត្រឹមត្រូវ[939] ចំណែកចៅក្រមអន្តរជាតិមិនបានឈានដល់ការសន្និដ្ឋានស្រដៀងគ្នានេះឡើយ[940]។ អវត្តមានសំឡេងគាំទ្រភាគច្រើនលើសលប់ពីចៅក្រមបួនរូប លើបញ្ហានេះ មានន័យថាអង្គជំនុំជម្រះសាលាដំបូងមិនអាចពិចារណាលើពិរុទ្ធភាព ឬភាពគ្មានពិរុទ្ធរបស់ ឌុច ទាក់ទងនឹងឧក្រិដ្ឋកម្មតាមច្បាប់ជាតិ នៃបទមនុស្សឃាតគិតទុកជាមុន ឬបទទារុណកម្មបានទេ[941]។ ទោះជាយ៉ាងណា ចៅក្រមអន្តរជាតិបានបញ្ជាក់ថា បញ្ហានេះ “មិនមានផលប៉ះពាល់ដល់ការវាយតម្លៃរបស់អង្គជំនុំជម្រះចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុងរបស់ជនជាប់ចោទ ឬការផ្តន្ទាទោសជាចុងក្រោយនោះទេ”[942]។

### ៥.១.៦. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះតុលាការកំពូល

### ៥.១.៦.១. បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម

សហព្រះរាជអាជ្ញា[943] ឌុច[944] និង ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១[945] ក្រុម២[946] និងក្រុម៣[947] បានប្តឹងសាទុក្ខលើសាលក្រម។

---

[937] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ២៥។

[938] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ២៧-៣៥។

[939] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ៣៦-៣៨។

[940] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ៣៩-៥៤។

[941] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ៦៥។

[942] សំណុំរឿង ០០១ សេចក្តីសម្រេចស្តីពីអញ្ញត្រកម្ម ទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E187 កថាខណ្ឌ ៥៥។

[943] សំណុំរឿង ០០១ សេចក្តីជូនដំណឹងរបស់ ឌុច អំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/2។ សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ក.ស.ព. ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ឯកសារ ។

[944] សំណុំរឿង ០០១ សេចក្តីជូនដំណឹងរបស់ ឌុច អំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/8។ សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ឌុច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F14។

[945] សំណុំរឿង ០០១ បណ្តឹងសាទុក្ខជាបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ F8។ សំណុំរឿង ០០១ សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំពោះសេចក្តីជូនដំណឹងអំពីគោលបំណង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ ឯកសារ F12។

[946] សំណុំរឿង ០០១ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី២) ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/6។ សំណុំរឿង ០០១ សេចក្តីជូនដំណឹងពីបណ្តឹងសារទុក្ខ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) និងបណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ E188/12។ សំណុំរឿង ០០១ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី២) លើសាលក្រមទាក់ទិននឹងសំណង ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ E188/14។ សំណុំរឿង ០០១ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ៖ បណ្តឹងសារទុក្ខប្រឆាំងនឹងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសាលក្រម ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ឯកសារ F11។ សំណុំរឿង ០០១ បណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមស្តីពីសំណងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី -ក្រុម២ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F13។

[947] សំណុំរឿង ០០១ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី៣) ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/4។ សំណុំរឿង ០០១ បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមចេញថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០១០ ឯកសារ F9។

សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល (១) ដំឡើងការផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារមួយជីវិត (២) ធ្វើការកំណត់ពិរុទ្ធភាពដាច់ដោយឡែកនូវបទចោទប្រកាន់ទាំងអស់ ដែលបានបញ្ជាក់ប្រឆាំងនឹង ឌុច និង (៣) ធ្វើការកំណត់ពិរុទ្ធភាពទទួលស្គាល់ការធ្វើឱ្យទៅជាទាសករលើអ្នកជាប់ឃុំមួយចំនួនធំនៅ ស-២១[948]។

ទាក់ទងនឹងការផ្តន្ទាទោស សហព្រះរាជអាជ្ញាបានតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងបានខកខានក្នុងការពិចារណាលើក្របខ័ណ្ឌផ្តន្ទាទោសអន្តរជាតិ និងក្នុងការថ្លឹងថ្លែងឱ្យបានត្រឹមត្រូវលើស្ថានទម្ងន់ទោស ខណៈដែលផ្តល់ទម្ងន់ច្រើនជាងទៅលើស្ថានសម្រាលទោស[949]។ សហព្រះរាជអាជ្ញាបានអះអាងថា ការផ្តន្ទាទោសណាដែលតិចជាងទោសជាប់ពន្ធនាគារអស់មួយជីវិត នឹងមិនឆ្លុះបញ្ចាំងគ្រប់គ្រាន់ដល់កំហឹងរបស់សហគមន៍ជាតិ និងអន្តរជាតិ ក្នុងទិដ្ឋភាពនៃអំពើឧក្រិដ្ឋទាំងឡាយរបស់ ឌុច និងមិនទប់ស្កាត់មិនឱ្យប្រព្រឹត្តបទឧក្រិដ្ឋទាំងឡាយដែលមានលក្ខណៈស្រដៀងគ្នានេះ នាពេលអនាគតនោះទេ[950]។

ពាក់ព័ន្ធទៅនឹងការកំណត់ពិរុទ្ធភាពត្រួតគ្នា សហព្រះរាជអាជ្ញាបានតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការកំណត់ពិរុទ្ធភាព ឌុច ចំពោះ៖ (១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយស្របបញ្ចូលឧក្រិដ្ឋកម្មទាំងអស់នោះក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង (២) ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្ម នៅពេលខ្លួនកំណត់បទល្មើសការរំលោភសេពសន្ថវៈថាជាការធ្វើទារុណកម្ម[951]។

ពាក់ព័ន្ធទៅនឹងការធ្វើឱ្យទៅជាទាសករ សហព្រះរាជអាជ្ញាបានតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅពេលដែលខ្លួនបានប្រើនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើឱ្យទៅជាទាសករ ដែលតម្រូវឱ្យមានពលកម្មជាធាតុផ្សំសំខាន់[952] និងជាលទ្ធផលខកខានក្នុងការកំណត់ពិរុទ្ធភាព ឌុច ចំពោះការធ្វើឱ្យទៅជាទាសករនៃអ្នកទោសនៅ ស-២១ ដែលមិនស្ថិតក្រោមពលកម្មដោយបង្ខំ[953]។

ឌុច បានលើកឡើងមូលដ្ឋានបណ្តឹងសាទុក្ខជាក់លាក់ ទាក់ទងនឹងយុត្តាធិការ (បុគ្គល)[954] និងបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការពិចារណាលើភ័ស្តុតាង ដែលបង្ហាញថាគាត់មិនមានអំណាចធ្វើការសម្រេចចិត្តដោយផ្ទាល់[955]។ គាត់បានតវ៉ាទៀតថា ការផ្តន្ទាទោសដែលបានកំណត់គឺធ្វើឡើងមិនត្រឹមត្រូវ និងមិនផ្អែកលើគោលការណ៍ច្បាប់កម្ពុជា[956]។ ជាលទ្ធផល គាត់បានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យបដិសេធសាលក្រមអង្គជំនុំជម្រះសាលាដំបូង និងសម្រេចថាគាត់គ្មានពិរុទ្ធភាព[957]។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានប្តឹងសាទុក្ខ និងបានស្នើសុំឱ្យតម្កល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញដល់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ១ ដែលត្រូវបានដកហូតដោយសាលក្រម។ ពួកគេបានអះអាងថា នៅពេលដែលឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលស្គាល់ហើយនោះ វាគួរតែត្រូវរក្សាទុករហូត លុះត្រាតែ "មានការបង្ហាញភ័ស្តុតាងជាក់លាក់ និងច្បាស់លាស់ ដែលបង្កឱ្យមានភាពសង្ស័យអំពីឋានៈនោះ"[958]។

---

[948] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ក.ស.ព. ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ឯកសារ F10 កថាខណ្ឌ ៨-១០។
[949] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ក.ស.ព. ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ឯកសារ F10 កថាខណ្ឌ ៨។
[950] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ក.ស.ព. ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ឯកសារ F10 កថាខណ្ឌ ១២១។
[951] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ក.ស.ព. ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ឯកសារ F10 កថាខណ្ឌ ៩។
[952] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ក.ស.ព. ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ឯកសារ F10 កថាខណ្ឌ ១០។
[953] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ក.ស.ព. ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ឯកសារ F10 កថាខណ្ឌ ២០៩។
[954] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ឌុច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F14 កថាខណ្ឌ ១១-៦៥, ៦៦-៧១។
[955] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ឌុច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F14 កថាខណ្ឌ ៧២-៩០។
[956] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ឌុច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F14 កថាខណ្ឌ ៩១-៩២។
[957] សំណុំរឿង ០០១ បណ្តឹងសាទុក្ខរបស់ ឌុច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F14 កថាខណ្ឌ ១០១។
[958] សំណុំរឿង ០០១ បណ្តឹងសាទុក្ខជាបន្ទាន់របស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ F8 កថាខណ្ឌ ១។ បើទោះជាបានដាក់ក្នុងនាមជាបណ្តឹងសាទុក្ខភ្លាមៗ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធមូល

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម២ បានដាក់បណ្តឹងសាទុក្ខស្រដៀងគ្នានេះ ស្នើសុំតម្កល់ឡើងវិញនូវឋានៈរបស់ខ្លួន ដែលត្រូវបានដកហូតដោយអង្គជំនុំជម្រះសាលាដំបូង[959]។ ក្រុមនេះក៏បានប្តឹងសាទុក្ខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ ទាក់ទងទៅនឹងការលុបឈ្មោះប្អូនស្រីថ្លៃរបស់គាត់ និងកូនរបស់នាង នៅក្នុងសាលក្រម[960]។ ជាចុងក្រោយ ក្រុម២ បានដាក់បណ្តឹងសាទុក្ខស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យច្រានចោលការបដិសេធសំណើសុំសំណង និងសុំឱ្យផ្តល់សំណងទាំងអស់ដែលបានស្នើសុំដោយក្រុម២[961] ផ្អែកលើមូលដ្ឋានដែលថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់សម្រាប់បដិសេធសំណើសុំសំណងជាច្រើន[962]។

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ បានប្តឹងសាទុក្ខសាលក្រម ផ្អែកលើមូលដ្ឋានចំនួនប្រាំ។ ពួកគេអះអាងថា អង្គជំនុំជម្រះសាលាដំបូង៖ (១) បានរំលោភលើវិធានផ្ទៃក្នុង និងការអនុវត្តរបស់សាលាក្តីអន្តរជាតិផ្សេងទៀត ដោយការបដិសេធឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ (២) មានកំហុសក្នុងអនុវត្តបទដ្ឋាន និងលក្ខណៈវិនិច្ឆ័យសមស្រប សម្រាប់ការផ្តល់ព័ត៌មានក្នុងវិធាននៃភ័ស្តុតាង ដូច្នេះ បានធ្វើឱ្យការបដិសេធឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីទៅជាគ្មានសុពលភាព (៣) បានផ្អែកលើការបកស្រាយមិនត្រឹមត្រូវលើវិធាន ២៣(២) ដែលមិនតម្រូវឱ្យមានការបញ្ជាក់ភ័ស្តុតាងអំពី “ចំណងពិសេសនៃសេចក្តីស្រឡាញ់” និងថា អង្គជំនុំជម្រះមានកំហុសក្នុងការសន្និដ្ឋានថា មិនមានភាពជាសាច់ញាតិ ឬចំណងនៃសេចក្តីស្រឡាញ់កើតមានសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន (៤) មានកំហុសអង្គហេតុ ក្នុងការបដិសេធមិនទទួលយកដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និង (៥) បកស្រាយមិនត្រឹមត្រូវនូវវិធាន ២៣(២) ស្តីពីសំណងផ្លូវចិត្ត និងសំណងសមូហភាព[963]។

---

ដ្ឋាននីតិវិធី ដែលបណ្តឹងសាទុក្ខបានដាក់ និងបានសម្រេចកំណត់ប្រភេទបណ្តឹងសាទុក្ខនេះថាជា សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខវិញ និងសារណាបណ្តឹងសាទុក្ខ ហើយបន្ទាប់មកបានអនុញ្ញាតឱ្យសហមេធាវីក្រុម ១ ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខបន្ថែម និងសារណាបណ្តឹងសាទុក្ខបន្ថែម លើបញ្ហាណាមួយផ្សេងទៀត។ សូមមើល សំណុំរឿង ០០១ សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ចំពោះសេចក្តីជូនដំណឹងអំពីគោលបំណង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០ ឯកសារ F12 កថាខណ្ឌ ១-៤។

[959] សំណុំរឿង ០០១ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី២) ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/6។

[960] សំណុំរឿង ០០១ សេចក្តីជូនដំណឹងពីបណ្តឹងសារទុក្ខ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ E188/12 កថាខណ្ឌ ២។

[961] សំណុំរឿង ០០១ សេចក្តីជូនដំណឹងពីបណ្តឹងសារទុក្ខ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ E188/12 កថាខណ្ឌ ៩។ សំណុំរឿង ០០១ បណ្តឹងសារទុក្ខប្រឆាំងនឹងសាលក្រមស្តីពីសំណងដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី -ក្រុម២ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ F13។

[962] សំណុំរឿង ០០១ សេចក្តីជូនដំណឹងពីបណ្តឹងសារទុក្ខ របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី (ក្រុម២) ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ E188/12 កថាខណ្ឌ ១។

[963] សំណុំរឿង ០០១ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ក្រុមទី៣) ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១០ ឯកសារ E188/4 កថាខណ្ឌ ៩-១៦។ សូមមើលផងដែរ សំណុំរឿង ០០១ បណ្តឹងសាទុក្ខ របស់សហមេធាវីក្រុម ៣ ឯកសារ F9។ ដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ក៏បានដាក់សារណាបន្ថែម ទាក់ទងទៅនឹងសំណងជាសមូហភាពសម្រាប់ជនរងគ្រោះទាំងអស់នៃសំណុំរឿង ០០១។ សូមមើល សំណុំរឿង ០០១ សារណាបន្ថែមស្តីពីសំណងរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ឯកសារ F25។ សំណើសុំសំណងជាសមូហភាពត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសារណាបន្ថែមនេះ និងបង្កើតបានជាសំណើសុំសាងសង់គ្រឹះស្ថានចារឹកឈ្មោះជនរងគ្រោះនៃមន្ទីរ ស-២១ នៅក្នុងបរិវេណនៃសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។ សូមមើល សំណុំរឿង ០០១ សហមេធាវីក្រុម ៣ សំណើរបស់សមាគមជនរងគ្រោះក្បែមក្សាន្ត សុំសាងសង់គ្រឹះស្ថានចារឹកឈ្មោះជនរងគ្រោះនៃមន្ទីរ ស-២១ នៅក្នុងបរិវេណនៃសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១១ ឯកសារ F25.1។

### ៥.១.៦.២. សាលដីកាលើបណ្តឹងសាទុក្ខ

សវនាការលើបណ្តឹងសាទុក្ខបានធ្វើឡើងរយៈពេលបីថ្ងៃ ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១១[964]។ សាលដីកាត្រូវបានប្រកាស[965] និងចេញនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២[966]។ សាលដីកានេះចែកជាប្រាំបួនជំពូក។

i. **ជំពូក ១** គឺជាសេចក្តីផ្តើម ដែលពិភាក្សាអំពីសាវតារ និងផ្តល់នូវប្រវត្តិនីតិវិធី។
ii. **ជំពូក ២** ពិភាក្សាអំពីបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខ។
iii. **ជំពូក ៣** ពិភាក្សាអំពីកំហុសដែលបានលើកឡើងទាក់ទងទៅនឹងយុត្តាធិការលើរូបបុគ្គល។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដែលថា បណ្តឹងសាទុក្ខរបស់ ឌុច លើបញ្ហាយុត្តាធិការលើរូបបុគ្គលមិនអាចទទួលយកបាន[967]។ អង្គជំនុំជម្រះតុលាការកំពូលបានវាយតម្លៃឃ្លា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដើម្បីកំណត់ថាតើ ទាំងអស់ ឬមួយផ្នែកនៃឃ្លានេះ បង្កើតបានជាលក្ខខណ្ឌតម្រូវយុត្តាធិការ របស់ អ.វ.ត.ក.[968]។ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យប្រវត្តិនៃការចរចាទាក់ទងនឹងគោលដៅដែលបានកំណត់ ដើម្បីធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋ នៅចំពោះមុខ អ.វ.ត.ក.[969] និងបានរកឃើញថា ជាអប្បបរមា៖

> ពាក្យថា "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" បានឆ្លុះបញ្ចាំងនូវគោលបំណងរបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលផ្តុំធនធានដែលមានកម្រិត ដើម្បីធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មទៅលើកម្មាភិបាលខ្មែរក្រហមមួយចំនួន ដែលនៅរស់រានមានជីវិត។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញផងដែរថា ពាក្យពេចន៍នេះមិនរាប់បញ្ចូលនូវបុគ្គលទាំងឡាយណា ដែលមិនមែនជាកម្មាភិបាលខ្មែរក្រហមនោះទេ[970]។

ចំពោះបញ្ហាថាតើ ពាក្យនេះសំដៅលើប្រភេទទីមួយ ឬប្រភេទទីពីរនៃកម្មាភិបាលខ្មែរក្រហមដែលនៅរស់រានមានជីវិត ឬយ៉ាងណានោះ អង្គជំនុំជម្រះយល់ឃើញថា ប្រវត្តិនៃការរៀបចំសេចក្តីព្រាងបង្ហាញថាវាសំដៅទៅលើកម្មាភិបាលខ្មែរក្រហមពីរប្រភេទ មួយជាមេដឹកនាំជាន់ខ្ពស់ ដែលស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត និងមួយក្រុមទៀតជាអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ដែលស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត[971]។ បន្ទាប់មកអង្គជំនុំជម្រះបានពិចារណាថាតើ ពាក្យទាំងបី "កម្មាភិបាលខ្មែរក្រហម" "ទទួលខុសត្រូវខ្ពស់បំផុត" និង "មេដឹកនាំជាន់ខ្ពស់" គឺជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការ ឬទេ។ អង្គជំនុំជម្រះបានសន្និដ្ឋានថា យុត្តាធិការលើរូបបុគ្គលនៃ អ.វ.ត.ក. គ្របដណ្តប់លើពាក្យ "កម្មាភិបាលខ្មែរក្រហម" និងថាបញ្ហាចោទថាតើ ជនជាប់ចោទគឺជាកម្មាភិបាលខ្មែរក្រហមម្នាក់ឬទេនោះ មានយុត្តិកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ចំពោះពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា "ការបកស្រាយពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ថាជាលក្ខខណ្ឌតម្រូវផ្នែក

---

964 សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ឯកសារ F1/2.1។ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១១ ឯកសារ F1/3.2។ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ឯកសារ F1/4.1។ មុនពេលសវនាការលើបណ្តឹងសាទុក្ខ អង្គជំនុំជម្រះតុលាការកំពូល បានបើកកិច្ចប្រជុំរៀបចំសវនាការជាសម្ងាត់ ជាមួយមេធាវីនៃម្ចាស់បណ្តឹងសាទុក្ខម្នាក់ៗ ដើម្បីឱ្យមានការពិភាក្សារវាងសហព្រះរាជអាជ្ញា និងសហមេធាវី ដើម្បីជួយសម្រួលដល់ការកំណត់កាលបរិច្ឆេទបើកសវនាការ និងដើម្បីពិនិត្យស្ថានភាពរឿងក្តី និងបញ្ហាដែលអាចមាន។ សំណុំរឿង ០០១ ប្រតិចារឹក ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ឯកសារ F1/1.1 ទំព័រ ១ (អង់គ្លេស)។

965 សំណុំរឿង០០១ ប្រតិចារឹក ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F1/5.1។

966 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28។

967 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៨, ៤៣។

968 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៤៤។

969 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៤៦-៥១។

970 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ៥២។

971 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៥៧។

យុត្តាធិការរបស់ អ.វ.ត.ក. នឹងផ្ទុយទៅនឹងកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ហើយការបកស្រាយបែបនេះអាចនាំឱ្យមានលទ្ធផលមួយមិនសមស្រប” ពីព្រោះពុំមានវិធីសាស្ត្រជាសត្យានុម័តសម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច និងធ្វើការកំណត់ចំណាត់ថ្នាក់ នៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាងនេះទៀតសញ្ញាណនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលយកមកប្រៀបធៀបគ្នានេះ គឺផ្ទុយទៅនឹងមាត្រា ២៩ ដែលចែងអំពីគោលការណ៍ដែលថា បញ្ជារបស់ថ្នាក់លើមិនបង្កើតបានជាមធ្យោបាយការពារឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ។ ការកំណត់ថាតើ ជនជាប់ចោទគឺជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” តម្រូវឱ្យមានឆន្ទានុសិទ្ធិទូលំទូលាយ និងមិនមានឆន្ទានុសិទ្ធិក្នុងការកំណត់ប្រភេទយុត្តាធិការផ្សេងទៀតរបស់ អ.វ.ត.ក. ដែលត្រូវបានចែងតាមរយៈនិយមន័យច្បាស់លាស់។ ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូល បានសន្និដ្ឋានថា ពាក្យ “អ្នកទទួលខុសត្រូវខ្ពស់បំផុត” គួរត្រូវបានបកស្រាយថាជា “គោលការណ៍ណែនាំនៃការចោទប្រកាន់ និងការស៊ើបអង្កេតសម្រាប់សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ដែលមិនអាចធ្វើការវិនិច្ឆ័យនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ”[972]។ ជាចុងក្រោយ ចំពោះពាក្យ “មេដឹកនាំជាន់ខ្ពស់” វិញ អង្គជំនុំជម្រះតុលាការកំពូលក៏សន្និដ្ឋានផងដែរថា ដោយសារតែភាពបត់បែនដែលមានជាប់មកជាមួយរបស់វា ចំពោះថាតើមនុស្សប្រភេទមួយណាដែលអាចរាប់បញ្ចូលនោះ ពាក្យនេះមិនដំណើរការជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ[973]។ ពាក្យនេះក៏ត្រូវបានរៀបរាប់ថាជា “គោលការណ៍ណែនាំនៃការចោទប្រកាន់ និងការស៊ើបអង្កេត” ផងដែរ ដើម្បីណែនាំសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា “ក្នុងការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងវិសាលភាពនៃការចោទប្រកាន់ និងការស៊ើបអង្កេត”[974]។

iv. **ជំពូក ៤** ពីភាក្យអំពីកំហុសដែលបានលើកឡើង ទាក់ទងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ជាដំបូង អង្គជំនុំជម្រះបានពិចារណា*តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* លើគោលការណ៍នីត្យានុកូលភាព[975]។ អង្គជំនុំជម្រះបានវាយតម្លៃថាតើ ការពឹងផ្អែករបស់អង្គជំនុំជម្រះសាលាដំបូងលើយុត្តិសាស្ត្ររបស់តុលាការ*មិនអចិន្ត្រៃយ៍*ត្រឹមត្រូវដែរ ឬទេ និងបានពិចារណាលើវិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក. លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងបរិបទនៃគោលការណ៍នីត្យានុកូលភាពអន្តរជាតិ[976]។ អង្គជំនុំជម្រះបានឯកភាពជាមួយអង្គជំនុំជម្រះសាលាដំបូង “ថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មអន្តរជាតិ ស្ថិតក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក.”[977]។

អង្គជំនុំជម្រះតុលាការកំពូលបន្ទាប់មកបានត្រឡប់ទៅពិនិត្យលើបញ្ហាថាតើ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញ ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងការធ្វើឱ្យទៅជាទាសករ ដែលមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក. បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥ ដែរ ឬទេ[978]។

ទាក់ទងទៅនឹងការធ្វើឱ្យទៅជាទាសករ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា “ការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា និយមន័យនៃការធ្វើឱ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ របស់អង្គជំនុំជម្រះសាលាដំបូង ដែលតម្រូវឱ្យមានភស្តុតាងបញ្ជាក់អំពីពលកម្មដោយបង្ខំនោះ ពុំមានមូលដ្ឋានត្រឹមត្រូវ នោះទេ”[979]។ យោងតាមយុត្តិសាស្ត្រអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រនិយមន័យរបស់អង្គជំនុំជម្រះសាលាដំបូង នៃអំពើធ្វើឱ្យទៅជាទាសករ

[972] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦១-៦៣។
[973] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៧៦។
[974] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៧៨។
[975] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៨៧-៩៧។
[976] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៩៨-៩៨។
[977] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១០៤។
[978] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១០៧។
[979] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១២៩។

ដោយមាន*ធាតុផ្សំសត្យានុម័ត*នៃអំពើធ្វើឱ្យទៅជាទាសករ “ដែលត្រូវបានកំណត់ចរិតលក្ខណៈតាមរយៈការប្រើអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស” និង*ធាតុផ្សំអត្តនោម័ត*ដែលជាការប្រើប្រាស់ដោយចេតនានូវ “អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស”[980]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការពឹងផ្អែករបស់អង្គជំនុំជម្រះសាលាដំបូងលើការជិះជាន់កម្លាំងពលកម្មថាជាការសន្មតលើការរកឃើញនៃអំពើធ្វើឱ្យទៅជាទាសករ មានន័យថាអង្គជំនុំជម្រះសាលាដំបូងកំពុងពិចារណាលើ ធាតុផ្សំនៃការខិតខំប្រឹងប្រែងក្នុងការបង្កើនផលចំណេញតាមរយៈការប្រើប្រាស់អំណាចទាំងឡាយ ក្នុងនាមជាម្ចាស់លើជនរងគ្រោះ ដែលអង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា មិនមែនជាធាតុផ្សំបន្ថែមនៃបទឧក្រិដ្ឋនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺជាគោលបំណងដោយប្រយោល តាមរយៈការប្រើអំណាចក្នុងនាមជាម្ចាស់[981]។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការខកខានមិនបានរកឃើញថា ឌុច មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើឱ្យទៅជាទាសករ ឬទេ ហើយបានសន្និដ្ឋានថាអង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសទេ[982]។

ទាក់ទងនឹងការរំលោភលើផ្លូវភេទវិញ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា “ការសង្កេតស្រាវជ្រាវពីទំនៀមទម្លាប់ និងសន្ធិសញ្ញានានា ដែលមានពីមុន និងក្នុងដែនកំណត់យុត្តាធិការពេលវេលារបស់ អ.វ.ត.ក. បង្ហាញថា ការរំលោភលើផ្លូវភេទមិនមែនជាបទល្មើសមួយដាច់ដោយឡែកនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ យោងតាមប្រភពនានានៃច្បាប់អន្តរជាតិ ក្នុងពេលនោះ”[983]។ ហេតុដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ក្នុងការសន្និដ្ឋានថា ការរំលោភលើផ្លូវភេទ ដែលកើតមានឡើងនៅ ស-២១ បង្កើតបានជាការរំលោភលើផ្លូវភេទដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបានបដិសេធផ្នែកនេះនៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដែលអះអាងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការខកខានមិនកំណត់ពិរុទ្ធភាពត្រួតគ្នាលើ ឌុច ចំពោះការរំលោភលើផ្លូវភេទ និងការធ្វើទារុណកម្មដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក ដែលបានកើតឡើងនៅ ស-២១[984]។

ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា “ត្រឹមឆ្នាំ១៩៧៥ មានភស្តុតាងបង្ហាញយ៉ាងច្បាស់អំពី*ទស្សនៈច្បាប់* និងការអនុវត្តរបស់រដ្ឋ ក្នុងការទទួលស្គាល់ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ សាសនា ឬនយោបាយ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ”[985]។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើនិយមន័យ នៃការធ្វើទុក្ខបុកម្នេញ ដោយបានសន្និដ្ឋានថា៖

> ការកំណត់របស់អង្គជំនុំជម្រះសាលាដំបូង អំពីនិយមន័យនៃការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រឹមឆ្នាំ១៩៧៥ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនមានកំហុសនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសត្រង់ផ្នែកខ្លះ នៅក្នុងការបកស្រាយរបស់ខ្លួន អំពីលក្ខខណ្ឌតម្រូវនៃការរើសអើងជាក់ស្តែងក្រោមធាតុផ្សំ*សត្យានុម័ត* នៃការធ្វើទុក្ខបុកម្នេញ[986]។

អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធ ការកំណត់ពិរុទ្ធភាពរបស់អង្គជំនុំជម្រះសាលាដំបូងលើ ឌុច ពីបទធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពាក់ព័ន្ធនឹងបុគ្គលមិនជាក់លាក់

---

980 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១៥២។
981 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១៥៨។
982 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១៦៦។
983 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១៨០។
984 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ១៨៣។
985 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២២៥។
986 សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២៣៨។

មួយចំនួន ដែលបានជាប់ឃុំ សួរចម្លើយ ធ្វើឱ្យទៅជាទាសករ និងសម្លាប់នៅ ស-២១ មិនមែនដោយមូលហេតុនយោបាយទេ ប៉ុន្តែជាលទ្ធផលនៃការកំណត់គោលដៅមិនរើសមុខ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល ធ្វើការកំណត់ពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងៗទៀត ដែលបានប្រព្រឹត្តប្រឆាំងពួកគេ ដែលអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ឌុច ទទួលខុសត្រូវ ពោលគឺការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត[987]។

ចំពោះបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុស ឬអត់ ក្នុងការខកខានមិនកំណត់ពិរុទ្ធភាពត្រួតគ្នាលើ ឌុច ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ ដែលជាចុងក្រោយគាត់ត្រូវបានរកឃើញថាទទួលខុសត្រូវនោះ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិផ្សេងទៀតបាន "អនុញ្ញាតឱ្យមានការចោទប្រកាន់ត្រួតគ្នា ហើយសម្រេចដាក់ពិរុទ្ធភាពពីបទល្មើសត្រួតគ្នា (ពិរុទ្ធភាពត្រួតគ្នា) ចំពោះអំពើដូចគ្នា ដែលអំពើនេះស្របតាមនិយមន័យនៃបទល្មើសអន្តរជាតិច្រើនដែលបទល្មើសទាំងនេះត្រូវបានយល់ឃើញថា មានលក្ខណៈខុសៗគ្នាជាសត្យានុម័ត"[988]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ការអនុវត្តត្រឹមត្រូវនៃលក្ខណៈវិនិច្ឆ័យនោះ នឹងនាំទៅរកការសន្និដ្ឋានថា ឌុច គប្បីត្រូវបានកំណត់ពិរុទ្ធភាពត្រួតគ្នាសម្រាប់បទឧក្រិដ្ឋនៃការសម្លាប់រង្គាល (រួមបញ្ចូលអំពើមនុស្សឃាត) ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត និងការធ្វើទុក្ខបុកម្នេញ ដោយសារតែបទល្មើសនីមួយៗដែលបានចោទប្រកាន់ មានធាតុផ្សំដាច់ដោយឡែកពីគ្នាជាសត្យានុម័ត ដែលមិនមាននៅក្នុងបទល្មើសផ្សេងទៀត[989]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គង តាមរយៈការស្របបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត នៅក្រោមការធ្វើទុក្ខបុកម្នេញ និងបានបង្គាប់ឱ្យកំណត់ពិរុទ្ធភាពដោយឡែកចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត[990]។

v. **ជំពូក ៥** ពិភាក្សាអំពីការលើកឡើងអំពីកំហុសទាក់ទងទៅនឹងការប្រកាសទោស។

ដំបូង អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើច្បាប់ជាធរមាន និងបានបដិសេធទឡ្ហីករណ៍របស់ ឌុច ដែលថាការផ្តន្ទាទោសគប្បីកំណត់ត្រឹមអ្វីដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩[991]។

បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូលត្រឡប់ទៅទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញា ដែលថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសដោយមិនបានផ្តន្ទាទោសកម្រិតខ្ពស់បំផុត ដែលខ្លួនអាចសម្រេចបាន ពោលគឺទោសដាក់ពន្ធនាគារអស់មួយជីវិត[992]។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា "មានកំហុសអង្គច្បាប់ចំពោះអានុភាពនៃកត្តាស្ថានសម្រាលទោស នៅក្នុងការសម្រេចដាក់ទោសរបស់អង្គជំនុំជម្រះសាលាដំបូង" ហើយបានធ្វើការពិនិត្យដោយខ្លួនឯងលើកត្តាស្ថានសម្រាលទោសទាំងនោះ[993]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា កត្តាស្ថានសម្រាលទោសមានតិចតួច និងបានធ្វើឱ្យបាត់បង់ឥទ្ធិពលដោយស្ថានទម្ងន់ទោស[994]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការផ្តន្ទាទោស ឌុច ដាក់ពន្ធនាគារ ៣៥ ឆ្នាំ មិនឆ្លុះបញ្ចាំងត្រឹមត្រូវអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងស្ថានភាពបុគ្គលរបស់ ឌុច នោះទេ ហើយអង្គជំនុំជម្រះសាលាដំបូង មានកំហុសឆ្គងក្នុងការកំណត់ទោសដែលមានលក្ខណៈមិនគ្រប់គ្រាន់ច្បាស់ក្រឡែត។ ដូច្នេះ អង្គជំនុំជម្រះតុលាការ

[987] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ២៨៤។
[988] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣០០។
[989] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៣២។
[990] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៣៦។
[991] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៥២។
[992] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៥៥។
[993] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៦៣-៣៧១។
[994] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៧១។

កំពូល សម្រេចប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើ ឌុច ដោយគ្មានការបន្ធូរបន្ថយទោស[995]។

ទាក់ទងទៅនឹងបញ្ហាឃុំខ្លួនគាត់ពីមុនដោយខុសច្បាប់ លើកលែងយោបល់ជំទាស់របស់ចៅក្រម Agnieszka Klonowiecka-Milart និង Chandra Nihal Jayasinghe អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានឆន្ទានុសិទ្ធិផ្តល់ដំណោះស្រាយចំពោះការចោទប្រកាន់អំពីការរំលោភសិទ្ធិនេះឡើយ ហើយកំហុសអង្គច្បាប់នេះបានប៉ះពាល់ដល់ការផ្តន្ទាទោសរបស់ ឌុច។ ដូច្នេះ ចៅក្រមភាគច្រើនយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ដែលនាំឱ្យមោឃៈការប្រកាសទោសក្នុងការសម្រេចកាត់បន្ថយរយៈពេលផ្តន្ទាទោសចំនួន ៥ ឆ្នាំ និងការគិតបញ្ចូលនូវរយៈពេលជាប់ឃុំឃាំង ចាប់ពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧[996]។

vi. **ជំពូក ៦** ពិភាក្សាអំពីការចោទប្រកាន់អំពីកំហុស ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា "បទដ្ឋាននៃការពិនិត្យឡើងវិញពីរដំណាក់កាល" របស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ការកំណត់លើភាពអាចទទួលយកបានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺមិន "ខុសច្បាប់"[997] ទេ ហើយអង្គជំនុំជម្រះសាលាដំបូងមិនបានបំពេញកិច្ចក្រៅវិធានផ្ទៃក្នុងឡើយ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ក្របខ័ណ្ឌគតិយុត្តិ ក្នុងការសម្រេចអំពីភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី នៅមានលក្ខណៈស្រពេចស្រពិល" និង "កាន់តែធ្វើឱ្យស្មុគស្មាញឡើងៗនៅចន្លោះដំណាក់កាលស៊ើបអង្កេត និងដំណាក់កាលជំនុំជម្រះ ដោយមានការប្រកាសជាច្រើនលើកច្រើនសារអំពីឋានៈដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានការពិនិត្យឱ្យបានល្អិតល្អន់ទៅលើលក្ខណៈសម្បត្តិគ្រប់គ្រាន់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"[998]។ អង្គជំនុំជម្រះតុលាការកំពូលក៏បានសន្និដ្ឋានទៀតថា បទដ្ឋាននៃការបង្ហាញភ័ស្តុតាងដែលអង្គជំនុំជម្រះបានប្រើ ដែលជា"បទដ្ឋានអាចជាការពិត" ឬ ដែលជា "ឧត្តមានុភាពនៃភ័ស្តុតាង" មានលក្ខណៈស្របច្បាប់[999]។ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើភ័ស្តុតាងដែលបានបង្កើតឡើង ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ ដែលបានប្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធឋានៈរបស់ខ្លួន និងបានសម្រេចទទួលយកអ្នកដាក់ពាក្យសុំចំនួនដប់នាក់បន្ថែមទៀត ជាដើមបណ្តឹងរដ្ឋប្បវេណី[1000]។ អង្គជំនុំជម្រះតុលាការកំពូលបានភ្ជាប់ជាឧបសម្ព័ន្ធ នូវបញ្ជីឈ្មោះមួយទៅនឹងសាលក្រម ដើម្បីបញ្ជាក់ថាតើ ដើមបណ្តឹងរដ្ឋប្បវេណីណាត្រូវបានទទួលយកក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១[1001]។

vii. **ជំពូក ៧** ពិភាក្សាអំពីការចោទប្រកាន់អំពីកំហុសទាក់ទងនឹងសំណង។ អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា ដោយសារតែមានការកម្រិតដែលមានចែងនៅក្នុងក្របខ័ណ្ឌសំណងរបស់ អ.វ.ត.ក. សំណើទាមទារសំណងជាក់លាក់ទាំងនេះ មិនអាចទទួលយកបានទេ។ ទោះជាយ៉ាងណា ដោយពិចារណាថា សំណើជាច្រើនត្រូវបានបដិសេធចោល ដោយសារភាពក្រីក្ររបស់ ឌុច និងដោយវាយតម្លៃថា សំណើមួយចំនួនមានភាពច្បាស់លាស់គ្រប់គ្រាន់ អង្គជំនុំជម្រះតុលាការកំពូល "លើកទឹកចិត្តដល់អាជ្ញាធរជាតិ សហគមន៍អន្តរជាតិ ឬអ្នកដែលអាចនឹងជួយផ្តល់ជំនួយបង្ហាញសាមគ្គីភាពជាមួយជនរងគ្រោះតាមរយៈការផ្តល់ជំនួយ ការគាំទ្រជាហិរញ្ញវត្ថុ ឬជំនួយតាមរូបភាព

[995] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៨៣-៣៨៤។
[996] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៣៩៩។
[997] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៤៨៦។
[998] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៤៩៣។
[999] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៥៣១។
[1000] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៥៣១ (និងកថាខណ្ឌបន្តបន្ទាប់)។
[1001] សូមមើល សំណុំរឿង ០០១ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ ក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងសាទុក្ខ ក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28.2។

ផ្សេងទៀតដែលអាចជួយរៀបចំ និងអនុវត្តទម្រង់នៃសំណងដែលសមស្របទាំងនេះ”[1002]។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធសំណើសុំសំណង និងបានគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[1003]។

viii. **ជំពូក ៨** គឺជាផ្នែកសម្រេចសេចក្តី។

ix. **ជំពូក ៩** គឺជាផ្នែកមតិជំទាស់រួមគ្នាលើផ្នែកខ្លះរបស់ចៅក្រម Agnieszka Klonowiecka-Milart និងចៅក្រម Chandra Nihal Jayasinghe លើសេចក្តីសម្រេចតាមមតិភាគច្រើន ក្នុងការដាក់ទោសមួយជីវិត។ ចៅក្រមទាំងពីររូបឯកភាពថា ចាំបាច់ត្រូវដាក់ពន្ធនាគារអស់មួយជីវិត ប៉ុន្តែយ៉ាងណាក៏ដោយ ពួកគាត់មិនឯកភាពទៅនឹងសេចក្តីសម្រេចតាមមតិភាគច្រើន ក្នុងការបដិសេធការទូទាត់សងសម្រាប់ការរំលោភធ្ងន់ធ្ងរលើសិទ្ធិជាសារវន្តរបស់ ឌុច ដែលកើតឡើងដោយសារការឃុំខ្លួនគាត់រយៈពេលយ៉ាងយូរមុនពេលជំនុំជម្រះ។ ពួកគាត់ចាត់ទុកថា ការឃុំខ្លួន ឌុច មុនការជំនុំជម្រះ ដែលបានបន្តអស់រយៈពេល ១០ ឆ្នាំ គឺផ្ទុយទៅនឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាគឺជាភាគី និងដែលបង្កើតបានជាច្បាប់ចងកាតព្វកិច្ចនៅចំពោះមុខ អ.វ.ត.ក.។ ចៅក្រម Klonowiecka-Milart និងចៅក្រម Jayasinghe បានឯកភាពថា ត្រូវតែមានចំណងទាក់ទងមួយចំនួនរវាងតុលាការផ្តន្ទាទោស និងនីត្យានុកូលភាពនៃការឃុំខ្លួន សម្រាប់ការទូទាត់សងដែលត្រូវផ្តល់ឱ្យ ប៉ុន្តែមិនឯកភាពថា ការអនុម័តយកយុត្តិសាស្ត្ររបស់តុលាការ *មិនអចិន្ត្រៃយ៍* ជាការត្រឹមត្រូវនោះឡើយ ដោយពិចារណាទៅលើឋានៈរបស់ អ.វ.ត.ក. នៅក្នុងប្រព័ន្ធតុលាការជាតិ។ ពួកគេយល់ឃើញថា ឌុច ត្រូវទទួលបានការទូទាត់សងសម្រាប់ការរំលោភសិទ្ធិរបស់គាត់ក្នុងការទទួលបានសេរីភាព និងថាផ្អែកលើសេចក្តីសម្រេចជាឯកច្ឆន្ទរបស់អង្គជំនុំជម្រះ ដែលថាភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មរបស់ ឌុច ចាំបាច់ត្រូវផ្តន្ទាទោសគាត់ដាក់ពន្ធនាគារអស់មួយជីវិតនោះ មានតែដំណោះស្រាយមួយប៉ុណ្ណោះដែលអាចធ្វើឡើង តាមរយៈការកែប្រែការប្រកាសទោសគាត់ទៅរយៈពេលឃុំខ្លួនមានពេលវេលាកំណត់វិញតែប៉ុណ្ណោះ។ ដូច្នេះ ចៅក្រមត្រូវផ្តល់ការបន្ធូរបន្ថយទោស ឌុច មកត្រឹមរយៈពេលសាមសិបឆ្នាំវិញ ដែលជាការទូទាត់សម្រាប់ការរំលោភបំពានលើសិទ្ធិជាសារវន្តរបស់គាត់ ដោយកត់សម្គាល់ថា ដោយយោងទៅលើអាយុរបស់គាត់ ដំណោះស្រាយនេះគឺជា “និមិត្តរូបសុទ្ធសាធ”[1004]។

អង្គជំនុំជម្រះតុលាការកំពូល ក៏បានចេញសាលដីកាសង្ខេបរបស់ខ្លួនផងដែរ[1005]។

## ៥.១.៧. ដំណាក់កាលក្រោយកំណត់ពិរុទ្ធភាព

### ៥.១.៧.១. ការឃុំខ្លួន និងជំនួយក្នុងសំណុំរឿង ០០២

នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើទៅក្រសួងមហាផ្ទៃ ឱ្យអនុវត្តទោសរបស់ ឌុច ដោយស្នើសុំថា ឌុច បន្តស្ថិតនៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក. រហូតដល់ពេលការចូលរួមរបស់គាត់ក្នុងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. លែងមានភាពចាំបាច់ (ឌុច ត្រូវធ្វើជាសាក្សីម្នាក់ក្នុងសំណុំរឿង ០០២) និងថា ចាំបាច់ត្រូវកំណត់មន្ទីរឃុំឃាំងសមស្របសម្រាប់ឃុំខ្លួន ឌុច នៅក្នុងប្រព័ន្ធពន្ធនាគារជាតិ[1006]។

គេបានកំណត់ថាពន្ធនាគារខេត្តកណ្តាលគឺជាកន្លែងផ្តល់អត្ថប្រយោជន៍ល្អបំផុតដល់ការឃុំខ្លួន ឌុច ហើយនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានស្នើសុំអគ្គនាយកដ្ឋានពន្ធនាគារ ផ្ទេរ ឌុច ទៅកាន់ពន្ធនាគារខេត្តកណ្តាល។ សហព្រះរាជអាជ្ញាក៏បានសម្របសម្រួលជាមួយនាយកដ្ឋានពន្ធនាគារថា

[1002] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៧១៧។
[1003] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ផ្នែកសម្រេចសេចក្តី។

[1004] សំណុំរឿង០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 ជំពូក ៩។
[1005] សំណុំរឿង ០០១ សេចក្តីសង្ខេបសាលដីកាអង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០១ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F26/3។
[1006] សំណុំរឿង ០០១ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យអនុវត្តទោស ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១២ ឯកសារ F29។

ទីកន្លែង និងស្ថានភាពនៃការឃុំខ្លួន ឌុច នឹងមិនត្រូវបានប្រែប្រួលដែលនាំឱ្យប៉ះពាល់ដល់ទណ្ឌិតរូបនេះ នៅក្នុងរយៈពេលនៃការជាប់ពន្ធនាគាររបស់គាត់ឡើយ។ ឌុច ត្រូវបានផ្ទេរចេញពីមន្ទីរឃុំឃាំង អ.វ.ត.ក. ទៅកាន់ពន្ធនាគារខេត្តកណ្ដាលនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីអនុវត្តទោសនៅសល់របស់គាត់[1007]។

ឌុច បានផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១ រយៈពេល ១៣ ថ្ងៃ ចាប់ផ្ដើមនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ និងបញ្ចប់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២[1008]។ ក្រោយមកគាត់បានផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ រយៈពេល ១២ ថ្ងៃ ចាប់ពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ ដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦[1009]។

ឌុច បានទទួលមរណភាពនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ខណៈពេលកំពុងអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតរបស់គាត់[1010]។

## ៥.២. សំណុំរឿង ០០២

### ៥.២.១. ទិដ្ឋភាពទូទៅអំពីជនជាប់ចោទ

- នួន ជា (១៩២៦-២០១៩) គឺជាអនុលេខា ប.ក.ក. ជាប្រធានសភាតំណាងប្រជាជន បានធ្វើជានាយករដ្ឋមន្ត្រីស្ដីទីនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក.[1011]។
- អៀង សារី (១៩២៥-២០១៣) គឺជាឧបនាយករដ្ឋមន្ត្រីការបរទេស នៃកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក.[1012]។
- អៀង ធីរិទ្ធ (១៩៣២-២០១៥) គឺជារដ្ឋមន្ត្រីសង្គមកិច្ចនៃកម្ពុជាប្រជាធិបតេយ្យ[1013]។

---

[1007] *កាំង ហ្គេកអ៊ាវ បានផ្ទេរទៅកាន់ពន្ធនាគារខេត្តកណ្ដាល* ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៣។

[1008] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/50.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/51.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/52.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/53.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/54.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/55.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ឯកសារ E1/56.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ ឯកសារ E1/57.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២ ឯកសារ E1/58.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ ឯកសារ E1/59.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២ ឯកសារ E1/60.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២ ឯកសារ E1/61.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ឯកសារ E1/62.1។

[1009] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/433.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៨ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/434.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៩ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/435.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី១៣ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/436.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី១៤ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/437.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី១៥ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/438.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី១៦ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/439.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២០ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/440.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២១ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/441.1។ សំណុំរឿង ០០២ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/442.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៣ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/443.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៧ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/444.1។

[1010] សំណុំរឿង ០០១ សេចក្ដីជូនព័ត៌មាន របស់អ្នកនាំពាក្យអយ្យការអមសាលាដំបូងខេត្តកណ្ដាល ក្នុងព្រឹត្តិការណ៍មរណភាពនៃទណ្ឌិត កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២០ ឯកសារ F32។

[1011] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៣០៤, ៣១៣-៣១៦, ៣១៩-៣២៣, ៧៤៤។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៥១៨, ៥៣០-៥៣២។

[1012] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ៣៥៧, ៤១២, ៤១៤, ៤១៩។

[1013] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤១២, ៤១៩។

- ខៀវ សំផន (កើតឆ្នាំ១៩៣១) គឺជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ[1014]។ គាត់ក៏ជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃ ប.ក.ក. ផងដែរ ហើយបានចូលរួមក្នុងកិច្ចប្រជុំនានារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ជាប្រចាំ[1015]។

- កាំង ហ្គេកអ៊ាវ (ហៅ ឌុច) គឺជាប្រធាន ម-១៣ (មន្ទីរសន្តិសុខស្ថិតនៅអមលាំង ខេត្តកំពង់ស្ពឺ) ពីខែកក្កដា ឆ្នាំ១៩៧១ ដល់ខែមករា ឆ្នាំ១៩៧៥ ជាអនុប្រធានមន្ទីរសន្តិសុខ ស-២១ ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ដល់ខែមីនា ឆ្នាំ១៩៧៦ និងជាប្រធានមន្ទីរ ស-២១ ពីខែមីនា ឆ្នាំ១៩៧៦ ដល់ពេលដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[1016]។ ដំបូងឡើយ ឌុច គឺជាផ្នែកមួយនៃសំណុំរឿង ០០២ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចលើកលែងចោទប្រកាន់នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ដោយសម្រេចថា សកម្មភាពឧក្រិដ្ឋរបស់គាត់បានស្ថិតនៅក្នុងបណ្តឹងវិវាទដ៏ទូលំទូលាយក្នុងសំណុំរឿង ០០១ រួចហើយ និងមិនមានភ័ស្តុតាងណាថ្មីទាក់ទងទៅនឹងការចូលរួមរបស់គាត់ ត្រូវបានបង្ហាញនៅក្នុងការស៊ើបអង្កេត នៃសំណុំរឿង ០០២ ទេ[1017]។

### ៥.២.២. ការស៊ើបអង្កេតបឋម ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ សហព្រះរាជអាជ្ញា បានផ្តួចផ្តើមការស៊ើបអង្កេតបឋមទៅក្នុងឧក្រិដ្ឋកម្ម ដែលអាចត្រូវបានប្រព្រឹត្តដោយមេដឹកនាំ កម្ពុជាប្រជាធិបតេយ្យ និងអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់សហចៅក្រមស៊ើបអង្កេត ដែលបានបើកកិច្ចស៊ើបសួរ។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ឧក្រិដ្ឋកម្មស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានប្រព្រឹត្ត ជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ដែលមានបំណងនាំមកនូវការផ្លាស់ប្តូរសង្គមកម្ពុជាទាំងស្រុង ស្របតាមមាគ៌ាមនោគមវិជ្ជា ហើយបានកំណត់អត្តសញ្ញាណ និងបញ្ជូនទៅធ្វើការស៊ើបអង្កេតលើស្ថានភាពអង្គហេតុដាច់ដោយឡែកពីគ្នាចំនួន ២៥ នៃការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការផ្លាស់ទីលំនៅដោយបង្ខំ ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ពលកម្មដោយបង្ខំ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា និងជាតិពន្ធុ ដែលជាភ័ស្តុតាងអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងតាមការអនុវត្តផែនការឧក្រិដ្ឋកម្មរួម។ សហព្រះរាជអាជ្ញា បានពិចារណាថា ការចោទប្រកាន់ផ្នែកអង្គហេតុទាំងនេះ បង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការបំពានបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា យោងតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដោយលើកឡើងថា សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណជនសង្ស័យចំនួនប្រាំរូប នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ប៉ុន្តែមិនបានកំណត់ឈ្មោះពួកគេជាសាធារណៈទេ[1018]។ ម្នាក់ក្នុងចំណោមជនសង្ស័យទាំងនេះគឺ ឌុច ដែលដូចបានពិភាក្សាខាងលើ ត្រូវបានជំនុំជម្រះដាច់ដោយឡែកក្នុងសំណុំរឿង ០០១ និងក្រោយមកត្រូវបានបំបែកចេញពីសំណុំរឿង ០០២។

សំណុំរឿងបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកកិច្ចស៊ើបសួរ[1019]។ ក្នុងអំឡុងរយៈពេលកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមចំនួនប្រាំមួយ

---

[1014] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៣៨១-៣៨៣។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៥៩១, ៥៩៦។
[1015] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៧៤៥, ៧៥៥។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៥៧៤, ៦០០-៦០៤។
[1016] សូមមើល ជំពូក ៥.១.១. សូមមើលផងដែរ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២២៣៥, ២១៤៨, ២១៥៧។
[1017] សំណុំរឿង ០០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D420។
[1018] សំណុំរឿង ០០២ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ឯកសារ D3។
[1019] សូមមើល សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ៣។

និងការបញ្ជាក់បំភ្លឺចំនួនមួយ ទាក់ទងទៅនឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1020]។

### ៥.២.៣. កិច្ចស៊ើបសួរផ្នែកតុលាការ

#### ៥.២.៣.១. ការឃុំខ្លួន និងការចោទប្រកាន់

ចន្លោះថ្ងៃទី១៩ ខែកញ្ញា និងខែវិច្ឆិកា ឆ្នាំ២០០៧ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន ត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំង អ.វ.ត.ក. តាមដីកាបង្គាប់របស់សហចៅក្រមស៊ើបអង្កេត[1021]។ ក្នុងអំឡុងរយៈពេលកិច្ចស៊ើបសួរ បុគ្គលម្នាក់ៗត្រូវបានចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[1022]។ ការឃុំខ្លួនបណ្តោះអាសន្នរបស់ពួកគេត្រូវបានបន្តជាថ្មីតាមកាលកំណត់[1023]។

#### ៥.២.៣.២. ភស្តុតាងនៅក្នុងសំណុំរឿង

បន្ថែមលើឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ក្នុងសំណុំរឿង ដើម្បីគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កំណត់ត្រានៅក្នុងសំណុំរឿងរួមមាន កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទចំនួន ៥៦ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនជាង ១.០០០ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងចំនួន ៣៦ របាយការណ៍អ្នកជំនាញប្រជាសាស្ត្រចំនួន ១ របាយការណ៍អ្នកជំនាញវេជ្ជសាស្ត្រជាច្រើន និងឯកសារសំខាន់ៗជាង ១១.៦០០។ សម្ភារៈដែលបានដាក់នៅក្នុងសំណុំរឿងដោយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគេ មានចំនួនជាង ៣៥០.០០០ ទំព័រ រួមទាំង ២២៣.០០០ ទំព័រទាក់ទងទៅនឹងអង្គហេតុនៃរឿងក្តី[1024]។

#### ៥.២.៣.៣. បញ្ហាប្រឈមផ្នែកយុត្តាធិការ

មេធាវីការពារក្តីបានលើកយកបញ្ហាប្រឈមផ្នែកយុត្តាធិការជាច្រើន នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ក្នុងអំឡុងពេលដំណាក់កាលស៊ើបអង្កេត នៃសំណុំរឿង ០០២[1025]។ សហ

---

[1020] សូមមើល សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 បុព្វកថា។

[1021] សំណុំរឿង ០០២ ដីកាឃុំខ្លួន នួន ជា ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ C10។ សំណុំរឿង ០០២ ដីកាឃុំខ្លួន អៀង សារី ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C23។ សំណុំរឿង ០០២ ដីកាឃុំខ្លួន អៀង ធីរិទ្ធ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C21។ សំណុំរឿង ០០២ ដីកាឃុំខ្លួន ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C27។

[1022] សំណុំរឿង ០០២ ការបង្ហាញខ្លួនលើកដំបូងរបស់ នួន ជា ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ ឯកសារ E3/54។ សំណុំរឿង ០០២ កំណត់ហេតុសួរចម្លើយ នួន ជា ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D275។ សំណុំរឿង ០០២ ការបង្ហាញខ្លួនលើកដំបូងរបស់ អៀង សារី ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ E3/92។ សំណុំរឿង ០០២ កំណត់ហេតុសួរចម្លើយ អៀង សារី ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ E3/525។ សំណុំរឿង ០០២ ការបង្ហាញខ្លួនលើកដំបូងរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ E3/664។ សំណុំរឿង ០០២ កំណត់ហេតុសួរចម្លើយ អៀង ធីរិទ្ធ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ E3/38។ សំណុំរឿង ០០២ ការបង្ហាញខ្លួនលើកដំបូងរបស់ ខៀវ សំផន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ D42។ សំណុំរឿង ០០២ កំណត់ហេតុសួរចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D285។

[1023] សូមមើ ឧទាហរណ៍ សំណុំរឿង ០០២ ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន នួន ជា ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ C9/6។ សំណុំរឿង ០០២ ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ខៀវ សំផន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ C26/8។ សំណុំរឿង ០០២ ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ C22/8។ សំណុំរឿង ០០២ ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ C20/8។

[1024] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ១៧។

[1025] សូមមើល សំណុំរឿង ០០២ សំណើអៀងសារីប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅអ.វ.ត. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩ ឯកសារ D240។ សំណុំរឿង ០០២ ពាក្យសុំរបស់អៀងសារីប្រឆាំងនឹងការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ឯកសារ D378។ ញត្តិផ្សេងទៀតរបស់អៀង សារីស្តីពីព្រំដែនកម្រិតលទ្ធភាពអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក. ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០ ឯកសារ D378/2។ សំណុំរឿង ០០២ សំណើសុំរបស់អៀងសារីជំទាស់ទៅនឹងការអនុវត្តអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនៅ អ.វ.ត.ក. ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០ ឯកសារ D379។ សំណើរបស់អៀង សារី: ជម្រើសមួយ ស្តីពីការអនុវត្តអំពើបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនៅអ.វ.ត.ក. ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D379/2។ សំណុំរឿង ០០២ សហមេធាវី អៀង សារី ពាក្យស្នើសុំរបស់ លោកអៀង សារី ប្រឆាំងនឹងការអនុវត្តន៍ អ វ ត ក នូវទម្រង់នៃការទទួលខុសត្រូវខាង ព្រហ្ម ទណ្ឌដែលគេហៅថា សហ

ចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ខ្លួននឹងដោះស្រាយភាគច្រើននៃបញ្ហាប្រឈមទាំងនេះ នៅពេលចេញដីកាដំណោះស្រាយ[1026] ប៉ុន្តែ មុនពេលចេញដីកាដំណោះស្រាយ ពួកគាត់បានសម្រេចដោះស្រាយទឡ្ហីករណ៍ដែលបានលើកឡើងទាក់ទងនឹងការលើកលែងទោស និងការអនុគ្រោះទោសរបស់ អៀង សារី បញ្ហាអំពី *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងភាពអាចអនុវត្តបាននៃទម្រង់ JCE។

### ៥.២.៣.៣.១. ការលើកលែងទោស និងការអនុគ្រោះទោស

បញ្ហាចោទអំពីការលើកលែងទោស និងការអនុគ្រោះទោស និង *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ត្រូវបានលើកឡើងដំបូងឡើយដោយ សហចៅក្រមស៊ើបអង្កេតផ្ទាល់។ នៅពេលចេញដីកាសម្រេចលើការឃុំខ្លួន អៀង សារី បណ្តោះអាសន្ន សហចៅក្រមស៊ើងអង្កេតជាដំបូងបានពិចារណាលើបញ្ហាថាតើ ការលើកលែងទោសនិងការអនុគ្រោះទោស ដែល អៀង សារី បានទទួលក្នុងឆ្នាំ១៩៩៦ ឬអង្គហេតុដែលថាគាត់ត្រូវបានកាត់ទោស*ដោយកំបាំងមុខ* ពីបទប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៩ នឹងរារាំងការចោទប្រកាន់រូបគាត់នៅ អ.វ.ត.ក. ដែរ ឬទេ។ ពួកគេបានសម្រេចថា ទាំងការលើកលែងទោស និងទាំងការអនុគ្រោះទោស មិនរារាំងការចោទប្រកាន់ឡើយ ដោយសារតែការលើកលែងទោសគ្របដណ្តប់លើអំពើក្រោមច្បាប់ផ្សេងគ្នា ហើយមិនមែនជាបទល្មើសស្ថិតក្រោមការចោទប្រកាន់នៅ អ.វ.ត.ក. នោះទេ ហើយមួយវិញទៀត ការអនុគ្រោះទោសប៉ះពាល់តែទៅលើការកំណត់ទោសប៉ុណ្ណោះ មិនមែនសាលក្រមផ្តន្ទាទោសឡើយ។ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនកើតមានឡើងទេនាពេលនោះ ដោយសារការជំនុំជម្រះឆ្នាំ១៩៧៩ គឺសម្រាប់តែអំពើប្រល័យពូជសាសន៍ ដែល អៀង សារី នាពេលនោះមិនត្រូវបានចោទពីបទប្រល័យពូជសាសន៍នោះទេ ហើយការជំនុំជម្រះពីមុនរបស់គាត់ទំនងជាមិនគ្របដណ្តប់រាល់អំពើទាំងអស់ ដែលគាត់ត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក. ឡើយ[1027]។ អង្គបុរេជំនុំជម្រះបានពិចារណាថា សុពលភាពនៃការលើកលែងទោស និងការអនុគ្រោះទោស មានភាពមិនច្បាស់លាស់ ប៉ុន្តែវាមិនបង្ហាញភ័ស្តុតាងច្បាស់លាស់ថាអាចរារាំងការផ្តន្ទាទោសពីបទប្រល័យពូជសាសន៍នៅចំពោះមុខ អ.វ.ត.ក. នោះឡើយ[1028]។

### ៥.២.៣.៣.២. គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ

ទាក់ទងនឹង*គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ជាគោលការណ៍ដែលមិនមានបុគ្គលណាដែលនឹងត្រូវទទួលខុសត្រូវ ត្រូវបានកាត់ទោស ឬដាក់ទណ្ឌកម្មជាថ្មីម្តងទៀតចំពោះបទល្មើសដែលរូបគាត់ត្រូវបានកំណត់ថាមានពិរុទ្ធភាព ឬថាគ្មានពិរុទ្ធភាពជាស្ថាពររួចហើយនោះឡើយ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា វិធាននៃផ្ទៃក្នុងមិនមានបទប្បញ្ញត្តិផ្ទាល់អំពី *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នោះទេ និងថា ភាគីមានការខ្វែងយោបល់គ្នាចំពោះបញ្ហាថាតើគប្បីស្វែងរកការណែនាំនៅក្នុងច្បាប់កម្ពុជាតែឯង ឬក៏ពីច្បាប់អន្តរជាតិផងដែរ ដែលច្បាប់នីមួយៗនេះកំណត់និយមន័យគោលការណ៍នេះខុសៗគ្នា ទាក់ទងទៅនឹងអ្វីដែលជា "បទល្មើសតែមួយ" ដែលច្បាប់កម្ពុជាសំដៅទៅលើ "អំពើតែមួយ" ចំណែកច្បាប់អន្តរជាតិហៅថា "បទល្មើសតែមួយ"។ យោងតាមការបកស្រាយនីមួយៗ ពួកគាត់បានកត់សម្គាល់ថា ដោយសារតែ អៀង សារី មិនត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍នាពេលនោះ ការចោទប្រកាន់បច្ចុប្បន្នអាចធ្វើឡើងសម្រាប់ "បទល្មើស" ផ្សេង និងថាដំណាក់កាលនៃរឿងក្តីនេះមិនអាចកំណត់ថាតើ ការចោទប្រកាន់ដោយ អ.វ.ត.ក. គឺសម្រាប់ "អំពើតែមួយ" ដូចគ្នាទៅនឹងបញ្ហានៅក្នុងការជំនុំជម្រះឆ្នាំ១៩៧៩ ឬអត់នោះឡើយ ជាចំណុចមួយដែលអាចបង្ហាញនៅក្នុង

---

ឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ D97។ សំណុំរឿង ០០២ សំណើរបស់លោកអៀង សារី ប្រឆាំងនឹង ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ នៅ អ.វ.ត.ក. ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D345/2។ សំណុំរឿង ០០២ សំណើរបស់អៀង សារី៖ ជម្រើសមួយ ស្តីពីការអនុវត្តការទទួលខុសត្រូវរបស់ ថ្នាក់លើនៅ អ.វ.ត.ក. ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ D345/3។

[1026] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ ដីកាសម្រេចលើសំណើរបស់លោកអៀង សារី ប្រឆាំងនឹង ការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើ នៅ អ.វ.ត.ក. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០ ឯកសារ D345/4។

[1027] សំណុំរឿង ០០២ ដីកាឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ C22 កថាខណ្ឌ ៧-១៤។

[1028] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ C22/I/74 កថាខណ្ឌ ៥៥-៦៣។

ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់គាត់[1029]។ ដូច្នេះ បញ្ហាចោទថាតើការលើកលែងទោស និងការអនុគ្រោះទោសរបស់ អៀង សារី ឬ*គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* បានរារាំងការចោទប្រកាន់គាត់នៅ អ.វ.ត.ក. ឬអត់នោះ ត្រូវបានទុកចោលរហូតដល់ពេលចេញដីកាដំណោះស្រាយ។

### ៥.២.៣.៣.៣. ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម (JCE)

ទាក់ទងនឹងភាពអាចអនុវត្តបាននៃ JCE នៅ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទម្រង់នីមួយៗនៃ JCE អាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មអន្តរជាតិ ប៉ុន្តែមិនអនុវត្តចំពោះឧក្រិដ្ឋកម្មជាតិទេ និងថា*ធាតុផ្សំអត្តនោម័ត* សម្រាប់ JCE III គឺជាការទទួលយកជាអត្តនោម័ត នូវផលវិបាកតាមធម្មជាតិ ឬដែលអាចប្រមើលដឹងបានរបស់ផែនការរួម។ ពួកគាត់យល់ឃើញថា JCE អាចត្រូវបានចាត់ទុកជាទម្រង់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មយោងតាមមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក. និងថា ការអនុវត្តរបស់វានឹងមិនរំលោភលើគោលការណ៍នីត្យានុកូលភាព ដោយសារតែយុត្តិសាស្ត្រដែលបានប្រើប្រាស់ក្នុងការវាយតម្លៃអំពី JCE នោះត្រូវបានតាក់តែងឡើងមុនពេលអង្គហេតុដែលជាកម្មវត្ថុនៃការស៊ើបអង្កេតនៅ អ.វ.ត.ក. កើតមានឡើង[1030]។

នៅពេលបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានពិចារណាថាតើ JCE ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥ ដែរ ឬទេ។ អង្គបុរេបានពិនិត្យរឿងក្តីអន្តរជាតិ អនុសញ្ញា និងសេចក្តីសម្រេចតាមផ្លូវច្បាប់ ហើយបានសន្និដ្ឋានថា JCE I និង II ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិគិតត្រឹមពេលនោះ។ ទោះជាយ៉ាងណា អង្គបុរេមិនអាចសន្និដ្ឋានបានថា JCE III បង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលដែលពាក់ព័ន្ធនោះទេ។ ក្នុងកាលៈទេសៈបែបទាំងនោះ អង្គបុរេយល់ឃើញថា គោលការណ៍នីត្យានុកូលភាព បានតម្រូវឱ្យ អ.វ.ត.ក. ចៀសវាងពីការពឹងផ្អែកលើ JCE III នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់ខ្លួន។ ដូច្នេះ អង្គបុរេជំនុំជម្រះ បានសម្រេចថា JCE III មិនអាចអនុវត្តបាននៅ អ.វ.ត.ក. ឡើយ[1031]។

### ៥.២.៣.៤. ដើមបណ្តឹងរដ្ឋប្បវេណី

ក្នុងអំឡុងពេលកិច្ចស៊ើបសួរ ផ្នែកគាំពារជនរងគ្រោះបានដាក់ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤.១២៨ ទៅសហចៅក្រមស៊ើបអង្កេត។ ក្នុងអំឡុងពេលស៊ើបអង្កេត អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០៤ នាក់ បានស្នើសុំប្តូរទម្រង់នៃការចូលរួមរបស់ខ្លួនទៅជាបណ្តឹងធម្មតា អ្នកដាក់ពាក្យចំនួន ១១ នាក់ បានដកពាក្យបណ្តឹងរបស់ខ្លួនចេញវិញ មានពាក្យបណ្តឹងចំនួន ១៩ ត្រូវបានរកឃើញថាបានដាក់ស្ទួនគ្នា និងពាក្យសុំចំនួនប្រាំមួយត្រូវបានដាក់ឡើងវិញតាមការស្នើសុំរបស់ជនរងគ្រោះ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ ទាក់ទងនឹងភាពអាចទទួលយកបាននៃពាក្យសុំសរុបចំនួន ៣.៩៨៨ ច្បាប់ ដោយបានកត់សម្គាល់ថា អ្នកដាក់ពាក្យចំនួន ១៨ នាក់ បានទទួលមរណភាពបន្ទាប់ពីបានដាក់ពាក្យសុំរបស់ខ្លួនរួចមក[1032]។

ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ២.១២៣ នាក់ ត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេត។ ពាក្យសុំមួយចំនួនត្រូវបានប្រកាសថាមិនអាចទទួលយកបាន ដោយសារជនរងគ្រោះបានទទួលរងព្យសនកម្មដែលមិនពាក់ព័ន្ធផ្ទាល់ទៅនឹងកាលៈទេសៈអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ទោះជាយ៉ាងណា ពាក្យសុំដែលមិនត្រូវបានទទួលយក ត្រូវបានរក្សាទុកនៅក្នុងសំណុំរឿង ក្នុងទម្រង់ជាពាក្យបណ្តឹង ដែលពួកវាត្រូវបានរួមបញ្ចូល

---

[1029] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ ឯកសារ ឯកសារ C22/I/74 កថាខណ្ឌ ៤១-៥៤។
[1030] សំណុំរឿង ០០២ ដីកាសម្រេចស្តីពីការអនុវត្តន៍នៅ អ វ ត ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌដែលគេហៅថា សហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D97/13 កថាខណ្ឌ ១២-១៣, ៦៨-២១ ផ្នែកសម្រេចសេចក្តី។
[1031] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/15/9 កថាខណ្ឌ ៦៩, ៨៣, ៨៧-៨៨។
[1032] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ១០។

គ្នាជាមួយនឹងពាក្យបណ្តឹងជនរងគ្រោះចំនួន ៤.១៥១ ដែលបានដាក់ទៅក្នុងសំណុំរឿងរួចហើយ ដោយសហព្រះរាជអាជ្ញា[1033]។

### ៥.២.៣.៥. ដីកាសន្និដ្ឋានស្ថាពរ

នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីទាំងឡាយថា ខ្លួនបានពិចារណាថា កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ត្រូវបានបញ្ចប់ហើយ[1034]។ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានណែនាំថា ខ្លួនបានដោះស្រាយបណ្តឹងឧទ្ធរណ៍ដែលនៅសេសសល់រួចអស់ហើយ[1035]។ បន្ទាប់មក សំណុំរឿងត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញាពិនិត្យ ដើម្បីរៀបចំដីកាសន្និដ្ឋានស្ថាពរ[1036]។

នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយបានស្នើឱ្យសហចៅក្រមស៊ើបអង្កេតចោទប្រកាន់ នួន ជា, អៀង សារី, អៀង ធីរិទ្ធ និង ខៀវ សំផន និងបញ្ជូនខ្លួនពួកគេទៅជំនុំជម្រះចំពោះបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[1037]។

### ៥.២.៣.៦. ដីកាដំណោះស្រាយ

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ[1038]។ ដីកាដំណោះស្រាយបែងចែកជាប្រាំមួយជំពូក។

i. **ជំពូក ១** ពិភាក្សាអំពីការកត់សម្គាល់ឃើញអំពីអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេត ដោយពិនិត្យមើលបរិបទប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធរដ្ឋបាលរបស់មជ្ឈិមបក្ស និងរចនាសម្ព័ន្ធរដ្ឋបាលទូទាំងប្រទេស រចនាសម្ព័ន្ធទំនាក់ទំនង រចនាសម្ព័ន្ធយោធា ជម្លោះប្រដាប់អាវុធ ការកត់សម្គាល់អំពីអង្គហេតុទាក់ទងនឹងឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនត្រូវចោទ។

ii. **ជំពូក ២** បង្ហាញពីច្បាប់ដែលត្រូវអនុវត្ត ការពិភាក្សាអំពីយុត្តិសាស្ត្ររបស់ អ.វ.ត.ក. ការកំណត់និយមន័យឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ និងចុងក្រោយបង្ហាញពីបទដ្ឋាននៃភ័ស្តុតាង។

iii. **ជំពូក ៣** ពិភាក្សាអំពីសំអាងច្បាប់របស់សហចៅក្រមស៊ើបអង្កេត ជាពិសេសលើបញ្ហាយុត្តាធិការលើរូបបុគ្គល ការលើកលែងទោស ការអនុគ្រោះទោស និង *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មដែលមានចែង និងអាចផ្តន្ទាទោសដោយក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។

iv. **ជំពូក ៤** បង្ហាញពីព័ត៌មានផ្ទាល់ខ្លួនរបស់ជនជាប់ចោទម្នាក់ៗ។

v. **ជំពូក ៥** បង្ហាញពីសេចក្តីសន្និដ្ឋានដែលថា នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ បានប្រព្រឹត្ត (តាមរយៈ JCE) បានរៀងចំផែនការ បានញុះញង់ បានបញ្ជា ឬ បានជួយ និងជំរុញ ឬទទួលខុសត្រូវក្នុងនាមជាការទទួលខុសត្រូវរបស់ថ្នាក់លើ នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ជាតិសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត, អំពើប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម និង ចាម, ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ នៃអំពើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្ស

[1033] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ១២។
[1034] សំណុំរឿង ០០២ សេចក្តីជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ ឯកសារ D317។
[1035] សំណុំរឿង ០០២ សេចក្តីជូនដំណឹងតាមវិធាន ៦៦(៤) ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ឯកសារ 0។
[1036] សំណុំរឿង ០០២ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ឯកសារ D385។
[1037] សំណុំរឿង ០០២ ដីកាសន្និដ្ឋានស្ថាពរតាមវិធាន ៦៦ របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ ឯកសារ D390។
[1038] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

ធម៌ ការបង្កឱ្យមានការឈឺចាប់ ឬរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនានូវ ឈ្លើយសឹក និងជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេសជនស៊ីវិលដោយខុសច្បាប់ ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់, និងអំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលជាការរំលោភលើក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦។

vi. **ជំពូក ៦** គឺជាសេចក្តីសម្រេចបន្តឃុំខ្លួនជនជាប់ចោទ រង់ចាំការបង្ហាញខ្លួនរបស់ពួកគេនៅចំពោះមុខ អ.វ.ត.ក.។

### ៥.២.៤. កិច្ចដំណើរការនីតិវិធីនៅអង្គបុរេជំនុំជម្រះ

ជនជាប់ចោទទាំងបួនរូបបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[1039]។ ទឡ្ហីករណ៍របស់ពួកគេផ្តោតជុំវិញបញ្ហាយុត្តាធិការរបស់ អ.វ.ត.ក. ដោយសារតែវិធានផ្ទៃក្នុងមិនអនុញ្ញាតឱ្យប្តឹងឧទ្ធរណ៍ទាក់ទងនឹងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតឡើយ[1040]។

នួន ជា បានលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើគោលការណ៍នីត្យានុកូលភាព នៅពេលដែលពួកគេសម្រេចលើយុត្តាធិការរបស់ អ.វ.ត.ក. លើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងទម្រង់នៃការទទួលខុសត្រូវ ដោយលើកឡើងថាបទល្មើសទាំងនេះមិនត្រូវបានទទួលស្គាល់នៅក្រោមច្បាប់កម្ពុជា ដែលមានជាធរមានចន្លោះឆ្នាំ១៩៧៥-១៩៧៩។ គាត់បានស្នើសុំអង្គបុរេជំនុំជម្រះឱ្យមោឃៈ ឬកែតម្រូវដីកាដំណោះស្រាយ ឱ្យបានត្រឹមកម្រិតមួយថា ការចោទប្រកាន់អំពីការទទួលខុសត្រូវរបស់គាត់ ត្រូវបញ្ជាក់យ៉ាងដាច់ដោយឡែក លើបទល្មើស និងទម្រង់នៃការទទួលខុសត្រូវនៅក្នុងច្បាប់សារធាតុ ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[1041]។

អៀង សារី បានលើកយកមូលដ្ឋានបណ្តឹងឧទ្ធរណ៍ជាច្រើន ជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក. លើឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ យោងតាមច្បាប់អន្តរជាតិ និងការអនុវត្តទម្រង់នៃការទទួលខុសត្រូវទាំងនោះដោយសហចៅក្រមស៊ើបអង្កេត ក៏ដូចជាមូលដ្ឋានផ្សេងទៀតទាក់ទងនឹងការអនុគ្រោះទោស និងការលើកលែងទោសរបស់គាត់ និងការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលថាវាមិននាំឱ្យចាប់ផ្តើម *គោលការណ៍ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*នោះទេ និងថាវាមិនរារាំងការចោទប្រកាន់គាត់[1042]។

ខៀវ សំផន បានលើកឡើងថា ដីកាដំណោះស្រាយបានរំលោភលើវិធានដែលចែងអំពីការស៊ើបអង្កេត និងបានបញ្ចប់ការស៊ើបអង្កេតមិនពេញលេញមុនពេលកំណត់ និងថា ការស៊ើបអង្កេតត្រូវបានធ្វើឡើងដើម្បីស្វែងរកតែភស្តុតាងដាក់បន្ទុកប៉ុណ្ណោះ។ គាត់បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធដីកាដំណោះស្រាយចោល បង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតបន្តកិច្ចស៊ើបសួរ និងចេញសេចក្តីសម្រេចថា មិនអាចចោទប្រកាន់រូបគាត់ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះបានឡើយ នៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ[1043]។

---

[1039] សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1។ សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/2/1។ សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/4/3។ សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6។

[1040] សូមមើល វិធានផ្ទៃក្នុង វិធាន ៧៤(៣) បង្ហាញពីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលអាចត្រូវបានប្តឹងទាស់ដោយជនត្រូវចោទ ទៅកាន់អង្គបុរេជំនុំជម្រះ។

[1041] សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1 កថាខណ្ឌ ៣៨។

[1042] សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/1/6។

[1043] សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/4/3។

អៀង អ៊ីរិទ្ធ បានលើកឡើងថា អ.វ.ត.ក. មិនមានយុត្តាធិការចោទប្រកាន់លើរូបគាត់ចំពោះឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវនៃអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឧក្រិដ្ឋកម្មជាតិ សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើនោះទេ។ គាត់បានលើកឡើងបន្ថែមទៀតអំពី ការរំលោភបំពានលើសិទ្ធិជំនុំជម្រះដោយត្រឹមត្រូវរបស់គាត់ រួមមានការផ្តល់សំអាងហេតុមិនគ្រប់គ្រាន់ និងមិនត្រឹមត្រូវនៅក្នុងដីកាដំណោះស្រាយ ដែលជាការធ្វើឡើងតាមទំនើងចិត្ត។ ដូច្នេះ គាត់បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ បដិសេធចោលដីកាដំណោះស្រាយលើចំណុចជាក់លាក់[1044]។

អង្គបុរេជំនុំជម្រះបានចេញសាលដីកាចំនួនបី លើបណ្តឹងឧទ្ធរណ៍ទាំងនេះ បានធ្វើការកែប្រែទៅលើដីកាដំណោះស្រាយពីរចំណុច និងបានច្រានចោលមូលដ្ឋានផ្សេងទៀតទាំងអស់នៃបណ្តឹងឧទ្ធរណ៍ ដូច្នេះបញ្ជូនរឿងក្តីនេះជាផ្លូវការទៅជំនុំជម្រះ។ អង្គបុរេជំនុំជម្រះបានចេញផ្នែកសម្រេចសេចក្តីរបស់ខ្លួនជាមុនដោយចេញសាលដីកាមានសំអាងហេតុតាមក្រោយ[1045]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្នុងអំឡុងរយៈពេលស្ថិតក្រោមយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក. ច្បាប់ទំនៀមទម្លាប់អន្តរជាតិតម្រូវឱ្យមានចំណងទាក់ទងរវាងអំពើជាមូលដ្ឋាន នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ[1046]។ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានបន្ថែមទៀតថា ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ អំពើរំលោភសេពសន្ថវៈមិនមានអត្ថិភាពជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់តែឯងនោះទេ ហើយបានដកអំពើរំលោភសេពសន្ថវៈចេញពីដីកាដំណោះស្រាយ ដោយកត់សម្គាល់ថាអង្គហេតុដែលកំណត់បទល្មើសថាជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ជាការរំលោភសេពសន្ថវៈ អាចកំណត់បទល្មើសថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត[1047]។ ដីកាដំណោះស្រាយមិនបានចេញជាថ្មីម្តងទៀត ដើម្បីដាក់បញ្ចូលការកែប្រែទាំងអស់នេះទេ ហើយដូច្នេះ ត្រូវតែអានភ្ជាប់ជាមួយសាលដីការបស់អង្គបុរេជំនុំជម្រះ[1048]។

អង្គបុរេជំនុំជម្រះក៏បានចេញសាលដីកាលើភាពអាចទទួលយកបាន របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដែលបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេតចំពោះឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់។ អង្គបុរេបានទទួលយកបណ្តឹងឧទ្ធរណ៍ ដែលបានដាក់ដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៧២៨ នាក់ ឱ្យក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយមានមតិជំទាស់លើផ្នែកខ្លះរបស់ចៅក្រម Catherine Marchi-Uhel អង្គបុរេ

---

[1044] សំណុំរឿង ០០២ បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/2/1។

[1045] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/14។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/1/26។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារ D427/2/12 & D427/3/12។ សាលដីកាទាំងអស់នេះ ត្រូវបានចេញដោយមានសំអាងហេតុតាមក្រោយ។ នេះគឺជាសាលដីកាមានសំអាងហេតុ៖ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/15។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 & D427/3/15។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30។

[1046] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 & D427/3/15 កថាខណ្ឌ ១៤៤-១៤៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ 311-313។

[1047] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 & D427/3/15 កថាខណ្ឌ ១៥៤។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៣៧១-៣៧២។

[1048] សូមមើល សំណុំរឿង ០០២/០២ សាលក្រម ឧបសម្ព័ន្ធ I៖ ប្រវត្តិនីតិវិធី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465.1 កថាខណ្ឌ ៦។

បានសម្រេចថា សហចៅក្រមស៊ើបអង្កេតបានបកស្រាយមិនត្រឹមត្រូវអំពីទំនាក់ទំនងហេតុទៅនឹងផលដែលចាំបាច់រវាងឧក្រិដ្ឋកម្មដែលត្រូវបានស៊ើបអង្កេត និងព្យសនកម្មដែលទទួលរង[1049]។

### ៥.២.៥. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះសាលាដំបូង

#### ៥.២.៥.១. អញ្ញត្រកម្ម និងសវនាការបឋម

វិធាន៨៩(១) នៃវិធានផ្ទៃក្នុង ផ្ដល់ឱកាសឱ្យភាគីដាក់អញ្ញត្រកម្មនៅដំណាក់កាលជំនុំជម្រះ ទាក់ទង *ជាអាទិ៍*ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យភាគីដាក់អញ្ញត្រកម្មទាំងនេះជាទម្រង់សង្ខេប នៅក្នុងឯកសារតែមួយ និងបានបដិសេធសំណើសុំពន្យារកាលបរិច្ឆេទកំណត់ដាក់អញ្ញត្រកម្ម រហូតដល់ក្រោយពេលដែល អង្គបុរេជំនុំជម្រះចេញសំអាងហេតុ សម្រាប់សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[1050]។ ក្រុមមេធាវីការពារក្ដីនីមួយៗ បានដាក់អញ្ញត្រកម្មទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ។

បន្ថែមលើបញ្ហាប្រឈមទៅនឹងភាពត្រឹមត្រូវនៃការស៊ើបអង្កេត និងធម្មានុរូបនៃវិធានផ្ទៃក្នុង នួន ជា បានលើកឡើងថា អ.វ.ត.ក. មិនមានយុត្តាធិការចោទប្រកាន់គាត់ទេ ដោយសារតែអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ និងដោយសារតែច្បាប់ជាតិ មិនបានផ្ដល់មូលដ្ឋានគតិយុត្តិសម្រាប់កំណត់ថាជាអំពើឧក្រិដ្ឋ ចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ នៅឆ្នាំ១៩៧៥ នោះឡើយ[1051]។

អៀង សារី បានជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក. លើមូលដ្ឋានជាច្រើន រួមមានផ្អែកលើការលើកលែងទោស និងការអនុគ្រោះទោសរបស់គាត់ គោលការណ៍*ស្ដីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* និងទាក់ទងទៅនឹងឧក្រិដ្ឋកម្មមួយចំនួន និងទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានចោទប្រកាន់[1052]។ គាត់ក៏បានដាក់ញត្តិបដិសេធផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយយោងទៅលើវិការៈផ្នែកនីតិវិធី[1053] ដែលក្នុងករណីខ្លះត្រូវបានអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថាជាអញ្ញត្រកម្ម[1054]។

ស្រដៀងគ្នានេះដែរ អៀង ធីរិទ្ធ បានជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក. ទាក់ទងនឹងឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវជាច្រើនដែលបានចោទប្រកាន់[1055]។

---

[1049] សំណុំរឿង ០០២ សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D404/2/4។

[1050] សំណុំរឿង ០០២ ការជូនដំណឹងរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹង នីតិវិធីដែលត្រូវបានធ្វើការកែប្រែសម្រាប់ដាក់អញ្ញត្រកម្ម និង ការបញ្ជាក់អំពីកាលបរិច្ឆេទសម្រាប់ការឆ្លើយតប ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០៧១ ឯកសារ E51។ សំណុំរឿង ០០២ ការជូនដំណឹងជាមុនអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E35។ សូមមើលផងដែរ សំណុំរឿង ០០២ អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង៖ អញ្ញត្រកម្ម ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E51/1។ សំណុំរឿង ០០២ ដីកាបង្គាប់ទៅមេធាវីការពារក្ដី អៀង សារី ស្ដីពីការដាក់អញ្ញត្រកម្ម ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E51/6។ សំណុំរឿង ០០២ សេចក្ដីណែនាំដល់ភាគីពាក់ព័ន្ធនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ឯកសារ E51/7។

[1051] សំណុំរឿង ០០២ អញ្ញត្រកម្មរួម ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E51/3។ សូមមើលផងដែរ សំណុំរឿង ០០២ អញ្ញត្រកម្មពាក់ព័ន្ធនឹងនីត្យានុកូលភាពវិធានផ្ទៃក្នុង និងអានុភាពដីកាអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E42។

[1052] សំណុំរឿង ០០២ សេចក្ដីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សារណៈក្រៅផ្លូវការនានានាពេលអនាគត ដែលត្រូវបានចេញជំនួសឱ្យសេចក្ដីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០៧១ ឯកសារ E51/4។ សូមមើលផងដែរ សំណុំរឿង ០០២ អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (អាជ្ញាយុកាលលើអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ) ចុះថ្ងៃទី១៤ ខែកម្ភៈ ឆ្នាំ២០១១ ឯកសារ E43។ សំណុំរឿង ០០២ អញ្ញត្រកម្មរបស់ អៀង សារី អនុលោមតាមវិធាន ៨៩ (វិធាន ៨៩(១)(គ)) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E48។

[1053] សំណុំរឿង ០០២ ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ ឯកសារ E58។

[1054] សូមមើល សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ៥០៨-៥១៦ ពិភាក្សាអំពីបញ្ហាថាតើ ការណ៍នេះពិតជាអញ្ញត្រកម្ម និងកត់សម្គាល់ថា អង្គជំនុំជម្រះសាលាដំបូងពេលខ្លះបានយោងទៅលើវាបែបដូច្នោះ។

[1055] សំណុំរឿង ០០២ អញ្ញត្រកម្មរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E44។

ខៀវ សំផន បានលើកឡើងថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើរូបគាត់ មិនមានយុត្តាធិការលើរឿងក្តីលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[1056] ហើយស្រដៀងគ្នានេះដែរមិនអាចប្រើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ បានទេ ដោយសារតែអាជ្ញាយុកាលដែលអាចអនុវត្តបាននោះ បានផុតរលត់ហើយ[1057]។

បន្ទាប់ពីបានទទួលអញ្ញត្រកម្មសង្ខេប និងចម្លើយតបពីសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី[1058] អង្គជំនុំជម្រះសាលាដំបូងបានសុំឱ្យភាគីដាក់សារណាបន្ថែមទៀតលើអញ្ញត្រកម្មជាក់លាក់។ អង្គជំនុំជម្រះបានបញ្ជាក់ថា ដោយសារដំណោះស្រាយលើបញ្ហាយុត្តាធិការលើរូបបុគ្គល ដែលបានលើកឡើងដោយ ខៀវ សំផន ពាក់ព័ន្ធនឹងការវាយតម្លៃចម្រុះគ្នាលើអង្គច្បាប់ និងអង្គហេតុនោះ អង្គជំនុំជម្រះនឹងមិនដោះស្រាយនៅក្នុងពេលសវនាការបឋមឡើយ ប៉ុន្តែនឹងដោះស្រាយវាដោយអំណះអំណាងផ្ទាល់មាត់ក្នុងអំឡុងពេលដំណាក់កាលដំបូងនៃការជំនុំជម្រះ បន្ទាប់មកមានសវនាការលើភស្តុតាង ទាក់ទងនឹងតួនាទីនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងបួនរូប។ អង្គជំនុំជម្រះក៏បានលើកឡើងផងដែរថា ខ្លួននឹងចេញសេចក្តីណែនាំបន្ថែម ឬសេចក្តីសម្រេចមានសំអាងហេតុ ក្នុងពេលឆាប់ៗ ទាក់ទងនឹងអំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរ ការជ្រៀតជ្រែកផ្នែកនយោបាយ និងវិធានផ្ទៃក្នុង[1059]។

សវនាការបឋមបានធ្វើឡើងរវាងថ្ងៃទី២៧ និងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១[1060]។ សវនាការនេះគ្របដណ្តប់លើ ការផ្តល់បញ្ជីសាក្សីបណ្តោះអាសន្នសម្រាប់ដំណាក់កាលទីមួយនៃការជំនុំជម្រះ និងការជំទាស់ណាមួយទៅនឹងបញ្ជីសាក្សីនេះ អញ្ញត្រកម្មទាក់ទងនឹងគោលការណ៍*ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* ការលើកលែងទោស និងការអនុគ្រោះទោស អាជ្ញាយុកាលទាក់ទងនឹងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ អាជ្ញាយុកាលទាក់ទងនឹងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងការបញ្ជាក់បឋមលើខ្លឹមសារនៃសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី[1061]។

អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចដាច់ដោយឡែក លើអញ្ញត្រកម្មទាក់ទងនឹងបញ្ហាខាងក្រោមនេះ៖

- **ធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង៖** អង្គជំនុំជម្រះយល់ឃើញថា កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មិនមានចែងហាមឃាត់ការអនុម័តវិធានផ្នែកនីតិវិធីនោះឡើយ ហើយអង្គជំនុំជម្រះបានឯកភាពជាមួយនឹងអង្គបុរេជំនុំជម្រះថា វិធានផ្ទៃក្នុងបានបង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក. និងមិនផ្ទុយទៅនឹងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជានោះទេ[1062]។
- **ឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ**៖ អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ដីកាដំណោះស្រាយមិនបានរៀបរាប់អំពីអង្គហេតុពាក់ព័ន្ធសំខាន់ៗ ដែលនាំទៅដល់ការចោទប្រកាន់អំពីឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ ឬទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបានចំពោះបទឧក្រិដ្ឋទាំងនោះឡើយ ហើយបើទោះជាអង្គជំនុំជម្រះសាលាដំបូងឯកភាពជាមួយនឹងសហព្រះរាជអាជ្ញាថា ញត្តិសុំបដិសេធ ឬធ្វើការកែប្រែដីកាដំណោះស្រាយ មិនបង្កើតបានជាផ្នែកមួយនៃក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. យ៉ាងណាក្តី ក៏អង្គជំនុំជម្រះមិនចាត់ទុកថាផ្នែកនៃដីកាដំណោះស្រាយ ដែលទាក់ទងនឹង

[1056] សំណុំរឿង ០០២ អញ្ញត្រកម្មទាក់ទងទៅនឹងយុត្តាធិការ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ E46។
[1057] សំណុំរឿង ០០២ អញ្ញត្រកម្មទាក់ទងទៅនឹងការរលត់បណ្តឹងអាជ្ញា (បទល្មើសជាតិ) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ E47។
[1058] សំណុំរឿង ០០២ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តីអនុលោមតាមវិធាន ៨៩ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១ ឯកសារ E51/5/3/1។ សំណុំរឿង ០០២ ចម្លើយតបរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងអញ្ញត្រកម្មបឋមរបស់មេធាវីការពារក្តីអនុលោមតាមវិធាន ៨៩ ចុះថ្ងៃទី ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១១ ឯកសារ E51/5/4។
[1059] សំណុំរឿង ០០២ សេចក្តីណែនាំទៅកាន់ភាគីទាក់ទងនឹងអញ្ញត្រកម្ម និងបញ្ហាពាក់ព័ន្ធ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ឯកសារ E51/7។
[1060] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E1/4.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E1/5.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E1/6.1។ សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E1/7.1។
[1061] សូមមើល សំណុំរឿង ០០២ ការរៀបចំកាលវិភាគសវនាការបឋម ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១១ ឯកសារ E86។
[1062] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ឯកសារ E51/14 កថាខណ្ឌ ៦-៧។

ឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ បំពេញតាមបុរេលក្ខខណ្ឌដើម្បីឱ្យដីកាដំណោះស្រាយនោះមានសុពលភាពនោះឡើយ។ ដោយសារតែមិនមានលទ្ធភាពណា ដែលអង្គជំនុំជម្រះសាលាដំបូង អាចធ្វើការកែប្រែដីកាដំណោះស្រាយ ឬបង្វែរវាត្រឡប់ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការកែប្រែនោះ អង្គជំនុំជម្រះសម្រេចថា ខ្លួនមិនមានមូលដ្ឋានក្នុងការកាត់ទោសជនជាប់ចោទ ចំពោះបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ នោះឡើយ[1063]។

- **ការលើកលែងទោស និងការអនុគ្រោះទោស និង គោលការណ៍*ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ***៖ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ខ្លួនបានប្រឈមនឹងអញ្ញត្រកម្មនានា ដែលលើកឡើងអំពីបញ្ហាសំខាន់ៗស្រដៀងគ្នាទៅនឹងបញ្ហា ដែលបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ និងថាបើទោះបីជាខ្លួនមិនមែនជាស្ថាប័នពិនិត្យមើលឡើងវិញ ឬជាស្ថាប័នដោះស្រាយបណ្តឹងឧទ្ធរណ៍ក៏ដោយ ដើម្បីឱ្យមានការសន្សំសំចៃធនធានតុលាការ អង្គជំនុំជម្រះមិនចេញសេចក្តីសម្រេចវែងនោះទេ ត្រង់ចំណុចណាដែលខ្លួនឯកភាពតាមអង្គបុរេជំនុំជម្រះ[1064]។ អង្គជំនុំជម្រះបានលើកឡើងថា ខ្លួនឯកភាពជាមួយនឹងការសម្រេចរបស់ អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងចំណុចខ្វះចន្លោះនៃការជំនុំជម្រះឆ្នាំ១៩៧៩ របស់ អៀង សារី និងនៅក្នុងផ្នែកសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះលើបញ្ហានេះ ហើយបានបន្តពិចារណាថា ដោយសារតែ អៀង សារី បានស្វែងរកការពឹងផ្អែកលើអានុភាពរួមគ្នានៃការជំនុំជម្រះឆ្នាំ១៩៧៩ និងការអនុគ្រោះទោសគាត់ក្នុងឆ្នាំ១៩៩៦ ដើម្បីទទួលបាននិទណ្ឌភាពពីឧក្រិដ្ឋកម្មណាមួយ ទាក់ទងទៅនឹងអង្គហេតុដែលបានកាត់ទោស ការអនុវត្តគោលការណ៍*ស្តីពីគ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* នឹងមានតម្លៃស្មើនឹងការលើកលែងទោស*តាមព្រឹត្តន័យ*ចំពោះអង្គហេតុទាំងឡាយដែលបានវិនិច្ឆ័យក្នុងឆ្នាំ១៩៧៩[1065]។

អង្គជំនុំជម្រះសាលាដំបូង បានសម្រេចលើកពេលពិចារណាលើបញ្ហាជាក់លាក់ ទាក់ទងនឹងយុត្តាធិការ ទៅសម្រេចនៅពេលក្រោយ[1066]។

### ៥.២.៥.២. ការបំបែកសំណុំរឿង

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ដើម្បីការពារលទ្ធភាពរបស់ខ្លួន ក្នុងការចេញសាលក្រមមួយទាន់ពេលវេលាក្នុងសំណុំរឿង ០០២ ដោយយោងទៅលើទំហំ នឹងភាពស្មុគស្មាញនៃដីកាដំណោះស្រាយ ក៏ដូចជាជនជាប់ចោទមានភាពទ្រុឌទ្រោមផ្នែករាងកាយ និងអាយុកាន់តែច្រើននោះ អង្គជំនុំជម្រះសាលាដំបូង តាមការផ្តួចផ្តើមរបស់ខ្លួន បានបំបែកសំណុំរឿង ០០២ ទៅជារឿងក្តីតូចៗ[1067]។ រឿងក្តីទីមួយ គឺសំណុំរឿង ០០២/០១ គឺត្រូវផ្តោតលើការចោទប្រកាន់ផ្នែកអង្គហេតុ ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ (លើកលែង ដោយមូលហេតុសាសនា) ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ (ទាក់ទងនឹងដំណាក់កាលទីមួយ និងទីពីរ)[1068]។

បន្ទាប់ពីសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីមួយ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះឱ្យពិចារណាឡើងវិញ និងឱ្យពង្រីកវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយមានទីតាំងឧក្រិដ្ឋ

---

[1063] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E122 កថាខណ្ឌ ១៥-១៦, ២២-២៣។

[1064] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និង ការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ២៣។

[1065] សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និង ការលើកលែងទោស និងការអនុគ្រោះទោស) ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E51/15 កថាខណ្ឌ ២៣, ៣២-៣៦។

[1066] សូមមើល សំណុំរឿង ០០២/០១ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ឯកសារ E124 កថាខណ្ឌ ៩ និងជើងទំព័រ ៧។

[1067] សំណុំរឿង ០០២/០១ ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E124។

[1068] សូមមើល សាលក្រម សំណុំរឿង ០០២/០២ ឧបសម្ព័ន្ធ ១៖ ប្រវត្តិនីតិវិធី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465.1 កថាខណ្ឌ ៧ និងជើងទំព័រដែលអមជាមួយ។

កម្មបន្ថែមចំនួនប្រាំបួន[1069]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើរបស់សហព្រះរាជអាជ្ញា ប៉ុន្តែមិនបានបដិសេធលទ្ធភាពបញ្ចូលការចោទប្រកាន់បន្ថែម ឬបទចោទបន្ថែមទៅនឹងការជំនុំជម្រះលើកទីមួយនោះទេ[1070]។ បន្ទាប់មកសហព្រះរាជអាជ្ញាបានស្នើសុំបន្ថែមទីតាំងឧក្រិដ្ឋកម្មចំនួនបី (ស្រុកកំពង់ត្រឡាចលើ ទួលពោធិ៍ជ្រៃ និង ស-២១ រួមទាំងទីតាំងពាក់ព័ន្ធរបស់វា គឺជើងឯក) ទៅក្នុងសំណុំរឿង ០០២/០១[1071]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធភាគច្រើននៃសំណើរបស់សហព្រះរាជអាជ្ញា ដោយអនុញ្ញាតតែការចោទប្រកាន់ទាក់ទងនឹងការសម្លាប់អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃភ្លាមៗបន្ទាប់ពីការជម្លៀសទីក្រុងភ្នំពេញ ដើម្បីបញ្ចូលទៅក្នុងសំណុំរឿង ០០២/០១[1072]។ អង្គជំនុំជម្រះសាលាដំបូងសម្រេចដូច្នេះផ្អែកលើតម្រូវការចាំបាច់ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី ភាពទ្រុឌទ្រោមផ្នែកសុខភាពរបស់ អៀង ធីរិទ្ធ និង អៀង សារី និងភាពមិនពាក់ព័ន្ធគ្នាជាក់ស្តែងរវាងទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតដែលបានស្នើឡើង និងវិសាលភាពដែលបានបង្កើតនៃសំណុំរឿង ០០២/០១[1073]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ខ្លួននឹងមិនពិចារណាលើការពង្រីកវិសាលភាពបន្ថែមទៀតនោះឡើយ[1074]។

សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខ ដោយតវ៉ាថា គួរតែពង្រីកវិសាលភាពដើម្បីបញ្ចូលស្រុកកំពង់ត្រឡាចលើ មន្ទីរស-២១ និង ជើងឯក[1075]។ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាថា វាជាការត្រឹមត្រូវសម្រាប់អង្គជំនុំជម្រះសាលាដំបូង ក្នុងការពិចារណាអំពីភាពឆាប់រហ័ស និងលំដាប់លំដោយនៃសំណុំរឿង ០០២/០១ ប៉ុន្តែថា មានកង្វះខាត *តាមសេចក្តីបញ្ជាក់ពីដំបូង* ការពិចារណាលើសំអាងហេតុ និងកត្តាដែលជាប់ពាក់ព័ន្ធ ដូចជាភាពជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ អង្គជំនុំជម្រះតុលាការកំពូលក៏បង្ហាញកង្វល់ថា ដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះ ត្រូវបានចេញដោយមិនបានស្នើសុំ

---

[1069] សំណុំរឿង ០០២/០១ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើការពិចារណាឡើងវិញលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង" ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ ឯកសារ E124/2។ ទីតាំងទាំងប្រាំបួនដែលរៀបរាប់នៅក្នុងសំណើនោះមាន ស្រុកកំពង់ត្រឡាចលើ (ស្រុក ១២) ទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ មន្ទីរសន្តិសុខ ស-២១ និងជើងឯក (មិនរាប់បញ្ចូលការដ្ឋានព្រៃ ស) មន្ទីរសន្តិសុខភូមិភាគឧត្តរ ក្រាំងតាចាន់ និងអ្នករកន្សែង ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងសហករណ៍ត្រាំកក់។

[1070] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ឯកសារ E124/7 កថាខណ្ឌ ១២។

[1071] សំណុំរឿង ០០២/០១ សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ឯកសារ E163។

[1072] សំណុំរឿង ០០២/០១ សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ឯកសារ E163/5 កថាខណ្ឌ ២-៣។ សូមមើលផងដែរ សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារD427 កថាខណ្ឌ ៧០៥-៧១១។ សំណុំរឿង ០០២/០១ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163) ឯកសារ E124/7.3 ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ កថាខណ្ឌ ១ (vii)។

[1073] សំណុំរឿង ០០២/០១ សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាធរមាន ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ឯកសារ E163/5 កថាខណ្ឌ ២។ សូមមើលផងដែរ កិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ឯកសារ E1/114.1 ទំព័រ ៩៣-៩៤, ៩៧-៩៨ (អង់គ្លេស)។

[1074] សូមមើល សំណុំរឿង ០០២/០១ សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់ អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ឯកសារ E223/2 កថាខណ្ឌ ៣។

[1075] សំណុំរឿង ០០២/០១ បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១ មានឧបសម្ពន្ធ (I) និងឧសម្ពន្ធសម្ងាត់ (II) ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ ឯកសារ E163/5/1/1។

ទស្សនយោបល់ពីភាគី។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា វិធីដែលអង្គជំនុំជម្រះសាលាដំបូងបំបែកសំណុំរឿង ០០២ គឺរំលោភលើសិទ្ធិរបស់ភាគីក្នុងការទទួលបានយោបល់ដែលមានសំអាងហេតុ និងសិទ្ធិផ្តល់ទស្សនយោបល់។ កំហុសទាំងនេះ តម្រូវឱ្យដីកាបំបែកកិច្ចដំណើរការនីតិវិធីទៅជាមោឃៈ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ទៀតថា អ.វ.ត.ក. គប្បីស្វែងរកការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីគាំទ្រការជំនុំជម្រះសំណុំរឿង ០០២ ឱ្យបានទាន់ពេលវេលាសមស្រប[1076]។

បន្ទាប់ពីបានស្តាប់ភាគីពាក់ព័ន្ធ[1077] អង្គជំនុំជម្រះសាលាដំបូងជាថ្មីម្តងទៀត បានបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២[1078]។ តាមរយៈសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទីពីរនេះ អង្គជំនុំជម្រះសាលាដំបូង បានកំណត់វិសាលភាពសំណុំរឿង ០០២/០១ មកត្រឹមវិសាលភាពដដែល ដូចដែលខ្លួនបានជ្រើសរើសមុនសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល មកត្រឹមការចោទប្រកាន់ទាក់ទងនឹង "ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរ និងការសម្លាប់ដែលបានធ្វើឡើងនៅទួលពោធិ៍ជ្រៃ"[1079]។

សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខ ស្នើសុំឱ្យដាក់បញ្ចូលការចោទប្រកាន់ទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[1080]។ នួន ជា ក៏បានប្តឹងសាទុក្ខ ស្នើសុំឱ្យមានការដាក់បញ្ចូលអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅតាមការដ្ឋាន និងសហករណ៍[1081]។ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាឃើញថា បរាជ័យរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តតាមការណែនាំពីមុនរបស់អង្គជំនុំជម្រះតុលាការកំពូលដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីត្រូវតែពិចារណាឱ្យបានដិតដល់លើភាពជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះ បង្កើតបានជាកំហុសអង្គច្បាប់ និងកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង។ ទោះជាយ៉ាងណាដោយយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានត្រៀមខ្លួនរួចរាល់ក្នុងការជំនុំជម្រះបទចោទដែលនៅសល់នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២/០១ និងដោយយល់ឃើញថា ការបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងពង្រីកវិសាលភាពសំណុំរឿង ០០២/០១ នៅពេលនោះ នឹងនាំឱ្យមានការពន្យារពេលមិនចាំបាច់នោះ អង្គជំនុំជម្រះតុលាការកំពូលបានណែនាំថា បទចោទប្រកាន់ដែលគប្បីបញ្ចូលក្នុងសំណុំរឿង ០០២/០១ ជាជម្រើសម្យ៉ាងទៀតនោះគឺបញ្ចូលទៅក្នុងសំណុំរឿង ០០២/០២ និងថាសំណុំរឿង ០០២/០២ ត្រូវចាប់ផ្តើមឱ្យបានឆាប់ដូចដែលអាចធ្វើទៅបាន។ ដើម្បីធ្វើទៅបាន អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ "នាពេលបច្ចុប្បន្ននេះបានក្លាយជាបញ្ហាសំខាន់"។

---

[1076] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ E163/5/1/13 កថាខណ្ឌ ៣៦-៥១។

[1077] សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E1/171.1។ សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E1/172.1។ សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E1/173.1 ។ កត់សម្គាល់ថា សវនាការទាំងអស់នេះដំបូងឡើយត្រូវបានគ្រោងធ្វើនៅថ្ងៃទី១៤ និង១៥ ខែកុម្ភៈ ឆ្នាំ២០១៣។ សូមមើល សំណុំរឿង ០០២/០១ ការណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ ០០២/០១ (ឯកសារ E163/5/1/13) ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E163/5/1/13/1។ អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ មុនពេលអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់ខ្លួន។

[1078] សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ ឯកសារ E1/176.1 ទំព័រ ២-៤ (អង់គ្លេស)។ សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារ E284។

[1079] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារ E284។

[1080] សំណុំរឿង ០០២/០១ បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ឯកសារ E284/2/1 ៨៤។

[1081] សំណុំរឿង ០០២/០១ បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ សហព្រះរាជអាជ្ញាលើសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ឯកសារ E284/4/1 កថាខណ្ឌ ៨៤។

អង្គជំនុំជម្រះតុលាការកំពូលបានណែនាំឱ្យការិយាល័យរដ្ឋបាល ស្វែងរកជាបន្ទាន់នូវលទ្ធភាពបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង[1082]។

កិច្ចប្រជុំរៀបចំសវនាការត្រូវបានធ្វើឡើង ដើម្បីពិភាក្សាលើទិដ្ឋភាពផ្សេងៗនៃការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរ ដែលក្នុងកិច្ចប្រជុំនោះប្រធានស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាលត្រូវបានពិគ្រោះយោបល់[1083]។ បន្ទាប់ពីកិច្ចប្រជុំនោះមក ប្រធានអង្គជំនុំជម្រះសាលាដំបូង បានសន្និដ្ឋានថា ការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង នឹងមិនបម្រើផលប្រយោជន៍យុត្តិធម៌នោះទេ ដោយសារតែដំណើរការនីតិវិធីជំនុំជម្រះនេះ មិនបានឆាប់រហ័សជាងដំណើរការនីតិវិធីនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះដែលមានស្រាប់ ដែលគាត់បានយល់ដឹងសំណុំរឿងរួចទៅហើយនោះឡើយ[1084]។

ក្នុងអំឡុងពេលធ្វើផែនការសំណុំរឿង ០០២/០២ បញ្ហាបំបែកសំណុំរឿង បានកើតឡើងជាថ្មីម្តងទៀត[1085]។ ភាគីនានាត្រូវបានស្តាប់ទស្សនយោបល់លើវិសាលភាពនៃសំណុំរឿង ០០២/០២[1086]។ សហព្រះរាជអាជ្ញាបានស្នើថា ទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ជាក់លាក់ ត្រូវដាក់បញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ និងថា ទីតាំងដែលនៅសល់ត្រូវដកចេញជាអចិន្ត្រៃយ៍[1087]។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានគាំទ្រសំណើរបស់សហព្រះរាជអាជ្ញា ប៉ុន្តែបានស្នើសុំវិសាលភាពទូលំទូលាយជាងនេះ និងបានតវ៉ាថា មិនមានបទចោទណា ឬកាលៈទេសៈអង្គហេតុពាក់ព័ន្ធណា គួរត្រូវបានទម្លាក់ចោលនោះទេ[1088]។ ខៀវ សំផន បានជំទាស់ទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមទៀត[1089] ចំណែក នួន ជា បានគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាដែលថា ទីតាំងដែលត្រូវបានដកចេញពីសំណុំរឿង ០០២/០២ ត្រូវដកចេញជាអចិន្ត្រៃយ៍ ប៉ុន្តែតវ៉ាថា ភស្តុតាងណាដែលនៅក្នុងកម្មវត្ថុណាមួយ នៅក្នុងវិសាលភាពដីកាដំណោះស្រាយនៃសំណុំរឿង ០០២ គួរត្រូវបានទទួលយក បើទោះបីជាវាមិនទាក់ទងផ្ទាល់

---

[1082] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២ សេចក្តីសង្ខេបនៃសំអាងហេតុ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ E284/4/7 កថាខណ្ឌ ៩-១១។

[1083] សូមមើល សំណុំរឿង ០០២/០១ អនុស្សរណៈរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E301/4 កថាខណ្ឌ ២។

[1084] សំណុំរឿង ០០២/០១ អនុស្សរណៈរបស់ប្រធានអង្គជំនុំកជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទីពីរនៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដើម្បីជំនុំជម្រះលើការចោទប្រកាន់ដែលមិនទាន់ត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E301/4 កថាខណ្ឌ ១០។

[1085] សូមមើល សំណុំរឿង ០០២/០២ ផែនការការងាររបស់ អង្គជំនុំជម្រះសាលាដំបូង សម្រាប់សំណុំរឿង ០០២/០០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E301/5។ សំណុំរឿង ០០២/០២ ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង (លម្អិត) ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E301/5.1។

[1086] សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ព័ន្ធ ក ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E301/2។ សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/1។ សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/2។ សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/3។ សំណុំរឿង ០០២/០២ ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឲ្យដាក់សារណាទាក់ទិននឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/4។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E1/238.1។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E1/238.2។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ E1/239.1។

[1087] សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ព័ន្ធ ក ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ឯកសារ E301/2។

[1088] សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/3។

[1089] សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/2 កថាខណ្ឌ ៣-៦។ សំណុំរឿង ០០២/០២ ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឲ្យដាក់សារណាទាក់ទិននឹងវិសាលភាពនៃ សំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/4 កថាខណ្ឌ ៦-៧។

ទៅនឹងទីតាំងឧក្រិដ្ឋកម្មដែលជាបញ្ហាចោទនៅក្នុងសំណុំរឿង ០០២/០២ ក៏ដោយ[1090]។ បន្ទាប់ពីនោះមក អង្គជំនុំជម្រះសាលាដំបូង បានបំបែកសំណុំរឿង ០០២ បន្តទៀត និងបានលើកឡើងថា សំណុំរឿង ០០២/០២ រួមបញ្ចូល៖

i. អំពើប្រល័យពូជសាសន៍លើជនជាតិចាម និងវៀតណាម (លើកលែងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជា នៅលើទឹកដីវៀតណាម)
ii. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ទូទាំងប្រទេស)
iii. ការបោសសម្អាតផ្ទៃក្នុង
iv. មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល
v. ការដ្ឋានទំនប់ ១ មករា ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការដ្ឋានទំនប់ត្រពាំងថ្ម
vi. សហករណ៍ត្រាំកក់
vii. ការប្រព្រឹត្តលើពុទ្ធសាសនិក (កំណត់ត្រឹមតែសហករណ៍ត្រាំកក់) ជនជាតិចាម (លើកលែងមន្ទីរសន្តិសុខក្រូចឆ្មារ) និងជនជាតិវៀតណាម (លើកលែងតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តន៍កម្ពុជាលើទឹកដីវៀតណាម)
viii. ការកំណត់គោលដៅលើអតីតមន្ត្រីសាធារណៈរដ្ឋខ្មែរ (កំណត់ត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)[1091]។

អង្គជំនុំជម្រះបានលើកឡើងថា ខ្លួននឹងដោះស្រាយបទចោទនៅក្នុងដីកាដំណោះស្រាយ ដែលមិនបានបញ្ចូលក្នុងសំណុំរឿង ០០២/០១ ឬសំណុំរឿង ០០២/០២ ក្នុងពេលវេលាសមស្រប[1092]។ ខៀវ សំផន បានប្ដឹងសាទុក្ខ ដោយអះអាងថាអង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន បានបំពេញកិច្ចផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ និងបានបណ្ដាលឱ្យមានភាពអយុត្តិធម៌ ដែលចាំបាច់ត្រូវធ្វើមោឃភាព[1093]។ អង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ បានតម្កល់សេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ប៉ុន្តែពិចារណាថា ស្ថានភាពនៃបទចោទដែលនៅសេសសល់មិនច្បាស់លាស់ ដោយសារតែភាពរុញរារបស់អង្គជំនុំជម្រះសាលាដំបូងម្ដងហើយម្ដងទៀត ទាក់ទងនឹងបទចោទដែលនៅសេសសល់ ហើយដើម្បីផលប្រយោជន៍នៃភាពប្រាកដប្រជាផ្នែកច្បាប់ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចព្យួរកិច្ចដំណើរការនីតិវិធី ទាក់ទងនឹងបទចោទដែលនៅក្រៅវិសាលភាពនៃ សំណុំរឿង ០០២/០១ និង ០០២/០២[1094]។

ខណៈដែលអង្គជំនុំជម្រះសាលាដំបូង បន្ទាប់មកបានផ្ដល់ការបញ្ជាក់ទាក់ទងនឹង "ផលវិបាកជាក់ស្ដែង និងផលវិបាកផ្លូវច្បាប់ រួមទាំង ផលវិបាកលើភស្តុតាង ដែលកើតចេញពីការបំបែកកិច្ចដំណើរការនីតិ

[1090] សំណុំរឿង ០០២/០២ ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឱ្យដាក់សារណាទាក់ទិននឹងវិសាលភាពនៃ សំណុំរឿង ០០២/០២ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ឯកសារ E301/5/4។
[1091] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ E301/9/1។ សំណុំរឿង ០០២/០២ បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹង សំណុំរឿង ០០២/០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ E301/9/1.1។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សេចក្ដីសម្រេចអំពីលំដាប់លំដោយ នៃអង្គហេតុដែលត្រូវជំនុំជម្រះ នៅក្នុសំណុំរឿង ០០២/០២ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E315។
[1092] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ E301/9/1 ផ្នែកសម្រេចសេចក្ដី។
[1093] សំណុំរឿង ០០២/០២ បណ្ដឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម លើសំណុំរឿង ០០២ និងលើការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/1 កថាខណ្ឌ ៦-៦៦។
[1094] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/3 កថាខណ្ឌ ៨៨-៩១។

វិធី”[1095] ខៀវ សំផន លើកឡើងអំពីតម្រូវការបញ្ជាក់បន្ថែម ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ លើប្រធានបទការបោសសម្អាតផ្ទៃក្នុង[1096]។ បន្ទាប់ពីបានស្ដាប់ភាគីលើកមូលហេតុនេះរួចមក អង្គជំនុំជម្រះសាលាដំបូង បានផ្ដល់ការបញ្ជាក់លើបញ្ហានោះ និងបានបញ្ជាក់វិសាលភាព សំណុំរឿង ០០២/០២ ដូចដែលបានបង្ហាញ នៅក្នុងសេចក្ដីសម្រេច លើការបំបែកកិច្ចដំណើរការនីតិវិធីចុងក្រោយរបស់ខ្លួន[1097]។ បន្ទាប់មក ដោយមានសំណើបន្ថែមមួយទៀតសុំការបញ្ជាក់បំភ្លឺ លើផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងបន្ទាប់ពីការស្ដាប់សវនាការលើកមូលហេតុនេះ[1098] និងសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចប់កិច្ចដំណើរការនីតិវិធី ទាក់ទងនឹងអង្គហេតុមិនបានបញ្ចូលក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ និង ០០២/០២[1099] នៅខែកុម្ភៈ ឆ្នាំ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចប់កិច្ចដំណើរការនីតិវិធី ទាក់ទងនឹងអង្គហេតុដែលមិនបានបញ្ចូលក្នុងសំណុំរឿង ០០២/០១ និង ០០២/០២[1100]។

## ៥.២.៦. សំណុំរឿង ០០២/០១

“*ការជំនុំជម្រះក្ដីនេះមានសារៈសំខាន់ចំពោះប្រទេសកម្ពុជាណាស់ ប៉ុន្តែវាមិនមែនសំខាន់សម្រាប់តែប្រទេសកម្ពុជាមួយប៉ុណ្ណោះទេ វាសំខាន់សម្រាប់ពិភពលោកទាំងមូលផងដែរ។ ការជំនុំជម្រះក្ដីនេះបង្ហាញឱ្យឃើញថា បទឧក្រិដ្ឋដែលមានលក្ខណៈធំធេង និងធ្ងន់ធ្ងរដូច្នេះ គេនឹងមិនអាចបំភ្លេចវាបាន។ ចំណែកឯអ្នកដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ ត្រូវតែនាំមកផ្ដន្ទាទោស*”[1101]

### ៥.២.៦.១. ការជំនុំជម្រះ

មុនពេលចាប់ផ្ដើមការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឱ្យភាគីទាំងអស់ដាក់បញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលខ្លួនស្នើឡើង និងបញ្ជីឯកសារ និងវត្ថុតាង ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ[1102]។ ភាគីបានស្នើជាសរុបសាក្សីចំនួន ១.០៥៤ នាក់ និងបានស្នើសុំឱ្យទទួលយកជាភស្តុតាងនូវឯកសារប្រមាណ ៧.៦០០[1103]។ ក្នុងអំឡុងពេលសវនាការបឋម ក្នុងខែមិថុនា ឆ្នាំ២០១១ ក្នុងពេលកិច្ចប្រជុំរៀបចំសវនាការក្នុងខែមេសា ឆ្នាំ២០១១ ខែសីហា ឆ្នាំ២០១២ និងខែមិថុនា ឆ្នាំ

---

[1095] សំណុំរឿង ០០២/០២ សេចក្ដីបញ្ជាក់បំភ្លឺអំពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿ០០២ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ឯកសារ E318 កថាខណ្ឌ ១, ៣។

[1096] សំណុំរឿង ០០២/០២ សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឱ្យផ្ដល់ការបំភ្លឺអំពីវិសាលភាពនៃបណ្ដឹងទៅអង្គជំនុំជម្រះ ពាក់ព័ន្ធនឹង “ការបោសសម្អាតផ្ទៃក្នុង” ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E420។

[1097] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ E1/444.1។ សំណុំរឿង ០០២/០២ សេចក្ដីសម្រេចលើសំណើបន្ទាន់របស់ ខៀវ សំផន សុំឱ្យផ្ដល់ការបំភ្លឺអំពីវិសាលភាពនៃការបោសសំអាតផ្ទៃក្នុង នៅក្នុងសំណុំរឿង ០០២/០២ ឯកសារ E420/1 ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៦ កថាខណ្ឌ ៤-៩។

[1098] សំណុំរឿង ០០២/០២ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំសេចក្ដីបញ្ជាក់ទាក់ទងនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E439។ សំណុំរឿង ០០២/០២ សេចក្ដីសង្កេតរបស់ក្រុមមេធាវីការពារក្ដី លោក ខៀវ សំផន ឆ្លើយតបទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំសេចក្ដីបញ្ជាក់ទាក់ទងនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E439/1។ សំណុំរឿង ០០២/០២ ចម្លើយរបស់ នួន ជា តបសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំសេចក្ដីបញ្ជាក់ទាក់ទងនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E439/2។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ឯកសារ E1/519.1។

[1099] សំណុំរឿង ០០២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំសេចក្ដីបញ្ជាក់ទាក់ទងនឹងបទចោទនៅសេសសល់ក្នុងសំណុំរឿង០០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ E439/3។ សូមមើលផងដែរ សំណុំរឿង ០០២ សេចក្ដីសម្រេចលើការកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ E439/5 កថាខណ្ឌ ១។

[1100] សំណុំរឿង ០០២ សេចក្ដីសម្រេចលើការកាត់បន្ថយវិសាលភាពនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ E439/5 កថាខណ្ឌ ១។

[1101] ប្រតិចារឹក ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ ឯកសារ E1/229.1 ទំព័រ ៣ (អង់គ្លេស)។

[1102] សំណុំរឿង ០០២ ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ឯកសារ E9។

[1103] សូមមើល សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៤។

២០១៣ និងក្នុងអំឡុងពេលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគី អំពីសាក្សីដែលខ្លួនមានបំណងកោះហៅ[1104]។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការជំនុំជម្រះនឹងចាប់ផ្តើមជាមួយនឹងប្រធានបទតាមលំដាប់លំដោយខាងក្រោម៖

> **ទីមួយ** អំពីរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ **ទីពីរ** អំពីតួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅមុនការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងនៅពេលជនជាប់ចោទបានទទួលការចាត់តាំងនូវតួនាទីទាំងនេះផង **ទីបី** តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគាត់តាមការចាត់តាំង ក្របខ័ណ្ឌនៃសិទ្ធិអំណាចរបស់ពួកគាត់ និងខ្សែបណ្តាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធនឹងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក និង**ទីបួន** គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្តីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1105]។

សេចក្តីថ្លែងបើកក្នុងសំណុំរឿង ០០២/០១ បានចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១[1106]។ ភាគីទាំងអស់ លើកលែងតែ អៀង សារី បានធ្វើសេចក្តីថ្លែងបើក[1107]។ សវនាការលើភស្តុតាងបានធ្វើឡើងចាប់ពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១[1108]។ សវនាការលើភស្តុតាងបានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣[1109] ហើយសេចក្តីថ្លែងបិទបានធ្វើឡើងនៅចន្លោះថ្ងៃទី១៦ និង ៣១ ខែតុលា ឆ្នាំ២០១៣[1110]។ ការជំនុំជម្រះ រួមទាំងសេចក្តីថ្លែងបិទ មានរយៈពេលសរុបចំនួន ២២២ ថ្ងៃសវនាការ[1111]។

ក្នុងរយៈពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ បុគ្គលចំនួន ៩២ នាក់ បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ ទាក់ទងនឹងអង្គសេចក្តីនៃកិច្ចដំណើរការនីតិវិធី រួមបញ្ចូលសាក្សីចំនួន ៥៨ នាក់ (ក្នុងចំណោមនោះមានប្រាំនាក់ជាសាក្សីអត្តចរិត ដែលបានកោះហៅតាមសំណើរបស់ ខៀវ សំផន) អ្នកជំនាញបីនាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣១ នាក់[1112]។ បុគ្គលប្រាំនាក់បានបង្ហាញខ្លួនពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកកំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹករបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនបានចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះចំនួន ១.១២៤។ អង្គជំនុំជម្រះបានទទួលយកភស្តុតាងឯកសារចំនួន ៥.៨២៤ រួមបញ្ចូលទាំងឯកសារសហកាល និងឯកសារវិភាគ កំណត់ត្រាជាសំឡេង និងជាវីដេអូ និងភស្តុតាងជាលាយលក្ខណ៍អក្សរ របស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី[1113]។

---

[1104] សូមមើល ឧទាហរណ៍ សំណុំរឿង ០០២ សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E312។ សំណុំរឿង ០០២ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ ឯកសារ E218។

[1105] សូមមើល សំណុំរឿង ០០២ សំណើរបស់លោក អៀង សារី សុំឱ្យដាក់បន្ថែមប្រធានបទថ្មីៗសម្រាប់សវនាការ ទៅក្នុងកម្មវិធីសវនាការ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១ ឯកសារ E89 កថាខណ្ឌ ១។

[1106] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E1/13.1។

[1107] អៀង សារី បានបោះបង់សិទ្ធិធ្វើសេចក្តីថ្លែងបើក។ សូមមើល សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E1/14.1 ទំព័រ ១១៧-១២១ (អង់គ្លេស)។

[1108] សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១ ឯកសារ E1/16.1។

[1109] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ E1/227.1។

[1110] សូមមើល សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៨។

[1111] សាលក្រម សំណុំរឿង ០០២/០១ ប្រវត្តិនីតិវិធី ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313.1 កថាខណ្ឌ ៤៥។

[1112] សាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៣២។ សូមមើលផងដែរ សំណុំរឿង ០០២/០១ សេចក្តីសម្រេចស្តាពរស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E312។

[1113] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៣២-៣៣។

### ៥.២.៦.២. សម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ការបំបែកសំណុំរឿង និងមរណភាព

ពីរបីថ្ងៃមុនពេលសេចក្ដីថ្លែងបើក ក្នុងសំណុំរឿង ០០២ និងបន្ទាប់ពីការពិនិត្យលើសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ ដោយអ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ និងក្រុមអ្នកជំនាញផ្នែកវិកលវិទ្យា និងការស្ដាប់សវនាការពីភាគីរួចមក អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា អៀង ធីរិទ្ធ មិនមានសម្បទាចូលរួមសវនាការទេ ដោយសារតែផលប៉ះពាល់នៃជំងឺវង្វេងវង្វាន់ស្មារតីដែលចេះតែវិវឌ្ឍទៅមុខ។ អង្គជំនុំជម្រះបានបង្គាប់ឱ្យបំបែកបទចោទប្រឆាំងនឹង អៀង ធីរិទ្ធ ចេញពីសំណុំរឿង ០០២ ដែលជាការព្យួរកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ និងការដោះលែងគាត់ដោយឥតលក្ខខណ្ឌ[1114]។ អង្គជំនុំជម្រះសាលាដំបូងមិនអាចរកសំឡេងគាំទ្របួន ដើម្បីសម្រេចថាតើខ្លួនមានយុត្តាធិការ ដាក់លក្ខខណ្ឌលើការដោះលែង អៀង ធីរិទ្ធ បានទេ (ថាតើត្រូវបង្គាប់ឱ្យគាត់ស្វែងរកការព្យាបាលផ្នែកវេជ្ជសាស្ត្រ ឬត្រូវដោះលែងដោយឥតលក្ខខណ្ឌ) ប៉ុន្តែបានឯកភាពគ្នាជាឯកច្ឆន្ទថា ផលវិបាកនៃការខ្វែងយោបល់គ្នាបែបនេះគឺត្រូវដោះលែង អៀង ធីរិទ្ធ[1115]។

បន្ទាប់ពីបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[1116] អង្គជំនុំជម្រះតុលាការកំពូល ដោយមានចៅក្រម Chandra Nihal Jayasinghe ជំទាស់ បានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ក្នុងការសន្និដ្ឋានថា អៀង ធីរិទ្ធ គប្បីត្រូវបានដោះលែងដោយឥតលក្ខខណ្ឌ និងបដិសេធដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឱ្យដោះលែងគាត់។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងស្នើសុំឱ្យមានការព្យាបាល អៀង ធីរិទ្ធ បន្ថែមទៀត បន្ទាប់មកបានបង្គាប់ឱ្យធ្វើការពិនិត្យ អៀង ធីរិទ្ធ ឡើងវិញ ថាតើគាត់មានសម្បទាចូលរួមសវនាការ ឬទេ និងធ្វើការសម្រេចជាថ្មីលើសម្បទាក្នុងការចូលរួមសវនាការរបស់គាត់ បន្ទាប់ពីការពិនិត្យនេះ[1117]។

អង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រ បានត្រួតពិនិត្យការព្យាបាលបែបវេជ្ជសាស្ត្ររបស់ អៀង ធីរិទ្ធ ក្នុងអំឡុងពេលឆមាសទីមួយនៃឆ្នាំ២០១២ និងបានកោះហៅឡើងវិញនូវអ្នកជំនាញ ដែលបានតែងតាំងដោយតុលាការ ដើម្បីធ្វើការវាយតម្លៃលើសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ ក្នុងខែសីហា ឆ្នាំ២០១២។ ផ្អែកលើការសន្និដ្ឋានរបស់អ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ការសន្និដ្ឋានរបស់ខ្លួនថា អៀង ធីរិទ្ធ មិនមានសម្បទាចូលរួមសវនាការទេ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ហើយជាថ្មីម្ដងទៀតបានបង្គាប់ឱ្យដោះលែងគាត់[1118]។

បន្ទាប់ពីមានការប្ដឹងសាទុក្ខបន្ថែមទៀតរបស់សហព្រះរាជអាជ្ញា[1119] អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសេចក្ដីសម្រេចទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ត្រង់ចំណុចដែលថា អង្គជំនុំជម្រះសាលាដំបូង បានបដិសេធមិនបង្គាប់ដាក់វិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ និងបង្គាប់ឱ្យមានរបបនៃការ

---

[1114] សំណុំរឿង ០០២ សេចក្ដីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E138។

[1115] សំណុំរឿង ០០២ សេចក្ដីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E138 កថាខណ្ឌ ៦២។

[1116] សំណុំរឿង ០០២ បណ្ដឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គ ជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E138/1/1។ សំណុំរឿង ០០២ សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខពាក់ព័ន្ធនឹងការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ឯកសារ E138/1/4។

[1117] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងសារទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ឯកសារ E138/1/7 ផ្នែកសម្រេចសេចក្ដី។

[1118] សំណុំរឿង ០០២ សេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមការជំនុំជម្រះ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E138/1/10។

[1119] សំណុំរឿង ០០២ បណ្ដឹងសាទុក្ខភ្លាមៗ ជំទាស់ទៅនឹងសេចក្ដីសម្រេចលើការវាយតម្លៃឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ E138/1/10/1/1។

ត្រូតពិនិត្យតាមផ្លូវតុលាការចំពោះ អៀង ធារិទ្ធ[1120]។ គាត់ត្រូវ៖ (១) ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ឬការិយាល័យរដ្ឋបាល (ឬអ្នកដែលត្រូវបានចាត់តាំង) មុនពេលផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ខ្លួន (២) មិនត្រូវចាកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងនោះទេ (៣) ទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រទៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង (៤) ត្រូវបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យផ្នែកសន្តិសុខ ដែលអនុវត្តដោយនគរបាលយុត្តិធម៌មួយខែម្តង[1121]។

អៀង ធីរិទ្ធ បានទទួលមរណភាពនៅផ្ទះ នៅខេត្តប៉ៃលិន នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥[1122]។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូងបានរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងនឹង អៀង ធីរិទ្ធ[1123]។

### ៥.២.៦.៣. សម្បទាក្នុងចូលរួមសវនាការ និងមរណភាពរបស់ អៀង សារី

មុនពេលចាប់ផ្តើមការជំនុំជម្រះ អៀង សារី បានស្នើសុំដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ ដោយសារតែអាយុ និងស្ថានភាពសុខភាពរបស់គាត់ ធ្វើឱ្យគាត់មានការលំបាកក្នុងការអង្គុយយូរនៅក្នុងសាលសវនាការ[1124]។ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងអ្នកជំនាញផ្នែកព្យាបាលមនុស្សចាស់ ឱ្យពិនិត្យ អៀង សារី រួមជាមួយនឹង នួន ជា និង អៀង ធីរិទ្ធ ដែលបានស្នើសុំអ្នកជំនាញឱ្យវាយតម្លៃសម្បទារបស់ខ្លួនក្នុងការចូលរួមសវនាការ[1125]។ អៀង សារី មិនបានជំទាស់ទៅនឹងរបាយការណ៍របស់អ្នកជំនាញដែលសន្និដ្ឋានថា រូបគាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ប៉ុន្តែស្នើសុំឱ្យមានការអនុវត្តអនុសាសន៍ជាក់លាក់របស់អ្នកជំនាញ ទាក់ទងនឹងកន្លែងអង្គុយរបស់គាត់នៅក្នុងសាលសវនាការ[1126]។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធការអនុវត្តសំណើសុំធ្វើសវនាការជំនុំជម្រះក្តីកន្លះថ្ងៃ[1127]។

នៅពាក់កណ្តាលខែឧសភា ឆ្នាំ២០១២ គឺបន្ទាប់ពីសវនាការលើអង្គសេចក្តីបានរយៈពេលប្រាំមួយខែ អង្គជំនុំជម្រះសាលាដំបូង បានកោះអញ្ជើញគ្រូពេទ្យព្យាបាល អៀង សារី មកផ្តល់សក្ខីកម្មអំពី សមត្ថភាពរបស់ អៀង សារី ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី បន្ទាប់ពីមានការលំបាកផ្នែកវេជ្ជសាស្ត្រ។ គ្រូពេទ្យបានផ្តល់អនុសាសន៍ថា អៀង សារី គួរចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់

---

[1120] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E138/1/10/1/5/7។ សូមមើលផងដែរ សំណុំរឿង ០០២ សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺអំពីការអនុវត្តសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (ឯកសារ E138/1/10/1/5/8) ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ E138/1/10/1/5/8/3។ សំណុំរឿង ០០២ ដីកាបង្គាប់ស្តីពីវិធានការដែលត្រូវអនុវត្តចំពោះជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ ឯកសារ E138/1/10/1/5/8/4។

[1121] សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឱ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E138/1/10/1/5/7 ផ្នែកសម្រេចសេចក្តី។

[1122] សំណុំរឿង ០០២ កំណត់ហេតុស្តីអំពីមរណភាពរបស់លោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ E359 ។ សំណុំរឿង ០០២ កំណត់ហេតុស្តីអំពីមរណភាពរបស់លោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ E359.1។ សំណុំរឿង ០០២ លិខិតបញ្ជាក់មរណភាពរបស់ លោកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ E359.3។

[1123] សំណុំរឿង ០០២ សេចក្តីសម្រេចបញ្ចប់កិច្ចដំណើការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ឯកសារ E359/1។

[1124] សំណុំរឿង ០០២ ញត្តិរបស់ អៀង សារី សុំដំណើរការសវនាការជំនុំជម្រះក្តីរយៈពេលកន្លះថ្ងៃ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១១ ឯកសារ E20។

[1125] សូមមើល សំណុំរឿង ០០២/០១ សាលក្រម ប្រវត្តិនីតិវិធី ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313.1 កថាខណ្ឌ ២០។

[1126] សំណុំរឿង ០០២ ដីកាកំណត់កាលបរិច្ឆេទសវនការ ស្តីពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ ឯកសារ E110។

[1127] សូមមើល សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ឯកសារ E238/9 កថាខណ្ឌ ៥។

ឃុំខ្លួនគាត់ និងយល់ឃើញថា ស្ថានភាពសុខភាពរបស់ អៀង សារី មិនអាចឱ្យគាត់មានវត្តមាននៅក្នុងសាលសវនាការឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានផ្អាកសវនាការក្នុងសប្តាហ៍នោះ ដោយពិចារណាឃើញថា សុខភាពរបស់ អៀង សារី មិនអាចឱ្យគាត់មានវត្តមានក្នុងសាលសវនាការ ឬបន្ទប់រង់ចាំបាន ហើយគាត់មិនបានលះបង់សិទ្ធិមានវត្តមានរបស់គាត់[1128]។

អៀង សារី ត្រូវបានវាយតម្លៃផ្នែកវេជ្ជសាស្ត្រលើសម្បទាចូលរួមសវនាការរបស់គាត់។ ផ្អែកលើការវាយតម្លៃទាំងនេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា អៀង សារី មានសម្បទាចូលរួមសវនាការ[1129]។

អៀង សារី បានដកការបោះបង់សិទ្ធិចូលរួមសវនាការ ដែលគាត់បានចេញអំពីសិទ្ធិមានវត្តមានរបស់គាត់ក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់ និងបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា គាត់មានបំណងអនុវត្តសិទ្ធិរបស់គាត់ ក្នុងការមានវត្តមានក្នុងសាលសវនាការ ក្នុងអំឡុងពេលផ្តល់សក្ខីកម្មរបស់សាក្សីទាំងអស់[1130]។ នៅពេលកិច្ចដំណើរការនីតិវិធីបានបន្ត អៀង សារី បានចូលរួមពីបន្ទប់ឃុំខ្លួនគាត់ តាមអនុសាសន៍របស់គ្រូពេទ្យប្រចាំមន្ទីរឃុំឃាំង ដែលបានកត់សម្គាល់ថា អៀង សារី ងាយនឹងអស់កម្លាំង និងជួបការលំបាកផ្នែកវេជ្ជសាស្ត្រ[1131]។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសំណើមួយ ដែលស្នើសុំឱ្យធ្វើការតាមដាន និងថតខ្សែអាត់សំឡេង និង/ឬវីដេអូ អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួន ដើម្បីមានកំណត់ត្រា ថាតើគាត់បានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីពិតម្យ៉ាងដែរ ឬទេ[1132]។ បន្ទាប់ពីមានបណ្តឹងវិវាទបន្ថែមទៀតលើបញ្ហានេះ[1133] និងថាតើគប្បីតែងតាំងអ្នកជំនាញបន្ថែមទៀត ដើម្បីធ្វើការសម្រេចលើសម្បទាចូលរួមសវនាការរបស់ អៀង សារី ឬយ៉ាងណានោះ[1134] អៀង សារី បានប្តឹងសាទុក្ខប្រឆាំងនឹងការបដិសេធសំណើរបស់គាត់សុំថតខ្សែអាត់សំឡេង និង/ឬវីដេអូនៅក្នុងបន្ទប់ឃុំខ្លួន និងសេចក្តីសម្រេចលើសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ[1135]។

អៀង សារី បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត[1136]។ នៅថ្ងៃនោះ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចរំលត់បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណីទាំងអស់ប្រឆាំងគាត់ នៅចំពោះមុខ អ.វ.ត.ក.[1137]។

---

[1128] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ឯកសារ E238/9 កថាខណ្ឌ ៧។

[1129] សំណុំរឿង ០០២ សេចក្តីសម្រេចស្តីពីសម្បទាជនជាប់ចោទ អៀង សារី ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ ឯកសារ E238/9 កថាខណ្ឌ ៧-១៣។

[1130] សំណុំរឿង ០០២ ការដកហូតលិខិតលះបង់សិទ្ធិរបស់លោក អៀង សារី ក្នុងការមានវត្តមាន ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E237/2។ សំណុំរឿង ០០២ ការជូនដំណឹងរបស់ អៀង សារី អំពីការដកពាក្យសុំលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងការធ្វើសក្ខីកម្មរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E249។

[1131] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E1/147.1 ទំព័រ ១-៤ (អង់គ្លេស) ។

[1132] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ ឯកសារ E1/147.1 ទំព័រ ១៧-២០, ២៧-២៨ (អង់គ្លេស)។

[1133] សូមមើល សំណុំរឿង ០០២ បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ ដែលបដិសេធសំណើរបស់គាត់សុំថតខ្សែអាត់សំឡេង និង/ឬ វីដេអូរបស់គាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E254/3/1/1 កថាខណ្ឌ ២, ៥, ១១។

[1134] សូមមើ សំណុំរឿង ០០២ បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសនាការនិងការបដិសេធរបស់អង្គជំនុំជម្រះក្នុងការតែងតាំងអ្នកជំនាញបន្ថែម ដើម្បីវាយតម្លៃសម្បទារបស់គាត់ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៣ ឯកសារ E238/9/2/1 កថាខណ្ឌ ១៧-១៩, ២២។

[1135] សំណុំរឿង ០០២ បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣ ដែលបដិសេធសំណើរបស់គាត់សុំថតខ្សែអាត់សំឡេង និង/ឬ វីដេអូរបស់គាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៣ ឯកសារ E254/3/1/1។ សំណុំរឿង ០០២ បណ្តឹងសាទុក្ខរបស់ អៀង សារី ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថា គាត់មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសនាការនិងការបដិសេធរបស់អង្គជំនុំជម្រះក្នុងការតែងតាំងអ្នកជំនាញបន្ថែម ដើម្បីវាយតម្លៃសម្បទារបស់គាត់ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០១៣ ឯកសារ E238/9/2/1។ អៀង សារី បានទទួលមរណភាពមុនពេលចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខទាំងនេះ។

[1136] សំណុំរឿង ០០២ លិខិតបញ្ជាក់មរណភាពរបស់លោក អៀង សារី ថ្ងៃទី១៤ ខែមិនា ឆ្នាំ២០១៣ ឯកសារ E270។

[1137] សំណុំរឿង ០០២ សេចក្តីសម្រេចលើការបញ្ចប់កិច្ចនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ ឯកសារ E270/1។

### ៥.២.៦.៤. សាលក្រមជំនុំជម្រះ

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម[1138] និងបានចេញសាលក្រមសំណុំរឿង ០០២/០១ ផ្តន្ទាទោស នួន ជា និង ខៀវ សំផន ចំពោះឧក្រិដ្ឋកម្មជាច្រើនប្រឆាំងមនុស្សជាតិ និងផ្តន្ទាទោសពួកគេដាក់ពន្ធនាគារអស់មួយជីវិត[1139]។ សាលក្រមមានកម្រាស់ ៩៨១ ទំព័រជាភាសាខ្មែរ ៦២៣ទំព័រជាភាសាអង់គ្លេស និង ៧៧៧ទំព័រជាភាសាបារាំង ដោយមិនរាប់បញ្ចូលឧបសម្ព័ន្ធរបស់វា។ សាលក្រមចែកជា ២០ ជំពូក។

i. **ជំពូក១** គឺជាសេចក្តីផ្តើម ដែលមានទិដ្ឋភាពនីតិវិធីសង្ខេប នៃសំណុំរឿង និងសេចក្តីសង្ខេបអំពីបទចោទ។
ii. **ជំពូក២** ពិភាក្សាអំពីបញ្ហាអញ្ញត្រកម្មពាក់ព័ន្ធនឹងយុត្តាធិការ គោលការណ៍នីត្យានុកូលភាព គោលការណ៍ស្តីពីភ័ស្តុតាង និងនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។
iii. **ជំពូក៣** ពិភាក្សាអំពីបរិបទប្រវត្តិសាស្ត្រនៃរឿងក្តី។
iv. **ជំពូក៤** ពិភាក្សាអំពីសំអាងហេតុ និងសំអាងច្បាប់ ទាក់ទងនឹងលក្ខខណ្ឌទូទៅចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក.។
v. **ជំពូក៥** ពិភាក្សាអំពីរចនាសម្ព័ន្ធរដ្ឋបាលពាក់ព័ន្ធ នៃ ប.ក.ក. និង កម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំងយោធារបស់ ប.ក.ក.។
vi. **ជំពូក៦** ពិភាក្សាអំពីរចនាសម្ព័ន្ធទំនាក់ទំនងការងារខាងក្នុងកម្ពុជាប្រជាធិបតេយ្យ ចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩។
vii. **ជំពូក៧** ពិភាក្សាអំពីតួនាទី និងមុខងាររបស់ នួន ជា។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា៖
   - គឺជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ហើយមិនត្រឹមតែបានគ្រប់គ្រងលើសេចក្តីសម្រេចផ្នែកនយោបាយប៉ុណ្ណោះទេ ថែមទាំងលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រដ្ឋបាល និងបញ្ហាយោធាផងដែរ
   - គឺជាសមាជិកពេញសិទ្ធិទាំងក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក.
   - គឺជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃ សភាតំណាងប្រជាជន
   - គឺជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជាប្រជាធិបតេយ្យ ពីខែកញ្ញា ឆ្នាំ១៩៧៦ ដល់ខែកញ្ញា ឆ្នាំ១៩៧៧ ក្នុងអំឡុងពេលអវត្តមាន ប៉ុល ពត
   - បានចូលរួមក្នុងបញ្ហាយោធា និងសន្តិសុខ ដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងសិទ្ធិអំណាចយូរអង្វែងរបស់គាត់នៅក្នុងបក្ស។
   - បានចូលរួមយ៉ាងសកម្មក្នុងប្រតិបត្តិការរបស់កងទ័ពបដិវត្តន៍កម្ពុជា ជាពិសេស ទាក់ទងនឹងសង្គ្រាមប្រឆាំងវៀតណាម បានទទួលរបាយការណ៍ និងបានផ្តល់ការណែនាំជាប្រចាំទាក់ទងនឹងបញ្ហាសន្តិសុខ ដោយផ្ទាល់ ឬតាមរយៈសេចក្តីសម្រេចរបស់បក្ស
   - បានទទួលខុសត្រូវជាផ្លូវការលើការឃោសនា ការអប់រំនយោបាយ វិន័យបក្ស បញ្ហាសន្តិសុខផ្ទៃក្នុង និងស្ថានការណ៍ខ្មាំង ដោយប្តេជ្ញាស្វែងរកខ្មាំង និងលុបបំបាត់ពួកគេ
   - បានត្រួតពិនិត្យសកម្មភាពបក្ស ដែលហួសពីតួនាទី និងការទទួលខុសត្រូវជាផ្លូវការដែលបានផ្តល់ឱ្យគាត់
   - បានអនុវត្តអំណាចធ្វើការសម្រេចចុងក្រោយរបស់បក្ស រួមជាមួយនឹង ប៉ុល ពត
   - មានអំណាច (និងតាមពិតទៅ) ធ្វើគោលនយោបាយ និងសេចក្តីសម្រេចរបស់ ប.ក.ក. និងអនុវត្តគោលនយោបាយនិងសេចក្តីសម្រេចទាំងនោះ។

viii. **ជំពូក៨** ពិភាក្សាអំពីតួនាទី និងមុខងាររបស់ ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន៖

[1138] សំណុំរឿង ០០២ ប្រតិចារិក ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E1/241.1។
[1139] សំណុំរឿង ០០២/០១ សាលក្រម៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313។

- គឺជាប្រធានគណៈប្រធានរដ្ឋ ពោលគឺជាប្រមុខរដ្ឋ តំណាងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងប្រទេស និងក្រៅប្រទេស
- ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក. ដែលបានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ជាប្រចាំ ដើម្បីចូលរួម និងធ្វើសេចក្តីសម្រេចសំខាន់ៗ
- ធ្លាប់ជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការ CPNLAF ហើយទទួលបានការទុកចិត្តធ្វើជាតំណាងឱ្យរណសិរ្ស FUNK រាជរដ្ឋាភិបាល GRUNK និងរបបកម្ពុជាប្រជាធិបតេយ្យជាសាធារណៈ ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស
- មានតួនាទីសំខាន់ទាក់ទងនឹងសេដ្ឋកិច្ចកម្ពុជាប្រជាធិបតេយ្យ ក្នុងសមត្ថកិច្ចរបស់គាត់ជាសមាជិកមន្ទីរ ៨៧០ ទទួលខុសត្រូវពាណិជ្ជកម្ម
- គឺជាសមាជិកដែលទទួលបានជំនឿចិត្ត និងទំនុកចិត្តពីមជ្ឈិមបក្ស ដែលបានរស់នៅ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងមេដឹកនាំជាន់ខ្ពស់ ប.ក.ក. ទាំងមុនឆ្នាំ១៩៧៥ និងទាំងពេលក្រោយមកទៀត នៅមន្ទីរ ក-៣ និង ក-១
- បានដឹងអំពីគោលនយោបាយរបស់ ប.ក.ក. និងបានដឹងព័ត៌មានអំពីស្ថានការណ៍នៅក្នុងប្រទេសកម្ពុជាជារួម រួមទាំងការដឹងអំពីការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់។

ix. **ជំពូក៩** រៀបរាប់អំពីច្បាប់ជាធរមាន ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃការបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

x. **ជំពូក១០** រៀបរាប់លម្អិតអំពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ ដែលក្នុងនោះប្រជាជនត្រូវបានជម្លៀសដោយបង្ខំពីភ្នំពេញ ហើយឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀតនៃការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និងការផ្លាស់ទីលំនៅដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានរកឃើញថាបានកើតមានឡើង។

xi. **ជំពូក១១** រៀបរាប់លម្អិតអំពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដែលក្នុងនោះប្រជាជនត្រូវបានផ្លាស់ទីដោយបង្ខំពីភូមិភាគកណ្តាល (ឧត្តរចាស់) ភូមិភាគនិរតី ភូមិភាគបស្ចិម និងភូមិភាគបូព៌ា ទៅកាន់តំបន់ ១០៣ (ព្រះវិហារ) តំបន់ ១០៦ (សៀមរាប) និង ភូមិភាគពាយ័ព្យ ហើយឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលមានការបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិត្រូវបានរកឃើញថាបានកើតមានឡើង។

xii. **ជំពូក១២** រៀបរាប់លម្អិតអំពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងទួលពោធិ៍ជ្រៃ ដែលអង្គជំនុំជម្រះបានរកឃើញថា មានការសម្លាប់អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ ដែលមានតម្លៃស្មើទៅនឹងការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

xiii. **ជំពូក១៣** ពិភាក្សាអំពីច្បាប់ជាធរមាន ទាក់ទងនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ជាពិសេសការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម (JCE) ការរៀបចំផែនការ ការញុះញង់ ការបញ្ជាការជួយនិងជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ។

xiv. **ជំពូក១៤** ពិភាក្សាអំពីសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹង JCE។ អង្គជំនុំជម្រះជឿជាក់ថា ត្រឹមខែមិថុនា ឆ្នាំ១៩៧៤ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៧ មានមនុស្សជាច្រើនដែលចូលរួមចំណែកក្នុងគោលបំណងរួម ដើម្បី "ធ្វើបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សមួយតាមរយៈ "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្ស ប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ" ហើយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម លេខាក្រសួងរដ្ឋាភិបាល និងភូមិភាគ និងតំបន់ស្វយ័ត រួមទាំងជនជាប់ចោទ គឺជាផ្នែកមួយនៃក្រុមនេះ ដោយមានគោលបំណងរួមជាក់លាក់ ក្នុងការកសាងឱ្យបានឆាប់រហ័ស និងការពារប្រទេស តាមរយៈបដិវត្តន៍សង្គមនិយមផ្អែកលើគោលការណ៍នៃការរក្សាការសម្ងាត់ ឯករាជ្យម្ចាស់ការ ប្រជាធិបតេយ្យប្រមូលផ្តុំ ខ្លួនទីពឹងខ្លួន និងសហាមូហភាព។ អង្គជំនុំជម្រះបានកត់សម្គាល់ថា គ្រាន់តែមានគោលបំណងរួមដូច្នេះគឺមិន

មានភាពគ្រប់គ្រាន់ ឬមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែបានរកឃើញថាគោលបំណងរួមនេះត្រូវបានអនុវត្តតាមវិធីឧក្រិដ្ឋ ពោលគឺ គោលនយោបាយស្តីពីការផ្លាស់ទីលំនៅប្រជាជន និងគោលនយោបាយស្តីពីការកំណត់គោលដៅ ដែលធ្វើឱ្យមាន និង/ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម[1140]។

xv. **ជំពូក១៥** ពិចារណាលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា នួន ជា បានប្រព្រឹត្ត តាមរយៈ JCE I ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ៖

- ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ៖
  - ការធ្វើមនុស្សឃាត
  - ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ
  - អំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ)
- ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ៖
  - ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ
  - អំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ)
- ទួលពោធិ៍ជ្រៃ៖
  - ការធ្វើមនុស្សឃាត
  - ការសម្លាប់រង្គាល
- ទាក់ទងនឹងទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវដែលត្រូវបានចោទ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការចូលរួមរបស់ នួន ជា ក្នុង JCE គ្របដណ្តប់លើការប្រព្រឹត្តទាំងអស់ ដែលបង្កើតបានជាមូលដ្ឋាននៃទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ហើយដូច្នេះ បានធ្វើការដាក់ពិរុទ្ធភាពតែចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈ JCE មួយប៉ុណ្ណោះ[1141]។

xvi. **ជំពូក១៦** ពិចារណាលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន បានប្រព្រឹត្ត តាមរយៈ JCE I នូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះ៖

- ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ៖
  - ការធ្វើមនុស្សឃាត
  - ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ
  - អំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ)
- ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ៖
  - ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ
  - អំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលមាន ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ)
- ទួលពោធិ៍ជ្រៃ៖
  - ការធ្វើមនុស្សឃាត
  - ការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ
- ទាក់ទងនឹងទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវដែលត្រូវបានចោទ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាឃើញថា ការចូលរួមរបស់ ខៀវ សំផន ក្នុង JCE គ្របដណ្តប់លើការប្រព្រឹត្តទាំងអស់ ដែលបង្កើតបានជាមូលដ្ឋាននៃទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ហើយដូច្នេះ បានធ្វើការដាក់ពិរុទ្ធភាពតែចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈ JCE មួយប៉ុណ្ណោះ[1142]។

---

[1140] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ៧៧៧-៨៨៧។
[1141] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៥.៤-១៥.៥ (ជាពិសេស កថាខណ្ឌ ៩៤០)។
[1142] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៦.៣-១៦.៤ (ជាពិសេស កថាខណ្ឌ ១០៥៣)។

xvii. **ជំពូក១៧** ពិភាក្សាអំពីការផ្តន្ទាទោសត្រួតគ្នា។ អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា ការរកឃើញរបស់ខ្លួនលើបទល្មើសការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ បានផ្អែកទៅលើការសម្លាប់តែមួយ និងថាការរកឃើញរបស់ខ្លួនទៅលើបទល្មើសនៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ ផ្អែកទៅលើការសម្លាប់តែមួយ[1143]។ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អំពើជាមូលដ្ឋានទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ភាគច្រើនផ្អែកលើអំពើតែមួយ ដែលជាមូលដ្ឋាននៃការរកឃើញរបស់អង្គជំនុំជម្រះលើឧក្រិដ្ឋកម្មផ្សេងទៀត ប៉ុន្តែដោយកត់សម្គាល់ឃើញថា ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត មានធាតុផ្សំដាច់ដោយឡែកពីគ្នា បានផ្តន្ទាទោសជនជាប់ចោទចំពោះឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ដែលមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ) ដោយសារតែបទល្មើសនីមួយៗមានធាតុផ្សំដាច់ដោយឡែកពីគ្នា មិនមាននៅក្នុងបទល្មើសផ្សេងទៀត[1144]។

xviii. **ជំពូក១៨** ពិភាក្សាអំពីការផ្តន្ទាទោស។

xix. **ជំពូក១៩** ពិភាក្សាអំពីសំណងដើមបណ្តឹងរដ្ឋប្បវេណី ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យគម្រោងផ្តួចផ្តើមដែលបានស្នើឡើងចំនួន ១៣ និងបានអនុម័តយល់ព្រមលើគម្រោងចំនួន ១១ ក្នុងចំណោមនោះ។

xx. **ជំពូក២០** គឺជាផ្នែកសេចក្តីសម្រេច។

### ៥.២.៦.៥. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះតុលាការកំពូល

#### ៥.២.៦.៥.១. បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម

នួន ជា, ខៀវ សំផន និងសហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខជំទាស់នឹងសាលក្រម[1145]។ ការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា បានរៀបរាប់មូលដ្ឋានបណ្តឹងសាទុក្ខចំនួន ២២៣[1146] ចំណែកការជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន វិញ មានមូលដ្ឋានបណ្តឹងសាទុក្ខចំនួន ១៤៨[1147]។ សហព្រះរាជអាជ្ញាបានលើកយកតែមួយចំណុចប៉ុណ្ណោះ អំពីកំហុសអង្គច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ដោយការបដិសេធលទ្ធភាពដែលថា ជនជាប់ចោទអាចទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាជា JCE III និងបានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល ប្រកាសថាទម្រង់នៃការទទួលខុសត្រូវនេះអាចអនុវត្តបាននៅ អ.វ.ត.ក.[1148]។

ក្នុងរយៈពេលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ នួន ជា តាមរយៈសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរជាច្រើន បានស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល ទទួលយក និងពិចារណាលើភស្តុតាងបន្ថែម។ សំណើរបស់គាត់រួមមាន ការស្នើសុំឱ្យទទួលសម្ភារៈសោតទស្សន៍ ការកោះហៅបុគ្គលចំនួនដប់ប្រាំមួយនាក់ក្នុងនាមជាសាក្សី និងអនុញ្ញាតទទួលយកជាភស្តុតាងនូវសម្ភារៈឯកសារ ឬសោតទស្សន៍

---

[1143] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១០៥៧។

[1144] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១០៥៨-១០៦០។

[1145] សំណុំរឿង ០០២/០១ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ F11។ សំណុំរឿង ០០២/០១ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ F16។ សំណុំរឿង ០០២/០១ សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ខៀវ សំផន ប្រឆាំងនឹងសាលក្រម សំណុំរឿង ០០២/០១ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ F17។

[1146] សំណុំរឿង ០០២ សេចក្តីជូនដំណឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313/1/1។

[1147] សំណុំរឿង ០០២ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E313/2/1។

[1148] សំណុំរឿង ០០២/០១ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ F11។

ផ្សេងទៀត[1149]។ អង្គជំនុំជម្រះតុលាការកំពូល បានទទួលយកផ្នែកខ្លះនៃសំណើរបស់ នួន ជា ដែលផ្ដួចផ្ដើមឱ្យមានការស៊ើបអង្កេតបន្ថែម ដែលត្រូវបានធ្វើឡើងដោយចៅក្រមតំណាងពីររូប[1150]។ នៅថ្ងៃទី២ ទី៣ និងទី៦ ខែកក្កដា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូល បានធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីបីរូប ដែល នួន ជា បានស្នើសុំឱ្យកោះហៅ[1151]។

អង្គជំនុំជម្រះតុលាការកំពូល បានគ្រោងធ្វើសវនាការបណ្ដឹងសាទុក្ខពីថ្ងៃទី១៦ ដល់ទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥ និងបានជូនដំណឹងដល់ភាគីថា ខ្លួនកំពុងពិចារណាលើការផ្លាស់ប្ដូរជាសក្ដានុពល ទៅលើការកំណត់បទល្មើស ទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវ ដែល នួន ជា និង ខៀវ សំផន ត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ដោយបានអញ្ជើញភាគីឱ្យដាក់សារណាលើបញ្ហាទាំងនេះ[1152]។ ការចាប់ផ្ដើមសវនាការបណ្ដឹងសាទុក្ខ ដោយសារបញ្ហាភ័ស្ដុភារ ត្រូវបានលើកពេលជាបន្ដបន្ទាប់ទៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥[1153] និងក្រោយមកដោយសារបញ្ហាពាក់ព័ន្ធនឹងមេធាវីរបស់ នួន ជា[1154] ត្រូវលើកទៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦[1155]។ សវនាការបានបន្ដរហូតដល់ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦[1156]។

### ៥.២.៦.៥.២. សាលដីកាបណ្ដឹងសាទុក្ខ

សាលដីកាត្រូវបានប្រកាស[1157] និងចេញនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦[1158]។ សាលដីកានេះចែកជាប្រាំមួយជំពូក។

i. **ជំពូក១** គឺជាប្រវត្តិនីតិវិធីនៃរឿងក្ដី។
ii. **ជំពូក២** ពិភាក្សាអំពីសំណើ ដែលអង្គជំនុំជម្រះតុលាការកំពូលបានទទួល ស្នើសុំដាក់ភ័ស្ដុតាងបន្ថែម។
iii. **ជំពូក៣** ពិភាក្សាអំពីបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខ។
iv. **ជំពូក៤** ពិចារណាលើបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន រួមគ្នា។
   ក. **ផ្នែក ក** ពិភាក្សាអំពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក.។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធទឡ្ហីករណ៍របស់ នួន ជា ទាក់ទងនឹងការលើកឡើងអំពីអធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង។
   ខ. **ផ្នែក ខ** ពិភាក្សាអំពីភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណា និងបដិសេធទឡ្ហីករណ៍ទាក់ទងនឹង (១) ភាពលម្អៀង និងអព្យាក្រឹតភាពរបស់ចៅក្រម (២) ភាពអយុត្តិធម៌ដែលបណ្ដាលមកពីការបរាជ័យក្នុងការកោះហៅសាក្សីជាក់

---

[1149] សូមមើល សំណុំរឿង ០០២ សេចក្ដីសម្រេចលើសំណើសុំដាក់ភស្ដុតាងបន្ថែមលើបណ្ដឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ - ផ្នែកសម្រេចសេចក្ដី ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ឯកសារ F2/9។
[1150] សំណុំរឿង ០០២ សេចក្ដីសម្រេចបណ្ដោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជាសុំឲ្យទទួល និងពិចារណាទៅលើភស្ដុតាងបន្ថែមទាក់ទងនឹងបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ F2/4/3 កថាខណ្ឌ២៤-២៦។
[1151] សូមមើល សំណុំរឿង ០០២/០១ សេចក្ដីសម្រេចលើផ្នែកខ្លះនៃសំណើរបស់ នួន ជា សុំកោះហៅសាក្សីលើបណ្ដឹងសាទុក្ខ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ឯកសារ F2/5។ សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ F1/1.1។ សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ F1/2.1។ សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ F1/3.1។
[1152] សំណុំរឿង ០០២/០១ ដីកាកំណត់កាលបរិច្ឆេទសវនាការបណ្ដឹងសាទុក្ខ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ ឯកសារ F30។
[1153] សំណុំរឿង ០០២/០១ ដីកាកំណត់កាលវិភាគស្ថាពរសម្រាប់សវនាការបណ្ដឹងសាទុក្ខ និងការជូនដំណឹងភាគីអំពីបញ្ហាដែលត្រូវលើកឡើង ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ F30/4។
[1154] សូមមើល ជំពូក ៥.២.៧.២។
[1155] សំណុំរឿង ០០២/០១ ដីកាកំណត់កាលបរិច្ឆេទសវនាការលើបណ្ដឹងសាទុក្ខ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ F30/17។
[1156] សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ F1/5.1។ សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ F1/6.1។ សំណុំរឿង ០០២/០១ ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ F1/7.1 ទំព័រ ១០២ (អង់គ្លេស)។
[1157] សំណុំរឿង ០០២ ប្រតិចារឹក ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F1/8.1។
[1158] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36។

លាក់ (៣) ដំណើរការទទួលយក និងប្រើប្រាស់ឯកសារ (៤) ពេលវេលា និងចំនួនទំព័រកំណត់ (៥) លំដាប់លំដោយនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (៦) ការចោទប្រកាន់អំពីការរំលោភសិទ្ធិទទួលបានសេចក្ដីសម្រេចមានសំអាងហេតុ និង (៧) ការចោទប្រកាន់អំពីការរំលោភសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទ និងវិសាលភាពនៃការជំនុំជម្រះ។

គ. ផ្នែក គ ពិភាក្សាអំពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការទទួលយកភ័ស្តុតាង។ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើទឡ្ហីករណ៍ដែលអង្គជំនុំជម្រះសាលាដំបូង៖ (១) ដាក់កម្រិតឱកាសក្នុងការស៊ើបអង្កេតក្នុងពេលជំនុំជម្រះ (២) អនុញ្ញាតឱ្យសាក្សីពិនិត្យចម្លើយរបស់ខ្លួនពីមុន មុនពេលផ្ដល់សក្ខីកម្ម និងឆ្លើយសំណួរដឹកមុខ ផ្អែកលើចម្លើយទាំងនោះ (៣) រឹតត្បិតលើវិសាលភាពនៃការសួរសំណួរខ្លាំងពេក (៤) ទទួលយក និងប្រើប្រាស់ភ័ស្តុតាងជាលាយលក្ខណ៍អក្សរជំនួសសក្ខីកម្មផ្ទាល់មាត់ (៥) ផ្អែកលើភ័ស្តុតាងចចាមអារ៉ាម (៦) ផ្អែកលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើជាភ័ស្តុតាងសម្ភារៈ (៧) ផ្អែកលើសក្ខីកម្មរបស់អ្នកជំនាញ និងប្រភពមិនផ្ទាល់ធ្វើជាភ័ស្តុតាងផ្ទាល់ (៨) វាយតម្លៃមិនត្រឹមត្រូវលើសាក្សីអង្គហេតុ (៩) សម្រេចថាភ័ស្តុតាងដែលបានបង្កើតដោយការធ្វើទារុណកម្ម មិនអាចទទួលយកបាននៅគ្រប់កាលៈទេសៈទាំងអស់ (១០) បង្ហាញសាក្សីនូវឯកសារដែលពួកគេមិនស្គាល់ (១១) បដិសេធការទាមទាររបស់មេធាវី ទាក់ទងនឹងការបង្កើតសំណៅដើមនៃឯកសារ និងដំណើរការនៃការរក្សាទុកឯកសារ (១២) ទទួលយកឯកសារដោយមិនមានការពិភាក្សាដេញដោល និង (១៣) ផ្អែកលើបទដ្ឋានបន្ទុកភ័ស្តុតាងមិនត្រឹមត្រូវ។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធទឡ្ហីករណ៍នីមួយៗទាំងអស់នេះ។

ឃ. **ផ្នែក ឃ** ពិភាក្សាអំពីឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្ដន្ទាទោស។ អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យ៖ (១) ការធ្វើមនុស្សឃាត (២) ការសម្លាប់រង្គាល (៣) អំពើអមនុស្សធម៌ផ្សេងៗទៀត (៤) ការធ្វើទុក្ខបុកម្នេញ (៥) ធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង (៦) ភាពអាចដឹងជាមុន និងគោលការណ៍នីត្យានុកូលភាព។

១. ទាក់ទងនឹងការធ្វើមនុស្សឃាត អង្គជំនុំជម្រះតុលាការកំពូល ជាដំបូង បានពិចារណាលើបញ្ហាចោទថាតើ *ធាតុផ្សំអត្តនោម័ត* នៃការធ្វើមនុស្សឃាតអាចរួមបញ្ចូល *ចេតនាប្រយោល* ជាជាងចេតនាផ្ទាល់ក្នុងការសម្លាប់ ឬយ៉ាងណា[1159]។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុស តាមរយៈការផ្អែកលើបទដ្ឋាន*ធាតុផ្សំអត្តនោម័ត* ទាបជាងនោះឡើយ[1160]។ អង្គជំនុំជម្រះតុលាការកំពូលបន្ទាប់មកបានពិចារណា ថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុសឬទេ នៅក្នុងការសន្និដ្ឋានរបស់ខ្លួន ទាក់ទងនឹងការធ្វើមនុស្សឃាត ដែលបានប្រព្រឹត្តក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងបានរកឃើញថាមិនមានកំហុសនៅក្នុងការសន្និដ្ឋានជារួមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការធ្វើមនុស្សឃាតបានកើតមានឡើង[1161]។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានពិចារណាផងដែរលើបញ្ហាថាតើអង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅក្នុងការសន្និដ្ឋានរបស់ខ្លួនទាក់ទងនឹងការធ្វើមនុស្សឃាត ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ និងបានរកឃើញថាមិនមានកំហុសណាមួយនោះឡើយ[1162]។

២. ទាក់ទងនឹងការសម្លាប់រង្គាល អង្គជំនុំជម្រះតុលាការកំពូល ជាដំបូង បានពិចារណាលើបញ្ហាថាតើ និយមន័យនៃការសម្លាប់រង្គាល បានរួមបញ្ចូល*ធាតុផ្សំអត្តនោម័ត* នៃ*ចេតនាប្រយោល* ដូចដែលបានរកឃើញដោយអង្គជំនុំជម្រះសាលាដំបូង ឬទេ និងថាតើធាតុផ្សំនៃការសម្លាប់រង្គាល គឺជាអត្ថិភាព និងការដឹងអំពីការសម្លាប់ទ្រង់ទ្រាយធំ ឬទេ[1163]។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសអង្គច្បាប់ ទាក់ទង

[1159] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក៤ (ឃ)(១)(ក)។
[1160] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ ៤១០។ អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើបញ្ហានេះ នៅក្នុងសំណុំរឿង ០០២/០២ ផងដែរ។ សូមមើល ជំពូក ៥.២.៧.៤.៣។
[1161] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក៤ (ឃ)(១)(ខ)។
[1162] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក៤ (ឃ)(១)(គ)។
[1163] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក៤ (ឃ)(២)(ក)។

នឹង*ធាតុផ្សំអត្តនោម័ត* ដែលខ្លួនយល់ឃើញថាតម្រូវឱ្យមានចេតនាផ្ទាល់[1164]។ អង្គជំនុំជម្រះមិនឯកភាពជាមួយនឹង នួន ជា ដែលថាធាតុផ្សំនៃការសម្លាប់រង្គាល គឺអត្ថិភាព និងការដឹងអំពីការសម្លាប់ទ្រង់ទ្រាយធំ ហើយបានរកឃើញថាអង្គជំនុំជម្រះសាលាដំបូងមិនមានកំហុស តាមរយៈការបដិសេធទឡ្ហីករណ៍នេះទេ[1165]។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើបញ្ហាថាតើ អង្គជំនុំជម្រះសាលាដំបូងមានកំហុស នៅក្នុងសំអាងហេតុរបស់ខ្លួន ឬទេ ទាក់ទងនឹងការសម្លាប់រង្គាល ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ។ អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសនៅក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការសម្លាប់រង្គាលត្រូវបានបង្ហាញ ពាក់ព័ន្ធទៅនឹងជនស៊ីវិល ដែលបានស្លាប់ដោយសារតែលក្ខខណ្ឌនៃការជម្លៀសពីភ្នំពេញ ដោយសារតែកម្រិតនៃចេតនាដែលជាលក្ខខណ្ឌតម្រូវមិនត្រូវបានបង្ហាញ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានរកឃើញទៀតថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ទាក់ទងនឹងការសម្លាប់រង្គាលទាហាន និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ដោយសារធាតុផ្សំសត្យានុម័តពីទំហំ មិនត្រូវបានបំពេញ[1166]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា ទាំងធាតុផ្សំសត្យានុម័តពីទំហំ និងទាំង*ធាតុផ្សំអត្តនោម័ត*ចាំបាច់ មិនត្រូវបានបង្ហាញត្រឹមត្រូវ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ហើយបានបដិសេធការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីបទសម្លាប់រង្គាល[1167]។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថា អង្គហេតុគាំទ្រការរកឃើញអំពីការធ្វើមនុស្សឃាត និងបានប្តូរការកំណត់បទល្មើសទៅជាបទធ្វើមនុស្សឃាតវិញ[1168]។ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាអង្គជំនុំជម្រះសាលាដំបូងមិនមានកំហុស នៅក្នុងការសម្រេចរបស់ខ្លួនអំពីបទសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃនោះទេ[1169]។

៣. ទាក់ទងនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការកំណត់ធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំ ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត បង្ហាញពីភាពច្របូកច្របល់ផ្នែកវិធីសាស្ត្រ ដោយសារពួកវាមិនបង្កើតបានជាឧក្រិដ្ឋកម្មជាក់លាក់ប្រឆាំងមនុស្សជាតិឡើយ ជាមួយនឹងនិយមន័យ និងធាតុផ្សំច្បាប់ជាក់លាក់ ក្នុងឆ្នាំ១៩៧៥។ ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូងគប្បីវាយតម្លៃការប្រព្រឹត្តពាក់ព័ន្ធ ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ និងទីពីរទាំងមូល ដើម្បីកំណត់ថាតើធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀត ត្រូវបានបំពេញ ឬទេ[1170]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ដោយសារតែអង្គជំនុំជម្រះសាលាដំបូងខកខានក្នុងការធ្វើការវិភាគដែលបានតម្រូវនោះ ខ្លួននឹងធ្វើការវិភាគនោះ បន្ទាប់ពីពិចារណាជាដំបូងលើសំអាងហេតុពាក់ព័ន្ធដែលបានជំទាស់នៅលើបណ្តឹងសាទុក្ខ[1171]។ បន្ទាប់មក អង្គជំនុំជម្រះតុលាការកំពូល បានពិចារណាលើអង្គហេតុដែលរងការជំទាស់ ដោយសម្រេចថា អង្គហេតុជាក់លាក់មួយចំនួនមិនសមហេតុផល ចំណែកឯអង្គហេតុមួយចំនួនទៀតត្រូវបានតម្កល់ បន្ទាប់មកក្រោយពីបានធ្វើការវិភាគជារួម អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការជម្លៀសចេញពីភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ មានតម្លៃស្មើទៅនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត[1172]។

---

[1164] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក៤ (ឃ)(២)(ក)(១)។
[1165] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក៤ (ឃ)(២)(ក)(២)។
[1166] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៥២៩-៥៤១។
[1167] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៥៤៦-៥៦០។
[1168] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៥៦១-៥៦២។
[1169] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៥៦៣-៥៦៦។
[1170] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៥៧២-៥៨៩។
[1171] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៥៩០។
[1172] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៥៩១-៦៦០។

៤. ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុស ក្នុងការសម្រេចថា ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អាចត្រូវបានប្រព្រឹត្តឡើង ប្រឆាំងនឹងក្រុមដែលមិនមែនជាសមាជិកក្រុមនយោបាយ ឬអ្នកដែលមានទស្សនៈនយោបាយ[1173]។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធអំណះអំណាងដែលថា "ប្រជាជនថ្មី" មិនមែនជាក្រុមដែលគេស្គាល់យ៉ាងច្បាស់[1174] និងថាអង្គជំនុំជម្រះសាលាដំបូង មានកំហុសក្នុងការសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញត្រូវបានប្រព្រឹត្តឡើង ក្នុងអំឡុងពេលការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ[1175]។ អង្គជំនុំជម្រះតុលាកាកំពូលយល់ឃើញថា ទោះជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញបានកើតឡើង ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ ដោយសារតែការផ្លាស់ទីលំនៅប្រជាជន គឺជាការអនុវត្តដ៏ទូលំទូលាយ ដែលបានប៉ះពាល់ដល់ប្រជាជនគ្រប់ផ្នែកទាំងអស់ ហើយដូច្នេះមិនមែនកើតចេញពីចេតនាធ្វើទុក្ខបុកម្នេញនោះទេ[1176]។

៥. ទាក់ទងនឹងធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសក្នុងការសន្និដ្ឋានថា មិនមានចំណងទាក់ទងទៅនឹងលក្ខខណ្ឌតម្រូវជម្លោះប្រដាប់អាវុធត្រឹមឆ្នាំ១៩៧៥[1177] និងផែនការរបស់រដ្ឋ ឬផែនការចាត់តាំង ឬ គោលនយោបាយរបស់រដ្ឋ ដែលជាធាតុផ្សំនៃលក្ខខណ្ឌតម្រូវតាមបរិបទឯករាជ្យនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[1178]។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានយល់ឃើញផងដែរថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសក្នុងការសន្និដ្ឋានថា អំពើដែលបានចោទប្រកាន់ មានចំណងទាក់ទងទៅនឹងការវាយប្រហារដ៏រីករាលដាល និងជាលក្ខណៈប្រព័ន្ធ សំដៅប្រឆាំងនឹងប្រជាជនស៊ីវិលនៃប្រទេសកម្ពុជា ដោយមូលហេតុនយោបាយ ក្នុងអំឡុងរយៈពេលយុត្តាធិការពេលវេលា ដែលជាបញ្ហាចោទក្នុងសំណុំរឿង ០០២/០១ នោះទេ និងថា ជនជាប់ចោទបានដឹងអំពីការវាយប្រហារនោះ ហើយអំពើរបស់ពួកគេបង្កើតបានជាផ្នែកមួយនោះ[1179]។

៦. ទាក់ទងទៅនឹងភាពអាចដឹងជាមុន និងគោលការណ៍នីត្យានុកូលភាព អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធអំណះអំណាងដែលថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសពាក់ព័ន្ធនឹងភាពអាចដឹងជាមុនថាជាបទល្មើស និងមានច្បាប់ចែង ដោយលើកឡើងថាខ្លួននឹងពិចារណាលើភាពអាចដឹងជាមុនថាជាបទល្មើស និងមានច្បាប់ចែងអំពីទម្រង់នៃការទទួលខុសត្រូវនៅក្នុងផ្នែកខាងក្រោម[1180]។

ង. **ផ្នែក ង** ពិភាក្សាអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល។

១. ទាក់ទងទៅនឹងការចូលរួមចំណែករបស់ជនជាប់ចោទក្នុង JCE អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស តាមរយៈការសន្និដ្ឋានថាគោលនយោបាយផ្លាស់ទីលំនៅប្រជាជន "បានបណ្តាលឱ្យ និង/ឬពាក់ព័ន្ធទៅនឹង" ការប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយសារតែការណ៍នេះបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង បានពិចារណាថាឧក្រិដ្ឋកម្ម ដែលជាទូទៅកើតចេញពីគោលបំណងរួម អាចត្រូវបានបង្កើតឡើងដោយជនជាប់ចោទ (ដែលនឹងពាក់ព័ន្ធនឹង JCE III ដែលមិនអាចអនុវត្តបាននៅ អ.វ.ត.ក.) ប៉ុន្តែបានលើកឡើងថា មិនមែនកំហុសទាំងអស់សុទ្ធតែនាំឱ្យមានការបដិសេធនៅដំណាក់កាលសាទុក្ខនោះទេ ហើយអង្គជំនុំជម្រះតុលាការកំពូល នឹងពិចារណាលើកំហុស

---

[1173] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៦៦៧-៦៨០។
[1174] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៦៨១-៦៨៦។
[1175] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៦៨៧-៦៩៧។
[1176] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៦៩៨-៧០៦។
[1177] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៧១១-៧២១។
[1178] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៧២២-៧៣២។
[1179] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៧៣៣-៧៥៧។
[1180] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៧៥៨-៧៦៦។

របស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការពិនិត្យឡើងវិញរបស់ខ្លួនលើសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងលើ JCE[1181]។

២. ពាក់ព័ន្ធទៅនឹងលក្ខណៈឧក្រិដ្ឋនៃគោលបំណងរួម អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ការបែងចែកដាច់ពីគ្នារបស់អង្គជំនុំជម្រះសាលាដំបូងរវាងគោលបំណងរួម (ដែលខ្លួនយល់ឃើញថាមិនអាចជាបទល្មើស) និងគោលនយោបាយឧក្រិដ្ឋនោះ បានធ្វើឱ្យមានការភាន់ច្រឡំក៏ដោយ ក៏ការណ៍នេះមិនមែនជាកំហុសដែលអាចប្ដឹងសាទុក្ខបាននោះឡើយ[1182]។

៣. ទាក់ទងទៅនឹងអត្ថិភាព និងខ្លឹមសារនៃគោលនយោបាយផ្លាស់ទីលំនៅប្រជាជន អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាមិនមានកំហុសជារួមណា ដែលអាចមោឃភាពសាលក្រមនោះទេ[1183]។

៤. ទាក់ទងនឹងអត្ថិភាព និងខ្លឹមសារនៃគោលនយោបាយកំណត់គោលដៅ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ភ័ស្តុតាងដែលអង្គជំនុំជម្រះសាលាដំបូងសំអាងលើមានកម្រិតខ្សោយ ពុំមានភាពច្បាស់លាស់ និងមានតម្លៃទាប និងចោទជាបញ្ហាដោយសារភ័ស្តុតាងដទៃទៀត។ ដូច្នេះ វាពុំសមហេតុផលក្នុងការសន្និដ្ឋានថា គោលនយោបាយមួយដែលកំណត់គោលដៅសម្លាប់ទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានអត្ថិភាពនៅក្នុងអំឡុងពេលនៃប្រតិបត្តិការណ៍នៅទួលពោធិ៍ជ្រៃ។ ដូច្នេះ ជនជាប់ចោទមិនអាចដាក់ឱ្យទទួលខុសត្រូវព្រហ្មទណ្ឌបានទេ[1184]។

៥. ទាក់ទងនឹងបរិបទនយោបាយជារួម អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើអំណះអំណាងអំពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងថា ប.ក.ក. បានអនុម័តគោលនយោបាយតស៊ូប្រដាប់អាវុធ ដែលជាបទដ្ឋានគតិយុត្តិទាក់ទងនឹងការចូលរួមចំណែកក្នុងគោលបំណងរួម ការរកឃើញដែលថាការចូលរួមចំណែកក្នុង JCE អាចត្រូវបានធ្វើឡើងតាមរយៈអំពើអកម្មដែលនាំឱ្យមានពិរុទ្ធ ការរកឃើញអំពីការចូលរួមចំណែករបស់ នួន ជា ក្នុងការអនុវត្តគោលបំណងរួម ការរកឃើញទាក់ទងនឹងការចូលរួមចំណែករបស់ ខៀវ សំផន ក្នុងការអនុវត្តគោលបំណងរួម ការរកឃើញថា ប.ក.ក. ជាបក្សដែលមានការឯកភាព និងឋានានុក្រម និងថាកងកម្លាំងប្រដាប់អាវុធបានចូលរួមក្នុងការជម្លៀសទីក្រុងភ្នំពេញមានការឯកភាពគ្នា ការរកឃើញទាក់ទងនឹងតួនាទីរបស់គណៈកម្មាធិការមជ្ឈិម ការរកឃើញទាក់ទងនឹងប្រជាធិបតេយ្យប្រមូលផ្ដុំ ការរកឃើញទាក់ទងនឹងច្បាប់ពាក់ព័ន្ធនឹងចេតនាតម្រូវ និងការរកឃើញស្ដីពីចេតនារបស់ នួន ជា និង ខៀវ សំផន។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាមិនមានកំហុសជារួមណា ដែលត្រូវមោឃៈសាលក្រមនោះទេ[1185]។

៦. ទាក់ទងនឹងគោលការណ៍នីត្យានុកូលភាព ដូចដែលវាពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសណាមួយឡើយ ដោយពិចារណាថា ការទទួលខុសត្រូវតាម JCE អាចត្រូវបានដឹងជាមុនយ៉ាងច្បាស់លាស់ថាជាបទល្មើស និងមានច្បាប់ចែង[1186]។

៧. ទាក់ទងនឹងការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថាជាការពុំសមស្រប ក្នុងការពិចារណាលើអំណះអំណាងទាំងអស់នេះ ដោយសារតែអំណះអំណាងទាំងនេះមិនអាចមោឃៈសាលក្រម ឬបណ្ដាលឱ្យមានភាពអយុត្តិធម៌ឡើយ “ពុំជាប់ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៃការយល់ឃើញផ្នែកអង្គច្បាប់ និងអង្គហេតុរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងទម្រង់នៃការទទួលខុសត្រូវទាំងនោះ ដូច្នេះ ការសម្រេចដាក់ពិរុទ្ធភាពលើ

[1181] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៧៧៣-៨១០។
[1182] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៨១៤-៨១៧។
[1183] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៨១៨-៨៦៨។
[1184] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ៩៧០-៨៧២។
[1185] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក៤(ង)(១)(ង)-(ណ)។
[1186] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 ផ្នែក(៤)(ង)(២)។

ជនជាប់ចោទពីបទឧក្រិដ្ឋទាំងនោះដោយផ្អែកលើសញ្ញាណនៃសហឧក្រិដ្ឋកម្មរួម ទុកជាបានការ”[1187]។

៨. ទាក់ទងនឹងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធការសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសារតែអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការទទួលខុសត្រូវមិនកើតចេញតាមរយៈ JCE ដោយសារតែអត្ថិភាពនៃគោលនយោបាយកំណត់គោលដៅ មិនត្រូវបានបង្ហាញបានត្រឹមត្រូវ និងដោយសារតែអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ៉ អង្គជំនុំជម្រះសាលាដំបូងបានផ្អែកក្នុងកម្រិតច្បាស់លាស់ទៅលើគោលនយោបាយកំណត់គោលដៅ នៅពេលធ្វើការសម្រេចអំពីការទទួលខុសត្រូវចំពោះការរៀបចំផែនការ ការញុះញង់ ការបញ្ជា (តែ នួន ជា ប៉ុណ្ណោះ) និងការជួយ និងជំរុញ ក៏ដូចជាការទទួលខុសត្រូវរបស់ថ្នាក់លើ (តែ នួន ជា ប៉ុណ្ណោះ)[1188]។

ច. **ផ្នែក ច** ពិភាក្សាអំពីមូលដ្ឋានបណ្ដឹងសាទុក្ខទាក់ទងទៅនឹងការផ្ដន្ទាទោស។ អង្គជំនុំជម្រះតុលាការកំពូល បានច្រានចោលមូលដ្ឋានបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ទាក់ទងទៅនឹងការផ្ដន្ទាទោស ដោយយល់ឃើញថា ខៀវ សំផន ខកខានក្នុងការបង្ហាញពីកំហុសនៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង[1189]។ អង្គជំនុំជម្រះតុលាការកំពូលពិចារណាលើផលប៉ះពាល់នៃការរកឃើញរបស់ខ្លួនលើការផ្ដន្ទាទោស និងបានសម្រេចថា ការកំណត់ទោសមួយជីវិតសម្រាប់ជនជាប់ចោទម្នាក់ៗ គឺជារឿងត្រឹមត្រូវ និងហេតុដូច្នេះ គាំទ្រការផ្ដន្ទាទោសដោយអង្គជំនុំជម្រះសាលាដំបូង[1190]។

v. **ជំពូក៥** ពិចារណាលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងលទ្ធភាពអនុវត្ត JCE III នៅ អ.វ.ត.ក.។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា បណ្ដឹងសាទុក្ខមិនអាចទទួលយកបានដោយកត់សម្គាល់ថា សហព្រះរាជអាជ្ញាមិនតវ៉ាថា កំហុសអង្គច្បាប់ដែលខ្លួនបានចោទប្រកាន់នោះបានធ្វើឱ្យសាលក្រមទៅជាមោឃៈនោះទេ ដូច្នេះ “សហព្រះរាជអាជ្ញាពុំបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់បណ្ដឹងសាទុក្ខរបស់ខ្លួន ដូចជាការបញ្ជាក់កំហុស “ដែលនាំឱ្យសេចក្ដីសម្រេចមោឃៈ””[1191]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាថាតើ បញ្ហាចោទដែលលើកឡើងដោយសហព្រះរាជអាជ្ញា គឺជាបញ្ហាទាក់ទងនឹងសារសំខាន់ទូទៅចំពោះយុត្តាធិការរបស់ អ.វ.ត.ក. ដែលតម្រូវឱ្យអង្គជំនុំជម្រះតុលាការកំពូលប្រើឆន្ទានុសិទ្ធិរបស់ខ្លួនធ្វើការប្រកាសលើបញ្ហានោះ ឬទេ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ខ្លួនមិនចាំបាច់ពិចារណាលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាដោយផ្អែកលើមូលដ្ឋានពិសេសនោះឡើយ ដោយកត់សម្គាល់ថា អង្គជំនុំជម្រះតុលាការកំពូលបានធ្វើការវិភាគសញ្ញាណនៃ JCE នេះរួចហើយ នៅក្នុងបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន[1192]។

vi. **ជំពូក៦** គឺជាផ្នែកសម្រេចសេចក្ដី។ អង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីមួយ៖ (១) បដិសេធការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង (២) តម្កល់ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទីពីរ (១) បដិសេធការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង (២) តម្កល់ការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង កំណត់បទចោទឡើងវិញ ដោយសម្រេចដាក់ពិរុទ្ធភាពពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ

[1187] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ១០៩៩។
[1188] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ១១០០-១១០១។
[1189] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ១១១០-១១១៦។
[1190] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ១១១៧-១១២១។
[1191] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ១១៣០-១១៣៧។
[1192] សំណុំរឿង ០០២/០១ សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ F36 កថាខណ្ឌ១១៣៨-១១៤៣។

និងពាក់ព័ន្ធនឹងអង្គហេតុដែលកើតឡើងនៅទួលពោធិ៍ជ្រៃ៖ (១) បដិសេធការសម្រេចដាក់ពិរុទ្ធភាពលើ នួន ជា និង ខៀវ សំផន ពីបទសម្លាប់រង្គាល បទមនុស្សឃាត និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (២) តម្កល់ការប្រកាសទោសដាក់ពន្ធនាគារអស់មួយជីវិតលើ នួន ជា និង ខៀវ សំផន របស់អង្គជំនុំជម្រះសាលាដំបូង (៣) បដិសេធបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាថាពុំអាចទទួលយកបាន និង (៤) បង្គាប់ថា នួន ជា និង ខៀវ សំផន ត្រូវស្ថិតនៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក. រង់ចាំការរៀបចំរួចរាល់ ស្របតាមច្បាប់ នឹងត្រូវផ្ទេរទៅពន្ធនាគារដែលត្រូវអនុវត្តទោសនៅទីនោះ។

## ៥.២.៧. សំណុំរឿង ០០២/០២

"រឿងក្តីបច្ចុប្បន្ន ហៅថា "សំណុំរឿង ០០២/០២" ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍រីពរីផ្សេងៗបំផុតមួយចំនួន ដែលបានកើតឡើងក្នុងចំណោមមហាសោកនាដកម្ម និងមហន្តរាយក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ" ប្រធានអង្គជំនុំជម្រះតុលាការកំពូល[1193]

### ៥.២.៧.១. ការជំនុំជម្រះ

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុខាងក្រោមបង្កើតបានជាមូលដ្ឋានសម្រាប់សំណុំរឿង ០០២/០២ និងមានលំដាប់លំដោយដូចខាងក្រោម៖

i. សហករណ៍៖
   ក. សហករណ៍ត្រាំកក់
ii. ការដ្ឋាន៖
   ក. ការដ្ឋានទំនប់ ១ មករា
   ខ. ការដ្ឋានទំនប់ត្រពាំងថ្ម
   គ. ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង
iii. ការប្រព្រឹត្តលើក្រុមគោលដៅ
   ក. ការប្រព្រឹត្តលើជនជាតិចាម
   ខ. ការប្រព្រឹត្តលើជនជាតិវៀតណាម
   គ. ការប្រព្រឹត្តលើអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ
iv. មន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង៖
   ក. មន្ទីរសន្តិសុខអូរកន្សែង
   ខ. មន្ទីរសន្តិសុខភ្នំក្រោល
   គ. មន្ទីរសន្តិសុខស-២១
v. បទបញ្ញត្តិពីការរៀបអាពាហ៍ពិពាហ៍
vi. លក្ខណៈនៃជម្លោះប្រដាប់អាវុធ
vii. តួនាទីរបស់ជនជាប់ចោទ[1194]

អង្គជំនុំជម្រះសាលាដំបូងបានរំលឹកថា ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានលើកពេលពិចារណាលើអញ្ញត្រកម្មជាច្រើនមកពេលជំនុំជម្រះក្រោយៗមកទៀត[1195]។ អង្គជំនុំជម្រះបានកត់សម្គាល់ថា បញ្ហាជាក់លាក់ដែលបានលើកឡើងជាអញ្ញត្រកម្ម មិនពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះទេ

---

[1193] សំណុំរឿង ០០២/០២ សេចក្តីសង្ខេបសាលដីកាក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារ F76.1 កថាខណ្ឌ ៥។

[1194] សំណុំរឿង ០០២/០២ បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលទាក់ទៅនឹង សំណុំរឿង ០០២/០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ E301/9/1.1។ សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ E301/9/1។ សំណុំរឿង ០០២/០២ សេចក្តីសម្រេចអំពីលំដាប់លំដោយ នៃអង្គហេតុដែលត្រូវជំនុំជម្រះ នៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E315។

[1195] សំណុំរឿង ០០២/០២ ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ១។

ហើយនឹងត្រូវពិចារណានៅក្នុងសាលក្រម[1196]។ អង្គជំនុំជម្រះបានបដិសេធសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំបន្ថែមបទចោទរំលោភសេពសន្ថវៈ ក្រៅបរិបទអាពាហ៍ពិពាហ៍ ដោយពិចារណាថាខ្លួនមិនមានសិទ្ធិអំណាចបន្ថែមអង្គហេតុ ឬបទចោទថ្មីទៅក្នុងដីកាដំណោះស្រាយ ដែលត្រូវបានច្រានចោលដោយសហចៅក្រមស៊ើបអង្កេតនោះទេ[1197]។ អង្គជំនុំជម្រះក៏បានកត់សម្គាល់ទៀតថា អញ្ញត្រកម្មចំនួនពីរ ទាក់ទងទៅនឹងមូលដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់និយមន័យនៃបទធ្វើទារុណកម្ម និងសំណើសុំធ្វើការកំណត់បទល្មើសរំលោភសេពសន្ថវៈឡើងវិញជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានកំណត់ដាច់ដោយឡែក ត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល ហើយដូច្នេះអង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាលើពួកវាទេ[1198]។

ការណ៍នេះបន្សល់ទុកនូវអញ្ញត្រកម្មចំនួនពីរ ដែលត្រូវបានលើកឡើងដោយ អៀង សារី មួយពាក់ព័ន្ធនឹងអាជ្ញាយុកាលចំពោះបទបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងមួយទៀតទាក់ទងទៅនឹងយុត្តាធិការលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការនិរទេស[1199]។' អង្គជំនុំជម្រះសាលាដំបូងបានស្នើឱ្យភាគីបញ្ជាក់ថាតើ ពួកគេនៅតែយល់ស្របទៅនឹងអញ្ញត្រកម្មទាំងអស់នេះ ឬទេ ក្រោយពេលមរណភាពរបស់ អៀង សារី និងសុំឱ្យបញ្ជាក់គោលជំហររបស់ពួកគេមុនពេលសវនាការបឋម[1200]។ ទាំង នួន ជា និងទាំង ខៀវ សំផន បានយល់ស្របទៅនឹងអញ្ញត្រកម្មទាក់ទងទៅនឹងបទបំពារបំពានយ៉ាងធ្ងន់ធ្ងរ ហើយ ខៀវ សំផន នៅតែរក្សាជំហរយល់ស្របទៅនឹងអញ្ញត្រកម្មទាក់ទងនឹងការនិរទេស[1201]។

សវនាការបឋមបន្ថែមទៀតលើបញ្ហាពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ត្រូវបានធ្វើឡើងនៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៤ និងបានពិភាក្សាអំពីសំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្ថានភាពអញ្ញត្រកម្ម ការពិនិត្យឡើងវិញលើបញ្ហាច្បាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ និងលំដាប់លំដោយនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ជាមួយនឹងការពិនិត្យជាបឋមលើសាក្សីសក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ[1202]។ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា ខ្លួនបានទទួលសារណាគ្រប់គ្រាន់ហើយលើបញ្ហាទាំងនេះ ហើយអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរយ៉ាងឆាប់ដូចដែលអាចធ្វើបាន[1203]។

នៅក្នុងខែកញ្ញា និងខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបដិសេធអញ្ញត្រកម្មចំនួនពីរដែលនៅសល់ ដោយបានសម្រេចថា ការជំទាស់ទាក់ទងនឹងការនិរទេស គប្បីលើកឡើង

---

[1196] សំណុំរឿង ០០២/០២ ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ២។ ទាំងនេះរួមបញ្ចូលសំណួរនានាទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការដាក់ក្នុងមន្ទីរឃុំឃាំង ថាតើអង្គហេតុនៅក្នុងដីកាដំណោះស្រាយបំពេញតាមលក្ខខណ្ឌតម្រូវគតិយុត្ត ដើម្បីបង្ហាញអំពើប្រល័យពូជសាសន៍ និងបញ្ហាប្រឈមផ្នែកគតិយុត្តចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ។
[1197] សំណុំរឿង ០០២/០២ ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ៣។
[1198] សំណុំរឿង ០០២/០២ ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ៤។
[1199] សំណុំរឿង ០០២/០២ ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ៤។
[1200] សំណុំរឿង ០០២/០២ ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤ ឯកសារ E306 កថាខណ្ឌ ៥។
[1201] សេចក្តីសន្និដ្ឋានមេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីអញ្ញត្រកម្មដែលអង្គជំនុំជម្រះមិនទាន់បានដោះស្រាយ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ឯកសារ E306/2។ ជំហរទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ ដែលលើកឡើងដោយក្រុមមេធាវីការពារ អៀង សារី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ឯកសារ E306/1។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងយុត្តាធិការទៅលើការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E306/5 កថាខណ្ឌ ២-៣។ សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ E306/6 កថាខណ្ឌ ២។
[1202] សំណុំរឿង ០០២/០២ របៀបវារៈសម្រាប់សវនាការបឋមបន្ថែមក្នុងសំណុំរឿង០០២/០២ (ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤) ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E311/1។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E1/240.1។
[1203] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E1/240.1 ទំព័រ ២១ (អង់គ្លេស)។

នៅដំណាក់កាលមុនការជំនុំជម្រះ[1204] និងបានសម្រេចថា មិនមានអាជ្ញាយុកាលដែលអាចអនុវត្តបានចំពោះបទប្បញ្ញត្តិស្តីពីការបំពារបំពានយ៉ាងធ្ងន់ធ្ងរ នៅក្នុងច្បាប់ អ.វ.ត.ក. នោះទេ[1205]។

សវនាការលើភ័ស្តុតាងក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមដោយសេចក្តីថ្លែងបើក នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧[1206]។ ការជំនុំជម្រះ រួមបញ្ចូលទាំងសេចក្តីថ្លែងបិទ មានរយៈពេលសរុប ២៨៣ ថ្ងៃសវនាការ[1207]។ ក្នុងអំឡុងពេលជំនុំជម្រះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មបុគ្គល ១៨៥ នាក់ រួមមានសាក្សី ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៦៣ នាក់ និងអ្នកជំនាញប្រាំបីនាក់[1208]។ មូលដ្ឋានភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ រួមមានឯកសារ ១០.៨០០ សម្រាប់ការវិភាគ និងការពិចារណាដោយអង្គជំនុំជម្រះសាលាដំបូង[1209]។

### ៥.២.៧.២. ការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០២/០២ និងបញ្ហានានាបណ្តាលមកពីការបំបែកសំណុំរឿង

នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ ខៀវ សំផន បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងផ្អាកការចាប់ផ្តើមសំណុំរឿង ០០២/០២ រហូតទាល់តែសាលក្រមសំណុំរឿង ០០២/០១ បានចេញ ហើយអង្គជំនុំជម្រះតុលាការកំពូលចេញសាលដីកាលើបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១[1210]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ដោយយល់ឃើញថា ខៀវ សំផន មិនបានបង្ហាញមូលហេតុសមស្របសម្រាប់ការពន្យារពេលនេះ[1211]។

នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ខៀវ សំផន បានស្នើសុំការពិចារណាឡើងវិញលើសំណើរបស់ខ្លួន ដោយបានយោង ទាំងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម និងវិសាលភាពនៃសំណុំរឿង ០០២[1212] និងទាំងការចេញសាលក្រមសំណុំរឿង ០០២/០១ របស់អង្គជំនុំជម្រះសាលាដំបូង[1213] ជាកាលៈទេសៈថ្មីដែលចាំបាច់សម្រាប់ការពិចារណាឡើងវិញ[1214]។ ម្យ៉ាងវិញ

---

[1204] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងយុត្តាធិការទៅលើការនិរទេស ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E306/5។

[1205] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់មេធាវីការពារក្តី ទាក់ទងនឹងអាជ្ញាយុកាលនៃការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ ឯកសារ E306/6។

[1206] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ E1/242.1។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ឯកសារ E1/519.1។

[1207] សូមមើ សាលក្រមសំណុំរឿង ០០២/០២ ឧបសម្ព័ន្ធ ១៖ ប្រវត្តិនីតិវិធី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465.1 កថាខណ្ឌ ៦៦។

[1208] សាលក្រមសំណុំរឿង ០០២/០២ ឧបសម្ព័ន្ធ ១៖ ប្រវត្តិនីតិវិធី ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465.1 កថាខណ្ឌ ៦៦។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សេចក្តីសម្រេចស្តីពីសាក្សីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលត្រូវបានស្នើសុំស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ E459។

[1209] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៥៦។

[1210] សំណុំរឿង ០០២/០២ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង ០០២/០១ មុននឹងចាប់ផ្តើមសំណុំរឿង ០០២/០២ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ ឯកសារ E301/5/5 កថាខណ្ឌ ៦៧។

[1211] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូលដលមានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ ឯកសារ E301/5/5/1 កថាខណ្ឌ ១៦។

[1212] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ឯកសារ E301/9/1/1/3។

[1213] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313។

[1214] សំណុំរឿង ០០២/០២ សំណើរបស់ លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និង សុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ E314/1 កថាខណ្ឌ ៦-១០, ៥៤។

ទៀត គាត់បានស្នើសុំឱ្យមានក្រុមប្រឹក្សាជំនុំជម្រះថ្មីដើម្បីកាត់សេចក្តីសំណុំរឿង ០០២/០២[1215]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ដោយយល់ឃើញថាការផ្អាកមិនចាំបាច់ និងដោយកត់សម្គាល់ថា ភាគីផ្សេងទៀត និងអង្គជំនុំជម្រះតុលាការកំពូល បានជំរុញឱ្យសំណុំរឿង ០០២/០២ ចាប់ផ្តើមឱ្យបានឆាប់ដូចដែលអាចធ្វើបាន។ អង្គជំនុំជម្រះបានបញ្ជូនសំណើបន្ទាប់បន្សំ សុំប្តឹងជំទាស់ចៅក្រម ទៅកាន់គណៈកម្មាធិការរដ្ឋបាលតុលាការ[1216]។ នៅថ្ងៃដដែល ដែលអង្គជំនុំជម្រះបានបដិសេធសំណើរបស់ ខៀវ សំផន អង្គជំនុំជម្រះក៏បានចេញដីកាកំណត់កាលវិភាគរៀបចំសវនាការលើអង្គសេចក្តី ក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ភាគីកំពុងស្ថិតក្នុងដំណើរការរៀបចំសេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ និងកំពុងរៀបចំសារណាបណ្តឹងសាទុក្ខ និងយល់ឃើញថា ភាគីនឹងទទួលបានអត្ថប្រយោជន៍ពីការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីភស្តុតាង បន្ទាប់ពីដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងសាទុក្ខ និងពីការកាត់បន្ថយកាលវិភាគសវនាការ ខណៈដែលពួកគេកំពុងរៀបចំសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ហើយបានកំណត់កាលវិភាគចាប់ផ្តើមវគ្គដំបូងនៃសវនាការលើភស្តុតាងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ដោយអង្គជំនុំជម្រះបើកសវនការបីថ្ងៃក្នុងមួយសប្តាហ៍[1217]។ អង្គជំនុំជម្រះបានបដិសេធសំណើរបស់ ខៀវ សំផន ដែលស្នើសុំឱ្យពិចារណាឡើងវិញលើដីកាកំណត់កាលវិភាគសវនាការ និងសុំឱ្យលើកពេលចាប់ផ្តើមការជំនុំជម្រះ រហូតដល់ពេលសារណាបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ត្រូវបានដាក់ ដែលអង្គជំនុំជម្រះយល់ឃើញថា មិនមានកាលៈទេសៈថ្មីណាចាំបាច់ត្រូវធ្វើការពិចារណាឡើងវិញនោះទេ[1218]។

នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ បានចាប់ផ្តើមជាមួយនឹងសេចក្តីថ្លែងបើករបស់សហព្រះរាជអាជ្ញា អមដោយសេចក្តីថ្លែងការណ៍របស់ នួន ជា និង ខៀវ សំផន។ ទាំង នួន ជា និង ទាំង ខៀវ សំផន បានជូនដំណឹងអង្គជំនុំជម្រះសាលាដំបូងថា ពួកគេបានណែនាំសហមេធាវីរបស់ខ្លួនឱ្យពហិការក្នុងការចូលរួមកិច្ចដំណើរការនីតិវិធី ក្នុងសំណុំរឿង ០០២/០២ ដោយសំអាងលើភាពចាំបាច់ក្នុងការផ្តោតលើការរៀបចំសារណាបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០១ និងកំពុងរង់ចាំសេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២[1219]។ ក្រោយមកក្រុមមេធាវីទាំងពីរបានចាកចេញពីសាលសវនាការ[1220]។ បន្ទាប់ពីបានស្តាប់សវនាការពីភាគីនៅសល់ដែលមានវត្តមាន អង្គជំនុំជម្រះសាលាដំបូង លើកពេលសវនាការរហូតដល់កិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤[1221]។ សហមេធាវីរបស់ នួន ជា និង ខៀវ សំផន មិនបានចូលរួមកិច្ចប្រជុំរៀបចំសវនាការទេ ហើយមិនបានផ្តល់ហេតុផលសម្រាប់អវត្តមានរបស់ពួកគេឡើយ[1222]។ អង្គជំនុំជម្រះសាលាដំបូង បានព្រមានសហមេធាវីថា ពួកគេកំពុងរារាំងកិច្ចដំណើរការនីតិវិធី ហើយបានបង្គាប់ឱ្យពួកគេចូលរួមក្នុងកិច្ចប្រជុំរៀបចំសវនាការថ្មី ដែលគ្រោងធ្វើនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ខណៈដែលលុបចោលសវនាការដែលបានគ្រោងទុកផ្សេងទៀត។ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា កាលបរិច្ឆេទសវនាការថ្មីនឹងផ្តល់ជូនក្នុងពេលវេលាសមស្រប[1223]។ បន្ទាប់ពីការព្យាយាមបន្ថែមទៀតក្នុង

---

[1215] សំណុំរឿង ០០២/០២ សំណើរបស់ លោក ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និង សុំឱ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៤ ឯកសារ E314/1 កថាខណ្ឌ ៤៨-៥៤។

[1216] សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E314/5។ សម្រាប់សេចក្តីសង្ខេបនៃសេចក្តីសម្រេចលើបណ្តឹងជំទាស់ សូមមើល ឧបសម្ព័ន្ធ ៥។

[1217] សំណុំរឿង ០០២/០២ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ឯកសារ E316។

[1218] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ឯកសារ E314/5/3។

[1219] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ E1/242.1 ទំព័រ ៦៤-៧៩ (អង់គ្លេស)។

[1220] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ E1/242.1 ទំព័រ ៨៧, ៩១ (អង់គ្លេស)។

[1221] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ឯកសារ E1/242.1 ទំព័រ ៨៧-៩៣ (អង់គ្លេស)។

[1222] សំណុំរឿង ០០២/០២ ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ ឯកសារ E320 កថាខណ្ឌ ៣-៤។

[1223] សំណុំរឿង ០០២/០២ ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤ ឯកសារ E320 កថាខណ្ឌ ៦-១០។

ការចាប់ផ្ដើមកិច្ចដំណើរការជំនុំជម្រះ និងមិនមានការចូលរួមរបស់សហមេធាវីការពារក្ដី ខៀវ សំផន[1224] នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យតែងតាំងសហមេធាវីប្រចាំការសម្រាប់ ខៀវ សំផន សម្រាប់រយៈពេលនៃសំណុំរឿង ០០២/០២[1225]។ លោកស្រី ទូច វរល័ក្ស និងលោក Calvin Saunders ត្រូវបានតែងតាំងជាសហមេធាវីប្រចាំការរបស់ ខៀវ សំផន ហើយបានបំពេញតួនាទីនេះរហូតដល់បិទបញ្ចប់សវនាការលើភ័ស្តុតាង ក្នុងសំណុំរឿង ០០២/០២[1226]។

### ៥.២.៧.៣. សាលក្រមជំនុំជម្រះ

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រម ក្នុងសំណុំរឿង ០០២/០២ រួមជាមួយនឹងសេចក្ដីសង្ខេបសំអាងហេតុ ដោយបានផ្ដន្ទាទោស នួន ជា និង ខៀវ ខំផន ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទ្រីក្រុងហ្សឺណែវ និងអំពើប្រល័យពូជសាសន៍ ហើយបានកាត់ទោសពួកគេដាក់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាលើទោសមួយជីវិតដែលបានដាក់រួចហើយក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលទោសទាំងពីរនេះទៅជារយៈពេលជាប់ពន្ធនាគារអស់មួយជីវិតតែមួយវិញ សម្រាប់ជនជាប់ចោទទាំងពីរ[1227]។ សាលក្រមជាលាយលក្ខណ៍អក្សរបានចេញនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩[1228]។

---

[1224] មេធាវីការពារក្ដី នួន ជា និង ខៀវ សំផន បានលើកឡើងម្ដងទៀតនូវមូលហេតុសម្រាប់ការមិនចូលរួមរបស់ខ្លួនក្នុងកិច្ចប្រជុំរៀបចំសវនាការ។ សូមមើល សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ឯកសារ E1/244.1។ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ជនជាប់ចោទទាំងពីរ ឱ្យចូលរួមក្នុងសវនាការសំណុំរឿង ០០២/០២ ដែលនឹងចាប់ផ្ដើមនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤។ សូមមើល សំណុំរឿង ០០២/០២ សេចក្ដីសម្រេចបន្ទាន់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៤ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ E320/1 កថាខណ្ឌ ១០។ មេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ជំហររបស់ខ្លួន។ សូមមើល សំណុំរឿង ០០២/០២ គោលជំហររបស់លោក ខៀវ សំផន បន្ទាប់ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង E320/1 ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E320/1/1 កថាខណ្ឌ ៨។ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានព្យាយាមបើកកិច្ចដំណើរការនីតិវិធី ប៉ុន្តែមេធាវីការពារក្ដី ខៀវ សំផន មិនមានវត្តមាន។ ក្រោយពីបានស្ដាប់សារណារបស់ ខៀវ សំផន និងភាគីផ្សេងទៀត អង្គជំនុំជម្រះសាលាដំបូងបានណែនាំ ខៀវ សំផន ថា សិទ្ធិរបស់គាត់ក្នុងការមានមេធាវីតាមឆន្ទៈរបស់គាត់មិនដាច់ខាតនោះទេ និងថាអង្គជុំនុំជម្រះអាចនឹងតែងតាំងមេធាវីផ្ទុយនឹងឆន្ទៈរបស់គាត់ ប្រសិនបើផលប្រយោជន៍យុត្តិធម៌តម្រូវដូច្នោះ។ អង្គជំនុំជម្រះបានបង្គាប់ឱ្យ ខៀវ សំផន ជូនដំណឹងអង្គជំនុំជម្រះសាលាដំបូងត្រឹមម៉ោង ៤:៣០ ល្ងាច នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ថាតើគាត់បានដកការណែនាំពីមុនរបស់គាត់ ទៅកាន់មេធាវីមិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ និងបានលើកពេលកិច្ចដំណើរការនីតិវិធីរហូតដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤។ សូមមើល សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E1/245.1 ទំព័រ២-១៧ (អង់គ្លេស)។ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានតែងតាំងមេធាវីការពារក្ដី ខៀវ សំផន គឺលោក គង់ សំអុន លោក Arthur Vercken និងលោកស្រី Anta Guissé ជាមេធាវីដែលត្រូវបានតែងតាំងដោយតុលាការសម្រាប់ការពារក្ដី ខៀវ សំផន និងបានបង្គាប់ពួកគេឱ្យបង្ហាញខ្លួនតាមកាលបរិច្ឆេទនៃការចាប់ផ្ដើមដែលបានកំណត់ពេលឡើងវិញនៃសំណុំរឿង ០០២/០២។ សូមមើល សំណុំរឿង ០០២/០២ សេចក្ដីសម្រេចស្ដីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E320/2។ សូមមើលផងដែរ សំណុំរឿង ០០២/០២ អនុស្សរណៈរបស់អង្គភាពគាំពារការការពារក្ដី ស្ដីពី៖ សេចក្ដីសម្រេចទាក់ទងនឹងការដកការចាត់តាំងលោក Arthur VERCKEN ជាសហមេធាវីអន្តរជាតិសម្រាប់លោក ខៀវ សំផន ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ F32/2។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ជាថ្ងៃមុនកាលបរិច្ឆេទចាប់ផ្ដើមថ្មី មេធាវីការពារក្ដី ខៀវ សំផន បានផ្ញើលិខិតមួយជូនដំណឹងអង្គជំនុំជម្រះសាលាដំបូងថា ពួកគេនឹងបន្តមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី មុនពេលបញ្ចប់សារណាបណ្ដឹងសាទុក្ខ បើទោះបីជាមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងតែងតាំងពួកគាត់ជាមេធាវីដែលត្រូវបានតែងតាំងដោយតុលាការក៏ដោយ។ សូមមើល លិខិតជូនទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E320/2/1។ សូមមើលផងដែរ សំណុំរឿង ០០២/០២ សេចក្ដីសម្រេចស្ដីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ឯកសារ E321/2 កថាខណ្ឌ១២។ អង្គជំនុំជម្រះសាលាដំបូងបានលុបចោលកាលបរិច្ឆេទជំនុំជម្រះទាំងអស់ក្នុងឆ្នាំ ២០១៤ និងបានលើកពេលកិច្ចដំណើរការនីតិវិធីរហូតដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E1/246.1 ទំព័រ ៤ (អង់គ្លេស)។

[1225] សំណុំរឿង ០០២ សេចក្ដីសម្រេចស្ដីអំពីការតែងតាំងមេធាវីប្រចាំការដោយតុលាការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ E321/2។

[1226] សំណុំរឿង ០០២/០២ សេចក្ដីសម្រេចបញ្ចប់ការតែងតាំងមេធាវីប្រចាំការសម្រាប់ ខៀវ សំផន ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៧ ឯកសារ E321/3។

[1227] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E1/529.1។

[1228] សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465។ សូមមើលផងដែរ សំណុំរឿង ០០២/ ០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ ៥១។

សាលក្រមមានកម្រាស ៣.៨៨៣ ទំព័រជាភាសាខ្មែរ ២.២៥៩ ទំព័រជាភាសាអង់គ្លេស និង ២.៦៨៦ ទំព័រជាភាសាបារាំង ដោយមិនរាប់បញ្ចូលឧបសម្ព័ន្ធរបស់វា។ សាលក្រមចែកជា ២៣ ជំពូក។

i. **ជំពូក១** គឺជាសេចក្តីផ្តើម ដែលមានប្រវត្តិសង្ខេបនៃកិច្ចដំណើរការនិតិវិធីរឿងក្តី និងសេចក្តីសង្ខេបអំពីបទចោទប្រកាន់។
ii. **ជំពូក២** លើកឡើងអំពីបញ្ហាបឋមលើយុត្តាធិការ គោលការណ៍នីត្យានុកូលភាព សំណុំរឿង គោលការណ៍នៃភ័ស្តុតាងនិងនីតិវិធី និងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។
iii. **ជំពូក៣** ពិភាក្សាអំពីបរិបទប្រវត្តិសាស្ត្រនៃរឿងក្តី។
iv. **ជំពូក៤** ពិភាក្សាអំពីទិដ្ឋភាពទូទៅនៃរយៈពេលដែលជាបញ្ហាចោទនៅក្នុងដីកាដំណោះស្រាយ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ជំពូកនេះមានទិដ្ឋភាពអង្គហេតុនៃវិសាលភាពពេលវេលានៃរឿងក្តី ដែលរួមបញ្ចូលលក្ខណៈនៃជម្លោះប្រដាប់អាវុធ លក្ខខណ្ឌទូទៅសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងលក្ខខណ្ឌទូទៅសម្រាប់ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។
v. **ជំពូក៥** រៀបរាប់អំពីរចនាសម្ព័ន្ធរដ្ឋបាល រួមមានរចនាសម្ព័ន្ធរបស់ ប.ក.ក. កម្ពុជាប្រជាធិបតេយ្យ និងកងកម្លាំងយោធារបស់ ប.ក.ក.។
vi. **ជំពូក៦** រៀបរាប់អំពីរចនាសម្ព័ន្ធទំនាក់ទំនងការងារ និងពិភាក្សាអំពីមធ្យោបាយទំនាក់ទំនងការងារ ប្រព័ន្ធនៃទំនាក់ទំនងការងារ និងទំនាក់ទំនងផ្នែកយោធា។
vii. **ជំពូក៧** ពិភាក្សាអំពីតួនាទី និងមុខងាររបស់ នួន ជា។ អង្គជំនុំជម្រះបានរកឃើញថា នួន ជា៖
    - គឺជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា តាំងពីសន្និបាតបក្សលើកទីមួយ ក្នុងឆ្នាំ១៩៦០
    - បានធ្វើជាប្រធានសភាតំណាងប្រជាជន
    - គឺជានាយករដ្ឋមន្ត្រីស្តីទីនៃកម្ពុជាប្រជាធិបតេយ្យ ពីខែកញ្ញា ឆ្នាំ១៩៧៦ ដល់ខែកញ្ញា ឆ្នាំ១៩៧៧ ក្នុងពេលដែល ប៉ុល ពត អវត្តមាន
    - បានគ្រប់គ្រងទាំងសេចក្តីសម្រេចនយោបាយ និងទាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រដ្ឋបាល និងបញ្ហាយោធា
    - បានចូលរួមក្នុងបញ្ហាយោធា និងសន្តិសុខ ដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងសិទ្ធិអំណាចយូរអង្វែងរបស់គាត់នៅក្នុងបក្ស
    - បានចូលរួមយ៉ាងសកម្មក្នុងសេចក្តីសម្រេចពាក់ព័ន្ធនឹងប្រតិបត្តិការរបស់កងទ័ពបដិវត្តន៍កម្ពុជា ជាពិសេស ទាក់ទងនឹងសង្គ្រាមប្រឆាំងវៀតណាម
    - បានចូលរួមក្នុងការគ្រប់គ្រងប្រតិបត្តិការមន្ទីរសន្តិសុខ ស-២១ បានទទួលរបាយការណ៍ជាប្រចាំ និងបានផ្តល់ការណែនាំលើបញ្ហាសន្តិសុខ ដោយផ្ទាល់ ឬតាមរយៈសេចក្តីសម្រេចរបស់បក្ស
    - បានចូលរួមក្នុងការឃោសនា ការអប់រំ មានលក្ខណៈទូលំទូលាយរួមបញ្ចូលទាំងផ្នែកវិន័យរបស់បក្ស និងកិច្ចការសន្តិសុខផ្ទៃក្នុង ព្រមទាំងសភាពការណ៍ខ្លាំងជាទូទៅ និងការគាំទ្រឱ្យវែកមុខនិងកម្ចាត់ខ្មាំងផងដែរ
    - បានត្រួតពិនិត្យសកម្មភាពបក្ស ដែលហួសពីតួនាទី និងការទទួលខុសត្រូវជាផ្លូវការដែលបានផ្តល់ឱ្យគាត់ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ និងបានអនុវត្តរួមជាមួយនឹង ប៉ុល ពត។
viii. **ជំពូក៨** ពិភាក្សាអំពីតួនាទី និងមុខងាររបស់ ខៀវ សំផន។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខៀវ សំផន៖
    - គឺជាប្រធានគណៈប្រធានរដ្ឋ បន្ទាប់ពីអនុម័តរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ និងទទួលខុសត្រូវលើការធ្វើការទំនាក់ទំនងការទូត ការចេញសេចក្តីថ្លែងការណ៍តំណាងកម្ពុជាប្រជាធិបតេយ្យ និងការគាំទ្រមាគ៌ាកម្ពុជាប្រជាធិបតេយ្យ
    - ជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម ប.ក.ក. នៅសន្និបាតបក្សលើកទីបី និងបានក្លាយជាសមាជិកពេញសិទ្ធិនៅសន្និបាតបក្សលើកទីបួន
    - ធ្លាប់ជាឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល GRUNK ជារដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការ CPNLAF ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយទោះបីជាគាត់មិនមានសិទ្ធិអំណាចយោធាផ្នែកប្រតិបត្តិ ក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏គាត់

បានធ្វើឱ្យចលនាតស៊ូទៅជាស្របច្បាប់ជាសាធារណៈ ដែលចុងក្រោយប្រកាសខ្លួនថាជា ប.ក.ក.

- បំពេញមុខងារនៅក្នុងមន្ទីរ ៨៧០ តាមការចាត់តាំងទៅកាន់មន្ទីរនោះ ឬជាផ្នែកមួយនៃការទទួលខុសត្រូវសេសសល់របស់គាត់ ក្នុងនាមជាសមាជិកបក្ស
- បានអនុវត្តកិច្ចការត្រួតពិនិត្យដ៏សំខាន់ ដូច្នេះហើយគាត់បានទទួលព័ត៌មានពេញលេញ អំពីបញ្ហាពាណិជ្ជកម្មនិងការនាំចេញនាំចូលរបស់កម្ពុជាប្រជាធិបតេយ្យ ទាំងក្នុងស្រុកនិងអន្តរជាតិ នៅចន្លោះពីខែតុលា ឆ្នាំ១៩៧៦ ដល់ដើមឆ្នាំ១៩៧៩
- ជាសមាជិក ប.ក.ក. ដែលទទួលបានព័ត៌មានពេញលេញ ដែលមានតួនាទីពិសេសនៅក្នុងបក្ស ដោយសារតែវត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលពិភាក្សានិងសម្រេចលើបញ្ហាសំខាន់ៗ។

ix. **ជំពូក៩** ពិភាក្សាអំពីច្បាប់ជាធរមាន នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអំពើប្រល័យពូជសាសន៍។

x. **ជំពូក១០** ពិភាក្សាអំពីសហករណ៍ ជាពិសេស សហករណ៍ត្រាំកក់។

xi. **ជំពូក១១** ពិភាក្សាអំពីការដ្ឋាន ជាពិសេស ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់ ១ មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។

xii. **ជំពូក១២** ពិភាក្សាអំពីមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការបោសសម្អាតផ្ទៃក្នុង ដំបូងពិភាក្សាអំពីអំណះអំណាងរបស់ នួន ជា ពាក់ព័ន្ធនឹងការគំរាមកំហែងរបស់វៀតណាម ទំនាស់ផ្ទៃក្នុង និងយុត្តិកម្មនៃគោលនយោបាយសន្តិសុខជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ មុនពេលពិភាក្សាលើមន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ អូរកន្សែង និង ភ្នំក្រោល។

xiii. **ជំពូក១៣** ពិភាក្សាអំពីការប្រព្រឹត្តចំពោះក្រុមគោលដៅ ជាពិសេស ពុទ្ធសាសនិក ជនជាតិចាម ជនជាតិវៀតណាម និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។

xiv. **ជំពូក១៤** ពិភាក្សាអំពីបទបញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍។

xv. **ជំពូក១៥** ពិភាក្សាអំពីច្បាប់ជាធរមាន ពាក់ព័ន្ធនឹងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ជាពិសេស ការប្រព្រឹត្តតាមរយៈ JCE ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងការជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ។

xvi. **ជំពូក១៦** ពិភាក្សាអំពីការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងលើ JCE រួមបញ្ចូលការរកឃើញថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម មានគោលបំណងរួមក្នុងការ "អនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" ដែលត្រូវបានបង្កើតឡើង ដើម្បីកសាង ការពារប្រទេស ឱ្យរួចផុតពីសត្រូវ និងផ្លាស់ប្តូរប្រជាជនទាំងស្រុងឱ្យក្លាយទៅជាសង្គមខ្មែររួបរួមគ្នាមួយ ដែលមានតែវណ្ណៈកម្មករ-កសិករ"។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការធ្វើមនុស្សឃាតដែលបានប្រព្រឹត្តឡើងដោយមានចេតនាប្រយោល មិនមែនជាផ្នែកមួយនៃគោលបំណងរួមតាមទម្រង់ JCE នោះទេ ហើយដូច្នេះ នៅក្នុងជំពូកបន្តបន្ទាប់ទៀត អង្គជំនុំជម្រះយល់ឃើញថា នួន ជា និង ខៀវ សំផន ទទួលខុសត្រូវចំពោះការធ្វើមនុស្សឃាតទាំងអស់នេះ តាមរយៈការជួយ និងការជំរុញ[1229]។

xvii. **ជំពូក១៧** ពិភាក្សាអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា។

xviii. **ជំពូ១៨** ពិភាក្សាអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន។

xix. **ជំពូក១៩** ពិភាក្សាអំពីវិរុទ្ធភាពពីបទល្មើសច្រើន។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា ការផ្តន្ទាទោសចំពោះបទល្មើសការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលកើតចេញពីអំពើតែមួយ គឺមានលក្ខណៈត្រួតគ្នា ហើយបានធ្វើការផ្តន្ទាទោសពីបទសម្លាប់រង្គាលតែមួយប៉ុណ្ណោះ នឹងថាការផ្តន្ទាទោសពីបទការធ្វើបាបដោយអមនុស្សធម៌ និងការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ដែលជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលកើតចេញពីអំពើ

[1229] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៩២១, ៣៩៧៧, ៤១៧៩, ៤១៨៣, ៤១៨៦, ៤១៩៩, ៤៣១១, ៤៣១៥, ៤៣១៧-៤៣១៨, ៤៣២៨។

តែមួយ គឺមានលក្ខណៈត្រតគ្នា ដូច្នេះអង្គជំនុំជម្រះធ្វើការផ្តន្ទាទោសពីបទការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព តែមួយប៉ុណ្ណោះ[1230]។

xx. **ជំពូក២០** ពិភាក្សាអំពីការផ្តន្ទាទោស។

xxi. **ជំពូក២១** ពិភាក្សាអំពីសំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលក្នុងនោះអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលគម្រោងដែលបានស្នើឡើងចំនួន ១៤ និងបានអនុម័តគម្រោង ១៣ ក្នុងចំណោមគម្រោងទាំងអស់នោះ។

xxii. **ជំពូក២២** គឺជាផ្នែកសម្រេចសេចក្តី។ នៅក្នុងជំពូកនេះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា អង្គជំនុំជម្រះបានបដិសេធសំណើរបស់ ខៀវ សំផន សុំឱ្យកំណត់វិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ កំណត់បទល្មើសឡើងវិញចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការសម្លាប់រង្គាល ទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត រួមបញ្ចូលចេតនាប្រយោល ដោយសារតែលក្ខខណ្ឌ និងកាលៈទេសៈដែលបានកំណត់លើជនរងគ្រោះ នៅតាមសហករណ៍ និងការដ្ឋាន ដែលបានពិនិត្យនៅក្នុងសំណុំរឿង ០០២/០២ និង មន្ទីរសន្តិសុខ ស-២១ ក្រាំងតាចាន់ និងភ្នំក្រោល ហើយបានសន្និដ្ឋានថា នួន ជា និង ខៀវ សំផន មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[1231] ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[1232] និងអំពើប្រល័យពូជសាសន៍[1233]។

xxiii. **ជំពូក២៣** បង្ហាញពីយោបល់ដោយឡែករបស់ចៅក្រម យូរ ឧត្តរា ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ចៅក្រម យូរ ឧត្តរា បានបង្ហាញការបកស្រាយរបស់គាត់លើនិយមន័យអំពើប្រល័យពូជសាសន៍ យោងតាមអនុសញ្ញាប្រល័យពូជសាសន៍ ពោលគឺថា អាចមានមូលដ្ឋានច្បាស់លាស់ក្នុងការពិនិត្យបរិបទទូលំទូលាយនៃព្រឹត្តិការណ៍ក្នុងប្រទេសកម្ពុជា ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ជាពិសេសថាតើមានចេតនាបំផ្លិចបំផ្លាញផ្នែកដ៏សំខាន់មួយនៃរចនាសម្ព័ន្ធរបស់ក្រុមជាតិសាសន៍ខ្មែរដែលមានអត្ថិភាពនាពេលនោះ ឬទេ។ គាត់យល់ឃើញថា ចំណុចនេះទាក់ទងតិចតួចនឹងការពិភាក្សាអំពី ក្រុមនយោបាយ និង/ឬ អំពើប្រល័យវប្បធម៌ និងថា ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា ខ្មែរក្រហមមានចេតនាបោសសម្អាតប្រទេសកម្ពុជាតាមរយៈចេតនាបំផ្លិចបំផ្លាញផ្នែកដ៏សំខាន់មួយនៃក្រុមជាតិសាសន៍ខ្មែរ ក្នុងចំនួនណាមួយ និងក្នុងលក្ខណៈសង្គមណាមួយ ដូចជាសាសនា មេដឹកនាំ និងនយោបាយ សង្គម និងវប្បធម៌ របស់ពួកគេដែលត្រូវបានកំណត់ថាជាក្រុម *ជាតិសាសន៍ខ្មែរ* នៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នោះ អ.វ.ត.ក. អាចមានលទ្ធភាពកំណត់អត្ថន័យឱ្យបានត្រឹមត្រូវចំពោះការស្លាប់ និងការបំផ្លិចបំផ្លាញបែបនោះបាន។

អង្គជំនុំជម្រះសាលាដំបូងក៏បានដាក់សេចក្តីសង្ខេបសាលក្រមរបស់ខ្លួនផងដែរ[1234]។

[1230] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៣៩១។

[1231] ទាំងអស់នេះគឺការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ សាសនា និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងអំពើដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ ការផ្លាស់ទីលំនៅដោយបង្ខំ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ក្នុងបរិបទនៃការរៀបការដោយបង្ខំ។

[1232] ទាំងអស់នេះគឺ ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបបែបអមនុស្សធម៌ និងការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

[1233] សម្រាប់ នួន ជា នេះគឺជាអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម និងជនជាតិចាម។ ខៀវ សំផន ត្រូវបានផ្តន្ទាទោសពីបទអំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាមតែប៉ុណ្ណោះ។

[1234] សំណុំរឿង ០០២/០២ សេចក្តីសង្ខេបសាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ ឯកសារ E465/5។

### ៥.២.៧.៤. កិច្ចដំណើរការនីតិវិធីអង្គជំនុំជម្រះតុលាការកំពូល

#### ៥.២.៧.៤. មរណភាពរបស់ នួន ជា និង ការបញ្ចប់កិច្ចដំណើរការនីតិវិធី

នួន ជា បានទទួលមរណភាពនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩[1235] មិនដល់មួយខែផងបន្ទាប់ពីបាន ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ជំទាស់នឹងសាលក្រមសំណុំរឿង ០០២/០២[1236]។ ពីរថ្ងៃក្រោយមក មេធាវីការពារក្តីរបស់គាត់បានប្តឹងទៅអង្គជំនុំជម្រះតុលាការកំពូលនូវសំណើសុំបន្ទាន់ ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលមរណភាពរបស់ នួន ជា នឹងមានទៅលើកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ សំណើនោះបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខពាក់ព័ន្ធនឹង នួន ជា ដែលនាំឱ្យសាលក្រមក្នុងសំណុំរឿង ០០២/០២ ចំពោះលោក នួន ជា ត្រូវអស់អានុភាពអនុវត្តទាំងស្រុង ដោយ នួន ជា នៅតែទទួលបានសិទ្ធិសន្មតជាមុនថាគ្មានទោសក្រោយពេលបានប្តឹងសាទុក្ខ ឬបើមិនដូច្នោះទេ អនុញ្ញាតឱ្យនីតិវិធីបណ្តឹងសាទុក្ខពាក់ព័ន្ធនឹង នួន ជា បន្តដំណើរការទៅមុខដើម្បីបម្រើផលប្រយោជន៍យុត្តិធម៌ ដោយធានាឱ្យ នួន ជា ទទួលបានការការពារដោយក្រុមមេធាវីការពារក្តីតាមឆន្ទៈរបស់គាត់ ក្រោយពីរូបគាត់ទទួលមរណភាព[1237]។

អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចប់នីតិវិធីបណ្តឹងសាទុក្ខ ប្រឆាំងនឹង នួន ជា ដោយលើកឡើងថា ខ្លួននៅតែបន្តពិនិត្យលើសំណើបន្ទាន់[1238]។ ក្រោយមកអង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ការបញ្ចប់កិច្ចដំណើរការនីតិវិធី ប្រឆាំងនឹង នួន ជា មិនបានមោឃៈសាលក្រមអង្គជំនុំជម្រះសាលាដំបូងទេ បណ្តឹងសាទុក្ខមិនអាចបន្តនីតិវិធីក្រោយមរណភាពរបស់ នួន ជា បានឡើយ ហើយដូច្នេះពុំមានការចេញសាលក្រម ឬសាលដីកាស្ថាពរលើភាពមានពិរុទ្ធ ឬគ្មានពិរុទ្ធរបស់ នួន ជា ដោយសារមរណភាពរបស់គាត់បានរារាំងការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះតុលាការកំពូលបានពន្យល់ថា សច្ចធារណ៍និរទោសមានអត្ថិភាពនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ប៉ុន្តែពុំមែនជាការយល់ឃើញថាគ្មានពិរុទ្ធ*ក្រោយមរណភាព*នោះទេ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានលើកឡើងផងដែរថា មរណភាពរបស់ នួន ជា មិនបានប៉ះពាល់ដល់ការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ[1239]។

#### ៥.២.៧.៤.២. បណ្តឹងសាទុក្ខលើសាលក្រមសំណុំរឿង ០០២/០២ និងសវនាការលើបណ្តឹងសាទុក្ខ

ខៀវ សំផន និងសហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខលើសាលក្រម។ ខៀវ សំផន បានលើកយកមូលដ្ឋានបណ្តឹងសាទុក្ខប្រមាណ ១.៨២៤[1240]។ សហព្រះរាជអាជ្ញាបានលើកយកមូលដ្ឋានបណ្តឹងសាទុក្ខតែមួយប៉ុណ្ណោះ គឺថាអង្គជំនុំជម្រះសាលាដំបូងមានកំហុស តាមរយៈការសន្និដ្ឋានថា អំពើរំលោភសេពសន្ថវៈក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត ទាក់ទងនឹងជនរងគ្រោះជាបុរស[1241]។ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ មេធាវីការពារក្តី ខៀវ សំផន សហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញខ្លួនពីចម្ងាយ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដោយសារតែការរាតត្បាតនៃជំងឺកូវីដ ១៩ នៅក្នុងសវនាការបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២[1242]។ អង្គជំនុំជម្រះតុលាការកំពូល បានស្តា

---

[1235] សំណុំរឿង ០០២/០២ លិខិតមរណភាពរបស់ នួន ជា ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ ឯកសារ F46/1.1។

[1236] សំណុំរឿង ០០២/០២ សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ E465/3/1។

[1237] សំណុំរឿង ០០២/០២ សំណើបន្ទាន់ ទាក់ទងនឹងផលប៉ះពាល់លើនីតិវិធីបណ្តឹងសាទុក្ខណៃការទទួលមរណភាពរបស់ នួន ជា នីមុនពេលចេញសាលដីកា ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៩ ឯកសារ F46/2។

[1238] សំណុំរឿង ០០២/០២ សេចក្តីសម្រេចបញ្ចប់កិច្ចដំណើរការនីតិវិធីលើជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩ ឯកសារ F46/3។

[1239] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើបន្ទាន់ពាក់ព័ន្ធទៅនឹងផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខក្រោយមរណភាពរបស់ នួន ជា នៅមុនពេលចេញសាលដីកា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ F46/2/4/2។

[1240] សូមមើល សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ១៥។ សំណុំរឿង ០០២/០២ សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ E465/4/1។

[1241] សំណុំរឿង ០០២/០២ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៩ ឯកសារ F50។

[1242] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ឯកសារ F1/9.1។

ប់សវនាការពីភាគីនីមួយៗ ក្នុងអំឡុងសវនាការរយៈពេលបួនថ្ងៃ ដែលបានធ្វើឡើងនៅថ្ងៃទី១៦-១៩ ខែសីហា ឆ្នាំ២០២១[1243]។

### ៥.២.៧.៤.៣. សាលដីកាបណ្តឹងសាទុក្ខ

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសសាលដីកាលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/០២ រួមជាមួយនឹងសំអាងហេតុសង្ខេប[1244]។ ក្នុងពេលធ្វើសេចក្តីព្រាងសាលដីកា ចៅក្រម Maureen Harding Clark បានលាឈប់ពីមុខតំណែង ហើយបានជំនួសដោយចៅក្រមបម្រុង Phillip Rapoza [1245]។ សាលដីកាជាលាយលក្ខណ៍អក្សរបានចេញនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២[1246]។

សាលដីកានេះចែកជាដប់ជំពូក និងមានឧបសម្ព័ន្ធចំនួនពីរ។

i. **ជំពូក១** ពិភាក្សាអំពីប្រវត្តិអង្គហេតុ និងប្រវត្តិនីតិវិធីនៃរឿងក្តី និងណែនាំអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និង សហព្រះរាជអាជ្ញា។
ii. **ជំពូក២** ពិភាក្សាអំពីបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខ។
iii. **ជំពូក៣** ពិភាក្សាអំពីរចនាសម្ព័ន្ធសារណាបណ្តឹងសាទុក្ខ និងតម្លៃនៃយុត្តិសាស្ត្ររបស់ អ.វ.ត.ក.។
iv. **ជំពូក៤** លើកឡើងអំពីមូលដ្ឋានបណ្តឹងសាទុក្ខសំខាន់របស់ ខៀវ សំផន និងការចោទប្រកាន់អំពីកំហុសនៅក្នុងការចេញ និងការប្រកាសសាលក្រម។ អង្គជំនុំជម្រះតុលាការកំពូលបានច្រានចោលទឡ្ហីករណ៍របស់ ខៀវ សំផន ដែលថាអង្គជំនុំជម្រះសាលាដំបូងមានកំហុស តាមរយៈការប្រកាសសាលក្រម និងការចេញសាលក្រមមានសំអាងហេតុពេញលេញ នៅកាលបរិច្ឆេទក្រោយ ដែលគាត់បានចោទប្រកាន់ថា បានរំលោភលើក្របខ័ណ្ឌនីតិវិធី និងបានធ្វើឱ្យសាលក្រមនោះទៅជាមោឃៈ។
v. **ជំពូក៥** លើកឡើងអំពីការចោទប្រកាន់អំពីកំហុសនៅក្នុងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ដោយបានបដិសេធការចោទប្រកាន់ដែលថា គោលការណ៍នីត្យានុកូលភាពត្រូវបានរំលោភ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តខុសចំពោះច្បាប់ស្តីពីការកែប្រែប្រភេទគតិយុត្តិនៃបទចោទ អង្គជំនុំជម្រះមានភាពលម្អៀង និងថាអង្គជំនុំជម្រះមានកំហុសនៅក្នុងសេចក្តីសម្រេចលើភស្តុតាង ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលជំនុំជម្រះ និងនៅក្នុងវិធីសាស្ត្របង្ហាញភស្តុតាងរបស់ខ្លួន។
vi. **ជំពូក៦** លើកឡើងអំពីការចោទប្រកាន់កំហុសទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួរ និងការជំនុំជម្រះ ដោយបានបដិសេធការចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការដោះស្រាយជាមួយនឹងបញ្ហាប្រឈមទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរ ក្នុងការដោះស្រាយជាមួយនឹងការចោទប្រកាន់ដែលពុំមានភស្តុតាងគាំទ្រគ្រប់គ្រាន់នៅក្នុងដីកាដំណោះស្រាយ ការចោទប្រកាន់អំពីកំហុសទាក់ទងនឹងកង្វះការកំណត់ប្រភេទគតិយុត្តិនៃអង្គហេតុសត្យានុម័ត និងអង្គហេតុដែលបានដកចេញពីសំណុំរឿង ០០២/០២ តាមរយៈការបំបែកសំណុំរឿង និងក្នុងការពឹងផ្អែកលើភស្តុតាងជាប់ពាក់ព័ន្ធនៅក្រៅវិសាលភាព។
vii. **ជំពូក៧** លើកឡើងអំពីកំហុសទាក់ទងនឹងឧក្រិដ្ឋកម្ម ជាពិសេសការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការចោទប្រកាន់ស្ទើរតែទាំងអស់របស់ ខៀវ សំផន ទាក់ទងនឹងកំហុសពាក់ព័ន្ធនឹងការធ្វើមនុស្សឃាត ដែលជាបទឧក្រិដ្ឋក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែយល់ស្របថា អង្គជំនុំជម្រះសាលាដំបូងមានកំហុស ក្នុងការសន្និដ្ឋានថា ការធ្វើមនុស្សឃាតត្រូវបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំក្រោល។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការចោទប្រកាន់របស់ ខៀវ

[1243] សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១ ឯកសារ F1/9.1។ ប្រតិចារឹក ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១ ឯកសារ F1/10.1។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២១ ឯកសារ F1/11.1។ សំណុំរឿង ០០២/០២ ប្រតិចារឹក ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២១ F1/12.1។
[1244] ប្រតិចារឹក ថ្ងៃទី ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារ F1/13.1។
[1245] ដីកាចាត់តាំងចៅក្រមបម្រុងជំនួសចៅក្រមជំនុំជម្រះ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារ F73។
[1246] សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76។

សំផន ទាក់ទងនឹងកំហុសពាក់ព័ន្ធនឹងការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស និងការធ្វើទារុណកម្ម ដែលជាបទឧក្រិដ្ឋនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានបដិសេធទឡ្ហីករណ៍ស្ទើរតែទាំងអស់របស់ ខៀវ សំផន ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញដែលជាបទឧក្រិដ្ឋកម្មក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែឯកភាពថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ការធ្វើទុក្ខបុកម្នេញលើប្រជាជនថ្មី បានកើតឡើងនៅការដ្ឋានទំនប់ ១ មករា។ អង្គជំនុំជម្រះតុលាការកំពូលក៏បានបដិសេធ ការចោទប្រកាន់របស់ ខៀវ សំផន ទាក់ទងនឹងកំហុសពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម។

viii. **ជំពូក៨** លើកឡើងអំពីការចោទប្រកាន់អំពីកំហុសទាក់ទងនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដោយបានបដិសេធការចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសទាក់ទងនឹងតួនាទីនិងមុខងាររបស់ ខៀវ សំផន និងការសន្និដ្ឋានរបស់ខ្លួនស្តីពីច្បាប់ជាធរមាននៃ JCE ការសន្និដ្ឋានរបស់ខ្លួនលើលក្ខណៈល្មើសនៃគោលបំណងរួម ការសន្និដ្ឋានរបស់ខ្លួនលើគោលនយោបាយឧក្រិដ្ឋ ការសន្និដ្ឋានរបស់ខ្លួនលើការចូលរួមចំណែករបស់ ខៀវ សំផន ទៅក្នុង JCE និងការដឹងឮ និងចេតនារបស់គាត់។ តាមការផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូលលើកឡើងកំហុសមួយ ដែលខ្លួនយល់ថាបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងបញ្ហាថាតើ JCE អាចអនុវត្តចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយ *ចេតនាមិនផ្ទាល់ (ផ្លូវច្បាប់)* ដែរឬទេ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសក្នុងការសន្និដ្ឋានថា ឧក្រិដ្ឋកម្មទាំងនោះមិនអាចបង្កើតបានជាផ្នែកមួយនៃផែនការរួមរបស់ JCE និងនៅក្នុងការសន្និដ្ឋានថា ខៀវ សំផន បានជួយ និងបានជំរុញឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ដោយមាន *ចេតនាមិនផ្ទាល់*។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ឧក្រិដ្ឋកម្មបែបនេះអាចគ្របដណ្តប់ដោយ JCE ឬត្រូវបានគ្របដណ្តប់ដោយ JCE និងថា ទម្រង់នៃការចូលរួមចំណែករបស់ ខៀវ សំផន គួរត្រូវបានកំណត់បទល្មើសឡើងវិញពីការជួយ និងការជំរុញ ទៅជាការចូលរួមចំណែកក្នុង JCE វិញ។

ix. **ជំពូក៩** លើកឡើងអំពីការប្រកាសទោស បង្ហាញអំពីច្បាប់ពាក់ព័ន្ធទៅនឹងការផ្តន្ទាទោសមេដឹកនាំជាន់ខ្ពស់ ដោយបញ្ជាក់ថា ខៀវ សំផន អនុវត្តទោសមួយជីវិតតែមួយ ចំពោះឧក្រិដ្ឋកម្មដែលជាបញ្ហាចោទនៅក្នុងសំណុំរឿង ០០២/០១ និង ០០២/០២ មិនមែនទោសមួយជីវិតពីរក្នុងពេលដំណាលគ្នាទេ ដោយពិចារណាលើការចោទប្រកាន់របស់ ខៀវ សំផន អំពីកំហុសទាក់ទងនឹងការដាក់ទោស និងដោយពិចារណាលើផលប៉ះពាល់នៃការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលលើការដាក់ទោស។

x. **ជំពូក១០** គឺជាផ្នែកសម្រេចសេចក្តី។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទជួយទំនុកបម្រុង នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយចេតនាប្រយោល នឹងសម្រេចដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទមនុស្សឃាតដោយចេតនាប្រយោល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមរយៈសហឧក្រិដ្ឋកម្មរួមវិញ បដិសេធការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទមនុស្សឃាត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅមន្ទីរសន្តិសុខភ្នំក្រោល បដិសេធការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ពីបទធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើប្រជាជនថ្មី នៅការដ្ឋានធ្វើការទំនប់ ១មករា តម្កល់ការដាក់ពិរុទ្ធភាពដែលរងការជំទាស់ផ្សេងទៀតរបស់ ខៀវ សំផន និងទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយសម្រេចដាក់ពិរុទ្ធភាពចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងបន្ថែមលើនេះ ពីបទអំពើអមនុស្សធម៌ផ្សេងៗទៀតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានចាត់ទុកថា ជាការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធទៅនឹង ជនរងគ្រោះជាបុរស។

អង្គជំនុំជម្រះតុលាការកំពូលក៏បានដាក់សេចក្តីសង្ខេបសាលដីការបស់ខ្លួនផងដែរ[1247]។

[1247] សំណុំរឿង ០០២/០២ សេចក្តីសង្ខេបសាលដីកាអង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ឯកសារ F76.1។

### ៥.២.៧.៥. ដំណាក់កាលក្រោយការផ្តន្ទាទោស

បន្ទាប់ពីភាគីបានធ្វើសារណាលើលក្ខខណ្ឌឃុំខ្លួនសមស្របរួចហើយ[1248] ខៀវ សំផន ត្រូវបានផ្ទេរទៅពន្ធនាគារខេត្តកណ្តាល នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ ដើម្បីបន្តអនុវត្តទោសជាប់ពន្ធនាគារអស់មួយជីវិតរបស់គាត់[1249]។

[1248] សូមមើល សំណុំរឿង ០០២/០២ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំព័ត៌មានពីសហព្រះរាជអាជ្ញាស្តីពីផែនការនៃលក្ខខណ្ឌឃុំខ្លួន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F77/1/1 ផ្នែក ១-២។

[1249] *សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាស្តីពីការផ្ទេរ ខៀវ សំផន ទៅពន្ធនាគារខេត្តកណ្តាល* ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣។ កត់សម្គាល់ថា សេចក្តីថ្លែងការណ៍ បានយោងមិនត្រឹមត្រូវថា ខៀវ សំផន ត្រូវអនុវត្តទោសមួយជីវិតចំនួនពីរ។ ត្រង់ចំណុចនេះ សូមមើល សំណុំរឿង ០០២/០២ សាលដីកា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២ ឯកសារ F76 កថាខណ្ឌ២០១៨-២០៣៤។

## ៥.៣. សំណុំរឿង ០០៣ និង ០០៤

### ៥.៣.១. បញ្ហាប្រឈមដែលមានពាក់ព័ន្ធនឹងសំណុំរឿង ០០៣ និង ០០៤

#### ៥.៣.១.១. បញ្ហាខ្វែងយោបល់ពាក់ព័ន្ធនឹងថាតើត្រូវបើកសំណុំរឿងបន្ថែម ឬទេ

សំណុំរឿង ០០៣ និង ០០៤ បានចាប់ផ្តើមបន្ទាប់ពីមានការខ្វែងយោបល់គ្នារវាង សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងបញ្ហាថាតើ រឿងក្តីបន្ថែមទៀត លើសពីសំណុំរឿង ០០១ និង ០០២ គួរបើកឬទេ។ នៅចុងឆ្នាំ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានបញ្ជូនបញ្ហាខ្វែងយោបល់ផ្លូវការទៅកាន់អង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅកាន់សហចៅក្រមស៊ើបអង្កេត ដើម្បីបើកសំណុំរឿង ០០៣ និង ០០៤[1250]។ ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិគាំទ្រការបើករឿងក្តីទាំងនេះក៏ដោយ ក៏សហព្រះរាជអាជ្ញាជាតិតវ៉ា ជាអាទិ៍ ថា ការបើករឿងក្តីថ្មីនេះមិនចាំបាច់នោះឡើយ ដោយសារតែអង្គហេតុ និងឧក្រិដ្ឋកម្មជាក់លាក់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី កំពុងត្រូវបានស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿង ០០២ ដែលអាចពង្រីកការស៊ើបអង្កេតរបស់ខ្លួនទៅលើជនសង្ស័យថ្មី បើទោះបីជាពួកគេមិនមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលបើករឿងក្តីនោះក៏ដោយ[1251]។

ចៅក្រមអង្គបុរេជំនុំជម្រះ មិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការ ដើម្បីសម្រេចលើការខ្វែងយោបល់គ្នា ដូច្នេះបានចេញ “សេចក្តីពិចារណា” បង្ហាញពីយោបល់របស់ពួកគេរៀងខ្លួន[1252]។ ចៅក្រមជាតិ យល់ឃើញថា ដោយសារតែការស៊ើបអង្កេតបឋមបានធ្វើឡើងជាឯកតោភាគី ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ដោយមិនមានការជូនដំណឹងដល់សហព្រះរាជអាជ្ញាជាតិ ការស៊ើបអង្កេតទាំងនោះរំលោភលើច្បាប់ អ.វ.ត.ក. កិច្ចព្រមព្រៀង និង វិធានផ្ទៃក្នុង ហើយបានពិចារណាថា មិនមានហេតុផលត្រូវបើករឿងក្តីថ្មីនោះទេ ដោយសារតែអង្គហេតុ និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ដែលជាបញ្ហាចោទនៅក្នុងសំណុំរឿង ០០៣ និង ០០៤ បានស្ថិតនៅក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ នៅក្នុងសំណុំរឿង ០០២ រួចហើយ[1253]។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិបានប្រៀបធៀបដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មី ដែលនឹងបើកសំណុំរឿង ០០៣ និង ០០៤ ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលកំពុងស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ ហើយបានពិចារណាថា ដីកាទាំងនេះមានអង្គហេតុថ្មី និងអង្គហេតុត្រួតគ្នាជាមួយនឹងអង្គហេតុដែលកំពុងស៊ើបអង្កេតក្នុងសំណុំរឿង ០០២។ ពួកគេបានពិចារណាថា ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិអាចជ្រើសរើសដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងអង្គហេតុថ្មី វាគឺជាឆន្ទានុសិទ្ធិរបស់គាត់ក្នុងការជ្រើសរើសដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីជាជាងដីការសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[1254]។

ដោយសារតែអង្គបុរេជំនុំជម្រះមិនអាចចេញសេចក្តីសម្រេចបាន សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរថ្មីនេះ ទៅសហចៅក្រមស៊ើបអង្កេត ដើម្បីបើកសំណុំរឿង ០០៣ និង ០០៤ ស្របតាមវិធាន ៧៤(១) នៃវិធានផ្ទៃក្នុង ដែលចែងថា កិច្ចរបស់សហព្រះរាជអាជ្ញាម្នាក់ត្រូវអនុវត្ត។ អតីតសហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរជាសម្ងាត់

---

[1250] សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ “សេចក្តីថ្លែងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីអង្គហេតុ និងសំអាងហេតុ សម្រាប់បញ្ហាខ្វែងយោបល់ អនុលោមតាមវិធាន ៧១(២)” នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ហើយសេចក្តីថ្លែងនេះត្រូវបានបញ្ជូនបន្តដោយការិយាល័យរដ្ឋបាលទៅកាន់ អង្គបុរេជំនុំជម្រះនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨។ សូមមើល ការខ្វែងយោបល់លេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក./អ.ប.ជ. វិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 (“សេចក្តីពិចារណា អ.ប.ជ. លើបញ្ហាខ្វែងយោបល់”)។ បញ្ហាខ្វែងយោបល់ក៏ពាក់ព័ន្ធទៅនឹងបញ្ហាថាតើត្រូវដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្នុងសំណុំរឿង ០០២ ដែរឬយ៉ាងណា។

[1251] សេចក្តីពិចារណា អ.ប.ជ. លើបញ្ហាខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ២៩។

[1252] សេចក្តីពិចារណា អ.ប.ជ. លើបញ្ហាខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 កថាខណ្ឌ ៤៤។

[1253] សេចក្តីពិចារណា អ.ប.ជ. លើបញ្ហាខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 យោបល់ចៅក្រម ប្រាក់ គឹម សាន, ន័យ ថុល និង ហួត វុទ្ធី។

[1254] សេចក្តីពិចារណា អ.ប.ជ. លើបញ្ហាខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 យោបល់ចៅក្រម Katinka Lahuis និង Rowan Downing។

ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿងដែលក្លាយជាសំណុំរឿង ០០៣[1255] និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿងដែលក្លាយជាសំណុំរឿង ០០៤[1256]។

### ៥.៣.១.២. បញ្ហាខ្វែងយោបល់ក្នុងអំឡុងពេលកិច្ចស៊ើបសួរ

បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤ បានបើក សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde បានធ្វើកំណត់ហេតុខ្វែងយោបល់ជាមួយនឹងសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ពាក់ព័ន្ធនឹងការរៀបចំផែនការពេលវេលាកិច្ចស៊ើបសួររបស់ពួកគេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានបំណងបន្តស៊ើបអង្កេតសំណុំរឿង ០០៣ និង ០០៤ ចំណែកសហចៅក្រមស៊ើបអង្កេតជាតិ មានបំណងរង់ចាំរហូតដល់បញ្ចប់ការស៊ើបអង្កេតសំណុំរឿង ០០២[1257]។ បញ្ហាខ្វែងយោបល់គ្នាត្រូវបានធ្វើកំណត់ហេតុជាសម្ងាត់ និងមិនមែនជាផ្នែកមួយនៃសំណុំរឿងក្នុងរឿងក្តីនីមួយៗដោយស្វ័យប្រវត្តិនោះទេ។ យោងតាមដីកាដំណោះស្រាយជាបន្តបន្ទាប់ ដែលបានចេញនៅក្នុងរឿងក្តីទាំងនោះ មានការខ្វែងយោបល់គ្នាចំនួនប្រាំផ្សេងទៀតត្រូវបានធ្វើកំណត់ហេតុនៅក្នុងសំណុំរឿង ០០៣[1258] និងការខ្វែងយោបល់គ្នាចំនួនប្រាំផ្សេងទៀតត្រូវបានធ្វើកំណត់ហេតុនៅក្នុងសំណុំរឿង ០០៤ (រួមបញ្ចូលទាំងរឿងក្តីបំបែករបស់វា)[1259]។ សហចៅក្រមស៊ើបអង្កេត មិនបានបញ្ជូនបញ្ហាខ្វែងយោបល់ទៅអង្គបុរេជំនុំជម្រះ ដើម្បីដោះស្រាយនោះទេ[1260]។

នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០ ចៅក្រម Siegfried Blunk ដែលជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី ជំនួសសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde ដែលបានលាឈប់ពីមុខតំណែង។ ចៅក្រម Laurent Kasper-Ansermet ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង[1261]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk បានចេញសេចក្តីប្រកាសព័ត៌មានរួមគ្នាជាមួយសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ពន្យល់

---

[1255] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

[1256] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។

[1257] *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០។

[1258] សូមមើល សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ ៥, ៧, ១៥, ២៧ យោងទៅការខ្វែងយោបល់ចំនួនប្រាំ ដែលបានចុះកំណត់ហេតុរវាងសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និង ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ ប៉ុន្តែយោងទៅការខ្វែងយោបល់ដែលចុះកំណត់ហេតុនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ដែលជាការខ្វែងយោបល់ទីបី។ មិនមានការលើកឡើងអំពីបញ្ហាខ្វែងយោបល់ក្នុងឆ្នាំ២០១០ ដែលបានចុះកំណត់ហេតុរវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde និងសហចៅក្រមស៊ើបអង្កេតជាតិនោះទេ។

[1259] សូមមើល សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 កថាខណ្ឌ ៣, ៧, ២១ យោងទៅការខ្វែងយោបល់ចំនួនប្រាំ ដែលបានចុះកំណត់ហេតុ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ និងថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩។ ចំនួននេះរួមបញ្ចូលទាំងការខ្វែងយោបល់ទាក់ទងនឹងសំណុំរឿង ០០៤ ដែលបានបំបែក។ មិនមានការលើកឡើងអំពីបញ្ហាខ្វែងយោបល់ក្នុងឆ្នាំ២០១០ ដែលបានចុះកំណត់ហេតុរវាងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde និងសហចៅក្រមស៊ើបអង្កេតជាតិនោះទេ។

[1260] សូមមើល សំណុំរឿង ០០៤ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1 យោបល់ជំទាស់របស់ចៅក្រម Maureen Harding Clark កថាខណ្ឌ ៧, ១៦ ពិភាក្សាអំពីបញ្ហាខ្វែងយោបល់នៅក្នុងសំណុំរឿង ០០៤ និងលើកឡើងថា ដូចក្នុង សំណុំរឿង ០០៣ ដែរ មិនមានការខ្វែងយោបល់ណាមួយត្រូវបានបញ្ជូនទៅ អ.ប.ជ. ទេ ប៉ុន្តែមិនលើកឡើងអំពីការខ្វែងយោបល់ក្នុងឆ្នាំ២០១០ ទេ។ សូមមើលផងដែរ សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 កថាខណ្ឌ ៤។ សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ៤។ សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៣។ សូមមើលផងដែរ វិធានផ្ទៃក្នុង វិធាន ៧២(២) ដែលចែងថា សហចៅក្រមណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ "អាច" បញ្ជូនបញ្ហាខ្វែងយោបល់ទៅអង្គបុរេជំនុំជម្រះ។

[1261] *Dr. Siegfried Blunk ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតថ្មី* ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១០។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde បានបម្រើការជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិរហូតដល់ថ្ងៃទី៣១ ខែវិច្ឆិកា ឆ្នាំ២០១០។

ថា ការងារនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ផ្តោតទៅលើការពិនិត្យ និងការវិភាគឯកសារនៅក្នុងសំណុំរឿង ជាពិសេសពីសំណុំរឿង ០០១ និង ០០២ ហើយនៅដំណាក់កាលនោះ មិនមានការស៊ើបអង្កេតតាមបណ្តាខេត្តកំពុងត្រូវបានធ្វើឡើងនោះឡើយ[1262]។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk បានលាឈប់ពីមុខតំណែង[1263] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានចាប់ផ្តើមធ្វើការបើកការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ ឡើងវិញ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមុនគាត់ និងសហចៅក្រមស៊ើបអង្កេតជាតិ បានបិទហើយនោះ ហើយក៏បានធ្វើការស៊ើបអង្កេតតាមបណ្តាខេត្តក្នុងសំណុំរឿង ០០៣ និង ០០៤[1264]។ គាត់ក៏បានជូនដំណឹងជនសង្ស័យអំពីសិទ្ធិរបស់ពួកគេផងដែរ[1265]។ សហចៅក្រមស៊ើបអង្កេតជាតិចាត់ទុកថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងមិនមានសិទ្ធិអំណាចចាប់ផ្តើមភារកិច្ចណាមួយឡើយ រហូតទាល់តែគាត់ទទួលបានការតែងតាំងជាផ្លូវការជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ពេញសិទ្ធិ)[1266]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet បានលាឈប់ពីមុខតំណែងជាផ្លូវការនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១២[1267]។ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ចៅក្រម Mark Harmon ត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី[1268]។

### ៥.៣.១.៣. សេចក្តីពិចារណាលើការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍

នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងជាសម្ងាត់ដល់ភាគី និងការិយាល័យរដ្ឋបាលថា ពួកគេកំពុងពិចារណាផ្អាកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣, ០០៤ និង ០០៤/០២ ជាអចិន្ត្រៃយ៍ ដោយសារ "សេចក្តីព្រួយបារម្ភយ៉ាងខ្លាំង [របស់ខ្លួន] អំពីការចាត់ចែងថវិកានាពេលបច្ចុប្បន្ននេះសម្រាប់ អ.វ.ត.ក. ទាំងភាគីជាតិ ទាំងភាគីអន្តរជាតិ ហើយ [ពួកគេ] យល់ឃើញថាស្ថានភាពបច្ចុប្បន្ននេះ និងចក្ខុវិស័យទៅមុខទៀត សម្រាប់ពេលឥឡូវនេះ មិនស្របតាមគោលការណ៍នៃការជំនុំជម្រះក្តីដោយយុត្តិធម៌ នីតិរដ្ឋ និងឯករាជភាពតុលាការ" នោះទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអញ្ជើញភាគី និងការិយាល័យរដ្ឋបាលឱ្យដាក់សារណាអំពីស្ថានភាពថវិការបស់ អ.វ.ត.ក.[1269]។

សារណារបស់មេធាវីការពារក្តីមកពីគ្រប់ក្រុមទាំងអស់បានគាំទ្រឱ្យផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍យ៉ាងឆាប់បំផុត ចំណែកឯសហព្រះរាជអាជ្ញាអន្តរជាតិវិញ ទោះបីជាមានការមិនពេញចិត្តទៅនឹងស្ថានភាពថវិកាដូចសហចៅក្រមស៊ើបអង្កេតដែរ យល់ឃើញថាការផ្អាកនេះគឺមិនមានមូលដ្ឋានច្បាស់លាស់ និងហួសពីអំណាចរបស់សហចៅក្រមស៊ើបអង្កេត។ ការិយាល័យរដ្ឋបាលបានផ្តល់ព័ត៌មានលម្អិត

---

1262 *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១១។

1263 *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

1264 សូមមើល សំណុំរឿង ០០៣ ដីកាសម្រេចអំពីការបើកកិច្ចស៊ើបសួរឡើងវិញ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D28។ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១២។ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២។

1265 សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D30។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D108។ សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D109។ សំណុំរឿង ០០៤/០២ សេចក្តីជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ [វិធាន ២១(១)(ឃ)] ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ D110។

1266 សំណុំរឿង ០០៣ យោបល់របស់ចៅក្រម Rowan DOWNING និងចៅក្រម Chang-Ho CHUNG នៃអង្គបុរេជំនុំជម្រះ ស្តីពីការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង១០ខែកុម្ភៈ ឆ្នាំ២០១២ យោបល់ ១០០២០១២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៧។ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១។ *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ* ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១។

1267 *សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង* ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២។ សូមមើលផងដែរ កំណត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ ផ្ញើជូនភាគីស្តីអំពីភាពមិនអាចដំណើរការបានដ៏ធ្ងន់ធ្ងរនៅ អ.វ.ត.ក. ដែលរារាំងការបំពេញកិច្ចស៊ើបសួរឲ្យបានសមស្របក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ឯកសារ D38។

1268 *ការរៀបចំដំណើរមកដល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២។

1269 សំណុំរឿង ០០៤ សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D349។

អំពីថវិកា និងការវិវឌ្ឍផ្នែកមូលនិធិ និងវឌ្ឍនភាពបច្ចុប្បន្ន (នាពេលនោះ) នៃមូលនិធិស្ម័គ្រចិត្ត ដែលត្រូវបានគេនិយាយថា បានបិទគម្លាតមូលនិធិពីមុនមកត្រឹមជាងពីរលានដុល្លារអាមេរិក។ អ.ស.ប. រដ្ឋសមាជិកនៃក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ និងអ្នកជំនាញពិសេសរបស់អគ្គលេខាធិការ អ.ស.ប. ក៏បានដាក់សារណាផ្តោតលើអំណះអំណាងថា អាណត្តិរបស់សហចៅក្រមស៊ើបអង្កេត មិនគ្របដណ្តប់លើការធ្វើសេចក្តីសម្រេចលើផ្នែកហិរញ្ញវត្ថុ ដែលទាក់ទងទៅនឹងថវិកា និងការផ្តល់ថវិការបស់ អ.វ.ត.ក. ទេ និងថា សហចៅក្រមស៊ើបអង្កេតគួរតែផ្តោតលើការបំពេញកិច្ចស៊ើបសួរ និងការសម្រេចលើរឿងក្តីដោយផ្អែកលើអង្គច្បាប់[1270]។

នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីសម្រេចមួយលើផលប៉ះពាល់នៃស្ថានភាពថវិកា ដោយពន្យារពេលចេញសេចក្តីសម្រេចស្តីពីការផ្អាកកិច្ចដំណើរការនីតិវិធី ប៉ុន្តែនៅតែពិនិត្យមើលបញ្ហានេះយ៉ាងសកម្ម រហូតដល់ពេលពួកគេចេញដីកាដំណោះស្រាយ ហើយបានអញ្ជើញការិយាល័យរដ្ឋបាលធ្វើសេចក្តីរាយការណ៍អំពីការផ្តល់ថវិកា យ៉ាងហោចណាស់រៀងរាល់មួយត្រីមាសម្តង[1271]។

## ៥.៣.១.៤. បញ្ហាខ្វែងយោបល់ពាក់ព័ន្ធនឹងបញ្ហាថាតើរឿងក្តីនឹងបន្តទៅជំនុំជម្រះ ឬទេ

ដូចឃើញខាងក្រោមនេះ លើកលែងតែពាក់ព័ន្ធនឹង អ៊ឹម ចែម ដែលសហចៅក្រមស៊ើបអង្កេតបានព្រមព្រៀងគ្នាថាមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. សហចៅក្រមស៊ើបអង្កេតមានការខ្វែងយោបល់គ្នាលើបញ្ហាថាតើរឿងក្តីគួរត្រូវបន្តទៅជំនុំជម្រះ ឬយ៉ាងណា ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា រឿងក្តីគួរត្រូវបន្ត ដោយសារតែមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា បុគ្គលដែលស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. បានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ចំណែកសហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា រឿងក្តីមិនគួរបន្តទៅជំនុំជម្រះទេ ដោយសារតែលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការបុគ្គលមិនត្រូវបានបំពេញ។ ជាលទ្ធផលនៃការខ្វែងយោបល់គ្នារបស់ពួកគេនេះ ពួកគេបានចេញដីកាដំណោះស្រាយពីរខ្វែងគ្នា ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយសហចៅក្រមស៊ើបអង្កេតជាតិចេញដីកាសម្រេចលើកលែងចោទប្រកាន់។ ការណ៍នេះបាននាំឱ្យមានបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍ខ្វែងគ្នាជាច្រើនត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចលើកលែងចោទប្រកាន់ ដែលអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនលើសលប់ លើបញ្ហាចុងក្រោយដែលបានលើកឡើងដោយបណ្តឹងឧទ្ធរណ៍ ទាក់ទងនឹងបញ្ហាថាតើរឿងក្តីគួរត្រូវបន្តទៅជំនុំជម្រះ ឬយ៉ាងណា ដែលនាំឱ្យមានភាពច្របូកច្របល់ផ្នែកនីតិវិធី ដែលជាលទ្ធផលនាំឱ្យមានការបញ្ចប់រឿងក្តីទាំងនេះ។

## ៥.៣.២. សំណុំរឿង ០០៣

## ៥.៣.២.១. ទិដ្ឋភាពទូទៅអំពីជនសង្ស័យ

សំណុំរឿង ០០៣ ពាក់ព័ន្ធនឹងជនសង្ស័យពីរនាក់។

- **ស៊ូ ម៉េត**៖ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ ស៊ូ ម៉េត គឺជាលេខាកងពល ៥០២ នៃកងទ័ពបដិវត្តន៍កម្ពុជា និងជាមេបញ្ជាការកងទ័ពជើងអាកាសនៃកងទ័ពបដិវត្តន៍កម្ពុជា ពីខែមិថុនា ឆ្នាំ ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ និងជាសមាជិកគណៈកម្មាធិការជំនួយគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក. ដែលត្រូវបានចាត់ទុកថាជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលមានឋានៈខ្ពស់បំផុត

[1270] សំណុំរឿង ០០៤ ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D349/6 កថាខណ្ឌ ៥-៧។

[1271] សំណុំរឿង ០០៤ ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D349/6 កថាខណ្ឌ ៦៩-៧០។

នៅក្នុងឋានានុក្រម ប.ក.ក. ដែលមានឥទ្ធិពលខ្លាំងនៅក្នុងអគ្គសេនាធិការ ដែលជាស្ថាប័នខ្ពស់បំផុតរបស់កងទ័ពបដិវត្តន៍កម្ពុជា[1272]។

នៅក្នុងកិច្ចដំណើរការនីតិវិធីដោយឡែក អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ យល់ឃើញថា មានភ័ស្តុតាងបញ្ជាក់ថា ស៊ូ ម៉េត គឺជាសមាជិកអគ្គសេនាធិការ និងជាមេបញ្ជាការកងពល ៥០២ (កងទ័ពជើងអាកាស)[1273]។

- **មាស មុត**៖ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ មាស មុត គឺជាលេខាកងពល ១៦៤ នៃកងទ័ពបដិវត្តន៍កម្ពុជា និងជាមេបញ្ជាការកងទ័ពជើងទឹកនៃកងទ័ពបដិវត្តន៍កម្ពុជា ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ និងជាសមាជិកគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក. ឬជាសមាជិកនៃគណៈកម្មាធិការជំនួយនៃគណៈកម្មាធិការមជ្ឈិម ដែលបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពលើក្រុងកំពង់សោម និងតំបន់ជុំវិញ និងបណ្តាកោះរបស់កម្ពុជា[1274]។

  នៅក្នុងកិច្ចដំណើរការនីតិវិធីដោយឡែក អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ យល់ឃើញថា មានភ័ស្តុតាងបញ្ជាក់ថា មាស មុត គឺជាមេបញ្ជាការកងពល ១៦៤ (កងទ័ពជើងទឹក) និងជាសមាជិកនៃអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា[1275]។

### ៥.៣.២.២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ បានចោទថា ស៊ូ ម៉េត និង មាស មុត បានចូលរួមក្នុងផែនការឧក្រិដ្ឋ ដើម្បីបោសសម្អាតសមាសភាពមិនល្អរបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលជាលទ្ធផលនាំឱ្យមានការស្លាប់យ៉ាងហោចណាស់រាប់ពាន់នាក់ និងឧក្រិដ្ឋកម្មនានាមានដូចជា ពលកម្មដោយបង្ខំ លក្ខខណ្ឌរស់នៅអមនុស្សធម៌ ការចាប់និងឃុំខ្លួនមិនស្របច្បាប់ ការធ្វើទុក្ខបុកម្នេញផ្នែករាងកាយ និងសតិបញ្ញា ការធ្វើទារុណកម្ម និងការសម្លាប់[1276]។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានកំណត់ប្រភេទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មមនុស្សឃាត និងការធ្វើទារុណកម្មយោងតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[1277]។

### ៥.៣.២.៣. កិច្ចស៊ើបសួរតាមផ្លូវតុលាការ

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើសំណុំរឿង ០០៣ ដែលបានបើកសំណុំរឿងនេះ[1278]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចៅក្រម Marcel Lemonde បានចេញដីកាចាត់ឱ្យស៊ើបសួរជំនួស ចាត់តាំងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឱ្យធ្វើការស៊ើបអង្កេតនៅតាមបណ្តាខេត្ត។ អនុលោមតាមដីកាចាត់ឱ្យស៊ើបសួរជំនួសនេះ អ្នកស៊ើបអង្កេតបានស្តាប់ចម្លើយសាក្សី ១៧ នាក់ ចន្លោះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០ ដល់ថ្ងៃ

---

[1272] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 កថាខណ្ឌ ២។

[1273] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ E465 កថាខណ្ឌ ៣៨០, ៤២៨, ៤៣៨។ ដោយសារតែមរណភាពរបស់គាត់មុន ស៊ូ ម៉េត មិនអាចតតាំងនឹងការរកឃើញនៅក្នុងសំណុំរឿង ០០២/០២ ទេ។ ពុំមានការកំណត់ដោយតុលាការអំពីមុខតំណែងរបស់ ស៊ូ ម៉េត អាចធ្វើទៅបានទេក្នុងសំណុំរឿង ០០៣ ដោយសាររឿងក្តីមិនត្រូវបានបើកសវនាការជំនុំជម្រះ។

[1274] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 កថាខណ្ឌ ៣។

[1275] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ E465 កថាខណ្ឌ ៣៨៦-៣៨៧, ៤២៨, ៤៣៣។ ដោយសារគាត់មិនមែនជាភាគីនៃកិច្ចដំណើរការនីតិវិធី មាស មុត មិនអាចតតាំងនឹងការរកឃើញនេះនៅក្នុងសំណុំរឿង ០០២/០២ បានទេ។ ពុំមានការកំណត់ដោយតុលាការអំពីមុខតំណែងរបស់ មាស មុត អាចធ្វើទៅបានទេក្នុងសំណុំរឿង ០០៣ ដោយសាររឿងក្តីមិនត្រូវបានបើកសវនាការជំនុំជម្រះ។

[1276] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 កថាខណ្ឌ ៤។

[1277] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1 កថាខណ្ឌ ៩។

[1278] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង “សេចក្តីសម្រេចស្តីពីសំណើសុំពន្យាពេលកំណត់ នឹងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣” ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D20/4/2.1 កថាខណ្ឌ ៣។

ទី២ ខែធ្នូ ឆ្នាំ២០១០ ទោះជាយ៉ាងណាកំណត់ហេតុស្តាប់ចម្លើយទាំងនេះមិនត្រូវបានដាក់ក្នុងសំណុំរឿង ឬជូនដំណឹងទៅកាន់ភាគីទេ រហូតដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១[1279]។

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried Blunk បានចេញសេចក្តីជូនដំណឹងបិទបញ្ចប់កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ដោយបានចេញសេចក្តីប្រកាសព័ត៌មាននៅថ្ងៃជាមួយគ្នានោះថា សំណុំរឿងនេះមានភស្តុតាងប្រមាណជាង ២០០០ កម្រាស់ជាង ៤៨.០០០ ទំព័រ[1280]។ យ៉ាងណាមិញ បន្ទាប់ពីការលាឈប់ពីមុខតំណែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet[1281] និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon[1282] យល់ឃើញថាតម្រូវឱ្យមានការស៊ើបអង្កេតបន្ថែម ហើយបានបន្តការស៊ើបអង្កេតលើរឿងក្តីនេះ។

សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងការចោទប្រកាន់ថ្មីប្រឆាំងនឹង មាស មុត នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤[1283] ហើយនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon បានដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ពីបទ មនុស្សឃាត ទារុណកម្ម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ[1284]។

មាស មុត ត្រូវបានកោះហៅសម្រាប់ការបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael Bohlander ដែលបានមោឃៈការចោទប្រកាន់មួយចំនួនធ្វើឡើងដោយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon និងបានបន្ថែមការចោទប្រកាន់អំពីអំពើប្រល័យពូជសាសន៍ ព្រមទាំងបទចោទបន្ថែមទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មជាតិ[1285]។

នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានជូនដំណឹងភាគីថា កិច្ចស៊ើបសួរប្រឆាំងនឹង មាស មុត[1286] បានបិទបញ្ចប់ហើយ ហើយភាគីមានពេល ៣០ថ្ងៃ ដើម្បីដាក់សំណើណាមួយសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម[1287]។ គាត់ក៏បានកាត់បន្ថយវិសាលភាពស៊ើបអង្កេតផងដែរ ដោយដកចេញការចោទប្រកាន់ទាំងអស់ទាក់ទងនឹង មន្ទីរសន្តិសុខ ស-២២ ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ទីតាំងសម្លាប់មនុស្សស្ទឹងតូច និងការចូលរួមរបស់កងទ័ពបដិវត្តន៍កម្ពុជាក្នុងការបោសសម្អាតភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា លើកលែងតែការបោសសម្អាតសមាជិកនៃអង្គភាពកងទ័ពបដិវត្តន៍នៅក្នុងតំបន់ទាំងអស់នេះ[1288]។

---

[1279] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង “សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣” ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១១ ឯកសារ D26/1/1 កថាខណ្ឌ ៤។

[1280] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ឯកសារ D13។ *សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត* ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១។

[1281] សំណុំរឿង ០០៣ ដីកាសម្រេចអំពីការបើកកិច្ចស៊ើបសួរឡើងវិញ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ឯកសារ D28។

[1282] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ ៤-៥។

[1283] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ឯកសារ D120។

[1284] សំណុំរឿង ០០៣ ដីកាសម្រេចដាក់ មាស មុត ឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D128.1។

[1285] សំណុំរឿង ០០៣ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D174។

[1286] កិច្ចស៊ើបសួរប្រឆាំងនឹង ស៊ូ ម៉េត ត្រូវបានរលត់ត្រឹមពេលនេះ ដោយសារមរណភាពរបស់គាត់។ សូមមើល ជំពូក ៥.៣.២.៤.។

[1287] សំណុំរឿង ០០៣ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំងនឹង មាស មុត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D225។

[1288] សំណុំរឿង ០០៣ សេចក្តីសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ ឯកសារ D226។

បន្ទាប់ពីការដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម និងការពិចារណាលើសំណើទាំងនេះ[1289] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញសេចក្តីជូនដំណឹងលើកទីពីរស្តីពីការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង មាស មុត នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧[1290]។

### ៥.៣.២.៤. មរណភាពរបស់ ស៊្វ ម៉េត

ស៊្វ ម៉េត បានទទួលមរណភាពនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ខណៈពេលគាត់ជាជនសង្ស័យស្ថិតក្រោមការស៊ើបអង្កេតតាមផ្លូវតុលាការ។ សហចៅក្រមស៊ើបអង្កេតបានស្វែងរក និងបានទទួលលិខិតមរណភាព និងខ្សែវីដេអូបុណ្យសពរបស់ ស៊្វ ម៉េត។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងភាគីថា ស៊្វ ម៉េត បានទទួលមរណភាព ហើយនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ បានជូនដំណឹងថាបណ្តឹងអាជ្ញាប្រឆាំងនឹង ស៊្វ ម៉េត បានរលត់[1291]។ ចំណុចនេះបានបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ប្រឆាំងនឹង ស៊្វ ម៉េត។

### ៥.៣.២.៥. បញ្ហាពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ក្នុងអំឡុងពេលកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអញ្ជើញភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ ដាក់សារណា និង "បុគ្គល ឬអង្គការដែលមានគុណវុឌ្ឍិ សូមដាក់សារណាមិនមែនជាភាគី" លើបញ្ហាថាតើ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាន ក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. "ការវាយប្រហាររបស់រដ្ឋ ឬអង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ*ផ្ទាល់ខ្លួន* អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិលបើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក."។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកត់សម្គាល់ថា៖

> អាចមានទឡ្ហីករណ៍ថា តាំងពីដើមដំបូងមកម្ល៉េះ ការពិភាក្សាពីមុនអំពីការបកស្រាយទស្សនាទាននេះប្រហែលជាអាចមើលរំលងផ្នែកគោលការណ៍សមហេតុផលដ៏សាមញ្ញ គឺថា យុទ្ធជន និងជនស៊ីវិល អាចមានអត្ថន័យខុសគ្នាទាំងស្រុង តែក្នុងករណីដែលយើងនិយាយអំពីយុទ្ធជន និងជនស៊ីវិលរបស់ *ខ្មាំង* តែប៉ុណ្ណោះ។ ខ្ញុំបានសម្រេចរួចហើយលើបញ្ហាចម្រូងចម្រាសអំពីភាពពាក់ព័ន្ធគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាមួយនឹងជម្លោះប្រដាប់អាវុធ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក.។ ដោយទុកបញ្ហានេះមួយឡែក គេក៏អាចផ្តល់ទឡ្ហីករណ៍ថែមទៀតថា៖ ក) ហាក់ដូចជាគ្មានការជំទាស់ទេថា របបណាមួយក្នុងគ្រាមានសន្តិភាព បានព្យាយាមបោសសម្អាតកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន ដូចជា ទាហានដែលមានជាតិពន្ធុ ឬជំនឿណាមួយនោះ គឺជារបបដែលបានប្រព្រឹត្តបទល្មើសផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទម្លាប់អន្តរជាតិ ពីព្រោះថា លក្ខណៈសម្បត្តិជាយុទ្ធជនរបស់ជនរងគ្រោះដោយសារពួកគាត់ជាទាហាននោះ គឺមិនជាប់ពាក់ព័ន្ធទាល់តែសោះនៅក្នុងបរិបទនេះ និង ខ) គ្មានមូលហេតុត្រូវគិតផ្ទុយទីនេះទេ ប្រសិនបើយុទ្ធនាការបោសសម្អាតបែបនេះបានកើតឡើងនៅក្នុងពេលមានជម្លោះប្រដាប់អាវុធ ឬក៏ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ[1292]។

---

[1289] សំណុំរឿង ០០៣ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ ឯកសារ D233/2។ សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរ ដើម្បីដាក់សម្ភារៈទៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧ ឯកសារ D234/2។ សំណុំរឿង ០០៣ សេចក្តីសម្រេចរួមលើសំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងការប្រើប្រាស់ជាសក្តានុពលនៃភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D251។

[1290] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 កថាខណ្ឌ ១៦។

[1291] សំណុំរឿង ០០៣ ការលើកលែងការចោទប្រកាន់ប្រឆាំង ស៊្វ ម៉េត ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ D86/3។

[1292] សំណុំរឿង ០០៣ សេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ឯកសារ D191 កថាខណ្ឌ ៣, ៥, ៧។

សហចៅក្រមបានទទួលសារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដីចំនួនដប់មួយ[1293] ក៏ដូចជាសារណាពីសហព្រះរាជអាជ្ញាអន្តរជាតិ និងក្រុមមេធាវីការពារក្ដី មាស មុត, អោ អាន និង យឹម ទិត្យ[1294]។ ក្រុមមេធាវីការពារក្ដីយល់ឃើញថា ការវាយប្រហាររបស់រដ្ឋ ឬអង្គការ ប្រឆាំងនឹងសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន មិនអាចមានតម្លៃស្មើទៅនឹងការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលទេ។

ចម្លើយតបដែលនៅសល់ត្រូវបានបែងចែកជាបីប្រភេទ៖ (១) អ្នកដែលចាត់ទុកថាការវាយប្រហារប្រឆាំងនឹងសមាជិកកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចមានតម្លៃស្មើទៅនឹងការវាយប្រហារសំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល (២) អ្នកដែលយល់ឃើញថា មានតែក្នុងពេលសន្តិភាពប៉ុណ្ណោះ ដែលសមាជិកនៃកងកម្លាំងប្រដាប់អាវុធ អាចជាគោលដៅតែមួយគត់នៃការវាយប្រហារ ដែល បើមិនដូច្នោះទេ បំពេញតាមលក្ខខណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង (៣) អ្នកដែលយល់ឃើញថា មានតែពេលដែលឧក្រិដ្ឋកម្មជាមូលដ្ឋានគឺជាការធ្វើទុក្ខបុកម្នេញ ទើបការវាយប្រហារលើកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ឬអង្គការ អាចជាការវាយប្រហារលើប្រជាជនស៊ីវិល។

ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា ជាគោលការណ៍សំខាន់ ការវាយប្រហាររបស់រដ្ឋ ឬអង្គការ ប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចមានតម្លៃស្មើទៅនឹងការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ប៉ុន្តែគាត់យល់ឃើញថា ចំណុចនេះ *មិន*អនុវត្តក្នុងកម្រិតដែលថាកងកម្លាំងប្រដាប់អាវុធដែលរងការវាយប្រហារនោះ មានសម្ព័ន្ធភាពជាមួយ ឬបើមិនដូច្នោះទេ គាំទ្រភាគីបដិបក្ខទៅនឹងជម្លោះប្រដាប់អាវុធនោះទេ[1295]។ អង្គជំនុំជម្រះសាលា

[1293] សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ក្នុងសំណុំរឿង ០០៣ និង ០០៤ – សាស្ត្រាចារ្យ Ben Saul ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/3។ សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ក្នុងសំណុំរឿង ០០៣ និង ០០៤ – Catherine Drummond, Philippa Webb និង Dapo Akande ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/4។ សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ក្នុងសំណុំរឿង ០០៣ និង ០០៤ –TRIAL (តាមដាននិទណ្ឌភាពជានិច្ច) ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/5។ សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ដោយសាស្ត្រាចារ្យ Robinson, De Guzman, Jalloh និង Cryer ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សម្រាប់សំណុំរឿង ០០៣ និង ០០៤ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/6។ សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ក្នុងសំណុំរឿង ០០៣ និង ០០៤ – Ido Rosenzweig ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/7។ សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ក្នុងសំណុំរឿង ០០៣ និង ០០៤ – Dr Joanna Nicholson ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/8។ សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ក្នុងសំណុំរឿង ០០៣ និង ០០៤ – Professor Nicholas Tsagourias ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/9; សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ក្នុងសំណុំរឿង ០០៣ និង ០០៤ – Oliver Windridge ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/10; សំណុំរឿង ០០៣ សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី ដាក់ដោយ Drs Williams និង Grey ជាការឆ្លើយតបទៅនឹងសេចក្ដីអំពាវនាវសុំឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ឯកសារ D191/11។ សំណុំរឿង ០០៣ សារណាមិនមែនជាភាគីដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀបមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore ស្ដីពីនីត្យានុកូលភាពនៃការ ដាក់គោលដៅវាយប្រហារយោធាខ្លួនឯង ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/12។ សំណុំរឿង ០០៣ ចម្លើយតបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Queen's University Belfast ទៅនឹង "ការអំពាវនាវឲ្យដាក់សារណាពីភាគីនៃសំណុំរឿង ០០៣ និង ០០៤ និងការអំពាវនាវឲ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដី" របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/13។

[1294] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្ដីអំពាវនាវឲ្យដាក់សារណារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/1។ សំណុំរឿង ០០៣ សារណារបស់ មាស មុត ស្ដីពីសំណួរថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬ អង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃ ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក. ឬយ៉ាងណា ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D191/2; សំណុំរឿង ០០៣ សារណារបស់ អោ អាន ស្ដីពីបញ្ហាថា តើការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាចត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬយ៉ាងណា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់១៩៧៩ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D306/3។ សំណុំរឿង ០០៣ សារណារបស់ យឹម ទិត្យ ស្ដីពីការបកស្រាយវាក្យស័ព្ទ “ប្រជាជនស៊ីវិល” តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ឯកសារ D306/1។

[1295] សំណុំរឿង ០០៣ ការជូនដំណឹងស្ដីពីការបកស្រាយ “ការវាយប្រហារទៅលើប្រជាជនស៊ីវិល” នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់ របស់របប ឬរដ្ឋនោះ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D191/18 កថាខណ្ឌ ៦៩។

ដំបូងធ្វើការសន្និដ្ឋានផ្ទុយពីនេះក្នុងសំណុំរឿង ០០២/០២ ដោយបានកត់សម្គាល់ថា “ក្រៅពីការយោងទៅសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ [...]ទោះបីជាការបកស្រាយអំពីការការពារដែលត្រូវបានអនុញ្ញាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមបញ្ចូលទាំងកងកម្លាំងប្រដាប់អាវុធក្នុងស្រុក អាចចាត់ទុកថាជាការប្រសើរក្តី ប៉ុន្តែមិនមានភាពច្បាស់លាស់ដែលថា ក្របខណ្ឌគតិយុត្តិដែលផ្តល់នូវការការពារបែបនេះ អាចប្រមើលឃើញ ឬអាចដឹងជាមុនថាមានច្បាប់ចែងនោះឡើយ នៅត្រឹមឆ្នាំ១៩៧៥”[1296]
។

## ៥.៣.២.៦. ដីកាសន្និដ្ឋានស្ថាពរ

បន្ទាប់ពីបិទបញ្ចប់កិច្ចស៊ើបសួរ សំណុំរឿងត្រូវបានបញ្ជូនទៅសហព្រះរាជអាជ្ញាពិនិត្យ ដើម្បីរៀបចំដីកាសន្និដ្ឋានស្ថាពរ។ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំឱ្យលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង មាស មុត ដោយផ្អែកលើមូលដ្ឋានដែលថា គាត់មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.[1297]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែក ស្នើសុំឱ្យបញ្ជូនខ្លួន មាស មុត ទៅជំនុំជម្រះចំពោះបទចោទដែលរៀបរាប់នៅក្នុងដីកាសន្និដ្ឋានស្ថាពរនោះ[1298]។

## ៥.៣.២.៧. ដីកាដំណោះស្រាយ

សហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ បានចេញដីកាដំណោះស្រាយផ្ទុយគ្នារៀងខ្លួន។ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់រឿងក្តីនេះ[1299]។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ពិភាក្សាអំពីប្រវត្តិ ប.ក.ក. និងរចនាសម្ព័ន្ធរដ្ឋបាល[1300] រចនាសម្ព័ន្ធយោធា[1301] គោលនយោបាយរបស់ ប.ក.ក. ក្នុងការបោសសម្អាតក្នុងជួរកងទ័ព[1302] និងតួនាទីរបស់ មាស មុត និងការចូលរួមក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[1303]។ ដីកានេះក៏ពិភាក្សាអំពីការពិចារណាលើភ័ស្តុតាង[1304] ដោយបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតជាតិយោងតែទៅលើសម្ភារៈដែលបានដាក់ក្នុងសំណុំរឿង មុនថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ប៉ុណ្ណោះ ជាពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried Blunk បានយល់ព្រមបិទបញ្ចប់ការស៊ើបអង្កេត[1305]។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណាលើលក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គល[1306] និងជាចុងក្រោយយល់ឃើញថា ការចូលរួមរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មមិនសកម្ម និងមិនកៀកកិតនឹងការប្រព្រឹត្តបទឧក្រិដ្ឋ[1307]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតជាតិសន្និដ្ឋានថា អ.វ.ត.ក. មិនមានយុត្តាធិការកាត់ទោស មាស មុត ហើយសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់[1308]។

---

[1296] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ E465 កថាខណ្ឌ ៣០៩។
[1297] សូមមើល សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី មាស មុត អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/6។
[1298] សំណុំរឿង ០០៣ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D256/7។
[1299] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។
[1300] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ជំពូក៣ ផ្នែក ក និង ខ។
[1301] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ជំពូក ៣ ផ្នែក ៣។
[1302] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ជំពូក ៣ ផ្នែក ៤។
[1303] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ជំពូក ៣ ផ្នែក ៥។
[1304] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ជំពូក ៤។
[1305] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 កថាខណ្ឌ ៣៥៩។
[1306] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ជំពូក ៥។
[1307] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 ជំពូក ៦។
[1308] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266 កថាខណ្ឌ ៤២៩-៤៣០។

ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិភាក្សាអំពីច្បាប់ជាធរមាន រួមបញ្ចូលទាំងយុត្តាធិការបុគ្គលនៅ អ.វ.ត.ក.[1309] ការពិចារណាលើភ័ស្តុតាង[1310] ការវិភាគអង្គហេតុ និងសំអាងហេតុ[1311] ការយល់ឃើញផ្នែកច្បាប់ស្តីពីយុត្តាធិការបុគ្គល[1312] សំអាងច្បាប់ស្តីពីឧក្រិដ្ឋកម្ម[1313] សំអាងច្បាប់ស្តីពីទម្រង់នៃការទទួលខុសត្រូវ[1314] និងភាពចាំបាច់នៃការឃុំខ្លួនមុនការជំនុំជម្រះ[1315] មុនពេលបញ្ចប់កិច្ចស៊ើបសួរពាក់ព័ន្ធនឹងអង្គហេតុ ដែលគាត់បានដកចេញពីការស៊ើបអង្កេតពីមុន និងការលើកលែងការចោទប្រកាន់ដោយផ្នែក[1316]។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ មាស មុត បញ្ជូនទៅជំនុំជម្រះពីបទ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[1317]។

### ៥.៣.២.៨. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

នៅក្នុងការស៊ើបអង្កេតនៃសំណុំរឿង ០០៣ ទាំងមូល មនុស្សចំនួន ៦៤៦ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[1318]។ នៅក្នុងរយៈពេលនៃការស៊ើបអង្កេត អ្នកដាក់ពាក្យ ១៨ នាក់ បានទទួលមរណភាព និងពីរនាក់បានដកពាក្យវិញ[1319]។

នៅថ្ងៃចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត បានចេញដីកាពីរដាច់ដោយឡែកពីគ្នាស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហចៅក្រមស៊ើបអង្កេតជាតិ បានច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង ៦៤២ ដែលបានដាក់ក្នុងសំណុំរឿង ០០៣ ក្រោយថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១១ នេះគឺជាកាលបរិច្ឆេទដែលគាត់ចាត់ទុកថាជាកាលបរិច្ឆេទកំណត់ សម្រាប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (បន្ទាប់ពីបិទបញ្ចប់ការស៊ើបអង្កេត នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១)[1320] ចំណែកសហចៅក្រមស៊ើបអង្កេតអន្តរជាតិវិញ បានពិនិត្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលើអង្គសេចក្តី និងបានប្រកាសថា ពាក្យសុំមួយចំនួនអាចទទួលយកបាន ហើយមួយចំនួនទៀតមិនអាចទទួលយកបាន[1321]។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្តឹងឧទ្ធរណ៍

[1309] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ៣។

[1310] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ៤។

[1311] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ៥។

[1312] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ៦។

[1313] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ៧។

[1314] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ៨។

[1315] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ៩។

[1316] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១០-១១។

[1317] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267 ជំពូក ១២។

[1318] សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269។

[1319] សំណុំរឿង ០០៣ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 កថាខណ្ឌ ៦, ៧។

[1320] សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D268.

[1321] សំណុំរឿង ០០៣ ដីកាសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D269.

ប្រឆាំងនឹងការជំទាស់របស់គាត់លើពាក្យសុំរបស់ពួកគេ[1322] ប៉ុន្តែចៅក្រមអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនដែលត្រូវការ ដើម្បីសម្រេចលើបណ្ដឹងឧទ្ធរណ៍នេះបាន[1323] ដោយទុកឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមិនមានចម្លើយច្បាស់លាស់អំពីឋានៈរបស់ខ្លួន។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានលើកឡើងថា ខ្លួនបានសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៣ ដោយសារពួកគាត់យល់ឃើញថា ដីកាដំណោះស្រាយទាំងពីរមានតម្លៃដូចគ្នា និងយល់ឃើញថាសំណុំរឿង ០០៣ គប្បីត្រូវតម្កល់ទុកក្នុងបណ្ណសារ ចំណែកចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះវិញ បានលើកឡើងថា ខ្លួនបានបដិសេធដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយផ្នែកដោយទទួលយកអ្នកដាក់ពាក្យប្រាំនាក់ ក្នុងចំណោមអ្នកដាក់ពាក្យដែលត្រូវបានបដិសេធ[1324]។

## ៥.៣.២.៩. បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

បន្ទាប់ពីកាចេញដីកាដំណោះស្រាយរួចមក សហព្រះរាជអាជ្ញាជាតិ[1325] និង មាស មុត[1326] បានប្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ មាស មុត បានលើកយកមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ចំនួនពីរ ពោលគឺ៖ (i) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ តាមរយៈការបកស្រាយថា វិធាន ៧៧(១៣) តម្រូវឱ្យដីកាដំណោះស្រាយទាំងពីរ ឬមានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះមានអានុភាពអនុវត្ត ប្រសិនបើអង្គបុរេជំនុំជម្រះមិនតម្កល់ដីកាណាមួយក្នុងចំណោមដីកាទាំងពីរ ដោយសំឡេងភាគច្រើនលើសលប់ និង (ii)ករណីអវត្តមានកំហុស ឬការរំលោភបំពានដែលជាកត្តាកំណត់ជាមូលដ្ឋានដោយសហចៅក្រមស៊ើបអង្កេតជាតិ ក្នុងការចេញដីកាសម្រេចលើកលែងចោទប្រកាន់របស់គាត់ ដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវតែមានអានុភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមតាមការអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ*។

សហព្រះរាជអាជ្ញាអន្តរជាតិបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ដោយជំទាស់ទៅនឹងភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍របស់ មាស មុត និងបានឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ ដោយលើកឡើងអំពីកំហុសអង្គហេតុ និងអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតជាតិ[1327]។

---

[1322] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាកក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ឯកសារ D269/3។

[1323] សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាកក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4។

[1324] សំណុំរឿង ០០៣ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាកក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D269/4 កថាខណ្ឌ ៤៤-៤៦, ១១១។

[1325] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3។

[1326] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4។ សូមមើលផងដែរ សំណុំរឿង ០០៣ ចម្លើយតបរបស់ មាស មុត ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាលើកលែងចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D266/5។ ចម្លើយតបរបស់មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ឯកសារ D267/12។ សំណុំរឿង ០០៣ សារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ឯកសារ D267/27។

[1327] សំណុំរឿង ០០៣ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងទៅនឹង ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2។ សូមមើលផងដែរ សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/9។ សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (D267) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D267/10។ សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងចម្លើយរបស់ មាស មុត ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ មាស មុត (D266) ចុះថ្ងៃទី៩ ខែសីហាឆ្នាំ២០១៩ D267/11។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសារណាបន្ថែមរបស់ មាស មុត ទៅលើបណ្ដឹងឧទ្ធរណ៍របស់ខ្លួន ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១០ ឯកសារ D267/29។

សវនាការស្តាប់អំណះអំណាងផ្ទាល់មាត់បានធ្វើឡើងពីថ្ងៃទី២៧ ដល់ ២៩ ខែវិច្ឆិកា ឆ្នាំ២០១៩[1328]។ អង្គបុរេជំនុំជម្រះបានចេញរបាយការណ៍សាធារណៈមួយស្តីពីសំណុំរឿង និងបណ្តឹងឧទ្ធរណ៍[1329]។

### ៥.៣.២.១០. សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

អង្គបុរេជំនុំជម្រះបានសម្រេចបញ្ចូលកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍ ហើយពិចារណាលើបណ្តឹងឧទ្ធរណ៍ទាំងបីនោះរួមគ្នា[1330]។ អង្គបុរេបានសម្រេចថា បណ្តឹងឧទ្ធរណ៍របស់ មាស មុត មិនអាចទទួលយកបាន[1331]។

អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ តាមរយៈការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ដោយមិនបានបញ្ជូនបញ្ហាខ្វែងយោបល់គ្នារបស់ខ្លួន លើបញ្ហានោះទៅអង្គបុរេជំនុំជម្រះ ឬបានអនុវត្តតាមគោលជំហរស្វ័យប្រវត្តិ ដែលថាកិច្ចដំណើរការនីតិវិធីត្រូវបន្តទៅមុខ[1332]។ អង្គបុរេបានពិចារណាថា សហចៅក្រមស៊ើបអង្កេត "បានសម្រេច [...] គេចវេសពី" យន្តការដែលផ្តល់ឱ្យអង្គបុរេជំនុំជម្រះ ដោះស្រាយបញ្ហាខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេត[1333]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត "បានរំលោភបំពានទៅលើមូលដ្ឋានស្នូល នៃប្រព័ន្ធច្បាប់ អ.វ.ត.ក."[1334] និងថា អត្ថបទច្បាប់ អ.វ.ត.ក. មិនមានភាពស្រពិចស្រពិលច្រើននោះទេ ដោយបានយោងទៅបទប្បញ្ញត្តិចែងក្នុងវិធាន ៦៧(១) នៃវិធានផ្ទៃក្នុងថា សហចៅក្រមស៊ើបអង្កេតត្រូវបិទបញ្ចប់ការស៊ើបអង្កេត ដោយការចេញដីកាដំណោះស្រាយមួយ និងដោយសន្និដ្ឋានថា ដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេត ជាលទ្ធផលគឺជាសេចក្តីសម្រេចតែមួយប៉ុណ្ណោះ[1335]។

ទោះបីជាអង្គបុរេជំនុំជម្រះឯកភាពលើលក្ខណៈខុសច្បាប់នៃការឯកភាពគ្នារបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នាយ៉ាងណាក្តី ក៏ចៅក្រមនៃអង្គបុរេមិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការ ដើម្បីចេញសេចក្តីសម្រេចលើអង្គសេចក្តីលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាបានឡើយ ហើយដូច្នេះចៅក្រមបានផ្តល់យោបល់ដោយឡែករបស់ខ្លួន។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ពិចារណាឃើញថា ដីកាដំណោះស្រាយទាំងពីរមានតម្លៃស្មើគ្នា ហើយដីកាទាំងពីរមានសុពលភាព ហើយយោងតាមសច្ចធារណ៍នៃនិរទោស ច្បាប់ពុំអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតណាម្នាក់មានឧត្តមភាពនោះទេ។ ហេតុដូច្នេះ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា គប្បីតម្កល់ទុកសំណុំរឿង ០០៣ នៅក្នុងបណ្ណសាររបស់ អ.វ.ត.ក.[1336]។ ផ្ទុយទៅវិញ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់មិនពេញលេញ និងមិនមានសុពលភាព ហើយដូច្នេះទុកជាមោឃៈ ដោយសារដីកានេះមិនបានអើពើចំពោះភ័ស្តុតាងរយៈពេលប្រាំពីរឆ្នាំ និងការចោទប្រកាន់ព្រហ្មទណ្ឌដែលបានប្តឹងមកសហ

---

[1328] សំណុំរឿង ០០៣ ប្រតិចារឹក ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/16.1 & D267/21.1។ សំណុំរឿង ០០៣ ប្រតិចារឹក ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/17.1 & D267/22.1។ សំណុំរឿង ០០៣ ប្រតិចារឹក ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/18.1 & D267/23.1។ អង្គបុរេជំនុំជម្រះបានដាក់ជាសាធារណៈនូវប្រតិចារឹកសំណួរ សួរទៅកាន់ភាគីនៅថ្ងៃទីបីនៃថ្ងៃសវនាការ។ សូមមើល សំណុំរឿង ០០៣ ប្រតិចារឹក ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/18.2 & D267/23.2។

[1329] សំណុំរឿង ០០៣ របាយការណ៍នៃសំណុំរឿង និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ ឯកសារ D266/15 & D267/20។

[1330] សំណុំរឿង ០០៣ សេចក្តីពិចារណារបស់ អ.ប.ជ. លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ ឯកសារ D266/27 & D267/35 កថាខណ្ឌ ៣៧-៤០ ("សេចក្តីពិចារណា អ.ប.ជ.")។

[1331] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ៥៤-៧៧។

[1332] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ១០៦។

[1333] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ៩០។

[1334] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ៩១។

[1335] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ១០៣។

[1336] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 យោបល់ចៅក្រម ប្រាក់ គឹមសាន, ន័យ ថុល និង ហួត វុទ្ធី កថាខណ្ឌ ១១៥-១១៧។

ចៅក្រមស៊ើបអង្កេតជាតិ[1337]។ ពួកគេយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ មិនបានបំពេញតាមបទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ឡើយ ហើយដូច្នេះពិចារណាថាវាគប្បីត្រូវបានបដិសេធចោលភ្លាមៗ[1338] តែទោះជាយ៉ាងណា ពួកគេបានវាយតម្លៃចំណុចមួយចំនួន ដែលសហព្រះរាជអាជ្ញាជាតិបានលើកឡើង មុនពេលបដិសេធចំណុចទាំងនោះលើអង្គសេចក្តី[1339]។ ពួកគេយល់ឃើញថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានសុពលភាព និងគប្បីត្រូវតម្កល់ បើទោះជាមានកំហុសនៃការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នាក៏ដោយ[1340]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានឯកភាពជារួមជាមួយនឹងការសម្រេចផ្នែកអង្គហេតុ និងអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើទំហំ លក្ខណៈ វិសាលភាព និងផលប៉ះពាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ប្រឆាំងនឹង មាស មុត និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនោះ ហើយបានពិចារណាថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់យ៉ាងត្រឹមត្រូវថា មាស មុត ស្ថិតក្នុងយុត្តាធិការលើរូបបុគ្គលរបស់ អ.វ.ត.ក.[1341]។ ពួកគាត់បានពិចារណាថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះគប្បីត្រូវបានគាំទ្រ និងថាសំណុំរឿង ០០៣ គប្បីត្រូវប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង[1342]។

### ៥.៣.២.១១. បណ្តឹងវិវាទពាក់ព័ន្ធនឹងស្ថានភាពសំណុំរឿង ០០៣

បន្ទាប់ពីការចេញសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង។ គាត់អះអាងថាចៅក្រមនៃអង្គបុរេជំនុំជម្រះទាំងអស់បានសន្និដ្ឋានជាឯកច្ឆន្ទថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព និងថាជាលទ្ធផល រឿងក្តីនេះត្រូវបានប្តឹងជាស្វ័យប្រវត្តិទៅអង្គជំនុំជម្រះសាលាដំបូង[1343]។

សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើនេះ ដោយយល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិចាប់យកសេចក្តីពិចារណារបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះក្រៅបរិបទ តាមរយៈការអះអាងថា ការសម្រេចថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព គឺជាការសម្រេចជាឯកច្ឆន្ទ ដោយសារចៅក្រមនៃអង្គបុរេជំនុំជម្រះ បានបដិសេធយ៉ាងស៊ីចង្វាក់គ្នាអំពីអត្ថិភាពនៃយុត្តាធិការលើរូបបុគ្គលលើ មាស មុត ហើយបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ពួកគាត់មិនមានបំណងឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះបន្តទៅជំនុំជម្រះនោះឡើយ។ សហចៅក្រមស៊ើបអង្កេតបានថ្លែងថា ខ្លួនយល់ឃើញថាសំណុំរឿង ០០៣ "គឺដូចគ្នាទាំងស្រុង លើបញ្ហាសំខាន់ៗនៃយុត្តាធិការបុគ្គល និងបញ្ហានៃដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា" ដូចសំណុំរឿង ០០៤/០២ និងយល់ឃើញថា ដោយសារសំណុំរឿងដូចគ្នា ចាំបាច់ត្រូវអនុវត្តដូចគ្នា រឿងក្តីនេះមិនគួរត្រូវបញ្ជូនទៅជំនុំជម្រះទេ ប៉ុន្តែគប្បីតម្កល់ទុកក្នុងបណ្ណសារ។ ពួកគាត់បានជំរុញដោយផ្ទាល់ឱ្យសហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍សេចក្តីសម្រេចនេះទៅអង្គបុរេជំនុំជម្រះ ដើម្បីអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាឡើងវិញ យ៉ាងហោចណាស់ធ្វើការបញ្ជាក់បំភ្លឺទស្សនៈរបស់ខ្លួនលើការទទួលយកជាឯកច្ឆន្ទរបស់ចៅក្រមអង្គបុរេជំនុំជម្រះទាំងអស់ លើសុពលភាពនៃដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងបញ្ហាជាក់លាក់ណាមួយផ្សេងទៀត[1344]។

មាស មុត បន្ទាប់មកបានដាក់ញត្តិស្នើសុំឱ្យបញ្ចប់ បោះត្រា និងរក្សាទុកសំណុំរឿង ០០៣ ក្នុងបណ្ណសារ[1345] ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានស្នើសុំអង្គបុរេជំនុំជម្រះឱ្យបិទបញ្ចប់ដំណាក់

[1337] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 យោបល់ចៅក្រម Olivier Beauvallet និង Kang Jin Baik កថាខណ្ឌ ១១៩, ២២៦-២៥០, ២៨៤។
[1338] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ១៩២។
[1339] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ១៩៣-១៩៧។
[1340] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ២៦២, ២៨៤។
[1341] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ២៨៧-៣៤០។
[1342] សំណុំរឿង ០០៣ សេចក្តីពិចារណា អ.ប.ជ. ឯកសារ D266/27 & D267/35 កថាខណ្ឌ ៣៤១-៣៤៤។
[1343] សំណុំរឿង ០០៣ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅកាន់សហចៅក្រមស៊ើបអង្កេតសុំឲ្យបញ្ជូនសំណុំរឿង០០៣ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ឯកសារ D270។
[1344] សំណុំរឿង ០០៣ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១ ឯកសារ D270/7 កថាខណ្ឌ ៣០-៣៣, ៥៣។
[1345] សំណុំរឿង ០០៣ សំណើរបស់ មាស មុត សុំបញ្ចប់ បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D272។

កាលមុនជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០៣ និងបានបង្គាប់ថា មាស មុត ត្រូវបញ្ជូនទៅជំនុំជម្រះ ដែលស្របទៅនឹងការសន្និដ្ឋានជាឯកច្ឆន្ទរបស់ខ្លួនដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព[1346]។

អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចរួមលើសំណើទាំងនេះ និងបានសម្រេចថា សំណើទាំងអស់នេះមិនអាចទទួលយកបាន ដោយលើកឡើងថា ទោះបីជាសហចៅក្រមស៊ើបអង្កេតមានអំណាចជាឯកតោភាគីក្នុងការបញ្ចប់កិច្ចស៊ើបសួរតែម្នាក់ឯង អង្គបុរេជំនុំជម្រះមិនមានអំណាចបែបនេះឡើយ។ អង្គបុរេជំនុំជុំម្រះយល់ឃើញថា ខ្លួនបានបំពេញភារកិច្ចរបស់ខ្លួននៅក្នុងសំណុំរឿង ០០៣ រួចហើយ តាមរយៈការចេញសេចក្ដីពិចារណារបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ និងបានសម្រេចលើចំណុចទាំងឡាយដែលបានលើកឡើងនៅក្នុងសំណើទាំងនោះ[1347]។

បន្ទាប់ពីសេចក្ដីសម្រេចនេះ សហចៅក្រមស៊ើបអង្កេតបានបង្គាប់ឱ្យភាគីដាក់សារណា ស្ដីពីយុត្តាធិការសេសសល់របស់ខ្លួនក្នុងការបញ្ចប់សំណុំរឿង ០០៣។ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងភាគីថា ប្រសិនបើសហព្រះរាជអាជ្ញាអន្តរជាតិមិនមានបំណងប្ដឹងសាទុក្ខរឿងក្ដីនេះទៅអង្គជំនុំជម្រះតុលាការកំពូលទេនោះ ដូចដែលធ្លាប់បានធ្វើក្នុងសំណុំរឿង ០០៤/០២ យុត្តាធិការសេសសល់របស់សហចៅក្រមស៊ើបអង្កេត ក្នុងការបញ្ចប់រឿងក្ដីនេះនៅតែមានដើម្បីធ្វើការសម្រេច[1348]។ នៅថ្ងៃជាមួយគ្នានេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីបំណងរបស់គាត់ក្នុងការប្ដឹងសាទុក្ខរឿងក្ដីនេះទៅកាន់អង្គជំនុំជម្រះតុលាការកំពូល[1349]។

## ៥.៣.២.១២. ការបញ្ចប់កិច្ចដំណើរការនីតិវិធី

សហព្រះរាជអាជ្ញាអន្តរជាតិ បានប្ដឹងសាទុក្ខចំពោះការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ដោយលើកឡើងថា បណ្ដឹងសាទុក្ខនេះអាចទទួលយកបាន និងថា អង្គជំនុំជម្រះតុលាការកំពូលគប្បីអនុវត្តយុត្តាធិការដែលជាប់មកជាមួយរបស់ខ្លួន ដើម្បីការពារផលប្រយោជន៍យុត្តិធម៌ និងថែរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី[1350]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា បរាជ័យរបស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង បានបន្តឱ្យមានការជាប់គាំងផ្នែកនីតិវិធី និងបណ្ដាលឱ្យមានព្យសនកម្មមិនអាចជួសជុលបានទៅលើកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ នៅក្នុងសំណុំរឿងនេះ និងថា បើសិនជាគ្មានកិច្ចអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូលទេនោះ កិច្ចដំណើរការនីតិវិធីនឹងស្ថិតក្នុងភាពមិនច្បាស់លាស់ ដែលមានតម្លៃស្មើទៅនឹងយុត្តិនិសេធ ដែលជាការរំលោភលើអាណត្តិ និងគោលការណ៍ជាសារវន្តរបស់ អ.វ.ត.ក.[1351]
។

អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា "បណ្ដឹងសាទុក្ខ" របស់សហព្រះរាជអាជ្ញាអន្តរជាតិមិនមែនជាបណ្ដឹងសាទុក្ខនោះទេ នៅក្នុងសមត្ថកិច្ចរបស់អង្គជំនុំជុំម្រះតុលាការកំពូល ហើយវាមានលក្ខណៈត្រឹមត្រូវជាងក្នុងការហៅវាថាជា "សំណើ" ដោយបានកត់សម្គាល់ថា "កម្រងច្បាប់នៃ អ.វ.ត.ក. ពុំបានដាក់បញ្ចូលបទប្បញ្ញត្តិដែលគាំទ្រភាគីឱ្យធ្វើបណ្ដឹងសាទុក្ខចេញពីអង្គបុរេជំនុំជម្រះ មកអង្គជំនុំជម្រះតុលា

---

[1346] សំណុំរឿង ០០៣ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបិទបញ្ចប់ដំណាក់កាលមុនការជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ឯកសារ D271/1។
[1347] សំណុំរឿង ០០៣ សេចក្ដីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីការពារក្ដី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D271/5 & 272/3។
[1348] សំណុំរឿង ០០៣ ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ដើម្បីបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D273។
[1349] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេត សុំឱ្យប្រកាសថាតើសហព្រះរាជអាជ្ញាអន្តរជាតិមានបំណងប្ដឹងទៅអង្គជំនុំជម្រះតុលាការកំពូលដែរឬទេ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D273/1។
[1350] សំណុំរឿង ០០៣ បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនរឿងក្ដីទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ឯកសារ 3។
[1351] សំណុំរឿង ០០៣ បណ្ដឹងសារទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនរឿងក្ដីទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ឯកសារ 3 កថាខណ្ឌ១-៤។

ការកំពូលនៅក្នុងកិច្ចដំណើរការនីតិវិធីឡើយ”[1352]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ឃើញថា នៅក្នុងសំណុំរឿង ០០៤/០២ សហព្រះរាជអាជ្ញាអន្តរជាតិ បានស្វែងរកការបំភ្លឺ និងភាពច្បាស់លាស់ផ្នែកច្បាប់ពីខ្លួន បន្ទាប់ពីការប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះថា ការចេញដីកាដំណោះស្រាយពីររបស់សហចៅក្រមស៊ើបអង្កេតគឺខុសច្បាប់ និងថា ដើម្បីផលប្រយោជន៍យុត្តិធម៌ និងភាពត្រឹមត្រូវ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាលើញត្តិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ[1353]។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ខ្លួននឹងពិចារណាលើសំណើក្នុងរឿងក្តីនេះក្នុងស្មារតីដូចមុនដែរ ដោយមិនធ្វើការវិនិច្ឆ័យឡើងវិញលើបញ្ហាដូចគ្នាទេ ប៉ុន្តែ “សម្រាប់គោលបំណងដែលមានកម្រិតតិចតួច គឺដើម្បីបញ្ជាក់សាឡើងវិញនូវគោលជំហរមិនប្រែប្រួលរបស់ខ្លួន និងដើម្បីកែតម្រូវ កំហុសឆ្គងក្នុងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ”[1354]។

អង្គជំនុំជម្រះតុលាការកំពូលជាដំបូងបានពិចារណាលើ អានុភាពនៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ដោយកត់សម្គាល់ថា សេចក្តីពិចារណាត្រូវបានប្រកាសជាឯកច្ឆន្ទថាបិទផ្លូវតវ៉ា និងត្រូវបានចាត់ទុកថាពេញលេញ។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ផលវិបាកច្បាស់លាស់នៃសេចក្តីប្រកាសជាឯកច្ឆន្ទនេះ “បង្ហាញថាជាការបញ្ចប់រឿងក្តី” ដែលបញ្ជាក់ថាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះថាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិមិនជោគជ័យទេ និង “បញ្ចប់រឿងក្តី”នេះ។ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានរកឃើញជាឯកច្ឆន្ទថាមានសុពលភាពដោយអង្គបុរេជំនុំជម្រះ។ អង្គជំនុំជម្រះតុលាការកំពូលបានបំភ្លឺអំពីស្ថានភាពសំណុំរឿង ០០៣ ដោយបានបញ្ជាក់ឡើងវិញអំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងសំណុំរឿង ០០៤/០២ ថា ដោយសារគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចអនុវត្តបាន និងជាក់លាក់ សំណើសុំឱ្យបញ្ជូនរឿងក្តីទៅអង្គជំនុំជម្រះសាលាដំបូង មិនអាចអនុវត្តបានទេ និងបានកត់សម្គាល់ថា ក្នុងសំណុំរឿង ០០៣ មិនមានការបញ្ជូនសំណុំរឿងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ទៅកាន់អង្គជំនុំជម្រះសាលាដំបូងទេ ដែលការណ៍នេះបញ្ជាក់ជាឯកច្ឆន្ទថា សំណុំរឿង ០០៣ ត្រូវបានបញ្ចប់ក្នុងអំឡុងពេលដំណាក់កាលកិច្ចដំណើរការនីតិវិធីមុនជំនុំជម្រះ[1355]។

ចៅក្រម Maureen Harding Clark បានភ្ជាប់យោបល់ជំទាស់របស់ខ្លួនទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល។ គាត់បានយោងបញ្ហាខ្វែងយោបល់ជាសារវន្តរវាង សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និងចៅក្រមនៃអង្គបុរេជំនុំជម្រះ នៅក្នុងរឿងក្តីនេះ ដោយបានទទួលស្គាល់ថា ទំនាស់ដំបូងទាក់ទងនឹងសំណុំរឿង ០០៣ និង ០០៤ មិនផ្តើមចេញពីភាពជាប់គាំង ឬភាពមិនច្បាស់លាស់ផ្នែកច្បាប់ដែលកើតឡើងពីដីកាដំណោះស្រាយ ឬពីអសមត្ថភាពរបស់អង្គបុរេជំនុំជម្រះក្នុងការឈានដល់ការឯកភាពគ្នានោះទេ ប៉ុន្តែផ្ទុយទៅវិញបញ្ហាទាំងអស់នេះកើតចេញពីការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាក្នុងឆ្នាំ២០០៨ ហើយគាត់បានបន្តពិនិត្យមើលការខ្វែងយោបល់គ្នានេះជាលម្អិត និងពិនិត្យបន្ថែមទៀតលើប្រវត្តិនីតិវិធីនៃរឿងក្តី។ ចៅក្រម Harding Clark បានពិចារណាឃើញថា សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះមិនសមហេតុផល និងយល់ឃើញថា ដោយសារតែមិនមានបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដំណោះស្រាយតែមួយគត់នោះគឺអង្គជំនុំជម្រះតុលាការកំពូល ត្រូវប្រើអំណាចដែលមានជាប់មកជាមួយរបស់ខ្លួន បដិសេធដីកានោះ ហើយបង្គាប់ឱ្យអង្គបុរេជំនុំជម្រះពិចារណាឡើងវិញលើដីកាដំណោះស្រាយដែលផ្ទុយគ្នាទាំងនោះ ដើម្បីធ្វើសេចក្តីសម្រេចមួយដែលច្បាស់លាស់ត្រឹមត្រូវតាមច្បាប់។ ចៅក្រមពិចារណាឃើញថា សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះមិនមានសុពលភាព និងត្រូវតែបដិសេធចោល ដោយសារមិនមានអ្នកធ្វើសេចក្តីសម្រេចដ៏សមហេតុផលណាម្នាក់ អាចធ្វើការ

[1352] សំណុំរឿង ០០៣ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែធ្នូ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 3/1/1/1 កថាខណ្ឌ ២៧-២៩ (“សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ឯកសារ”)។
[1353] សំណុំរឿង ០០៣ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ឯកសារ 3/1/1/1 កថាខណ្ឌ ៣២។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2។
[1354] សំណុំរឿង ០០៣ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ឯកសារ 3/1/1/1 កថាខណ្ឌ ៣៣។
[1355] សំណុំរឿង ០០៣ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ឯកសារ 3/1/1/1 កថាខណ្ឌ ៣៤-៤៣។

កំណត់មិនសមហេតុផលដូចដែលអង្គបុរេជំនុំជម្រះបានធ្វើនោះឡើយ និងថាហេតុដូច្នេះ រឿងក្ដីនេះគប្បីត្រូវបញ្ចប់ក្នុងកាលៈទេសៈទាំងនេះ[1356]។

នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ឱ្យបោះត្រា និងដាក់សំណុំរឿង ០០៣ ក្នុងបណ្ណសារជាផ្លូវការ[1357]។ ការណ៍នេះបានបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ប្រឆាំងនឹង មាស មុត។

### ៥.៣.៣. សំណុំរឿង ០០៤

#### ៥.៣.៣.១. ទិដ្ឋភាពទូទៅរបស់ជនជាប់សង្ស័យ

សំណុំរឿង ០០៤ មានជនសង្ស័យចំនួន បី នាក់។

- **អ៊ឹម ចែម**៖ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ និងសហចៅក្រមស៊ើបអង្កេត អ៊ឹម ចែម (កើតឆ្នាំ១៩៤៦) គឺជាលេខាស្រុកព្រះនេត្រព្រះ ក្នុងតំបន់ ៥ (ភូមិភាគពាយ័ព្យ)[1358]។

នៅក្នុងកិច្ចដំណើរការនីតិវិធីដាច់ដោយឡែក អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ក៏បានរកឃើញនៅក្នុងភស្តុតាងដែលមានថា អ៊ឹម ចែម ជាលេខាស្រុកព្រះនេត្រព្រះ[1359]។

- **អោ អាន**៖ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ អោ អាន (១៩៣៣-២០២០) គឺជាលេខាតំបន់ ៤១ មុនពេលត្រូវបានតែងតាំងជាអនុលេខាភូមិភាគកណ្តាល[1360]។

  នៅក្នុងកិច្ចដំណើរការនីតិវិធីដាច់ដោយឡែក អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ក៏បានរកឃើញនៅក្នុងភស្តុតាងដែលមានថា អោ អាន គឺជាលេខាតំបន់ ៤១ និងក្រោយមកជាប្រធានស្តីទីនៃភូមិភាគកណ្តាល[1361]។

- **យឹម ទិត្យ**៖ យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ យឹម ទិត្យ (កើតឆ្នាំ១៩៣៦) គឺជាលេខាតំបន់ ១, ៣, ៤ (ភូមិភាគពាយ័ព្យ) និង តំបន់ ១៣ (ភូមិភាគនិរតី) និងជាលេខាស្រុកគិរីវង់[1362]។

  នៅក្នុងកិច្ចដំណើរការនីតិវិធីដាច់ដោយឡែក អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ក៏បានរកឃើញនៅក្នុងភស្តុតាងដែលមានថា យឹម ទិត្យ ជាលេខាតំបន់ ១៣[1363]។

---

[1356] សំណុំរឿង ០០៣ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ឯកសារ 3/1/1/1 យោបល់ជំទាស់របស់ចៅក្រម Maureen Harding Clark។

[1357] សំណុំរឿង ០០៣ ដីកាបង្គាប់ឲ្យបញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារដ្ឋាន ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ឯកសារ D275។

[1358] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ D308/3 កថាខណ្ឌ១៤០, ១៥៨។

[1359] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ E465 កថាខណ្ឌ ១២៣៣។ ដោយសារគាត់មិនមែនជាភាគីទៅនឹងកិច្ចដំណើរការនិតិវិធី អ៊ឹម ចែម មិនអាចតតាំងនឹងការរកឃើញនេះនៅក្នុងសំណុំរឿង ០០២/០២ បានទេ។

[1360] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 កថាខណ្ឌ ២៣៣, ២៤៥-២៤៧, ២៥០។

[1361] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៧៦, ១៤៦៥, ១៤៧០, ៣២០២។ ដោយសារគាត់មិនមែនជាភាគីទៅនឹងកិច្ចដំណើរការនិតិវិធី អោ អាន មិនអាចតតាំងនឹងការរកឃើញនេះនៅក្នុងសំណុំរឿង ០០២/០២ បានទេ។ មិនមានការកំណត់ចុងក្រោយតាមផ្លូវតុលាការចុង អំពីមុខតំណែងរបស់ អោ អាន អាចធ្វើទៅបានទេ ក្នុងសំណុំរឿង ០០៤/០២ ដោយសាររឿងក្ដីមិនត្រូវបានបើសវនាការជំនុំជម្រះ។

[1362] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 កថាខណ្ឌ ៣២៣, ៣២៧, ៣៥៧។

[1363] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ E465 កថាខណ្ឌ ៩១៥។ ដោយសារគាត់មិនមែនជាភាគីទៅនឹងកិច្ចដំណើរការនិតិវិធី យឹម ទិត្យ មិនអាចតតាំងនឹងការរកឃើញនេះនៅក្នុងសំណុំរឿង ០០២ បានទេ។ មិនមានការកំណត់ចុងក្រោយតាមផ្លូវតុលាការចុង អំពីមុខតំណែងរបស់ យឹម ទិត្យ អាចធ្វើទៅបានទេ ក្នុងសំណុំរឿង ០០៤ ដោយសាររឿងក្ដីមិនត្រូវបានបើសវនាការជំនុំជម្រះ។

### ៥.៣.៣.២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបីបានចោទប្រកាន់ថា អោ អាន, អ៊ឹម ចែម, និង យឹម ទិត្យ ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មជាតិ និងអន្តរជាតិជាច្រើន ដែលបានប្រព្រឹត្តនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ ដីកានេះបានចោទប្រកាន់ថា អោ អាន បានដឹកនាំកម្មាភិបាលមួយក្រុម ពីភូមិភាគនិរតី ដែលបានបោសសម្អាត និងជំនួសកម្មាភិបាលដែលមានស្រាប់នៅក្នុងភូមិភាគកណ្ដាល (ឧត្តរចាស់) និងលេខាតំបន់ ៤១។ ដីកានេះក៏បានចោទទៀតថា យឹម ទិត្យ និង តាម៉ុក បានដឹកនាំកម្មាភិបាលនិរតីមួយក្រុមទៀត ទៅបោសសម្អាត និងជំនួសកម្មាភិបាលដែលមានស្រាប់នៅភូមិភាគពាយ័ព្យ និងថាជាផ្នែកមួយនៃការបោសសម្អាតដ៏ទូលំទូលាយជាងនេះនៅក្នុងភូមិភាគពាយ័ព្យ ដែលដឹកនាំដោយ តាម៉ុក និង យឹម ទិត្យ នោះ អ៊ឹម ចែម ក៏បានដឹកនាំការបោសសម្អាតមួយនៅស្រុកព្រះនេត្រព្រះ ក្នុងតំបន់ ៥ នៃភូមិភាគពាយ័ព្យផងដែរ ហើយក៏បានក្លាយជាលេខាស្រុកនោះ[1364]។

### ៥.៣.៣.៣. កិច្ចស៊ើបសួរតាមផ្លូវតុលាការ

ក្នុងអំឡុងរយៈពេលនៃកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងសេចក្ដីបញ្ជាក់បំភ្លឺពាក់ព័ន្ធជាច្រើន ប្ដឹងទៅសហចៅក្រមស៊ើបអង្កេតអំពី៖ (១) ទីតាំងឧក្រិដ្ឋកម្មថ្មី នៅក្នុងតំបន់ ១ នៃភូមិភាគពាយ័ព្យ និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងខ្មែរក្រោម នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ និងបានបញ្ជាក់បំភ្លឺ និងបន្ថែមឧក្រិដ្ឋកម្មដែលត្រូវធ្វើការស៊ើបអង្កេត ទាក់ទងទៅនឹងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ ដែលផ្អែកជាចម្បងលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ពាក្យបណ្ដឹង និងបទសម្ភាសន៍ដែលបានទទួល ឬបានជូនដំណឹងក្នុងសំណុំរឿង ០០២ បន្ទាប់ពីបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (២) ព័ត៌មានទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាយេនឌ័រ និង (៣) អង្គហេតុទាក់ទងនឹងវត្តតាមាក់[1365]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark Harmon បានចោទប្រកាន់ អ៊ឹម ចែម និង អោ អាន ជាផ្លូវការ[1366]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Michael Bohlander ក្រោយមកបានចោទប្រកាន់ អោ អាន ពីបទឧក្រិដ្ឋបន្ថែមទៀត[1367] បានចោទប្រកាន់ យឹម ទិត្យ[1368] ក្រោយមកបានកែប្រែបទចោទប្រឆាំងគាត់[1369] និងបានផ្អាកកិច្ចស៊ើបសួរបណ្ដោះអាសន្នប្រឆាំងនឹង អោ អាន និង យឹម ទិត្យ ពាក់ព័ន្ធនឹងអង្គហេតុជាក់លាក់[1370]។

---

[1364] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីបី ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។

[1365] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65។ សំណុំរឿង ០០៤ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ D191។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ ឯកសារ D237 ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ D237/1។ សំណុំរឿង ០០៤ ចម្លើយតបទៅដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវត្តអង្គតាមាក់ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥ ឯកសារ D254/1។ សំណុំរឿង ០០៤ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D272/1។

[1366] សំណុំរឿង ០០៤ ដីកាសម្រេចដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ឯកសារ D239។ សំណុំរឿង ០០៤/០២ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ឯកសារ D242។

[1367] សំណុំរឿង ០០៤/០២ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ អោ អាន ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ D303។

[1368] សំណុំរឿង ០០៤ កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងរបស់ យឹម ទិត្យ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D281។

[1369] សំណុំរឿង ០០៤ ដីកាសម្រេចកែប្រែបែបបទចោទប្រឆាំង យឹម ទិត្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ឯកសារ D350។ សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ ឧបសម្ព័ន្ធ ១ ភ្ជាប់ទៅនឹងដីកាសម្រេចកែប្រែបែបបទចោទប្រឆាំង ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ឯកសារ D350.1។

[1370] សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន*(២) ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D307/4។ សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរលើអង្គហេតុពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ៦កន្លែង ចុះថ្ងៃទី១៧

### ៥.៣.៣.៤. បញ្ហាពាក់ព័ន្ធនឹងការមានផ្ទៃពោះដោយបង្ខំ និងការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ

សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សំណើមួយស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ស៊ើបអង្កេតការមានផ្ទៃពោះដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត[1371]។ សហព្រះរាជអាជ្ញាអន្តរជាតិបានគាំទ្រសំណើនេះ ប៉ុន្តែមានការបកស្រាយខុសគ្នាចំពោះស្ថានភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥[1372]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដោយសម្រេចថា មិនមាននិយមន័យដាច់ស្រេចអំពីទស្សនៈនៃការមានផ្ទៃពោះដោយបង្ខំ ឬការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ នៅក្នុងច្បាប់កម្ពុជា ឬច្បាប់អន្តរជាតិ ចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ និងមិនមានបទដ្ឋានសិទ្ធិមនុស្សច្បាស់លាស់ ដែលភ្ជាប់ទៅនឹងអំពើ ដែលបង្កើតបានជាការមានផ្ទៃពោះដោយបង្ខំ ដែលការរំលោភបំពានអាចឈានទៅរកការប្រព្រឹត្តបទល្មើសមួយនៃទម្រង់អំពើអមនុស្សធម៌ផ្សេងៗទៀតនោះទេ។ គាត់បានពិចារណាឃើញថា ដូច្នេះការស៊ើបអង្កេតត្រូវហាមឃាត់ដោយគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង*។ គាត់បានកត់សម្គាល់ថា បន្ទាប់ការស៊ើបអង្កេតអស់រយៈពេលជាច្រើនឆ្នាំទៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមានភ័ស្តុតាងណាដែលគាំទ្រគោលនយោបាយនៃការបង្កឱ្យមានផ្ទៃពោះដោយបង្ខំ ឬការមានផ្ទៃពោះដោយបង្ខំឡើយ[1373]។

### ៥.៣.៣.៥. ការបំបែកកិច្ចដំណើរការនីតិវិធីរឿងក្ដី អ៊ឹម ចែម និងការបង្កើតសំណុំរឿង ០០៤/០១

នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេត បានអញ្ជើញភាគីឱ្យដាក់សារណា លើបញ្ហាថាតើ អ៊ឹម ចែម គប្បីត្រូវចាត់ទុកថាជា “មេដឹកនាំជាន់ខ្ពស់” ឬស្ថិតក្នុងចំណោម “ជនដែលទទួលខុសត្រូវខ្ពស់បំផុត” ដែលគាត់ស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬយ៉ាងណា[1374]។ អ៊ឹម ចែម បានលើកឡើងថា គាត់គឺជាកម្មាភិបាលថ្នាក់ទាប ដែលមិនមែនជា “មេដឹកនាំជាន់ខ្ពស់” ហើយក៏មិនមានភ័ស្តុតាងបញ្ជាក់ថា គាត់ស្ថិតក្នុងចំណោម “ជនដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ[1375]។ ស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាជាតិ បានសន្និដ្ឋានថា អ៊ឹម ចែម ដូចគ្នានឹងជនសង្ស័យផ្សេងទៀតក្នុងសំណុំរឿង ០០៣ និង ០០៤ មិនមែនជាមេដឹកនាំជាន់ខ្ពស់ និងមិនស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ហើយដូច្នេះ មិនស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. នោះទេ[1376]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិ បានសន្និដ្ឋានថា ដោយបាន៖ (១) អនុវត្តសិទ្ធិអំណាចស្ទើរតែទាំងស្រុងលើជីវិតរបស់មនុស្សចំនួន ១០០.០០០ នាក់ ដែលរស់នៅក្នុងស្រុករបស់គាត់ក្នុងឋានៈជាលេខាស្រុកព្រះនេត្រព្រះ ពីខែមិថុនា ឆ្នាំ១៩៧៧ ដល់ខែមករា ឆ្នាំ១៩៧៩ (២) បានដឹកនាំការប្រជុំដើម្បីផ្ដល់ការណែនាំកម្មាភិបាលស្រុក និងឃុំផ្សេងទៀត ស្ដីពីការអនុវត្តពលកម្មដោយបង្ខំរបស់ ប.ក.ក. គោលនយោបាយខ្លាំង និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង (៣) ដើរតួនាទីសំខាន់ក្នុងការបោសសម្អាតនៅភូមិភាគពាយ័ព្យ និងការបង្កើត និងប្រតិបត្តិការមន្ទីរសន្តិសុខភ្នំត្រយ៉ោង ដែលជាមន្ទីរសន្តិសុខ

ខែមីនា ឆ្នាំ២០១៧ ឯកសារ D349។ សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងអំពីគោលបំណងដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវតាមរយៈការចេញដីកា និងអំពីការផ្អាកកិច្ចស៊ើបសួរបណ្ដោះអាសន្ន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ ឯកសារ D342។ សំណុំរឿង ០០៤ សេចក្ដីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ *ស្ទួន*(២) ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D354។

[1371] សំណុំរឿង ០០៤ សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យមានកិច្ចស៊ើបសួរប្រឆាំង អោ អាន និង ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦ ឯកសារ D301។

[1372] សំណុំរឿង ០០៤/០២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួររបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងនឹងឧក្រិដ្ឋកម្មស្ដីពី ការមានផ្ទៃពោះដោយបង្ខំ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ឯកសារ D301/2។

[1373] សំណុំរឿង ០០៤ ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និង បង្កឲ្យមានផ្ទៃពោះដោយបង្ខំ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D301/5។

[1374] សូមមើល សំណុំរឿង ០០៤/០១ សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251 ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D251/6 កថាខណ្ឌ១។

[1375] សំណុំរឿង ០០៤/០១ សេចក្ដីសង្កេតរបស់អ្នកស្រី អ៊ឹម ចែម ស្ដីពីបញ្ហាថាតើអ្នកស្រីគួរត្រូវបានចាត់ទុកជា "មេដឹកនាំជាន់ខ្ពស់" ឬ បុគ្គលម្នាក់ស្ថិតក្នុងចំណោម “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D251/4 កថាខណ្ឌ 2។

[1376] សំណុំរឿង ០០៤/០១ សេចក្ដីសង្កេតរបស់សហព្រះរាជអាជ្ញាជាតិ អំពីការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស លើករណី អ៊ឹម ចែម យោងតាមឯកសារលេខ D251 ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D251/6 កថាខណ្ឌ ១៣។

មួយ ក្នុងចំណោមមន្ទីរសន្តិសុខធំបំផុតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ អ៊ឹម ចែម មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមទេ ប៉ុន្តែស្ថិតក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងទំហំធំធេង ដែលបានបណ្តាលឱ្យមានទុក្ខវេទនាដល់ប្រជាជនកម្ពុជាប្រមាណជាង ១០០.០០០ នាក់ និងនាំឱ្យមានការស្លាប់មនុស្សរាប់ម៉ឺននាក់ ក្នុងអំឡុងពេលនៃរបបនោះ[1377]។

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីថា ពួកគាត់មានបំណងបំបែកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង អ៊ឹម ចែម និងលើកលែងចោទប្រកាន់រឿងក្តីប្រឆាំងគាត់ ដោយសារខ្វះយុត្តាធិការបុគ្គល និងបានអញ្ជើញភាគីឱ្យដាក់សារណាលើការបំបែកសំណុំរឿងនេះ[1378]។ នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយពិចារណាថា ការស៊ើបអង្កេតលើការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម ត្រូវបានបិទបញ្ចប់ហើយនោះ ខណៈដែលការស៊ើបអង្កេតប្រឆាំងនឹងជនសង្ស័យផ្សេងទៀត ក្នុងសំណុំរឿង ០០៤ បានបន្ត សហចៅក្រមស៊ើបអង្កេតបានសម្រេចបំបែករឿងក្តី អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤។ ពួកគាត់បានបង្គាប់ឱ្យក្រឡាបញ្ជីរៀបចំបង្កើតសំណុំរឿងថ្មី គឺសំណុំរឿង ០០៤/០១ និងបានណែនាំភាគីទៅនឹងសំណុំរឿង ០០៤/០១ ឱ្យដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរដែលនៅសេសសល់ណាមួយ[1379]។

### ៥.៣.៣.៥.១. ដីកាសន្និដ្ឋានស្ថាពរ

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿង ០០៤/០១ ទៅសហព្រះរាជអាជ្ញា ដើម្បីដាក់ដីកាសន្និដ្ឋានស្ថាពរ[1380]។ សហព្រះរាជអាជ្ញាជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំឱ្យលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម[1381] ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិវិញ បានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែក ស្នើសុំឱ្យចោទប្រកាន់និងបញ្ជូន អ៊ឹម ចែម ទៅជំនុំជម្រះ[1382]។ អ៊ឹម ចែម បានឆ្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដោយលើកឡើងថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើរូបគាត់ទេ[1383]។

### ៥.៣.៣.៥.២. ដីកាដំណោះស្រាយ

នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានចេញផ្នែកសម្រេចសេចក្តី នៃដីកាដំណោះស្រាយ ដោយបានលើកលែងបទចោទប្រឆាំងនឹង អ៊ឹម ចែម និងបានជូនដំណឹងដល់ភាគីថា ដីកាដំណោះស្រាយដែលមានសំអាងហេតុ នឹងត្រូវផ្តល់ជូននៅពេលក្រោយ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ពួកគាត់យល់ឃើញថា មិនមានភ័ស្តុតាងបញ្ជាក់ថា អ៊ឹម ចែម គឺជាមេដឹកនាំជាន់ខ្ពស់ ឬជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ផ្អែកលើការវាយតម្លៃជារួមលើអំពើ និងការចូលរួមរបស់គាត់ នៅក្នុងរបបខ្មែរក្រហម និងការវាយតម្លៃលើភ័ស្តុតាងទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងអស់ និងទម្រង់នៃការទទួលខុសត្រូវ ដែលគាត់ត្រូវបានចោទប្រកាន់ ព្រមទាំងការចោទប្រកាន់ដែលរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូន

---

1377 សំណុំរឿង ០០៤ សារណាលើបញ្ហាថាតើ អ៊ឹម ចែម គួរត្រូវបានចាត់ទុកថាជា "មេដឹកនាំជាន់ខ្ពស់" ឬ ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរឬយ៉ាងណា ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ D251/5 កថាខណ្ឌ ៤៤-៤៩, ៥១។

1378 សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីគោលបំណងលើកលែងការចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម និងបំបែកកិច្ចដំណើការនីតិវិធីប្រឆាំងគាត់ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ D286។

1379 សំណុំរឿង ០០៤/០១ ដីកាសម្រេចបំបែកសំណុំរឿងទាក់ទង អ៊ឹម ចែម ចេញពីសំណុំរឿង០០៤ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ D286/7។

1380 សូមមើល សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308 កថាខណ្ឌ ៧។

1381 សំណុំរឿង ០០៤/០១ ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អ៊ឹម ចែម អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ឯកសារ D304/1 កថាខណ្ឌ ៣៨។

1382 សំណុំរឿង ០០៤/០១ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង អ៊ឹម ចែម (សំណៅកោសលុបសាធារណៈ) ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D304/2 កថាខណ្ឌ ៥៤១។

1383 សំណុំរឿង ០០៤/០១ ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងអ្នកស្រី តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D304/6។

រឿងឱ្យស៊ើបសួរបន្ថែម ដែលគាត់មិនត្រូវបានចោទប្រកាន់ផងដែរ។ ផ្អែកលើមូលហេតុនេះ ពួកគាត់យល់ឃើញថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើ អ៊ឹម ចែម ទេ[1384]។

ដីកាដំណោះស្រាយពេញលេញមានសំអាងហេតុបានចេញនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧[1385]។ ជំពូកទីមួយគឺជាសេចក្តីផ្តើម ហើយជំពូកទី២ លើកអំពីច្បាប់ជាធរមាន រួមបញ្ចូលទាំងយុត្តាធិការបុគ្គល ឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក. និងទម្រង់នៃការទទួលខុសត្រូវ។ ជំពូកទីបីពាក់ព័ន្ធទៅនឹងការពិចារណាលើភស្តុតាង ដែលលើកឡើងអំពីភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាងនៃប្រភេទនានានៃភស្តុតាង។ សហចៅក្រមស៊ើបអង្កេត បានពិចារណាលើភស្តុតាងមួយចំនួនធំ ដែលបានផ្អែកលើក្នុងសំណុំរឿង ០០៤/០១ ដែលមានកំណត់ហេតុនៃការស្តាប់ចម្លើយ ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត និងប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ពីរឿងក្តី អ.វ.ត.ក. ផ្សេងទៀត ដែលត្រូវទទួលបាននូវសច្ចធារណ៍នៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[1386]។ ពួកគាត់បានផ្តល់តម្លៃជាភស្តុតាងតិចតួចដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬមិនផ្តល់តម្លៃជាភស្តុតាងណាមួយឡើយប្រសិនបើមិនដឹងអំពីកាលៈទេសៈដែលឯកសារទាំងនោះត្រូវបានធ្វើឡើង[1387]។ ស្រដៀងគ្នានេះដែរ ពួកគេចាត់ទុកថា ចំនួនជនរងគ្រោះ ដែលបានផ្តល់ឱ្យនៅក្នុងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៧ និង ១៩៩៨ ក៏ដូចជា របាយការណ៍របស់រដ្ឋាភិបាលឆ្នាំ១៩៨៤ គឺមិនគួរឱ្យជឿជាក់បាន នឹងមានតម្លៃជាភស្តុតាងតិចតួច[1388] ។ ជំពូកបួនលើកឡើងអំពីការវិភាគផ្នែកអង្គហេតុ និងសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត ដែលក្នុងនោះពួកគេពិភាក្សាជាអាទិ៍អំពីសាវតាររបស់ អ៊ឹម ចែម តួនាទីនិងសិទ្ធិអំណាចរបស់គាត់ នៅក្នុងភូមិភាគពាយ័ព្យ។ ជំពូក៥ ដល់ ៧ ត្រូវបានកោសល្បុប និងមិនមានជាសាធារណៈទេ។ សហចៅក្រមស៊ើបអង្កេតជាចុងក្រោយបានសន្និដ្ឋានថា អ៊ឹម ចែម មិនមែនជាជនម្នាក់ក្នុងចំណោមជនទាំងឡាយដែល “ទទួលខុសត្រូវខ្ពស់បំផុត” នៅក្នុងអត្ថន័យនៃច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក. នោះទេ[1389]។

### ៥.៣.៣.៥.៣. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

នៅថ្ងៃជាមួយគ្នាដែលសហចៅក្រមស៊ើបអង្កេត បានចេញផ្នែកសម្រេចសេចក្តីនៃដីកាដំណោះស្រាយ ពួកគាត់ក៏បានចេញសេចក្តីសម្រេចដាច់ដោយឡែកមួយ បដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំង ១.៨៤២ នាក់ ដោយសារពួកគាត់យល់ឃើញរួមគ្នាថា បទបចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម គប្បីត្រូវលើកលែងចោទប្រកាន់[1390]។

### ៥.៣.៣.៥.៤. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

សហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ សំណុំរឿង ០០៤/០១ ដោយលើកឡើងនូវមូលដ្ឋានបណ្តឹងឧទ្ធរណ៍ចំនួនប្រាំមួយ ពាក់ព័ន្ធទៅនឹងកំហុសអង្គច្បាប់ និងកំហុសអង្គហេតុ របស់សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយ[1391]។ ជារួម មូលដ្ឋានបណ្តឹងឧទ្ធរណ៍ទាំងអស់នេះទាក់ទងទៅនឹង៖

(i) ការខកខានរបស់ ស.ច.ស. ក្នុងការពិចារណាលើរាល់អង្គហេតុទាំងអស់ ដែលខ្លួនត្រូវបានប្តឹងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបឋម និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ

---

[1384] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (ផ្នែកសម្រេចសេចក្តី) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D308។
[1385] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ D308/3។
[1386] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ D308/3 កថាខណ្ឌ ១០៣, ១០៨។
[1387] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ D308/3 កថាខណ្ឌ ១០៧។
[1388] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ D308/3 កថាខណ្ឌ ១៣៥។
[1389] សំណុំរឿង ០០៤/០១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ D308/3 កថាខណ្ឌ ៣២៥។
[1390] សំណុំរឿង ០០៤/០១ ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D307។
[1391] សំណុំរឿង ០០៤/០១ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ ឯកសារ D308/3/1/1។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D308/3/1/11។ សំណុំរឿង ០០៤/០១ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ ឯកសារ D308/3/1/13។

ស៊ើបសួរបន្ថែម សម្រាប់រឿងក្ដី អ៊ឹម ចែម និងរបៀបដែលអង្គហេតុទាំងអស់នេះអាចប៉ះពាល់លើបញ្ហាថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនានាស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬយ៉ាងណា។ (ii) កំហុសក្នុងរបៀបដែល ស.ច.ស. វិភាគ និងអនុវត្តធាតុផ្សំនៃឧក្រិដ្ឋកម្មសម្លាប់រង្គាល និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និង (iii) កំហុសក្នុងការរកឃើញនានាអំពីមុខតំណែងរបស់ អ៊ឹម ចែម នៅថ្នាក់ស្រុក និងថ្នាក់តំបន់ ក្នុងតំបន់ ១៣[1392]។

សហមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនបានប្ដឹងឧទ្ធរណ៍ទេ ប៉ុន្តែបានដាក់សារណាស្ដីពីគោលជំហររបស់ អ.វ.ត.ក. នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដោយលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានកំហុស តាមរយៈការពិចារណាថា ច្បាប់ អ.វ.ត.ក. មិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬយុត្តាធិការបទល្មើសរបស់តុលាការធម្មតា ទៅលើព្រឹត្តិការណ៍នានា ដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក. ឡើយ និងបានអះអាងថា កំហុសនេះ "អាចនឹងមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរ" លើផលប្រយោជន៍របស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងទៀតនៃរបបខ្មែរក្រហម និង "ធ្វើឱ្យខូចមរតករបស់" អ.វ.ត.ក. យ៉ាងធ្ងន់ធ្ងរ ដោយការរៀបចំឱ្យមានតុលាការមួយ ដែលការលើកលែងទោសស្ទើរតែទាំងស្រុងលើឧក្រិដ្ឋកម្មឃោរឃៅក្នុងសម័យខ្មែរក្រហមត្រូវបានអនុវត្តនៅក្នុងប្រទេសកម្ពុជាតាមរយៈយន្តការនេះ"[1393]។ ពួកគេបានស្នើសុំថា អង្គបុរេជំនុំជម្រះ "ដោះស្រាយសំអាងហេតុដែលមានការភាន់ច្រឡំ នៅក្នុងដីកាដំណោះស្រាយ នៅលើវិសាលភាពនៃយុត្តាធិការផ្តាច់មុខរបស់ អ.វ.ត.ក. និងប្រកាសថា កម្រិតដែលតុលាការកម្ពុជាសាមញ្ញមានសមត្ថភាពលើផ្លូវច្បាប់ និងស្ថាប័នក្នុងការដោះស្រាយឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម គឺជាបញ្ហាមួយដែលត្រូវប្រគល់ជូនតុលាការទាំងនោះឱ្យដោះស្រាយដោយខ្លួនឯង"[1394]។

សវនាការស្តាប់អំណះអំណាងផ្ទាល់មាត់បានធ្វើឡើងនៅថ្ងៃទី១១ និង ១២ ខែធ្នូ ឆ្នាំ២០១៧[1395]។

## ៥.៣.៣.៥.៥. សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

អង្គបុរេជំនុំជម្រះបានយល់ឃើញជាឯកច្ឆន្ទថា បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអាចទទួលយកបាន[1396] ក្រោយមកបានពិភាក្សាលើបញ្ហាបឋមជាក់លាក់ ដោយបានប្រកាសថា៖ (១) ការពន្យារពេលចេញដីកាដំណោះស្រាយមានសំអាងហេតុ បន្ទាប់ពីការបញ្ចប់ការស៊ើបអង្កេតប្រឆាំងនឹង អ៊ឹម ចែម គឺជាការពន្យារពេលមួយហួសហេតុមិនសមហេតុផល[1397]។ (២) សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការចេញ "ដីកាដំណោះស្រាយពីរដាច់ពីគ្នា" ដែលផ្នែកសម្រេចសេចក្ដីត្រូវបានចេញមុន ហើយចេញសំអាងហេតុតាមក្រោយ[1398]។ (៣) សហចៅក្រមស៊ើបអង្កេតទទួលយកអង្គហេតុមកពិនិត្យ និងមិនទទួលយកបុគ្គលមកពិនិត្យ ហើយមានតែអង្គហេតុទេដែលត្រូវបានបំបែក ដូច្នេះការបំបែកសំណុំរឿង អ៊ឹម ចែម ចេញពីសំណុំរឿង ០០៤ ហើយការបង្កើតសំណុំរឿង ០០៤/០១ បានបំបែកជាប្រយោលនូវការចោទ

---

[1392] សំណុំរឿង ០០៤/០១ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៧ ឯកសារ D308/3/1/1 កថាខណ្ឌ ២។

[1393] សំណុំរឿង ០០៤/០១ សារណារបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D308/3/1/9។ សូមមើលផងដែរ សំណុំរឿង ០០៤/០១ ចម្លើយតបរបស់អ្នកស្រី អ៊ឹម ចែម ទៅនឹងសារណារបស់ ស.ម.ត.ដ ស្ដីពីជំហរ អវតក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា (D308/3/1/9) ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧ ឯកសារ D308/3/1/18។

[1394] សំណុំរឿង ០០៤/០១ សារណារបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D308/3/1/9 កថាខណ្ឌ ១៦-១៧, ៣១-៣២។

[1395] សំណុំរឿង ០០៤/០១ ប្រតិចារឹក ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧ D308/3/1/19/1.1។ សំណុំរឿង ០០៤/០១ ប្រតិចារឹក ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៧ ឯកសារ D308/3/1/19.1.2។ សំណុំរឿង ០០៤/០១ ប្រតិចារឹក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ឯកសារ D308/3/1/19/2.1។

[1396] សំណុំរឿង ០០៤/០១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២៣-២៧ ("សេចក្ដីពិចារណា អ.ប.ជ.")។

[1397] សំណុំរឿង ០០៤/០១ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២៨-៣១។

[1398] សំណុំរឿង ០០៤/០១ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ៣២-៣៥។

ប្រកាន់ពីបទព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹង អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤[1399]។ (៤) សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការវាយតម្លៃលើភាពអាចជឿជាក់បាន និងតម្លៃជាភស្តុតាង[1400] និង (៥) សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការបកស្រាយច្បាប់ អ.វ.ត.ក. ថាបានដកហូតពីតុលាការកម្ពុជាធម្មតានូវយុត្តាធិការរបស់ពួកគេទៅលើឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម[1401]។ ទោះជាយ៉ាងណា ចៅក្រមអង្គបុរេជំនុំជម្រះ មិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ដែលនាំឱ្យមានការលើកលែងការចោទប្រកាន់[1402]។ បន្ទាប់មកអង្គបុរេជំនុំជម្រះបានបង្ហាញយោបល់របស់សមាជិកផ្សេងៗរបស់ខ្លួន។

ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី បានកត់សម្គាល់ថា យុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានកំណត់ត្រឹមតែជនទាំងឡាយណា ដែលជាមេដឹកនាំជាន់ខ្ពស់ ឬអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្ម ហើយពួកគាត់មិនយល់ឃើញថា អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. នោះទេ និងបានតម្កល់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានលើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់[1403]។

ទាក់ទងនឹងមូលដ្ឋានទីមួយ និងទីពីរនៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចៅក្រម Baik Kang Jin និងចៅក្រម Olivier Beauvallet បានផ្តល់ទស្សនៈថា អំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថាសហចៅក្រមស៊ើបអង្កេត ខកខានក្នុងការធ្វើការសម្រេចផ្នែកច្បាប់ត្រឹមត្រូវ ទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងទីតាំងឧក្រិដ្ឋកម្មជាច្រើន គប្បីត្រូវបានតម្កល់ និងថាសហចៅក្រមស៊ើបអង្កេតខកខានក្នុងការពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងអស់នេះ និងក្នុងការវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទាំងនោះ[1404]។

ពួកគាត់បានពិចារណាទៀតថា សហចៅក្រមស៊ើបអង្កេតមានកំហុសអង្គច្បាប់ តាមរយៈការខកខានមិនបានស៊ើបអង្កេត និងធ្វើការសម្រេចលើការចោទប្រកាន់ ដែលពួកគាត់បានទទួលយកមកពិនិត្យ ដែលរួមមានទីតាំងឧក្រិដ្ឋកម្មដែលមិនបានចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម និងមិនបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន[1405]។ ពួកគាត់បានពិចារណាថា សហចៅក្រមស៊ើបអង្កេតមានកំហុសតាមរយៈការស្វែងរកឱ្យមានការបង្ហាញចំនួនត្រឹមត្រូវ និងច្បាស់លាស់នៃជនរងគ្រោះសម្រាប់ទីតាំងឧក្រិដ្ឋកម្មដែលមិនបានចោទប្រកាន់[1406]។ ដោយយោងទៅលើកំហុសទាំងអស់នេះ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិនិត្យថាតើ ការចោទប្រកាន់អំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅតាមទីតាំងទាំងអស់នេះ ត្រូវបានដោះស្រាយយ៉ាងសមស្របទៅនឹងបទដ្ឋានដែលត្រូវការ សម្រាប់ការវាយតម្លៃលើភស្តុតាង[1407]។ ពួកគាត់បានផ្តល់យោបល់ទាំងស្មាក់ស្មើរថា ការចោទប្រកាន់នៅការដ្ឋានទំនប់ត្រពាំងថ្ម វត្តព្រះនេត្រព្រះ និងទីតាំងពាក់ព័ន្ធ មន្ទីរសន្តិសុខភ្នំមិចក្រី និងទីតាំងសម្លាប់មនុស្សភូមិតារ៉ុត និងមន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្សវត្តចំការខ្នុរ គប្បីត្រូវបានដាក់បញ្ចូលក្នុងបទចោទប្រកាន់ និងត្រូវបានពិចារណាត្រឹមត្រូវ នៅក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. លើ អ៊ឹម ចែម[1408]។

ទាក់ទងនឹងមូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ យល់ស្របជាមួយនឹងអំណះអំណាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនបានកំណត់ធាតុផ្សំគតិយុត្តិមិនត្រឹមត្រូវចំពោះចេតនា *ជាមុន* ការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់នោះគឺថា

---

[1399] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ៣៦-៤០។
[1400] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ៤១-៦៣។
[1401] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ៦៤-៨០។
[1402] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 ផ្នែកសម្រេចសេចក្តី។
[1403] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ៩០, ៩២។
[1404] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ១៤២, ១៦០, ១៧២, ១៧៩, ១៩៤, ២០១, ២១១។
[1405] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២១២-២១៣។
[1406] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២១៤។
[1407] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២១៥។
[1408] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២១៦-២៤៨។

មានមូលដ្ឋានដ៏សមហេតុក្នុងការជឿជាក់ថា អ៊ឹម ចែម មាន*ចេតនាឧក្រិដ្ឋ*ដែលចាំបាច់សម្រាប់បទឧក្រិដ្ឋនៃការសម្លាប់រង្គាល[1409]។

ពាក់ព័ន្ធនឹងមូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តមិនត្រឹមត្រូវចំពោះនិយមន័យនៃឧក្រិដ្ឋកម្មសម័យទំនើប នៃការបាត់ខ្លួនដោយបង្ខំ ជំនួសឱ្យធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងថា ប្រសិនបើធាតុផ្សំច្បាប់ត្រឹមត្រូវនៃអំពើអមនុស្សធម៌ផ្សេងៗទៀតត្រូវបានអនុវត្តនោះ គ្មានអ្នកវិនិច្ឆ័យដោយមិនលម្អៀងណាមួយអាចរកឃើញថា ភស្តុតាងពុំមានគ្រប់គ្រាន់បង្ហាញអំពីអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការបាត់ខ្លួនដោយបង្ខំនៅការដ្ឋានប្រឡាយស្ពានស្រែង និងមន្ទីរសន្តិសុខភ្នំត្រយោង និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម[1410]។

ជាចុងក្រោយ ទាក់ទងនឹងមូលដ្ឋានទីប្រាំនិងទីប្រាំមួយនៃបណ្តឹងឧទ្ធរណ៍ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានផ្តល់យោបល់ថា សហចៅក្រមស៊ើបអង្កេតមានកំហុស ក្នុងការសន្និដ្ឋានថា មានភស្តុតាងមិនគ្រប់គ្រាន់បញ្ជាក់ថា អ៊ឹម ចែម បានកាន់មុខតំណែងជាលេខាស្រុកកោះអណ្តែត និងជាសមាជិកគណៈកម្មាធិការតំបន់ ១៣ ដែលមានផលប៉ះពាល់ពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គាត់ ចំពោះទីតាំងឧក្រិដ្ឋកម្មនៅក្នុងភូមិភាគនិរតី[1411]។

ចុងក្រោយ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានសន្និដ្ឋានថា តាមការយល់ឃើញរបស់ពួកគាត់ តាមរយៈការអនុវត្តនិយមន័យត្រឹមត្រូវនៃឧក្រិដ្ឋកម្ម និងបទដ្ឋាននៃភស្តុតាងដែលត្រូវការ ការវាយតម្លៃលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានលើកឡើង ឬបានចោទប្រកាន់ និងការវាយតម្លៃត្រឹមត្រូវលើតួនាទី និងការទទួលខុសត្រូវរបស់ អ៊ឹម ចែម វាអាចកំណត់បានថា អ៊ឹម ចែម ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.[1412]។

### ៥.៣.៣.៥.៦. ការបញ្ចប់កិច្ចដំណើរការនីតិវិធី

ដោយសារតែសហចៅក្រមស៊ើបអង្កេតបានលើកលែងការចោទប្រកាន់រួមគ្នា ប្រឆាំងនឹង អ៊ឹម ចែម ហើយចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រលើសលប់ដែលត្រូវការ ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ អង្គបុរេជំនុំជម្រះបានប្រកាសជាឯកច្ឆន្ទថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតមានសុពលភាពអនុវត្ត ពោលគឺរឿងក្តីត្រូវលើកលែងការចោទប្រកាន់[1413]។ ចំណុចនេះបានបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/០១ ប្រឆាំងនឹង អ៊ឹម ចែម។

### ៥.៣.៣.៦. ការបំបែកកិច្ចដំណើរការនីតិវិធីរឿងក្តី អោ អាន និងការបង្កើតសំណុំរឿង ០០៤/០២

នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីថា ពួកគាត់យល់ឃើញថាកិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន ត្រូវបិទបញ្ចប់ហើយ[1414]។ នៅថ្ងៃដដែលនោះ ពួកគាត់បានបំបែករឿងក្តី អោ អាន ចេញពីការស៊ើបអង្កេតសំណុំរឿង ០០៤ ដែលកំពុងធ្វើ និងបានបង្គាប់ឱ្យមានការបង្កើតសំណុំរឿង ០០៤/០២ ថ្មី សម្រាប់ អោ អាន[1415]។ សហចៅក្រមស៊ើអង្កេតអន្តរជាតិ បានសម្រេចកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតបន្ថែមទៀត ដោយដកចេញអង្គហេតុពាក់ព័ន្ធនឹងការចាប់ខ្លួន និងការសម្លាប់ជនជាតិចាម នៅក្នុងភូមិភាគបូព៌ា[1416]។

---

[1409] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២៦៣។
[1410] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២៧០-២៨២។
[1411] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ២៨៣, ២៩២-៣២០។
[1412] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 កថាខណ្ឌ៣២១-៣៣៩។
[1413] សំណុំរឿង ០០៤/០១ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ D308/3/1/20 ផ្នែកសម្រេចសេចក្តី។
[1414] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334។
[1415] សំណុំរឿង ០០៤ ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D334/1។
[1416] សំណុំរឿង ០០៤/០២ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D337។

### ៥.៣.៣.៦.១. ដីកាសន្និដ្ឋានស្ថាពរ

បន្ទាប់ពីដោះស្រាយសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមរួចហើយ[1417] សហចៅក្រមស៊ើបអង្កេតបានចេញសេចក្ដីជូនដំណឹងជាលើកទីពីរ អំពីការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន[1418]។ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅឱ្យសហព្រះរាជអាជ្ញា ដើម្បីឱ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពរ[1419]។ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំឱ្យលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង អោ អាន[1420] ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិវិញបានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំឱ្យចោទប្រកាន់ និងបញ្ជូនខ្លួន អោ អាន ទៅជំនុំជម្រះ[1421]។

### ៥.៣.៣.៦.២. ដីកាដំណោះស្រាយ

នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីថា ពួកគាត់ពិចារណាឃើញថា ដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ជារួមត្រូវបានអនុញ្ញាតតាមច្បាប់ជាធរមាន[1422] ហើយពួកគាត់បានធ្វើកំណត់ហេតុបញ្ហាខ្វែងយោបល់ទាក់ទងនឹងការចេញដីកាដំណោះស្រាយផ្ទុយគ្នានៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ ប៉ុន្តែមិនបានបញ្ជូនបញ្ហាខ្វែងយោបល់នេះ ទៅអង្គបុរេជំនុំជម្រះនោះទេ[1423]។

---

1417 ទាក់ទងនឹងកិច្ចស៊ើបសួរដែលស្នើសុំដោយមេធាវីការពារក្ដី សូមមើល សំណុំរឿង ០០៤/០២៖ ដីកាសម្រេចរួមលើសេចក្ដីកែសម្រួលសំណើទី១ សំណើទី៨ និងសំណើទី១១ សុំបំពេញកិច្ចស៊ើបសួររបស់ អោ អាន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D326។ ដីកាសម្រេចលើសេចក្ដីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ២ របស់ អោ អាន ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D188/1/1។ ដីកាសម្រេចលើសេចក្ដីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៣ របស់ អោ អាន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ឯកសារ D189/2។ ដីកាសម្រេចលើសេចក្ដីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី៤ របស់ អោ អាន ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ឯកសារ D244/1។ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៥ របស់ អោ អាន ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D260/1។ ដីកាសម្រេចលើសំណើទីប្រាំមួយរបស់ អោ អាន សុំឲ្យបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ឯកសារ D276/1។ ដីកាសម្រេចលើសំណើលើកទីប្រាំរបស់ អោ អានសុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D277/1។ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៩ របស់ អោ អាន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ D300/2។ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ លើកទិដប់របស់ អោ អាន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D311/1។ ដីកាសម្រេចលើកទី១២របស់ អោ អាន សុំបំពេញកិច្ចស៊ើបសួរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D320/1។ ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៣ របស់ អោ អាន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ ឯកសារ D345/1។ ទាក់ទងនឹងកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ សូមមើល សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរដើម្បីដាក់ផែនទី និងសម្ភារៈពីសំណុំរឿង ០០២ ទៅក្នុងសំណុំរឿង ០០៤/០២ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ឯកសារ D342/1។ សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿង ០០៤ និងការទទួលខុសត្រូវរបស់ អោ អាន ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D41/2។ ដីកាសម្រេចរួមលើសំណើសុំកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ និង បង្កឲ្យមានផ្ទៃពោះដោយបង្ខំ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D301/5។ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ឯកសារពាក់ព័ន្ធនឹងអំពើហិង្សាផ្លូវភេទ ឬយ៉េនឌ័រ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំចូលទៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D310/1។ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងសាក្សីបីនាក់ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ D314/1។

1418 សំណុំរឿង ០០៤/០២ សេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ឯកសារ D334/2។

1419 សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ D360 កថាខណ្ឌ ១០។

1420 សំណុំរឿង ០០៤/០២ ដីកាសន្និដ្ឋានស្ថាបពរ ទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/4។

1421 សំណុំរឿង ០០៤/០២ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/5។

1422 សំណុំរឿង ០០៤/០២ ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D355/1 កថាខណ្ឌ១៣-១៦។

1423 សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ១០, ៩៩។

សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាដំណោះស្រាយលើកលែងការចោទប្រកាន់រឿងក្តីនេះ[1424]។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ បានរកឃើញថា តួនាទីរបស់ អោ អាន ជាលេខាតំបន់ ៤១ នៃភូមិភាគកណ្តាល មានរយៈពេលខ្លីប៉ុណ្ណោះ គាត់មិនត្រូវបានតែងតាំងជាផ្លូវការ គាត់បានធ្វើការតាមបញ្ជានិងការណែនាំរបស់ កែ ពក ដែលមានអំណាចនិងឥទ្ធិពល និងជាមនុស្សតែម្នាក់គត់នៅថ្នាក់ភូមិភាគដែលរួចជីវិតពីការបោសសម្អាតភូមិភាគកណ្តាល[1425]។ សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា ការចូលរួមរបស់ អោ អាន នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មគឺ “មិនមានស្វ័យភាព” “មិនសកម្ម” និង “មិនផ្ទាល់” និងថា គាត់មិនបានចូលរួមក្នុងការបង្កើតគោលនយោបាយ ប.ក.ក.[1426]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតជាតិពិចារណាឃើញថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើ អោ អាន ទេ និងបានលើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់[1427]។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញដីកាដំណោះស្រាយ ចោទប្រកាន់ អោ អាន និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1428]។ គាត់បានបញ្ជូន អោ អាន ទៅជំនុំជម្រះពីបទ៖ (១) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងជនជាតិចាម នៅខេត្តកំពង់ចាម (២) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅ (i) ទីតាំងពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ (ii) ទីតាំងសម្លាប់មនុស្សគោកព្រីង (iii) មន្ទីរសន្តិសុខមិត្តសុប (iv) មន្ទីរសន្តិសុខទួលបេង និងវត្តអង្គញ្ចី (v) មន្ទីរសន្តិសុខវត្តអូរត្រកួន (vi) មន្ទីរសន្តិសុខវត្តបាធាយ (vii) ទីតាំងសម្លាប់មនុស្សវត្តភ្នំប្រុស (viii) មន្ទីរសន្តិសុខវត្តតាមាក (ix) ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម និងព្រៃឈរ តំបន់ ៤១ និង (x) ការរំលោភលើក្រុមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ទាក់ទងនឹងបទមនុស្សឃាតគិតទុកជាមុន[1429]។

### ៥.៣.៣.៦.៣. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

មនុស្សចំនួន ១.៩២០ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០៤/០២[1430]។ នៅថ្ងៃដដែលនោះដែរ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយដាច់ដោយឡែក ដែលពួកគាត់ម្នាក់ៗបានចេញសេចក្តីសម្រេចផ្សេងគ្នាលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហចៅក្រមស៊ើបអង្កេតជាតិបានចេញដីកាបដិសេធពាក្យសុំទាំងនោះ ដោយសារគាត់យល់ឃើញថារឿងក្តីត្រូវបានលើកលែងការចោទប្រកាន់ ចំណែកឯសហចៅក្រមស៊ើបអង្កេតអន្តរជាតិវិញ បានចេញសេចក្តីសម្រេចទទួលយកអ្នកដាក់ពាក្យចំនួន ៤៣៤ នាក់ និងបដិសេធអ្នកដាក់ពាក្យផ្សេងទៀត[1431]។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធពាក្យសុំរបស់ខ្លួន[1432] ប៉ុន្តែចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការ ដើម្បីធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍[1433] ដូច្នេះទុកឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះមិនមានចម្លើយច្បាស់លាស់អំពីថា

---

[1424] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359។

[1425] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 កថាខណ្ឌ៥៥២-៥៥៣។

[1426] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 កថាខណ្ឌ ៥៥៣។

[1427] សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D359 កថាខណ្ឌ៥៥៤-៥៥៥។

[1428] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360។

[1429] សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 ជំពូក១៤។

[1430] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 កថាខណ្ឌ៣។

[1431] សំណុំរឿង ០០៤/០២ ដីកាសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D361។ សំណុំរឿង ០០៤/០២ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D362។

[1432] សំណុំរឿង ០០៤/០១ បណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D362/5។

[1433] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6។

នៈរបស់ខ្លួន។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ បានលើកឡើងថា ពួកគាត់បានសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/០២ ដោយសារតែពួកគាត់យល់ឃើញថាសេចក្តីសម្រេចលើកលែងចោទប្រកាន់រឿងក្តីនេះគប្បីត្រូវតម្កល់ ចំណែកឯចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះវិញបានលើកឡើងថា ពួកគាត់បានបដិសេធដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រង់ផ្នែកខ្លះដើម្បីទទួលយកអ្នកដាក់ពាក្យបន្ថែមប្រាំបីនាក់ ក្នុងចំណោមអ្នកដាក់ពាក្យដែលត្រូវបានបដិសេធ[1434]។

### ៥.៣.៣.៦.៤. បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

សហព្រះរាជអាជ្ញាជាតិបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធរឿងក្តីប្រឆាំងនឹង អោ អាន ដោយសារមិនមានយុត្តាធិការបុគ្គល[1435]។ សហព្រះរាជអាជ្ញាជាតិ បានតវ៉ាថា ដោយសារតែ អោ អាន មិនមានស្វ័យភាព ឬសិទ្ធិអំណាច*តាមព្រឹត្តន័យ* ដូច្នេះ អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើរូបគាត់ទេ[1436]។

អោ អាន ក៏បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះផងដែរ ដោយលើកឡើងនូវមូលដ្ឋានបណ្តឹងឧទ្ធរណ៍ចំនួន ១៨ មូលដ្ឋានទីមួយនោះគឺថាការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាគឺមិនស្របទៅនឹងច្បាប់ អ.វ.ត.ក. និងបានរំលោភលើសិទ្ធិជាសារវន្តរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងគោលការណ៍ស្តីពីភាពប្រាកដប្រជាផ្នែកច្បាប់។ គាត់បានស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងចោទប្រកាន់រឿងក្តីនេះ[1437]។

សហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់[1438]។ គាត់បានតវ៉ាថា កំហុសអង្គហេតុ និងអង្គច្បាប់បានធ្វើឱ្យដីកាសម្រេចលើកលែងចោទប្រកាន់ទៅជាមោឃៈ ដែលរួមមាន៖

(១) ខកខានមិនបានធ្វើការសន្និដ្ឋានណាមួយថាតើ ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ត្រូវបានធ្វើឡើងដែរឬទេ និងថាតើ អោ អាន មានការទទួលខុសត្រូវណាមួយចំពោះឧក្រិដ្ឋកម្មទាំងនោះដែរឬទេ (កំហុសអង្គច្បាប់)។ (២) ការផ្តល់ស្លានទម្ងន់មិនត្រឹមត្រូវក្នុងការវាយតម្លៃរបស់ខ្លួនអំពីយុត្តាធិការបុគ្គល ចំពោះពេលខ្លះការសន្និដ្ឋានមិនត្រឹមត្រូវ ឬមិនពេញលេញទាក់ទងនឹងកម្រិតដែល អោ អាន បានធ្វើតាមបញ្ជាថ្នាក់លើ និង/ឬ ប្រព្រឹត្តអំពើក្រោមការបង្ខិតបង្ខំ ឬការគំរាមកំហែង (កំហុសអង្គហេតុ និងអង្គច្បាប់)។ (៣) ការបកស្រាយច្បាប់ អ.វ.ត.ក. ខុស ដោយសន្និដ្ឋានថា ប្រភេទនៃ “ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះ

---

[1434] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ឯកសារ D362/6 កថាខណ្ឌ៤៣, ១១៧។

[1435] សំណុំរឿង ០០៤/០២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/8/1 កថាខណ្ឌ៩៨។

[1436] សំណុំរឿង ០០៤/០២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/8/1 កថាខណ្ឌ៨៣-៩៧។

[1437] សំណុំរឿង ០០៤/០២ បណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងសេចក្តីសម្រេចលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D360/5/1 កថាខណ្ឌ១-៦។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D359/3/4។ សំណុំរឿង ០០៤/០២ ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩ ឯកសារ D360/11។

[1438] សំណុំរឿង ០០៤/០២ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D359/3/1។ សូមមើលផងដែរ សំណុំរឿង ០០៤/០២ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អានប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D360/9។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០៤/២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ឯកសារ D360/10។ សំណុំរឿង ០០៤/០២ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹង បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩ ឯកសារ D359/3/5។

ឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាចសំដៅតែទៅលើ កាំង ហ្គេកអ៊ាវ (“ឌុច”) (កំហុសអង្គច្បាប់)។ (៤) ការវាយតម្លៃខុសអំពីភាពអាចជឿជាក់បាននៃភស្តុតាងក្នុងសំណុំរឿង (កំហុសអង្គហេតុ)។ (៥) ការសន្និដ្ឋានផ្អែកអង្គហេតុមួយចំនួនដែលមិនសមហេតុផល ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរលើការកំណត់យុត្តាធិការបុគ្គល និង (៦) ការខកខានមិនបានពិចារណាឱ្យបានដិតដល់អំពីផលប៉ះពាល់សំខាន់នៃឆន្ទៈរបស់ អោ អាន និងការចូលរួមសំខាន់ៗក្នុងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ជាកត្តាមួយដែលគួរត្រូវបានពិចារណាក្នុងការវាយតម្លៃថាតើ អ៊ោ អាន ស្ថិតនៅក្នុងប្រភេទយុត្តាធិការជាជនទាំងឡាយ “ដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មរបបកម្ពុជាប្រជាធិបតេយ្យឬទេ[1439]។

សវនាការស្ដាប់អំណះអំណាងផ្ទាល់មាត់បានធ្វើនៅថ្ងៃទី១៩ ដល់ ២១ ខែមិថុនា ឆ្នាំ២០១៩[1440]។ អង្គបុរេជំនុំជម្រះបានចេញរបាយការណ៍សាធារណៈអំពីសំណុំរឿង និងបណ្ដឹងឧទ្ធរណ៍[1441]។

### ៥.៣.៣.៦.៥. សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

អង្គបុរេជំនុំជម្រះបានពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន រួមបញ្ចូលគ្នា[1442]។

ជាបឋម អង្គបុរេជំនុំជម្រះបានពិភាក្សាអំពីសិទ្ធិអំណាចរបស់ខ្លួនលើដំណាក់កាលស៊ើបអង្កេតដែលខ្លួនយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការយល់ច្រឡំ និងបានលើកឡើងថា អង្គបុរេជំនុំជម្រះបានបំពេញមុខងារជាតុលាការស៊ើបអង្កេតថ្នាក់ទីពីរ និងមានសិទ្ធិអំណាចចុងក្រោយលើដំណាក់កាលស៊ើបអង្កេត។ ដូច្នេះ អង្គបុរេបានពិភាក្សាអំពីអំណាចក្នុងការពិនិត្យរបស់ខ្លួន ក្នុងនាមជាតុលាការស៊ើបអង្កេតថ្នាក់ទីពីរ និងវិសាលភាពនៃអំណាចក្នុងការពិនិត្យរបស់ខ្លួននៅក្នុងរឿងក្ដីបច្ចុប្បន្ន ក៏ដូចជាគោលជំហររបស់ អ.វ.ត.ក. នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា[1443]។ អង្គបុរេបានកត់សម្គាល់ថា មានការពន្យារពេលច្រើនហួសហេតុក្នុងការចេញដីកាដំណោះស្រាយ[1444] និងបានជំទាស់ទៅនឹង “សេចក្ដីពិចារណាលើភស្តុតាង” នៅក្នុងដីកាដំណោះស្រាយទាំងពីរ ដោយបានរំលឹកថា ខ្លួនបានដោះស្រាយបញ្ហានេះរួចហើយនៅក្នុងសំណុំរឿង ០០៤/០១ និងថាច្បាប់ជាធរមាន និងយុត្តិសាស្ត្រ មិនបានប្រមើលមើលពីការពិចារណាលើភស្តុតាង ដែលសហចៅក្រមស៊ើបអង្កេតបានប្រើនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ[1445]។ បន្ទាប់មក អង្គបុរេជំនុំជម្រះបានពិភាក្សាលើការចេញដំណាលគ្នានូវដីកាដំណោះស្រាយផ្ទុយគ្នា ដែលខ្លួនចាត់ទុកថាបានរំលោភលើក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក. និង “ធ្វើឱ្យខូចដល់មូលដ្ឋានគ្រឹះនៃការិយាល័យតុលាការរបស់ [សហចៅក្រមស៊ើបអង្កេត]”[1446]។ អង្គបុរេជំនុំជម្រះបានរិះគន់សហចៅក្រមស៊ើបអង្កេត ចំពោះការទុកចោលបញ្ហាខ្វែងយោបល់របស់ខ្លួន ទាក់ទងនឹងយុត្តាធិការបុគ្គលមិនមានដំណោះស្រាយ ជាជាងដាក់

---

[1439] សំណុំរឿង ០០៤/០២ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន (D359) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ D359/3/1 កថាខណ្ឌ២។

[1440] សំណុំរឿង ០០៤/០២ ប្រតិចារឹក ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/8.1 & D360/17.1។ សំណុំរឿង ០០៤/០២ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/9.1 & D360/18.1។ សំណុំរឿង ០០៤/០២ ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/10.1 & D360/19.1។

[1441] សំណុំរឿង ០០៤/០២ របាយការណ៍អំពីរឿងក្ដី និងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D359/7 & D360/16។

[1442] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ២៤-២៧ (“សេចក្ដីពិចារណា អ.ប.ជ.”)។

[1443] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ៣៤-៥៩។

[1444] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ៦០-៧២។

[1445] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ៧៣-៨៧។

[1446] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ៨៨-១២៤។

បញ្ហាខ្វែងយោបល់នោះមកអង្គបុរេជំនុំជម្រះដើម្បីធ្វើការដោះស្រាយ តាមរយៈនីតិវិធីដែលមានចែងក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក.[1447]។

ក្រោយមក អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិអាចទទួលយកបាន ព្រមទាំងផ្នែកខ្លះនៃបណ្តឹងឧទ្ធរណ៍របស់ អោ អាន[1448]។ យ៉ាងណាមិញ ចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចឯកភាពគ្នាលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ទាំងនេះ និងមិនអាចរកបានសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការ ដើម្បីធ្វើសេចក្តីសម្រេច ហើយបានបង្ហាញយោបល់របស់ខ្លួនដូចខាងក្រោម[1449]។

ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ បានបង្ហាញយោបល់របស់ខ្លួន ជាដំបូងបានពិភាក្សាអំពីប្រវត្តិសំណុំរឿង ០០៤ ដោយកត់សម្គាល់ថា ការស៊ើបអង្កេតបឋមក្នុងសំណុំរឿង ០០៣ និង ០០៤ ត្រូវបានធ្វើឡើង "ជាសម្ងាត់ និងជាឯកតោភាគី" ដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងថាភាពចម្រូងចម្រាសនៅក្នុងរឿងក្តី អោ អាន បានបន្តរហូតដល់ពេលចេញដីកាដំណោះស្រាយផ្ទុយគ្នា[1450]។ បន្ទាប់មកពួកគាត់បានពិភាក្សាអំពីការបង្កើត អ.វ.ត.ក. និងគោលបំណងរបស់វា និងអត្ថន័យនៃពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" និងបានសម្រេចថា សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. ប្រាំពីរនាក់គឺជា "មេដឹកនាំជាន់ខ្ពស់" និងថា ឌុច ស្ថិតនៅក្នុងប្រភេទ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[1451]។ ពួកគាត់យល់ឃើញថា ការប្តឹងប្រឆាំងនឹងបុគ្គលផ្សេងទៀតគឺជាការរំលោភលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា និងបានចាត់ទុកថា ការស៊ើបអង្កេតបឋមដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិគឺខុសច្បាប់ ដូច្នេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលផ្អែកលើលទ្ធផលនៃការស៊ើបអង្កេតខុសច្បាប់គឺមិនមានសុពលភាពទេ[1452]។ ពួកគាត់យល់ឃើញថា ដីកាសម្រេចលើកលែងចោទប្រកាន់គប្បីត្រូវតម្កល់[1453]។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានពិចារណាលើសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ និងបានផ្តល់យោបល់ថា មានតែដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះមានសុពលភាព ពីព្រោះសហចៅក្រមស៊ើបអង្កេតម្នាក់អាចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពតែម្នាក់ឯង យោងតាមច្បាប់ជាធរមាន ប៉ុន្តែការចេញដីកាសម្រេចលើកលែងចោទប្រកាន់ដំណាលគ្នា ដោយមិនបានបញ្ជូនមកអង្គបុរេជំនុំជម្រះគឺ *អនុវត្តហួសសិទ្ធិអំណាចគតិយុត្ត* ដូច្នេះហើយមិនមានសុពលភាពទេ[1454]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ យល់ឃើញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានប្រព្រឹត្តកំហុស ឬបានរំលោភបំពានទៅលើការប្រើប្រាស់ឆន្ទានុសិទ្ធិ ដែលជាកត្តាកំណត់ជាមូលដ្ឋាន ក្នុងការសម្រេចថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នោះទេ ហេតុដូច្នេះហើយចៅក្រមអន្តរជាតិបានលើកឡើងថា ខ្លួននឹងតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងយល់ឃើញថា អោ អាន ស្ថិតនៅក្នុងយុត្តាធិការ

---

[1447] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៩៩។

[1448] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ១២៥-១៦៨។

[1449] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ១៦៩។

[1450] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ១៧៣-១៨២។

[1451] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ១៨៣-២៥១។

[1452] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ២៥០-២៥១។

[1453] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ២៨១-២៨២។

[1454] សំណុំរឿង ០០៤/០២ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៣១៧-៣២៩។

បុគ្គលរបស់ អ.វ.ត.ក.[1455]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានលើកឡើងថា ខ្លួនបានកែប្រែបទចោទទី១ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីកំណត់ថា អោ អាន ត្រូវបានចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម នៅក្នុងខេត្តកំពង់ចាម ក្នុងភូមិភាគកណ្ដាល[1456]។

## ៥.៣.៣.៦.៦. ការបញ្ចប់កិច្ចដំណើរការនីតិវិធី

សំណុំរឿង ០០៤/០២ តាមកាលប្បវត្តិគឺជារឿងក្ដីដំបូង ដែលភាគីបានលើកពីផលវិបាកនៃសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ បន្ទាប់ពីការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា[1457]។ សហព្រះរាជអាជ្ញាអន្តរជាតិបានត្រៀមរៀបចំសម្រាប់ការជំនុំជម្រះ តាមរយៈការដាក់សំណើទៅអង្គជំនុំជម្រះសាលាដំបូង សុំពន្យារពេលដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ និងកិច្ចប្រជុំរៀបចំសវនាការ[1458]។ បន្ទាប់មក អោ អាន បានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យធ្វើការបញ្ជាក់ថាតើ សំណុំរឿង ០០៤/០២ បានប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូងដែរឬទេ ឬ សុំឱ្យផ្តល់ការណែនាំដើម្បីឱ្យគាត់អាចដាក់អញ្ញត្រកម្ម[1459]។

ដោយសារតែមិនមានការដាក់ឯកសារណាមួយបញ្ជូនទៅកាន់អង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងទៅកាន់ភាគីនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានប្រគល់អនុស្សរណៈអន្តរការិយាល័យដោយផ្ទាល់ទៅឱ្យការិយាល័យរដ្ឋបាល ស្ដីពីវឌ្ឍនភាពនៃសំណុំរឿង ០០៤/០២ ដោយបង្ហាញអំពីការព្រួយបារម្ភរបស់ខ្លួន និងបានស្នើសុំការិយាល័យរដ្ឋបាលឱ្យអនុវត្តវិធានការរដ្ឋបាល ដើម្បីបន្តដំណើរការរឿងក្ដីទៅមុខ និង/ឬ ព្យាយាមដោះស្រាយបញ្ហាពន្យារពេលនេះ[1460]។ ការិយាល័យរដ្ឋបាលបានឆ្លើយតបថា "ខ្លួនអាចអនុវត្តសកម្មភាពតុលាការបានតែតាមការណែនាំ ឬការបង្គាប់របស់អង្គជំនុំជម្រះដែលបានទំនាក់ទំនងដោយក្រឡាបញ្ជីរបស់ពួកគេប៉ុណ្ណោះ" ហើយដូច្នេះខ្លួនបាន "បំពេញបានយ៉ាងត្រឹមត្រូវ នូវរាល់កិច្ចការដែលទាក់ទងនឹងបរិបទនេះ"[1461]។

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីការទទួលឯកសារទាំងអស់ ដែលបានផ្ញើមកដោយភាគីកន្លងមក ដូច្នេះកត់សម្គាល់ថា ទាំងសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ និងទាំងសំណុំរឿង ក៏ដូចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនត្រូវបានជូនដំណឹង ឬបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងទេ[1462]។ មួយសប្ដាហ៍ក្រោយមក អង្គភាពបណ្ណសារ បានទទួលការណែនាំពីរផ្ទុយគ្នាពីក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ៖ មួយឱ្យជូនដំណឹងអំពីសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ទៅអង្គជំនុំជម្រះសាលាដំបូង និងមួយទៀតឱ្យតម្កល់សំណុំរឿងទុកក្នុងបណ្ណសារ[1463]។

---

[1455] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៦៣១។

[1456] សំណុំរឿង ០០៤/០២ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ៦៣២។

[1457] ប្រវត្តិនីតិវិធីក៏ត្រូវបានរៀបរាប់លម្អិតដោយអង្គជំនុំជម្រះតុលាការកំពូលផងដែរ នៅក្នុងសេចក្ដីសម្រេចបញ្ចប់កិច្ចដំណើរការនិតិវិធីរបស់ខ្លួន។ សូមមើល សំណុំរឿង ០០៤/០២ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 ("សំណុំរឿង ០០៤/០២ សេចក្ដីសម្រេចបញ្ចប់របស់ អ.ជ.ត.ក")។

[1458] សំណុំរឿង ០០៤/០២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់ក្នុងវិធាន ៨០ និងបើកកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D363/1.1.1។ បញ្ជីសាក្សីត្រូវបានដាក់នៅពីរបីសប្ដាហ៍ក្រោយមក។ សូមមើល សំណុំរឿង ០០៤/០២ សារណារបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ អនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាមួយឧបសម្ព័ន្ធសម្ងាត់ ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ឯកសារ D363/1.1.4។

[1459] សំណុំរឿង ០០៤/០២ សំណើសុំការបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងមិនបានទទួលដោយស្របច្បាប់នូវសំណុំរឿង ០០៤/០២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D363/1.1.2។

[1460] សំណុំរឿង ០០៤/០២ ការវិវឌ្ឍនៃ សំណុំរឿង ០០៤/០២ រឿងក្ដី អោ អាន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ ឯកសារ E004/2/1.2.14។

[1461] សំណុំរឿង ០០៤/០២ អនុស្សរណៈអន្តរការិយាល័យ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ ឯកសារ E004/2/1.2.15។

[1462] សំណុំរឿង ០០៤/០២ សារអេឡិចត្រូនិកពីក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ឯកសារ D359/33.1.1 & D360/42.1.1 (ឯកសារភ្ជាប់ ២)។

[1463] សំណុំរឿង ០០៤/០២ សារអេឡិចត្រូនិកពីមន្ទីរសំណុំរឿង និងការណែនាំដាក់ឯកសារ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ឯកសារ D359/33.1.1 & D360/42.1.1 (ឯកសារភ្ជាប់ ៣-៤)។

ប្រធានអង្គបុរេជំនុំជម្រះ និងចៅក្រមអន្តរជាតិនៃអង្គបុរេ បានបញ្ជូនអនុស្សរណៈដាច់ដោយឡែកពីគ្នា ទៅកាន់ផ្នែកគ្រប់គ្រងតុលាការ ដោយមានណែនាំផ្ទុយគ្នា លើបញ្ហាថាតើត្រូវជូនដំណឹងអំពីឯកសារទៅអង្គជំនុំជម្រះសាលាដំបូង ឬយ៉ាងណា[1464]។ ការិយាល័យរដ្ឋបាលបានបញ្ជូនអនុស្សរណៈមួយទៅកាន់ប្រធានអង្គបុរេជំនុំជម្រះ ដោយលើកឡើងថា ខ្លួន "មិនមានអាណត្តិបកស្រាយសេចក្តីសម្រេចតុលាការណាមួយឡើយ និងមិនដោះស្រាយការណែនាំផ្ទុយគ្នារបស់ក្រឡាបញ្ជីនោះទេ" និងបានស្នើសុំឱ្យមាន "សេចក្តីណែនាំដែលអាចអនុវត្តបាន"[1465]។

សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សំណើមួយទៅអង្គបុរេជំនុំជម្រះ អំពាវនាវឱ្យចាត់វាល់វិធានការចាំបាច់ផ្នែករដ្ឋបាលទាំងអស់ ដើម្បីឱ្យមានការបញ្ជូនជាបន្ទាន់នូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿង ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[1466] និងបានបញ្ជូនអនុស្សរណៈស្រដៀងគ្នានេះទៅកាន់ការិយាល័យរដ្ឋបាល[1467] ដែលការិយាល័យរដ្ឋបាលបានឆ្លើយតបវិញថា ខ្លួនអនុវត្តតែកិច្ចតុលាការប៉ុណ្ណោះ បន្ទាប់ពីមានការណែនាំពីអង្គជំនុំជម្រះពាក់ព័ន្ធ[1468]។

នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានបញ្ជូនអនុស្សរណៈអន្តរការិយាល័យមួយទៅកាន់ភាគីទាំងអស់ក្នុងសំណុំរឿង ០០៤/០២ និងបានចម្លងជូនចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ នឹងក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ដោយរៀបរាប់លម្អិតអំពីភាពជាប់គាំងផ្នែករដ្ឋបាលរវាងអង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល កត់សម្គាល់ថា មានការណែនាំពីរផ្ទុយគ្នាត្រូវបានបញ្ជូនទៅអង្គភាពបណ្ណសារដោយអង្គបុរេជំនុំជម្រះ និងបានលើកឡើងថា ពួកគាត់បានធ្វើគ្រប់មធ្យោបាយដែលអាចធ្វើបាន និងថាកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដល់ទីបញ្ចប់ហើយ[1469]។

បន្ទាប់មក ប្រធានអង្គបុរេជំនុំជម្រះបានចេញអនុស្សរណៈអន្តរការិយាល័យ ទៅកាន់ភាគីទាំងអស់ថា៖ (១) អង្គបុរេបាន "បំពេញភារកិច្ចរបស់ខ្លួនរួចអស់ហើយ" និងមិនតម្រូវឱ្យចាត់វិធានការរដ្ឋបាលណាបន្ថែមទៀតទេ (២) មានតែសេចក្តីពិចារណាដែលបានឯកភាពជាឯកច្ឆន្ទប៉ុណ្ណោះមាន "អនុភាពអនុវត្តបាន" ចំណែកឯយោបល់របស់ចៅក្រមជាតិ និងអន្តរជាតិ គឺជា "យោបល់ផ្ទាល់ខ្លួន" មិនមាន "អានុភាពអនុវត្តបាន" ទេ និង (៣) អង្គបុរេជំនុំជម្រះនឹងមិនចាត់វិធានការរដ្ឋបាលណាបន្ថែមទៀត ដើម្បីជូនដំណឹង ឬបញ្ជូនសំណុំរឿងនេះឡើយ[1470]។

បន្ទាប់មកអង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីថ្លែងការមួយទៅកាន់ភាគី*ជាអាទិ៍*ថា អង្គជំនុំជម្រះមិនមានសិទ្ធិចូលមើលសំណុំរឿង និងមិនអាចចូលមើលវាបានទេ ប្រសិនបើមិនមានការជូនដំណឹង និងការបញ្ជូនសំណុំរឿងទេនោះ និងថា ការចេញសេចក្តីសម្រេចផ្លូវការមួយដោយអង្គជំនុំជម្រះសាលាដំបូងមិនអាចធ្វើទៅបានទេ។ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូង បានពន្យល់អំពីការយល់ឃើញរបស់ខ្លួនថា "ទឡ្ហីករណ៍អាចលើកឡើងបានក្នុងកាលៈទេសៈពិសេសនៃរឿងក្តីនេះ ហើយអង្គជំនុំជម្រះសាលាដំបូងមាន*សិទ្ធិអំណាចពិសេស*ក្នុងការដោះស្រាយបញ្ហាបឋមៗ ដែលភាគីបានលើកឡើង" ហើយចៅក្រមជាតិបានលើកឡើងថា ឯកសារនិងសំណើទាំងអស់ ដែលបានដាក់មកអង្គជំនុំជម្រះសាលាដំបូង នឹងត្រូវ

---

[1464] សំណុំរឿង ០០៤/០២ អនុស្សរណៈអន្តរការិយាល័យពីប្រធានអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារ D359/34 & D360/43។ សំណុំរឿង ០០៤/០២ អនុស្សរណៈអន្តរការិយាល័យពីចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ឯកសារ D359/33.1.5 & D360/42.1.5។

[1465] សំណុំរឿង ០០៤/០២ អនុស្សរណៈអន្តរការិយាល័យពីប្រធានស្តីទី និងអនុប្រធានរដ្ឋបាល ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ឯកសារ D363.1.2។

[1466] សំណុំរឿង ០០៤/០២ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលដែលតម្រូវទាំងអស់ដើម្បីបញ្ជូនសំណុំរឿង ០០៤/០២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D359/25 & D360/34។

[1467] សំណុំរឿង ០០៤/០២ អនុស្សរណៈអន្តរការិយាល័យពីសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ E004/2/1.2.16។

[1468] សំណុំរឿង ០០៤/០២ អនុស្សរណៈអន្តរការិយាល័យពីប្រធានស្តីទី និងអនុប្រធានរដ្ឋបាល ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ E004/2/1.2.17។

[1469] សំណុំរឿង ០០៤/០២ អនុស្សរណៈអន្តរការិយាល័យពីចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/36 & D360/45។

[1470] សំណុំរឿង ០០៤/០២ អនុស្សរណៈរបស់ប្រធាន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/37 & D360/46។

បង្វែរត្រឡប់ទៅវិញ ដោយប្រកាសថា "នឹងពុំមានការជំនុំជម្រះក្តីលើសំណុំរឿង០០៤/២ ពាក់ព័ន្ធ អោ អាន នៅពេលនេះ ឬនៅពេលអនាគតឡើយ"[1471]។

នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងសាទុក្ខទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ប្រឆាំងនឹង "ការរំលត់ជាធរមាន" នៃសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង[1472]។

អង្គជំនុំជម្រះតុលាការកំពូលបានទទួលយកបណ្តឹងសាទុក្ខនេះ ក្នុងគោលបំណងផ្តល់នូវភាពប្រាកដប្រជាផ្នែកច្បាប់ ការបំភ្លឺ ភាពស្ថិតស្ថេរ និងដើម្បីតម្កល់សុចរិតភាពរបស់ អ.វ.ត.ក.[1473] និងបានបញ្ចប់រឿងក្តីប្រឆាំងនឹង អោ អាន ដោយមូលហេតុមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព ដោយលើកឡើងថា អង្គបុរេជំនុំជម្រះគប្បីសម្រេចថាពុំមានដីកាដំណោះស្រាយណាមួយមានសុពលភាព ហើយមិនគួរធ្វើការពិភាក្សាណាមួយលើអង្គសេចក្តីរបស់ដីកាដំណោះស្រាយទាំងពីរនោះទេ[1474]។ អង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានទទួលសំណុំរឿង ០០៤/០២ ទេ នឹងហេតុដូច្នេះ មិនមានកំហុសក្នុងការមិនបន្តការជំនុំជម្រះប្រឆាំងនឹង អោ អាន នោះទេ[1475]។ ជាលទ្ធផល អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង "ពុំមានសិទ្ធិអំណាចធ្វើចំណាត់ការ ឬសម្រេចបញ្ហាណាមួយដែលបញ្ជូនមកចំពោះមុខខ្លួន"[1476]ឡើយ។

នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ជាផ្លូវការឱ្យបោះត្រា និងដាក់បញ្ចូលសំណុំរឿង ០០៤/០២ ទៅក្នុងបណ្ណសារ[1477]។ ចំណុចនេះបានបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/០២ ប្រឆាំងនឹង អោ អាន។

### ៥.៣.៣.៧. សំណុំរឿង ០០៤ - កិច្ចដំណើរការនីតិវិធីប្រឆាំងនឹង យឹម ទិត្យ

#### ៥.៣.៣.៧.១. ការបិទបញ្ចប់កិច្ចស៊ើបសួរ

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីអំពីការបិទបញ្ចប់កិច្ចស៊ើបសួរ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកាត់បន្ថយវិសាលភាពនៃការស៊ើបអង្កេតដោយដកចេញនូវអង្គហេតុដែលបានចោទមួយចំនួន[1478]។ បន្ទាប់ពីកិច្ចស៊ើបសួរបន្ថែម សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងលើកទីពីរ អំពីការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំងនឹង យឹម ទិត្យ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧[1479]។

---

[1471] *សេចក្តីថ្លែងការណ៍ របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក. ស្តីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន* ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០។

[1472] សំណុំរឿង ០០៤/០២ បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ឯកសារ D363/1.1.11។

[1473] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាព សំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ៦៥ ("សំណុំរឿង ០០៤/០២ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ឯកសារ")។

[1474] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ៥៣, ៧០, ៧១ (vi)។

[1475] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ៧០។

[1476] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 កថាខណ្ឌ៧០។

[1477] សំណុំរឿង ០០៤/០២ ដីកាបង្គាប់ឲ្យដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ឯកសារ D363/3។

[1478] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D358 ។ សំណុំរឿង ០០៤ ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ យោងតាមវិធានផ្ទៃក្នុង ៦៦ស្ទួន ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៧ ឯកសារ D359។

[1479] សំណុំរឿង ០០៤ សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D368។

#### ៥.៣.៣.៧.២. ដីកាសន្និដ្ឋានស្ថាពរ

សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿង ទៅឱ្យសហព្រះរាជអាជ្ញា ដើម្បីឱ្យពួកគេដាក់ដីកាសន្និដ្ឋានស្ថាពរ[1480]។ សហព្រះរាជអាជ្ញាជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរ ស្នើសុំឱ្យលើកលែងការចោទប្រកាន់ទាំងអស់ប្រឆាំងនឹង យឹម ទិត្យ[1481] ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានស្ថាពរដាច់ដោយឡែក ស្នើសុំឱ្យចោទប្រកាន់ យឹម ទិត្យ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះ[1482]។

#### ៥.៣.៣.៧.៣. ដីកាដំណោះស្រាយ

សហចៅក្រមស៊ើបអង្កេតបានចុះកំណត់ហេតុបញ្ហាខ្វែងយោបល់ ទាក់ទងនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា[1483]។ បញ្ហាខ្វែងយោបល់គ្នានេះមិនបានបញ្ជូនទៅអង្គបុរេជំនុំជម្រះនោះទេ[1484]។ មិនយូរប៉ុន្មានបន្ទាប់មក សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា[1485]។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ បានលើកលែងការចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ ផ្អែកលើមូលដ្ឋានថា យឹម ទិត្យ មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. មិនមែនជា “មេដឹកនាំជាន់ខ្ពស់” ឬ ស្ថិតក្នុងចំណោមជនទាំងឡាយ “ដែលទទួលខុសត្រូវខ្ពស់បំផុត”[1486] ចំណែកសហចៅក្រមស៊ើបអង្កេតអន្តរជាតិវិញ បានចេញដីកាដំណោះស្រាយចោទប្រកាន់ យឹម ទិត្យ និងបញ្ជូនខ្លួនគាត់ទៅជំនុំជម្រះពីបទ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[1487]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានបញ្ចប់កិច្ចស៊ើបសួរលើអង្គហេតុ ដែលពីមុនបានដកចេញពីការស៊ើបអង្កេត និងបានបដិសេធការចោទប្រកាន់ជាក់លាក់មួយចំនួនផងដែរ[1488]។ សហចៅក្រមស៊ើបអង្កេតបានចេញដីការួមគ្នាបញ្ចប់ការស៊ើបអង្កេតដែលនៅសេសសល់ក្នុងសំណុំរឿង ០០៤[1489]។

#### ៥.៣.៣.៧.៤. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

នៅក្នុងការស៊ើបអង្កេតនៃសំណុំរឿង ០០៤ ទាំងមូល មានមនុស្ស ២.០១៤ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤[1490]។ នៅថ្ងៃនោះដែរ ពួកគាត់បានចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ដោយសហចៅក្រមស៊ើបអង្កេតម្នាក់ៗចេញសេចក្តីសម្រេចដាច់ដោយឡែកពីគ្នាលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហចៅក្រមស៊ើប

---

[1480] សំណុំរឿង ០០៤ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨ ឯកសារ D378។

[1481] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានស្ថាពរពាក់ព័ន្ធនឹង យឹម ទិត្យ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ឯកសារ D378/1 កថាខណ្ឌ៣៤, ៣៦។

[1482] សំណុំរឿង ០០៤ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ប្រឆាំងនឹង យឹម ទិត្យ ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D378/2។

[1483] សូមមើល សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 កថាខណ្ឌ២១។ សំណុំរឿង ០០៤ ដីកាសម្រេចលើកលើងចោទប្រកាន់ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381 កថាខណ្ឌ១៣។

[1484] សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ១៤។

[1485] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381។ សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

[1486] សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។

[1487] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក១២។

[1488] សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ជំពូក ១០-១១។

[1489] សំណុំរឿង ០០៤ ដីកាសម្រេចបញ្ចប់កិច្ចស៊ើបសួរដែលនៅសេលសល់ទាំងអស់ក្នុងចំណោមកិច្ចស៊ើបសួរសំណុំរឿង ០០៤ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D385។

[1490] សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384 កថាខណ្ឌ២។ យ៉ាងហោចណាស់ដើមបណ្តឹងរដ្ឋប្បវេណីបួននាក់ ក្រោយមកបានដកពាក្យវិញ (សូមមើល កថាខណ្ឌ ៥, ៨)។

អង្កេតជាតិបានចេញដីកាបដិសេធពាក្យសុំទាំងអស់ ដោយសារគាត់យល់ឃើញថា រឿងក្ដីនេះត្រូវបានលើកលែងចោទប្រកាន់ ចំណែកសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាលើពាក្យសុំនីមួយៗ និងបានចេញសេចក្ដីសម្រេចទទួលយកពាក្យសុំមួយចំនួន និងបដិសេធពាក្យសុំមួយចំនួនផ្សេងទៀត[1491]។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធពាក្យសុំរបស់ពួកគេ[1492] ប៉ុន្តែចៅក្រមនៃអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការ ដើម្បីធ្វើសេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍បាន[1493] ដូច្នេះទុកឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះមិនមានចម្លើយច្បាស់លាស់អំពីឋានៈរបស់ខ្លួន។ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ បានលើកឡើងថា ពួកគាត់បានសម្រេចបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤ ដោយសារតែពួកគាត់យល់ឃើញថា សេចក្ដីសម្រេចលើកលែងចោទប្រកាន់រឿងក្ដីនេះគប្បីត្រូវតម្កល់ ចំណែកឯចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះវិញបានលើកឡើងថា ពួកគាត់បានបដិសេធដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រង់ផ្នែកខ្លះ និងបានទទួលយកអ្នកដាក់ពាក្យ ១៤ នាក់ ក្នុងចំណោមអ្នកដាក់ពាក្យដែលត្រូវបានបដិសេធ[1494]។

### ៥.៣.៣.៧.៥. បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

សហព្រះរាជអាជ្ញាជាតិបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យលើកលែងការចោទប្រកាន់ប្រឆាំងនឹង យឹម ទិត្យ ដោយសារមិនមានយុត្តាធិការបុគ្គល[1495]។ យឹម ទិត្យ បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ ដោយអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុស តាមរយៈការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា និងបានជំរុញឱ្យអង្គបុរេជំនុំជម្រះបដិសេធដីកាទាំងពីរនោះចោល[1496]។ យឹម ទិត្យ ក៏បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដាច់ដោយឡែក ដោយចោទប្រកាន់ថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសន្និដ្ឋានថា យឹម ទិត្យ ស្ថិតក្នុងចំណោមជនទាំងឡាយដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម និងបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងលើកលែងចោទប្រកាន់រឿងក្ដីប្រឆាំងនឹងរូបគាត់[1497]។ សហព្រះរាជអាជ្ញាអន្តរជាតិបានប្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ដោយអះអាងថា វាមានកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើន ដែលនាំឱ្យមានការសន្និដ្ឋានខុសយ៉ាងច្បាស់ក្រឡែតថា យឹម ទិត្យ មិនស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក.[1498]។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹង

---

[1491] សំណុំរឿង ០០៤ ដីកាបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D383។ សំណុំរឿង ០០៤ ដីកាសម្រេចលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D384។

[1492] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D384/5។

[1493] សំណុំរឿង ០០៤ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7។

[1494] សំណុំរឿង ០០៤ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D384/7 កថាខណ្ឌ៤២-៤៤, ១៣៦។

[1495] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/4/1។

[1496] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 & D382/21 កថាខណ្ឌ២០។ សូមមើលផងដែរ សំណុំរឿង ០០៤ ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/26។ សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជាអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ឯកសារ D382/29។ សំណុំរឿង ០០៤ ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D381/27 & D382/30។

[1497] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22។

[1498] សំណុំរឿង ០០៤ បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19។ សូមមើលផងដែរ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជ

ដីកាសម្រេចលើកលែងចោទប្រកាន់ដែរ ដោយសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុ ក្នុងការសន្និដ្ឋានថា យឹម ទិត្យ មិនស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក. និងលើកឡើងជាជម្រើសម្យ៉ាងទៀតថា ប្រសិនបើចៅក្រមនៃអង្គបុរេជំនុំជម្រះ មិនអាចចេញសេចក្តីសម្រេចដោយសំឡេងគាំទ្រភាគច្រើនលើសលប់ទេនោះ ក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. តម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[1499]។

អង្គបុរេជំនុំជម្រះបានសម្រេចថា ខ្លួននឹងសម្រេចលើបណ្តឹងឧទ្ធរណ៍ផ្អែកលើសារណាជាលាយលក្ខណ៍អក្សរ និងពុំមានការធ្វើអំណះអំណាងផ្ទាល់មាត់ទេ[1500]។

## ៥.៣.៣.៧.៦. សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

អង្គបុរេជំនុំជម្រះបានពិចារណាលើបណ្តឹងឧទ្ធរណ៍ទាំងប្រាំរួមគ្នា[1501]។ អង្គបុរេយល់ឃើញថា បណ្តឹងឧទ្ធរណ៍ទាំងអស់អាចទទួលយកបាន លើកលែងតែផ្នែកជាក់លាក់នៃបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[1502]។

បន្ទាប់មកអង្គបុរេជំនុំជម្រះបានពិចារណាលើបញ្ហាថាតើ ការចេញដំណាលគ្នានៃដីកាដំណោះស្រាយពីរផ្ទុយគ្នា ត្រូវបានអនុញ្ញាតដោយក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. ឬទេ[1503]។ អង្គបុរេបានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានដាក់បញ្ហាខ្វែងយោបល់គ្នាជាសម្ងាត់ ក្នុងសំណុំរឿង ០០៤ រួមបញ្ចូលទាំងទាក់ទងទៅនឹងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ប៉ុន្តែពុំមានបញ្ហាខ្វែងយោបល់គ្នាណាមួយក្នុងចំណោមបញ្ហាទាំងនេះ ត្រូវបានបញ្ជូនមកចំពោះមុខខ្លួននោះទេ[1504]។ អង្គបុរជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេត "បានប្រព្រឹត្តកំហុសលើអង្គច្បាប់ដ៏ធំធេង" ដោយសន្និដ្ឋានថា ក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក. អនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា[1505]។ អង្គបុរេជំនុំជម្រះបានយោងទៅយុត្តិសាស្ត្រក្នុងសំណុំរឿង ០០៤/០២ និងសំណុំរឿង ០០៣ ដែលពន្យល់ថា សហចៅក្រមស៊ើបអង្កេតគប្បីប្រើយន្តការដោះស្រាយវិវាទ ដែលច្បាប់ អ.វ.ត.ក. ផ្តល់ឱ្យ និងថា ការខកខានក្នុងការធ្វើដូច្នោះ ហើយបែរជាចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាវិញនោះ ពួកគាត់ "បានប្រព្រឹត្តកំហុសធ្ងន់ដែលធ្វើឱ្យប៉ះពាល់ទៅដល់មូលដ្ឋានប្រព័ន្ធចម្រុះ និងដំណើរការដោយត្រឹមត្រូវរបស់ អ.វ.ត.ក. "[1506]។ ដោយសារចៅក្រមនៃអង្គបុរេជំនុំជម្រះ មិនអាចទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ដែល

---

អាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤ (D382) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/16។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ ២០២០ ឯកសារ D382/27។ សំណុំរឿង ០០៤ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D382/28។ សំណុំរឿង ០០៤ ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់គាត់ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ប្រឆាំង យឹម ទិត្យ (D381) ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ឯកសារ D381/28។

[1499] សំណុំរឿង ០០៤ បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/20។

[1500] សំណុំរឿង ០០៤ សេចក្តីសម្រេចលើសវនាការផ្ទាល់មាត់ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/41 & D382/40។

[1501] សំណុំរឿង ០០៤ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ៣០-៣៣ ("សេចក្តីពិចារណា អ.ប.ជ.")។

[1502] សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ៣៧-៨៣។

[1503] សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ៨៤-១១៥។

[1504] សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ៩០។

[1505] សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ៩៤។

[1506] សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ៩៥-១១៥។

ត្រូវការ ដើម្បីធ្វើសេចក្តីសម្រេចលើអង្គសេចក្តី (ក្រៅពីការសន្និដ្ឋានជាឯកច្ឆន្ទលើភាពអាចទទួលយកបាន និងនីត្យានុកូលភាពនៃការចេញដីការដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា) ពួកគាត់បង្ហាញយោបល់របស់ខ្លួនដូចខាងក្រោម[1507]។

ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះផ្តល់យោបល់ថា គោលបំណងរបស់ អ.វ.ត.ក. គឺដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត[1508]។ ពួកគាត់បានរំលឹកអំពីការពិភាក្សាដេញដោលនៅចំពោះមុខរដ្ឋសភាជាតិ លើសេចក្តីព្រាងច្បាប់ អ.វ.ត.ក. ពាក់ព័ន្ធនឹងចំនួនមនុស្សដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក. និងបានកត់សម្គាល់ថា គោលបំណងពិតប្រាកដនៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីកាត់សេចក្តីបុគ្គលបួនឬប្រាំនាក់ ដែលអ្នកទាំងនោះសុទ្ធតែស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០១ និង ០០២[1509]។ ចៅក្រមបានរំលឹកថា បុគ្គលប្រាំនាក់ដែលមាននៅក្នុងរឿងក្តីទាំងនោះ ត្រូវបានទទួលស្គាល់ថាជាមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ដែលស្របទៅនឹងការពិភាក្សានៅចំពោះមុខរដ្ឋសភាជាតិ ប៉ុន្តែដូច្នេះ មិនមាននៅសល់បុគ្គលណាផ្សេងទៀតត្រូវចោទប្រកាន់ និងជំនុំជម្រះនៅចំពោះមុខ អ.វ.ត.ក. នោះទេ[1510]។ ពួកគាត់បានសន្និដ្ឋានថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតជាតិដែលថា អ.វ.ត.ក. មិនមានយុត្តាធិការបុគ្គលលើ យឹម ទិត្យ និងថា រឿងក្តីប្រឆាំងនឹងគាត់គប្បីត្រូវលើកលែងចោទប្រកាន់នោះ គឺជា "ការត្រឹមត្រូវ"[1511]។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ បានផ្តល់យោបល់ថា បើទោះបីជាការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាខុសច្បាប់ ក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានអានុភាពអនុវត្ត ចំណែកដីកាសម្រេចលើកលែងចោទប្រកាន់វិញគឺពុំមានសុពលភាពទេ អនុលោមតាម "គោលជំហរស្វ័យប្រវត្តិ"[1512]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមនីតិវិធីស្របទៅនឹងច្បាប់ជាធរមាន ចំណែកការចេញដីកាសម្រេចលើកលែងចោទប្រកាន់វិញគឺពុំមានមូលដ្ឋានគតិយុត្តិនោះទេ[1513]។ ហេតុដូច្នេះ ចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះ ផ្តល់យោបល់ថា បណ្តឹងសាទុក្ខរបស់ យឹម ទិត្យ ទាក់ទងនឹងការចេញដីកាដំណោះស្រាយពីរ និងដំណោះស្រាយដែលស្នើឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ គប្បីត្រូវបដិសេធចោល[1514]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានបន្តបដិសេធមូលដ្ឋានផ្សេងទៀតនៃបណ្តឹងឧទ្ធរណ៍ ដែលដាក់ដោយ យឹម ទិត្យ សហព្រះរាជអាជ្ញាជាតិ និងដោយសហព្រះរាជអាជ្ញាអន្តរជាតិ[1515]។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានពិចារណាថា តាមទស្សនៈរបស់ពួកគាត់ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព ចំណែកដីកាសម្រេចលើកលែងចោទប្រកាន់មិនមានសុពលភាព ហើយដូច្នេះទុកជាមោឃៈ ហើយដោយសារតែចៅក្រមនៃអង្គបុរេជំនុំជម្រះ មិនអាចរកសំឡេងគាំទ្រភាគច្រើនលើសលប់ដែលត្រូវការ ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូច្នេះសេចក្តីសម្រេចជាស្វ័យប្រវត្តិនោះគឺថា

---

1507 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១១៦។

1508 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១១៨-១២២។

1509 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១២៣។

1510 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១២៨-១២៩។

1511 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១៣១។

1512 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១៦៧។

1513 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១៦៨-១៧៥។

1514 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១៧៧។

1515 សំណុំរឿង ០០៤ សេចក្តីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១៧៨-៤៧៨, ៤៩០-៤៩៧, ៥១០, ៥១៥។

រឿងក្ដីនេះត្រូវតែប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង[1516]។ ជាចុងក្រោយពួកគាត់ធ្វើការសន្និដ្ឋានអំពីផលវិបាកដែលកើតចេញពីការខកខានរបស់ អ.វ.ត.ក. និងអាជ្ញាធរកម្ពុជា ក្នុងការចោទប្រកាន់រឿងក្ដីចុងក្រោយនៅ អ.វ.ត.ក. ប្រកបដោយប្រសិទ្ធភាព[1517]។ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គប្បីត្រូវបានគាំទ្រ ហើយរឿងក្ដីនេះគប្បីប្ដឹងទៅអង្គជំនុំជម្រះសាលាដំបូង[1518]។

### ៥.៣.៣.៧.៧. ការបញ្ចប់កិច្ចដំណើរការនិតិវិធី

សហព្រះរាជអាជ្ញាអន្តរជាតិ បានប្ដឹងសាទុក្ខប្រឆាំងនឹងការខកខានរបស់ អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះ ទៅកាន់អង្គជំនុំជម្រះតុលាការកំពូល ដោយអះអាងថា បរាជ័យរបស់អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងសហចៅក្រមស៊ើបអង្កេត ក្នុងការអនុវត្តយុត្តាធិការរបស់ពួកគេលើរឿងក្ដីនេះ បានបន្តភាពជាប់គាំងផ្នែកនីតិវិធី និងបណ្ដាលឱ្យមានព្យសនកម្មមិនអាចជួសជុលបានចំពោះរដ្ឋបាលតុលាការ ក្នុងសំណុំរឿង ០០៤។ សហព្រះរាជអាជ្ញាអន្តរជាតិបានសន្និដ្ឋានថា អង្គជំនុំជម្រះតុលាការកំពូលគប្បីបង្គាប់ឱ្យរឿងក្ដីនេះបន្តទៅជំនុំជម្រះ ពីព្រោះ៖ (១) ដីកាដំណោះស្រាយផ្ទុយគ្នាមិនត្រូវបានចេញដោយខុសច្បាប់ទេ (២) ដីកាដំណោះស្រាយផ្ទុយគ្នាមិនមោឃៈ និងគ្មានសុពលភាពឡើយ ទោះបីជាការចេញក្នុងពេលដំណាលគ្នារបស់វាខុសច្បាប់ក៏ដោយ (៣) ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសំឡេងភាគច្រើនលើសលប់ទេ (៤) សំណុំរឿង ០០៤ មិនខុសច្បាប់ទេ[1519]។

អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "បណ្ដឹងសាទុក្ខ" មិនអាចទទួលយកបានក្នុងឋានៈជាបណ្ដឹងសាទុក្ខនោះទេ ប៉ុន្តែដើម្បីផលប្រយោជន៍នៃយុត្តិធម៌ អង្គជំនុំជម្រះតុលាការកំពូលនឹងប្រើឆន្ទានុសិទ្ធិរបស់ខ្លួន និងផ្ដល់ការបំភ្លឺ និងភាពប្រាកដប្រជាផ្នែកច្បាប់ លើបញ្ហាតែមួយប៉ុណ្ណោះ គឺស្ថានភាពសំណុំរឿង ០០៤ ស្របជាមួយនឹងយុត្តិសាស្ត្ររបស់ខ្លួនក្នុងសំណុំរឿង ០០៤/០២ និង ០០៣ និងក្នុងនាមជាអង្គជំនុំជម្រះថ្នាក់ចុងក្រោយ[1520]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា ខ្លួនបានដោះស្រាយរួចហើយអំពីផលប៉ះពាល់នៃការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/០២ និងចម្លើយទៅនឹងការបញ្ជូនទៅជំនុំជម្រះក្នុងករណីមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនោះគឺ "ចម្លើយដែលច្បាស់លាស់នោះគឺថា ទេ"[1521]។ អង្គជំនុំជម្រះបានលើកឡើងថា សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤ គឺពេញលេញ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ ខកខានក្នុងការបង្ហាញមូលហេតុដែលនឹងអនុញ្ញាតឱ្យអង្គជំនុំជម្រះតុលាការកំពូល ផ្លាស់ប្ដូរគោលជំហរពីមុនរបស់ខ្លួនក្នុងសំណុំរឿង ០០៤/០២ និង ០០៣ ក្រោមកាលៈទេសៈដូចគ្នានេះ[1522]។ ជាចុងក្រោយអង្គជំនុំជម្រះបានលើកឡើងថា សំណុំរឿង ០០៤ មិនអាចបន្តនៅរ៉ាំរ៉ៃតទៅទៀតបានទេ ហើយសំណើសុំឱ្យបញ្ជូនទៅជំនុំជម្រះត្រូវបដិសេធ[1523]។

ទោះបីជាយល់ស្របជាមួយនឹងមតិភាគច្រើននៃអង្គជំនុំជម្រះតុលាការកំពូល លើលទ្ធផលនៃសេចក្ដីសម្រេចក៏ដោយ ក៏ចៅក្រម Maureen Harding Clark បានចេញយោបល់ជំទាស់ ដោយពន្យល់ថា គាត់មិនឯកភាពជាមួយនឹងសហការីរបស់គាត់ ចំពោះសំអាងផ្លូវច្បាប់សម្រាប់ការបញ្ចប់សំណុំរឿង ០០៤។

[1516] សំណុំរឿង ០០៤ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ៥២១-៥២៣។

[1517] សំណុំរឿង ០០៤ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ៥២៤។

[1518] សំណុំរឿង ០០៤ សេចក្ដីពិចារណា អ.ប.ជ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ D381/45 & D382/43 ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[1519] សំណុំរឿង ០០៤ បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ អំពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចដែលបានតម្រូវ ដោយក្របខ័ណ្ឌគតិយុត្តិ អ.វ.ត.ក. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ ឯកសារ 2។

[1520] សំណុំរឿង ០០៤ សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីពីការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការបញ្ជូនសំណុំរឿង ០០៤ ទៅជំនុំជម្រះដូចបានតម្រូវដោយក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1 កថាខណ្ឌ១៩-២៤ ("សេចក្ដីសម្រេចបញ្ចប់របស់ អ.ជ.ត.ក")។

[1521] សំណុំរឿង ០០៤ សេចក្ដីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1 កថាខណ្ឌ២៧។

[1522] សំណុំរឿង ០០៤ សេចក្ដីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1 កថាខណ្ឌ២៩។

[1523] សំណុំរឿង ០០៤ សេចក្ដីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1 កថាខណ្ឌ៣១។

គាត់យល់ឃើញថា សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ មិនមានសុពលភាព និងលើកឡើងថា សេចក្តីពិចារណានេះគប្បីត្រូវបដិសេធចោលដោយសារភាពពុំសមស្របរបស់វា។ គាត់យល់ឃើញថា កិច្ចដំណើរការនីតិវិធីគប្បីបញ្ចប់ ដោយយោងទៅលើការខ្វែងយោបល់គ្នាដែលពុំអាចសម្របសម្រួលបាន រវាងភាគីជាតិ និងភាគីអន្តរជាតិនៃដំណើរការនីតិវិធីមុនការជំនុំជម្រះ[1524]។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបង្គាប់ជាផ្លូវការឱ្យបោះត្រា និងបញ្ចូលសំណុំរឿង ០០៤ ទៅក្នុងបណ្ណសារ[1525]។ ការណ៍នេះបានបញ្ចប់កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤ ប្រឆាំងនឹង យឹម ទិត្យ។

## ៦. សំណង

ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់នៅចំពោះមុខ អ.វ.ត.ក. ចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ តាមរយៈការគាំទ្រផ្នែកអយ្យការ និងតាមរយៈការស្វែងរកចំណាត់ការរដ្ឋប្បវេណីសមស្របសម្រាប់សំណងសមូហភាព និងផ្លូវចិត្ត ប្រឆាំងនឹងជនជាប់ចោទ ចំពោះព្យសនកម្មដែលជាបច្ច័យផ្ទាល់ពីឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស[1526]។ ពាក្យ "សំណងសមូហភាព" ត្រូវបានបកស្រាយបញ្ជាក់ថា អ.វ.ត.ក. មិនផ្តល់សំណងហិរញ្ញវត្ថុជាលក្ខណៈបុគ្គល ដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មស្ថិតក្នុងយុត្តាធិការរបស់ខ្លួនឡើយ ចំណែកពាក្យ "សំណងផ្លូវចិត្ត" សំដៅលើការជួសជុលព្យសនកម្មផ្លូវចិត្ត មិនមែនជួសជុលព្យសនកម្មខាងសម្ភារៈនោះទេ[1527]។

គំនិតផ្តួចផ្តើមគម្រោងចំនួនម្ភៃប្រាំមួយត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០២ ហើយគម្រោងទាំងអស់នេះត្រូវបានពិភាក្សាខាងក្រោម។ សម្រាប់ព័ត៌មានបន្ថែមអំពីសំណើទាំងនេះ ដែលមិនត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង សូមមើលជំពូកនៅក្នុងសាលក្រមក្រោមចំណងជើងថា "សំណងដើមបណ្តឹងរដ្ឋប្បវេណី"។

### ៦.១. សំណុំរឿង ០០១

នៅក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើជាច្រើនប្រភេទពីដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែយល់ឃើញថាខ្លួន "មានការលំបាកក្នុងការបំពេញភារកិច្ចរបស់ខ្លួនចំពោះសំណើសុំនៅចំពោះមុខអង្គជំនុំជម្រះ និងប្រភេទនៃសំណង ដែលអនុញ្ញាតស្របតាមវិធានផ្ទៃក្នុង"[1528]។ អង្គជំនុំជម្រះសាលាដំបូងបានអនុម័តសំណើចំនួនពីរ[1529]។

#### ៦.១.១. ការចងក្រង និងការបោះពុម្ពផ្សាយពាក្យសម្តីសុំអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ (ហៅ ឌុច)

សំណងនេះគឺជាការបោះពុម្ពផ្សាយដែលមានពាក្យសម្តីសុំអភ័យទោស និងវិប្បដិសារី ដែល ឌុច បានថ្លែងនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០១ ទាំងមូល ចាប់ពីសេចក្តីថ្លែងបើករបស់គាត់ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩ រហូតដល់ការកត់សម្គាល់ចុងក្រោយរបស់គាត់នៅសវនាការបណ្តឹងសាទុក្ខ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១។ បន្ទាប់ពីសាលដីកាលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាការ

---

[1524] សំណុំរឿង ០០៤ សេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ឯកសារ 2/1/1/1 យោបល់ជំទាស់របស់ចៅក្រម Maureen Harding Clark។
[1525] សំណុំរឿង ០០៤ ដីកាបង្គាប់ឲ្យបញ្ចូលសំណុំរឿង០០៤ ទៅក្នុងបណ្ណសារដ្ឋាន ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ឯកសារ D388។
[1526] វិធានផ្ទៃក្នុង វិធាន ២៣(១), ២៣ស្ទួនបួន។
[1527] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១១១៥។ សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៤៤០៨-៤៤០៩។ សូមមើលផងដែរ សំណុំរឿង ០០១ សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28 កថាខណ្ឌ ៦៥៨។
[1528] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៦៦២។
[1529] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ជំពូក ៤.៤.៣។

កំពូល[1530] អ.វ.ត.ក. បានចងក្រងពាក្យសម្តីរបស់ ឌុច ដែលទទួលស្គាល់ការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខ ស-២១។ ការចងក្រងនេះមាន ២១ ទំព័រ រួមទាំងរូបថត និងត្រូវបានចែកចាយពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២។

គម្រោងសំណងនេះគឺជាលទ្ធផលមកពីសារណារួមគ្នារបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកថាពាក្យសម្តីសុំអភ័យទោសរបស់ ឌុច មានសារសំខាន់ចំពោះពួកគាត់ ក្នុងការស្វែងរកការបិទបញ្ចប់អតីតកាលដ៏ឈឺចាប់ និងដើម្បីបន្តវិថីនៃការផ្សះផ្សា។ តាមរយៈការទទួលស្គាល់ការឈឺចាប់របស់ជនរងគ្រោះជាលាយលក្ខណ៍អក្សរ ការបោះពុម្ពផ្សាយនេះចូលរួមចំណែកក្នុងការបង្កើតកំណត់ត្រារឿងរ៉ាវដែលបានកើតឡើង ស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះនិងអ្នករស់រានមានជីវិត ព្រមទាំងចូលរួមចំណែកដល់ការផ្សះផ្សារបស់ពួកគាត់ផងដែរ។

| | |
|---|---|
| **ដៃគូអនុវត្ត** | អ.វ.ត.ក, ផ្នែកគាំពារជនរងគ្រោះ |
| **ម្ចាស់ជំនួយ** | GIZ |

### ៦.១.២. ការបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី

តាមសំណើសុំរបស់ពួកគេ ឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង ០០១ ត្រូវបានរៀបរាប់ឈ្មោះជាផ្លូវការនៅក្នុងសាលក្រម និងត្រូវបានផ្សព្វផ្សាយជាសាធារណៈក្នុងសំណៅបោះពុម្ព និងអនឡាញ។ ការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី និងការឈឺចាប់របស់ពួកគេជាផ្លូវការ មានអត្ថន័យជានិមិត្តរូបគួរឱ្យកត់សម្គាល់។ បញ្ជីពេញលេញរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ មាននៅក្នុងសាលក្រម និងសាលដីកា[1531]។

| | |
|---|---|
| **ដៃគូអនុវត្ត** | អ.វ.ត.ក, ផ្នែកគាំពារជនរងគ្រោះ |
| **ម្ចាស់ជំនួយ** | GIZ |

## ៦.២. សំណុំរឿង ០០២/០១

បន្ទាប់ពីវិសោធនកម្មវិធានផ្ទៃក្នុង ជាពិសេសការបញ្ចូលវិធាន ២៣ស្ទួនបួន អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់លទ្ធភាពរបស់ខ្លួនក្នុងការអនុម័តគម្រោង ដែលស្នើឡើងជំនួសមុខឱ្យដើមបណ្តឹងរដ្ឋប្បវេណីដែលរួមជាក្រុម ដែលតាមរយៈការអនុវត្តគម្រោងនោះ ចូលរួមចំណែកក្នុងការស្តារនីតិសម្បទាការធ្វើសមាហរណកម្មសាជាថ្មី និងការស្តារសេចក្តីថ្លៃថ្នូរឡើងវិញ[1532]។ បន្ថែមលើនេះ គម្រោងទាំងនេះត្រូវតែបានរៀបចំឡើង ឬកំណត់អត្តសញ្ញាណដោយមានកិច្ចសហការជាមួយផ្នែកគាំពារជនរងគ្រោះ និងធានាបាននូវមូលនិធិគាំទ្រគ្រប់គ្រាន់ពីខាងក្រៅ[1533]។ អង្គជំនុំជម្រះសាលាដំបូងបានអនុម័តគម្រោងសំណងចំនួន ១១ គម្រោង[1534]។

---

[1530] សូមមើលផងដែរ សំណុំរឿង ០០១ ការចងក្រងនូវពាក្យសូមអភ័យទោសរបស់ កាំង ហ្គេកអ៊ាវ ហៅឌុច នៅក្នុងអំឡុងពេលសវនាការកន្លងមក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28.1។

[1531] សំណុំរឿង ០០១ សាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 ឧបសម្ព័ន្ធ III។ សំណុំរឿង ០០១ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកក្នុងសាលក្រម ឬសាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ឯកសារ F28.2។

[1532] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១១១៦។

[1533] វិធានផ្ទៃក្នុង វិធាន ២៣ស្ទួនបួន(៣)។

[1534] សំណុំរឿង ០០២/០១ សាលក្រម ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 ជំពូក ១៩.៣, ១៩.៥។

### ៦.២.១. ទិវាជាតិនៃការចងចាំ

ទិវាជាតិនៃការចងចាំ ប្រារព្ធឡើងនៅថ្ងៃទី២០ ខែឧសភា ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យរាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៨។ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ បានស្នើសុំឱ្យមានមួយថ្ងៃសម្រាប់ការរំលឹកអំពីការឈឺចាប់របស់ពួកគេ ស្តារសេចក្តីថ្លៃថ្នូររបស់ពួកគេឡើងវិញ ដោះស្រាយទុក្ខលំបាកផ្លូវចិត្ត និងសង្គមរបស់ពួកគេ និងរំលឹកដល់វិញ្ញាណក្ខន្ធអ្នកស្លាប់។ ជាពិសេស ទិវានេះគឺជាថ្ងៃរំលឹកពីអតីតកាលដ៏ឃោរឃៅរបស់ប្រទេស និងមូលហេតុដែលវាមិនគួរត្រូវបានប្រព្រឹត្តឡើងជាថ្មីម្តងទៀត។

ទិវានេះដើមឡើយត្រូវបានប្រកាសថាជាថ្ងៃឈប់សម្រាកជាតិ ក្នុងឆ្នាំ២០១៨។ ទោះបីជាឋានៈផ្លូវការនៃទិវាជាតិនៃការចងចាំ ក្រោយមកត្រូវបានបន្ទាបតម្លៃក៏ដោយ ក៏ទិវានេះបន្តទទួលបានការកត់សម្គាល់នៅក្នុងផ្នែកជាច្រើន។ ព្រឹត្តិការណ៍នៃការចងចាំជាសាធារណៈ និងជាសមូហភាពបង្កើតបានជាកន្លែងមួយសម្រាប់ប្រជាជនកម្ពុជាទាំងអស់ដើម្បីធ្វើការរំលឹក ផ្សះផ្សា និងស្វែងយល់អំពីប្រវត្តិសាស្ត្ររួមគ្នារបស់ពួកគេ។ ទិវានេះក៏ជាឱកាសមួយសម្រាប់ពិធីផ្សេងៗ ដើម្បីឧទ្ទិសកុសលដល់អ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។

| | |
|---|---|
| **ដៃគូអនុវត្ត** | រាជរដ្ឋាភិបាលកម្ពុជា |

### ៦.២.២. គម្រោងសាងសង់ប្រូជនីយស្ថានសម្រាប់រម្លឹកជាសាធារណៈនៅភ្នំពេញ - *"សម្រាប់អ្នកដែលបាត់បង់ជីវិត"*

គម្រោងសំណងលក្ខណៈសិល្បៈនេះ ជាការគោរពដល់អ្នកដែលរងការបណ្តេញចេញដោយបង្ខំ ពីទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥។ វាមានការសាងសង់ប្ដូជនីយស្ថានចម្លាក់ដែលមានចំណងជើងថា "សម្រាប់អ្នកដែលបាត់បង់ជីវិត" ដោយវិចិត្រករខ្មែរ-បារាំង ឈ្មោះ សេរ៉ា អ៊ីង។ រូបចម្លាក់នេះដំបូងឡើយត្រូវបានសាងសង់នៅជាប់នឹងស្ថានទូតបារាំងក្នុងទីក្រុងភ្នំពេញ ដែលជាទីតាំងមួយក្នុងចំណោមទីតាំងជាច្រើនដែលប្រជាជនឆ្លងកាត់ដោយថ្មើរជើង នៅពេលដែលពួកគេត្រូវបានជម្លៀសចេញពីទីក្រុងដោយបង្ខំដោយខ្មែរក្រហម។ នៅដើមខែមករា ឆ្នាំ២០១៨ រូបចម្លាក់នេះត្រូវបានផ្លាស់ប្តូរទីតាំងទៅលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន នៅសារមន្ទីរទួលស្លែង ដែលជាទីតាំងអតីតមន្ទីរសន្តិសុខ ស-២១។

| | |
|---|---|
| **ដៃគូអនុវត្ត** | សេរ៉ា អ៊ីង ស្ថានទូតបារាំង សមាគម ANVAYA, ស្ថាបត្យករ OUBA SAS/ACYC SARL |
| **ម្ចាស់ជំនួយ** | សាធារណរដ្ឋបារាំង, សមាគម ANVAYA, ស្ថាបត្យករ OUBA SAS/ACYC SARL, "ក្រុមមិត្តភាព បារាំង-កម្ពុជា" នៃរដ្ឋសភាបារាំង |
| **រយៈពេលគម្រោង** | ១២ ខែ |
| **ទីតាំង** | ភ្នំពេញ |

### ៦.២.៣. វិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម

តាមរយៈសំណងនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលការថែទាំ និងការព្យាបាលបែបវិជ្ជាជីវៈសម្រាប់ព្យសនកម្មយូរអង្វែងរបស់ពួកគេ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអញ្ជើញឱ្យនិយាយអំពីបទពិសោធន៍ដ៏តក់ស្លុតរបស់ពួកគេ ឬអានសក្ខីកម្មរបស់ពួកគេ។ ដោយមានជំនួយពីអ្នកជំនាញផ្លូវចិត្ត ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានលើកទឹកចិត្តឱ្យកត់ត្រាការចងចាំរបស់ខ្លួនជាលាយលក្ខណ៍អក្សរ។ សក្ខីកម្មទាំងអស់នេះក្រោយមកត្រូវបានអាន និងប្រគល់ជូនដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងពិធីសាធារណៈ ដែលធ្វើឡើងស្របតាមពិធីបុណ្យសាសនា ឬជំនឿ និងទំនៀមទម្លាប់វប្បធម៌របស់ពួកគេ។

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) |
| **ម្ចាស់ជំនួយ** | ក្រសួងប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ *Stiftung Kriegstrauma-Therapie* និងប្រទេសអូស្ត្រាលី |
| **រយៈពេលគម្រោង** | ១៦ ខែ |
| **ទីតាំង** | ភ្នំពេញ |

### ៦.២.៤. ក្រុមជួយខ្លួនឯង

គម្រោងសំណាងនេះគាំទ្រការបង្កើតក្រុមជួយខ្លួនឯង ដែលផ្តល់ការព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកចូលរួមត្រូវបានណែនាំអំពីរចនាសម្ព័ន្ធ ដែលពួកគេអាចចែករំលែកអារម្មណ៍ និងគាំទ្រគ្នាទៅវិញទៅមក ខណៈពេលដែលទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍របស់សមាជិកក្រុមផ្សេងទៀត។ គម្រោងនេះបានផ្តល់កន្លែងសម្រាប់ផ្ទះបញ្ចាំង និងធ្វើឱ្យអ្នកចូលរួមទទួលបានការគោរពចំពោះខ្លួនឯងឡើងវិញ និងសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តដែលអាចធ្វើឱ្យប្រសើរឡើងនូវជីវិតរបស់ពួកគេ។ តាមរយៈការចូលរួមក្នុងក្រុមជួយខ្លួនឯង អ្នកចូលរួមត្រូវបានផ្តល់មធ្យោបាយដើម្បីដោះស្រាយភាពឯកោ និងភាពដាច់ឆ្ងាយពីគេរបស់ពួកគេ តាមរយៈការចែករំលែកបទពិសោធន៍ និងការភ្ជាប់ទំនាក់ទំនងជាមួយសមាជិកក្រុមផ្សេងទៀត។

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) |
| **ម្ចាស់ជំនួយ** | ក្រសួងប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ *Stiftung Kriegstrauma-Therapie* និងប្រទេសអូស្ត្រាលី |
| **រយៈពេលគម្រោង** | ១៦ ខែ |
| **ទីតាំង** | ភ្នំពេញ |

### ៦.២.៥. ការតាំងពិព័រណ៍អចិន្ត្រៃយ៍អំពីការផ្លាស់ទីលំនៅដោយបង្ខំ

គម្រោងសំណាងនេះមានធាតុផ្សំពីរ៖ ការតាំងពិព័រណ៍ និងព្រឹត្តិការណ៍អប់រំពាក់ព័ន្ធ។ វារក្សាការចងចាំរបស់ជនរងគ្រោះ និងបទពិសោធន៍របស់ពួកគេក្នុងរបបខ្មែរក្រហម លើកកម្ពស់ការផ្សះផ្សាគ្នារវាងប្រជាជនកម្ពុជា តាមរយៈអន្តរកម្មប្រកបដោយអត្ថន័យ និងការអប់រំ ហើយបម្រើជាវេទិកាសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្សេងទៀត ដើម្បីចែករំលែក និងពង្រីកចំណេះដឹងប្រវត្តិសាស្ត្ររបស់ពួកគេ។ គម្រោងសំណាងនេះលើកកម្ពស់បន្ថែមទៀតដល់ការអប់រំសាធារណៈ អំពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ និងស្វែងរកការពង្រឹងកំណត់ត្រាសង្គមអំពីអ្វីដែលបានកើតឡើង។ ការតាំងពិព័រណ៍ចំនួនប្រាំបី ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១៣ នាក់ ដែលបានចូលរួមក្នុងព្រឹត្តិការណ៍សម្ពោធ នៅទូទាំងសារមន្ទីរខេត្តចំនួនប្រាំបី។

> "*ការតាំងពិព័រណ៍បែបនេះ មានសារៈសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជា ជាពិសេសយុវជនជំនាន់ក្រោយ។ ថ្វីត្បិតតែការតាំងពិព័រណ៍នេះមានទំហំតូចក៏ដោយ ប៉ុន្តែវាបានជូនដំណឹងដល់ទស្សនិកជនអំពីទិដ្ឋភាពមួយនៃប្រវត្តិសាស្ត្រខ្មែរក្រហម។ វានឹងមានប្រយោជន៍ ប្រសិនបើការតាំងពិព័រណ៍បែបនេះអាចពង្រីកទៅគ្រប់ស្រុកទូទាំងប្រទេស ដើម្បីឱ្យសហគមន៍មូលដ្ឋានមានឱកាសស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម*"។ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ មកពីខេត្តស្វាយរៀង

| ដៃគូអនុវត្ត | មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់ |
| **រយៈពេលគម្រោង** | ១៥ ខែ |
| **ទីតាំង** | បាត់ដំបង, តាកែវ, ស្វាយរៀង, បន្ទាយមានជ័យ, ក្រុងព្រះសីហនុ, កំពង់ធំ, សៀមរាប, ក្រចេះ |

## ៦.២.៦. ការតាំងពិព័រណ៍ចល័តស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម និង អ.វ.ត.ក.

គម្រោងសំណងនេះគឺជាការតាំងពិព័រណ៍អន្តរកម្ម ដែលរួមបញ្ចូលគ្នារវាងខ្សែភាពយន្ត និងសម្ភារៈសោតទស្សន៍ផ្សេងៗទៀត ដែលរៀបចំឡើងដើម្បីជូនដំណឹងដល់ប្រជាជនកម្ពុជា អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដំណើរការរបស់ អ.វ.ត.ក. និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសង្កត់ធ្ងន់លើការផ្លាស់ទីលំនៅដោយបង្ខំ។ គម្រោងនេះមានចំណងជើងថា *"ការតាំងពិព័រណ៍ចល័តអំពីការផ្លាស់ទីលំនៅដោយបង្ខំ"* ហើយអ្នកទស្សនាត្រូវបានលើកទឹកចិត្តឱ្យឆ្លុះបញ្ចាំង និងពង្រីកចំណេះដឹងរបស់ពួកគេលើប្រធានបទជាមូលដ្ឋាន និងរបៀបដែលប្រធានបទទាំងនោះពាក់ព័ន្ធទៅនឹងជីវិតរបស់ពួកគេ ឬរបៀបដែលពួកវាបន្តជះឥទ្ធិពលដល់ពួកគេសព្វថ្ងៃនេះ។

ការតាំងពិព័រណ៍ចល័តនេះ ជំរុញឱ្យមានការទទួលស្គាល់ជាសាធារណៈអំពីទុក្ខលំបាករបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ជាពិសេសតាមរយៈព្យសនកម្មដែលបណ្តាលមកពីការផ្លាស់ទីលំនៅដោយបង្ខំរបស់ប្រជាជននៅទូទាំងប្រទេស។ ការតាំងពិព័រណ៍នេះក៏ជូនដំណឹងដល់សាធារណជនអំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន និងលើកទឹកចិត្តឱ្យមានការចូលរួមក្នុងចំណោមប្រជាជនកម្ពុជា ដើម្បីឆ្លុះបញ្ចាំងពីអតីតកាល។

| ដៃគូអនុវត្ត | អង្គការក្តីករុណា (KdK) & យុវសន្តិភាព (YfP) |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់, វិទ្យាស្ថានអាល្លឺម៉ង់សម្រាប់ទំនាក់ទំនងបរទេស (ifa), Narrowcasters Pty. Ltd |
| **រយៈពេលគម្រោង** | ១២ ខែ |
| **ទីតាំង** | កំពត, សៀមរាប, កំពង់ស្ពឺ, ក្រចេះ, កំពង់ធំ, រតនគិរី, ត្បូងឃ្មុំ, ព្រៃវែង, ស្ទឹងត្រែង |

## ៦.២.៧. ជំពូកកម្មវិធីសិក្សាស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងការសម្លាប់នៅទួលពោធិ៍ជ្រៃ

គម្រោងសំណងនេះពង្រឹងការស្វែងយល់អំពីការជម្លៀសប្រជាជនទ្រង់ទ្រាយធំ នៅជុំវិញប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម។ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលភស្តុតាងអំពីការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ និងការសម្លាប់អ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ នៅទួលពោធិ៍ជ្រៃនៅក្នុងរយៈពេល ២២២ ថ្ងៃសវនាការ។ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំជំពូកមួយបន្ថែមទៀត អំពីការផ្លាស់ទីលំនៅដោយបង្ខំ និងការសម្លាប់នៅទួលពោធិ៍ជ្រៃ ដើម្បីដាក់បញ្ចូលជាផ្លូវការទៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀន អំពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ សៀវភៅសិក្សាដែលមានជំពូកនេះ គឺជាធនធានប្រវត្តិសាស្ត្រដ៏សំខាន់ សម្រាប់សិស្សថ្នាក់ទីប្រាំបួន ដល់ទីដប់ពីរ ហើយត្រូវបានគាំទ្រដោយក្រសួងអប់រំ យុវជន និងកីឡា។

ក្រៅពីការអប់រំ ជំពូកនេះគឺជាការទទួលស្គាល់ជាផ្លូវការអំពីព្យសនកម្ម និងទុក្ខលំបាករបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្លឹមសារនៃមេរៀននីមួយៗផ្អែកលើសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សីដែលបានផ្ដល់ឱ្យក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង ០០២/០១។

| | |
|---|---|
| **ដៃគូអនុវត្ត** | មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) |
| **ម្ចាស់ជំនួយ** | ក្រសួងប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់, GIZ - សេវាសន្តិភាពពលរដ្ឋ |
| **រយៈពេលគម្រោង** | ៩ ខែ |
| **ទីតាំង** | ទូទាំងប្រទេស |

### ៦.២.៨. ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍នៅសំរោងក្នុង

គម្រោងសំណងនេះពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ (CPLC) នៅសំរោងក្នុង ខេត្តបាត់ដំបង ដែលជាទីតាំងមួយក្នុងចំណោមទីតាំងដែលមនុស្សជាច្រើនត្រូវបានឃុំខ្លួន និងសម្លាប់។ CPLC បង្កើតកន្លែងសុវត្ថិភាពសម្រាប់សហគមន៍ ក្នុងការចូលរួមក្នុងកិច្ចសន្ទនាអន្តរជំនាន់ ការរៀបរាប់អំពីការពិត ការរំលឹក និងការចងក្រងឯកសារអំពីទីតាំងនៃការចងចាំ និងរឿងរ៉ាវផ្ទាល់ខ្លួន។ គម្រោងនេះក៏មានគោលបំណងផ្ដល់អំណាចដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋានដើម្បីទ្រទ្រង់ CPLC តាមរយៈការកសាងសមត្ថភាព ក្នុងការរៀបចំផែនការចូលរួម និងការអនុវត្តគម្រោង។

គម្រោងសំណងនេះបម្រើមនុស្សជំនាន់ក្រោយ និងមនុស្សជំនាន់មុនដូចគ្នា។ អ្នកទស្សនាជំនាន់ក្រោយប្រើទីកន្លែងសម្រាប់សកម្មភាពដូចជា វេទិកាសាធារណៈ កិច្ចសន្ទនាអន្តរជំនាន់ សាលសំដែង ការប្រគំតន្ត្រី សិក្ខាសាលាសហគមន៍ ការតាំងពិព័រណ៍ ការបញ្ចាំងភាពយន្ត និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ មនុស្សជំនាន់មុនប្រើ CPLC ជាមជ្ឈមណ្ឌលសង្គម ដើម្បីចែករំលែករឿងរ៉ាវ និងស្វែងរកការធ្វើឱ្យធូរស្បើយ និងការផ្សះផ្សានៅក្នុងសហគមន៍។

| | |
|---|---|
| **ដៃគូអនុវត្ត** | យុវសន្តិភាព (YfP) |
| **ម្ចាស់ជំនួយ** | ភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ |
| **រយៈពេលគម្រោង** | ២ ឆ្នាំ |
| **ទីតាំង** | បាត់ដំបង |

### ៦.២.៩. កូនសៀវភៅរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងអង្គហេតុដែលបានវិនិច្ឆ័យក្នុងសំណុំរឿង ០០២/០១

គម្រោងសំណងនេះបានប្រែក្លាយសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទៅជាការនិទានរឿងជាលាយលក្ខណ៍អក្សរ និងគំនូរ ដែលសាធារណជនអាចចូលមើលបានកាន់តែងាយស្រួល។ ការផលិតសៀវភៅគំនូរនេះ បានផ្ដល់សិទ្ធិអំណាចដល់ដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈការផ្ដល់កន្លែងមួយដើម្បីចែករំលែកបទពិសោធន៍របស់ពួកគេក្នុងរបបខ្មែរក្រហម និងដើម្បីឱ្យសំឡេងរបស់ពួកគេត្រូវបានគេស្ដាប់ និងកត់ត្រាទុក។ សៀវភៅដែលត្រូវបានបោះពុម្ពនិងផ្សព្វផ្សាយនោះ មានរឿងរ៉ាវដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ២៩។

ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ គម្រោងសំណងនេះគឺជាទម្រង់មួយនៃការចងក្រងឯកសារ ការអប់រំ ការទទួលស្គាល់ ការចងចាំ និងការលើកកម្ពស់ការយល់ដឹង ដើម្បីជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជន។

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) |
| **ម្ចាស់ជំនួយ** | ក្រសួងប្រតិបត្តិការណ៍សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសហព័ន្ធអាល្លឺម៉ង់, GIZ - សេវាសន្តិភាពពលរដ្ឋ |
| **រយៈពេលគម្រោង** | ១០ ខែ |
| **ទីតាំង** | ទូទាំងប្រទេស |

## ៦.២.១០. ការបោះពុម្ពផ្សាយ និងចែកចាយសាលក្រមពេញលេញ និងសាលក្រមសង្ខេប

ការបោះពុម្ពផ្សាយ និងការចែកចាយសាលក្រមសំណុំរឿង ០០២/០១ គឺជាការទទួលស្គាល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី។ ការបោះពុម្ពផ្សាយសាលក្រមពេញលេញ និងសាលក្រមសង្ខេប ផ្តល់ព័ត៌មានសំខាន់ៗអំពីការរកឃើញរបស់ អ.វ.ត.ក. ដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងវិស័យសាធារណៈ។ មន្ត្រីរដ្ឋាភិបាល អ្នកអប់រំ អង្គការសង្គមស៊ីវិល និងអ្នកផ្សេងទៀតដែលចាប់អារម្មណ៍ អាចប្រើប្រាស់សាលក្រម ឬសេចក្តីសង្ខេបសាលក្រម នៅក្នុងគំនិតផ្តួចផ្តើម និងគំនិតផ្តួចផ្តើមអប់រំរៀងៗខ្លួន។ សំណៅបោះពុម្ពបានចែកចាយដល់ដើមបណ្តឹងរដ្ឋប្បវេណី សាធារណជន អ្នកអនុវត្តច្បាប់ និងអ្នកដទៃទៀត។ អ.វ.ត.ក. បន្តធ្វើយ៉ាងណាឱ្យសាលក្រមនេះ និងសាលក្រមផ្សេងទៀត ក៏ដូចជាឯកសារច្បាប់សំខាន់ៗ អាចរកបាននៅមជ្ឈមណ្ឌលធនធានរបស់ខ្លួន ក្នុងរាជធានីភ្នំពេញ និងតាមអ៊ីនធឺណិត។

| | |
|---|---|
| **ដៃគូអនុវត្ត** | អ.វ.ត.ក. - ផ្នែកកិច្ចការសាធារណៈ, ផ្នែកគាំពារជនរងគ្រោះ, សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| **ម្ចាស់ជំនួយ** | អ.វ.ត.ក. |
| **រយៈពេលគម្រោង** | កំពុងបន្ត |
| **ទីតាំង** | ក្នុងតំបន់ (ភ្នំពេញ), ទូទាំងប្រទេស (ការផ្សព្វផ្សាយ), ទូទាំងសកលលោក (តាមអ៊ីនធឺណិត)។ |

## ៦.២.១១. ការបោះពុម្ពផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី

ការបោះពុម្ពផ្សាយឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅលើគេហទំព័រ អ.វ.ត.ក. ត្រូវបានស្នើឡើងជាគម្រោងសំណងមួយដើម្បីគោរពដល់ការចូលរួមរបស់ពួកគេ ក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះ និងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការស្វែងរកយុត្តិធម៌ - មិនត្រឹមតែសម្រាប់ពួកគេផ្ទាល់នោះទេ ប៉ុន្តែថែមទាំងសម្រាប់សមាជិកគ្រួសាររបស់ពួកគេ ដែលបានស្លាប់ក្រោមរបបខ្មែរក្រហម។ ឈ្មោះត្រូវបានបោះពុម្ពជាអក្សរខ្មែរ និងឡាតាំង។ ឈ្មោះសិទ្ធិវ័ន្តដែលស្នើសុំបន្តជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ត្រូវបានដាក់បញ្ចូលផងដែរ។ ឈ្មោះចំនួន ៣.៨៦៧ និងព័ត៌មានមូលដ្ឋានផ្សេងទៀត ដែលកំណត់អត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបោះពុម្ពផ្សាយនៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ និងនៅលើគេហទំព័ររបស់ អ.វ.ត.ក.។

| | |
|---|---|
| **ដៃគូអនុវត្ត** | អ.វ.ត.ក. - ផ្នែកកិច្ចការសាធារណៈ, ផ្នែកគាំពារជនរងគ្រោះ, សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី |
| **ម្ចាស់ជំនួយ** | អ.វ.ត.ក. |
| **រយៈពេលគម្រោង** | កំពុងបន្ត |

| | |
|---|---|
| **ទីតាំង** | ក្នុងតំបន់ (ភ្នំពេញ), ទូទាំងប្រទេស (ការផ្សព្វផ្សាយ), ទូទាំងសកលលោក (តាមអ៊ីនធឺណិត)។ |

## ៦.៣. សំណុំរឿង ០០២/០២

ក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងភាគច្រើនបានអនុវត្តតាមវិធីសាស្ត្រពីមុនរបស់ខ្លួន ក្នុងការវាយតម្លៃលើសំណង និងបានអនុម័តគម្រោងចំនួន ១៣[1535]។

### ៦.៣.១. កម្មវិធីសិក្សា (App) អំពីប្រវត្តិសាស្ត្រខ្មែរក្រហម

កម្មវិធីសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាធនធានអប់រំដែលផ្តល់ការរៀបរាប់បែបអប់រំអំពីរបបខ្មែរក្រហម ដោយប្រើលក្ខណៈសោតទស្សន៍អន្តរកម្ម ដូចជា ភាពយន្ត រូបថត និងភ្លេង រួមជាមួយនឹងសក្ខីកម្មរបស់អ្នករស់រានមានជីវិត អត្ថបទ និងការរកឃើញរបស់ អ.វ.ត.ក.។ កម្មវិធីនេះរៀបចំឡើងដើម្បីជាជំនួយដល់ការបង្រៀន និងការស្វែងយល់អំពីប្រវត្តិសាស្ត្រ វាក៏ផ្តល់ព័ត៌មានអំពីយុត្តិធម៌ សិទ្ធិមនុស្ស និងសន្តិភាពផងដែរ។ កម្មវិធីនេះគឺជាកាតាលីករមួយសម្រាប់ការផ្លាស់ប្តូរព័ត៌មានដ៏មានអត្ថន័យ រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី និងមនុស្សជំនាន់ក្រោយ។

| | |
|---|---|
| **ដៃគូអនុវត្ត** | មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា |
| **ម្ចាស់ជំនួយ** | សហភាពអឺរ៉ុប, មូលនិធិ Rei |
| **រយៈពេលគម្រោង** | ២៤ ខែ |
| **ទីតាំង** | ទូទាំងប្រទេស |

### ៦.៣.២. ការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូអ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ

គម្រោងសំណងនេះមានធាតុផ្សំសំខាន់បីគឺ៖ ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ឃុំ ការបណ្តុះបណ្តាលសាស្ត្រាចារ្យមហាវិទ្យាល័យ និងការអប់រំចល័ត ឬវេទិកានៅតាមថ្នាក់រៀនសម្រាប់សិស្ស។

ធាតុផ្សំទាំងអស់ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់សមត្ថភាពផ្នែកគរុកោសល្យរបស់គ្រូបង្រៀនកម្ពុជាដើម្បីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដោយប្រើប្រាស់វិធីសាស្ត្រខុសៗគ្នា រួមបញ្ចូលទាំងការប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដើម្បីការពារកុំឱ្យអំពើឃោរឃៅកើតមានឡើងសាជាថ្មី។ ធាតុផ្សំទាំងអស់នេះត្រូវបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា។

> "*ខ្ញុំបានទទួលចំណេះដឹងជាច្រើន និងបានសិក្សាអំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតក្នុងអំឡុងពេលរបបខ្មែរក្រហមពីវេទិកានេះ។ បទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាអាចឱ្យយើងយល់ពីអ្វីដែលបានកើតឡើងក្នុងរបបនោះ ហើយបានជួយរំលឹកយើងកុំឱ្យធ្វើខុសដូចមុនទៀត។ ខ្ញុំស្នើឱ្យក្រុមធ្វើបទបង្ហាញបែបនេះបន្ថែមទៀតដល់សិស្ស*"។ សិស្សថ្នាក់ទី១០ មកពីវិទ្យាល័យចំរើនវិជ្ជា"

| | |
|---|---|
| **ដៃគូអនុវត្ត** | មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) |
| **ម្ចាស់ជំនួយ** | UNOPS |
| **រយៈពេលគម្រោង** | ៣៦ ខែ |

[1535] សំណុំរឿង ០០២/០២ សាលក្រម ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 ជំពូក ២១.៣, ២១.៥។

| | |
|---|---|
| **ទីតាំង** | កំពង់ចាម, ត្បូងឃ្មុំ, ក្រចេះ, ស្ទឹងត្រែង, រតនៈគិរី, មណ្ឌលគិរី, ព្រៃវែង |

## ៦.៣.៣. គម្រោង "អណ្ដើក"

អណ្ដើកតក្កាហានគឺជាស្នាដៃមហោស្រពដើមរបស់អ្នកនិពន្ធខ្មែរ និងអ្នកដឹកនាំភាពយន្តខ្លីឈ្មោះ ជា សុខយូ។ ការសំដែងត្រូវបានបង្កើតឡើងសហការគ្នាជាមួយសិល្បករខ្មែរវ័យក្មេងមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ វារួមបញ្ចូលសកម្មភាពពហុព័ត៌មានផ្នែកវប្បធម៌ និងអប់រំ ដែលបង្ហាញនៅក្នុងសិក្ខាសាលាជាមួយសិស្សវិទ្យាល័យ និងនិស្សិតសាកលវិទ្យាល័យ។ វាត្រូវបានអមដោយការបញ្ចាំងភាពយន្ត ការតាំងពិព័រណ៍រូបថត និងការសន្ទនាអន្តរជំនាន់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងនាមជាសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ការសំដែងនេះជួយលើកកម្ពស់សន្តិភាព ការចងចាំ និងការផ្សះផ្សាតាមរយៈការសំដែងល្ខោនសហគមន៍ និងការសន្ទនាអន្តរជំនាន់។

> *"ខ្ញុំបានមើល គម្រោងអណ្ដើក ថ្ងៃនេះ វាបានផ្ដល់ជាគំនិតឱ្យខ្ញុំនិយាយរឿងរបស់ឪពុកម្ដាយខ្ញុំ ដែលជាជនរងគ្រោះក្នុងរបបខ្មែរក្រហម។ ខ្ញុំបង្រៀនមុខវិជ្ជាសិល្បៈបុរាណចម្រុះ ដូចជា ច្រៀង ច្រៀងជាក្រុម របាំអប្សរា ដែលខ្ញុំបានបាត់កាលពីនៅក្មេង។ ហើយឥឡូវនេះ ខ្ញុំគិតថាខ្ញុំគួរតែបញ្ចូលសិល្បៈ រឿងរបស់ឪពុកម្ដាយខ្ញុំ និងមេរៀនពីសៀវភៅប្រវត្តិសាស្ត្រនៅក្នុងថ្នាក់របស់ខ្ញុំ ដើម្បីធ្វើឱ្យវាកាន់តែមានអន្តរកម្ម និងការចូលរួម"*។ គ្រូសិល្បៈមកពីវិទ្យាល័យព្រែកលាប

| | |
|---|---|
| **ដៃគូអនុវត្ត** | សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់, សកម្មភាពសិល្បៈខ្មែរ, យុវសន្តិភាព |
| **ម្ចាស់ជំនួយ** | វិទ្យាស្ថានអាល្លឺម៉ង់សម្រាប់ទំនាក់ទំនងបរទេស (ifa) តាមរយៈ មូលនិធិ "Zivik", សភាពអឺរ៉ុប តាមរយៈ UNOPS |
| **រយៈពេលគម្រោង** | ១៥ ខែ |
| **ទីតាំង** | ទូទាំងប្រទេស |

## ៦.៣.៤. គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម

គម្រោងសំណងនេះបានប្រមូលផ្ដុំអ្នកផលិតភាពយន្ត អ្នកថតរូប និងអ្នកស្រាវជ្រាវវ័យក្មេងមកពីសហគមន៍ចាម ដើម្បីបង្កើតប្រវត្តិដើមបណ្ដឹងរដ្ឋប្បវេណីចាម ទៅជាទម្រង់ភាពយន្តឯកសារ។ ភាពយន្តឯកសារនេះបង្ហាញពីដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ដែលកូនៗរបស់ពួកគេបានចូលរួមផងដែរក្នុងការបង្កើត និងការផលិតគម្រោងនេះ។ គម្រោងនេះបានផលិតភាពយន្តឯកសារចំនួនពីរ កត់ត្រាសក្ខីកម្មជាច្រើន និងបណ្ដុះបណ្ដាលនិស្សិតសារព័ត៌មានជនជាតិចាម ក្នុងដំណើរការនេះ។ លើសពីនេះ អ្នករៀបចំបានរៀបចំការតាំងពិព័រណ៍រូបថត រួមជាមួយនឹងការបញ្ចាំងភាពយន្តនៅទូទាំងប្រទេស ដែលបានរួមគ្នាផ្ដួចផ្ដើមកិច្ចសន្ទនាអន្តរជំនាន់ និងអន្តរសាសនា។

គម្រោងសំណងនេះបានផ្ដល់អត្ថប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចាម គ្រួសាររបស់ពួកគេ និងមនុស្សជំនាន់ក្រោយ តាមរយៈការអប់រំសាធារណជនអំពីបទពិសោធន៍ និងការធ្វើបាបសហគមន៍ចាមដោយខ្មែរក្រហម។

| | |
|---|---|
| **ដៃគូអនុវត្ត** | សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់ |
| **ម្ចាស់ជំនួយ** | ស្ថានទូតស្វីសនៅទីក្រុងបាងកក, មូលនិធិ Heinrich Böll |

| | |
|---|---|
| **រយៈពេលគម្រោង** | ១២ ខែ |
| **ទីតាំង** | ភ្នំពេញ, កំពង់ចាម, ត្បូងឃ្មុំ, កំពង់ឆ្នាំង |

### ៦.៣.៥. ផ្កាស្លាក្រោមអង្គការ

ការសម្តែងរបាំដើមនេះ រួមមានកិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើយេនឌ័រ តាមរយៈសិល្បៈ និងគាំទ្រការផ្លាស់ប្តូរសមភាពយេនឌ័រ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះដោយសារការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ គំនិតផ្តួចផ្តើមនេះបង្ហាញពីទិដ្ឋភាពពិសេសៗ ដូចជាការរងទុក្ខរបស់បុរស ការមានផ្ទៃពោះដោយបង្ខំ និងសកម្មភាពមួយចំនួនតូចនៃការតស៊ូរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រោមរបបខ្មែរក្រហម។ រៀបចំឡើងដោយមានកិច្ចសហការពីអង្គការក្រៅរដ្ឋាភិបាលចំនួនបួន គម្រោងសំណងនេះលើកកម្ពស់ការសន្ទនាអន្តរជំនាន់ ការស្វែងយល់តាមរយៈភាពយន្តឯកសារពាក់ព័ន្ធ និងការសម្តែង ការតាំងពិព័រណ៍ វេទិកាមហោស្រព សិក្ខាសាលា និងការបញ្ចាំងភាពយន្ត។ ក្នុងនាមជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី គម្រោងនេះបានទទួលស្គាល់បទពិសោធន៍ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈសិល្បៈ វប្បធម៌ ការសន្ទនា ការចូលរួមយ៉ាងទូលំទូលាយ និងការផ្សព្វផ្សាយ។

| | |
|---|---|
| **ដៃគូអនុវត្ត** | ក្តីករុណា (KdK), ក្រុមសិល្បៈខ្មែរ, មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា, អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) |
| **ម្ចាស់ជំនួយ** | ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ស្វីស, ក្រសួងសហប្រតិបត្តិការនិងអភិវឌ្ឍសេដ្ឋកិច្ចអាល្លឺម៉ង់ តាមរយៈ GIZ, USAID |
| **រយៈពេលគម្រោង** | ៣ ឆ្នាំ |
| **ទីតាំង** | ភ្នំពេញ, បាត់ដំបង, កំពត |

### ៦.៣.៦. សំឡេងពីជនជាតិភាគតិច

គម្រោងសំណងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណង លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការធ្វើបាបជនជាតិភាគតិច ជាពិសេសជនជាតិចាម និងវៀតណាម ដោយរបបខ្មែរក្រហម។ តាមរយៈការប្រមូល និងការផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រផ្ទាល់មាត់ និងអមដោយវីដេអូសវនាការ និងឯកសារពាក់ព័ន្ធ ការពិភាក្សាប្រកបដោយបរិយាបន្ន បង្កើតការយល់ដឹងកាន់តែសម្បូរបែប អំពីជីវិតរបស់ជនជាតិភាគតិច។ គម្រោងនេះចូលរួមដោយសិស្សានុសិស្ស និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ក្នុងការសន្ទនាអំពីការសន្ទត់ជាតួយ៉ាង និងការរើសអើង តាមរយៈការសាកសួរយ៉ាងសកម្មអំពីរឿងរ៉ាវប្រវត្តិសាស្ត្រ និងផ្តល់វេទិកាសម្រាប់ជនរងគ្រោះ-អ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ អំពើហិង្សាលើជាតិពន្ធុ និងការរើសអើង ដើម្បីចែករំលែករឿងរ៉ាវរបស់ពួកគេ។

| | |
|---|---|
| **ដៃគូអនុវត្ត** | ក្តីករុណា (KdK) |
| **ម្ចាស់ជំនួយ** | GIZ-សេវាសន្តិភាពពលរដ្ឋ, ស្ថានទូតស្វីសនៅទីក្រុងបាងកក |
| **រយៈពេលគម្រោង** | ១២ ខែ |
| **ទីតាំង** | ត្បូងឃ្មុំ, កំពង់ឆ្នាំង, កណ្តាល, ស្វាយរៀង |

### ៦.៣.៧. រឿងរ៉ាវមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២

ក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៣.៨៦៧ នាក់ ដែលត្រូវបានទទួលយកក្នុងសំណុំរឿង ០០២ មានតែ ៩៤ នាក់ប៉ុណ្ណោះត្រូវបានកោះហៅមកផ្ដល់សក្ខីកម្មក្នុងតុលាការ។ គម្រោងសំណងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងប្រាប់អំពីរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលរងនូវឧក្រិដ្ឋកម្ម ដែលត្រូវបានពិនិត្យក្នុងសំណុំរឿង ០០២/០២ ប៉ុន្តែមិនមានឱកាសផ្ដល់សក្ខីកម្មដោយផ្ទាល់។ សៀវភៅកត់ត្រា ទទួលស្គាល់ និងរំលឹកប្រវត្តិសាស្ត្រទាំងនេះ ដោយផ្ដល់នូវធនធានដ៏មានអត្ថន័យ និងអាចចូលប្រើប្រាស់បានសម្រាប់មនុស្សជំនាន់ក្រោយ។

ជំពូកនីមួយៗចាប់ផ្ដើមដោយទំព័របង្ហាញអំពីស្នាដៃសិល្បៈរបស់សិល្បករខ្មែរ។ សៀវភៅនេះរួមមានជីវប្រវត្តិដើមបណ្ដឹងរដ្ឋប្បវេណី រៀបចំតាមឧក្រិដ្ឋកម្មផ្សេងៗគ្នា។ សៀវភៅនេះត្រូវបានចែកចាយដល់អ្នកចូលរួមទាំងអស់ ដើមបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត បណ្ណាល័យតាមសាលារៀន នឹងសាកលវិទ្យាល័យ បណ្ណាល័យជាតិ និងអន្តរជាតិ និងមជ្ឈមណ្ឌលស្រាវជ្រាវ និងឯកសារ សម្រាប់គោលបំណងអប់រំ។

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) |
| **ម្ចាស់ជំនួយ** | មូលនិធិ Heinrich Böll |
| **រយៈពេលគម្រោង** | ១២ ខែ |
| **ទីតាំង** | ជាតិ និងអន្តរជាតិ |

### ៦.៣.៨. ការប្រកួតប្រជែងតាក់តែងបទចម្រៀង៖ *"ពេលវេលាដែលត្រូវចងចាំ"*

ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យមានការប្រកួតប្រជែងតាក់តែងបទចម្រៀង "ពេលវេលាដែលត្រូវចងចាំ" ជាមធ្យោបាយមួយនៃការចូលរួមរបស់យុវជន ដើម្បីបញ្ចូនភាពច្នៃប្រឌិតបែបសិល្បៈរបស់ពួកគេ និងទទួលស្គាល់ ព្រមទាំងរំលឹកបទពិសោធន៍របស់អ្នករស់រានមានជីវិតក្រោមរបបខ្មែរក្រហម។ តន្ត្រីករវ័យក្មេងបានផ្សព្វផ្សាយសារអំពីការយល់ដឹង ការអាណិតអាសូរ ក្ដីសង្ឃឹម និងទំនួលខុសត្រូវរួមគ្នារបស់ពួកគេចំពោះមនុស្សជំនាន់មុនរបស់ប្រទេសកម្ពុជា តាមរយៈបទចម្រៀង។ ការប្រកួតក៏បានផ្ដល់ឱកាសដល់សិល្បករវ័យក្មេង ក្នុងការឆ្លុះបញ្ចាំងពីអតីតកាលដ៏ខ្លោចផ្សារបស់ពួកគេ និងបង្ហាញពីគំនិត និងអារម្មណ៍របស់ពួកគេតាមរយៈអំណាចសិល្បៈ។

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការកម្មវិធីអភិវឌ្ឍធនធានយុវជន (YRDP) |
| **ម្ចាស់ជំនួយ** | GIZ-សេវាសន្តិភាពពលរដ្ឋ |
| **រយៈពេលគម្រោង** | ១០ ខែ |
| **ទីតាំង** | ភ្នំពេញ |

### ៦.៣.៩. ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់

គម្រោងសំណងនេះរួមបញ្ចូលប្រវត្តិសាស្ត្រ និងសិល្បៈ ហើយត្រូវបានអនុវត្តដោយក្រុមនិស្សិតសកលវិទ្យាល័យ ដែលស្រាវជ្រាវ និងចងក្រងឯកសារអំពីទីតាំងមន្ទីរសន្តិសុខក្រាំងតាចាន់ ដោយមានការពិគ្រោះយោបល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី។ ការចងចាំរបស់អ្នករស់រានមានជីវិតពីអតីតមន្ទីរសន្តិសុខនេះ ត្រូវបានចាប់យកតាមរយៈកិច្ចសន្ទនាអន្តរជំនាន់កម្រិតឃុំ។ គម្រោងនេះបានផលិតសៀវភៅប្រវត្តិសាស្ត្រ នឹងកូនសៀវភៅគំនូរជាឯកសារព័ត៌មាន សម្រាប់អ្នកចូលទស្សនានៅទីកន្លែងផ្ទាល់។ ផ្លូវដើរប្រវែង ២៧១ម៉ែត្រក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីណែនាំអ្នកទស្សនារហូតដល់ទីតាំងនោះ រួមជាមួយនឹងមគ្គ

ទ្វេសក៍ទេសចរណ៍សហគមន៍ដែលមានការបណ្ដុះបណ្ដាល។ គម្រោងសំណាងនេះបម្រើជាការការពារការកើតឡើងវិញនៃអំពើឃោរឃៅទ្រង់ទ្រាយធំ តាមរយៈការស្រាវជ្រាវ ឯកសារ និងការអប់រំសហគមន៍។

| | |
|---|---|
| **ដៃគូអនុវត្ត** | យុវសន្តិភាព (YfP), វិទ្យាស្ថានសន្តិភាពកម្ពុជា (PIC) |
| **ម្ចាស់ជំនួយ** | International Coalition of Sites of Conscience |
| **រយៈពេលគម្រោង** | ៦ ខែ |
| **ទីតាំង** | តាកែវ |

## ៦.៣.១០. ការចូលមើលកំណត់ត្រារបស់តុលាការ និងសម្ភារៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក. (ម.ត.ឯ.ច.) ត្រូវបានបង្កើតឡើងក្រោមទីស្ដីការគណៈរដ្ឋមន្ត្រី ក្នុងឆ្នាំ២០១៥ ដើម្បីធ្វើជាឃ្លាំងដាក់ឯកសារសាធារណៈ "ទាំងសំណៅរឹង និងទាំងសំណៅអេឡិចត្រូនិច ដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក. សម្រាប់គោលបំណងអប់រំ និងស្រាវជ្រាវ។" អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ការធ្វើឱ្យរឿងរ៉ាវរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលប្រើប្រាស់បានកាន់តែងាយស្រួល អាចជាការទទួលស្គាល់ជាផ្លូវការអំពីព្យសនកម្មដែលខ្មែរក្រហមបានប្រព្រឹត្តលើពួកគាត់ រំលឹកបទពិសោធន៍របស់ពួកគាត់ និងធានាថាការរងទុក្ខរបស់ពួកគាត់នឹងមិនត្រូវបានគេបំភ្លេចចោលនោះទេ។

ទោះបីជាការងាររួមគ្នារវាង អ.វ.ត.ក. និង ម.ត.ឯ.ច. ក៏ដោយ ក៏មជ្ឈមណ្ឌលធនធាន អ.វ.ត.ក. បន្តផ្ដល់លទ្ធភាពប្រើប្រាស់សម្ភារៈសាធារណៈរបស់ អ.វ.ត.ក. នៅកណ្ដាលរាជធានីភ្នំពេញ។

| | |
|---|---|
| **ដៃគូអនុវត្ត** | មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក., អ.វ.ត.ក. |
| **ម្ចាស់ជំនួយ** | រាជរដ្ឋាភិបាលកម្ពុជា |
| **រយៈពេលគម្រោង** | កំពុងដំណើរការ |
| **ទីតាំង** | ភ្នំពេញ |

## ៦.៣.១១. ការព្យាបាលនិងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

គម្រោងសំណាងនេះជួយជនរងគ្រោះ-អ្នករស់រានមានជីវិតនៃអំពើទារុណកម្ម អំពើហិង្សាផ្លូវភេទ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងភាពអត់ឃ្លាន ក្នុងចំណោមឧក្រិដ្ឋកម្មផ្សេងទៀត ដើម្បីព្យាបាលតាមរយៈសេវាផ្លូវចិត្ត។ ធ្វើការនៅកម្រិតសហគមន៍ អ្នកសម្របសម្រួលបានផ្ដល់វគ្គអប់រំផ្លូវចិត្ត ការព្យាបាលជាបុគ្គល និងជាក្រុម ការសន្ទនាតាមសហគមន៍ វេទិកាជាតិ និងការកសាងសមត្ថភាព។ គម្រោងនេះបានអនុវត្តវិធីសាស្ត្ររួម និងសម្របសម្រួល ដើម្បីដោះស្រាយតម្រូវការសុខភាពផ្លូវចិត្ត បន្ទាប់ពីអំពើហិង្សាដ៏យូរអង្វែង។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមមានអាយុចន្លោះពី ៥០-៧០ ឆ្នាំ និងរស់នៅតាមសហគមន៍ជនបទ។

> *"បន្ទាប់ពីការចូលរួមក្នុងការព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្មជាមួយអង្គការ TPO ខ្ញុំសង្កេតឃើញថា ខ្ញុំមានអារម្មណ៍ធូរស្បើយបាន៧០%។ នៅពេលណាដែលខ្ញុំនឹកឃើញរឿងអតីតកាល និងរឿងសោកសៅ ខ្ញុំបានប្រឈមជាមួយនឹងអារម្មណ៍របស់ខ្ញុំដោយការធ្វើសមាធិ និងលំហាត់ដកដង្ហើម។ ដូច្នេះ បញ្ហារបស់ខ្ញុំដូចជាការគិតច្រើន កំហឹង ឈឺក្បាល និងតឹងទ្រូង ត្រូវបានកាត់បន្ថយ។ លំហាត់ទាំងនេះក៏ជួយខ្ញុំឱ្យបំភ្លេចវាផងដែរ ព្រោះការលំបាកទាំងនេះបានកន្លងផុតទៅហើយ។ម្យ៉ាងទៀត នៅពេលអ្នកជិតខាងខ្ញុំអានសក្ខីកម្មរបស់ខ្ញុំ ខ្ញុំមាន*

*អារម្មណ៍ថា ពួកគេយល់ពីការលំបាករបស់ខ្ញុំ ហើយចែករំលែកការឈឺចាប់ជាមួយខ្ញុំ"*។ - អ្នកចូលរួម

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការចិត្តសង្គមអន្តរវប្បធម៌ (TPO) |
| **ម្ចាស់ជំនួយ** | USAID |
| **រយៈពេលគម្រោង** | ៣ ឆ្នាំ |
| **ទីតាំង** | ក្រចេះ, ស្វាយរៀង, ត្បូងឃ្មុំ, កំពង់ឆ្នាំង, សៀមរាប, ពោធិ៍សាត់, កណ្ដាល, កំពង់ធំ, កំពង់ចាម, បាត់ដំបង, កំពត, តាកែវ, ព្រៃវែង, មណ្ឌលគិរី, កែប |

## ៦.៣.១២. ការអប់រំផ្នែកច្បាប់និងសិទ្ធិពលរដ្ឋដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនជាតិភាគតិច

គម្រោងសំណាងនេះត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយការធ្វើបាបលើក្រុមជនជាតិភាគតិចវៀតណាម ក្រោមរបបខ្មែរក្រហម។ គម្រោងនេះមានគម្រោងសាកល្បងផ្នែកអប់រំច្បាប់និងពលរដ្ឋ ព្រឹត្តិការណ៍ពិគ្រោះយោបល់នៅតាមសហគមន៍ ការផលិតសម្ភារៈផ្សព្វផ្សាយជាភាសាដែលអាចចូលប្រើបានសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី និងសិក្ខាសាលាផ្សព្វផ្សាយ និងអប់រំតាមសហគមន៍ចំនួនបី ដែលរៀបចំនៅលំនៅដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

គោលបំណងនៃគម្រោងនេះគឺផ្ដល់ការអប់រំ និងការផ្ដល់សិទ្ធិអំណាច តាមរយៈកិច្ចសហប្រតិបត្តិការជាមួយកម្មវិធីសង្គមស៊ីវិល ដែលចូលរួមក្នុងការផ្សព្វផ្សាយសហគមន៍គោលដៅ។ គម្រោងនេះបានផ្ដល់ចំណេះដឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណី អំពីការការពារដែលមាននៅក្រោមក្របខ័ណ្ឌច្បាប់ និងរដ្ឋបាលរបស់ប្រទេសកម្ពុជា ដើម្បីអាចឱ្យពួកគេដឹងជាផ្លូវការនូវអត្តសញ្ញាណស្របច្បាប់របស់ខ្លួន និងរបស់កូនពួកគេយោងទៅតាមច្បាប់។

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការការពារសិទ្ធិជនជាតិភាគតិច (MIRO) |
| **ម្ចាស់ជំនួយ** | ក្រសួងសហប្រតិបត្តិការនិងអភិវឌ្ឍសេដ្ឋកិច្ចអាល្លឺម៉ង់ តាមរយៈ GIZ-សេវាសន្តិភាពពលរដ្ឋ |
| **រយៈពេលគម្រោង** | ១២ ខែ |
| **ទីតាំង** | កំពង់ឆ្នាំង |

## ៦.៣.១៣. ការគាំពារ និងការផ្ដល់ប្រឹក្សាអំពីសុខភាពផ្លូវចិត្ត

គម្រោងសំណាងនេះបានផ្ដល់ជំនួយសុខភាពផ្លូវចិត្ត និងការប្រឹក្សា ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានវ័យចំណាស់។ វាបានជួយដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការប្រឈមនឹងរបួសផ្លូវចិត្ត ជំងឺបាក់ទឹកចិត្ត និងជំងឺថប់បារម្ភ និងបានលើកកម្ពស់ការផ្សះផ្សា និងការជាសះស្បើយ ក្នុងចំណោមជំនាន់មនុស្ស។ គម្រោងនេះបានដោះស្រាយយ៉ាងសកម្មអំពីជីវភាពរស់នៅ បរិយាបន្នសង្គម តម្រូវការផ្នែកផ្លូវចិត្ត និងផ្នែករូបវន្តរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងកាន់តែទូលាយជាងនេះទៀតនោះ គឺជនរងគ្រោះ-អ្នករស់រានមានជីវិតដែល "មិនមានតំណាង"។

*"ខ្ញុំរីករាយណាស់ដែលបានចូលរួមជាមួយសមាគមមនុស្សចាស់ និងបានជជែកជាមួយមនុស្សចាស់ផ្សេងទៀត។ យើងនិយាយហើយយើងចែករំលែកច្រើន អំពីរឿងរ៉ាវដែលយើងបានជួបកន្លងមក"* -ដើមបណ្ដឹងរដ្ឋប្បវេណីមកពីខេត្តបន្ទាយមានជ័យ

| | |
|---|---|
| **ដៃគូអនុវត្ត** | អង្គការ HelpAge កម្ពុជា |
| **ម្ចាស់ជំនួយ** | សហភាពអឺរ៉ុបតាមរយៈ UNOPS, ភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ |
| **រយៈពេលគម្រោង** | ២៥ ខែ |
| **ទីតាំង** | បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប |

## ៧. មុខងារសេសសល់

### ៧.១. ដំណើរការពិគ្រោះយោបល់

ខណៈពេលដែល អ.វ.ត.ក. បានបន្តដំណើរការការងាររបស់ខ្លួន និងប្រមើលជាមុនអំពីចុងបញ្ចប់នៃបន្ទុករឿងក្តីរបស់ខ្លួន វាគឺជារឿងចាំបាច់ក្នុងការពិចារណាលើអ្វីដែលត្រូវកើតឡើងចំពោះ អ.វ.ត.ក. នៅពេលដែល អ.វ.ត.ក. បានបញ្ចប់អាណត្តិតុលាការរបស់ខ្លួនយោងតាមមាត្រា ១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា។ នៅខែកញ្ញា ឆ្នាំ២០១៨ គណៈកម្មាធិការដឹកនាំរបស់ អ.វ.ត.ក. បានសរសេរលិខិតទៅកាន់ UNSG ស្នើសុំឱ្យ អ.វ.ត.ក. និងរាជរដ្ឋាភិបាលកម្ពុជា ពិគ្រោះយោបល់គ្នា និងចាប់ផ្តើមបង្កើតក្របខ័ណ្ឌមួយសម្រាប់ការបញ្ចប់ការងារ អ.វ.ត.ក. និងសម្រាប់កំណត់មុខងារសេសសល់ដែលពាក់ព័ន្ធ ដែលត្រូវការអនុវត្ត បន្ទាប់ពីការបញ្ចប់អាណត្តិ។ គណៈកម្មាធិការដឹកនាំនេះក៏បានស្នើសុំឱ្យដាក់របាយការណ៍មួយនៅចុងខែមិថុនា ឆ្នាំ២០១៩ ផងដែរ[1536]។

ពីថ្ងៃទី១៤ ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ទីប្រឹក្សាច្បាប់ អ.ស.ប. និងអគ្គលេខាធិការរងនៃការិយាល័យកិច្ចការច្បាប់ បានមកបំពេញទស្សនកិច្ចនៅកម្ពុជា ក្នុងពេលចេញសាលក្រមសំណុំរឿង ០០២/០២។ ក្នុងដំណើរទស្សនកិច្ចនោះ លោកបានជួបជាមួយភាគីពាក់ព័ន្ធរបស់ អ.វ.ត.ក. រួមទាំងឧបនាយករដ្ឋមន្ត្រី អ្នកសម្របសម្រួល UNAKRT និងប្រធានរដ្ឋបាលស្តីទី ដើម្បីពិភាក្សាអំពីការបង្កើតក្របខ័ណ្ឌ និងអាណត្តិដែលនៅសល់របស់ អ.វ.ត.ក.។ លោកក៏បានជួបជាមួយសហព្រះរាជអាជ្ញា និងចៅក្រមនៃ អ.វ.ត.ក. ផងដែរ ដើម្បីបង្ហាញប្រាប់ពួកគេអំពីគោលបំណងនៃបេសកកម្ម និងស្តាប់ទស្សនៈរបស់ពួកគេលើការងារតុលាការរបស់ អ.វ.ត.ក. និងមុខងារសេសសល់របស់វាដែលអាចមាន។ នៅក្នុងជំនួបនោះ ពួកគេបានចាត់តាំងជនបង្គោលសម្រាប់បន្តការពិភាក្សាលើមុខងារសេសសល់ ហើយបានដឹកភាពគ្នាថា ការពិភាក្សាបែបនេះនឹង "អនុវត្តតាមកម្រិតការងារ"[1537]។

តំណាងមកពីការិយាល័យកិច្ចការច្បាប់បានមកទស្សនកិច្ចនៅភ្នំពេញជាបន្តបន្ទាប់ ពីថ្ងៃទី៤ ដល់ទី៨ ខែកុម្ភៈ ឆ្នាំ២០១៩ និងបានជួបជាមួយតំណាងរាជរដ្ឋាភិបាលកម្ពុជា អ្នកសម្របសម្រួល UNAKRT និងសមាជិកមកពីការិយាល័យផ្សេងៗនៃ អ.វ.ត.ក. ដើម្បីបន្តបង្កើតក្របខ័ណ្ឌសម្រាប់ការបញ្ចប់អាណត្តិរបស់ អ.វ.ត.ក. និងកំណត់មុខងារសេសសល់របស់វា។ បន្ទាប់ពីជំនួបក្នុងខែកុម្ភៈ ឆ្នាំ២០១៩ ការិយាល័យកិច្ចការច្បាប់ បានចេញរបាយការណ៍មួយស្តីពីលទ្ធផលបឋមនៃការពិគ្រោះយោបល់ និងបានដាក់របាយកាណ៍នេះទៅកាន់គណៈកម្មាធិការដឹកនាំ UNAKRT នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩[1538] ខណៈដែលការពិគ្រោះយោបល់នៅបន្តធ្វើ[1539]។

ក្នុងអំឡុងពេលពិគ្រោះយោបល់រវាង អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា ភាគីទាំងពីរបានគាំទ្រស្ថាប័នមុខងារសេសសល់ ដែលមានទាំងសមាសភាពភាគីជាតិ និងភាគីអន្តរជាតិ។ វាច្បាស់ណាស់ថា មុខងារសេសសល់គប្បីរួមបញ្ចូលទៅក្នុងក្របខ័ណ្ឌ និងរចនាសម្ព័ន្ធបច្ចុប្បន្ន ជាជាងព្យាយាមបង្កើតស្ថាប័នមុខងារសេសសល់ថ្មី[1540]។ ចំណុចនេះគឺជាមូលដ្ឋានដែលការពិគ្រោះយោបល់បានបន្ត ដោយបានបញ្ចប់ក្នុងសេចក្តីព្រាងកិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានភ្ជាប់ទៅនឹងរបាយការណ៍របស់ UNSG ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ស្តីពីការបញ្ចប់ការពិគ្រោះយោបល់[1541]។

---

[1536] របាយការណ៍ UNSG អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មុខងារសេសសល់ ឯកសារ A/75/809 ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ("របាយការណ៍ UNSG")។

[1537] របាយការណ៍ UNSG កថាខណ្ឌ ២៧។

[1538] របាយការណ៍ UNSG កថាខណ្ឌ ២៨-២៩។

[1539] សូមមើល UNGA សេចក្តីសម្រេចចិត្តដែលបានអនុម័តដោយមហាសន្និបាត ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ កម្មវត្ថុពិសេសពាក់ព័ន្ធនឹងកម្មវិធីចិរកាស្នើឡើងសម្រាប់ឆ្នាំ២០២០ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ឯកសារ A/RES/74/263។ UNGA, សេចក្តីសម្រេចចិត្តដែលបានអនុម័តដោយមហាសន្និបាត នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មុខងារសេសសល់ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ ឯកសារ A/RES/75/257។

[1540] របាយការណ៍ UNSG កថាខណ្ឌ ៣២។

[1541] កិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា កថាខណ្ឌ ៣១ ឧបសម្ព័ន្ធ។

កិច្ចព្រមព្រៀងបន្ថែមនេះក្រោយមកត្រូវបានអនុម័តដោយ UNGA[1542] ប្រកាសឱ្យប្រើដោយព្រះបាទនរោត្តម សីហមុនី និងត្រូវបានផ្តល់ស័ច្ចាប័នដោយរាជរដ្ឋាភិបាលកម្ពុជា[1543] ដែលចូលជាធរមាននៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២១។

## ៧.២. កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀង អ.វ.ត.ក.

កិច្ចព្រមព្រៀងបន្ថែមចែងថា អ.វ.ត.ក. អនុវត្តមុខងារសេសសល់របស់ខ្លួន សម្រាប់រយៈពេលបីឆ្នាំដំបូង បន្ទាប់ពីការបញ្ចប់កិច្ចដំណើរការនីតិវិធី[1544]។ ក្នុងអំឡុងរយៈពេលដំបូងនេះ អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវពិនិត្យវឌ្ឍនភាពរបស់ អ.វ.ត.ក. និងកំណត់ថាតើខ្លួនគួរបន្តអនុវត្តមុខងារឬយ៉ាងណា ឬក៏មួយផ្នែកនៃកិច្ចព្រមព្រៀងនោះ និងសម្រាប់រយៈពេលប៉ុន្មាន។ មុខងារសេសសល់ដែលត្រូវអនុវត្តរួមមាន[1545]៖

- ពិនិត្យលើការអនុវត្ត និងដឹកនាំធ្វើចំណាត់ការលើការពិនិត្យសាលដីកាស្ថាពរ[1546]
- ផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី
- ដាក់ទណ្ឌកម្ម ឬបញ្ជូនទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច នូវជនណាដែលបង្កការជ្រៀតជ្រែកដោយចេតនាទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ឬការផ្តល់សក្ខីកម្មក្លែងក្លាយ
- គ្រប់គ្រងការអនុវត្តទោស និង តាមដានលើការប្រព្រឹត្តចំពោះទណ្ឌិត
- ថែទាំ រក្សាទុក និងគ្រប់គ្រងបណ្ណសាររបស់ អ.វ.ត.ក.
- ឆ្លើយតបទៅនឹងសំណើសុំសិទ្ធិចូលពិនិត្យមើលឯកសារ
- ផ្សព្វផ្សាយព័ត៌មានដល់សាធារណជន និងតាមដានលើការអនុវត្តសំណងដែលបានផ្តល់ជូនដើមបណ្តឹងរដ្ឋប្បវេណី។

ទាក់ទងនឹងបណ្ណសាររបស់ខ្លួន អ.ស.ប. និង រាជរដ្ឋាភិបាលកម្ពុជា "ព្រមព្រៀងថា ជាការសំខាន់ដែលធានាថាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញត្រូវបានរក្សាទុកដោយអនុលោមតាមបទដ្ឋានអន្តរជាតិ ហើយសាធារណជនអាចចូលមើលបានយ៉ាងទូលំទូលាយ"[1547]។ ដើម្បីរក្សាទុក និងផ្សព្វផ្សាយអំពីកេរដំណែលរបស់ខ្លួន អ.វ.ត.ក. ត្រូវអនុញ្ញាតឱ្យសាធារណជនចូលប្រើប្រាស់សំណៅអេឡិចត្រូនិក និងសំណៅបោះពុម្ពនៅក្នុងបណ្ណសារសាធារណៈរបស់ខ្លួន[1548]។ ទាំងរាជរដ្ឋាភិបាលកម្ពុជា និងទាំង អ.ស.ប. នឹងទទួលបានសំណុំបណ្ណសារសាធារណៈរបស់ អ.វ.ត.ក. មួយច្បាប់ម្នាក់ ក្នុងអំឡុងពេលដំណាក់កាលមុខងារសេសសល់នេះ ព្រមទាំងឯកសារនិងសម្ភារៈសម្ងាត់ពេញលេញនៅពេលបញ្ចប់មុខងារសេសសល់[1549]។

កិច្ចព្រមព្រៀងបន្ថែមចែងថា ក្នុងអំឡុងពេលដំណាក់កាលមុខងារសេសសល់ ចៅក្រម អ.វ.ត.ក. ត្រូវទទួលបានបៀវត្សរ៍ដោយសមាមាត្រទៅនឹងការងារតែប៉ុណ្ណោះ និងត្រូវធ្វើការពីចម្ងាយ លើកលែងតែនៅពេលត្រូវការមានវត្តមាននៅ អ.វ.ត.ក. តាមការស្នើសុំរបស់ប្រធានអង្គជំនុំជម្រះ[1550]។ ដូចគ្នានេះដែរ សហព្រះរាជអាជ្ញា មេធាវីការពារក្តី និង សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ត្រូវទទួលបានបៀវត្សរ៍ដោយសមាមាត្រទៅនឹងការងារតែប៉ុណ្ណោះ និងត្រូវធ្វើការពីចម្ងាយ លើកលែងតែ នៅពេលដែលមុខ

---

[1542] UNGA, សេចក្តីសម្រេចចិត្តដែលបានអនុម័តដោយមហាសន្និបាត នៅថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា - មុខងារសេសសល់ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ ឯកសារ អ.ស.ប. លេខ A/RES/75/257 B ឧបសម្ព័ន្ធ។

[1543] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា ចូលជាធរមានថ្ងៃទី ១២ ខែមករា ឆ្នាំ ២០២២។

[1544] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១។

[1545] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២(១)-(២)។

[1546] សំណើសុំពិនិត្យសាលដីកាអាចធ្វើបានតែក្នុងអំឡុងពេលទណ្ឌិតនៅមានជីវិតប៉ុណ្ណោះ ដោយទណ្ឌិតផ្ទាល់ ឬដោយសហព្រះរាជអាជ្ញា។ សូមមើល កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា២(៣)។

[1547] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣។

[1548] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣(២)។

[1549] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៣(៣)។

[1550] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១។

ងារពួកគេតម្រូវឱ្យមានវត្តមាននៅ អ.វ.ត.ក.។ កិច្ចប្រជុំពេញអង្គរបស់តុលាការត្រូវធ្វើពីចម្ងាយ ហើយវិសោធនកម្មវិធានផ្ទៃក្នុងត្រូវធ្វើពីចម្ងាយដោយនីតិវិធីជាលាយលក្ខណ៍អក្សរ[1551]។

អ.វ.ត.ក. បានចាប់ផ្តើមមុខងារសេសសល់របស់ខ្លួននៅថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ បន្ទាប់ពីការបញ្ចប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ និងការចេញសាលដីកាក្នុងសំណុំរឿង ០០២/០២។

[1551] កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២(៥)។

## ៨. ឧបសម្ព័ន្ធ

### ៨.១. ឧបសម្ព័ន្ធ ១៖ អានបន្ថែម

គោលបំណងនៃឯកសារបោះពុម្ពផ្សាយរៀបរាប់ខាងក្រោមនេះ គឺសម្រាប់ប្រើប្រាស់ជាការណែនាំចំពោះការអានបន្ថែម និងព័ត៌មានបន្ថែម។ ដូច្នេះ ការដាក់បញ្ចូលឯកសារទាំងនេះមិនបង្កើតបានជាការឯកភាពដោយផ្ទាល់ឬដោយប្រយោលរបស់ អ.វ.ត.ក. លើខ្លឹមសាររបស់ឯកសារទាំងនោះឡើយ។ ប្រសិនបើឯកសារបោះពុម្ពផ្សាយទាំងនេះ ឬផ្នែកណាមួយនៅក្នុងឯកសារទាំងនេះ ត្រូវបានយោងដោយការិយាល័យតុលាការ និងអង្គជំនុំជម្រះរបស់ អ.វ.ត.ក. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន អ្នកអានគប្បីត្រូវបានណែនាំដោយសុចរិតភាព ភាពអាចជឿជាក់បាន និងការវាយតម្លៃទម្ងន់នៅក្នុងឯកសារនោះ។

<u>**ជំពូក១**</u>

**ប្រវត្តិសាស្ត្រខ្មែរក្រហម និងកម្ពុជាប្រជាធិបតេយ្យ**

**ក. ឯកសារ អ.វ.ត.ក.**

- សំណុំរឿង ០០១ សាលក្រម ឯកសារ E188 (ផ្នែក ២.១, ២.៣, ៣.២)
- សំណុំរឿង ០០២ ដីកាដំណោះស្រាយ ឯកសារ D427 (ជំពូក ១)
- សំណុំរឿង ០០២/០១ សាលក្រម ឯកសារ E313 (ជំពូក ៣)
- សំណុំរឿង ០០២/០២ សាលក្រម ឯកសារ E465 (ជំពូក ៣-៦)
- សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងចោទប្រកាន់ ឯកសារ D266 (ជំពូក ៣)
- សំណុំរឿង ០០៣ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D267 (ផ្នែក ៥.១)
- សំណុំរឿង ០០៤ ដីកាសម្រេចលើកលែងចោទប្រកាន់ ឯកសារ D381 (ជំពូក ៣)
- សំណុំរឿង ០០៤ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D382 (ជំពូក ៥)
- សំណុំរឿង ០០៤/០២ ដីកាសម្រេចលើកលែងចោទប្រកាន់ ឯកសារ D359 (ជំពូក ២)
- សំណុំរឿង ០០៤/០២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ឯកសារ D360 (ជំពូក ៦)

**ខ. ការបោះពុម្ពផ្សាយផ្សេងទៀត**

- សៀវភៅនិពន្ធដោយ Elizabeth Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* (ផ្នែកកិច្ចការសាធារណៈ: ១៩៨៦)
- សៀវភៅនិពន្ធដោយ François Bizot, *The Gate* (Vintage, 2011)
- សៀវភៅនិពន្ធដោយ Nayan Chanda *សត្រូវបងប្អូនឯង៖* សង្គ្រាមក្រោយសង្គ្រាម (MacMillan ១៩៨៦)
- សៀវភៅនិពន្ធដោយ David Chandler *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា* (Routledge បោះពុម្ពលើកទី៤ ឆ្នាំ ២០០៧)
- សៀវភៅនិពន្ធដោយ David Chandler បងទី១៖ ប្រវត្តិនយោបាយរបស់ ប៉ុល ពត (Westview Press ២០០០)
- សៀវភៅនិពន្ធដោយ David Chandler, The Tragedy of Cambodian History: Politics, War, and Revolution Since 1945 (Silkworm Books, 1991)
- សៀវភៅនិពន្ធដោយ David Chandler *សំឡេងពីមន្ទីរស-២១* (University of California Press ១៩៩៩)

- សៀវភៅនិពន្ធដោយ David Chandler និងអ្នកនិពន្ធផ្សេងទៀត (Eds), Pol Pot Plans the Future: Confidential Leadership Documents from Democratic Kampuchea, 1976-1977 (New Haven, Connecticut, Yale University Southeast Asia Studies 1988)
- សៀវភៅនិពន្ធដោយ Howard J. De Nike និងអ្នកនិពន្ធផ្សេងទៀត (eds), Genocide in Cambodia: Documents from the Trial of Pol Pot and Ieng Sary (University of Pennsylvania Press, 2000)
- សៀវភៅនិពន្ធដោយ Nic Dunlop *ពេជ្ឈឃាតបាត់ខ្លួន* (Walker & Co ២០០៦)
- សៀវភៅនិពន្ធដោយ Craig Etcheson, The Rise and Fall of Democratic Kampuchea (Routledge, 1984)
- សៀវភៅនិពន្ធដោយ Alexander Hinton, *Why Did They Kill? Cambodia in the Shadow of Genocide* (University of California Press, 2005)
- សៀវភៅនិពន្ធដោយ Henry Kamm, *Cambodia: Report from a Stricken Land* (Arcade Publishing, 1998)
- សៀវភៅនិពន្ធដោយ Khieu Samphan៖ *ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់* (រោងពុម្ពពន្លឺខ្មែរ ២០០៤)
- សៀវភៅនិពន្ធដោយ Ben Kiernan៖ *តើ ប៉ុល ពត ចូលកាន់អំណាចបែបណា?*៖ អាណានិគមនិយម ជាតិនិយម និង សង្គមនិយមក្នុងប្រទេសកម្ពុជា, ១៩៣០-១៩៧៥ (Yale University Press ១៩៨៤)
- សៀវភៅនិពន្ធដោយ Ben Kiernan៖ របប ប៉ុល ពត៖ ជាតិសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្រោមរបបខ្មែរក្រហម, ពីឆ្នាំ១៩៧៥-១៩៧៩ (បោះពុម្ពលោកទី៣ ឆ្នាំ២០០៨)
- សៀវភៅនិពន្ធដោយ Ben Kiernan and Chanthou Boua (eds.), *Peasants and Politics in Kampuchea 1942-1981* (1982)
- សៀវភៅនិពន្ធដោយ Henri Locard, Pol Pot's Little Red Book: The Sayings of Angkar (Silkworm Books, 2005)
- សៀវភៅនិពន្ធដោយ Andrew Mertha, Brothers in Arms: Chinese Aid to the Khmer Rouge, 1975-1979 (Cornell University Press, 2014)
- សៀវភៅនិពន្ធដោយ Stephen J. Morris, Why Vietnam Invaded Cambodia: Political Culture and the Causes of War (Stanford University Press, 1999)
- សៀវភៅនិពន្ធដោយ អ៊ីសា ឧស្មាន៖ The Cham Rebellion: Survivors' Stories from the Villages (មជ្ឈមណ្ឌលឯកសារកម្ពុជា ២០០៦)
- សៀវភៅនិពន្ធដោយ អ៊ីសា ឧស្មាន៖ OUKOUBAH – Justice for the Cham Muslims under the Democratic Kampuchea Regime (មជ្ឈមណ្ឌលឯកសារកម្ពុជា ២០០២)
- សៀវភៅនិពន្ធដោយ នរោត្តម សីហនុ៖ Shadow Over Angkor, Vol. One: Memoirs of His Majesty King Norodom Sihanouk of Cambodia (3DGraphics Publishing, 2005)
- សៀវភៅនិពន្ធដោយ François Ponchaud *កម្ពុជា ឆ្នាំសូន្យ* (Henry Holt & Co., ១៩៧៨)

- សៀវភៅនិពន្ធដោយ William Shawcross, Sideshow: Kissinger, Nixon, and the Destruction of Cambodia (Cooper Square Press, 2002)
- សៀវភៅនិពន្ធដោយ Philip Short, *Pol Pot: Anatomy of a Nightmare* (Herry Holt and Co. 2005)
- សៀវភៅនិពន្ធដោយ ហ៊ុយ វណ្ណៈ៖ កងពលធំខ្មែរក្រហមលេខ ៧០៣៖ ពីជ័យជំនះទៅការបំផ្លាញខ្លួនឯង (មជ្ឈមណ្ឌលឯកសារកម្ពុជា ២០០៣)
- សៀវភៅនិពន្ធដោយ Michael Vickery, *Cambodia, 1975-1982* (South End Press, 1983)
- សៀវភៅនិពន្ធដោយ Michael Vickery, *Kampuchea, Politics, Economy and Society* (L. Rienner Publishers, 1986)

## ជំពូក ២

## ការចរចា ការបង្កើត និងប្រតិបត្តិការរបស់ អ.វ.ត.ក.

### ក. ឯកសាររាជរដ្ឋាភិបាលកម្ពុជា

- ព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស លេខ. នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦
- រាជរដ្ឋាភិបាលកម្ពុជា ការិយាល័យព្រះរាជអាជ្ញាយោធា ដីកាបញ្ជូនសំណុំរឿងទៅស៊ើបអង្កេត (ដីកាបញ្ជូនរឿងទៅជំនុំជម្រះទី១របស់ អ៊ុង ជឿន ហៅ តាម៉ុក) ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ តុលាការយោធា លេខ 019/99
- រាជរដ្ឋាភិបាលកម្ពុជា ការិយាល័យព្រះរាជអាជ្ញាយោធា ដីកាបញ្ជូនសំណុំរឿងទៅស៊ើបអង្កេតលើកទីពីរ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះទី១ របស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច) តុលាការយោធា ឯកសារលេខ 029/99 ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩។
- រដ្ឋសភាជាតិ និងព្រឹទ្ធសភាអនុម័តច្បាប់ អ.វ.ត.ក. នៅថ្ងៃទី២ និងទី ១៥ ខែមករា ឆ្នាំ២០០១ នស/រកម/០៨០១/១២
- ព្រះរាជក្រឹត្យតែងតាំងសមាសភាពមន្ត្រីតុលាការ លេខ នស/រកត/០៥០៦/២១៤ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦
- ឯកសារតុលាការយោធា ពាក់ព័ន្ធនឹង កាំង ហ្គេកអ៊ាវ ហៅ ឌុច កាលបរិច្ឆេទច្រើន ឯកសារ C5/5

### ខ. ឯកសារ អ.ស.ប.

- ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម អ.ស.ប. ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា៖ របាយការណ៍របស់តំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក Thomas Hammarberg ដាក់អនុលោមតាមសេចសម្រេចចិត្តរបស់គណៈកម្មការលេខ ១៩៩៦/៥៤ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩៧ ឯកសារ អ.ស.ប.លេខ E/CN.4/1997/85
- គណៈកម្មការសិទ្ធិមនុស្ស របាយការណ៍ស្តីពីសម័យប្រជុំលើកទីហាសិបបី (ថ្ងៃទី១០ ខែមីនា-១៨ ខែមេសា ឆ្នាំ១៩៩៧) បំពេញបន្ថែមលេខ.៣ ឯកសារ អ.ស.ប. លេខ E/1997/23 E/CN.4/1997/150
- UNGA/UNSC, លិខិតចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ពីនាយករដ្ឋមន្ត្រីទីមួយ និងទីពីរ របស់ប្រទេសកម្ពុជា ផ្ញើជូនអគ្គលេខាធិការ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ឯកសារ A/51/930 S/1997/488

- UNGA, សេចក្តីសម្រេចចិត្តៈ ស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ ឯកសារ អ.ស.ប. លេខ A/RES/52/135
- UNGA, លិខិតចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៨ ពីអគ្គលេខាធិការ ទៅកាន់មហាសន្និបាត ផ្ញើជូនប្រធានមហាសន្និបាត ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៩៨ ឯកសារ អ.ស.ប. លេខ A/52/1007
- UNGA/UNSC, លិខិតចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៩ ពីនាយករដ្ឋមន្ត្រីកម្ពុជា ផ្ញើជូនអគ្គលេខាធិការ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប. លេខ A/53/851 S/1999/230 ឧបសម្ព័ន្ធ
- UNGA/UNSC, របាយការណ៍របស់ក្រុមអ្នកជំនាញសម្រាប់កម្ពុជា ដែលត្រូវបានបង្កើតឡើងអនុលោមតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 52/135 នៅក្នុង លិខិតដូចគ្នាចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ពីអគ្គលេខាធិការផ្ញើជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ ឯកសារ អ.ស.ប. លេខ A/53/850-S/1999/231
- បណ្ណសារ អ.ស.ប. "លិខិតពីលោក Kofi Annan ផ្ញើជូនសម្តេច ហ៊ុន សែន ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០០" ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០០ ឯកសារលេខ S-1096-0225-05-00024
- បណ្ណសារ អ.ស.ប. "លិខិតឆ្លើយឆ្លងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០០០" ចុះថ្ងៃទី២០-២១ ខែមីនា ឆ្នាំ២០០០ ឯកសារលេខ S-1096-0225-05-00021
- សន្និសីទសារព័ត៌មានប្រចាំថ្ងៃ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២។
- បណ្ណសារ អ.ស.ប. "ក្រៅផ្លូវការ៖ ការកាត់ទោសខ្មែរក្រហម" ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០០៣ ឯកសារលេខ S-1094-0010-03-00021
- UNGA, សេចក្តីសម្រេចចិត្តដែលបានអនុម័តដោយមហាសន្និបាត លេខ 57/228 ការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ ឯកសារ អ.ស.ប. លេខ A/RES/57/228
- សេចក្តីប្រកាសព័ត៌មាន អ.ស.ប. សេចក្តីព្រាងអត្ថបទស្តីពីការកាត់ក្តីខ្មែរក្រហម ដែលបានបង្ហាញក្នុងគណៈកម្មការទីបី ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៣
- សេចក្តីប្រកាសព័ត៌មាន អ.ស.ប. គណៈកម្មការទីបីអនុម័តសេចក្តីព្រាងសេចក្តីសម្រេចចិត្តស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៣
- អ.ស.ប. *មហាសន្និបាតអនុម័តសេចក្តីព្រាងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងកម្ពុជា ស្តីពីការកាត់ក្តីខ្មែរក្រហម* ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ ឯកសារ អ.ស.ប. លេខ GA/10135
- សន្និសីទសារព័ត៌មានប្រចាំថ្ងៃ អ.ស.ប. ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៤

## ៨.២. ឧបសម្ព័ន្ធ២៖ ក្រមខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌប្រតិបត្តិ

### ក. ឯកសារគន្លឹះ

- ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានធ្វើវិសោធនកម្ម (ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤) - ច្បាប់ អ.វ.ត.ក.
- កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣) - កិច្ចព្រមព្រៀងរវាង អ.ស.ប. នឹងរាជរដ្ឋាភិបាលកម្ពុជា

- កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្តីពី ការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់ អ.វ.ត.ក. (ថ្ងៃទី១២ ខែមករា ឆ្នាំ ២០២២) - កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាង អ.ស.ប. និងរាជរដ្ឋាភិបាលកម្ពុជា
- កិច្ចព្រមព្រៀងបំពេញបន្ថែមរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បន្ថែមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ទាក់ទងទៅនឹងឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម (ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៤) - កិច្ចព្រមព្រៀងបំពេញបន្ថែមលើឧបករណ៍ប្រើប្រាស់ បរិក្ខារ និងសេវាកម្ម ដូចដែលបានធ្វើវិសោធនកម្ម (ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១)
- កិច្ចព្រមព្រៀងបំពេញបន្ថែមរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បន្ថែមលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ទាក់ទងទៅនឹងសុវត្ថិភាព និងសន្តិសុខ (ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៤) - កិច្ចព្រមព្រៀងបំពេញបន្ថែមទៅលើសុវត្ថិភាព និងសន្តិសុខ
- វិធានផ្ទៃក្នុង វិសោធនកម្មលើកចុងក្រោយ វិសោធនកម្មទី១០ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២

**ខ. របាយការណ៍អគ្គលេខាធិការ អ.ស.ប.**

- របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ឯកសារ A/57/769
- របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៣ ឯកសារ A/58/617
- របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៤ ឯកសារ A/59/432
- របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការកាត់ក្តីខ្មែរក្រហម – កិច្ចព្រមព្រៀងបន្ថែម ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ឯកសារ A/59/432/Add.1
- របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៥ ឯកសារ A/60/565
- របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ឯកសារ A/62/304
- របាយការណ៍របស់អគ្គលេខាធិការ ស្តីពីការកាត់ក្តីខ្មែរក្រហម ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២ ឯកសារ A/67/380
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ឯកសារ A/68/532
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ ឯកសារ A/69/536
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ A/70/403

- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ឯកសារ A/71/338
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ ឯកសារ A/72/341
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ឯកសារ A/73/331
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ A/74/359
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២០ ឯកសារ A/75/242
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ ឯកសារ A/76/331
- របាយការណ៍របស់អគ្គលេខាធិការ៖ សំណើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០២២ ឯកសារ A/77/513
- របាយការណ៍ស្តីពីការប្រើប្រាស់សិទ្ធិអំណាចការប្តេជ្ញាចិត្ត និងការស្នើសុំកញ្ចប់ថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៣ A/78/515

### គ. ឯកសារ អ.ស.ប. ទាក់ទងនឹងមុខងារសេសសល់

- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា – មុខងារសេសសល់ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ឯកសារ A/75/L.51
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា – មុខងារសេសសល់ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ឯកសារ A/75/L.51/Add.1
- សេចក្តីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ - អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា – មុខងារសេសសល់ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២១ ឯកសារ A/RES/75/257
- របាយការណ៍របស់អគ្គលេខាធិការ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា – មុខងារសេសសល់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ឯកសារ A/75/809
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា – មុខងារសេសសល់ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២១ ឯកសារ A/75/L.107
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា – មុខងារសេសសល់ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១ ឯកសារ A/RES/75/257 B

## ៨.៣. ឧបសម្ព័ន្ធ ៣៖ បញ្ជីឈ្មោះមន្ត្រីតុលាការសំខាន់ៗ

### ក. អង្គជំនុំជម្រះ

| អង្គជំនុំជម្រះតុលាការកំពូល | | |
|---|---|---|
| គង់ ស្រីម (ប្រធាន) | កម្ពុជា | ២០០៦ - |
| ម៉ុង មុន្នីចរិយា | កម្ពុជា | ២០០៦ - |
| សោម សិរីវឌ្ឍ | កម្ពុជា | ២០០៦ - |

| | | |
|---|---|---|
| យ៉ា ណារិន | កម្ពុជា | ២០០៦ - |
| Chandra Nihal JAYASINGHE | ស្រីលង្កា | ២០០៦ - |
| Florence Ndepele Mwachande MUMBA | សំប៊ី | ២០១២ - |
| Katrien Gabriël WITTEMAN | ហូឡង់ | ២០២៤ - |
| Motoo NOGUCHI | ជប៉ុន | ២០០៦ - ២០១២ |
| Agnieszka KLONOWIECKA-MILART | ប៉ូឡូញ | ២០០៦ - ២០១៨ |
| Maureen HARDING CLARK | អៀរឡង់ | ២០១៩ - ២០២២ |

| ***អង្គជំនុំជម្រះសាលាដំបូង*** | | |
|---|---|---|
| និល ណុន (ប្រធាន) | កម្ពុជា | ២០០៦ - |
| យូរ ឧត្តរា | កម្ពុជា | ២០០៦ - |
| យ៉ា សុខន | កម្ពុជា | ២០០៦ - |
| Claudia FENZ | អូទ្រីស | ២០១៤ - |
| Martin KAROPKIN | ស.រ.អ. | ២០១៩ - |
| Silvia CARTWRIGHT | នូវែលសេឡង់ | ២០០៦ - ២០១៤ |
| Jean-Marc LAVERGNE | បារាំង | ២០០៦ - ២០១៩ |

| ***អង្គបុរេជំនុំជម្រះ*** | | |
|---|---|---|
| ប្រាក់ គឹមសាន (ប្រធាន) | កម្ពុជា | ២០០៦ - |
| ហួត វុទ្ធី | កម្ពុជា | ២០០៦ - |
| ន័យ ថុល | កម្ពុជា | ២០០៦ - |
| BAIK Kang-Jin | កូរ៉េ | ២០១៥ - |
| Olivier BEAUVALLET | បារាំង | ២០១៥ - |
| Katina LAHUIS | ហូឡង់ | ២០០៦ - ២០១២ |
| Rowan DOWNING | អូស្ត្រាលី | ២០០៦ - ២០១៥ |
| Catherine MARCHI-UHEL | បារាំង | ២០១០ - ២០១១ |
| CHUNG Chang-Ho | កូរ៉េ | ២០១២ - ២០១៥ |

**ចៅក្រមបម្រុង៖**

***អង្គបុរេជំនុំជម្រះ***

- **ប៉ែន ពេជ្រសាលី** (កម្ពុជា)៖ ២០០៦-បច្ចុប្បន្ន
- **Katinka LAHUIS** (ហូឡង់)៖ ២០១០-២០១២
- **Stephen BWANA** (តង់សានី)៖ ២០១២-បច្ចុប្បន្ន

***អង្គជំនុំជម្រះសាលាដំបូង***

- **យូរ ឧត្តរា** (កម្ពុជា)៖ ២០០៦
- **ធូ មណី** (កម្ពុជា)៖ ២០០៦-បច្ចុប្បន្ន
- **Claudia FENZ** (អូទ្រីស)៖ ២០០៦-២០១៤
- **Martin KAROPKIN** (ស.រ.អ.)៖ ២០១៤-២០១៩

***អង្គជំនុំជម្រះតុលាការកំពូល***

- **ម៉ុង មុន្នីចរិយា** (កម្ពុជា)៖ ២០០៦-
- **ស៊ីន រិទ្ធ** (កម្ពុជា)៖ ២០០៦-បច្ចុប្បន្ន
- **Martin KAROPKIN** (ស.ស.អ.)៖ ២០០៦-២០០៨
- **Catherine MARCHI UHEL** (បារាំង)៖ ២០០៨-២០១០
- **Florence MUMBA** (សំប៊ី)៖ ២០១០-២០១២
- **Philip RAPOZA** (ស.រ.អ.)៖ ២០១២-២០២៤

•Motoo NOGUCHI (ជប៉ុន)៖ ២០២៤-បច្ចុប្បន្ន

## ខ. ការិយាល័យសហចៅក្រមស៊ើបអង្កេត

| សហចៅក្រមស៊ើបអង្កេត | | |
|---|---|---|
| យូ ប៊ុនឡេង | កម្ពុជា | ២០០៦ - |
| Michael BOHLANDER | អាល្លឺម៉ង់ | ២០១៥ - |
| Marcel LEMONDE | បារាំង | ២០០៦ - ២០១០ |
| Siegfried BLUNK | អាល្លឺម៉ង់ | ២០១០ - ២០១១ |
| Laurent KASPER-ANSERMET (បម្រុង) | ស្វីស | ២០១១ - ២០១២ |
| Mark HARMON | ស.រ.អ. | ២០១២ - ២០១៥ |

### សហចៅក្រមស៊ើបអង្កេតបម្រុង៖

- **ថោង អុល** (កម្ពុជា)៖ ២០០៦-
- **Siegfried BLUNK** (អាល្លឺម៉ង់)៖ ២០០៨-២០១០
- **Laurent KASPER-ANSERMET** (ស្វីស)៖ ២០១០-២០១១
- **Olivier BEAUVALLET** (បារាំង)៖ ២០១២-២០១៥
- **Maureen HARDING CLARK** (អៀរឡង់)៖ ២០១៥-២០១៩

## គ. ការិយាល័យសហព្រះរាជអាជ្ញា

| សហព្រះរាជអាជ្ញា | | |
|---|---|---|
| ជា លាង | កម្ពុជា | ២០០៦ - |
| Dale LYSAK | កាណាដា | ២០២៣ - |
| Robert PETIT | កាណាដា | ២០០៦ - ២០០៩ |
| Andrew CAYLEY | ចក្រភពអង់គ្លេស | ២០០៩ - ២០១៣ |
| Nicholas KOUMJIAN | ស.រ.អ. | ២០១៣ - ២០១៩ |
| Brenda HOLLIS | ស.រ.អ. | ២០១៩ - ២០២២ |

### សហព្រះរាជអាជ្ញាបម្រុង៖

- **ជួន ស៊ុនឡេង** (កម្ពុជា)៖ ២០០៦ - ២០២០
- **Paul COFFEY** (ស.រ.អ.)៖ ២០០៦ - ២០០៩
- **Nicholas KOUMJIAN** (ស.រ.អ.)៖ ២០០៩ - ២០១៥
- **Brenda J. HOLLIS** (ស.រ.អ.)៖ ២០១៥ - ២០១៩
- **Fergal GAYNOR** (អៀរឡង់)៖ ២០១៩ -

## ឃ. ការិយាល័យរដ្ឋបាល

| ប្រធាន និងអនុប្រធានរដ្ឋបាល | | |
|---|---|---|
| ស៊ាន វិសុទ្ធ (ប្រធាន) | កម្ពុជា | ២០០៦ - |
| ក្រាញ់ តូនី (ប្រធានស្ដីទី) | កម្ពុជា | ២០០៩ - |
| Knut ROSANDHAUG (អនុប្រធាន) | ន័រវែស | ២០០៨ - |
| Michelle LEE | ចិន | ២០០៦ - ២០០៨ |

## ៨.៤. ឧបសម្ព័ន្ធ ៤៖ ឯកសារសំខាន់ៗនៃរឿងក្ដី

| | សំណុំរឿង ០០១ | សំណុំរឿង ០០២ | |
|---|---|---|---|
| ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ | D3 | | |
| ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម | - | D3/V, D83, D98/I, D146/3, D146/4, D196 | |
| សេចក្ដីជូនដំណឹងតាមវិធាន ៦៦ | D89 | D317 | |
| ដីកាដំណោះស្រាយ | D99 | D427 | |
| សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ | D99/3/42 | • អៀង ធីរិទ្ធ និង នួន ជា៖ D427/2/12, D427/3/12, D427/2/15, D427/3/15<br>• អៀង សារី៖ D427/1/30, D427/1/26<br>• ខៀវ សំផន៖ D427/4/14, D427/4/15 | |
| | | សំណុំរឿង ០០២/០១ | សំណុំរឿង ០០២/០២ |
| សវនាការបឋម | E1/3.1, E1/4.1 | E1/4.1 រហូតដល់ E1/7.1 | E1/240.1 |
| សវនាការលើអង្គសេចក្ដី | E1/5.1 រហូតដល់ E1/77.1 | E1/13.1 រហូតដល់ E1/227.1 | E1/247.1 រហូតដល់ E1/519.1 |
| សេចក្ដីថ្លែងបិទ | E1/78.1 រហូតដល់ E1/82.1 | E1/228.1 រហូតដល់ E1/237.1 | E1/520.1 រហូតដល់ E1/528.1 |
| សាលក្រម | E188 | E313 | E465 |
| សវនាការលើបណ្ដឹងសាទុក្ខ | F1/2.1, F1/3.1, F1/4.1 | F1/5.1, F1/6.1, F1/7.1 | F1/9.1, F1/10.1, F1/11.1, F1/12.1 |
| សាលដីកា | F28 | F36 | F76 |

| | សំណុំរឿង ០០៣ | សំណុំរឿង ០០៤ | សំណុំរឿង ០០៤/០១ | សំណុំរឿង ០០៤/០២ |
|---|---|---|---|---|
| ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ | D1 | D1 | | |
| ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម | D120 | D27, D65, D191, D237/1, D254/1, D272/1 | | |
| សេចក្ដីជូនដំណឹងតាមវិធាន ៦៦ | D13, D225 | D358, D368 | D285 | D334, D334/2 |
| ដីកាដំណោះស្រាយ | D266, D267 | D381, D382 | D308, D308/3 | D359, D360 |
| ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី | D268, D269 | D383, D384 | - | D361, D362 |

| | | | | |
|---|---|---|---|---|
| សវនាការលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ | D266/16.1 & D267/21.1<br>D266/17.1 & D267/22.1<br>D266/18.1 & D267/23.1 [1552] | - [1553] | D308/3/1/19/1.1<br>D308/3/1/19/2.1 | D359/8.1 & D360/17.1<br>D359/9.1 & D360/18.1<br>D359/10.1 & D360/19.1 |
| របាយការណ៍នៃសំណុំរឿងនិងបណ្ដឹងឧទ្ធរណ៍ | D266/15 & D267/20 | - | - | D359/7 & D360/16 |
| សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ | D266/27 & D267/35 | D381/45 & D382/43 | D308/3/1/20 | D359/24 & D360/33 |
| សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាននៃដើមបណ្ដឹងរដ្ឋប្បវេណី | D269/4 | D384/7 | - | D362/6 |
| សេចក្ដីសម្រេចបញ្ចប់របស់ អ.ជ.ត.ក. | 3/1/1/1 | 2/1/1/1 | - | E004/2/1/1/2 |
| ដីកាបង្គាប់ឲ្យបញ្ជូលសំណុំរឿងទៅក្នុងបណ្ណសារដ្ឋាន | D275 | D388 | - | D363/3 |

[1552] ប្រតិចារឹកកោសល្យុបសាធារណៈ បានដាក់ជាឯកសារ D266/18.2 & D267/23.2។
[1553] អង្គបុរេជំនុំជម្រះបានសម្រេចកំណត់លើបណ្ដឹងឧទ្ធរណ៍ ដោយពុំមានសវនាការផ្ទាល់មាត់។ សូមមើលឯកសារ D381/41 & D382/40។

## ៨.៥. ឧបសម្ព័ន្ធ ៥៖ សេចក្តីសម្រេចរៀបចំតាមមូលបទ

### ក. សេចក្តីសម្រេចលើបណ្តឹងជំទាស់

**អង្គបុរេជំនុំជម្រះ**

- សេចក្តីសម្រេចជាសាធារណៈស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ផុល ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសារ C11/29
- សាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះសហចៅក្រមស៊ើបអង្កេត Marcel Lemonde ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ Doc. 7
- សាលដីកាលើបណ្តឹងរបស់ នួន ជា សុំប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ឯកសារ Doc. 4
- សាលដីកាលើពាក្យសុំតាមវិធានផ្ទៃក្នុង ៣៥ របស់លោក អៀង សារី សម្រាប់ការប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ ឯកសារ Doc. 5
- សាលដីកាលើពាក្យបណ្តឹងតាមវិធានផ្ទៃក្នុង ៣៤ របស់លោក អៀង សារី និង លោកស្រី អៀង ធីរិទ្ធ ប្តឹងជំទាស់ចៅក្រម Marcel Lemonde ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ ឯកសារ Doc. 8
- សាលដីកាលើបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ Doc. 8

**អង្គជំនុំជម្រះសាលាដំបូង**

- សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី ដែលប្តឹងជំទាស់ចំពោះលោកចៅក្រម និល ណុន ចៅក្រម Silvia CARTWRIGHT ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម ធូ មណី ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១១ ឯកសារ E55/4
- សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង ធីរិទ្ធ និង អៀង សារី ប្តឹងជំទាស់ចៅក្រម យូរ ឧត្តរា ចេញពីអង្គចៅក្រមពិសេស និងសំណើសុំឱ្យមានសវនាការជាសាធារណៈ ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ឯកសារ E63/5
- សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម Silvia Cartwright ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១១ ឯកសារ E137/5
- សេចក្តីសម្រេចលើបណ្តឹងជំទាស់ចំពោះចៅក្រម Silvia Cartwright ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១២ ឯកសារ E171/2
- សេចក្តីសម្រេចលើបណ្តឹងរបស់ អៀង សារី សុំប្តឹងជំទាស់លោកស្រីចៅក្រម Cartwright ចុះថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១២ ឯកសារ E191/2
- សេចក្តីសម្រេចលើសំណើបន្ទាន់បង្ខំពាក់ព័ន្ធនឹងបណ្តឹងជំទាស់ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E314/11
- សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ E314/12
- សំអាងហេតុចំពោះសេចក្តីសម្រេចលើបណ្តឹងជំទាស់ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ ឯកសារ E314/12/1

**អង្គជំនុំជម្រះតុលាការកំពូល**

- សេចក្តីសម្រេចលើសំណើរបស់ អៀង ធីរិទ្ធ សុំផិតចិត្តចៅក្រម សោម សិរិវឌ្ឍ ដោយសារកង្វះឯករាជភាព ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១១ ឯកសារ Doc. 1/4
- សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបណ្តឹងផិតចិត្ត លោកស្រីចៅក្រម Silvia Cartwright ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ឯកសារ E137/5/1/3
- សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន ប្តឹងផិតចិត្តចៅក្រមប្រាំមួយរូបនៃអង្គជំនុំជម្រះតុលាការកំពូលដែលបានសម្រេចសេចក្តីនៅក្នុងសំណុំរឿង ០០២/១ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ ឯកសារ Doc. 11

## ខ. សេចក្តីសម្រេចលើធនធាន

- ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្តីផ្តល់ធនធានបន្ថែម ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ឯកសារ D304/1
- ដីកាសម្រេចថែមទៀតលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការការពារក្តីផ្តល់ធនធានបន្ថែម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ឯកសារ D304/4
- ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបង្គាប់ឲ្យអង្គភាពគាំពារការពារក្តីផ្តល់ធនធានបន្ថែម ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៦ D304/7
- ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ ពាក់ព័ន្ធនឹងធនធានរបស់មេធាវីការពារក្តី ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D312/1
- ដីកាសម្រេចទី២ លើសំណើបន្ទាន់របស់ យឹម ទិត្យ ទាក់ទងនឹងធនធានបន្ថែមរបស់មេធាវីការពារក្តី ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ឯកសារ D312/4
- ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំបន្តផ្តល់ធនធានចាំបាច់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ ឯកសារ D304/11
- ដីកាសម្រេចបន្ទាន់របស់ ស.ច.ស.អ. លើសំណើបំពេញការងារពីចម្ងាយ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ D321/1
- ដីកាសម្រេចរបស់ ស.ច.ស.អ. លើសំណើបន្ទាន់សុំធ្វើការពីចម្ងាយ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ឯកសារ D321/4
- ដីកាសម្រេចរបស់ ស.ច.ស.អ. លើសំណើរួមរបស់មេធាវីការពារក្តីសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញចំពោះសេចក្តីសម្រេច និងឯកសារពាក់ព័ន្ធនឹងសំណើសុំធនធាន ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ឯកសារ D304/12
- ដីកាសម្រេចរួមរបស់ ក.ស.ច.ស. លើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D349/6
- ចម្លើយតបរបស់ អ.ជ.ត.ក. ទៅនឹងសំណើសុំឱ្យតែងតាំងក្រុមមេធាវីការពារក្តី នួន ជា ឡើងវិញ ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ F46/5
- សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំការបន្តថវិការបស់ក្រុមមេធាវីការពារក្តីលោក អោ អាន ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D360/26

- សេចក្តីសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យបដិសេធសេចក្តីសម្រេចលើផែនការសកម្មភាពរបស់អង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១ ឯកសារ D381/42 & D382/41
- សេចក្តីសម្រេចលើសំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំចេញដីកាបង្គាប់ដើម្បីការពារសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងដោយប្រសិទ្ធភាព និងការជំនុំជម្រះត្រឹមត្រូវយុត្តិធម៌ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២១ ឯកសារ F70/1/1

## ៨.៦. ឧបសម្ព័ន្ធ ៦៖ ព័ត៌មានហិរញ្ញវត្ថុ

### ក. វិភាគទានហិរញ្ញវត្ថុឆ្នាំ២០០៦-២០២២

| ម្ចាស់ជំនួយ | ផ្នែកភាគីជាតិ | % | ផ្នែកភាគីអន្តរជាតិ | % | សរុប | % |
|---|---|---|---|---|---|---|
| ជប៉ុន | ១៦.០៨៦.០២៥ | ១៦% | ៧២.១៨១.៧២១ | ៣១% | **៨៨.២៦៧.៧៤៦** | ២៧% |
| កម្ពុជា 1/ | ៤៥.៥០៦.៣៥៧ | ៤៦% | - | 0% | **៤៥.៥១៦.០៦៨** | ១៤% |
| អូស្ត្រាលី 2/ | ៣.៧៣៣.១៧២ | ៤% | ៣១.៨០១.៩២១ | ១៤% | **៣៥.៥៣៥.០៩៣** | ១១% |
| ស.រ.អ. 3/ | - | 0% | ៣២.២២០.៧៩៣ | ១៤% | **៣២.២២០.៧៩៣** | ១០% |
| សហភាពអឺរ៉ុប | ១៥.៦៣៥.០៤៥ | ១៦% | ១៧.២០៧.៣០៧ | ៧% | **៣២.៨៤២.៣៥២** | ១០% |
| អាល្លឺម៉ង់ 4/ | ៣.៩៨២.៣៣៧ | ៤% | ១៤.២៧១.៦៤១ | ៦% | **១៨.២៥៣.៩៧៨** | ៥% |
| ស៊ុយអែដ | - | 0% | ១៤.៩៩០.៧៩៧ | ៦% | **១៤.៩៩០.៧៩៧** | ៥% |
| ចក្រភពអង់គ្លេស | ១.៥៤៧.៩៨២ | ២% | ១១.៩៨២.៣៧៧ | ៥% | **១៣.៥៣០.៣៥៩** | ៤% |
| បារាំង | ២៣៣.២៨១ | 0% | ១០.៣៣៦.៣៤៣ | ៤% | **១០.៥៦៩.៦២៤** | ៣% |
| ន័រវែស | ១.០០៦.៨៨០ | ១% | ៩.២៤៤.៣២៥ | ៤% | **១០.២៥១.២០៥** | ៣% |
| សាធារណរដ្ឋកូរ៉េ | - | 0% | ៦.៥២៩.០០០ | ៣% | **៦.៥២៩.០០០** | ២% |
| មូលនិធិ អ.ស.ប. (៣០ ប្រទេស) | ៥.៣៧១.៤១៧ | ៥% | - | 0% | **៥.៣៧១.៤១៧** | ២% |
| ហ្វាំងឡង់ | ៦.៨០០ | 0% | ៣.៥៨៣.២៥៣ | ២% | **៣.៥៩០.០៥៣** | ១% |
| កាណាដា 5/ | - | 0% | ២.៤៨៧.៥៣៨ | ១% | **២.៤៨៧.៥៣៨** | ១% |
| ដាណឺម៉ាក | - | 0% | ២.០៤៨.៩៩១ | ១% | **២.០៤៨.៩៩១** | ១% |
| ហូឡង់ | ៩.៣៨៨ | 0% | ១.៨០០.៩០៩ | ១% | **១.៨១០.២៩៧** | ១% |
| ឥណ្ឌា | ១.១០០.០០០ | ១% | - | 0% | **១.១០០.០០០** | 0% |
| អេស្ប៉ាញ | - | 0% | ១.០៧៨.៧២៩ | 0% | **១.០៧៨.៧២៩** | 0% |
| នូវែលសេឡង់ | ១៦០.២៦០ | 0% | ៨៦៧.៨១៤ | 0% | **១.០២៨.០៧៤** | 0% |
| អូទ្រីស | - | 0% | ៦៨២.៩៣៩ | 0% | **៦៨២.៩៣៩** | 0% |
| អៀរឡង់ | ៤.១០០ | 0% | ៣១៩.១៦១ | 0% | **៣២៣.២៦១** | 0% |
| បែលហ្ស៊ិក | - | 0% | ១៨៩.៨០៤ | 0% | **១៨៩.៨០៤** | 0% |
| លុចសំបួ | ២០.០០០ | 0% | ១៣៩.០១០ | 0% | **១៥៩.០១០** | 0% |
| Microsoft | - | 0% | ១០០.០០០ | 0% | **១០០.០០០** | 0% |
| Open Society Institute | - | 0% | ៦១.១៧៤ | 0% | **៦១.១៧៤** | 0% |
| ម៉ាឡេស៊ី | ៥០.០០០ | 0% | - | 0% | **៥០.០០០** | 0% |
| កាតា | ២០.០០០ | 0% | ២០.០០០ | 0% | **៤០.០០០** | 0% |
| សាធារណរដ្ឋឆែក | - | 0% | ៤៨.៧២៦ | 0% | **៤៨.៧២៦** | 0% |
| លិចតិនស្តាញ | - | 0% | ៣៣.១០៨ | 0% | **៣៣.១០៨** | 0% |
| ស្វីស | ៥១.៧២៥ | 0% | ៧.៣៦៤ | 0% | **៥៩.០៨៩** | 0% |
| ថៃ | ២៤.៣៣១ | 0% | - | 0% | **២៤.៣៣១** | 0% |
| ស៊ីលី | ១៥.០០០ | 0% | ៥.០០០ | 0% | **២០.០០០** | 0% |
| អ៊ីរ៉ាក់ | - | 0% | ២.០០០ | 0% | **២.០០០** | 0% |
| អាមេនី | - | 0% | ១.០០០ | 0% | **១.០០០** | 0% |
| ណាមីប៊ី | - | 0% | ៥០០ | 0% | **៥០០** | 0% |
| Information Today Inc | - | 0% | ៥០០ | 0% | **៥០០** | 0% |
| ហិរញ្ញប្បទាន អ.ស.ប. ដល់ អ.វ.ត.ក. 6/ | ៣.២៥៥.០០០ | ៣% | - | 0% | **៣.២៥៥.០០០** | ១% |
| កម្ចី អ.ស.ប. ផ្តល់ជូន អ.វ.ត.ក. 6/ | ៧៨០.០០០ | ១% | - | 0% | **៧៨០.០០០** | 0% |
| បុគ្គល | ១.១០០ | 0% | ២.០០០ | 0% | **៣.១០០** | 0% |
| ការសម្រួល7/ | - | - | (១៩.៣៨៩) | - | **(១៩.៣៨៩)** | - |
| ការប្រាក់ទទួលបាន | - | - | ៥.៤៥៦.៥៦២ | - | **៥.៤៥៦.៥៦២** | - |
| **សរុប8/** | **៩៨.៦០០.២០០** | **១០០%** | **២៣៩.៦៨២.៩១៦** | **១០០%** | **៣៣៨.២៩២.៨២៧** | **១០០%** |

1/ វិភាគទានជាប្រភេទសេវាកម្មឬជាទំនិញរបស់រាជរដ្ឋាភិបាលកម្ពុជាគិតជាប្រាក់មានចំនួន ២១,៥ លានដុល្លារ។

2/ រួមបញ្ចូលថវិកាចំនួន ៨៤.៩៥៣ ដុល្លារ បានទទួលក្នុងឆ្នាំ២០០៣ និង ២០០៤ ចំពោះគម្រោង CMB03X01 - ជំនួយប្រតិបត្តិការសម្រាប់ការជំនុំជម្រះក្តីខ្មែរក្រហម

3/ មិនរាប់បញ្ចូលថវិកាចំនួន ១.១៦៤.៦២០ ដុល្លារ ដែលបានទទួល ប៉ុន្តែបានផ្ទេរទៅមូលនិធិ OLA Trust Fund

4/ វិភាគទានអាល្លឺម៉ង់ក្នុងចំនួន ៤៧៦.៥០២ ដុល្លារ ត្រូវបានទុកដោយឡែកសម្រាប់ការចំណាយផ្នែកគាំពារជនរងគ្រោះ ហើយមិនត្រូវបានបង្ហាញនៅក្នុងតារាងនេះទេ។

5/ រដ្ឋាភិបាលកាណាដាបានផ្តល់វិភាគទានជាប្រភេទសេវាកម្មឬជាទំនិញចំនួន ១.៣៧២.២០០ ដុល្លារ តាមមធ្យោបាយបញ្ជូនអ្នកស៊ើបអង្កេតបីរូបទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងរយៈពេលពីឆ្នាំ២០១៥-២០១៧។

6/ ការផ្តល់ហិរញ្ញប្បទាន និងកម្ចីដល់ភាគីជាតិ ក៏ត្រូវបានរួមបញ្ចូលផងដែរ នៅក្នុងវិភាគទានសរុបនៃផ្នែកភាគីអន្តរជាតិ ដូចដែលពួកវាត្រូវបានបម្រុងទុកដំបូង សម្រាប់ផ្នែកភាគីអន្តរជាតិ។ ស្របជាមួយនឹងម្ចាស់ជំនួយនីមួយៗ ថវិកាចំនួន ៤,១ លានដុល្លារ ត្រូវបានផ្ទេរទៅភាគីជាតិ ក្នុងអំឡុងឆ្នាំ២០១៣ និង ២០១៤ (ហិរញ្ញប្បទានចំនួន ៣,៣ លានដុល្លារ ក្នុងឆ្នាំ២០១៣ និង កម្ចីចំនួន ០,៨ លានដុល្លារ ក្នុងឆ្នាំ២០១៤) ហើយដូច្នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងវិភាគទានសរុបនៃផ្នែកភាគីជាតិផងដែរ។ ជាលទ្ធផល នៅក្នុងការបង្ហាញនេះ ហិរញ្ញប្បទានសរុប រួមបញ្ចូលថវិកាចំនួន ៤,១ លានដុល្លារពីរដង

7/ ចំណេញ/ខាត លើការប្តូររូបិយប័ណ្ណបរទេស

8/ តារាងនេះមិនឆ្លុះបញ្ចាំងពីថវិកាឧបត្ថម្ភធនជាទៀតទាត់ ដែលទទួលបានដោយផ្នែកភាគីអន្តរជាតិទេ។ ធនធានឧបត្ថម្ភធន ត្រូវបានប្រើប្រាស់ដើម្បីសម្រួលដល់ការចំណាយខ្ពស់ជាងវិភាគទានស្ម័គ្រចិត្ត ចាប់តាំងពីឆ្នាំ២០១៥

## ខ. ការចំណាយ




## គ. សេចក្ដីសម្រេចចិត្តរបស់មហាសន្និបាត អ.ស.ប. លើសំណើសុំប្រាក់ឧបត្ថម្ភធន

- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៤ ឯកសារ A/RES/68/247B
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ ឯកសារ A/RES/69/274
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ឯកសារ A/RES/70/248
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៦ ឯកសារ A/RES/71/272
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧ ឯកសារ A/RES/72/262
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨ ឯកសារ A/RES/73/279
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ A/RES/74/263
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ឯកសារ A/RES/75/253
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ឯកសារ A/RES/76/246
- សេចក្ដីសម្រេចចិត្តអនុម័តដោយមហាសន្និបាត នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ ឯកសារ A/RES/77/263

## ៨.៧. ឧបសម្ព័ន្ធ ៧៖ ស្ថិតិផ្សព្វផ្សាយ

| | **សវនាការសាធារណៈ**<br>ប្រជាជន (ថ្ងៃ) | **ទស្សនកិច្ចសិក្សា**<br>ប្រជាជន<br>(ទស្សនកិច្ច) | **ទស្សនកិច្ច**<br>ប្រជាជន (ក្រុម) | **ទស្សនកិច្ច VIP**<br>ប្រជាជន (គណៈប្រតិភូ) | **ការបញ្ចាំង**<br>ប្រជាជន (ការបញ្ចាំង) | **សុន្ទរកថា**<br>ប្រជាជន<br>(ឱកាស) | **សរុប**<br>ប្រជាជន |
|---|---|---|---|---|---|---|---|
| ២០០៩ | ៣៣.០១០<br>(៨៧) | ៣.០១៨<br>(១០) | - | - | - | ៤.០០០<br>(១) | **៤០.០២៨** |
| ២០១០ | ៣.៣២៦<br>(៥) | ២៩.២៩១<br>(៨០) | ១.៧៨០<br>(៦៩) | ១៥១<br>(២៣) | ៣១.១១៨<br>(៧១) | ១៦.១០០<br>(៥) | **៨១.៧៦៦** |
| ២០១១ | ១៩.២០៧<br>(២៥) | ២៥.៤០០<br>(៧៤) | ៤៤៧<br>(៣៨) | ១១៩<br>(៣២) | ២៣.៩៩១<br>(៥៦) | ៣១.៦២០<br>(១៣) | **១០០.៧៨៤** |
| ២០១២ | ៦០.៤៩២<br>(១៣៣) | ១០.១៤៧<br>(៣១) | ៩៤៩<br>(៤៦) | ៩០<br>(១៨) | ១០.៦៩៦<br>(២៣) | ១៤.១០០<br>(២០) | **៩៦.៤៧៤** |
| ២០១៣ | ៣៦.៨៧១<br>(៨៤) | ១១.០៤០<br>(៣៩) | ៥៩៤<br>(៥២) | ៩៥<br>(២៤) | ២.៥៨៣<br>(៩) | ៨.០០០<br>(៧) | **៥៩.១៨៣** |
| ២០១៤ | ៣.៤០៧<br>(៦) | ២៨.១៤១<br>(៩២) | ៧៩២<br>(៥៤) | ២០<br>(១០) | - | ១៥.៩១០<br>(១៥) | **៤៨.២៧០** |
| ២០១៥ | ៣៨.៩២៤<br>(១២៥) | ៨.៣៧៥<br>(៣៣) | ៣៣០<br>(២២) | ៣៦<br>(៨) | - | ១.៦០០<br>(៣) | **៤៩.២៦៥** |
| ២០១៦ | ៤០.៥៥៦<br>(១៤៩) | ៥.០៧០<br>(២០) | ៧៦២<br>(២៤) | ៧៤<br>(២៥) | - | ៤.៩០០<br>(៧) | **៥១.៣៦២** |
| ២០១៧ | ៦.១៤៨<br>(១៦) | ២៥.៨៣៦<br>(៩៦) | ៤១៩<br>(៤៤) | ៣៩<br>(១២) | ២.៦០០<br>(៦) | ២.០០០<br>(១) | **៣៧.០៤២** |
| ២០១៨ | ៨០២<br>(១) | ២៨.៩៣៨<br>(១០០) | ៧៥៦<br>(៤២) | ៣៣<br>(៨) | ៥០០<br>(២) | ៣.០៨៩<br>(៤) | **៣៤.១១៨** |
| ២០១៩ | ១.២២៨<br>(៣) | ២៦.៦៦៣<br>(៨៩) | ៣៨៩<br>(២៤) | ២៧<br>(៨) | - | - | **២៨.៣០៧** |
| ២០២០ | - | ៧.៤៤៧<br>(៣៨) | ១៨៥<br>(១៤) | ១៥<br>(៧) | - | - | **៧.៦៤៧** |
| ២០២១ | ១២៣<br>(៤) | - | ៦១<br>(២) | ៧<br>(៣) | - | - | **១៩១** |
| ២០២២ | ៥៧៤<br>(១) | ៤.៨០២<br>(២២) | ៣៩១<br>(១០) | ៧២<br>(៤) | - | - | **៥.៨៣៩** |
| **សរុប** | **២៤៤.៦៦៨**<br>(៦៣៩) | **២១៤.១៦៨**<br>(៧២២) | **៧.៨៥៥**<br>(៤៤៦) | **៧៧៨**<br>(១៨២) | **៧១.៤៨៨**<br>(១៦៧) | **១០១.៣១៩**<br>(៧៦) | **៦៤០.២៧៦** |